# អារម្ភកថា

សៀវភៅពុទ្ធកិច្ច ៤៥ ព្រះវស្សានេះ មានខ្លឹមសារជាផែនទី និងជាប្លង់សម្រាប់អ្នកត្រូវការសិក្សា ងាយស្រួលក្នុងការស្វែងរកចំណុចដែលខ្លួនត្រូវការ ទៅតាមដំណើរយាងប្រោសសត្វ ដោយធម្មទេសនារបស់ព្រះសម្ពុទ្ធបរមគ្រូ ក្នុងរយៈពេល ៤៥ ព្រះវស្សា ។

ក្នុងសៀវភៅនេះ មានខ្លឹមសារធម៌សង្ខេបៗ ដោយលើកមកគ្រាន់តែដើម្បីបញ្ជាក់ថា តើធម៌នេះ វិន័យនេះ ព្រះអង្គសម្តែងក្នុងទីណា សម្តែងប្រោសអ្នកណា សម្តែងក្នុងវស្សាទីប៉ុន្មាន និងមានប្រវត្តិរឿងរ៉ាវកើតឡើងយ៉ាងណា ទើបព្រះអង្គសម្តែងព្រះធម្មទេសនា ឯសេចក្តីពិស្តារ គប្បីស្វែងរកតាមការចង្អុលប្រាប់គម្ពីរ ដែលលើកមកជាភស្តុតាង ។

ដោយសៀវភៅនេះក្រាស់ពេក ខ្ញុំមិនអាចដាក់ភាសាបាលីផងបានទេ សៀវភៅនេះដកស្រង់ពីព្រះត្រៃបិដក អដ្ឋកថា យកមកជាគោលអាង ដោយមិនបាននិពន្ធជារបៀបថ្មីអ្វីទេ គ្រាន់តែប្រមូលមកពីទីផ្សេងៗ ដាក់ជាប្រវត្តិតាមដំណើររឿង ។

ខ្ញុំព្រះករុណាសង្ឃឹមថា សៀវភៅនេះនឹងបានជាជំនួយការដ៏សំខាន់ដល់ពុទ្ធបរិស័ទគ្រប់វ័យ ទាំងគ្រហស្ថ បព្វជិត បណ្ឌិត និងអ្នកសិក្សាថ្មី ដើម្បីស្រាវជ្រាវរាវរកប្រវត្តិរឿងរ៉ាវក្នុងរយៈពេល ៤៥ ព្រះវស្សា ដែលជាដំណើរយាងសម្តែងធម៌ របស់ព្រះសម្ពុទ្ធជាម្ចាស់ ។

ការងារនេះ ខ្ញុំព្រះករុណា និងសព្រហ្មចារីប្រឹងប្រែងផ្ទៀងផ្ទាត់យ៉ាងផ្ចិតផ្ចង់ តែទុកជាដូចម្តេចក្តី រាល់ការងារតែងតែមានខ្វះចន្លោះជាពុំខាន ជួនដោយអចេតនា ជួនដោយការចេះមិនដល់ យល់មិនជ្រៅ ដូច្នេះគ្រប់កំហុសឆ្គងដែលអាចមានដោយប្រការណាក្តី ខ្ញុំព្រះករុណា និងសព្រហ្មចារីសូមផ្ញើទុកលើបណ្ឌិត សប្បុរសទាំងអស់ដែលបានអាន ជួយកែតម្រូវដោយសុទ្ធចិត្តផង យើងខ្ញុំរង់ចាំទទួលនូវការកែតម្រូវគ្រប់យ៉ាង ។

សូមមិត្តអ្នកអាន បានទទួលនូវចំណេះដឹងដើម្បីជាប្រយោជន៍ផ្ទាល់ ប្រយោជន៍ជាតិ សាសនា និងទទួលបាននូវសេចក្តីសុខគ្រប់ពេលវេលាកុំបីអាក់ខានឡើយ ។

## ឧទ្ទិសកថា

បុណ្យធម្មទាននេះ ខ្ញុំព្រះករុណាសូមឧទ្ទិសចំពោះបុព្វការីជនទាំងឡាយ មានមាតាបិតា ជីដូន ជីតា និងគ្រូឧបជ្ឈាយាចារ្យ និងសូមជូនពុទ្ធបរិស័ទទាំងអស់ ទាំងក្នុងប្រទេស មានលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស ជាគ្រូរបស់ខ្ញុំព្រះករុណាជាដើមផង ទាំងក្រៅប្រទេស មានញោមឡោ ស៊ីរុន ជាដើម និងសូមឧទ្ទិសដល់ពពួកសត្វទាំងអស់ ដែលមានចិត្តអាចអនុមោទនាបាន ព្រមទាំងអ្នកដែលកំពុងតែអានសៀវភៅនេះទាំងអស់ផងដែរ សូមបុព្វការីជនដែលបានរៀបរាប់មកនេះ អនុមោទនានូវបុណ្យកុសលក្នុងការងារនេះ ដែលកើតឡើងដោយសេចក្ដីព្យាយាម របស់ខ្ញុំព្រះករុណា និងសព្រហ្មចារីដែលរួមជួយក្នុងការងារនេះទាំងអស់ សូមអនុមោទនាបុណ្យធម្មទាន ! សូមអនុមោទនា ! កាលបើបានអនុមោទនាហើយ សូមឱ្យបានសម្រេចនូវអាយុសម្បត្តិ វណ្ណសម្បត្តិ ពលសម្បត្តិ សុខសម្បត្តិ ជាពិសេសសូមឱ្យបានបញ្ញាសម្បត្តិគ្រប់ៗ គ្នា ។

# មាតិការឿង

មាតិការឿង............................................................លេខទំព័រ
ព្រះវស្សាទី ១ ............................................................ ៤
ព្រះវស្សាទី ២ គង់នៅវត្តវេឡុវ័ន ......................................... ៤២
ព្រះវស្សាទី ៣ គង់នៅវត្តវេឡុវ័នទៀត .................................... ៥២
ព្រះវស្សាទី ៤ គង់នៅវត្តវេឡុវ័ន ......................................... ៧២
ក្រោយចេញព្រះវស្សាទី ៤ យាងទៅនគរកបិលពស្តុ ...................... ៧៨
ព្រះវស្សាទី ៥ គង់នៅគោដាគារសាលា ក្រុងវេសាលី ..................... ៨៤
ទ្រង់សម្ដែងវត្តបទ ៧ ដល់មហាលិ ស្ដេចលិច្ឆវី ............................ ៩៣
ក្រោយពីចេញព្រះវស្សាទី ៥ ហើយ ...................................... ១០០
ព្រះវស្សាទី ៦ គង់នៅមកុលបពិត ដែនមគធ .............................. ១១៥
ក្រោយពីចេញព្រះវស្សាទី ៦ ហើយ ...................................... ១១៩
ព្រះវស្សាទី ៧ គង់ចាំវស្សានៅស្ថានតាវត្តិង្ស .............................. ១២៦
ក្រោយចេញវស្សាទី ៧ យាងទៅនគរសាវត្ថី ............................... ១៣០
ព្រះវស្សាទី ៨ គង់នៅភេសកឡាវ័ន ភគ្គជនបទ ........................... ១៣៧
ក្រោយចេញវស្សាទី ៨ គង់នៅភេសកឡាវ័ន .............................. ១៤២
ព្រះវស្សាទី ៩ គង់នៅឃោសិតារាម ក្រុងកោសម្ពី ....................... ១៤៩
ក្រោយចេញវស្សាទី ៩ ................................................... ១៥៩
ព្រះវស្សាទី ១០ គង់នៅព្រៃបាលិលេយ្យក ................................ ១៦៦
ក្រោយចេញវស្សាទី ១០ ................................................. ១៦៧
ព្រះវស្សាទី ១១ គង់នៅស្រុកព្រាហ្មណ ឯកនាលា ....................... ១៨១
ព្រះវស្សាទី ១២ គង់នៅទៀបគល់ស្ដៅ ស្រុកវេរញ្ជា ...................... ១៨៨

ក្រោយចេញវស្សាទី ១២ .................................................. ១៩៦
ព្រះវស្សាទី ១៣ គង់នៅចាលិកបព៌ត ក្រុងចាលិកា ......................... ២១២
ក្រោយចេញវស្សាទី ១៣ ហើយ .......................................... ២១៤
ព្រះវស្សាទី ១៤ គង់នៅវត្តជេតពន ក្រុងសាវត្ថី ........................... ២២៦
ក្រោយចេញវស្សាទី ១៤ .................................................. ២៣៥
ព្រះវស្សាទី ១៥ គង់នៅនិគ្រោធារាម ក្រុងកបិលពស្តុ ..................... ២៤០
ព្រះវស្សាទី ១៦ គង់នៅអាគាឡវចេតិយ៍ ដែនអាឡវី ....................... ២៥០
ព្រះវស្សាទី ១៧ គង់នៅវត្តវេឡុវ័ន ក្រុងរាជគ្រឹះ ........................... ២៦៥
ក្រោយចេញវស្សាទី ១៧ .................................................. ២៧៣
ព្រះវស្សាទី ១៨ គង់នៅចាលិកបព៌ត ក្រុងចាលិកា ......................... ២៧៨
ក្រោយចេញវស្សាទី ១៨ .................................................. ២៨៦
ព្រះវស្សាទី ១៩ គង់នៅចាលិកបព៌ត ក្រុងចាលិកា ......................... ២៩២
ព្រះវស្សាទី ២០ គង់នៅវត្តវេឡុវ័ន ក្រុងរាជគ្រឹះ .......................... ៣០៩
ព្រះវស្សាទី ២១-៤៤ គង់នៅក្រុងសាវត្ថី ជាប្រចាំ គឺ ....................... ៣១៦
ព្រះបាទបសេនទិកោសល ព្រះរាជាក្រុងសាវត្ថិ ............................ ៣១៨
អនាថបិណ្ឌិកសេដ្ឋី អ្នកកសាងវត្តជេតពន ................................. ៣២៣
មហាឧបាសិកា វិសាខា អ្នកសាងវត្តបុព្វារាម ............................. ៣៤០
ព្រះវស្សាទី ២០ .......................................................... ៣៥៧
សេចក្តីសន្និដ្ឋាន ប្រហែលក្នុងវស្សាទី ២៦ ................................ ៣៥៩
ប្រហែលក្នុងអំឡុងពេលវស្សាទី ៣៧ .................................... ៣៦០
ប្រហែលក្នុងអំឡុងពេលវស្សាទី ៣៨ .................................... ៣៦៨
ប្រហែលក្នុងអំឡុងពេលវស្សាទី ៤៣ .................................... ៣៧២

នៅក្នុងព្រះវស្សាទី ៤៤ ទ្រង់ ........................................ ៣៧៣
ក្រោយចេញវស្សាទី ៤៤ ........................................ ២៧៦
ព្រះវស្សាទី ៤៥ គង់នៅស្រុកវេឡុវគ្រាម ........................................ ៣៩១
បច្ឆិមពុទ្ធវចនៈទ្រង់បរិនិព្វានទៅនគរកុសិនារា ........................................ ៤៣១
ប្រាប់ដំណឹងបរិនិព្វាន ........................................ ៤១៦
មល្លបាមោក្ខ ៤ និងការថ្វាយភ្លើង ........................................ ៤២១
ស្ថានទីបរិនិព្វាន ........................................ ៤២២
ទោណព្រាហ្មណ៍រម្ងាប់អធិករណ៍ ........................................ ៤២៥
ការបែងចែកព្រះបរមសារីរិកធាតុ ........................................ ៤២៧
ព្រះបាទអជាតសត្រូវ និងមហាកស្សបត្ថេរ រក្សាព្រះធាតុ ........................................ ៤៣៥
រឿងព្រះមហាកស្សបត្ថេរ ........................................ ៤៣៨
រឿងព្រះអានន្ទត្ថេរ ........................................ ៤៣៩
រឿងព្រះអានន្ទនិព្វាន ........................................ ៤៤២
រឿងព្រះចុន្ទត្ថេរ ........................................ ៤៤៣

ចំណែកឈ្មោះគម្ពីរដែលដកស្រង់មក យើងខ្ញុំមិនបានដាក់ទេ ពីព្រោះឯកសារមុនបាត់អស់ មិនអាចវាយកុំព្យូទ័រទាន់ទេ ព្រោះប្រញាប់ពេក បើមិត្តអ្នកអានឆ្ងល់សូមទាក់ទងមក ទូរស័ព្ទលេខ : ០១២ ៨២៦ ៨០០

សេម រឿយ

# ព្រះវស្សាទី ១

## ទ្រង់គង់ចាំព្រះវស្សានៅ ព្រៃឥសិបតនមិគទាយវ័ន ក្រុងពារាណសី

(១) ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ កាលព្រះអង្គទ្រង់សម្ដែង **ព្រះធម្មចក្កប្បវត្តនសូត្រ** ដែលជាធម្មទេសនាដំបូងបំផុត **ឱ្យអញ្ញាកោណ្ឌញ្ញៈ** តាំងនៅក្នុងសោតាបត្តិផល ហើយបានក្រាបទូលសូមបព្វជ្ជាឧបសម្បទា ចំពោះព្រះសាស្ដា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ជាសង្ឃសាវ័កអង្គដំបូងក្នុងព្រះពុទ្ធសាសនា ហើយទ្រង់គង់ចាំព្រះវស្សាដំបូង ក្នុងព្រៃឥសិបតនមិគទាយវ័ន ។

ថ្ងៃតមក ព្រះអង្គទ្រង់ប្រទានឱវាទដល់បញ្ចវគ្គិយ៍ដ៏សេស ដោយធម្មីកថា ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិលបានកើតឡើងដល់ **ព្រះវប្បៈ** និង **ព្រះភទ្ទិយៈ** ថា **ធម្មជាតិណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតិនោះទាំងអស់ សុទ្ធតែមានការរលត់ទៅវិញជាធម្មតា** លោកទាំងពីរបានសម្រេចធម៌ហើយ បានក្រាបទូលសូមបព្វជ្ជាឧបសម្បទា ព្រះសាស្ដាទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ដល់អ្នកទាំងពីរនោះ។

(ស្រង់ចេញអំពីគម្ពីរព្រះវិន័យ មហាវគ្គ ភាគ ៦ )

ក្នុងអដ្ឋកថា អង្គុត្តរនិកាយ ឯកនិបាត ពោលថា បញ្ចវគ្គិយ៍បានសម្រេចធម៌មួយថ្ងៃមួយអង្គៗ តាមលំដាប់ គឺ :

ក្នុងថ្ងៃ ១ រោច ព្រះវប្បៈ បានសម្រេចសោតាបត្តិផល

ក្នុងថ្ងៃ ២ រោច ព្រះភទ្ទិយៈ បានសម្រេចសោតាបត្តិផល

ក្នុងថ្ងៃ ៣ រោច ព្រះមហានាម បានសម្រេចសោតាបត្តិផល

ក្នុងថ្ងៃ ៤ រោច ព្រះអស្សជិ បានសម្រេចសោតាបត្តិផល

លុះដល់ថ្ងៃ ៥ រោច ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្ដែង **អនត្ត-លក្ខណសូត្រ** ព្រះបញ្ចវគ្គីយ៍ទាំងអស់បានសម្រេចអរហត្តផល ។

**ខណៈនោះព្រះអរហន្តកើតឡើងក្នុងលោកមាន ៦ អង្គ**

(២) ក្នុងគ្រាដែលព្រះពោធិសត្វប្រសូតិ ក្រោយពី **កាឡទេវិលតាបស** ទាយថា ព្រះរាជបុត្រសិទ្ធត្ថកុមារ នឹងបានត្រាស់ជាព្រះពុទ្ធជាម្ចាស់ ដឹងថាខ្លួនឯងមានអាយុមិនទាន់ការត្រាស់ដឹង របស់ព្រះពោធិសត្វនេះ ទើបទៅកាន់ផ្ទះប្អូនស្រី ក្នុងក្រុងកបិលព័ស្ដុ ប្រាប់ឱ្យ **ក្មួយនាលកៈ** បួសក្នុងថ្ងៃនោះ ព្រោះខ្លួនឯងជ្រាបថា នាលកៈមានឧបនិស្ស័យនឹងបានសម្រេចមគ្គផល បានណែនាំឱ្យនាលកៈតាំងចិត្តអធិដ្ឋានថា នឹងបួសឧទ្ទិសចំពោះព្រះមានព្រះភាគអង្គនោះ ។

ក្រោយពីបួសហើយ **នាលកតាបស** គេចទៅបំពេញព្យាយាម នៅព្រៃហេមពាន្ត កាលព្រះពោធិសត្វត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ និងទ្រង់សម្ដែងធម្មចក្កប្បវត្តនសូត្រហើយ ៧ ថ្ងៃ ទើបនាលកតាបសចូលមកគាល់ព្រះពុទ្ធអង្គទូលសួរវត្តបដិបត្តិរបស់មុនី ។ ព្រះសាស្ដាទ្រង់ត្រាស់អំពី **មោនេយ្យបដិបត្តិ** គឺគោលបដិបត្តិរបស់មុនី ៣ ប្រការ បានដល់ **កាយមោនេយ្យ វចីមោនេយ្យ** និង **មនោមោនេយ្យ** ដើម្បីការសម្រេចផលដ៏ខ្ពង់ខ្ពស់បំផុតដល់នាលកៈ ។

នាលកតាបសស្តាប់វត្តបដិបត្តិ ដែលជាគុណធមិរបស់អ្នកប្រាជ្ញដូច្នេះហើយ កើតសេចក្តីជ្រះថ្លា ក្រាបទូលសូមបព្វជ្ជាឧបសម្បទា លុះបានឧបសម្បទាហើយ ព្រះនាលកៈ ជាអ្នកមានសេចក្តីប្រាថ្នាតិច **ក្នុងការឃើញ ១ ក្នុងការស្តាប់ ១ ក្នុងការសួរ ១** ។

ព្រះនាលកៈថ្វាយបង្គំព្រះសាស្តាក្រាបទូលលាចូលព្រៃ ដោយតាំងចិត្តថា នឹងមិនត្រឡប់មកគាល់ព្រះសាស្តា ដើម្បីស្តាប់ធមិ និងសួរមោនេយ្យបដិបទាទៀត ដោយបំណងឆ្ពោះមុខទៅបដិបត្តិតែម្យ៉ាង ចូលទៅកាន់ជើងភ្នំ ស្នាក់នៅក្នុងស្រុកមួយ លោកស្នាក់នៅមួយកន្លែងមួយថ្ងៃ អង្គុយបំពេញព្យាយាមក្បែរគល់ឈើមួយៗត្រឹមតែមួយថ្ងៃ ចូលទៅបិណ្ឌបាតក្នុងភូមិមួយៗ ម្តង មិនដដែលៗ លោកត្រាច់អំពីព្រៃមួយទៅកាន់ព្រៃមួយ អំពីដើមឈើមួយ ទៅកាន់ដើមឈើមួយ អំពីស្រុកមួយទៅកាន់ស្រុកមួយ បំពេញមោនេយ្យបដិបទា យ៉ាងឧក្រិដ្ឋ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តផល ។

វេលាតមក ព្រះនាលកៈដឹងថានឹងមានជីវិតតទៅទៀតត្រឹម ៧ ខែ មុននឹងបរិនិព្វាន លោកជម្រះកាយដណ្តប់សង្ឃាដិពីរជាន់បែរមុខទៅរកទិស ដែលព្រះមានព្រះភាគគង់នៅ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ថាន ផ្គងអញ្ជលីឈរផ្អែកនឹងថ្មភ្នំ **ហិង្គុលិកៈ** បរិនិព្វានក្នុងទីនោះដោយអនុបាទិសេសនិព្វាន ព្រះសាស្តាស្តេចនិមន្តយាងទៅធ្វើឈាបនកិច្ច និងឱ្យរើសអដ្ឋិធាតុតម្កល់ទុកក្នុងព្រះចេតីយ៍ក្នុងភ្នំនោះឯង ។

(៣) សម័យនោះ យសកុលបុត្រ ជាបុត្ររបស់សេដ្ឋីក្នុងក្រុងពារាណសី កើតសេចក្ដីនឿយណាយក្នុងការគ្រប់គ្រងផ្ទះ ចូលទៅគាល់ព្រះសម្ពុទ្ធត្រង់ព្រៃឥសិបតនមិគទាយវ័ន ព្រះមានព្រះភាគទ្រង់សម្ដែង **អនុបុព្វីកថា** គឺ **ទានកថា** ពោលអំពីទាន **សីលកថា** ពោលអំពីសីល **សគ្គកថា** ពោលអំពីស្ថានសួគ៌ **អាទីនវកថា** ពោលអំពីទោសរបស់កាមទាំងឡាយ **នេក្ខម្មានិសង្សកថា** ពោលអំពីអានិសង្សនៃការចេញចាកកាម ហើយទ្រង់សម្ដែង **អរិយសច្ចៈ ៤** គឺទុក្ខ ហេតុឱ្យកើតទុក្ខ សេចក្ដីរំលត់ទុក្ខ និងផ្លូវរំលត់ទុក្ខ បានដល់អរិយមគ្គមានអង្គ ៨ យសកុលបុត្របានត្រាស់ដឹងធម៌ជាសោតាបន្ន ក្នុងទីនោះឯង ។

សេដ្ឋីជាបិតា ចេញតាមរកយសកុលបុត្រ បានជួបព្រះមានព្រះភាគ ថ្វាយបង្គំហើយ ព្រះអង្គទ្រង់សម្ដែងអនុបុព្វីកថា និងសម្ដែងធម្មទេសនា គឺ អរិយសច្ចៈ ៤ សេដ្ឋីបានត្រាស់ដឹងធម៌ ទូលសូមថ្វាយខ្លួនជាឧបាសក ដល់ព្រះរតនត្រៃជាសរណៈស្មើដោយជីវិត រាប់ជាឧបាសកដែលថ្វាយខ្លួន ដល់ព្រះរតនត្រៃជាសរណៈជាមនុស្សដំបូងបង្អស់ក្នុងលោក ។

ខណៈដែលព្រះពុទ្ធអង្គទ្រង់សម្ដែងធម៌ដល់បិតា យសកុលបុត្រពិចារណាឃើញធម៌តាមដែលខ្លួនបានដឹងច្បាស់ ចិត្តក៏រួចផុតចាកអាសវៈទាំងឡាយ បានសម្រេចព្រះអរហត្តផល ។

**សម័យនោះ មានព្រះអរហន្តកើតឡើងក្នុងលោក ៧ អង្គ រួមទាំងព្រះយស**

ក្រោយអំពីយសកុលបុត្របានសម្រេចធម៌ហើយ ព្រះមានព្រះភាគបាន

ត្រាស់ជាមួយនឹងសេដ្ឋីជាបិតាថា ចិត្តរបស់យសផុតហើយចាកអាសវៈទាំងឡាយ យសកុលបុត្រមិនគួរ នឹងត្រឡប់ទៅជាគ្រហស្ថបរិភោគកាមទៀតទេ ។

សេដ្ឋីក្រាបទូលថា ជាលាភរបស់យស យសកុលបុត្របានល្អហើយ ព្រះអង្គ ! សូមព្រះមានព្រះភាគ មានយសកុលបុត្រជាបច្ឆាសមណៈ ប្រោសទ្រង់ទទួលភត្តាហាររបស់ខ្ញុំព្រះអង្គ ដើម្បីសោយក្នុងថ្ងៃស្អែកចុះព្រះអង្គ ! សេដ្ឋីជ្រាបការទទួលនិមន្តរបស់ព្រះសម្ពុទ្ធហើយ ក្រាបថ្វាយបង្គំលា ធ្វើប្រទក្សិណហើយត្រឡប់ទៅ កាលសេដ្ឋីជាបិតាត្រឡប់ទៅមិនយូរប៉ុន្មាន យសកុលបុត្របានទូលសូមបព្វជ្ជាឧបសម្បទ ព្រះអង្គទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ដល់យសកុលបុត្រ ។

លុះព្រឹកឡើង ព្រះមានព្រះភាគមានព្រះយសជាបច្ឆាសមណៈ យាងទៅកាន់និវេសន៍របស់សេដ្ឋីជាបិតា មាតា និងអតីតភរិយារបស់ព្រះយស នាំគ្នាមកគាល់ ព្រះពុទ្ធអង្គត្រាស់អនុបុព្វីកថា និងទ្រង់សម្តែងអរិយសច្ច ៤ ទាំង ២ នាក់បានត្រាស់ដឹងធម៌ បានសម្រេចហើយក្រាបទូលថា ខ្ញុំម្ចាស់ទាំងពីរនាក់សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង និងព្រះភិក្ខុសង្ឃផង ជាសរណៈស្មើដោយជីវិតសូមព្រះអង្គទ្រង់ចាំនូវខ្ញុំម្ចាស់ទាំងពីរថា ជាឧបាសិកា ចាប់ផ្តើមតាំងពីថ្ងៃនេះតទៅ ។

មាតា និងអតីតភរិយារបស់ព្រះយស បានជាឧបាសិកាអ្នកពោលដល់ព្រះរតនត្រៃ ជាគ្រាដំបូងក្នុងលោក ( **បឋមតិសរណគមនឧបាសិកា**) ។

ក្រោយអំពីនោះ ព្រះយសបាននាំសម្លាញ់ជាគ្រហស្ថចំនួន ៥៤ នាក់ ចូលគាល់ ព្រះពុទ្ធអង្គទ្រង់សម្តែងអនុបុព្វីកថា និងអរិយសច្ច ៤ ទាំងអស់គ្នាបានសម្រេចធម៌ ក្រាបទូលសូមបព្វជ្ជាឧបសម្ប័ទ ព្រះពុទ្ធអង្គទ្រង់ប្រទានឯហិភិក្ខុឧបសម្បទា ដល់សម្លាញ់ទាំងនោះ ហើយបានត្រាស់ដឹងជាព្រះអរហន្តគ្រប់ៗ អង្គ

**ក្នុងសម័យនោះ មានព្រះអរហន្តកើតឡើងក្នុងលោក ៦១ អង្គ**

**ក្រោយអំពីចេញព្រះវស្សាទី ១ ហើយ**

(៤) ទ្រង់បញ្ជូនសាវ័ក ៦០ អង្គ ទៅប្រកាសព្រះសាសនា ទ្រង់ត្រាស់ថា អ្នកទាំងឡាយ ចូរត្រាច់ចារិកទៅ ដើម្បីប្រយោជន៍អនុគ្រោះដល់ពួកជនច្រើន ដើម្បីអនុគ្រោះសត្វលោក ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ អ្នកទាំងឡាយចូរកុំទៅផ្លូវមួយ ២ រូប ពួកអ្នកចូរសម្តែងធម៌ លម្អបទដើម លម្អបទកណ្តាល លម្អបទចុង ចូរប្រកាសព្រហ្មចរិយធម៌ ដោយអត្ថព្រមទាំងព្យញ្ជនៈ ដ៏បរិសុទ្ធិបរិបូរណ៌ សូម្បីតថាគតក៏នឹងទៅកាន់ ឧរុវេលសេនានិគម ដើម្បីសម្តែងធម៌ដែរ ។

(៥) ទ្រង់អនុញ្ញាតឱ្យសាវ័កទាំង ៦០ រូប មានសិទ្ធិបំបួសកុលបុត្របាន ក្រោយអំពីព្រះអង្គទ្រង់ឃើញសេចក្តីលំបាករបស់ភិក្ខុ និងកុលបុត្រអ្នកប្រាថ្នានឹងបួស ដែលមកអំពីជនបទ និងទិសផ្សេងៗ ដោយតាំងចិត្តដែលនឹងឱ្យព្រះពុទ្ធអង្គបំបួស ទើបទ្រង់អនុញ្ញាតឱ្យភិក្ខុ បព្វជ្ជានិងឧបសម្ប័ទកុលបុត្រ ក្នុងជនបទនោះៗ ដោយវិធីឱ្យទទួលត្រៃសរណគមន៍ គឺមានព្រះរតនត្រៃជាសរណៈ

( **តិសរណគមនូបសម្បទា** ) ។ ក្រោយមកទ្រង់អនុញ្ញាតដល់ ការបព្វជ្ជាជាសាមណេរ ហើយបើសាមណេរនោះជាអ្នកមានបញ្ញា គប្បីសម្តែងសិក្ខាបទ ១០ ដល់សាមណេរទាំងឡាយ ពិតណាស់ **បព្វជ្ជា** គឺការបួសជាសាមណេរ សម្រេចដោយសរណគមន៍ប៉ុណ្ណោះ ចំណែកសិក្ខាបទ ១០ សាមណេរគួរសិក្សាដើម្បីធ្វើសិក្ខាឱ្យបរិបូរណ៍ ។

កាលបើសាមណេរមិនទាន់អាចនឹងរៀនសិក្ខាបទទាំងនោះបាន នឹងប្រាប់តែត្រឹមខ្លឹមសារដើម្បីឱ្យសាមណេរយល់ក្នុងការគ្រងចីវរ សង្ឃាដិ កាន់បាត្រ ការឈរ អង្គុយជាដើម គួរបម្រុងមើលថែឱ្យដូចក្មេងតូច គួរណែនាំលោកឱ្យស្គាល់ធម្មទំនៀមរបស់បព្វជិត ដែលនឹងប្រព្រឹត្តប្រតិបត្តិខ្លួនឱ្យល្អក្រៃលែងឡើងទៅ ។ ក្រោយអំពីព្រះពុទ្ធអង្គ ទ្រង់បញ្ជូនសាវ័កទាំង ៦០ រូប ចេញទៅផ្សព្វផ្សាយព្រះសាសនាហើយ ព្រះអង្គយាងទៅកាន់ឧរុវេលាសេនានិគម តែមួយព្រះអង្គឯង ។

( ៦ ) ក្នុងចន្លោះផ្លូវទ្រង់ប្រោស **ភទ្ទវគ្គិយជាសម្លាញ់នឹងគ្នា** ៣០ នាក់ក្នុងចំការកប្បាសឈ្មោះ **កប្បាសិការនាសណ្ឌ** ជិតតំបន់ឧរុវេលា ភទ្ទវគ្គិយទាំង ៣០ នាក់ ពួកខ្លះបានដល់សោតាបត្តិផល ពួកខ្លះបានដល់សកទាគាមិផល ពួកខ្លះបានដល់អនាគាមិផល មិនមានអ្នកណានៅជាបុថុជ្ជន ឬជាព្រះខីណាស្រព ភទ្ទ-វគ្គិយក្រាបទូលសូមបព្វជ្ជាឧបសម្បទ ព្រះអង្គទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ដល់ភទ្ទវគ្គិយទាំងនោះ ។

(៧) ទ្រង់យាងដល់ឧរុវេលាសេនានិគម ទ្រង់ប្រោសជដិល ៣ នាក់ បងប្អូន គឺ **ឧរុវេលកស្សប នទីកស្សប** និង **គយាកស្សប** រួមទាំងបរិវារ ១០០០ នាក់ ឱ្យសម្រេចសោតាបត្តិផលទាំងអស់ ពួកជដិលទូលសូមបព្វជ្ជា ឧបសម្បទា ព្រះអង្គទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ហើយស្ដេចយាងចារិក ទៅកាន់តំបន់គយាសីសៈ ទ្រង់សម្ដែងអាទិត្តបរិយាយសូត្រ ដល់ភិក្ខុជដិលទាំងអស់នោះ រហូតបានសម្រេចអរហត្តផលទាំងអស់អង្គ ។

(៨) ក្រោយអំពីជដិលភិក្ខុបានសម្រេចអរហត្តផលហើយ ព្រះពុទ្ធអង្គយាងទៅកាន់ ក្រុងរាជគ្រឹះតាមពាក្យប្ដេជ្ញា ដែលទទួលទុកជាមួយព្រះបាទពិម្ពិសារមុនត្រាស់ដឹង ទ្រង់គង់ក្នុង **លដ្ឋិវ័ន** (ចំការត្នោតជិទង់) ព្រមដោយភិក្ខុជដិល ១០០០ រូប ។

ព្រះរាជាព្រមដោយរាជបរិវារចូលមកគាល់ ព្រះពុទ្ធអង្គទ្រង់សម្ដែងមហានារទជាតក និងអរិសច្ច ៤ ប្រោសព្រះរាជា និងរាជបរិវារ ភាគច្រើនបានសម្រេចសោតាបត្តិផល ដ៏សេសទទួលត្រៃសរណគមន៍ សូមថ្វាយខ្លួនជាឧបាសកក្នុងព្រះពុទ្ធសាសនា ហើយទូលអារាធនាព្រះសាស្ដា ព្រមដោយភិក្ខុសង្ឃសោយភត្តាហារក្នុងថ្ងៃស្អែក ។

លុះព្រឹកឡើង ព្រះសម្ពុទ្ធទ្រង់យាងចូលទៅទទួលមហាទានក្នុងព្រះរាជនិវេសន៍ ក្រោយពីសម្រេចភត្តកិច្ចហើយ ព្រះបាទពិម្ពិសារថ្វាយវេឡុវ័នឧទ្យានឱ្យជាអារាម រាប់ថាជា **អារាមដំបូងក្នុងព្រះពុទ្ធសាសនា និងទ្រង់អនុញ្ញាត**

**ឱ្យសង្ឃសាវ័កទទួលអារាម ដែលមានអ្នកថ្វាយបាន ។**

ក្នុងថ្ងៃតមក ព្រះបាទពិម្ពិសារចូលគាល់ព្រះសម្ពុទ្ធ ទូលដំណាលហេតុការណ៍ថា កាលយប់មិញខ្ញុំព្រះអង្គ បានឮសំឡេងចម្លែកគួរឱ្យខ្លាច មិនដឹងថានឹងមានហេតុអាក្រក់អ្វីកើតឡើងដល់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា ទ្រង់កុំបារម្ភឡើយមហាបពិត្រ នោះគឺសំឡេងញាតិ ក្នុងអតីតៈរបស់ព្រះអង្គដែលទៅកើតជាប្រេត ញាតិទាំងនោះបំណងនឹងជួបចំពោះព្រះអង្គតែម្នាក់គត់ រង់ចាំអស់មួយពុទ្ធន្តរ ( មួយចន្លោះព្រះពុទ្ធ ) មកហើយ ត្រាច់ទៅដោយសង្ឃឹមថា កាលព្រះអង្គថ្វាយទានចំពោះព្រះពុទ្ធហើយ នឹងឧទ្ទិសឱ្យដល់ពួកគេខ្លះ ប្រេតទាំងនោះនាំគ្នាមកសូមចំណែកបុណ្យ ព្រោះកាលម្សិលមិញព្រះអង្គបរិច្ចាគទានហើយ មិនបានឧទ្ទិសចំណែកកុសលទៅឱ្យ ទើបបញ្ចេញសំឡេងស្រែកដូច្នោះ ។

ទើបព្រះរាជា អារាធនាព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃទទួលការថ្វាយទានក្នុងថ្ងៃស្អែកឡើង ដើម្បីឧទ្ទិសទានឱ្យដល់ញាតិទាំងនោះ ។ ព្រឹកឡើងកាលព្រះរាជា **ថ្វាយភត្តាហារ** ទ្រង់ឧទ្ទិសថា សូមទាននេះចូរមានដល់ញាតិទាំងឡាយរបស់យើង ភត្តាហារដែលជាទិព្វ ក៏កើតដល់ប្រេតទាំងនោះ បានបរិភោគយ៉ាងឆ្អែតស្កប់ស្កល់ កាលព្រះរាជាថ្វាយសំពត់ជាដើម ទ្រង់ឧទ្ទិសថា សូមទាននេះចូរមានដល់ញាតិទាំងឡាយ សម្បត្តិគ្រប់យ៉ាងដែលជាទិព្វ ក៏កើតដល់ប្រេតទាំងនោះបានប្រើប្រាស់ ។

ខណៈដែលស្រោចទឹកទក្ខិណោទក ព្រះរាជាទ្រង់ឧទ្ទិសថា សូមទាននេះ

ចូរមានដល់ញាតិទាំងឡាយរបស់យើង ស្រះបោក្ខរណីក៏កើតដល់ប្រេតទាំងនោះ បានងូតផឹក រម្ងាប់សេចក្ដីស្រេកឃ្លាន មានការរីករាយសប្បាយចិត្ត តអំពីនោះ ព្រះមានព្រះភាគទ្រង់អធិដ្ឋាន ឱ្យព្រះរាជាឃើញបណ្ដាពពួកញាតិទាំងនោះ មាន រាងកាយឆ្អែតឆ្អន់ ពណ៌សម្បុរផូរផង់ និងពាក់ភស្ត្រាភរណៈដែលជារបស់ទិព្វ ដោយអានិសង្សរបស់បុណ្យ ដែលព្រះបាទពិម្ពិសារទ្រង់ឧទ្ទិសឱ្យ ព្រះមានព្រះ ភាគទ្រង់ត្រាស់ថា **ទក្ខិណាដែលមហាបពិត្រថ្វាយ** ឧទ្ទិសដល់ពួកញាតិក្នុងថ្ងៃ នេះ ព្រោះហេតុដែលព្រះសង្ឃជាស្រែបុណ្យដ៏កំពូលរបស់លោក ជាទក្ខិណាដែល តាំងទុកល្អហើយក្នុងព្រះសង្ឃ ទើបទាននេះសម្រេចផលក្នុងខណៈនេះភ្លាម ។

អដ្ឋកថាពោលថា **ទក្ខិណាទាន** រមែងសម្រេចផលក្នុងខណៈនោះបាន ត្រូវជាទាន ប្រកបដោយអង្គ ៣ គឺ :

**អត្តនា អនុមោទនេន** ដោយការអនុមោទនាដោយខ្លួនឯង ១

**ទាយិកានំ ឧទ្ទិសេន** ដោយការឧទ្ទិសឱ្យរបស់ទាយក ១

**ទក្ខិណេយ្យសម្បទេន** ដោយការដល់ព្រមដោយទក្ខិណេយ្យបុគ្គល ១

ចប់ទេសនា ការសម្រេចធម៌បានកើតដល់ជនជាច្រើន ដែលស្លុតចិត្ត ព្រោះការពណ៌នាទោស នៃការកើតក្នុងអត្តភាពជាប្រេត ព្រះមានព្រះភាគទ្រង់ ត្រាស់សម្ដែង **តិរោកុឌ្ឌសូត្រ** នេះដល់ទេវតា និងមនុស្សទាំងឡាយទៀត ការ ត្រាស់ដឹងធម៌បានប្រព្រឹត្តទៅរហូត ៧ ថ្ងៃ ។

ក្នុងអដ្ឋកថា ពោលដល់បុព្វកម្មរបស់ប្រេតទាំងឡាយនោះ សេចក្ដីសង្ខេប

ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមបុស្សៈ គ្រានោះក្នុងនគរឈ្មោះ **កាសី** ព្រះរាជាព្រះនាមថា **ជយសេន** ព្រះមហេសីព្រះនាមថា **សិរិមា** ជាព្រះរាជមាតាបិតារបស់ព្រះសម្មាសម្ពុទ្ធបុស្សៈ ព្រះរាជាឧបដ្ឋាកព្រះសម្មាសម្ពុទ្ធបុស្សៈដោយព្រះអង្គឯងរហូតមកមិនព្រមឱ្យអ្នកដទៃឧបដ្ឋាក ។ មានបងប្អូនមាតាផ្សេងគ្នារបស់ព្រះសម្មាសម្ពុទ្ធបុស្សៈបីនាក់គិតថា ព្រះពុទ្ធទាំងឡាយរមែងឧប្បត្តិឡើងក្នុងលោកដើម្បីអនុគ្រោះសត្វលោក មិនមែនអនុគ្រោះដល់បុគ្គលតែម្នាក់ ក៏រកឧបាយឱ្យជាយដែនបង្ករការបះបោរ ទើបព្រះរាជាជយសេនបញ្ជូនឱរសទាំង ៣ ចេញទៅបង្ក្រាប កាលបានជ័យជំនះត្រឡប់មក បានទទួលពរអំពីព្រះរាជបិតាថា ពួកខ្លួនប្រាថ្នានឹងឧបដ្ឋាកព្រះពុទ្ធត្រឹមតែ ៣ ខែ ព្រះរាជបិតាទ្រង់អនុញ្ញាត ក្រោយមកទើបនាំបុរសជាបរិវារ ១000 នាក់ សមាទានសីល ១០ ស្លៀកដណ្តប់សំពត់កាសាវៈ បញ្ជាឱ្យនាយឃ្លាំង ប្រមូលបញ្ជីរួមគ្នាបើកស្បៀងតាមវារៈអំពីឃ្លាំងទាំងឡាយ របស់បងប្អូនទាំង ៣ អង្គ ថ្វាយទាន ។

កាលដល់វេលាថ្វាយទាន កូនរបស់កម្មករទាំងនោះស្រែកយំ ត្រូវការយាគូ និងភត្តជាដើម កម្មករទាំងនោះកាលភិក្ខុសង្ឃនៅមិនទាន់មក ក៏ចែករបស់ទាំងនោះចំណែកខ្លះដល់កូនរបស់ខ្លួនមុន ក្នុងវេលាដែលភិក្ខុសង្ឃឆាន់ស្រេចហើយ ទើបមិនមានវត្ថុនៅសេសសល់ឡើយ ផលនៃការលាក់លៀមអាហារដែលនឹងប្រគេនដល់សង្ឃ កាលអស់ជីវិតទៅ កម្មករទាំងនោះបានទៅកើតក្នុងបេត្តិវិស័យ ។

ពួកប្រេតទាំងនោះ រង់ចាំពេលវេលាដែលនឹងបានអាហារអស់កាលដ៏យូរ

ណាស់ ចូលគាល់ទូលសួរព្រះពុទ្ធកន្លងមកហើយអស់ ៣ ព្រះអង្គ រហូតដល់សម័យព្រះកស្សបសម្ពុទ្ធ ត្រាស់ថា ពួកអ្នកនៅមិនទាន់បានក្នុងកាលរបស់តថាគត លុះអំណើះអស់ពីតថាគត កាលមហាប្រថពីដុះឡើងបាន ១ យោជន៍ ព្រះពុទ្ធព្រះនាមថាគោតមនឹងឧប្បត្តិឡើង ក្នុងកាលណោះញាតិរបស់ពួកអ្នកនឹងជាព្រះរាជានាមថា ព្រះបាទពិម្ពិសារ ព្រះរាជានោះនឹងថ្វាយទានចំពោះព្រះសាស្តា ហើយនឹងឱ្យចំណែកបុណ្យដល់ពួកអ្នក ពួកអ្នកនឹងបានអាហារក្នុងគ្រានោះឯង ប្រេតទាំងនោះ ត្រូវរង់ចាំមកទៀតអស់មួយចន្លោះព្រះពុទ្ធទៀត ។

កាលព្រះតថាគតស្តេចឧប្បត្តិហើយ ព្រះរាជឱរសមកកើតជាជដិល ៣ នាក់បងប្អូន សមុហ៍បញ្ជីរបស់ព្រះរាជឱរសទាំង ៣ ព្រះអង្គនោះ បានមកកើតជាព្រះបាទពិម្ពិសារ នាយឃ្លាំងបានជាវិសាខសេដ្ឋី ជាអ្នកដែលព្រះបាទពិម្ពិសារប្រោសប្រាណ បានចូលទៅគាល់ព្រះពុទ្ធអង្គគ្រាដំបូង ក្នុងលដ្ឋិវ័នព្រមជាមួយនឹងព្រះបាទពិម្ពិសារ ស្តាប់ធម៌ហើយសម្រេចសោតាបត្តិផល តមកបានធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល ។

ព្រះបាទពិម្ពិសារថ្វាយទានក្នុងថ្ងៃដំបូងមិនបានឧទ្ទិសឱ្យ ទើបប្រេតទាំងនោះបញ្ចេញសំឡេង បង្ហាញខ្លួនដល់ព្រះរាជា ដើម្បីស្រែកសូមចំណែកបុណ្យដូចពោលមកហើយ ។

( ៩ ) ចំណែក **ព្រះអញ្ញាកោណ្ឌញ្ញៈ** ធ្វើដំណើរទៅក្រុងកបិលពស្តុឱ្យ **បុណ្ណមាណព** បុត្ររបស់នាងមន្តានី ជាក្មួយប្រុសបួសដោយឃើញថា បុណ្ណ-

មាណពកាលបួសហើយ នឹងជាកំពូលធម្មកថិកក្នុងព្រះសាសនា ទើបត្រឡប់ទៅកាន់ស្រុកព្រាហ្មណ៍ឈ្មោះ **ទោណវត្ថុ** ដែលជាមាតុភូមិរបស់លោក បំបួសក្មួយប្រុសហើយ ខ្លួនឯងក៏ត្រឡប់មកគាល់ព្រះទសពល ក្រាបទូលលាទៅចម្រើនសមណធម៌នៅ **ស្រះមណ្ឌាកិនី** ព្រៃឆទ្ទន្ត ក្នុងហិមវន្តប្រទេស បន្ទាប់អំពីកើតសេចក្តីក្រែងចិត្តដែលអគ្គសាវ័កទាំងពីរ ត្រូវសម្តែងសេចក្តីឱនលំទោនចំពោះខ្លួនទាំងការដែលនឹងត្រូវបដិសណ្ឋារៈជាមួយគ្រហស្ថបព្វជិត ដែលមកកាន់សំណាក់របស់លោក ដែលនឹងជាហេតុមិនឱ្យមានពេលចម្រើនសេចក្តីស្ងប់ ប្រការមួយទៀត លោកបំណងនឹងនៅដោយសេចក្តីត្រេកអរក្នុងវិវេក នៅទីនោះលោកបានអាស្រ័យមេហ្វូងដំរីត្រកូលឆទ្ទន្តជាឧបដ្ឋាក ។

(១០ ) ព្រះបុណ្ណមន្តានីបុត្រ បំពេញព្យាយាមក្នុងនគរកបិលពស្តុធ្វើទុកក្នុងចិត្តដោយប្រាជ្ញា មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ព្រមដោយបដិសម្ភិទា ៤ វិមោក្ខ ៨ អភិញ្ញា ៦ និងបានដឹងច្បាស់កថាវត្ថុ គឺពាក្យពេចន៍ដែលគួរពោល ១០ ប្រការ បានដល់ **ការប្រាថ្នាតិច, សន្តោស, ស្ងប់ស្ងាត់, មិនច្របូកច្របល់ដោយពួកគណៈ, ប្រារព្ធព្យាយាម, បរិបូរណ៍ដោយសីល, សមាធិ, បញ្ញា, វិមុត្តិ, និងវិមុត្តិញាណទស្សនៈ ។**

កុលបុត្រ ៥០០ នាក់ សូមបួសក្នុងសំណាក់ខ្លួន ព្រះថេរៈទូន្មានកុលបុត្រទាំងនោះដោយកថាវត្ថុ ១០ ភិក្ខុទាំងនោះតាំងនៅក្នុងឱវាទរបស់លោកហើយបានសម្រេចអរហត្តគ្រប់រូប ក្រោយពីសម្រេចអរហត្តផលហើយ ភិក្ខុទាំងនោះ

ចូលទៅរកព្រះបុណ្ណមន្តានីបុត្រ ជាព្រះឧបជ្ឈាយ៍ក្រាបទូលថា ពួកខ្ញុំបានសម្រេចផលហើយ ដល់ទីបំផុតនៃព្រហ្មចរិយហើយ ទាំងជាអ្នកបានកថាវត្ថុ ១០ ប្រការ ពួកខ្ញុំប្រាថ្នានឹងចូលគាល់ព្រះមានព្រះភាគ លោកម្ចាស់ !

ព្រះបុណ្ណមន្តានីបុត្តត្ថេរពិចារណាថា ព្រះសាស្តារមែងទ្រង់ជ្រាបថា យើងបានកថាវត្ថុ ១០ ប្រការ ប្រសិនបើយើងនឹងទៅគាល់ព្រះអង្គ ដោយមានភិក្ខុទាំងនេះហែហមជាប់តាមយើងទៅផង ក៏នឹងជាការច្របូកច្របល់ដោយពួកគណៈរមែងមិនសមគួរ ទើបពោលនឹងភិក្ខុទាំងនោះថា លោកអ្នកមានអាយុទាំងឡាយ ចូរទៅគាល់ព្រះបរមសាស្តាមុនចុះ ថ្វាយបង្គំព្រះយុគលបាទតាមពាក្យរបស់យើងផងថា យើងនឹងជាប់តាមទៅខាងក្រោយ ។

(១១) រយៈកាលដំបូងដែលព្រះអង្គត្រាស់ដឹង ខណៈដែលគង់នៅទៀបគល់រាជាយតនៈ **តបុស្សៈ** និង **ភល្លិកៈ** ពាណិជ្ជ ២ នាក់បងប្អូនជាអ្នកដែនឧត្តរាបថៈ ចេញអំពី ឧក្កលាជនបទ ចូលមកជួញដូរនៅក្រុងរាជគ្រឹះ បានថ្វាយសដូវផង់ និងសដូវដុំដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលជាព្រះក្រយាហារគ្រាដំបូង បន្ទាប់អំពីត្រាស់ដឹង បានឈ្មោះថា **ទ្វេវាចិកឧបាសក** ជាឧបាសកមួយគូគ្រាដំបូងក្នុងលោកដែលពោលវាចាសូមដល់ព្រះពុទ្ធនិងព្រះធម៌ ជាសរណៈ (ក្នុងវេលានោះនៅមិនទាន់មានព្រះសង្ឃ) ដែលព្រះអង្គទ្រង់បានប្រទាន **ព្រះកេសធាតុ** ដល់បងប្អូននោះពីរនាក់ គាត់បានបញ្ចុះព្រះកេសធាតុទុកក្នុងប្រអប់មាស សាងចេតិយ៍បញ្ចុះព្រះកេសធាតុនោះបូជាទុកក្នុង **ក្រុងអសិតញ្ជនៈ ដែនឧត្តរាបថៈ**

ដែលជាភូមិកំណើតរបស់អ្នកទាំងពីរ ។

តមក អ្នកទាំងពីរបានទទួលដំណឹងថា ក្រោយអំពីព្រះសាស្ដាទ្រង់សម្ដែងបឋមទេសនាហើយ ស្ដេចចេញចាកពារាណសីយាងទៅកាន់ក្រុងរាជគ្រឹះ ពីរនាក់បងប្អូនបានតាមមកគាល់ឯក្រុងរាជគ្រឹះ ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ដល់ពួកគេទាំងពីរនាក់ ពួកគេបានសម្រេចសោតាបត្តិផល **តបុស្សៈ** ជាឧបាសកមិនបួស **ភល្លិកៈ** បួសហើយបានសម្រេចអរហត្តផល ព្រមទាំងអភិញ្ញា ៦ កាលព្រះពុទ្ធអង្គគង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់សរសើរជនទាំងពីរថា ជាកំពូលជាងឧបាសកអ្នកដល់សរណៈមុនអ្នកដទៃ ។

(១២) សម័យនោះ **ឧបតិស្សៈ** និង **កោលិតៈ** ប្រព្រឹត្តព្រហ្មចរិយក្នុងសំណាក់របស់សញ្ជ័យបរិព្វាជក ក្នុងក្រុងរាជគ្រឹះ ទាំងពីរនាក់បានធ្វើកតិកានឹងគ្នាថា អ្នកណាបានអមតធម៌មុនអ្នកនោះនឹងប្រាប់ដល់ម្នាក់ទៀត ព្រឹកឡើងឧបតិស្សៈបានឃើញ **អស្សជិថេរៈ** កំពុងត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ មានឥរិយាបថដែលគួរជ្រះថ្លា កាលអស្សជិភិក្ខុត្រឡប់អំពីបិណ្ឌបាត ទើបឧបតិស្សៈចូលទៅរក ពោលថា **ឥន្ទ្រីយ៍របស់លោកផូរផង់ ពណ៌សម្បុររបស់លោកបរិសុទ្ធផូរផង់ លោកបួសចំពោះអ្នកណា នរណាជាសាស្ដារបស់លោក ហើយលោកពេញចិត្តក្នុងធម៌របស់អ្នកណា ។**

អស្សជិថេរៈតបថា ព្រះមហាសមណសក្យបុត្រ ទ្រង់ចេញបួសអំពីសក្យត្រកូល យើងបួសឧទ្ទិសចំពោះព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គ

នោះជាសាស្តារបស់យើង យើងពេញចិត្តក្នុងធម៌របស់ព្រះមានព្រះភាគអង្គនោះ ឧបតិស្សៈសួរថា ព្រះសាស្តារបស់លោកទូន្មានយ៉ាងណា ? ណែនាំយ៉ាងណា ?

ព្រះអស្សជិភិក្ខុពោលថា យើងជាអ្នកបួសថ្មី ទើបមកកាន់ធម្មវិន័យនេះ មិនយូរ មិនអាចសម្តែងធម៌ឱ្យពិស្តារបាន តែនឹងពោលសេចក្តីដល់អ្នកដោយបំព្រួញថា :

**ធម៌ទាំងឡាយណាកើតពីហេតុ ព្រះតថាគតទ្រង់សម្តែងហេតុ**
**នៃធម៌ទាំងឡាយនោះ និងការរលត់នៃធម៌ទាំងនោះ ព្រះមហា-**
**សមណៈ មានប្រក្រតីពោលយ៉ាងនេះ ។**

ឧបតិស្សៈបានស្តាប់ធម្មបរិយាយនេះ ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិលថា **ធម្មជាតិណាមួយមានការកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា** បានកើតឡើងដល់ឧបតិស្សៈបរិព្វាជកក្នុងខណៈនោះ ។

វេលាតមក ឧបតិស្សៈចូលទៅរកកោលិតៈ រៀបរាប់ហេតុការណ៍គ្រប់យ៉ាងឱ្យសម្លាញ់ស្តាប់ កោលិតៈស្តាប់ធម្មបរិយាយនោះ ក៏បានធម្មចក្ខុដូចគ្នា សម្លាញ់ទាំងពីរ ទើបចូលទៅលាសញ្ជ័យជាអាចារ្យ ហើយធ្វើដំណើរទៅកាន់វត្តវេឡុវ័ន ដើម្បីគាល់ព្រះពុទ្ធអង្គ ព្រមដោយបរិវារ ២៥០ នាក់ទៀត ។

ព្រះមានព្រះភាគទតឃើញសម្លាញ់ទាំងពីរដើរមកពីចម្ងាយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សម្លាញ់ពីរនាក់នោះគឺ **ឧបតិស្សៈ** និង

**កោលិតៈ** កំពុងមក អ្នកទាំងពីរនេះឯងនឹងជា **គូអគ្គសាវ័ក** ដ៏កំពូលរបស់តថាគត ។ លុះមកដល់ហើយ សម្លាញ់ទាំងពីរបានឱនក្បាលចុះទៀបយុគលបាទរបស់ព្រះមានព្រះភាគ ហើយក្រាបទូលថា សូមពួកខ្ញុំព្រះអង្គ គប្បីបានបព្វជ្ជាឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគផង ព្រះអង្គ !

ព្រះមានព្រះភាគត្រាស់ថា **ពួកអ្នកចូរមកជាភិក្ខុចុះ ធម៌ដែលតថាគតសម្ដែងល្អហើយ ពួកអ្នកចូរប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីធ្វើទីបំផុតទុក្ខចុះ** ព្រោះហេតុដែលឧបតិស្សៈ ជាបុត្ររបស់នាងសារីព្រាហ្មណី និងព្រះកោលិតៈជាបុត្ររបស់មោគ្គលីព្រាហ្មណី ទើបអ្នកស្រុកហៅលោកតាមនាមរបស់មាតាថា **សារីបុត្រ** និង **មោគ្គល្លាន** ។

កាលសម្លាញ់ទាំងពីរបួសហើយយ៉ាងនេះ ព្រះសារីបុត្រនោះ កាលណាបាននៅក្នុងវិហារតែមួយជាមួយព្រះអស្សជិថេរៈ កាលនោះលោកចូលទៅឧបដ្ឋាកព្រះថេរៈដោយសេចក្ដីគោរពថា ព្រះថេរៈមានអាយុនេះជាបុព្វាចារ្យរបស់យើង យើងអាស្រ័យលោកអ្នកមានអាយុនេះ ទើបបានដឹងច្បាស់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ តែថាកាលណាមិនបាននៅក្នុងវិហារជាមួយគ្នា កាលនោះប្រសិនបើបានដឹងថា ព្រះថេរៈនៅក្នុងទិសណា លោកក៏នឹងងាកមុខទៅទិសនោះថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយផ្គងអញ្ជលីនមស្ការ ភិក្ខុទាំងឡាយឃើញការធ្វើនោះហើយ សន្ទនាគ្នាថា ព្រះសារីបុត្រទោះបីជាអគ្គសាវ័កហើយក៏ដោយតែនៅថ្វាយបង្គំទិសរៀងរាល់ថ្ងៃ លោកមិនទាន់លះទិដ្ឋិរបស់ពួកព្រាហ្មណ៍ទេដឹង?

ព្រះមានព្រះភាគទ្រង់ដឹងដោយសោតធាតុដែលជាទិព្វ ទើបទ្រង់ឱ្យហៅពួកភិក្ខុទាំងនោះមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រមិនបានថ្វាយបង្គំទិសទេ សារីបុត្រជាអ្នកបូជាអាចារ្យ លោកបានដឹងធម៌ព្រោះអាស្រ័យអ្នកណា ទើបលោកនមស្ការទៅរកអ្នកនោះ ដែលជាអាចារ្យរបស់ខ្លួន ។

(១៣) **ព្រះមហាមោគ្គល្លាន** ឧបសម្បទាហើយ គេចទៅបំពេញព្យាយាមក្នុង **កល្លវាលមុត្តគ្រាម** ក្នុងថ្ងៃទី ៧ ខណៈដែលព្រះពុទ្ធអង្គគង់នៅភេសកឡាវ័ន ក្នុងដែនសុង្សុមារគិរី ដែលនៅចន្លោះវេសាលី និងសាវត្ថី ព្រះអង្គទ្រង់ជ្រាបដោយព្រះញាណថា ព្រះមោគ្គល្លានត្រូវសេចក្តីព្យាយាមក្នុងការដើរចង្ក្រមបៀតបៀនរហូត ៧ ថ្ងៃ អង្គុយងោកងក់នៅចុងបំផុតនៃទីចង្ក្រម ទើបយាងទៅប្រាកដព្រះអង្គត្រង់កល្លវាលមុត្តគ្រាម ប្រទានឱវាទថា មោគ្គលានពេលអ្នកមានសញ្ញាយ៉ាងណា អ្នកគប្បីធ្វើទុកក្នុងចិត្តនូវសញ្ញានោះឱ្យច្រើន នឹងលះបង់ការងុយងោកបាន ប្រសិនបើលះបង់មិនបានអ្នកគប្បីបដិបត្តិដូច្នេះ គឺៈ

១ ពិចារណាដល់ធម៌តាមដែលបានស្តាប់ហើយ និងបានរៀនមកហើយ

២ ស្វាធ្យាយធម៌តាមដែលបានស្តាប់ហើយ និងបានរៀនមក ហើយដោយពិស្តារ ។

៣ ច្បារត្រចៀកទាំងពីរខាង យកដៃស្ទាបខ្លួន ។

៤ ក្រោកឡើងឈរ យកទឹកលាងភ្នែក សំឡឹងមើលទិសទាំងឡាយ-ងើយមើលផ្កាយ ។

**៥ ធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញា សម្គាល់ថា ពេលថ្ងៃ ឬ ពេលយប់ រមែងមានពន្លឺភ្លឺដូចគ្នា ។**

**៦ អធិដ្ឋានការដើរចង្ក្រម សង្រួមឥន្ទ្រីយ៍ មិនគិតទៅខាងក្រៅ ។**

**៧ សម្រេចដំណេក តម្រួតជើងឆ្វេងលើជើងស្តាំ មានសតិ-សម្បជញ្ញៈក្នុងការដេក ការលក់ និង ការភ្ញាក់ឡើង ។**

ម្នាលមោគ្គល្លាន អ្នកគប្បីសិក្សាយ៉ាងនេះឯង នឹងលះសេចក្តីងុយងោកបាន ហើយអ្នកគប្បីសិក្សាយ៉ាងនេះទៀតថា យើងនឹងមិនប្រកាន់ខ្លួនចូលទៅកាន់ត្រកូល យើងនឹងមិននិយាយពាក្យពេចន៍ដែលជាហេតុឱ្យឈ្លោះគ្នា យើងមិនសរសើរការច្រឡូកច្រឡំដោយពួកជន ទាំងគ្រហស្ថ និងបព្វជិត ហើយត្រាស់ **ធាតុកម្មដ្ឋាន** ពោលដោយការពិចារណាកាយ ដោយអំណាចធាតុ ៦ គឺ បឋវីធាតុ អាបោធាតុ តេជោធាតុ អាកាសធាតុ និងវិញ្ញាណធាតុ ថា ធាតុទាំងនោះមិនមែនយើង មិនមែនរបស់យើង មិនមែនតួខ្លួនរបស់យើង មិនគួរប្រកាន់មាំដោយតណ្ហា និងទិដ្ឋិ ។ ព្រះមោគ្គល្លានបានសម្រេចអរហត្តផល ក្រោយពីឧបសម្បទាហើយ ៧ ថ្ងៃ , ព្រះសូត្រនេះ ទាំងជាព្រះឱវាទ ទាំងជាវិបស្សនាសម្រាប់ព្រះមោគ្គល្លានត្ថេរ ។

( ១៤ ) **ព្រះសារីបុត្រ** ក្រោយពីឧបសម្បទាហើយ ក្នុងថ្ងៃទី ១៥ ខណៈដែលកំពុងថ្វាយការបក់ផ្លិតនៅខាងក្រោយព្រះសាស្តា ត្រង់ល្អាងសូករខាតា លើភ្នំគិជ្ឈកូដ បានស្តាប់ **ទីឃនខសូត្រ** ដែលព្រះអង្គទ្រង់សម្តែងដល់ **ទីឃនខ-**

**បរិព្វាជក** ជាក្មួយប្រុស សម្ដែងពីរឿងទិដ្ឋិជាហេតុឱ្យកើតការវិវាទ ឱ្យពិចារណាកាយជារបស់មិនទៀង ជាទុក្ខ ជាជម្ងឺ ជារបស់ទ្រុឌទ្រោម ជារបស់សោះសូន្យ ជារបស់មិនមែនខ្លួន ឱ្យលះបង់សេចក្ដីពេញចិត្តក្នុងកាយ ការហួងហែងក្នុងកាយ និងទ្រង់សម្ដែងវេទនា ៣ ដែលអាស្រ័យបច្ច័យតាក់តែងកើតឡើង មានការអស់ទៅ សូន្យទៅ រលត់ទៅជាធម្មតា មិនគួរប្រកាន់មាំដោយទិដ្ឋិ ។

ព្រះសារីបុត្រ បានឮព្រះមានព្រះភាគសម្ដែងការលះធម៌ទាំងនោះ ការរលាស់ចេញនូវធម៌ទាំងនោះដោយបញ្ញាដ៏ប្រពៃ បានដឹងច្បាស់តាមធម៌នោះ ចិត្តរបស់លោកក៏រួចផុតចាកអាសវៈសម្រេចអរហត្តផល ដល់ទីបំផុតនៃសាវ័កបារមីញ្ញាណ និងបញ្ញា ១៦ ក្នុងទីនោះឯង , ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិលកើតឡើងហើយដល់ទីឃនខបរិព្វាជកថា **ធម្មជាតិណាមួយមានការកើតជាធម្មតា ធម្មជាតិនោះទាំងអស់មានការរលត់ទៅជាធម្មតា ។**

លំដាប់នោះ ទីឃនខបរិព្វាជក ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះគោតម ភាសិតរបស់ព្រះអង្គជាក់ច្បាស់ណាស់ ប្រៀបដូចបុគ្គលផ្ងាររបស់ដែលផ្កាប់ បើករបស់ដែលបិទ ប្រាប់ផ្លូវដល់មនុស្សវង្វេងផ្លូវ ឬទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា អ្នកមានចក្ខុនឹងឃើញរូប ខ្ញុំព្រះអង្គសូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង និងព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះគោតមទ្រង់ចាំទុកខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់សរណៈស្មើដោយជីវិត ចាប់ផ្ដើមតាំងពីថ្ងៃនេះតទៅ ។

អដ្ឋកថាពោលថា ព្រះសារីបុត្រដូចបុគ្គលដែលឃើញអ្នកដទៃ កំពុងបរិភោគអាហារ តែខ្លួនឯងបន្ទោបង់ការឃ្លានបាន ទាំងមិនបានបរិភោគអាហារនោះឡើយ ។

( ១៥ ) ថ្ងៃដែលព្រះសារីបុត្រសម្រេចអរហត្តផល ក្នុងវេលារសៀល មានការប្រជុំសង្ឃ ក្នុងវត្តវេឡុវ័ន ដែលហៅថា **ចតុរង្គសន្និបាត** ប្រកបដោយអង្គ ៤ គឺ :

**~ ជាថ្ងៃ ១៥ កើត ខែមាឃបុណ្ណមី**

**~ ភិក្ខុ ១២៥០ រូប មកប្រជុំគ្នាដោយមិនបានណាត់គ្នាជាមុន**

**~ ភិក្ខុដែលមកប្រជុំសុទ្ធតែជាព្រះអរហន្តខីណាស្រព-ដែលបានអភិញ្ញា ៦**

**~ ភិក្ខុទាំងអស់សុទ្ធតែជាឯហិភិក្ខុឧបសម្បទា** ( បួសដោយឫទ្ធិ )

ក្នុងទីប្រជុំសង្ឃគ្រានោះ ព្រះពុទ្ធអង្គទ្រង់ស្ថាបនា ព្រះសារីបុត្រ និងព្រះមោគ្គល្លាន **ឱ្យជាគូអគ្គសាវ័ក** ត្រាស់ថា សាវ័កបារមីញាណរបស់អ្នកទាំងពីរនេះម្នាក់ៗ ក៏បានបំពេញមករហូតពេញបរិបូរណ៍ហើយ រាប់ដោយអសង្ខេយ្យ និង មួយសែនមហាកប្ប ។

តមកទ្រង់សម្តែង **ឱវាទបាតិមោក្ខ** ក្នុងកណ្តាលទីប្រជុំសង្ឃ ក្នុងវត្តវេឡុវ័ន ដែលមានភិក្ខុបុរាណជដិល ១000 រូប ភិក្ខុបរិវាររបស់សារីបុត្រ និងព្រះមោគ្គល្លាន ២៥0 រូប ទៀត, **ឱវាទបាតិមោក្ខ** នោះថា :

**ខន្តិ បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា**
**ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ**
**វិហេឋយន្តោ ។**

អំណត់ គឺសេចក្ដីអត់ធន់ជាតបធម៌ដ៏ឧត្ដម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតិដ៏ឧត្ដម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃមិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ**

កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀតបៀន (អ្នកដទៃ) ១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេក និងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

ក្នុងសម័យរបស់ព្រះមានព្រះភាគនៃយើងនេះ ការជួបជុំសង្ឃដូច្នេះមានតែម្តង គឺក្នុងឆ្នាំដំបូងក្រោយអំពីត្រាស់ដឹងហើយ ៩ ខែ ។

(១៦) សម័យមួយ ព្រះសាស្តាគង់នៅក្នុងព្រះគន្ធកុដិ នាវេឡុវ័នវិហារ បានស្តាប់ហេតុនៃផែនដីកម្រើក ទ្រង់ជ្រាបដោយព្រះញាណថា **បិប្ផលិមាណព** បុត្ររបស់កបិលព្រាហ្មណ៍ ក្នុងស្រុកមហាតិត្ថៈ ដែនមគធៈ និង **នាងភទ្ទកា-បិលានី** ជាភរិយា លះបង់សម្បត្តិដែលប្រមាណមិនបាន បួសឧទ្ទិសតថាគត ផែនដីកម្រើកក្នុងពេលនេះកើតពីកម្លាំងនៃគុណរបស់បុគ្គលទាំងពីរ ត្រង់ផ្លូវដែលបែកគ្នាទៅស្វែងរកសច្ចធម៌ សូម្បីតថាគតក៏គួរអនុគ្រោះអ្នកទាំងពីរ ទើបព្រះពុទ្ធអង្គយាងចេញអំពីព្រះគន្ធកុដិ ទៅគង់ទៀបគល់ពហុបុត្តកនិគ្រោធ (ដើមជ្រៃ) តាមផ្លូវចន្លោះក្រុងរាជគ្រឹះ និងនាលន្ទា ដើម្បីសង្គ្រោះបិប្ផលិមាណព ដែលមាននាមត្រកូលថា **កស្សប** ។

**បិប្ផលិមាណព** មើលឃើញព្រះពុទ្ធអង្គពីចម្ងាយ មានព្រះរស្មីផ្សាយចេញពីព្រះវរកាយដូចពណ៌មាស ប្រាកដក្នុងចិត្តថា អ្នកនេះជាព្រះសាស្តារបស់យើង ទើបចូលទៅថ្វាយបង្គំ ក្រាបទូលសូមជាសាវ័ក ព្រះពុទ្ធអង្គប្រទានឧប-សម្បទាដោយព្រះឱវាទ ៣ ប្រការ ត្រាស់ថា ម្នាលកស្សប អ្នកគប្បីសិក្សាយ៉ាងនេះថា :

**១. យើងនឹងចូលទៅតាំងសេចក្តីខ្មាស និង ការកោតក្រែងក្នុងពួកភិក្ខុ ទាំងជាថេរៈ មជ្ឈិមភិក្ខុ និង នវកភិក្ខុ យ៉ាងខ្លាំងក្លា ។**

**២. យើងនឹងស្តាប់ធម៌យ៉ាងណាមួយ ដែលប្រកបដោយកុសល យើងនឹងផ្ទៀងត្រចៀកស្តាប់ធម៌ និងពិចារណាសេចក្តីតាមធម៌នោះ ។**

**៣. យើងនឹងមិនលះបង់សតិដែលប្រព្រឹត្តទៅ ក្នុងកាយរបស់យើង និងពិចារណា កាយគតាសតិ ។**

ឧបសម្បទាវិធីនេះ ឈ្មោះថា **ឱវាទបដិគ្គហណូបសម្បទា** ជាឧប-សម្បទារបស់ព្រះកស្សប កាលព្រះអង្គប្រទានឧបសម្បទា ដល់ព្រះកស្សប ហើយ យាងចេញអំពីដើមពហុបុត្តកនិគ្រោធដោយមានព្រះកស្សប ជាបច្ឆាសមណៈ ។

តាមចន្លោះផ្លូវ ព្រះពុទ្ធអង្គទ្រង់ចុះទៅគង់ទៀបគល់ឈើមួយ ទើបកស្សបភិក្ខុក្រាលសង្ឃាដិសាច់ល្អរបស់ខ្លួន សម្រាប់ឱ្យព្រះពុទ្ធអង្គគង់ ព្រះសាស្តាទ្រង់ជ្រាបដោយព្រះញាណថា បារមីរបស់កស្សបដែលសន្សំមកហើយនោះ ល្មមនឹងគ្រងសំពត់ដែលព្រះអង្គទ្រង់ប្រើប្រាស់ ទើបទ្រង់អង្អែលសំពត់នោះត្រាស់ថា កស្សប ! សង្ឃាដិដែលធ្វើដោយសំពត់ចាស់ផ្ទាំងនេះរបស់អ្នកទន់ល្អ កស្សបភិក្ខុជ្រាបថា ព្រះសាស្តាមានបំណងនឹងដណ្តប់ ទើបបង្អោនថ្វាយនូវសង្ឃាដិនោះចំពោះព្រះអង្គ និងសូមប្រទានចីវរចាស់ ដែលព្រះអង្គទ្រង់ប្រើប្រាស់ ដណ្តប់ជំនួស ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា កស្សបធម្មតាចីវរចាស់ព្រោះការប្រើប្រាស់របស់ព្រះពុទ្ធទាំងឡាយ បុគ្គលអ្នកអាចក្នុងការបំពេញវត្តបដិបត្តិ ទើបសមគួរទទួល ព្រោះថា ក្នុងថ្ងៃដែលតថាគតបង្សុកូលយកសំពត់នេះ មហាប្រថពីបាន

កម្រើករហូតដល់ទឹកទ្រទ្រផែនដី ។

ក្រោយមក ទើបប្ដូរចីវរជាមួយនឹងកស្សបភិក្ខុ ក្នុងខណៈនោះ ផែនដីបានកម្រើកទៀត ដូចទទួលដឹងថា ព្រះអង្គទ្រង់ធ្វើវត្ថុដែលធ្វើបានដោយកម្រ ព្រោះថា ចីវរដែលព្រះអង្គដណ្ដប់ហើយ មិនធ្លាប់ប្រទានឱ្យដល់សាវ័កអង្គណាឡើយ ។

កស្សបភិក្ខុមិនតម្កើងខ្លួនថា យើងបានចីវររបស់ព្រះពុទ្ធមកគ្រង តែត្រឡប់គិតថា យើងគួរធ្វើយ៉ាងណាឱ្យក្រៃលែងឡើង **ទើបសមាទានធុតង្គ ១៣** ក្នុងសំណាក់ព្រះសម្ពុទ្ធ និងប្រកាន់ខ្ជាប់វត្ត ៣ ប្រការគឺ **កាន់បង្សុកូលចីវរ ១ សមាទានការត្រាច់បិណ្ឌបាតជាវត្ត ១ សមាទានការនៅព្រៃជាវត្ត ១** សូម្បីនៅក្នុងទីជិតព្រះសម្មាសម្ពុទ្ធ កស្សបភិក្ខុក៏ប្រព្រឹត្តបដិបត្តិ ដូច្នេះជាប្រក្រតី ។

ព្រះកស្សបជាសេក្ខបុគ្គលត្រឹម ៧ ថ្ងៃ ក្នុងអរុណទី ៨ បានសម្រេចអរហត្តផលព្រមដោយបដិសម្ភិទា ៤ ព្រះសម្ពុទ្ធទ្រង់សរសើរថា កស្សបជាកំពូលជាងភិក្ខុទាំងឡាយអ្នកទ្រទ្រង់ធុតង្គ ។

**នាងភទ្ទាកាបិលានី** ក្រោយពេលបែកផ្លូវគ្នាពីប្ដីហើយ ដើរទៅស្នាក់នៅក្នុងសំណាក់របស់បរិព្វាជកឈ្មោះ **តិត្ថយារាម** ជិតវត្តជេតពនដែរ អស់រយៈ ៥ ឆ្នាំ ព្រោះខណៈនោះ ព្រះសម្ពុទ្ធនៅមិនទាន់ទ្រង់អនុញ្ញាតឱ្យស្ត្រីបួស ក្រោយអំពីព្រះនាងមហាបជាបតិគោតមីឧបសម្បទាហើយ ទើបនាងចូលមកបួសក្នុងសំណាក់របស់ភិក្ខុនី បំពេញសមណធម៌ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ព្រះសម្ពុទ្ធទ្រង់លើកតម្កើង នាងភទ្ទាកាបិលានីថេរីថា ជាកំពូលជាងភិក្ខុនីទាំង

ពួង អ្នកមានបុព្វេនិវាសានុស្សតិញ្ញាណ ។

(១៧) **ព្រះបាទសុទ្ធោទនៈ** ទ្រង់ឮថា ព្រះឱរសរបស់ព្រះអង្គប្រព្រឹត្ត ទុក្ករកិរិយា ៦ ឆ្នាំ បានសម្រេចសម្មាសម្ពោធិញ្ញាណហើយ ប្រកាសធម្មចក្រដ៏ បវរ គង់នៅឯវេឡុវ័ននិវិហារ ក្នុងក្រុងរាជគ្រឹះ ទើបទ្រង់បញ្ជាឱ្យអាមាត្យព្រម ដោយបរិវារ ១០០០ នាក់ ទៅកាន់ក្រុងរាជគ្រឹះ ដើម្បីទូលនិមន្តឱ្យព្រះសាស្ដា ស្ដេចយាងមកកាន់ក្រុងកបិលពស្ដុ ដោយព្រះរាជបិតា មានព្រះបំណងនឹងជួប ។

អាមាត្យទទួលព្រះតម្រាស់របស់ព្រះរាជាហើយ ប្រញាប់ធ្វើដំណើរទៅ កាន់ក្រុងរាជគ្រឹះ ចូលទៅកាន់វត្តវេឡុវ័នក្នុងវេលាសម្ដែងធម៌ អាមាត្យស្ដាប់ ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ បានសម្រេចអរហត្តផល ព្រមដោយ បុរសជាបរិវារ ១០០០ នាក់ ទាំងដែលកំពុងឈរនោះឯង ទើបក្រាបទូលសូម បព្វជ្ជាឧបសម្បទា ព្រះអង្គទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ដល់ជនពួកនោះ ទាំងអស់គ្នា ។

ចាប់ផ្ដើមពីសម្រេចអរហត្តហើយ ភិក្ខុទាំងនោះមិនបានបញ្ជូនដំណឹងឱ្យ ព្រះរាជាទ្រង់ជ្រាប ព្រះរាជាទ្រង់បញ្ជូនអាមាត្យព្រមដោយបរិវារ ១០០០ នាក់ ដោយទំនងដូចមុន រហូតដល់ ៩ លើក ក៏មិនមានអ្នកណានាំដំណឹងត្រឡប់មក ប្រាប់វិញ លុះគ្រប់គ្នាញ៉ាំងកិច្ចរបស់ខ្លួនឱ្យសម្រេច គឺបានអរហត្តផលហើយ ក៏ ស្នាក់នៅក្នុងក្រុងរាជគ្រឹះនោះឯង ។

ក្នុងទីបំផុត ទើបព្រះរាជាបញ្ជូន **កាឡុទាយីអាមាត្យ** ដែលជាសហជាតិ

របស់ព្រះពុទ្ធអង្គ ជាអ្នកទៅទូលអារាធនាព្រះសាស្តា កាឡុទាយីទទួលព្រះ-តម្រាស់នោះហើយក្រាបទូលថា សូមឱ្យខ្ញុំព្រះអង្គបានបួសផង ព្រះបាទសុទ្ធោ-ទនៈត្រាស់ថា អ្នកនឹងបួស ឬមិនបួសក៏ដោយចុះ អ្នកត្រូវតែនាំបុត្ររបស់យើងត្រឡប់មកឱ្យបាន ។ កាលទៅដល់ក្រុងរាជគ្រឹះ កាឡុទាយីអាមាត្យព្រមទាំងបរិវារបានស្តាប់ធម្មទេសនាហើយ ក៏បានសម្រេចអរហត្តផល តាំងនៅក្នុងភាពជាឯហិភិក្ខុដូចគ្នាដែរ ។

លុះដល់ក្នុងថ្ងៃពេញបូរមីខែ ៤ ( ខែចេត្រ ) ព្រះកាឡុទាយិត្ថេរគិតថា ឥឡូវនេះ ឈានចូលកាន់វស្សានរដូវ ( រដូវស្លឹកឈើលាស់ ) ពូជធាផ្សេងៗ ច្រូតកាត់រៀបរយហើយ ស្រួលដល់ការធ្វើដំណើរ ឃើញថាជាកាលសមគួរដែលព្រះទសពលនឹងធ្វើការសង្គ្រោះព្រះញាតិហើយ ទើបព្រះកាឡុទាយិត្ថេរចូលទៅក្រាបទូលឱ្យស្តេចយាងទៅក្រុងកបិលពស្តុ រៀបរាប់ដល់ផ្លូវដែលត្រូវយាងទៅដើម្បី ត្រូវការឱ្យព្រះសាស្តាយាងចារិកទៅកាន់នគររបស់រាជត្រកូល ។

ព្រះសម្ពុទ្ធ ទ្រង់យាងព្រមដោយព្រះខីណាស្រពពីរម៉ឺនរូប គឺភិក្ខុជាកុល-បុត្រនៅដែនអង្គៈ និងមគធៈមួយម៉ឺនរូប ភិក្ខុកុលបុត្រនៅដែនកបិលពស្តុមួយម៉ឺនរូប ស្តេចចារិកទៅដោយមិនប្រញាប់ប្រញាល់ ។

ក្នុងការធ្វើដំណើរ ព្រះកាឡុទាយិត្ថេរបាននាំដំណឹង មកឱ្យព្រះរាជាទ្រង់ជ្រាបដោយឫទ្ធិ ព្រះរាជាទតឃើញព្រះថេរៈមកក៏ទ្រង់ពេញព្រះទ័យ ប្រគេនអាហារបិណ្ឌបាតដែលបានចាត់ត្រៀមទុកដើម្បីព្រះអង្គ ដល់ព្រះថេរៈ ហើយ

ត្រាស់ថា និមន្តលោកឆាន់ភត្តាហារនេះសិន សឹមនាំបិណ្ឌបាតអំពីទីនេះទៅថ្វាយដល់បុត្ររបស់យើង រហូតទាល់តែបុត្ររបស់យើងធ្វើដំណើរមកដល់ព្រះនគរ ។

ព្រះថេរៈបាននាំបិណ្ឌបាតទៅរាល់ថ្ងៃដោយឧបាយនេះ កាលជនក្នុងវាំងកំពុងឃើញនោះឯង ព្រះថេរៈបោះបាត្រដែលពេញទៅដោយភត្ត ដែលនឹងនាំទៅថ្វាយព្រះសាស្ដា ក្នុងលំហអាកាស សូម្បីខ្លួនឯងក៏ហោះឡើងកាន់វេហាស៍ ហើយបង្អោនបិណ្ឌបាតចូលទៅថ្វាយព្រះសាស្ដារៀងរាល់ថ្ងៃដូច្នេះ ព្រះសាស្ដាសោយបិណ្ឌបាតរបស់ព្រះរាជាប៉ុណ្ណោះ ក្នុងចន្លោះផ្លូវនៃការធ្វើដំណើរ ។

រាល់ថ្ងៃក្រោយធ្វើភត្តកិច្ចស្រេចហើយ ព្រះកាឡុទាយិត្ថេរបានសម្ដែងធម្មីកថា ដែលប្រកបដោយពុទ្ធគុណដល់ព្រះរាជា និងបរិស័ទ ហើយក្រាបទូលព្រះរាជាឱ្យទ្រង់ជ្រាបថា ថ្ងៃនេះព្រះសាស្ដាយាងមកអស់រយៈផ្លូវប៉ុណ្ណេះៗ ហើយព្រះថេរៈបានធ្វើរាជត្រកូលទាំងអស់ឱ្យមានសេចក្ដីជ្រះថ្លា កើតឡើងក្នុងព្រះសាស្ដាទាំងដែលមិនទាន់បានឃើញព្រះអង្គ ដោយហេតុនេះ ទើបព្រះសាស្ដាទ្រង់លើកតម្កើងព្រះថេរៈថា ជាកំពូលជាងព្រះសាវ័កទាំងឡាយ អ្នកញ៉ាំងរាជត្រកូលឱ្យជ្រះថ្លា ។ ពួកព្រះញាតិទាំងឡាយប្រជុំគ្នា ដើម្បីត្រៀមរកទីគង់នៅរបស់ព្រះសាស្ដា ឃើញថា ប្រាសាទរបស់ស្ដេចនិគ្រោធសក្យៈគួររីករាយ ទើបជួសជុលត្រៀមទទួលព្រះសាស្ដា ។

កាលព្រះសាស្ដាយាងដល់ក្រុងកបិលពស្ដុហើយ ទ្រង់គង់នៅនា **និគ្រោធារាម** របស់ស្ដេចនិគ្រោធសក្យៈ ប្រថាប់គង់លើពុទ្ធាសនៈហើយ ពួកសក្យវង្ស

វ័យចាស់គិតថា សិទ្ធត្ថជាអ្នកនៅក្មេងជាងពួកយើង ទើបបញ្ជារាជកុមារកម្លោះៗ ថា ពួកអ្នកចូរថ្វាយបង្គំ ពួកយើងនឹងអង្គុយខាងក្រោយពួកអ្នក ។ ព្រះមានព្រះភាគទ្រង់ជ្រាបអធ្យាស្រ័យរបស់ពួកសក្យៈ ទ្រង់ព្រះតម្រិះថា ពួកព្រះញាតិរមែងមិនថ្វាយបង្គំតថាគត ទើបទ្រង់ចូលចតុត្ថជ្ឈានជាបាទនៃអភិញ្ញា ទ្រង់ធ្វើបាដិហារិយ៍ទ្រង់រោយល្អងធុលីព្រះបាទ លើក្បាលនៃព្រះញាតិទាំងនោះ ។

**ព្រះបាទសុទ្ធោទនៈ** ឃើញភាពអស្ចារ្យដូច្នោះត្រាស់ថា បពិត្រព្រះមានព្រះភាគ ក្រោយពីព្រះអង្គប្រសូតិហើយ ៧ ថ្ងៃ ខណៈដែលភីលៀងនាំចូលទៅថ្វាយបង្គំកាឡទេវិលតាបស ខ្ញុំព្រះអង្គបានឃើញព្រះបាទរបស់ព្រះអង្គ ទៅប្រតិស្ឋានលើជដារបស់តាបស ទើបថ្វាយបង្គំព្រះអង្គជាលើកដំបូង តមកក្នុងថ្ងៃវប្បមង្គល ( ថ្ងៃច្រត់ព្រះនង្គ័ល ) ខ្ញុំព្រះអង្គឃើញស្រមោលដើមព្រីងដែលព្រះអង្គគង់នៅ មិនបានរេទៅតាមព្រះអាទិត្យ ទើបខ្ញុំព្រះអង្គថ្វាយបង្គំជាលើកទី ២ ឥឡូវនេះខ្ញុំព្រះអង្គបានឃើញបាដិហារិយ៍ ដែលមិនធ្លាប់ឃើញពីមុនមក ទើបថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ នេះជាការថ្វាយបង្គំលើកទី ៣ របស់ខ្ញុំព្រះអង្គ ។

កាលព្រះរាជាថ្វាយបង្គំហើយ ពួកសក្យរាជទាំងពួងបាននាំគ្នាថ្វាយបង្គំទាំងអស់គ្នា មិនមានសេសសល់សូម្បីតែ ១ អង្គ ព្រមគ្នាអង្គុយប្រជុំដោយព្រះហឫទ័យស្រុះស្រួល ។ លំដាប់នោះ **ភ្លៀងបោក្ខរពព័ស្ស** បានធ្លាក់ចុះមក ទឹកសូម្បីមួយដំណក់ក៏មិនបានធ្លាក់ចុះ លើសរីរៈរបស់អ្នកណាម្នាក់ ព្រះញាតិទាំងពួងទ្រង់ឃើញហេតុនោះហើយ កើតសេចក្តីអស្ចារ្យក្រៃលែងណាស់ ។ ព្រះមានព្រះភាគ

ត្រាស់ថា ភ្លៀងបោក្ខរព័ស្សដែលធ្លាក់ត្រង់ញាតិសមាគមរបស់យើង មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតកាលក៏បានធ្លាក់ដូចគ្នា ទើបត្រាស់ **វេស្សន្តរជាតក** ព្រះញាតិទាំងអស់ស្តាប់ធម្មទេសនានោះហើយ ថ្វាយបង្គំធ្វើប្រទក្សិណហើយចៀសចេញទៅ មិនមានអ្នកណាម្នាក់សូម្បីតែព្រះរាជា ឬមហាមាត្យដែលនឹងទូលនិមន្តឱ្យទទួលបិណ្ឌបាតឡើយ ។

(១៨) ថ្ងៃទី ២ ព្រះសម្ពុទ្ធស្តេចចូលទៅបិណ្ឌបាតក្នុងក្រុងកបិលពស្តុព្រមដោយភិក្ខុសង្ឃពួកធំ ព្រះរាជាទ្រង់ជ្រាប ទើបប្រញាប់យាងទៅឈរខាងមុខព្រះភក្ត្រព្រះសាស្តា ត្រាស់ថា បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុអ្វី ទើបព្រះអង្គធ្វើឱ្យខ្ញុំព្រះអង្គខ្មាស់គេ វង្សរបស់យើងជាវង្សក្សត្រ មិនធ្លាប់មានក្សត្រអង្គណាត្រាច់បិណ្ឌបាតដូច្នេះទេ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ពាក្យថាវង្សក្សត្រនោះជាវង្សរបស់ព្រះអង្គ ចំណែកវង្សរបស់តថាគត ដែលមានព្រះសម្ពុទ្ធទីបង្ករជាដើមនោះ ឈ្មោះថា **ពុទ្ធវង្ស** ដែលសម្រេចការចិញ្ចឹមជីវិតដោយការត្រាច់បិណ្ឌបាតប៉ុណ្ណោះ ហើយត្រាស់ព្រះគាថាថា :

**បុគ្គលមិនគួរប្រមាទ ក្នុងបិណ្ឌបាតដែលខ្លួនបានទទួល**
**គួរប្រព្រឹត្តសុចរិតធម៌ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងនៅ**
**ជាសុខ ទាំងក្នុងលោកនេះ ទាំងលោកខាងមុខ ។**

វេលាចប់ព្រះគាថា **ព្រះពុទ្ធបិតា** បានសម្រេច **សោតាបត្តិផល** ក្នុងចន្លោះផ្លូវនោះឯង តពីនោះមកទៀត ព្រះរាជាទូលអារាធនាថ្វាយភត្តាហារក្នុង

ព្រះរាជនិវេសន៍ ខាងក្រោយភត្ត ព្រះពុទ្ធអង្គទ្រង់អនុមោទនា ហើយយាងត្រឡប់ទៅនិគ្រោធារាមវិញ ។

ថ្ងៃទី ៣ យាងទៅសោយភត្តាហារក្នុងព្រះរាជនិវេសន៍ទៀត ខាងក្រោយ ភត្តព្រះអង្គត្រាស់ព្រះគាថាថា :

**បុគ្គលគួរប្រព្រឹត្តធម៌ឱ្យជាសុចរិត អ្នកប្រព្រឹត្តធម៌ជាប្រក្រតី**
**រមែងនៅជាសុខ ទាំងក្នុងលោកនេះ ទាំងលោកខាងមុខ ។**

(១៩) **ព្រះពុទ្ធបិតា** តាំងនៅក្នុង **សកទាគាមិផល ព្រះនាងមហាប-ជាបតិគោតមី** បានសម្រេច **សោតាបត្តិផល** ពួកស្រីស្នំក្រមការចូលមកគាល់ព្រះសាស្តា មានព្រះនាងយសោធរាតែម្នាក់ពោលថា ប្រសិនបើព្រះអង្គឃើញគុណរបស់ខ្ញុំម្ចាស់ ក៏នឹងស្តេចយាងមកដោយព្រះអង្គឯង ពេលនោះខ្ញុំម្ចាស់នឹងបានថ្វាយបង្គំ ។

(២០) ព្រះសាស្តាយាងទៅកាន់ប្រាសាទរបស់ព្រះនាងយសោធរា ព្រមដោយព្រះអគ្គសាវ័កទាំងពីរ ទ្រង់ឱ្យព្រះពុទ្ធបិតាទទួលបាត្រ ត្រាស់នឹងអគ្គសាវ័កទាំងពីរថា មាតារបស់រាហុលមានគុណដល់តថាគតច្រើនណាស់ ខណៈដែលព្រះនាងថ្វាយបង្គំ កុំគប្បីពោលឃាត់ កាលយាងដល់ ព្រះនាងយសោធរាថ្វាយបង្គំហើយ ប្រមៀលព្រះសិរសាចុះលើខ្នងព្រះបាទាទាំងពីរ របស់ព្រះមានព្រះភាគ ។

ព្រះរាជាត្រាស់ដល់ការគោរពស្រឡាញ់ ដែលព្រះនាងមានចំពោះព្រះអង្គថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសុណិសារបស់ខ្ញុំព្រះអង្គបានស្តាប់ដំណឹងថា

ព្រះអង្គទ្រង់ស្លៀកដណ្តប់សំពត់កាសាវៈ ព្រះនាងក៏ទ្រង់សំពត់កាសាវៈដែរ បានដឹងថាព្រះអង្គមានភត្តតែមួយពេល ក៏មានភត្តតែមួយពេលដែរ ទ្រង់ដឹងថាព្រះអង្គទ្រង់លះបង់ទីដេក ទីអង្គុយដ៏ប្រសើរ ក៏ទ្រង់ផ្ទុំចំពោះតែលើគ្រែតូចដែលចងដោយផ្ទាំងសំពត់ បពិត្រព្រះអង្គដ៏ចម្រើន ព្រះសុណិសារបស់ខ្ញុំព្រះអង្គ ប្រកបព្រមដោយគុណសម្បត្តិយ៉ាងនេះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ព្រះសុណិសាដែលព្រះអង្គរក្សាគ្រប់គ្រងឥឡូវនេះ រក្សាខ្លួនឯងបានក្នុងពេលដែលញាណចាស់ក្លាហើយនោះ មិនគួរអស្ចារ្យទេ ចំណែកក្នុងអតីតៈ រាជធីតានេះមិនមានការរក្សា ត្រាច់ទៅត្រង់ជើងភ្នំក៏រក្សាខ្លួនបាន សូម្បីញាណនៅមិនទាន់ចាស់ក្លា ដើម្បីទ្រង់បន្ទោបង់សេចក្តីសោករបស់ព្រះនាង ព្រះពុទ្ធទ្រង់ត្រាស់ **ចន្ទកិន្នរជាតក** ពោលដោយសេចក្តីស្រឡាញ់ភក្តីរបស់ព្រះនាង ចំពោះស្វាមីក្នុងអតីតកាល កាលសោយព្រះជាតិជាកិន្នរនៅក្នុងព្រៃហិមពាន្ត ទ្រង់ប្រោសព្រះនាងយសោធរាឱ្យសម្រេចសោតាបត្តិផល ។

(២១) ថ្ងៃទី ៤ ព្រះញាតិទាំងឡាយបានធ្វើមង្គល ៣ ប្រការគឺ **អាភរណមង្គល អភិសេកមង្គល អាវាហមង្គល** ដល់ស្តេចសក្យនន្ទ (ព្រះអនុជផ្សេងមាតាគ្នា) ព្រះសាស្តាទទួលនិមន្តយាងទៅក្នុងកិច្ចមង្គលនោះ ព្រមដោយភិក្ខុ ៥០០ រូប សោយភត្តាហារស្រេច ទ្រង់អនុមោទនាហើយ បានទ្រង់ប្រទានបាត្រដល់ព្រះហស្តព្រះនន្ទ ដោយមានព្រះបំណងនឹងឱ្យបួស ព្រះនាងជនបទកល្យាណីទតឃើញម្ចាស់បងនន្ទយាងទៅតាមព្រះពុទ្ធអង្គដូច្នោះ ទើបត្រាស់ថា សូមព្រះ

អយ្យបុត្រប្រញាប់ត្រឡប់មកវិញ ព្រះនន្ទមិនអាចទូលឱ្យព្រះសាស្តាទទួលបាត្រវិញដោយសេចក្តីគោរព បានយាងតាមទៅកាន់វិហារ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលនន្ទ អ្នកបួសបានឬទេ ? កាលមិនអាចបដិសេធទាំងដែលមិនបានប្រាថ្នាសោះ នន្ទកុមារក្រាបទូលថា បួសបានព្រះអង្គ ព្រះពុទ្ធអង្គទ្រង់ឱ្យព្រះនន្ទបួសហើយដោយ **ឯហិភិក្ខុឧបសម្បទា** ។

ព្រះសាស្តាមានព្រះបំណងនឹងកម្ចាត់សេចក្តីមិនត្រេកអរ ចំពោះការបួសរបស់ព្រះនន្ទ ទើបនាំទៅស្ថានសួគ៌ជាន់តាវតឹង្ស ដោយអានុភាពរបស់ព្រះអង្គសក្កទេវរាជដឹងការយាងមក ទើបមកគាល់ព្រមដោយពួកនាងអប្សរហែហមព្រះសម្ពុទ្ធត្រាស់ឱ្យព្រះនន្ទមើលនាងទេពអប្សរ អ្នកមានបាទជើងដូចសត្វព្រាបហើយត្រាស់ **កុណាលជាតក** ដើម្បីបន្ទោបង់រាគៈរបស់ព្រះនន្ទ ព្រះនន្ទធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ហើយផ្តើមចម្រើនវិបស្សនា ក្នុងវេលាតមកមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ព្រះសម្ពុទ្ធទ្រង់លើកតម្កើងព្រះនន្ទត្ថេរថា ជាកំពូលជាងភិក្ខុសាវ័ក អ្នកអាចគ្រប់គ្រងទ្វារក្នុងឥន្ទ្រីយ៍ទាំងឡាយបាន ។

(២២ ) **ព្រះនាងមហាបជាបតិគោតមី** ទ្រង់ឃើញព្រះរូបរបស់ព្រះមានព្រះភាគហើយ កើតសោមនស្សយ៉ាងក្រៃលែង ទ្រង់ព្រះតម្រិះថា បុត្ររបស់យើងនៅក្នុងវាំងអស់ ២៩ ឆ្នាំ យើងមិនធ្លាប់បានថ្វាយវត្ថុណាមួយឡើយសូម្បីត្រឹមតែចេកមួយផ្លែ ឥឡូវនេះ យើងនឹងថ្វាយចីវរនេះដល់បុត្ររបស់យើងព្រះរាជាត្រាស់បញ្ជាឱ្យត្រៀមជាស្រេច តាក់តែងផ្លូវតាំងពីក្លោងទ្វារព្រះរាជវាំង

រហូតដល់ព្រះវិហារនិគ្រោធារាម ។

កាលយាងដល់ព្រះវិហារហើយ ព្រះនាងក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មីមួយគូនេះ ខ្ញុំម្ចាស់រវៃអំបោះ និងត្បាញដោយខ្លួនឯង តាំងចិត្តឧទ្ទិសចំពោះព្រះមានព្រះភាគ សូមព្រះអង្គប្រោសទទួលសំពត់ថ្មីមួយគូនេះរបស់ខ្ញុំម្ចាស់ចុះ ព្រះមានព្រះភាគត្រាស់ថា **ម្នាលគោតមី ព្រះនាងចូរថ្វាយដល់សង្ឃចុះ** ។

ព្រះនាងបានទូលអង្វរកដល់ ៣ ដង ព្រះពុទ្ធអង្គក៏នៅតែត្រាស់ថា ម្នាលគោតមី ព្រះនាងចូរថ្វាយចំពោះសង្ឃចុះ កាលថ្វាយសង្ឃហើយ ឈ្មោះថាព្រះនាងបានបូជាចំពោះតថាគត និងសង្ឃ ព្រោះចេតនា ៣ គឺ **មុនឱ្យ ១ កំពុងឱ្យ ១ ត្រេកអរកាលឱ្យហើយ ១** សេចក្ដីប្រាថ្នារបស់ព្រះនាងនឹងរួមតែមួយ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលដ៏យូរដល់ព្រះនាង ។

ប្រការមួយទៀត ដែលទ្រង់ឱ្យថ្វាយសង្ឃ ក៏ដើម្បីប្រយោជន៍ដល់ជនជំនាន់ក្រោយ បានកើតសេចក្ដីគោរពកោតក្រែងក្នុងព្រះសង្ឃផង កាលជនជំនាន់ក្រោយគោរពកោតក្រែងក្នុងព្រះសង្ឃ ក៏នឹងទំនុកបំរុងសង្ឃដោយបច្ច័យ ៤ សង្ឃកាលមិនលំបាកដោយបច្ច័យ ៤ ក៏នឹងតាំងចិត្តសិក្សាព្រះពុទ្ធវចនៈ និងធ្វើសមណធម៌ កាលបើដូច្នោះ សាសនារបស់តថាគត នឹងតាំងនៅដល់ ៥000 ឆ្នាំ ។

(២៣) ថ្ងៃទី ៧ ព្រះនាងយសោធរា បញ្ជូនរាហុលកុមារទៅគាល់ព្រះសម្ពុទ្ធទូលសូមទ្រព្យ រាហុលកុមារបានយាងទៅតាមក្រោយបណ្ដើរ ទូលសូម

បណ្ដើរថា បពិត្រព្រះសមណៈ សូមប្រោសប្រទានទ្រព្យមតិកដល់ខ្ញុំព្រះអង្គ ពោលយ៉ាងនេះញយៗ ព្រះសាស្ដាទ្រង់ព្រះតម្រិះថា កុមារនេះប្រាថ្នាទ្រព្យជាសម្បត្តិរបស់បិតា ដែលប្រព្រឹត្តទៅក្នុងវដ្ដៈ មានតែសេចក្ដីចង្អៀតចង្អល់ តថាគតនឹងឱ្យអរិយទ្រព្យ ៧ ប្រការ ដែលតថាគតបានត្រង់ពោធិមណ្ឌលដល់កុមារនេះ តថាគតនឹងធ្វើកុមារនេះឱ្យជាម្ចាស់នៃលោកុត្តរទ្រព្យចុះ ទើបត្រាស់ឱ្យសារីបុត្របំបួសរាហុលកុមារឱ្យជាសាមណេរ ។

ព្រះសារីបុត្រទូលសួរថា ខ្ញុំព្រះអង្គនឹងឱ្យរាហុលកុមារទ្រង់ផ្នួសយ៉ាងណាព្រះអង្គ ? ព្រះមានព្រះភាគត្រាស់ថា ដំបូងគប្បីឱ្យកោរសក់ ហើយឱ្យគ្រងសំពត់ពណ៌ទឹកអម្ចត់ ដោយការដណ្ដប់ឆៀងស្មា ឱ្យថ្វាយបង្គំបាទាភិក្ខុទាំងឡាយ អង្គុយច្រហោងផ្គងអញ្ជលី ហើយឱ្យទទួលត្រៃសរណគមន៍ ។ ព្រះមោគ្គល្លានកោរព្រះកេសាហើយឱ្យសំពត់កាសាវៈ ព្រះសារីបុត្រឱ្យសរណគមន៍ ព្រះមហាកស្សបជាឱវាទាចារ្យ បព្វជ្ជា **រាហុលកុមារឱ្យជាសាមណេរអង្គដំបូងក្នុងព្រះពុទ្ធសាសនា** ខណៈដែលមានព្រះជន្មាយុត្រឹមតែ ៧ ខួប ។

ព្រះពុទ្ធបិតាទ្រង់តូចព្រះទ័យថា កាលនន្ទ និងរាហុលបួសហើយ នឹងមិនមានអ្នកបន្តវង្សត្រកូល ទើបចូលទៅក្រាបទូលសូមពរថា ព្រះអង្គមិនគប្បីបំបួសកុលបុត្រណា ដែលមាតាបិតាមិនទាន់អនុញ្ញាត ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតតាមពាក្យអង្វររបស់ព្រះពុទ្ធបិតា តពីនោះមក ទ្រង់បញ្ញត្តហាម **មិនឱ្យបំបួសកុលបុត្រដែលមិនបានអនុញ្ញាតអំពីមាតាបិតា ឬ អ្នកគ្រប់គ្រងជាមុន** និងទ្រង់

បញ្ញត្តថា **អ្នកមានអាយុមិនទាន់គ្រប់ឧបសម្បទា ឱ្យបព្វជ្ជាជាសាមណេរ** ដោយវិធីទទួល **ត្រៃសរណគមន៍** គឺឱ្យបញ្ចេញវាចាសូមដល់ព្រះរតនត្រៃ និងឱ្យសមាទានសីល ១០ ប្រការ វិធីបួសនេះហៅថា **តិសរណគមនបព្វជ្ជា** និងទ្រង់អនុញ្ញាត **ឱ្យភិក្ខុទទួលសាមណេរជាឧបដ្ឋាកបានលើសពី ១ រូប ។**

(២៤) ថ្ងៃទី ៨ ព្រះមានព្រះភាគទ្រង់សម្តែង **មហាធម្មបាលជាតក** ពោលដោយកុសលកម្មបថ ១០ ប្រការ ដែលជាហេតុមិនឱ្យស្លាប់ក្នុងវ័យក្មេង ត្រាស់ថា ៖

**ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ**
**រមែងនាំមកនូវសេចក្តីសុខ អ្នកប្រព្រឹត្តធម៌ មិនទៅកាន់ទុគ្គតិ ។**

ចប់ព្រះពុទ្ធតម្រាស់ **ព្រះពុទ្ធបិតា** តាំងនៅក្នុង **អនាគាមិផល** ។

ក្នុងមួយរយៈនេះ ព្រះបាទសុទ្ធោទនពុទ្ធបិតា ទ្រង់កោះប្រជុំសក្យត្រកូលទាំងអស់ ត្រាស់ឱ្យកុមារក្នុងមួយត្រកូលៗ ចេញបព្វជ្ជា ទើបមានខត្តិយកុមារមួយពាន់អង្គចេញបួសព្រមគ្នា ។

ខណៈដែលទ្រង់គង់នៅក្នុងនិគ្រោធារាម ព្រះសម្ពុទ្ធទ្រង់ដឹងដោយព្រះញាណថា **កិម្ពិលសក្យរាជ** នៃក្រុងកបិលពស្តុ មានឧបនិស្ស័យនឹងបានសម្រេចមគ្គផល ទើបទ្រង់និមិត្តរូបស្រីដ៏ស្អាតតាំងពីវ័យជំទង់ វ័យក្រមុំ វ័យកណ្តាល-មនុស្សរហូតដល់វ័យជរា មានការឈឺ និងស្លាប់ជាទីបំផុត ឱ្យប្រាកដដល់កិម្ពិល-សក្យៈពិចារណា **វ័យរមែងកន្លងទៅឆាប់រហ័ស រូបកាយយើងនេះក៏ដូចគ្នា**

កើតសេចក្តីស្លុតចិត្ត ក្នុងសភាពដែលបានឃើញ កើតការនឿយណាយ ប្រាថ្នានឹងចេញបួស ។

ក្នុងគ្រានោះ **អនុរុទ្ធសក្យ:** សម្រេចចិត្តនឹងចេញបួសក្នុងធម្មវិន័យ បានទៅបបួលសក្យៈអង្គដទៃៗ ឱ្យបួសផង ទើបជាហេតុឱ្យកិម្ពិលៈសម្រេចចិត្តនឹងចេញបួសភ្លាមៗ ។

(២៥) ព្រះសាស្តាគង់នៅក្នុងនិគ្រោធារាម ក្រុងកបិលពស្តុអស់ពេលពីរសប្តាហ៍ ទើបយាងត្រឡប់ទៅកាន់ក្រុងរាជគ្រឹះវិញ ដោយប្រើផ្លូវដែលស្តេចយាងចេញទៅបួស ទ្រង់ឈប់សម្រាកត្រង់ **អនុបិយអម្ពវ័ន** ក្នុងទីនោះពួកព្រះរាជ-វង្ស ៦ អង្គ គឺ **ភទ្ទិយៈ អនុរុទ្ធ អានន្ទ ភគ្គុ កិម្ពិលៈ** សក្យវង្សកបិលពស្តុ និង **ទេវទត្ត** ជាសក្យវង្សទេវទហៈ ព្រមដោយ **ឧបាលិ** នាយភូសាមាលាក្នុងរាជសំណាក់ ។ តាមមកទូលសូមបព្វជ្ជាឧបសម្បទា ទៅកាន់ព្រះតំណាក់ព្រះ-មានព្រះភាគ ព្រះអង្គទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ដល់លោកគ្រប់អង្គភិក្ខុទាំងនោះ និមន្តតាមព្រះបរមសាស្តាដល់ក្រុងរាជគ្រឹះ ។

(២៦) ខណៈដែលព្រះសម្ពុទ្ធទ្រង់គង់ក្នុងអនុបិយអម្ពវ័ន ទព្វមល្លកុមារដែលជាឱរសរបស់ស្តេចមល្លៈក្រុងកុសិនារាមួយអង្គ ទើបមានព្រះជន្ម ៧ ខួប ឃើញព្រះសាស្តា ក៏កើតសេចក្តីជ្រះថ្លា សូមអនុញ្ញាតព្រះអយ្យកាដើម្បីនឹងបួស ទើបព្រះអយ្យកានាំទៅគាល់ព្រះសាស្តា ។ ព្រះសម្ពុទ្ធទ្រង់ប្រទានភិក្ខុមួយរូបឱ្យជាបព្វជ្ជាចារ្យ ខណៈដែលកំពុងកោរជុកដំបូងតាំងនៅក្នុង **សោតាបត្តិផល**

ជុកទីពីរតាំងនៅក្នុង **សកទាគាមិផល** ជុកទី ៣ តាំងនៅក្នុង **អនាគាមិផល** លុះកោរសក់ស្រេចទព្វសាមណេរតាំងនៅក្នុង **អរហត្តផល** ព្រះសម្ពុទ្ធទ្រង់ឱ្យសាមណេរឧបសម្បទាក្នុងខណៈនោះ ហើយតាមព្រះពុទ្ធអង្គទៅក្រុងរាជគ្រឹះ ។

(២៧) យាងដល់ក្រុងរាជគ្រឹះ គង់នៅក្នុងព្រៃសីតវ័ន ក្នុងទីនោះ **អនាថបិណ្ឌិកគហបតី** អ្នកក្រុងសាវត្ថី ធ្វើដំណើរមកកាន់ក្រុងរាជគ្រឹះដោយធុរៈខ្លះ ជ្រាបដំណឹងថា ខណៈនេះព្រះសាស្ដាឧប្បត្តិឡើងហើយ កើតបីតិយ៉ាងក្រៃលែង ទើបចេញទៅគាល់ព្រះពុទ្ធអង្គ ទៅកាន់ទីគង់នៅតាំងពីអរុណមិនទាន់រះ ព្រះសាស្ដាទ្រង់សម្ដែងធម្មទេសនាប្រោស អនាថបិណ្ឌិកគហបតីបានសម្រេចសោតាបត្តិផល ក្រាបទូលអារាធនាព្រះសម្ពុទ្ធ ឱ្យទ្រង់ទទួលភត្តាហារក្នុងថ្ងៃស្អែកឡើងបន្ទាប់មក ក្រាបទូលសូមឱ្យព្រះសាស្ដា យាងទៅប្រោសពួកជនទាំងឡាយនៅក្រុងសាវត្ថី ដោយខ្លួននឹងមានបំណងកសាងអារាមថ្វាយផង ។

---

**សេចក្ដីស្រឡាញ់ រមែងមាន ដល់បុគ្គលដែលច្រឡូកច្រឡំ ទុក្ខដែលជាប់តាម ចំពោះសេចក្ដីស្រឡាញ់នេះ ក៏រមែងកើតឡើង បុគ្គលឃើញទោស ដែលកើតអំពីសេចក្ដីស្រឡាញ់ហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។** (សុត្តន្តបិកដ ខុទ្ទកនិកាយ សុត្តនិបាត ភាគ ៥៤ ទំព័រ ១៣)

# ព្រះវស្សាទី ២

## ទ្រង់គង់ចាំព្រះវស្សា ក្នុងវត្តវេឡុវ័ន ក្រុងរាជគ្រឹះ

(១) **ព្រះភទ្ទិយៈ** ឧបសម្បទាហើយ ស្តាប់ព្រះធម្មទេសនាអំពីព្រះមានព្រះភាគ បានសម្រេចវិជ្ជា ៣ ជាអ្នកមិនប្រមាទបំពេញព្យាយាម សមាទានប្រព្រឹត្តធុតង្គ ១៣ បដិបត្តិវិបស្សនាមិនយូរប៉ុន្មាន ក៏សម្រេចព្រះអរហត្តផលព្រមដោយអភិញ្ញា ៦ ក្នុងវស្សានេះ ។

ខណៈដែលព្រះភទ្ទិយៈនៅក្នុងព្រៃក្តី ក្បែរគល់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានថា សុខហ្ន៎ ! សុខហ្ន៎ ! ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះដល់ព្រះមានព្រះភាគ ដោយគិតថា ព្រះភទ្ទិយៈ ទំនងជាមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយធម៌ នៅរឭកដល់សេចក្តីសុខក្នុងរាជសម្បត្តិ ទើបបានបន្លឺឧទានដូច្នេះជានិច្ច ព្រះសម្ពុទ្ធមានតម្រាស់ឱ្យហៅព្រះថេរៈមក ត្រាស់សួរថា អ្នកឃើញប្រយោជន៍អ្វី ក្នុងការបន្លឺវាចាដូច្នេះ ? ព្រះភទ្ទិយៈទូលថា ខ្ញុំព្រះអង្គកាលពិចារណាឃើញហេតុ គឺសុខដែលកើតអំពីវិវេក និងសុខដែលកើតពីផលសមាបត្តិដ៏កំពូលនេះ ទើបបន្លឺឧទានថា សុខហ្ន៎ ! សុខហ្ន៎ ! ដូច្នេះ ព្រះអង្គ !

(២) **ព្រះកិម្ពិលៈ** ចម្រើនវិបស្សនាកម្មដ្ឋាន បានសម្រេចព្រះអរហត្តព្រមដោយវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ អភិញ្ញា ៦ ក្នុងព្រះវស្សានេះ ។

(៣) **ព្រះទេវទត្ត** ចម្រើនឈាន ៤ បានលោកិយអភិញ្ញា ។

(៤) **ព្រះអនុរុទ្ធ** ឧបសម្បទាហើយ រៀនកម្មដ្ឋានអំពីព្រះសារីបុត្រ

សម្រេចទិព្វចក្ខុញ្ញាណ តមក គេចទៅបំពេញព្យាយាមឯបាចីនវង្សមិគទាយវ័ន ដែនចេតិយ៍ ។

(៥) **ព្រះភគ្គុ** ឧបសម្បទាហើយ ចេញទៅបំពេញព្យាយាមនៅ **ពាលកលោណការាម** ជិតក្រុងកោសម្ពីតែម្នាក់ឯង គ្រាមួយត្រូវថិនមិទ្ធគ្របសង្កត់ ទើបចេញទៅដើរចង្ក្រម បានដួលចុះក្នុងទីចង្ក្រមនោះ ព្យាយាមក្រោកឡើងដើរចង្ក្រមបន្ត ព្រមទាំងពិចារណាសង្ខារ ឃើញទោសនៃការមិនទៀង កើតការនឿយណាយ ចិត្តក៏រួចផុតចាកអាសវកិលេស បានសម្រេចជាព្រះអរហន្ត ក្នុងទីចង្ក្រមនោះឯង ។

(៦) **ព្រះឧបាលិ** កាលឧបសម្បទាហើយ ទូលសូមអនុញ្ញាតទៅបំពេញព្យាយាមក្នុងព្រៃ ព្រះសម្ពុទ្ធទ្រង់ឃើញឧបនិស្ស័យរបស់ព្រះឧបាលិថា តទៅនឹងជាអ្នកជំនាញក្នុងព្រះវិន័យ បើឧបាលិទៅចម្រើនសមណធម៌ក្នុងព្រៃ ក៏នឹងសម្រេចតែផ្នែកវិបស្សនាធុរៈតែម្យ៉ាង ប្រសិនបើលោកនៅក្នុងសំណាក់តថាគតនោះ នឹងសម្រេចទាំងគន្ថធុរៈ ទាំងវិបស្សនាធុរៈ ទើបត្រាស់ថា អ្នកចូរចម្រើនសមណធម៌នៅក្នុងទីនេះចុះ ។

ព្រះសម្ពុទ្ធទ្រង់បង្រៀនព្រះវិន័យបិដកដល់ព្រះឧបាលិ ដោយព្រះអង្គឯង ព្រះឧបាលិ សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ក្នុងវស្សានេះ តមកខាងក្រោយ លោកបានវិនិច្ឆ័យរឿង ៣ រឿង គឺរឿងភារុកច្ឆកៈ ១ រឿងអជុកៈ ១ និងរឿងព្រះកុមារកស្សប ១ កាលវិនិច្ឆ័យ

សម្រេចមួយរឿងៗ ព្រះសាស្ដាបានទ្រង់ប្រទានសាធុការ ទ្រង់លើកតម្កើងព្រះថេរៈថា ជាកំពូលជាងវិន័យធរទាំងឡាយ ក្នុងវេលាសម្ដែងបាតិមោក្ខ ព្រះឧបាលិត្ថេរឱ្យឱវាទដល់ភិក្ខុទាំងឡាយថា ៖

**ភិក្ខុអ្នកចេញបួសថ្មីៗ ដោយសទ្ធា នៅថ្មីចំពោះការសិក្សា គួរគប់រកកល្យាណមិត្ត ស្នាក់នៅក្នុងពួកសង្ឃជាអ្នកឈ្លាស សិក្សាព្រះវិន័យឱ្យយល់ ជាអ្នកឈ្លាសក្នុងវត្ថុដែលគួរ និងមិនគួរ ទាំងមិនគួរប្រព្រឹត្តខ្លួនឱ្យជាអ្នកមានមុខមាត់ ។**

## ក្រោយអំពីចេញព្រះវស្សាទី ២ ហើយ

( ៧ ) ភិក្ខុ ៥០០ រូបជាសិស្សរបស់ព្រះបុណ្ណមន្តានីបុត្រ ធ្វើដំណើរមកដល់ក្រុងរាជគ្រឹះ ចូលគាល់ថ្វាយបង្គំព្រះសម្ពុទ្ធក្នុងវត្តវេឡុវ័ន ព្រះពុទ្ធអង្គទ្រង់ធ្វើបដិសណ្ឋារៈចំពោះអាគន្តុកភិក្ខុ ហើយត្រាស់សួរថា ភិក្ខុរូបណាហ្ន៎ ដែលពួកភិក្ខុមិត្តសព្រហ្មចារីជាតិភូមិលើកតម្កើងថា ខ្លួនឯងជាអ្នកប្រាថ្នាតិច សន្ដោសស្ងប់ស្ងាត់ មិនច្រឡូកច្រឡំដោយពួកគណៈ ប្រារព្ធសេចក្ដីព្យាយាម បរិបូរណ៍ដោយសីល បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈ ថែមទាំងសម្ដែងសេចក្ដីប្រាថ្នាតិចជាដើមនោះដល់ភិក្ខុទាំងឡាយទៀតផង ជាអ្នកទូន្មាន ណែនាំឱ្យយល់ បបួលភិក្ខុមិត្តសព្រហ្មចារី ឱ្យឃើញច្បាស់ ឱ្យសមាទាន ឱ្យអាចហ៊ាន ឱ្យរីករាយ ។

ភិក្ខុទាំងនោះទូលតបថា ពួកខ្ញុំព្រះអង្គ ធ្វើដំណើរមកអំពីក្រុងកបិលពស្តុ ភិក្ខុដូចពោលមកនោះ ឈ្មោះបុណ្ណមន្តានីបុត្រ ជាឧបជ្ឈាយ៍របស់ពួកខ្ញុំ-

ព្រះអង្គ ឱ្យពួកខ្ញុំព្រះអង្គដើរមកគាល់ព្រះអង្គមុន ចំណែកលោកខ្លួនឯងនឹងជាប់តាមមកចូលគាល់ជាខាងក្រោយ ។

(៨) ក្នុងសម័យនោះឯង ក្រុងវេសាលីកើតការរាំងស្ងួត សន្ទូងងាប់ព្រោះត្រូវកំដៅថ្ងៃ មនុស្សអត់ឃ្លានស្លាប់បាត់បង់ជីវិត សាកសពដេរដាសទូទាំងព្រះនគរ អមនុស្សបានធុំក្លិនសាកសព ក៏នាំគ្នាចូលមកក្នុងព្រះនគរ មនុស្សស្លាប់កាន់តែកើនឡើងព្រោះក្លិនបដិកូលនោះ អាសន្នរោគក៏កើតឡើងដល់សត្វទាំងឡាយ **អ្នកដែនវេសាលីត្រូវភ័យ ៣ ប្រការគឺ :**
**ទុព្ភិក្ខភ័យ ១ អមនុស្សភ័យ ១ និងព្យាធិភ័យ ១** បៀតបៀន ពួកស្តេចលិច្ឆវីប្រជុំប្រឹក្សាគ្នាថា បានឮមកថា ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងហើយក្នុងលោក ព្រះ-មានព្រះភាគអង្គនោះទ្រង់សម្តែងធម៌ ដើម្បីប្រយោជន៍អនុគ្រោះដល់សត្វទាំងពួង ទ្រង់មានអានុភាពច្រើន ប្រសិនបើព្រះអង្គយាងមកប្រោស ភ័យគ្រប់យ៉ាងក៏នឹងស្ងប់រម្ងាប់ទៅ ទើបទ្រង់បញ្ជូនស្តេចលិច្ឆវីឈ្មោះ **មហាលិ** ដែលព្រះបាទពិម្ពិសារទ្រង់ប្រោសប្រាណ និងអាមាត្យម្នាក់ធ្វើដំណើរទៅ ដើម្បីអង្វរករព្រះ-បាទពិម្ពិសារឱ្យទូលអារាធនា ព្រះសម្ពុទ្ធឱ្យទ្រង់យាងទៅកាន់ក្រុងវេសាលី ។

ព្រះសាស្តាទ្រង់ពិចារណាថា បើសម្តែង **រតនសូត្រ** ក្នុងក្រុងវេសាលីនឹងធ្វើឱ្យភ័យស្ងប់បាន ថែមទាំងមហាជនដែនវជ្ជីកាលបានស្តាប់ព្រះសូត្រនេះហើយ នឹងបានសម្រេចមគ្គផលច្រើន ទើបទ្រង់ទទួលពាក្យទូលអារាធនារបស់ពួកស្តេចលិច្ឆវី ។

ព្រះបាទពិម្ពិសារទ្រង់ព្រួថា ព្រះពុទ្ធអង្គទ្រង់ទទួលពាក្យអារាធនាហើយ បានត្រៀមផ្លូវសម្រាប់យាងឱ្យរៀបរយ ទ្រង់បញ្ជូនព្រះសម្មុទ្ធព្រមដោយភិក្ខុ ៥០០ រូប យាងទៅតាមផ្លូវឆ្លងស្ទឹងគង្គា ព្រះរាជាបញ្ជាឱ្យរោយផ្កាឈើលើកទង់ជ័យ និងស្វែតច្ឆត្រ ២ ជាន់ដើម្បីព្រះមានព្រះភាគរហូតអស់ផ្លូវ ប្រើពេលធ្វើដំណើរ ៥ ថ្ងៃ ទើបដល់ក្រុងវេសាលី ពួកស្ដេចលិច្ឆវីចេញមកទទួលព្រះមានព្រះភាគតាំងពីក្នុងស្ទឹង ខណៈនោះឯង មហាមេឃក៏តាំងឡើងទាំង ៤ ទិស គ្រាន់តែព្រះមានព្រះភាគ ឈានព្រះបាទដំបូងចុះមាត់ច្រាំងស្ទឹងគង្គា ភ្លៀងក៏ធ្លាក់ចុះមកយ៉ាងខ្លាំងក្នុងទីគ្រប់កន្លែង ទឹកហូរទៅត្រឹមជង្គង់ ភ្លៅ ចង្កេះ សាកសពទាំងពួងត្រូវទឹកផាត់នាំចុះកាន់ស្ទឹងគង្គាអស់ ផ្ទៃដីក៏ស្អាត ។

ព្រះពុទ្ធអង្គទ្រង់ប្រថាប់ឈរជិតទ្វារព្រះនគរ ទ្រង់ត្រាស់ឱ្យព្រះអានន្ទស្វាធ្យាយ **រតនសូត្រ** ពោលសច្ចវាចាដែលអាស្រ័យគុណរបស់ព្រះរតនត្រ័យ ដើម្បីកម្ចាត់ឧបទ្រវៈទាំងនោះត្រង់ទ្វារនគរ ហើយប្រោះព្រំទឹកព្រះពុទ្ធមន្តទូទៅទាំងព្រះនគរ ព្រមដោយស្ដេចលិច្ឆវី ។

កាលព្រះអានន្ទពោល **យំ កិញ្ចិ** ពួកអមនុស្សម្នាក់ៗ នាំគ្នាគេចចេញពីព្រះនគរទៅ ឧបទ្រវភ័យគ្រប់យ៉ាងក៏ស្ងប់អស់ មហាជននាំគ្នាចេញមកបូជាព្រះ-មានព្រះភាគដោយគ្រឿងក្រអូប និងដោយផ្កាឈើជាដើម ហើយនាំព្រះអង្គចូលទៅកាន់សាលា ត្រង់កណ្ដាលព្រះនគរព្រមដោយព្រះភិក្ខុសង្ឃ និងព្រះរាជាសូម្បីស្ដេចសក្កទេវរាជក៏ប្រថាប់គង់ជិត ទេវបរិស័ទក្នុងទេវលោកទាំងពីរ ។

ព្រះសម្ពុទ្ធបានត្រាស់ **រតនសូត្រ** នោះដល់ទេវតា និងមនុស្សទាំងឡាយ រហូតអស់ ៧ ថ្ងៃទៀត ក្នុងទីបំផុតនៃព្រះធម្មទេសនា សិរីសួស្តីបានកើតមានដល់រាជត្រកូល និងមហាជន ឧបទ្រវៈទាំងពួងស្ងប់រម្ងាប់អស់ ការត្រាស់ដឹងធម៌កើតមានដល់សត្វទាំងឡាយជាច្រើន ។

គ្រានោះ ព្រះឥន្ទ្រទ្រង់ត្រិះរិះថា ព្រះមានព្រះភាគទ្រង់អាស្រ័យគុណព្រះរតនត្រៃធ្វើសច្ចវាចា ឱ្យកើតសិរីសួស្តីដល់អ្នកនគរហើយ សូម្បីយើងក៏គប្បីអាស្រ័យគុណព្រះរតនត្រ័យ ពោលដើម្បីសិរីសួស្តីដល់អ្នកនគរដែរ ទើបត្រាស់ ៣ គាថាចុងបំផុតថា **យានីធ ភូតានិ សមាគតានិ** ជាដើម ។ (ហៅយានីតូច)

(៩) តពីនោះមក ព្រះសម្ពុទ្ធយាងត្រឡប់មកក្រុងរាជគ្រឹះវិញ ពួកស្តេចលិច្ឆវីទាំងឡាយយាងជូនដំណើរមករហូតដល់មាត់ច្រាំងស្ទឹងគង្គា ដោយគ្រឿងសក្ការសមានៈ (ការរាប់អាន) ដ៏ធំ បណ្តា **នាគរាជ** ទាំងឡាយក្នុងស្ទឹងគង្គាគិតថា ពួកមនុស្សធ្វើសក្ការៈព្រះពុទ្ធអង្គ ពួកយើងនឹងមិនធ្វើអ្វីខ្លះឬ ? ម្នាក់ៗ នាំគ្នាមកគាល់អង្វរករថា សូមព្រះពុទ្ធអង្គទ្រង់ប្រោសអនុគ្រោះដល់ ពួកខ្ញុំព្រះអង្គទាំងឡាយផងចុះ ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្ត ទើបពួកនាគរាជនាំព្រះសម្ពុទ្ធព្រមដោយភិក្ខុសង្ឃទៅកាន់ពិភពនាគ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់នាគបរិស័ទពេញមួយរាត្រី ក្នុងថ្ងៃទីពីរ នាគរាជទាំងឡាយនាំគ្នាថ្វាយមហាសក្ការៈ និងថ្វាយមហាទាន ដោយខាទនីយភោជនីយាហារដែលជាទិព្វ ព្រះពុទ្ធអង្គទ្រង់អនុមោទនា ហើយយាងចេញពីពិភពនាគ ពួកភុម្មដ្ឋទេវតា និងទេវតាទាំងឡាយ

រហូតដល់អកនិដ្ឋព្រហ្ម ក៏បានធ្វើមហាសក្ការៈដោយន័យនេះដូចគ្នា ។

ក្នុងកាលដែលព្រះមានព្រះភាគយាងមកវិញ ព្រះបាទពិម្ពិសារ បាននាំព្រះអង្គ ត្រឡប់ទៅកាន់ក្រុងរាជគ្រឹះ ទ្រង់គង់ក្នុងវេឡុវ័នវិហារ ព្រះសាស្តាទ្រង់ដឹងដល់ការដែលភិក្ខុទាំងឡាយ មានសេចក្តីរីករាយក្នុងអានុភាពរបស់ព្រះអង្គ ទ្រង់ត្រាស់ថា ការបូជាយ៉ាងពិសេសនេះ មិនបានកើតឡើងដោយពុទ្ធានុភាពរបស់តថាគតទេ តាមពិត ជាអានុភាពនៃការបូជា ដែលមានប្រមាណតិចតួចរបស់តថាគតក្នុងអតីតៈ ទើបភិក្ខុទាំងនោះទូលសូមព្រះវរោកាសឱ្យត្រាស់ហេតុនោះ ព្រះអង្គទ្រង់ត្រាស់អតីតនិទានថា :

ជនទាំងឡាយបានធ្វើផ្លូវឱ្យរាបស្មើ រហូតចម្ងាយផ្លូវដែលទ្រង់យាងនោះ ដោយផលនៃកម្ម ដែលតថាគតបានដកស្មៅ នូវលានព្រះចេតីយ៍របស់ព្រះ-បច្ចេកពុទ្ធជាម្ចាស់ ។ ជនទាំងឡាយបានបូជាតថាគត ដោយក្រាលផ្កាឈើច្រើនប្រភេទទាំងលើគោក ទាំងក្នុងទឹក ដោយផលនៃកម្មដែលតថាគតបានបូជាព្រះ-ចេតីយ៍ របស់ព្រះបច្ចេកពុទ្ធដោយផ្កាឈើព្រៃ ។ ភ្លៀងដែលធ្លាក់ចុះក្នុងក្រុងវេសាលីនោះ ដោយផលនៃកម្មដែលតថាគតប្រស់ព្រំទឹកត្រង់លានព្រះចេតីយ៍ ។

មនុស្ស និងទេវតាទាំងឡាយបានលើកទង់បដា និងលើកស្វេតច្ឆត្រតម្រួតគ្នាឡើងរហូតដល់អកនិដ្ឋភព ជាផលដែលតថាគតបានលើកទង់ និងចងឆ័ត្រ បូជាចំពោះព្រះចេតីយ៍របស់ព្រះបច្ចេកពុទ្ធជាម្ចាស់នោះ ការបូជាដ៏លើស-លប់ចំពោះតថាគតពេលនេះ មិនមែនកើតដោយអានុភាពនៃនាគ ទេវតា ឬ

ព្រហ្ម តែកើតឡើងអំពីកុសលកម្មដែលតថាគតបានធ្វើទុកហើយ ក្នុងអតីតៈនោះឯង ។

( ១០ ) តអំពីនោះ ព្រះសាស្តាយាងទៅកាន់ក្រុងសាវត្ថី ដើម្បីទទួលការថ្វាយវត្តជេតពន តាមពាក្យទូលអារាធនារបស់អនាថបិណ្ឌិកសេដ្ឋី ។

( មានការសន្និដ្ឋានថា ការយាងទៅកាន់ក្រុងសាវត្ថីគ្រានេះ ដើម្បីទៅទទួលការថ្វាយព្រះជេតវនវិហាររបស់អនាថបិណ្ឌិកសេដ្ឋី តែកាលទទួលហើយ ការកសាងគង់នឹងនៅមិនទាន់សម្រេចរៀបរយ លុះជិតចូលព្រះវស្សា ទើបត្រូវយាងត្រឡប់មកក្រុងរាជគ្រឹះវិញ ដើម្បីឱ្យទាន់វេលាចាំវស្សាទី ៣ សេចក្តីលំអិតរឿង អនាថបិណ្ឌិកមហាឧបាសក នៅក្នុងចន្លោះដើមវស្សាទី ២១-៤៥ ) ។

( ១១ ) **ព្រះបុណ្ណមន្តានីបុត្រ** ជ្រាបថាព្រះមានព្រះភាគយាងដល់ក្រុងសាវត្ថី គង់នៅក្នុងវិហារជេតវន ទើបធ្វើដំណើរអំពីក្រុងកបិលពស្តុ មកចូលគាល់ព្រះអង្គនៅក្នុងព្រះគន្ធកុដិ ព្រះមានព្រះភាគទ្រង់មានបដិសណ្ឋារៈ និងទ្រង់សម្តែងធម្មកថាឈ្មោះ **អនន្តន័យ** ដែលអាស្រ័យកថាវត្ថុ ១០ ថា ម្នាលបុណ្ណៈ សូម្បីកថានេះក៏ឈ្មោះថា **អប្បិច្ឆកថា** និង **សន្តុដ្ឋិកថា** ដូចគ្នា ព្រះថេរៈស្តាប់ធម៌ហើយទូលលាព្រះសាស្តា ចូលទៅសម្រាកពេលថ្ងៃក្បែរគល់ឈើមួយ ក្នុងអន្ធវ័ន ព្រោះក្នុងវេលាក្រោយអាហារ ព្រះជេតវនវិហារនឹងអ៊ូអរដោយមហាជនដែលចូលមក ចំណែកអន្ធវ័នស្ងប់ស្ងាត់គួរដល់ការបំពេញព្យាយាម ។

ក្រោយអំពីព្រះបុណ្ណមន្តានីបុត្រ ចូលទៅសម្រាកនៅក្នុងអន្ធវ័នហើយ

ភិក្ខុមួយរូបចូលទៅរកព្រះសារីបុត្រ ប្រាប់ថា ឥឡូវនេះព្រះមន្តានីបុត្រ ចេញពីព្រះគន្ធកុដិទៅកាន់អន្ធវ័នហើយ ទើបព្រះសារីបុត្រប្រញាប់ជាប់តាមទៅ ដោយបំណងនឹងសន្ទនាធម៌ប្រការខ្លះ ឃើញព្រះបុណ្ណមន្តានីបុត្រ កំពុងសម្រាកនៅទៀបគល់ឈើមួយដើម ទើបព្រះសារីបុត្រគង់សម្រាកទៀបគល់ឈើមួយដើមទៀត មិនឆ្ងាយណាស់ណាទេ ។

ក្នុងវេលារសៀលចេញអំពីសម្រាកហើយ ព្រះសារីបុត្របានចូលទៅរកព្រះថេរៈ ម្នាក់ៗប្រាស្រ័យណែនាំខ្លួនហើយ ព្រះសារីបុត្របានសួរបញ្ហាពោលដោយការប្រព្រឹត្តិព្រហ្មចរិយៈ សួរដល់លំដាប់ **វិសុទ្ធិ ៧** ថា លោកដ៏មានអាយុលោកប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីសីលវិសុទ្ធិឬ ព្រះថេរៈបានវិសជ្ជនាបញ្ហាដែលសួរហើយដោយលំដាប់ថា:

**សីលវិសុទ្ធិ** ជាប្រយោជន៍ដល់ **ចិត្តវិសុទ្ធិ**

**ចិត្តវិសុទ្ធិ** ជាប្រយោជន៍ដល់ **ទិដ្ឋិវិសុទ្ធិ**

**ទិដ្ឋិវិសុទ្ធិ** ជាប្រយោជន៍ដល់ **កង្ខាវិតរណវិសុទ្ធិ**

**កង្ខាវិតរណវិសុទ្ធិ** ជាប្រយោជន៍ដល់ **ញាណទស្សនវិសុទ្ធិ**

**ញាណទស្សនវិសុទ្ធិ** ជាប្រយោជន៍ដល់ **អនុបាទាបរិនិព្វាន**

ដែលមានចំណុចឧបមាដោយរថ ៧ រថ ដូចសម្តែងទុកក្នុង រថវិនីតសូត្រថា ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគដើម្បីអនុបាទាបរិនិព្វាន ព្រះថេរៈទាំងពីរសួរ និងឆ្លើយដោយបញ្ហាក្នុងរឿងដែលទាក់ទងជាមួយនឹងកថា

វត្ថុ ១០ ប្រការប៉ុណ្ណោះ ។

ព្រះសារីបុត្រពោលថា ជាលាភដ៏ល្អរបស់ខ្ញុំ និងសព្រហ្មចារីទាំងឡាយ ដែលបានប្រសព្វ បានអង្គុយជិតព្រះបុណ្ណមន្តានីបុត្រ ចំណែកព្រះបុណ្ណថេរៈពោលថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំកំពុងនិយាយជាមួយនឹងលោកម្ចាស់ ដែលជាអគ្គ-សាវ័ក ដែលទ្រទ្រង់គុណដូចព្រះសាស្តា ធម៌ដែលលោកម្ចាស់ជ្រើសរើសមកសួរ ដោយបញ្ហាដ៏ជ្រាលជ្រៅ ជាដំណើរព្រះសាវ័ក អ្នកយល់ដឹងទូទៅដល់ពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាដោយពិតប្រាកដនឹងគប្បីសួរ ជាលាភរបស់មិត្ត-សព្រហ្មចារីដោយពិត ព្រះថេរៈទាំងពីរម្នាក់ៗ រីករាយចំពោះភាសិតរបស់គ្នានិងគ្នា ។

ព្រះសាស្តាទ្រង់សរសើរថា ព្រះបុណ្ណមន្តានីបុត្តត្ថេរ ជាកំពូលជាងភិក្ខុទាំងឡាយ ក្នុងការសម្តែងធម៌ មិនប្រាកដពិតថាព្រះបុណ្ណមន្តានីបុត្តត្ថេរបរិនិព្វានពេលណា និងកន្លែងណាទេ ព្រោះស្រាវជ្រាវមើលមិនឃើញ ។

( ១២ ) **ព្រះអានន្ទ** បានទទួលស្តាប់កថាវត្ថុ ១០ អំពីការសម្តែងនៃព្រះបុណ្ណមន្តានីបុត្តត្ថេរបានសម្រេច **សោតាបត្តិផល** ក្នុងវស្សានេះ ។

# ព្រះវស្សាទី ៣

## គង់គង់ចាំព្រះវស្សា ក្នុងវត្តវេឡុវ័ន ក្រុងរាជគ្រឹះ

(១) **រាជគហសេដ្ឋី** ប្រាថ្នានឹងសាងសេនាសនៈថ្វាយភិក្ខុសង្ឃទាំងក្នុងគ្រានោះ ព្រះមានព្រះភាគនៅមិនទាន់បញ្ញត្ត សេនាសនៈដល់ភិក្ខុទាំងឡាយ ពួកភិក្ខុនាំគ្នាទៅស្នាក់នៅទៀបគល់ឈើខ្លះ ភ្នំខ្លះ ញកភ្នំខ្លះ ល្អាងខ្លះ ព្រៃខ្មោចខ្លះ គំនរចំបើងខ្លះ សេដ្ឋីក្រុងរាជគ្រឹះទៅព្រៃអម្ពវ័នតាំងពីព្រឹក ឃើញភិក្ខុទាំងនោះដើរចេញអំពីទីនោះៗ បរិបូរណ៍ដោយឥរិយាបថ មានសេចក្តីជ្រះថ្លាទើបចូលទៅទូលភិក្ខុទាំនោះ ឱ្យទូលសួរព្រះមានព្រះភាគ ដើម្បីសូមអនុញ្ញាតកសាងសេនាសនៈថ្វាយ ។

ព្រះមានព្រះភាគទ្រង់អនុញ្ញាតសេនាសនៈ ៥ ប្រភេទ គឺ: **វិហារ ១ កុដិប្រ៉ក់ថេវ ១ កុដិច្រើនជាន់ ១ កុដិត្រងោល ១ និងល្អាងដែលសាងឡើង ១** ដើម្បីឱ្យភិក្ខុមានទីកន្លែងមាំទាំ ព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ រាជគហសេដ្ឋីបានកសាងវិហារ ៦០ ខ្នង ត្រឹមតែមួយថ្ងៃប៉ុណ្ណោះ កាលកសាងស្រេច រាជគហសេដ្ឋីចូលទៅគាល់ក្រាបទូលអារាធនាព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ ឱ្យទ្រង់ទទួលភត្តាហារក្នុងថ្ងៃស្អែកឡើង ។

លុះព្រឹកឡើង ក្រោយភត្តកិច្ច រាជគហសេដ្ឋីក្រាបទូលព្រះអង្គថា ខ្ញុំព្រះអង្គត្រូវការបុណ្យ ត្រូវការស្ថានសួគ៌ បានកសាងវិហារ ៦០ ខ្នងនេះទុកហើយ ខ្ញុំព្រះអង្គនឹងគប្បីបដិបត្តិដូចម្តេច ក្នុងវិហារទាំងនោះ ព្រះអង្គ? ព្រះសាស្តា-

ត្រាស់ថា ម្នាលគហបតី អ្នកចូរថ្វាយវិហារទាំងនោះដល់សង្ឃ ដែលមកអំពីទិស ទាំងបួន ទាំងដែលមកហើយ ទាំងដែលមិនទាន់មក ព្រះសាស្ដាទ្រង់អនុមោទនា សេនាសនៈរបស់រាជគហសេដ្ឋីដោយគាថាថា :

**ការថ្វាយវិហារដល់សង្ឃដើម្បីការសម្ងំនៅ ដើម្បីចម្រើនវិបស្សនា ព្រះពុទ្ធទាំងឡាយ សរសើរការថ្វាយសេនាសនទានដល់សង្ឃ ថាជាទាន ដ៏កំពូល ។**

ព្រោះហេតុដូច្នោះ បុគ្គលដែលឈ្លាសកាលពិចារណាឃើញប្រយោជន៍ ខ្លួន គប្បីកសាងវិហារជាទីរីករាយ ឱ្យភិក្ខុទាំងឡាយអ្នកដែលជាពហុសូតនៅ ក្នុងបរិវេណនេះចុះ ម្យ៉ាងទៀត គប្បីមានចិត្តជ្រះថ្លាថ្វាយបាយ ទឹក សំពត់ និង សេនាសនៈដ៏សមគួរដល់ពួកលោក ព្រោះពួកលោករមែងសម្ដែងធម៌ ដែលជា គ្រឿងលះបង់នូវទុក្ខដល់ជនទាំងឡាយ ជនទាំងនោះបានដឹងធម៌ហើយ នឹងផុត ចាកអាសវៈ បរិនិព្វានក្នុងលោកនេះ ។

ក្រៅពីនោះ ទ្រង់អនុញ្ញាត **សង្ឃភត្ត ឧទ្ទេសភត្ត និមន្តនភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត បាដិបទិកភត្ត** និងទ្រង់អនុញ្ញាតភេសជ្ជៈ ៥ ប្រភេទ គឺ **ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ** ដើម្បីឱ្យភិក្ខុ ទាំងឡាយ បានភេសជ្ជៈច្រើនប្រភេទ ក្នុងគ្រាមានអាពាធ ។

(២) ថ្ងៃមួយ ព្រះមានព្រះភាគចេញពីទីសម្រាកពេលថ្ងៃ ហើយបាន យាងទៅកាន់ **អម្ពលដ្ឋិកា** ដែលនៅចន្លោះក្រុងរាជគ្រឹះនឹងនាលន្ទា ដែលជាទីគង់

នៅរបស់រាហុលសាមណេរ រាហុលឃើញព្រះមានព្រះភាគយាងមកពីចម្ងាយ ទើបក្រាលអាសនៈ និងតាំងទឹកលាងព្រះបាទទុក លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់លាងព្រះបាទហើយ **បន្សល់ទឹកទុកក្នុងភាជនៈបន្តិច** ត្រាស់ជាមួយនឹង សាមណេរថា ម្នាលរាហុល អ្នកឃើញទឹកដែលនៅសល់ក្នុងភាជនៈនេះឬទេ ? សាមណេរក្រាបទូលថា ឃើញនៅសល់បន្តិចព្រះអង្គ ព្រះអង្គត្រាស់ថា រាហុល សមណធម៌របស់អ្នកគ្មានគុណធម៌ ក្នុងការនិយាយកុហកទាំងដឹងខ្លួន ក៏មានតិច ដូចទឹកនៅសល់នោះដែរ ។

បន្ទាប់មក ព្រះមានព្រះភាគ **ទ្រង់ចាក់ទឹកដែលសល់នោះទាំងអស់** ត្រាស់ថា ម្នាលរាហុល សមណធម៌របស់អ្នកនិយាយកុហកទាំងដឹងខ្លួន ក៏ជារបស់ដែលគេបោះចោលហើយដូចគ្នាដូច្នោះ ។ ព្រះមានព្រះភាគ **ទ្រង់ផ្កាប់ភាជនៈទឹកនោះចុះ** ត្រាស់ថា ម្នាលរាហុល សមណធម៌របស់អ្នកនិយាយកុហកទាំងដឹងខ្លួន ក៏ជារបស់ដែលគេផ្កាប់ចោលហើយដូចគ្នា លំដាប់នោះ ព្រះមានព្រះភាគ **ទ្រង់ផ្ងារភាជនៈទឹកនោះឡើង** ត្រាស់ថា ម្នាលរាហុល សមណធម៌របស់អ្នកនិយាយកុហកទាំងដឹងខ្លួន ក៏ជារបស់ទទេដូចគ្នា ដូច្នោះ ។ ម្នាលរាហុល អ្នកពោលកុហកទាំងដឹងខ្លួននឹងមិនធ្វើអំពើបាបមិនមាន ព្រោះហេតុនោះឯង ម្នាលរាហុល **អ្នកគប្បីសិក្សាថា យើងនឹងមិនពោលកុហក សូម្បីត្រឹមតែដើម្បីសើចលេង។**

ព្រះអង្គត្រាស់សួរទៀតថា ម្នាលរាហុល **កញ្ចក់មានប្រយោជន៍ដូចម្តេច ?** រាហុលទូលថា **មានប្រយោជន៍សម្រាប់ឆ្លុះមើលខ្លួនឯង** ព្រះអង្គ !

ទើបព្រះអង្គត្រាស់ទូន្មានថា ម្នាលរាហុល ដូច្នោះឯង កាលអ្នកនឹងធ្វើកម្មណា ដោយកាយ វាចា និងចិត្ត អ្នកគប្បីត្រួតពិចារណាថា កម្មណាបៀតបៀនខ្លួន បៀតបៀនអ្នកដទៃ ជាអកុសល មានទុក្ខជាផល មានទុក្ខជាវិបាក **កម្មនោះអ្នកមិនគួរធ្វើ** ។ ចំណែកកម្មណាធ្វើហើយមិនបៀតបៀនខ្លួន មិនបៀតបៀនអ្នកដទៃ ជាកុសល មានសុខជាផល មានសុខជាវិបាក **អ្នកគប្បីមានបីតិ និងបាមោជ្ជៈ សិក្សាក្នុងកុសលធម៌នោះ ទាំងថ្ងៃទាំងយប់ចុះ** ។

ម្នាលរាហុល សមណព្រាហ្មណ៍ទាំងឡាយ **ក្នុងអតីតៈ** ក៏ជម្រះកាយកម្ម វចីកម្ម និងមនោកម្មហើយយ៉ាងនេះ **ក្នុងអនាគត** ក៏នឹងជម្រះយ៉ាងនេះ **សូម្បីក្នុងបច្ចុប្បន្ន** ក៏រមែងជម្រះយ៉ាងនេះ ព្រោះហេតុដូច្នោះ អ្នកកាលនឹងសិក្សាតាមសមណព្រាហ្មណ៍ ក៏គប្បីសិក្សាយ៉ាងនេះ ដូចគ្នា ព្រះមានព្រះភាគទ្រង់ឱ្យឱវាទសាមណេររាហុល ដោយអំណាចនៃបុគ្គលគួរណែនាំដូច្នេះ។

(៣) សម័យមួយ ព្រះមានព្រះភាគយាងទៅគង់ **ក្នុងបាវារិកម្ពវ័ន** ចំការស្វាយរបស់ **ទុស្សបាវារិកសេដ្ឋី** ជិតស្រុកនាលន្ទា បាវារិកសេដ្ឋីនោះកាលបានស្តាប់ធម៌របស់ព្រះសាស្តាហើយ កើតសេចក្តីជ្រះថ្លា សាងវិហារថ្វាយព្រះមានព្រះភាគ ប្រកបដោយកុដិជាទីពួនសម្ងំ និងមណ្ឌបជាដើម ទុកក្នុងឧទ្យាននោះ ។ ក្នុងបាវារិកម្ពវ័ននេះ ព្រះសារីបុត្រចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាក្នុងព្រះមានព្រះភាគជាម្ចាស់ថា **សមណៈ ឬ ព្រាហ្មណ៍ដទៃ នឹងមានបញ្ញាជាគ្រឿងត្រាស់ដឹង ស្មើ**

**ដោយព្រះអង្គនោះ មិនមានក្នុងអនាគត មិនមានក្នុងអតីតៈ និងរមែងមិនមានក្នុងបច្ចុប្បន្ន ។**

ព្រះអង្គត្រាស់ថា អ្នកមិនមានចេតោបរិយញ្ញាណ ក្នុងព្រះអរហន្តសម្មាសម្ពុទ្ធ ទាំងដែលជាអតីតៈ អនាគត និងបច្ចុប្បន្ន ហេតុអ្វី ទើបអ្នកហ៊ានពោល **អាសភិវាចា** គឺ ពាក្យប្រកាសថា ព្រះពុទ្ធអង្គជាឯកក្នុងលោកដូច្នេះ ។ ព្រះសារីបុត្រទូលតបថា ខ្ញុំព្រះអង្គ មិនមានញាណដែលអាចនឹងដឹងហេតុនៃសីល សមាធិ បញ្ញា និងវិមុត្តិរបស់ព្រះពុទ្ធទាំងឡាយ ខ្ញុំព្រះអង្គមិនមានញាណជាគ្រឿងកំណត់ដឹងព្រះទ័យ ក្នុងព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលជាអតីតៈ អនាគត និងសូម្បីក្នុងបច្ចុប្បន្នបាន តែថាខ្ញុំព្រះអង្គតាំងនៅក្នុង **សាវ័កបារមីញាណ** រមែងដឹងអំពីការកាន់យកដោយន័យ ដែលស្របតាមធម៌ ដឹងតាមក្រសែព្រះធម៌ថា ព្រះពុទ្ធទាំងឡាយដែលមានមកក្នុងអតីតកាល ដែលនឹងមានមកក្នុងអនាគតកាល សូម្បីកំពុងមានក្នុងបច្ចុប្បន្នគ្រប់ព្រះអង្គ ក៏ទ្រង់លះបង់នីវរណៈ ៥ ទ្រង់មានព្រះហឫទ័យតាំងមាំក្នុងសតិប្បដ្ឋាន ៤ ទ្រង់ចម្រើនពោជ្ឈង្គៈ ៧ តាមសេចក្តីពិតហើយ ទើបបានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ។ ព្រះមានព្រះភាគត្រាស់ថា សាធុ សារីបុត្រ ព្រោះហេតុនោះឯង អ្នកគប្បីពោលធម្មបរិយាយនេះដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជានិច្ចចុះ បើថាមោឃបុរសពួកណា ដែលនៅមានសេចក្តីសង្ស័យក្នុងតថាគត មោឃបុរសទាំងនោះ នឹងលះបង់សេចក្តីសង្ស័យនោះចេញបាន ព្រោះបានស្តាប់ធម្មបរិយាយនេះរបស់អ្នក ។

(៤ ) ខណៈដែលព្រះអង្គគង់នៅក្នុងបាវារិកម្ពវ័ននេះ មេភូមិឈ្មោះអសិពន្ធកបុត្រ ចូលទៅគាល់ដល់ទីប្រថាប់ ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាព្រះអរហន្តសម្មាសម្ពុទ្ធ អាចធ្វើសត្វលោកទាំងអស់ដែលស្លាប់ទៅហើយ ឱ្យចូលដល់សុគតិបានទេ ព្រះអង្គ ?

ព្រះសាស្តាត្រាស់ថា ម្នាលនាយគាមណី តថាគតសុំសួរត្រឡប់ជាមុនថា បុរសក្នុងលោកនេះសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក និយាយញុះញង់ និយាយគំរោះគំរើយ និយាយរោយរាយ ច្រើនទៅដោយអភិជ្ឈា មានចិត្តព្យាបាទ មានការឃើញខុស ពួកមហាជនមកប្រជុំគ្នា ហើយគប្បីបួងសួង សរសើរ ប្រណមដៃ ដើរប្រទក្សិណជុំវិញអ្នកនោះថា បុរសនេះកាលស្លាប់ទៅគប្បីទៅកាន់សុគតិទេវលោក ព្រោះហេតុនៃការបួងសួង និងប្រណមដៃជាដើម បានឬទេ ? ម្នាលនាយគាមណី ប្រៀបដូចបុរសចោលដុំថ្មធំចុះក្នុងអន្លង់ទឹកជ្រៅ មហាជនសូម្បីនឹងបួងសួង ប្រណមដៃប្រទក្សិណជុំវិញស្រះនោះ សូមឱ្យដុំថ្មអណ្តែតឡើងមក ដុំថ្មនោះនឹងគប្បីផុះឡើង អណ្តែតឡើងបានឬទេ ? ក៏បុគ្គលដែលប្រព្រឹត្តក្នុងអកុសលកម្មបថ ១០ នោះ កាលអស់ជីវិតទៅ គប្បីចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរកតែម្យ៉ាងប៉ុណ្ណោះ ។

បុគ្គលក្នុងលោកនេះវៀរចាក **អកុសលកម្មបថ ១០** គឺ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ មិនច្រើនទៅដោយអភិជ្ឈា មិនមានចិត្តព្យាបាទ មានសម្មាទិដ្ឋិ បុគ្គលនោះកាល

អស់ជីវិតទៅ **គប្បីចូលទៅកាន់សុគតិទេវលោក** ដោយមិនត្រូវអង្វរកសូមឡើយ ។ កាលព្រះសាស្ដាត្រាស់ដូច្នេះហើយ មេភូមិអសិពន្ធកបុត្រ ក្រាបទូលថា ខ្ញុំព្រះអង្គ សូមដល់ព្រះមានព្រះភាគជាម្ចាស់ផង ព្រះធម៌ផង និងព្រះភិក្ខុសង្ឃផង ថាជាសរណៈ សូមព្រះមានព្រះភាគទ្រង់ចាំខ្ញុំព្រះអង្គថាជាឧបាសក ដល់ព្រះរតនត្រៃជាសរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះតទៅ ។

(៥) ក្នុងវស្សានេះ ព្រះអង្គទ្រង់អនុញ្ញាតវិធីឧបសម្បទា ដែលហៅថា **ញត្តិចតុត្ថកម្មវាចា** កម្មមានញត្តិជាទី ៤ គឺ លើកដំបូងជាការប្រកាសសូមទទួលបុគ្គលនោះចូលពួក ទីពីរ ទីបី និងទីបួន ជាការសូមមតិអំពីសង្ឃក្នុងទីប្រជុំ ដែលជាសិក្ខាបទអនុវត្តមកដល់សព្វថ្ងៃនេះ ។

ក្នុងថេរគាថា សម្ដែងថា ក្នុងវេលាដែលជាគ្រហស្ថ **រាធៈ** ជាព្រាហ្មណ៍ទាល់ក្រត្រូវកូនចៅរមិលគុណ ទើបគិតថា ប្រយោជន៍អ្វីដែលយើងនឹងនៅគ្រប់គ្រងផ្ទះ បានសូមបួសនឹងភិក្ខុទាំងនោះ ព្រះថេរៈទាំងនោះហាមថា កុំឡើយរាធៈអាយុច្រើនហើយ មិនអាចនឹងបំពេញវត្តបដិបត្តិបាន ទើបរាធៈទៅគាល់ព្រះសាស្ដា ក្រាបទូលបំណងរបស់ខ្លួនឱ្យទ្រង់ជ្រាប ព្រះសាស្ដាត្រួតមើលឧបនិស្ស័យហើយ ត្រាស់បង្គាប់ឱ្យសារីបុត្រជាអ្នកបំបួស ទើបព្រះសារីបុត្រធ្វើការបំបួសរាធព្រាហ្មណ៍ដោយ **ញត្តិចតុត្ថកម្ម** ជាភិក្ខុបួសដោយវិធីនេះមុនគេ ព្រះរាធៈបួសមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្ត ព្រះសាស្ដាត្រាស់នឹងភិក្ខុទាំងឡាយថា រាធៈនេះកំពូលជាងភិក្ខុសាវ័កតថាគតអ្នកមានបដិភាណ ។

ចំណែកក្នុងគាថាធម្មបទ សម្តែងទុកថា ព្រះសាស្តាទ្រង់ប្រារព្ធរឿងព្រះរាធៈ ខណៈដែលគង់នៅជេតវនវិហារថា ក្នុងវេលាដែលនៅជាគ្រហស្ថ រាធៈជាព្រាហ្មណ៍ទាល់ក្រនៅក្នុងក្រុងសាវត្ថី អាស្រ័យចិញ្ចឹមជីវិតក្នុងសំណាក់របស់ភិក្ខុទាំងឡាយ ជួយជម្រះស្មៅ បោសសំអាតបរិវេណ និងបម្រើភិក្ខុជាដើម ភិក្ខុទាំងឡាយសង្គ្រោះរាធៈហើយ តែមិនប្រាថ្នានឹងឱ្យបួស ។ ព្រះសាស្តាទ្រង់ត្រួតមើលសត្វលោកក្នុងថ្ងៃមួយ ទ្រង់ជ្រាបថា រាធព្រាហ្មណ៍នឹងបានជាព្រះអរហន្ត ទើបយាងទៅកាន់ទីស្នាក់នៅរបស់ព្រាហ្មណ៍ ត្រាស់សួរ ដឹងសេចក្តីថា ភិក្ខុទាំងនោះសង្គ្រោះត្រឹមអាហារតែមិនឱ្យបួស ទើបព្រះសាស្តាមានតម្រាស់ឱ្យប្រជុំសង្ឃ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ មាននរណាដែលរឭកដល់គុណរបស់ព្រាហ្មណ៍នេះបានខ្លះទេ ព្រះសារីបុត្រក្រាបទូលថា កាលខ្ញុំព្រះអង្គត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ រាធៈព្រាហ្មណ៍នេះធ្លាប់ ប្រគេនភិក្ខាមួយវែករបស់ខ្លួនដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គរឭកដល់គុណរបស់ព្រាហ្មណ៍នេះបាន ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្រ កាលដែលអ្នកនឹងលើកព្រាហ្មណ៍អ្នកមានឧបការគុណនេះចេញអំពីទុក្ខមិនគួរឬ ? ព្រះសារីបុត្រទូលតបថា ល្អព្រះអង្គ ! ខ្ញុំព្រះអង្គនឹងឱ្យរាធព្រាហ្មណ៍នេះបួស ។

ទើបព្រះសារីបុត្របំបួសរាធព្រាហ្មណ៍ដោយ **ញត្តិចតុត្ថកម្ម** ជាភិក្ខុដំបូង កាលបួសហើយ ព្រះរាធៈជាអ្នកប្រដៅងាយ បដិបត្តិតាមពាក្យដែលឧបជ្ឈាយ៍ទូន្មាន ២-៣ ថ្ងៃក៏បានសម្រេចព្រះអរហត្ត ពួកភិក្ខុសរសើរព្រះសារីបុត្រថា

ជាអ្នកមានកតញ្ញូកតវេទី រឮកដល់ឧបការគុណត្រឹមតែបាយមួយវែក អនុគ្រោះឱ្យព្រាហ្មណ៍ទាល់ក្របានបួស សរសើរព្រះរាធៈថា សូម្បីព្រះរាធៈក៏ជាអ្នកអត់ធន់ចំពោះឱវាទ ហើយបានលោកអ្នកឱ្យឱវាទក៏អត់ធន់ដូចគ្នា ។

( ៦ ) សម័យនោះ ព្រះមានព្រះភាគគង់នៅភ្នំគិជ្ឈកូដ នគររាជគ្រឹះ សម័យនោះ ពួកតិរ្ថិយ៍ប្រជុំគ្នាពោលធម៌ ជនទាំងឡាយនាំគ្នាចូលទៅរកបរិព្វាជកតិរ្ថិយ៍ដើម្បីស្ដាប់ធម៌ ព្រះបាទពិម្ពិសារទ្រង់ព្រះតម្រិះថា ដូចម្ដេចហ្ន៎ ! ភិក្ខុទាំងឡាយនឹងគប្បីប្រជុំគ្នាសម្ដែងធម៌ខ្លះ ទើបចូលទៅគាល់សូមប្រទានឱកាសឱ្យសង្ឃប្រជុំគ្នា ព្រះអង្គទ្រង់អនុញ្ញាតឱ្យសង្ឃប្រជុំគ្នាសម្ដែងធម៌ **ទ្រង់អនុញ្ញាតថ្ងៃប្រជុំសម្ដែងធម៌របស់សង្ឃក្នុងថ្ងៃ ១៤ , ១៥ , និងថ្ងៃ ៨ នៃបក្ខ ។**

## ក្រោយអំពីចេញព្រះវស្សាទី ៣ ហើយ

( ៧ ) តាំងពីព្រះសាស្ដា ទ្រង់បញ្ញត្តវិធីឧបសម្បទាដោយញត្តិចតុត្ថកម្មហើយ ភិក្ខុទាំងឡាយក៏ធ្វើការបំបួសកុលបុត្រ ដោយប្រជុំសង្ឃមានត្រឹម ២ រូបខ្លះ ៣ រូបខ្លះ ៤ រូបខ្លះ ពួកភិក្ខុកើតសេចក្ដីសង្ស័យថា គណៈសង្ឃនឹងត្រូវមានភិក្ខុចំនួនប៉ុន្មាន ? ទើបក្រាបទូលសួរព្រះសាស្ដា ព្រះអង្គទ្រង់បញ្ញត្តថា តាំងពីនេះទៅគណៈសង្ឃត្រូវមានមិនតិចជាង ១០ អង្គ ទើបអាចឱ្យឧបសម្បទាដល់កុលបុត្របាន ។

តមក កាលព្រះកច្ចាយនត្ថេរ ជាបុត្រព្រាហ្មណ៍បុរោហិតរបស់ព្រះបាទចណ្ឌបជោតិ ជាស្ដេចនៃដែនអវន្តី បានបួសក្នុងសំណាក់ព្រះពុទ្ធអង្គ សម្រេច

អរហត្តផលហើយ ព្រះសាស្តាបញ្ជូនព្រះថេរៈ ត្រឡប់ទៅប្រកាសសាសនាក្នុងដែនអវន្តី ឧបាសកម្នាក់ឈ្មោះ សោណកុដិកណ្ណៈ បំណងនឹងឧបសម្ប័ទក្នុងព្រះពុទ្ធសាសនា ព្រះមហាកច្ចាយនត្ថេរបព្វជ្ជាឱ្យ តែរកភិក្ខុគ្រប់ ១០ រូបតាមការបញ្ញត្តិវិធីឧបសម្បទាទម្រាំបាន អស់ពេលដល់ទៅ ៣ ឆ្នាំ ក្រោយអំពីព្រះ-សោណកុដិកណ្ណៈ សម្រេចអរហត្តផលហើយ បំណងនឹងទៅថ្វាយបង្គំព្រះសាស្តាទើបចូលទៅលាព្រះឧបជ្ឈាយ៏ ព្រះមហាកច្ចាយនត្ថេរទើបបញ្ជាឱ្យព្រះសោណ-កុដិកណ្ណៈ ទៅទូលសូមពុទ្ធានុញ្ញាតអំពីព្រះសាស្តា ៥ ប្រការ គឺ :

១. ដែនអវន្តី លំបាកក្នុងការរកភិក្ខុ សូមអនុញ្ញាតធ្វើឧបសម្បទា-កម្ម ដោយគណសង្ឃតិចជាង ១០ រូប ព្រះសាស្តាអនុញ្ញាតឱ្យសង្ឃ ៥ រូបជាគណបូរកៈក្នុងកម្មនេះ ។

២. ដែនអវន្តី មានផ្ទៃដីខ្មៅ និងភក់មិនស្រួលដល់ការដើរដោយជើងទទេ ព្រះសាស្តាអនុញ្ញាតឱ្យពាក់ស្បែកជើងបានក្នុងចន្លោះផ្លូវ (វៀរ-ចន្លោះផ្ទះ) ។

៣. ដែនអវន្តី មានអាកាសធាតុក្តៅ ប្រជាជននិយមងូតទឹករាល់ថ្ងៃ សូមឱ្យភិក្ខុងូតទឹកបានរាល់ថ្ងៃដូចគ្នា ព្រះសាស្តាក៏ទ្រង់អនុញ្ញាតដែរ ។

៤. ដែនអវន្តី និយមប្រើប្រាស់ស្បែកសត្វជាកម្រាលអង្គុយ សូមអនុញ្ញាតឱ្យភិក្ខុប្រើប្រាស់ស្បែកសត្វជាអាសនៈ ព្រោះកន្ទេលជារបស់រកបានដោយលំបាក ក៏ទ្រង់អនុញ្ញាតដែរ ។

**៥. សូមឱ្យភិក្ខុទទួលចីវរបញ្ញើរបស់ភិក្ខុដទៃបាន សូម្បីលើសកំណត់ ១០ ថ្ងៃ ព្រោះមានផ្លូវឆ្ងាយ ការធ្វើដំណើរប្រើពេលយូរ ព្រះសាស្តាក៏ទ្រង់អនុញ្ញាត ។**

ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ អនុញ្ញាតឱ្យធ្វើការឧបសម្បទាកុលបុត្រក្នុងបច្ចន្តជនបទ ដោយគណបូរកៈមានត្រឹម ៥ រូបបាន តអំពីករណីរបស់ព្រះសោណកុដិកណ្ណត្ថេរ ជាមូលហេតុជាប់តមករហូតសព្វថ្ងៃ ។

( ៨ ) ក្រោពីនោះ នៅមានបញ្ញត្តិគុណសម្បត្តិរបស់ឧបជ្ឈាយ៍ថា ត្រូវតែជាអ្នកបួសមកហើយយ៉ាងតិចត្រឹម ១០ វស្សា នឹងត្រូវជាអ្នកចេះដឹងក្នុងធម្មវិន័យយ៉ាងល្អ មូលហេតុមកពី **ព្រះឧបសេនវង្គន្តបុត្រ** ជាឧបជ្ឈាយ៍ក្នុងការបំបួសភិក្ខុមួយរូប ដោយនាំភិក្ខុនោះមកគាល់ព្រះអង្គ ។ ព្រះអង្គត្រាស់សួរថា ព្រះឧបសេនមានវស្សាប៉ុន្មានហើយ ? ទូលតបថា ២ វស្សា ចំណែកសិស្សទើបតែបានមួយវស្សា ព្រះអង្គទ្រង់តិះដៀលថាមិនគួរ ព្រោះនៅមិនទាន់បែកធ្លាយក្នុងធម្មវិន័យ ។ ព្រោះហេតុនេះ ទើបបញ្ញត្តសិក្ខាបទថា ភិក្ខុល្ងង់មិនឈ្លាសវៃកុំគប្បីបំបួសកុលបុត្រ ភិក្ខុណាបំបួសត្រូវអាបត្តិទុក្កដ តថាគតអនុញ្ញាតឱ្យភិក្ខុមានវស្សា ១០ ឬលើសជាង ១០ អាចបំបួសកុលបុត្របាន ។

( ៩ ) ខណៈដែលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវេឡុវ័នវិហារ មេភូមិឈ្មោះ មណិចូឡកៈ ចូលទៅក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន រាជបរិស័ទក្នុងរាជវាំងសន្ទនាគ្នាថា មាស និងប្រាក់រមែងសមគួរដល់សមណសក្យ-

បុត្រ ខ្ញុំព្រះអង្គបានពោលនឹងបរិស័ទនោះថា សមណសក្យបុត្ររមែងមិនត្រេក-អរក្នុងមាស និងប្រាក់ រមែងមិនទទួលនូវមាស និងប្រាក់ តាមពាក្យដែលព្រះមានព្រះភាគត្រាស់ តែខ្ញុំព្រះអង្គក៏មិនអាចធ្វើឱ្យបរិស័ទនោះយល់ព្រមបាន ,

ព្រះមានព្រះភាគត្រាស់ថា សាធុនាយគាមណី អ្នកពោលតាមពាក្យដែលតថាគតពោលហើយ មិនពោលបង្កាច់តថាគតដោយពាក្យមិនពិត ព្រោះថា **មាស និងប្រាក់មិនសមគួរដល់សមណសក្យបុត្រទេ** ។ ម្នាលនាយគាមណី មាស និងប្រាក់គួរដល់អ្នកណា បញ្ចកាមគុណក៏គួរដល់អ្នកនោះ អ្នកគប្បីចាំទុកដោយមួយចំណែកថា បញ្ចកាមគុណមិនមែនជាធម៌របស់សមណៈ មិនមែនជាធម៌របស់សក្យបុត្រ តថាគតពោលយ៉ាងនេះថា អ្នកត្រូវការស្មៅគប្បីស្វែងរកស្មៅ អ្នកត្រូវការឈើគប្បីស្វែងរកឈើ អ្នកត្រូវការរទេះគប្បីស្វែងរករទេះ តថាគតមិនបានពោលថា សមណសក្យបុត្រគប្បីត្រេកអរ គប្បីស្វែងរកមាស និងប្រាក់ដោយបរិយាយណាមួយឡើយ ។ ក្នុងភេសជ្ជក្ខន្ធកៈ ពោលថា ព្រះសាស្តាទ្រង់អនុ-ញ្ញាតឱ្យភិក្ខុត្រេកអរក្នុងកប្បិយភណ្ឌៈ គឺវត្ថុដែលគួរសម្រាប់សង្ឃ ដែលបានមកអំពីមាស និងប្រាក់ដែលមានអ្នកបវារណាទុកក្នុងដៃកប្បិយការកៈ តែមិនឱ្យត្រេកអរស្វែងរកមាស និងប្រាក់ដោយខ្លួនឯងឡើយ ។

(១០) សម័យនោះ ពួកភិក្ខុនាំគ្នាចារិកទៅគ្រប់រដូវកាល ដើរជាន់សន្ទូងក្នុងស្រែ បៀតបៀនសត្វល្អិតជាច្រើនឱ្យលំបាក អ្នកស្រុកទាំងឡាយនាំគ្នាតិះដៀលថា សូម្បីសត្វក៏គង់ចេះធ្វើសំបុកក្នុងរដូវភ្លៀង ហេតុអ្វីសាវ័ករបស់ព្រះ

សមណគោតម ទើបមិនស្នាក់នៅមួយកន្លែង ត្រាច់ដើរជាន់ពូជឱ្យខូចដូច្នេះ ព្រះអង្គទ្រង់ជ្រាប ទើបទ្រង់បញ្ញត្តការចូលចាំវស្សាទុក ២ យ៉ាងដូច្នេះគឺ :

- **តាំងពី ១ រោច ខែអាសាឍ ដល់ថ្ងៃពេញបូរមី ខែអស្សុជ ជាវស្សាទី១**
- **តាំងពី ១ រោច ខែស្រាពណ៍ ដល់ថ្ងៃពេញបូរមីខែ កត្តិក ជាវស្សាទី ២**

(១១) **គោធិកៈ** ឱរសរបស់ស្តេចមល្លៈក្នុងដែនបាវ៉ា ព្រមដោយសម្លាញ់ ៣ នាក់ គឺ **សុពាហុ វល្លិយៈ** និង **ឧត្តិយៈ** ធ្វើដំណើរទៅកាន់ក្រុងកបិលពស្តុ វេលាដែលព្រះសាស្តាសម្តែងបាដិហារិយ៍ ក្នុងសមាគមព្រះញាតិឯនិគ្រោធារាម បានឃើញបាដិហារិយ៍ហើយកើតសេចក្តីជ្រះថ្លា ទូលសូមបព្វជ្ជាឧបសម្បទា ហើយទៅស្នាក់រួមគ្នាឯ **កាឡសិលា** ភ្នំឥសិគិលិ ។ ថ្ងៃមួយ ព្រះគោធិកៈចូលទៅកាន់ក្រុងរាជគ្រឹះ ព្រះបាទពិម្ពិសារចូលទៅជួប និមន្តឱ្យគង់ចាំវស្សារហូតត្រៃមាស ទ្រង់បញ្ជាឱ្យសាងកុដិប្រគេន តែមិនបានប្រក់ដំបូល ព្រះគោធិកៈក៏គង់នៅក្នុងកុដិដែលមិនមានដំបូលនោះ ដល់រដូវភ្លៀង ភ្លៀងក៏មិនធ្លាក់ ព្រះបាទពិម្ពិសារដឹងហេតុនោះ ទើបញ្ជាឱ្យប្រក់ដំបូល និងលាបបូកឱ្យល្អ ធ្វើការឆ្លងហើយប្រគេនដល់ភិក្ខុសង្ឃជាច្រើន. ព្រះគោធិកៈជាអ្នកមិនប្រមាទ មានសេចក្តីព្យាយាមបដិបត្តិសមណធម៌ កើតឈានម្តងម្កាលហើយក៏សាបសូន្យទៅជាយ៉ាងនេះរហូតដល់ ៦ ដង ដោយអំណាចនៃរោគរ៉ាំរៃមួយប្រភេទ លើកទី ៧ ព្រះគោធិកៈគិតថា អ្នកមានឈានសាបសូន្យហើយ រមែងមានគតិមិនទៀង ទើបកាន់កាំបិតកោរសក់ដេកលើគ្រែ បំណងនឹងផ្តាច់ជីវិតខ្លួនឯង មារដឹងចិត្តរបស់

ព្រះគោធិកៈថា ជាអ្នកអស់អាល័យដូច្នោះ កាលព្រះគោធិកៈផ្តើមតាំងវិបស្សនា រមែងសម្រេចអរហត្តបាន មារមិនត្រូវការឃើញព្រះគោធិកៈផុតចាកអំណាចរបស់ខ្លួន ទើបចូលទៅក្រាបទូលព្រះពុទ្ធអង្គឱ្យទ្រង់ហាម ព្រះសាស្តាត្រាស់ថា **អ្នកប្រាជ្ញទាំងឡាយ រមែងមិនអាល័យក្នុងជីវិត** ហើយយាងទៅកាន់ទីលំនៅដ្ឋានរបស់ព្រះគោធិកៈ ។

ព្រះគោធិកៈគិតថា យើងនឹងមានប្រយោជន៍អ្វីដោយជីវិតនេះ ទើបដេកផ្ងារយកកាំបិតកាត់បំពង់ក ទុក្ខវេទនាទាំងឡាយកើតឡើង ព្រះគោធិកៈគ្របសង្កត់វេទនា ហើយកំណត់វេទនានោះជាអារម្មណ៍ តាំងសតិមាំ ពិចារណាមូលកម្មដ្ឋាន ក៏សម្រេចព្រះអរហត្ត ជា **សមសីសីបរិនិព្វាន** (អស់អាសវៈនិងជីវិតមិនមុនមិនក្រោយគ្នា ) មារចេញត្រាច់តាមរកវិញ្ញាណរបស់ព្រះគោធិកត្ថេរ ក្នុងទីណាក៏មិនឃើញ ទើបត្រឡប់ទៅទូលសួរព្រះសាស្តា ព្រះអង្គត្រាស់ថា គោធិកៈដកតណ្ហាឡើងព្រមទាំងឫស សម្រេចអរហត្តផលបរិនិព្វានហើយ មារតូចចិត្តអន្តរធានទៅក្នុងទីនោះឯង ។

( ១២ ) ព្រះសម្ពុទ្ធគង់នៅលើភ្នំគិជ្ឈកូដ ត្រាស់ព្រះសូត្រផ្សេងៗ ដូចជា **អាដានាដិយសូត្រ** ដល់ភិក្ខុសាវ័កសម្រាប់ជាគ្រឿងការពារភ័យអំពីអមនុស្សតាមពាក្យក្រាបទូល របស់ស្តេចវេស្សវ័ណមហារាជ ទាំងក្នុងខណៈនោះ ពួកភិក្ខុកំពុងគង់នៅក្នុងព្រៃភ្នំដែលពេញទៅដោយអមនុស្ស ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូររៀន ចូរខ្វល់ខ្វាយ ចូរចងចាំអាដានាដិយសូត្រនេះដើម្បី

គ្រប់គ្រង ដើម្បីរក្សា ដើម្បីការមិនបៀតបៀនដល់ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាទាំងឡាយ ។

(១៣) កាលព្រះសាស្តាគង់នៅលើភ្នំគិជ្ឈកូដ គ្រានោះសក្កទេវរាជស្តេចចូលទៅទូលសួរព្រះមានព្រះភាគដោយគាថាថា :

**បពិត្រព្រះអង្គដ៏ចម្រើន កាលមនុស្សទាំងឡាយ**
**ប្រាថ្នានូវបុណ្យ ទានដែលឱ្យហើយក្នុងបុគ្គល**
**ណាមានផលច្រើន ព្រះអង្គ !**

ព្រះមានព្រះភាគត្រាស់សម្តែងតបថា :

**ទានដែលឱ្យដល់អរិយសង្ឃ ដែលជាអ្នកស្មោះ-**
**ត្រង់ ប្រកបដោយបញ្ញា និងសីល ទានដូច្នេះ**
**មានផលច្រើន មានអានិសង្សច្រើន !**

អដ្ឋកថាពោលថា ក្នុងគ្រានោះ ពួកអ្នកស្រុកអង្គៈ និងមគធៈបានកាន់យកទឹកដោះថ្លា ទឹកឃ្មុំ និងស្ករអំពៅដ៏ច្រើន គរទុកក្នុងកន្លែងមួយ យកឧសផ្ទុកក្នុងរទេះប្រមាណ ៦០ រទេះ ហើយបង្កាត់ភ្លើង ខណៈដែលភ្លើងឆេះទើបចាក់របស់ដ៏ប្រណីតទាំងនោះទៅក្នុងគំនរភ្លើងតែម្តង គិតថា ពួកយើងនឹងបូជាស្តេចព្រហ្ម ដោយការប្រកាន់ជឿថា ការចាក់របស់ចុះទៅម្តង នឹងបានផលតបស្នងវិញ។

ស្តេចសក្កទេវរាជត្រិះរិះថា ជនទាំងនេះធ្វើវត្ថុដែលគ្មានផល យើងកុំឱ្យពួកគេវិនាសឡើយ យើងនឹងធ្វើឱ្យពួកគេថ្វាយទានដល់ព្រះពុទ្ធ និងព្រះសង្ឃ

ដើម្បីពួកគេនឹងបានប្រសព្វបុណ្យច្រើន ទើបប្លែងជាស្តេចមហាព្រហ្ម ស្តេចឈរនៅក្នុងអាកាស ត្រាស់សួរថា សក្ការៈនេះដើម្បីនរណា មហាជនទូលតបថា ដើម្បីព្រះអង្គ សូមព្រះអង្គទ្រង់ទទួលគ្រឿងបូជារបស់ពួកខ្ញុំព្រះអង្គផងចុះ ។

ទើបសក្កទេវរាជនាំជននៃដែនទាំងពីរទៅគាល់ព្រះសាស្តា ទូលសួរថា ជន ទាំងនេះប្រាថ្នាបុណ្យ ទានដែលថ្វាយដល់អ្នកណាទើបនឹងមានផលច្រើន មានអានិសង្សច្រើន ព្រះសាស្តាត្រាស់តបដោយគាថាថា **ទានដែលថ្វាយដល់អរិយសង្ឃ រមែងមានផលច្រើន មានអានិសង្សច្រើន** កាលចប់ទេសនា ជនទាំងឡាយ បានសម្រេចអមតធម៌ បន្ទាប់មកជនទាំងនោះ នាំគ្នាថ្វាយទានដ៏វិសេសវិសាលដល់ភិក្ខុសង្ឃ ។

(១៤) ត្រាស់ **សក្កបញ្ហសូត្រ** ទ្រង់ដោះស្រាយបញ្ហារបស់សក្កទេវរាជ ត្រង់ល្អាងឥន្ទសាលៈ ចន្លោះភ្នំវេទិយកៈ ផ្នែកខាងជើងនៃស្រុកព្រាហ្មណ៍ ខាងកើតនៃក្រុងរាជគ្រឹះ សម័យនោះ សក្កទេវរាជទ្រង់ឃើញបុព្វនិមិត្ត ៥ ប្រការ ទ្រង់ជ្រាបថា ឥឡូវនេះយើងអស់អាយុហើយ ព្រោះគ្រឿងសម្គាល់នៃការចុតិប្រាកដ ព្រះសាស្តាទ្រង់ជ្រាបថាសក្កទេវរាជខ្លាចមរណភ័យ ទើបទ្រង់សួរបញ្ហាដប់បួនចំណុច ព្រោះកាលដោះស្រាយបញ្ហាទាំង ១៤ ចំណុចនោះហើយ សក្កទេវរាជនឹងតាំងនៅក្នុងសោតាបត្តិផល ។

(បញ្ហា ១៤ ចំណុច របស់ស្តេចសក្កៈ នៅក្នុងទីឃនិកាយមហាវគ្គ)

កាលព្រះមានព្រះភាគទ្រង់ព្យាករណ៍បញ្ហាទាំងនោះចប់ ការត្រាស់ដឹងធម៌បានកើតឡើងហើយដល់សក្កទេវរាជ ព្រមទាំងទេវតាចំនួនច្រើន លុះបានជាព្រះសោតាបន្នហើយ ក៏ទ្រង់ចុតិចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគជាម្ចាស់នុ៎ះឯង ហើយកើតជាសក្កទេវរាជកម្លោះធម្មតា ការចុតិបដិសន្ធិរបស់ពួកទេវតារមែងមិនប្រាកដឡើយ ដូចជាការប្រាសទៅនៃអណ្តាតប្រទីប ចំណែកអ្នកដែលទ្រង់ជ្រាបមានពីរនាក់ គឺព្រះមានព្រះភាគ ព្រោះទ្រង់មានព្រះញាណ ហើយនិងសក្កទេវរាជព្រោះទ្រង់ចុតិខ្លួនឯង ។

អដ្ឋកថាពោលទុកថា សក្កទេវរាជអង្គនេះ ចុតិពីអត្តភាពនៃសក្កទេវ-រាជនេះហើយ នឹងកើតក្នុងជាន់អវិហា ហើយសម្រេចអនាគាមិផលក្នុងទីនោះចុងក្រោយនឹងជាអកនិដ្ឋគាមីព្រហ្ម នឹងបរិនិព្វានក្នុងទីនោះ ។

( ១៥ ) ត្រាស់ **បាសាណសូត្រ** លើភ្នំគិជ្ឈកូដ ជាមួយនឹងមារដែលមានចិត្តបាប មារបានប្រមៀលដុំថ្មធំទៅក្បែរទីប្រថាប់របស់ព្រះពុទ្ធអង្គ ក្នុងទីវាលវេលាយប់ខែងងឹត ភ្លៀងកំពុងធ្លាក់ប៉ប្រុយ ព្រះសាស្តាត្រាស់សន្ទាប់មារជាអ្នកមានចិត្តបាបថា ម្នាលមារ សូម្បីអ្នកនឹងប្រមៀលភ្នំគិជ្ឈកូដនេះទាំងអស់ សេចក្តីញាប់ញ័រក៏មិនមានដល់ព្រះពុទ្ធទាំងឡាយ ដែលរួចផុតហើយដោយប្រពៃ មារតូចចិត្តថា ព្រះមានព្រះភាគជាម្ចាស់បានស្គាល់យើង ព្រះសុគតនឹងស្គាល់យើងបានវិនាសទៅក្នុងទីនោះឯង ។

( ១៦ ) គ្រាមួយ ព្រះបាទពិម្ពិសារមានព្រះបរមរាជឱង្ការមេត្តាប្រោស

ប្រទានឱ្យបញ្ជូនទូតទៅកាន់ក្រុងចំប៉ា ដែនអង្គៈ បញ្ជាឱ្យសោណកោឡិវិសសេដ្ឋីបុត្រមកគាល់ ដូចមានព្រះករណីយកិច្ចប្រការខ្លះ សោណៈចេញដំណើរព្រមជាមួយអ្នកស្រុកដែនអង្គៈមួយចំនួន មកគាល់តាមព្រះរាជតម្រាស់ លុះមកដល់និងថ្វាយបង្គំហើយ ព្រះបាទពិម្ពិសារទ្រង់ណែនាំអ្នកស្រុកអង្គៈទាំងនោះ ក្នុងប្រយោជន៍បច្ចុប្បន្ន ហើយបញ្ជាឱ្យជនទាំងនោះទៅគាល់ព្រះសាស្តា ដើម្បីព្រះពុទ្ធអង្គទ្រង់ប្រៀនប្រដៅសម្បរាយិកត្ថប្រយោជន៍[១] ពួកគេទើបនាំគ្នាទៅគាល់ព្រះសាស្តាឯភ្នំគិជ្ឈកូដ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែងអនុបុព្វីកថា និងអរិយសច្ច ៤ ជនទាំងអស់បានសម្រេចធម៌ក្នុងទីនោះ បានប្រកាសថ្វាយខ្លួនជាឧបាសកអ្នកដល់ព្រះរតនត្រ័យជាទីពឹងទីរឭក ។

**សោណសេដ្ឋីបុត្រ** មានការគិតថា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ នឹងប្រព្រឹត្តព្រហ្មចរិយៈឱ្យបរិសុទ្ធដូចស័ង្ខដែលខាត់ហើយមិនបានទេ យើងគប្បីកោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ[២] ចេញចាកផ្ទះបួសជាបព្វជិត ក្រោយពីបរិស័ទគេចទៅមិនយូរ **សោណកោឡិវិសៈ** បានចូលទៅក្រាបទូលសូមបួស លុះបានបួសក្នុងសំណាក់ព្រះសម្ពុទ្ធហើយ ទៅគង់នៅក្នុងព្រៃសីតវ័នលោកប្រារព្ធសេចក្តីព្យាយាមរហូតជើងទាំងពីរបែក ទឹកន្លែងចង្ក្រមប្រឡាក់ដោយលោហិតដូចកន្លែងសម្លាប់គោ ។ ព្រះសោណៈគិតថា ក្នុងបណ្តាសាវ័ករបស់

---

[១] ប្រយោជន៍លោកខាងមុខ មាន សទ្ធា សីល ចាគ បញ្ញា

[២] សំពត់ជ្រលក់ទឹកអម្ចត់ គឺ សំពត់របស់បព្វជិតអ្នកបួស ហៅថា សំពត់កាសាយៈ

ព្រះមានព្រះភាគដែលប្រារព្ធសេចក្ដីព្យាយាម យើងក៏ជាភិក្ខុ ១ រូប ។ តែដូចម្ដេច ទើបចិត្តយើងមិនរួចផុតចាកអាសវៈ សម្បត្តិក្នុងត្រកូលរបស់យើងមាន យើងអាចបរិភោគសម្បត្តិ និងបំពេញកុសលបាន យើងនឹងលាសិក្ខាទៅជាគ្រហស្ថ ប្រើប្រាស់ភោគទ្រព្យ និងធ្វើបុណ្យល្អជាង។

ព្រះសាស្ដាទ្រង់ជ្រាបការរវើរវាយចិត្តរបស់ព្រះសោណៈ ទើបយាងអំពីភ្នំគិជ្ឈកូដ ទៅប្រាកដចំពោះមុខព្រះសោណៈក្នុងព្រៃសីតវ៉ន ត្រាស់ថា សោណៈ កាលអ្នកនៅគ្រប់គ្រងផ្ទះ អ្នកជាមនុស្សឈ្លាសក្នុងការដេញពិណ ក៏សម័យណា ខ្សែពិណរបស់អ្នកតឹងពេក ធូរពេក ឬមិនតឹងមិនធូរពេក អ្នករមែងដឹងក្នុងសំឡេងនោះដូចម្ដេច សេចក្ដីព្យាយាមអ្នកប្រារព្ធខ្លាំងពេក រមែងប្រព្រឹត្តទៅដើម្បីការរាយមាយចិត្ត ការព្យាយាមដែលធូរពេករមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីខ្ជិលច្រអូស ម្នាលសោណៈ អ្នកចូរតាំងសេចក្ដីព្យាយាមឱ្យស្មើ ចូរតាំងឥន្ទ្រីយ៍ឱ្យស្មើ និងចូរកាន់យកនិមិត្តក្នុងការស្មើនោះ ព្រះសោណៈធ្វើតាមព្រះ-ឱវាទនោះ គេចចេញចាកពួកនៅតែម្នាក់ឯង មានសេចក្ដីព្យាយាម តាំងចិត្តមាំក្នុងព្រះឱវាទ មិនយូរប៉ុន្មាន ព្រះសោណកោឡិវិសត្ថេរក៏បានជាព្រះអរហន្ត ១ រូប ក្នុងបណ្ដាព្រះអរហន្តទាំងឡាយ ។

កាលសម្រេចព្រះអរហត្តហើយ ព្រះសោណៈបានចូលទៅគាល់ព្រះមានព្រះភាគ នៅឯព្រះគន្ធកុដិភ្នំគិជ្ឈកូដ ក្រាបទូលថា ខ្ញុំព្រះអង្គបានធ្វើកិច្ចដែលគួរធ្វើចប់ហើយ សម្រេចប្រយោជន៍របស់ខ្លួនហើយ អស់កិលេសជាគ្រឿងប្រកប

ក្នុងភព រួចផុតព្រោះដឹងដោយប្រពៃ ភិក្ខុនោះរមែងជាអ្នកបង្អោនទៅក្នុង នេក្ខម្មៈ ១ សេចក្តីស្ងប់ស្ងាត់ ១ ការមិនបៀតបៀន ១ ការអស់តណ្ហា ១ ការអស់ឧបាទាន ១ ការមិនវង្វេង ១ ។

# ព្រះវស្សាទី ៤

## ទ្រង់គង់ចាំព្រះវស្សា ក្នុងវេឡុវ័នវិហារ ក្រុងរាជគ្រឹះ

(១) ក្នុងវស្សានេះ **ឧគ្គសេន** បុត្រគហបតីក្រុងរាជគ្រឹះ ហ្វឹកហាត់ការសម្តែងសិល្បៈ អំពីឪពុកក្មេក ដើរសម្តែងតាមស្រុក តាមនិគម មកដល់ក្រុងរាជគ្រឹះដោយលំដាប់ឱ្យប្រកូកប្រកាសថា ៧ ថ្ងៃទៀត សេដ្ឋីបុត្រឈ្មោះឧគ្គសេននឹងសម្តែងសិល្បៈដល់អ្នកនគរ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញឧគ្គសេនដោយព្រះញាណថា ស្អែកនេះឧគ្គសេននឹងសម្តែងសិល្បៈ មហាជននឹងប្រជុំគ្នាដើម្បីមើលការសម្តែង ទ្រង់ព្រះតម្រិះថា តថាគត នឹងសម្តែងគាថា ៤ បទ ក្នុងសមាគមនោះ ការសម្រេចធម៌នឹងមានដល់សត្វដ៏ច្រើន សូម្បីឧគ្គសេនក៏នឹងតាំងនៅក្នុងព្រះអរហត្តផល ។

លុះព្រឹកឡើង ឧគ្គសេនបានឡើងទៅកាន់ខ្សែស្នូរដ៏ខ្ពស់ អ្នកនគរមកប្រជុំគ្នាដើម្បីមើលការសម្តែង ឧគ្គសេនឈរនៅលើទីបំផុតខ្សែស្នូរនោះ ហើយលោតបង្វិលខ្លួនក្នុងអាកាសអស់ ៧ ត្រឡប់ ចុះមកឈរលើទីបំផុតខ្សែស្នូរនោះវិញ ។

កាលព្រះសាស្តាយាងចូលមកកាន់ព្រះនគរ មហាជនសម្លឹងមើលតែព្រះ-អង្គ ឧគ្គសេនអន់ចិត្តថា មិនមានអ្នកណាចាប់អារម្មណ៍ក្នុងការសម្តែងរបស់ខ្លួន ព្រះសាស្តាទ្រង់ដឹងចិត្តរបស់ឧគ្គសេន ទើបទ្រង់ត្រាស់ឱ្យព្រះមោគ្គល្លានទៅប្រាប់ឧគ្គសេនថា ចូរអ្នកធ្វើសេចក្តីត្រេកអរឱ្យដល់បរិស័ទចុះ ចូរអ្នកធ្វើឱ្យមហាជនរីករាយចុះ ។ ឧគ្គសេនបានឮពាក្យពេចន៍នោះហើយ មានសេចក្តីត្រេកអរគិតថា

ព្រះសាស្តាបំណងនឹងមើលសិល្បៈរបស់យើង ទើបពោលថា ខ្ញុំនឹងធ្វើសេចក្តីត្រេកអរដល់បរិស័ទ នឹងញ៉ាំងមហាជនឱ្យរីករាយ ហើយលោតអំពីចុងខ្សែស្នូរឡើងកាន់អាកាសត្រឡប់ខ្លួន ១៤ ដង ចុះមកឈរលើខ្សែស្នូរដូចដើមវិញ ។

លំដាប់នោះព្រះសាស្តាត្រាស់ថា ម្នាលឧគ្គសេន **ធម្មតាបណ្ឌិតគប្បីដកសេចក្តីអាល័យក្នុងខន្ធទាំងឡាយ ជាអតីតៈ អនាគត និងបច្ចុប្បន្ន ទើបនឹងផុតចាកទុក្ខមានជាតិជាដើមបាន** , ឧគ្គសេនកំពុងឈរលើទីបំផុតខ្សែស្នូរនោះឯង បានសម្រេចអរហត្តផលព្រមទាំងបដិសម្ភិទា ៤ ចុះចាកទីបំផុតខ្សែស្នូរមកជិតព្រះសាស្តា ក្រាបចុះទៀបបាទទូលសូមបួស ព្រះសាស្តាទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ដល់លោក , ឧគ្គសេនជាអ្នកទ្រទ្រង់នូវបរិក្ខារ ៨ ដូចជាព្រះថេរៈមានវស្សា ៦០ ក្នុងខណៈនោះឯង ការត្រាស់ដឹងធម៌កើតឡើងដល់មហាជនក្នុងទីនោះដ៏ច្រើនលើសលប់ ។

(២) **ជីវកកោមារភត្ត** ជាបុត្ររបស់នាងគណិកាឈ្មោះ **សាលវតី** ត្រូវម្តាយឱ្យស្រីបម្រើនាំមកចោលក្នុងគំនរសម្រាម អភយរាជកុមារទ្រង់នាំទៅចិញ្ចឹមទុកជាឱរស ជ្រើសរើសនាមថា **ជីវកៈ** កាលមានអាយុ ១៦ ឆ្នាំ ទៅរៀនវិជ្ជាពេទ្យនៅក្រុងតក្កសីលា ៧ ឆ្នាំ រៀនចប់ហើយបានព្យាបាលសេដ្ឋី គហបតីអ្នកនគរសាកេតក្រុងពារាណសី និងរាជគ្រឹះ ឱ្យជាសះស្បើយច្រើននាក់ ទាំងបានព្យាបាលព្រះបាទចណ្ឌបជោតិ ព្រះរាជានៃក្រុងឧជ្ជេនីឱ្យជាអំពីរោគ រហូតទ្រង់សប្បាយព្រះអង្គា **ព្រះបាទចណ្ឌបជោតិ** ព្រះរាជទានសំពត់សិវេយ្យកៈ អំពី

**ដែនសីពី ១ គូ** កាត់ថ្លៃមិនបាន ដល់ពេទ្យជីវកកោមារភត្ត ។

សម័យនោះ ព្រះសាស្តាគង់នៅលើភ្នំគិជ្ឈកូដ ពេទ្យជីវកផ្សំភេសជ្ជៈថ្វាយការបញ្ចុះលាមកក្នុងព្រះវរកាយចំពោះព្រះសាស្តា ទើបបានទទួលតែងតាំងអំពីព្រះបាទពិម្ពិសារ ឱ្យជាពេទ្យប្រចាំវាំង ដើម្បីថ្វាយឱសថដល់ព្រះសាស្តា ។ កាលព្រះសាស្តាទ្រង់ស្បើយចាករោគ ជាប្រក្រតីហើយ ជីវកកោមារភត្តថ្វាយសំពត់សាច់ដ៏ល្អគូនោះដល់ព្រះសាស្តា និងសូមឱ្យទ្រង់អនុញ្ញាតគហបតីចីវរដល់សង្ឃផង ។ ព្រះអង្គទ្រង់ទទួលសំពត់សីពីគូនោះហើយ ទ្រង់ចង្អុលបង្ហាញជីវកកោមារភត្តឱ្យឃើញច្បាស់ ឱ្យសមាទាន ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយធម្មីកថា **ហើយទ្រង់អនុញ្ញាតគហបតីចីវរដល់សង្ឃ** ។

ក្រោយអំពីស្តាប់ព្រះធម្មទេសនាហើយ ទេព្យជីវកបានសម្រេចសោតា-បត្តិផល ទូលថ្វាយចំការស្វាយឱ្យជាព្រះអារាម ឱ្យសាងព្រះគន្ធកុដិសម្រាប់ព្រះពុទ្ធអង្គ សាងកុដិ និងមណ្ឌប ទីសម្រាកពេលថ្ងៃ និងពេលយប់ក្នុងអម្ពវ័ននោះស្រេចហើយអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយភត្តាហារ ព្រមទាំងចីវរ ហើយស្រោចទឹកទក្ខិណោទកថ្វាយវិហារចំពោះព្រះសាស្តា ព្រះអង្គទ្រង់ទទួលអនុមោទនា ។ តមកកាលព្រះអង្គគង់នៅព្រះវិហារជេតវ័ន ទ្រង់បានសរសើរពេទ្យជីវកកោមារភត្តថា ជាកំពូលជាងឧបាសកទាំងពួង អ្នកញ៉ាំងពួកជនឱ្យកើតសេចក្តីជ្រះថ្លា ។

ព្រះសម្ពុទ្ធទ្រង់គង់ក្នុងអម្ពវ័នរបស់ពេទ្យជីវកកោមារភត្តម្តងម្កាល ចន្លោះ

ពេលដែលគង់នៅក្នុងអម្ពវ័ន ព្រះអង្គទ្រង់សម្តែង **បឋម-ទុតិយជីវកម្ពវនសូត្រ** ដល់ភិក្ខុទាំងឡាយថា ឱ្យចម្រើនសមាធិ កាលបើចិត្តតាំងមាំហើយ សភាវៈទាំងពួងរមែងប្រាកដតាមសេចក្តីពិតថា មិនទៀង គឺ ចក្ខុ រូប ចក្ខុវិញ្ញាណ សោត ឃាន ជិវ្ហា កាយ និងចិត្ត រមែងប្រាកដតាមពិតថា មិនទៀង ។ និងត្រាស់ថា អ្នកទាំងឡាយចូរពួនសម្ងំបំពេញសេចក្តីព្យាយាម ព្រោះភិក្ខុកាលពួនសម្ងំ មានចិត្តតាំងមាំ មានសតិសម្បជញ្ញៈ សភាវៈទាំងពួងរមែងប្រាកដច្បាស់តាមពិត ។

ខណៈដែលព្រះអង្គគង់នៅក្នុងជីវកម្ពវ័ន ពេទ្យជីវកចូលទៅគាល់ព្រះមានព្រះភាគ ដល់ទីប្រថាប់ទូលសួរថា ខ្ញុំព្រះអង្គបានស្តាប់មកថា ជនទាំងឡាយសម្លាប់សត្វឧទ្ទិសចំពោះព្រះគោតម ព្រះសមណគោតមសូម្បីដឹងដូច្នោះ ក៏នៅតែសោយសាច់ដែលគេធ្វើចំពោះខ្លួន ការពោលដូច្នេះឈ្មោះថា ពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិត ពិតមែនឬ ? ព្រះអង្គត្រាស់ថា ម្នាលជីវក ជនទាំងនោះឈ្មោះថា ពោលបង្កាច់តថាគតដោយពាក្យមិនពិត តថាគតពោលត្រឹមតែថា **សាច់ដែលមិនគួរបរិភោគ ៣** ប្រភេទគឺ **សាច់ដែលខ្លួនឃើញ ១ សាច់ដែលខ្លួនបានឮ ១ សាច់ដែលខ្លួនសង្ស័យ ១** ម្នាលជីវក អ្នកណាសម្លាប់សត្វចំពោះតថាគត ឬសាវ័ករបស់តថាគត អ្នកនោះរមែងជួបបាបជាច្រើនដោយហេតុ ៥ ប្រការ គឺ សត្វនោះកាលត្រូវគេចងកនាំមក ១ កាលត្រូវបញ្ជាឱ្យសម្លាប់ ១ កាលកំពុងត្រូវសម្លាប់ ១ សត្វនោះរមែងសោយទុក្ខទោមនស្ស ហើយញ៉ាំងឱ្យតថាគត និងសាវ័កតថាគត ឱ្យត្រេកអរដោយ-

សាច់ជាអកប្បិយៈ ១ និងសម្លាប់ចំពោះតថាគត និងសាវ័ក ១ អ្នកនោះរមែងជួបបាប មិនជាបុណ្យឡើយ ។

(៣) តពីនោះ ស្ដេចពុទ្ធដំណើរទៅកាន់ទក្ខិណាគីរីជនបទ ទតឃើញថ្នាលស្រែរបស់អ្នកដែនមគធៈ ពូនដីលើកភ្លឺជាតារាង ៤ ជ្រុង ទាំងបណ្ដោយ និងទទឹង ទើបត្រាស់ឱ្យព្រះអានន្ទធ្វើការកាត់ដេរចីវរឱ្យជាតារាង ៤ ជ្រុង ដូចជាថ្នាលស្រែរបស់អ្នកមគធៈ , ព្រះអានន្ទថ្វាយចីវរដែលកាត់ដេរស្រេចហើយ ឱ្យទ្រង់ទត ព្រះអង្គទ្រង់ពេញព្រះទ័យ និងអនុញ្ញាតឱ្យប្រើសំពត់ ៣ ផ្ទាំង គឺ **សង្ឃាដិមួយជាន់ ១ ចីវរ ១ ស្បង់ ១** ។ តមកទ្រង់អនុញ្ញាតត្រៃចីវរ គឺ **សំពត់សង្ឃាដិពីរជាន់ ១ ចីវរ ១ ស្បង់ ១** ទាំងនេះដើម្បីឱ្យភិក្ខុប្រើសម្រាប់ការពាររងា ហើយត្រាស់ថា ភិក្ខុមិនគប្បីមានចីវរច្រើនជាងនេះ ភិក្ខុណាមានគប្បីពិន័យអាបត្តិតាមធម៌វិន័យ (គឺចីវរអាចជានិស្សគ្គីយ៍ បើលោកមិនឈ្លាស) ។

សម័យតមក មានអ្នកប្រគេនចីវរដល់ព្រះអានន្ទ លោកបំណងនឹងប្រគេនចីវរនោះដល់ព្រះសារីបុត្រ តែខណៈនោះ ព្រះសារីបុត្តនៅដែនសាកេត ទើបព្រះអានន្ទចូលទៅទូលសួរថា គប្បីបដិបត្តិដូចម្ដេចចំពោះអតិរេកចីវរ (ចីវរដែលមានលើសសំពត់ដែលអធិដ្ឋានជាត្រៃចីវរ) ព្រះមានព្រះភាគសួរព្រះអានន្ទថា ប៉ុន្មានថ្ងៃទៀតសារីបុត្តត្រឡប់មក ព្រះអានន្ទទូលថា ប្រមាណជា ១០ ថ្ងៃទៀត ព្រះអង្គ ! ទ្រង់មានពុទ្ធប្បញ្ញត្តិឱ្យរក្សា **អតិរេកចីវរបានត្រឹម ១០ ថ្ងៃ** និងអនុញ្ញាតឱ្យភិក្ខុ **វិកប្បអតិរេកចីវរ** គឺធ្វើឱ្យជារបស់មានម្ចាស់ពីរ ដើម្បីមិន

ត្រូវអាបត្តិ ព្រោះការរក្សាទុកលើសកំណត់ ។

ក្នុងវេលាតមក មានចីវរច្រើនប្រភេទកើតឡើងដល់សង្ឃ ភិក្ខុទាំងឡាយមិនទុកចិត្តថា ចីវរប្រភេទណាដែលទ្រង់អនុញ្ញាត ទើបក្រាបទូលរឿងនោះចំពោះព្រះសាស្ដា ព្រះអង្គត្រាស់ថា តថាគតអនុញ្ញាតចីវរ ៦ ប្រភេទ គឺ **ចីវរធ្វើដោយសំបកឈើ ១ ធ្វើដោយកប្បាស ១ ធ្វើដោយសូត្រ ១ ធ្វើដោយរោមសត្វ ១ ធ្វើដោយសំបកធ្មៃ ១ និងធ្វើដោយរបស់លាយគ្នា ១ ។**

( ៤ ) ក្រោយពីនោះ ព្រះសាស្ដាយាងទៅក្រុងពារាណសី ព្រមដោយសង្ឃសាវ័ក គង់ក្នុងឥសិបតនមិគទាយវ័ន ឧបាសិកាឈ្មោះ **សុប្បិយា** ទៅកាន់វិហារដើម្បីសួរសុខទុក្ខព្រះសង្ឃអាពាធ ភិក្ខុមួយរូបពោលថា អាត្មាត្រូវការទឹកស្ងោសាច់ ដើម្បីនាំមកផ្សំភេសជ្ជៈ ទើបនាងត្រឡប់ទៅវិញ ហើយបញ្ជាទាសីឱ្យចេញទៅរកទិញសាច់ ក្នុងថ្ងៃនោះជាថ្ងៃឧបោសថ ទើបមិនមានសាច់លក់ នាងដឹងហើយទើបប្រើកាំបិតចៀសាច់ភ្លៅរបស់ខ្លួន ឱ្យគេនាំទៅស្ងោ ហើយឱ្យនាំយកទៅប្រគេន, ខ្លួនឯងប្រើសំពត់រុំភ្លៅចូលទៅដេកក្នុងបន្ទប់ កាលស្វាមីត្រឡប់មកជ្រាបសេចក្ដីហើយ រឹតតែត្រេកអរក្នុងការធ្វើទានរបស់ភរិយា ទើបទៅគាល់ព្រះសាស្ដា ទូលនិមន្តឱ្យទទួលភត្តាហារក្នុងផ្ទះរបស់ខ្លួន, ព្រឹកឡើងក្រោយភត្ត-កិច្ច ព្រះសាស្ដាអនុមោទនាហើយ ត្រាស់សួររកនាងសុប្បិយា ទ្រង់ដឹងថា នាងឈឺ ទើបត្រាស់ឱ្យនាំនាងចេញមកគាល់ ខណៈដែលនាងឃើញព្រះសាស្ដានោះឯងមុខដំបៅត្រង់ភ្លៅក៏សះជាប្រក្រតី ព្រះសាស្ដាត្រាស់សួរដល់មូលហេតុ ទ្រង់ជ្រាប

ហើយ ទ្រង់យាងត្រឡប់មកហៅប្រជុំសង្ឃ សាកសួរថាភិក្ខុណា សូមទឹកស្ងោសាច់អំពីនាងសុប្បិយា ភិក្ខុនោះទូលទទួលថា ខ្ញុំព្រះអង្គសូម ព្រះសាស្ដាទ្រង់តិះដៀលការធ្វើដូច្នោះថាមិនសមគួរ ទើបទ្រង់បញ្ញត្តសិក្ខាបទហាមភិក្ខុឆាន់ **សាច់មនុស្ស** អ្នកប្រព្រឹត្តល្មើសត្រូវអាបត្តិថុល្លច្ច័យ, ក្រៅពីនោះថែមទាំងទ្រង់បញ្ញត្តហាមភិក្ខុមិនឱ្យឆាន់សាច់ ៩ យ៉ាងទៀត គឺ **សាច់ដំរី សាច់សេះ សាច់ឆ្កែស្រុក សាច់ឆ្កែព្រៃ សាច់ពស់ រាជសីហ៍ សាច់ខ្លាធំ សាច់ខ្លាដំបង សាច់ខ្លារខិន** ភិក្ខុណាឆាន់ត្រូវអាបត្តិទុក្កដ បន្ទាប់មក ទើបទ្រង់យាងមកកាន់ក្រុងរាជគ្រឹះវិញ។

## ក្រោយអំពីចេញព្រះវស្សាទី ៤ ហើយ

(៥) ព្រះសាស្ដាពុទ្ធដំណើរទៅក្រុងកបិលពស្តុ ក្រោយអំពីទ្រង់ដឹងថាព្រះពុទ្ធបិតាទ្រង់ប្រឈួនធ្ងន់ ព្រះអង្គសម្ដែង **អនិច្ចតាទិធម្មសូត្រ** ពោលអំពីសង្ខារទាំងឡាយមិនទៀងជាទុក្ខ ធម៌ទាំងឡាយជាអនត្តា ប្រោសពុទ្ធបិតាឱ្យបាន **សម្រេចព្រះអរហត្ត នឹងបរិនិព្វាន** តមកមិនហួស ៧ ថ្ងៃ , ក្នុងសៀវភៅ **ជិនមហានិទាន** និងសៀវភៅ **ព្រះសាវ័កនិព្វាន**[១] សរសេរថា ព្រះអង្គស្ដេចគង់ក្នុងនិគ្រោធារាម ដើម្បីធ្វើការបូជាព្រះសពព្រះពុទ្ធបិតា ទ្រង់ប្រោសឱ្យព្រះ-មហាកស្សប ពិចារណាកន្លែងធ្វើជើងថ្ករ ឱ្យព្រះសារីបុត្រទទួលភារៈក្នុងការ

---

[១] សៀវភៅទាំងពីរនេះ មានជាភាសាថៃ ដែលគេបានចងក្រងទុកយូរហើយ

ស្រង់ជម្រះព្រះសព                    កាលដើងថ្កររសម្រេចហើយ

ព្រះអង្គទ្រង់លើកព្រះសិរសា

ព្រះពុទ្ធបិតាហើយស្រោចទឹកស្រង់ព្រះសិរសាបណ្តើរត្រាស់ថា **បុគ្គលណាមានចិត្តប្រាថ្នាព្រះពោធិញ្ញាណ ចូរឧស្សាហ៍អភិបាលបម្រុងមាតាបិតា ប្រព្រឹត្តកុសលសុចរិតធម៌ នឹងសម្រេចតាមបំណងគ្រប់ប្រការ ។**

ព្រះសាស្តាទ្រង់ជាប្រធានថ្វាយភ្លើងព្រះសព ព្រះមហាបជាបតិគោតមី ព្រមទាំងបណ្តាព្រះញាតិ ៦ ព្រះនគរ ចូលគាល់ថ្វាយព្រះភ្លើងតាមលំដាប់ ព្រះអង្គទ្រង់សម្តែង **អនិច្ចតាទិធម្មសូត្រ** ម្តងទៀត ដើម្បីរម្ងាប់សេចក្តីសោករបស់មហាជន មានអ្នកសម្រេចធម៌ជាច្រើន, ព្រះញាតិទាំងឡាយ **បំពេញទក្ខិណានុប្បទាន** ឧទ្ទិសថ្វាយដោយកតញ្ញូតាធម៌ ព្រះអង្គទ្រង់ត្រាស់អនុមោទនាហើយ យាងត្រឡប់មកកាន់និគ្រោធារាមវិញ (គេធ្វើទក្ខិណានុប្បទានដោយការដឹងគុណ) ។

(៦) ក្រោយអំពីថ្វាយភ្លើងព្រះសពហើយ ព្រឹកឡើងយាងទៅហាមពួកសក្យៈ និងពួកកោលិយៈ ដែលបោះបន្ទាយនៅមាត់ស្ទឹងរោហិណីទាំងសងខាង កើតវិវាទក្នុងរឿងដណ្តើមទឹកស្រែគ្នា ឈ្លោះនិងវាយតប់គ្នារាលដាលរហូតដល់ជាតិត្រកូល វាយកម្លាំងទ័ព ច្បាំងគ្នាដូចជាសង្គ្រាម ព្រះអង្គទ្រង់ជ្រាបថា បើព្រះអង្គយាងទៅ ការវិវាទគ្នានឹងស្ងប់ ទាំង ២ ខាង កាលបានស្តាប់ព្រះធម្មទេសនាហើយ នឹងថ្វាយព្រះរាជកុមារឱ្យបួស សមាគមធំនឹងមានព្រោះហេតុនៃការសាមគ្គី ។ កាលព្រះអង្គយាងមកដល់ ត្រាស់សួរថា ពួកអ្នកកើតវិវាទគ្នា

ដោយហេតុអ្វី ? ក្សត្រទាំង ២ ផ្នែកក្រាបទូលមូលហេតុនៃការវិវាទ ព្រះសាស្តាត្រាស់ថា ម្នាលមហារាជទាំងឡាយ ដូចម្តេចក៏ពួកមហាបពិត្រ នឹងញ៉ាំងក្សត្រដែលកាត់ថ្លៃមិនបានឱ្យវិនាស ដោយហេតុនៃទឹកដែលមានតម្លៃបន្តិចបន្តួចសោះ ហើយត្រាស់ **ផន្ទនជាតក ទុទ្ទុភាយជាតក និងលដុកិកជាតក** ដើម្បីរម្ងាប់ការឈ្លោះវិវាទគ្នា. ហើយត្រាស់ **រុក្ខធម្មជាតក និងវដ្តកជាតក** ឱ្យកើតការសាមគ្គីព្រមព្រៀមគ្នាថា ពួកញាតិដែលមានច្រើនរឹតតែល្អក្រៃលែង ដើមឈើដែលកើតក្នុងព្រៃ សូម្បីធំជាម្ចាស់ព្រៃ បើតាំងនៅម្នាក់ឯង រមែងត្រូវកម្លាំងខ្យល់បំបាក់បាន ជាដើម។ ក្នុងទីបំផុតត្រាស់ **អត្តទណ្ឌសូត្រថា** តថាគតបានឃើញពួកសត្វកំពុងបម្រាស់នឡៀលដោយតណ្ហា និងទិដ្ឋិ ដូចត្រីក្នុងថ្លុកមានទឹកតិច ភ័យបានចូលមកដល់យើងហើយ ព្រោះបានឃើញមនុស្សទាំងឡាយខឹងគ្នានិងគ្នា អ្នកចូរធ្វើកិលេសក្នុងអតីតៈឱ្យរីងស្ងួតកិលេសក្នុងអនាគតកុំឱ្យមាន បច្ចុ-ប្បន្នគប្បីមានសតិតាំងមាំ សិក្សាត្រៃសិក្ខាដើម្បីកម្ចាត់ធូលីទាំងឡាយ អ្នកនឹងជាអ្នកស្ងប់ត្រាច់ទៅ ។

(៧) ក្សត្រទាំងពីរខាងស្តាប់ព្រះធម្មទេសនាហើយ នាំគ្នាបោះអាវុធចោល នមស្ការព្រះពុទ្ធអង្គហើយពោលថា ប្រសិនបើព្រះអង្គមិនយាងមក ពួកខ្ញុំព្រះអង្គក៏នឹងកាប់សម្លាប់គ្នារហូតឈាមហូរជាស្ទឹង ពួកខ្ញុំព្រះអង្គបានរួចរស់ជីវិតក៏ដោយអាស្រ័យព្រះអង្គពិត កាលបានជ្រាបថា ក្នុងអតីតៈធ្លាប់ជាព្រះញាតិនឹងគ្នា ទើបថ្វាយរាជកុមារ ៥០០ គឺ កុមារស្តេចសក្យៈ ២៥០ និង កុមារស្តេចកោ-

លិយៈ ២៥០ ឱ្យបួសក្នុងព្រះសាសនា ព្រះអង្គទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ដល់រាជកុមារទាំងអស់ ។ ចាប់ផ្ដើមពីព្រឹកឡើង ព្រះមានព្រះភាគមានភិក្ខុទាំងនោះជាបច្ឆាសមណៈ យាងត្រាច់បិណ្ឌបាតក្នុងព្រះនគរទាំងពីរ ជួនកាលយាងទៅដែនកបិលពស្តុ ជួនកាលយាងទៅដែនទេវទហៈ. ពួកភិក្ខុទាំងនោះមិនបានបួសដោយសទ្ធា ទើបគិតចង់សឹក សូម្បីរាជកុមារីទាំងនោះក៏នៅទាក់ទង និងផ្ញើសំបុត្រទៅបបួលឱ្យសឹក ធ្វើឱ្យកើតការនឿយណាយក្នុងសមណភេទខ្លាំងឡើង ព្រះអង្គទ្រង់ជ្រាបការរសាប់រសល់របស់ពួកភិក្ខុ ទើបនាំភិក្ខុរាជកុមារទៅស្រះតាវ៉ៅដោយអានុភាពរបស់ព្រះអង្គ ភិក្ខុទាំងនោះបានឃើញទឹកន្លែង និងវត្ថុដ៏គួរមនោរម្យ សេចក្ដីត្រេកអរក្នុងព្រះជាយាក៏សាបសូន្យទៅ ព្រះសាស្ដាទើបត្រាស់ **កុណាលជាតក** បង្ហាញឱ្យឃើញទោសរបស់មាតុគ្រាម តាមពាក្យពេចន៍របស់សត្វតាវ៉ៅឈ្មោះកុណាល ភិក្ខុទាំងនោះបានសម្រេចសោតាបត្តិផល ព្រមដោយឫទ្ធិដែលសម្រេចដោយមគ្គ ។ បន្ទាប់មក ទ្រង់នាំភិក្ខុទាំងឡាយទៅកាន់ព្រៃហិមពាន្ត ត្រាស់កម្មដ្ឋានដើម្បីឱ្យសម្រេចមគ្គខាងលើ ហើយទ្រង់សម្ដែងអរិយសច្ច ៤ ភិក្ខុ ៥០០ រូបនោះចម្រើនវិបស្សនា តាំងនៅក្នុងអរហត្តផល ព្រមដោយបដិសម្ភិទា ៤ ព្រះមានព្រះភាគគង់នៅក្នុងព្រៃហិមពាន្តជាមួយភិក្ខុ ៥០០ រូបនោះអស់មួយរយៈពេល ហើយទើបយាងត្រឡប់មកកាន់និគ្រោធារាម ភិក្ខុទាំងនោះកាលដែលទៅ គឺទៅដោយអានុភាពរបស់ព្រះអង្គ តែក្នុងពេលត្រឡប់វិញត្រឡប់មកដោយអានុភាពរបស់ខ្លួនឯងផ្ទាល់ ។

អដ្ឋកថាពោលថា ពួកទេវតាជុំវិញព្រៃធំនោះ នាំគ្នាមកនមស្ការព្រះពុទ្ធអង្គ និងពួកព្រះខីណាស្រពទើបបានសម្រេចព្រះអរហត្តក្នុងខណៈនោះ បានឈរនៅក្នុងទីដ៏សមគួរមួយ បន្ទាប់មកពួកទេវតាក្នុងសែនចក្រវាឡមកប្រជុំគ្នា ព្រោះបានស្តាប់សំឡេងទេវតាទាំងនោះដោយលំដាប់ មានទេវតាក្នុងជម្ពូទ្វីប បុព្វវិទេហទ្វីប អមរគោយានទ្វីប និងឧត្តរកុរុទ្វីបជាដើម ចក្រវាឡទាំងអស់រហូតព្រហ្មលោកចង្អៀតណែនទៅដោយទេវតាដែលមកប្រជុំគ្នា ក្នុងព្រៃធំជិតក្រុងកបិលពស្តុ។

ព្រះមានព្រះភាគទតឃើញការប្រជុំរបស់ទេវតាហើយ ទ្រង់ព្រះតម្រិះថា ពួកភិក្ខុទាំងនេះមិនដឹងថា មានសមាគមទេវតាធំយ៉ាងនេះ តថាគតនឹងពោលដល់ឈ្មោះ និងគោត្ររបស់ពួកទេវតាទាំងអស់ ដែលមកប្រជុំគ្នាក្នុងសមាគមនេះ តមកក៏ទ្រង់ពិចារណាធម្មទេសនាដ៏សមគួរដល់ចរិតទេវតាទាំងនោះ ដូចជាពួកទេវតារាគចរិត ក៏សម្តែង **សម្មាបរិព្វាជនីយសូត្រ** ពួកទោសចរិតក៏សម្តែង **មហាព្យូហសូត្រ** ពួកមោហចរិតក៏សម្តែង **ចូឡព្យូហសូត្រ** ជាដើម, កាលព្រះមានព្រះភាគទ្រង់សម្តែង **មហាសមយសូត្រ** ចប់ ទេវតាបានសម្រេចព្រះអរហត្តជាច្រើន ចំណែកអ្នកបានជាសោតាបន្នប្រមាណមិនបាន ព្រោះអត្ថជាទីស្រឡាញ់ពេញចិត្ត និងត្រូវអធ្យាស្រ័យរបស់ពួកទេវតាទាំងឡាយ ។ ឯព្រះជាយារាជកុមារី ៥០០ នោះ ក៏បំណងនឹងចេញបួស នាំគ្នាទៅគាល់ព្រះនាងមហាបជាបតិគោតមី ។

(៨) **ព្រះនាងមហាបជាបតិគោតមី** ព្រមដោយសាកិយានីជាបរិវារ ចូលទៅគាល់ព្រះពុទ្ធអង្គនៅវិហារនិគ្រោធារាម ទូលសូមបួសក្នុងព្រះធម្មវិន័យ ព្រះមានព្រះភាគត្រាស់ហាមថា ម្នាលគោតមី នាងកុំត្រេកអរក្នុងការដែលស្ត្រីចេញចាកផ្ទះបួសជាបព្វជិត ក្នុងព្រះធម្មវិន័យដែលតថាគតប្រកាសនេះឡើយ ព្រះនាងមហាបជាបតីគោតមីទូលសូមអស់ ៣ ដង ព្រះមានព្រះភាគក៏ទ្រង់មិនអនុញ្ញាត ព្រះនាងមហាបជាបតិគោតមីទ្រង់តូចព្រះទ័យ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយយាងត្រឡប់ទៅកាន់រាជត្រកូល, បន្ទាប់មក ព្រះសាស្តាយាងចារិកទៅកាន់ក្រុងវេសាលី ទាល់តែវេលាជិតចូលព្រះវស្សា ។

---

**កាលទាំងឡាយតែងតែកន្លងផុតទៅ រាត្រីទាំងឡាយតែងតែ**
**ឆ្លងហួសទៅ ជំនាន់នៃវ័យទាំងឡាយ តែងតែលះបង់ទៅ-**
**ជាលំដាប់ កាលបើបុគ្គលសម្លឹងឃើញភ័យនុ៎ះ ក្នុងសេចក្តីស្លាប់**
**ហើយ គប្បីលះបង់នូវអាមិសក្នុងលោកនេះចេញ ហើយសម្លឹង**
**យកនូវសន្តិបទ គឺ ព្រះនិព្វាន ។** (សំយុត្តនិកាយ សគាថវគ្គ)

# ព្រះវស្សាទី ៥

## ទ្រង់គង់ចាំព្រះវស្សា ក្នុងគោជាគារសាលា ព្រៃមហាវ័ន ក្រុងវេសាលី

### ព្រះអង្គយាងមកគង់ក្នុងគោជាគារសាលាដំបូង

(១) **ព្រះនាងមហាបជាបតិគោតមី** តូចព្រះទ័យក្នុងការដែលព្រះ-អង្គបដិសេធ ទើបកោរព្រះកេសាទ្រង់គ្រងសំពត់កាសាវៈ កាន់ភេទបព្វជ្ជាឧទ្ទិសចំពោះព្រះទសពល ខាងក្នុងព្រះរាជនិវេសន៍នោះឯង ទ្រង់ឱ្យសាកិយានីទាំង ៥០០ ជាព្រះជាយារបស់សក្យកុមារ ៥០០ ដែលចេញបួសត្រង់មាត់ស្ទឹងរោហិណី កាន់ភេទបព្វជ្ជាដូចគ្នា ហើយនាំពួកសាកិយានីទាំងនោះ យាងតាមព្រះសាស្ដាទៅកាន់ក្រុងវេសាលី ព្រះនាងមានព្រះបាទទាំងពីរពង មានព្រះវរកាយប្រឡាក់ប្រឡូសដោយធូលី ទ្រង់ជាទុក្ខតូចព្រះទ័យ មានព្រះភក្ត្រជោគដោយទឹកព្រះ-នេត្រ ទ្រង់ឈរព្រះកន្សែងត្រង់ក្លោងទ្វារខាងក្រៅ ។

ព្រះអានន្ទឃើញព្រះនាងឈរព្រះកន្សែង បានចូលទៅសាកសួរសេចក្ដីដឹងថាព្រះពុទ្ធអង្គមិនទ្រង់អនុញ្ញាតឱ្យស្ត្រីបានបួស ទើបទូលឱ្យព្រះនាងរង់ចាំសិនបន្ទាប់មក ព្រះអានន្ទចូលទៅក្រាបទូលព្រះសាស្ដា សូមឱ្យទ្រង់អនុញ្ញាតស្ត្រីបានបួសជាបព្វជិត ព្រះអានន្ទទូលសូមអស់ ៣ ដង ព្រះសាស្ដាក៏ទ្រង់មិនអនុញ្ញាត

ទើបព្រះអានន្ទទូលសួរព្រះពុទ្ធអង្គថា ការដែលស្ត្រីចេញចាកផ្ទះ បួសជាបព្វជិត អាចនឹងធ្វើឱ្យជាក់ច្បាស់នូវមគ្គផលនិព្វានបានឬទេ ព្រះអង្គ ? ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ស្ត្រីអាចធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល សកទាគាមិផល អនាគាមិផល ឬអរហត្តផលបាន ។ ទើបព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី ជាព្រះមាតុច្ឆារបស់ព្រះអង្គ ជាអ្នកមានឧបការៈច្រើន ទ្រង់ទំនុកបម្រុងបីបាច់រក្សា ទ្រង់ថ្វាយខីរធារាកាលព្រះជនីសោយព្រះវិលាល័យ សូមប្រទានវរោកាស ទ្រង់អនុញ្ញាតឱ្យព្រះនាងបានបួសជាបព្វជិតក្នុងព្រះធម្មវិន័យដែលព្រះតថាគតប្រកាសហើយចុះ ព្រះអង្គ ! ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ហេតុដែលតថាគតមិនអនុញ្ញាត ព្រោះឃើញថា ប្រសិនបើអនុញ្ញាតឱ្យស្ត្រីបួស ព្រះធម្មវិន័យនេះនឹងតាំងនៅមិនបានយូរ តែតថាគតនឹងបញ្ញត្តគរុធម៌ ៨ ប្រការនេះ ប្រៀបដូចជារាំងទំនប់ស្រះទឹកដ៏ធំទុកជាមុន ដើម្បីមិនឱ្យទឹកហូរចេញដូច្នោះ ហើយត្រាស់ថា ប្រសិនបើព្រះនាងព្រមទទួលគរុធម៌នេះបាន ធម៌នោះនឹងជាឧបសម្បទារបស់ព្រះនាង ។

ព្រះអានន្ទរៀនគរុធម៌ ៨ ប្រការនោះហើយ ចេញមកប្រកាសប្រាប់ដល់ព្រះនាងមហាបជាបតិគោតមីថា ប្រសិនបើព្រះនាងព្រមទទួលគរុធម៌ ៨ ប្រការដែលព្រះអង្គទ្រង់បញ្ញត្តទុកបាន ធម៌នោះឯងនឹងជាឧបសម្បទារបស់ព្រះនាង ។ ទោមនស្សរបស់ព្រះនាងមហាបជាបតិគោតមី ស្ងប់ភ្លាមមួយរំពេច មានចិត្ត

រីករាយពោលថា បពិត្រព្រះអានន្ទ ខ្ញុំម្ចាស់ព្រមទទួលគរុធម៌ ៨ ប្រការ ទើបព្រះអានន្ទសម្តែងគរុធម៌ដែលព្រះអង្គទ្រង់បញ្ញត្តហើយ ដូច្នេះគឺ :

១. ភិក្ខុនីទោះបីមានវស្សា ១០០ ត្រូវថ្វាយបង្គំភិក្ខុសូម្បីបួសក្នុងថ្ងៃនោះ ។

២. ភិក្ខុនីមិនគប្បីនៅចាំវស្សា ក្នុងអាវាសដែលមិនមានភិក្ខុ ។

៣. ភិក្ខុនីត្រូវខ្វល់ខ្វាយធម៌ ២ ប្រការគឺ សួរថ្ងៃឧបោសថ ១ ចូលទៅស្តាប់ឱវាទអំពីភិក្ខុសង្ឃរាល់កន្លះខែ ១ ។

៤. ភិក្ខុនីចេញវស្សាហើយ ត្រូវបវារណាក្នុងសង្ឃទាំងពីរផ្នែក ។

៥. ភិក្ខុនីត្រូវអាបត្តិសង្ឃាទិសេសហើយ ត្រូវប្រព្រឹត្តបក្ខមានត្ត ក្នុងសង្ឃទាំងពីរ ។

៦. ភិក្ខុនីត្រូវស្វែងរកឧបសម្បទាឱ្យដល់សិក្ខមានា អ្នកសិក្សាក្នុងធម៌ ៦ អស់ ២ ឆ្នាំហើយ ក្នុងសំណាក់សង្ឃទាំងពីរ ។

៧. ភិក្ខុនីមិនគប្បីជេរភិក្ខុ ដោយបរិយាយណាមួយឡើយ ។

៨. ភិក្ខុនីមិនគប្បីទូន្មានភិក្ខុ តែឱ្យភិក្ខុប្រដៅភិក្ខុនីបាន ។

ព្រះនាងមហាបជាបតិគោតមីពោលថា បពិត្រព្រះអានន្ទ ខ្ញុំម្ចាស់ព្រមទទួលគរុធម៌ ៨ ប្រការនេះគ្រប់យ៉ាង នឹងមិនល្មើសអស់មួយជីវិត ព្រះនាងមហាបជាបតិគោតមី បានបួសហើយ **ដោយការទទួលគរុធម៌ ៨ ប្រការ ជាភិក្ខុនីអង្គដំបូងក្នុងព្រះពុទ្ធសាសនា ។**

(២) បន្ទាប់មក **ទ្រង់មានព្រះពុទ្ធានុញ្ញាតឱ្យភិក្ខុ បំបួសភិក្ខុនីបាន** ព្រះអានន្ទទូលសួរថា ភិក្ខុត្រូវប្រកបដោយធម៌ដូចម្តេច ទើបជាអ្នកទូន្មានភិក្ខុនីបាន ព្រះអង្គត្រាស់ថា ភិក្ខុដែលទូន្មានភិក្ខុនីបាន ត្រូវប្រកបដោយធម៌ ៨ ប្រការគឺៈ

១. ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខ ដល់ព្រមដោយអាចារៈ និង-គោចារៈ មានប្រក្រតីឃើញភ័យក្នុងទោសសូម្បីតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។

២. ជាពហូសូត ទ្រទ្រង់សុត្តៈ ជាអ្នកបានស្តាប់ច្រើន ចងចាំរត់មាត់ ស្ទាត់ជំនាញ ចាក់ធ្លុះយ៉ាងល្អដោយទិដ្ឋិ ។

៣. ជាអ្នកចាំព្រះបាតិមោក្ខទាំង ២ បានដោយពិស្តារ វែកញែកវិនិច្ឆ័យបានត្រឹមត្រូវទាំងដោយសូត្រ និងព្យញ្ជនៈ ។

៤. ជាអ្នកមានវាចាល្អ ច្បាស់លាស់ មិនមានទោស ឱ្យដឹងប្រយោជន៍ ។

៥. ជាអ្នកអាចចង្អុលបង្ហាញឱ្យភិក្ខុនីឃើញច្បាស់ ដោយធម្មីកថា។

៦. ជាទីពេញចិត្តរបស់ភិក្ខុនីដោយច្រើន ។

៧. ជាអ្នកមិនធ្លាប់ត្រូវអាបត្តិធ្ងន់ជាមួយភិក្ខុនី ។

៨. ជាអ្នកមានវស្សា ២០ ឬលើសជាង ។

ព្រះសាស្តាទ្រង់ប្រោសឱ្យភិក្ខុទាំងឡាយ បំបួសសាកិយានីជាភិក្ខុនី ហើយឱ្យជាសាវិកា របស់ព្រះនាងបជាបតិគោតមីភិក្ខុនី បន្ទាប់មក ព្រះមហាបជាបតិ-គោតមីភិក្ខុនី ចូលទៅគាល់ព្រះសាស្តា ទូលសួរដល់សិក្ខាបទរបស់ភិក្ខុនី ព្រះមាន

ព្រះភាគត្រាស់ថា ម្នាលគោតមី ពួកនាងចូរសិក្សាក្នុងសិក្ខាបទដូចភិក្ខុទាំងឡាយ សិក្សាតាមដែលតថាគតបញ្ញត្តទុកហើយនោះ ។ ព្រះមហាបជាបតិគោតមីភិក្ខុនី បានទូលសូមប្រទានឱកាសថា សូមព្រះអង្គទ្រង់សម្តែងធម៌ ខ្ញុំម្ចាស់បានស្តាប់ហើយ នឹងគប្បីជាអ្នកចេញចាកពួក តែម្នាក់ឯង មិនប្រមាទ មានសេចក្តីព្យាយាម មានចិត្តដាច់ស្រឡះចុះ ព្រះអង្គត្រាស់ថា គោតមី នាងគប្បីដឹងធម៌ទាំងនេះ គឺ ធម៌ដែលប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក ដើម្បីមិនប្រកបសត្វទុក ដើម្បីមិនសន្សំកិលេស ដើម្បីការប្រាថ្នាតិច ដើម្បីសេចក្តីសន្តោស ដើម្បីវិវេក ដើម្បីប្រារព្ធសេចក្តីព្យាយាម ដើម្បីជាមនុស្សចិញ្ចឹមងាយ ។ ម្នាលគោតមី នាងគប្បីចងចាំទុកថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ។

ព្រះមហាបជាបតិគោតមីភិក្ខុនី ទទួលកម្មដ្ឋានក្នុងសំណាក់របស់ព្រះ-សាស្តា ត្រឹមតែមួយព្រះអង្គឯង គេចចេញចាកពួកគណៈមិនយូរ ក៏បានសម្រេចអរហត្តផលព្រមដោយបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ។ **បដិសម្ភិទា** គឺ ការបែកធ្លាយ ៤ ប្រការ បានដល់ :

| | |
|---|---|
| **១. អត្ថប្បដិសម្ភិទា** | បែកធ្លាយក្នុងផល |
| **២. ធម្មប្បដិសម្ភិទា** | បែកធ្លាយក្នុងធម៌ |
| **៣. និរុត្តិបដិសម្ភិទា** | បែកធ្លាយក្នុងភាសា |
| **៤. បដិភាណប្បដិសម្ភិទា** | បែកធ្លាយក្នុងបដិភាណ |

**វិមោក្ខ គឺការរួចផុតចាកកិលេសដោយអំណាចនៃសមាបត្តិ ៨ ប្រការគឺ :**

**រូបសមាបត្តិ ៤ អរូបសមាបត្តិ ៤**

**អភិញ្ញា គឺ ការដឹងដ៏ក្រៃលែង ៦ ប្រការបានដល់ :**

**១. ឥទ្ធិវិធិញាណ** ញាណដែលធ្វើឱ្យសម្តែងឫទ្ធិផ្សេងៗ បាន

**២. ទិព្វសោតញាណ** ញាណដែលធ្វើឱ្យមានត្រចៀកទិព្វ

**៣. ចេតោបរិយញ្ញាណ** ញាណដែលកំណត់ចិត្តអ្នកដទៃបាន

**៤. បុព្វេនិវាសានុស្សតិញ្ញាណ** ញាណដែលធ្វើឱ្យរឭកជាតិបាន

**៥. ទិព្វចក្ខុញាណ** ញាណដែលធ្វើឱ្យមានភ្នែកទិព្វ

**៦. អាសវក្ខយញ្ញាណ** ញាណដែលធ្វើឱ្យអាសវៈអស់ទៅ

សម័យដែលព្រះអង្គគង់នៅក្នុងជេតវនវិហារ ទ្រង់លើកតម្កើងព្រះមហាបជាបតិគោតមីថេរីថា **ជាបឋមសាវិកា ដែលជារត្តញ្ញូ** (អ្នកបួសមុនគេ) ។

(៣) បន្ទាប់មកទៀត **ព្រះនាងយសោធរា** ទ្រង់បួសក្នុងសំណាក់របស់ព្រះមហាបជាបតិគោតមីថេរី កាលបួសហើយព្រះនាងយសោធរាមាននាមថា **ព្រះភទ្ទាកច្ចានាភិក្ខុនី** ចម្រើនវិបស្សនា មិនដល់កន្លះខែក៏បានសម្រេចព្រះ-អរហត្ត ជាអ្នកស្ទាត់ជំនាញក្នុងអភិញ្ញាទាំងឡាយ អង្គុយសមាធិមួយគ្រា រឭកជាតិបានដល់ទៅមួយអសង្ខេយ្យ និងមួយសែនមហាកប្ប ក្នុងសម័យដែលព្រះអង្គគង់នៅក្នុងវត្តជេតពន ទ្រង់សរសើរព្រះភទ្ទាកច្ចានាថេរីថា ជាកំពូលជាងភិក្ខុនីសាវិកា ដែលជាអ្នកសម្រេចអភិញ្ញាធំ ។

ក្នុងអង្គុត្តរនិកាយ ឯកនិបាតពោលទុកថា អ្នកសម្រេចអភិញ្ញាធំ ក្នុងសម័យរបស់ព្រះសម្មាសម្ពុទ្ធអង្គនេះមាន ៤ នាក់ គឺ **ព្រះសារីបុត្តត្ថេរ ព្រះមហាមោគ្គល្លានត្ថេរ ព្រះពាកុលត្ថេរ និងព្រះភទ្ទាកច្ចានាថេរី** ដែលរឭកជាតិបានមួយអសង្ខេយ្យ និងមួយសែនមហាកប្ប សាវ័កដ៏សេសអាចរឭកបានត្រឹមតែមួយសែនមហាកប្បប៉ុណ្ណោះ ។

(៤) ព្រះនាងរូបនន្ទា ត្រិះរិះថា ព្រះម្ចាស់បងធំរបស់យើងលះរាជសម្បត្តិចេញបួស បានជាព្រះពុទ្ធក្នុងលោក រាហុលកុមារក៏បួស ម្ចាស់បងនន្ទក៏បួស សូម្បីព្រះមាតា និងព្រះនាងម្ចាស់យសោធរាក៏បួស ក្រោយពីព្រះនន្ទសម្រេចព្រះអរហត្តហើយ ព្រះនាងគិតថា យើងនឹងបួសដែរ ទើបចូលទៅសូមបួសក្នុងសំណាក់របស់ព្រះនាងមហាបជាបតិគោតមីថេរីជាព្រះមាតា ព្រះនាងបួសដោយសេចក្តីស្រឡាញ់ក្នុងព្រះញាតិ មិនបានបួសដោយសទ្ធាទេ ។

រូបនន្ទាភិក្ខុនី ជាអ្នកស្រវឹងក្នុងរូបរបស់ខ្លួនឯង ដឹងថាព្រះអង្គទ្រង់តិះដៀលរូប និងសម្តែងទោសនៃការស្រវឹងក្នុងរូបច្រើន ទើបមិនហ៊ានទៅកាន់សំណាក់ព្រះសាស្តា លុះដល់វេនទៅទទួលឱវាទរបស់ព្រះអង្គ ក៏បញ្ជូនភិក្ខុនីដទៃទៅជំនួស ទើបព្រះមានព្រះភាគត្រាស់ថា កាលដល់វារៈរបស់អ្នកណា អ្នកនោះត្រូវតែមកទទួលឱវាទដោយខ្លួនឯង រូបនន្ទាភិក្ខុនីទើបចូលមកទទួលស្តាប់ឱវាទតាមវេណ ។ ព្រះអង្គទ្រង់ជ្រាបការមករបស់រូបនន្ទាភិក្ខុនី ទ្រង់ព្រះតម្រិះថា ព្រះធម្មទេសនាដូចម្តេចនឹងធ្វើឱ្យនាងដឹងច្បាស់ ទើបនិម្មិតរូបស្ត្រីវ័យជំទង់

១៦ ឆ្នាំ ប្រដាប់ដោយអលង្ការស្រស់ស្អាត ឈរបក់ផ្លិតក្នុងទីជិតព្រះអង្គ ដោយបំណងនឹងសម្តែងទោសនៃសេចក្តីស្រវឹងក្នុងរូប ដូចបុរសត្រូវការជួសបន្ទាដោយបន្លា, រូបនន្ទាភិក្ខុនីសម្លឹងមើលរូបនិមិត្តនោះហើយ សម្លឹងមើលអត្តភាពរបស់ខ្លួន ដឹងថាខ្លួនដូចសត្វក្អែកដែលឈរនៅខាងមុខនាងហង្សមាស គិតថា ស្ត្រីនេះមានរូបស្អាត កើតសេចក្តីស្រឡាញ់ក្នុងរូបនោះយ៉ាងខ្លាំង ក្នុងលម្អរបស់ស្រីក្រមុំនោះ ព្រះសាស្តាទ្រង់ជ្រាប ទើបទ្រង់សម្តែងរូបនោះឱ្យទ្រុឌទ្រោមចុះដោយលំដាប់ ។ ខណៈដែលភិក្ខុនីកំពុងពិចារណា ស្ត្រីនោះក៏ប្តូរភាពជាមនុស្សវ័យកណ្តាលវ័យជរា ត្រូវព្យាធិគ្របសង្កត់ បោះផ្លិតស្លឹកត្នោតចោល ដួលចុះដេកត្រាំក្នុងគំនរមូត្រលាមករបស់ខ្លួនហើយស្លាប់ទៅ ក្លាយជាសាកសពដែលពេញទៅដោយរបស់បដិកូលទាំងឡាយ រូបនន្ទាភិក្ខុនីឃើញអត្តភាពនោះជារបស់មិនទៀងថា ស្រីនេះដល់នូវការចាស់ ឈឺ និងស្លាប់ក្នុងទីនេះ កើតអនិច្ចសញ្ញាថា កាយនេះទាំងរបស់យើង និងអ្នកដទៃក៏មិនទៀងដូចគ្នា កើតទុក្ខសញ្ញា និងអនត្តសញ្ញា ជាបន្តមកទើបព្រះសាស្តាត្រាស់សម្តែងព្រះគាថាថា :

**ម្នាលនន្ទា នាងចូរមើលកាយមិនស្អាត ជារបស់ស្អុយនេះ សរីរៈរបស់ស្រីនោះដូចម្តេច សរីរៈរបស់នាងក៏ដូច្នោះ នាងចូរឃើញធាតុទាំងឡាយជារបស់សូន្យ ចូរផ្តាច់សេចក្តីពេញចិត្តក្នុងភពចេញ នាងនឹងជាអ្នកស្ងប់ត្រាច់ទៅ ។**

រូបនន្ទាភិក្ខុនី បញ្ជូនញាណតាមក្រសែព្រះធម្មទេសនា បានសម្រេចសោតាបត្តិផលហើយ លំដាប់នោះ ព្រះសាស្ដាទ្រង់អប់រំវិបស្សនាដើម្បីមគ្គផលខាងលើ ទើបត្រាស់ថា ម្នាលនន្ទា នាងកុំធ្វើសេចក្ដីយល់ថា សារៈក្នុងកាយនេះមាន សរីរៈនេះដែលកម្មសាងឡើងដោយឆ្អឹង ៣០០ កំណាត់ ចងរឹតដោយខ្សែសរសៃ ៩០០ បូកលាបដោយសាច់ និងឈាម ពាសដោយស្បែក ជាទីធ្លាក់ចុះនៃជរា និងមរណៈ ដែលមានតែការទ្រុឌទ្រោមជាលក្ខណៈ មិនមានខ្លឹមសារណានឹងគប្បីកាន់យកបាន ក្នុងកាលចប់ទេសនា រូបនន្ទាថេរីបានសម្រេចអរហត្តផល ព្រះធម្មទេសនានោះ បានជាប្រយោជន៍ដល់មហាជនជាច្រើនទៀតផង ។

( ៥ ) ខណៈដែលព្រះមានព្រះភាគ គង់នៅក្នុងគោដាគារសាលា ទ្រង់ប្រារព្ធបញ្ហា របស់សក្កទេវរាជដល់មហាជនថា កាលព្រះអង្គគង់នៅក្នុង **ល្អាងឥន្ទសាលៈ** ចន្លោះភ្នំ **វេទយិកៈ** ទិសខាងជើងនៃស្រុកព្រាហ្មណ៍ឈ្មោះ **អម្ពសណ្ឌៈ** ទិសខាងកើតនៃក្រុងរាជគ្រឹះ ទ្រង់ដោះស្រាយបញ្ហាផ្សេងៗ របស់សក្កទេវរាជជាដើមថា :

សក្កទេវរាជទូលសួរថា **ទេវតា មនុស្ស អសុរ នាគ គន្ធព្វ និងសត្វទាំងឡាយ មានអ្វីជាគ្រឿងចង ?** ព្រះមានព្រះភាគទ្រង់ព្យាករណ៍ថា **មានសេចក្ដីច្រណែន និងសេចក្ដីកំណាញ់ជាគ្រឿងចង** , សក្កទេវរាជទូលសួរថា សេចក្ដីច្រណែន និងសេចក្ដីកំណាញ់មានអ្វីជាឫសគល់ មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើត , ក៏កាលអ្វីមាន សេចក្ដីច្រណែន និងសេចក្ដី

កំណាញ់ទើបមាន , ហើយកាលអ្វីមិនមាន សេចក្តីច្រណែន និងសេចក្តីកំណាញ់រមែងមិនមាន ?

ព្រះមានព្រះភាគទ្រង់ព្យាករណ៍ថា សេចក្តីច្រណែន និងសេចក្តីកំណាញ់មានសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ជានិទាន ជាសមុទ័យ ជាកំណើត ជាដែនកើត កាលសេចក្តីស្រឡាញ់ និងសេចក្តីស្អប់នៅមាន សេចក្តីច្រណែន និងសេចក្តីកំណាញ់រមែងមាន កាលមិនមានសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ សេចក្តីច្រ-ណែន និងសេចក្តីកំណាញ់ក៏មិនមានដែរ ។

ក្រៅពីនោះ សក្កទេវរាជទូលសួរបញ្ហាផ្សេងៗ ច្រើនប្រការទៀត កាលព្រះមានព្រះភាគ ទ្រង់ព្យាករណ៍បញ្ហាគ្រប់ ១៤ ខហើយ ធម្មចក្ខុប្រាសចាកធូលីប្រាសចាកមន្ទិល បានកើតឡើងហើយដល់សក្កទេវរាជ ព្រមទាំងទេវតាដទៃទៀតជាច្រើនថា ធម្មជាតិណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតិនោះទាំងអស់មានការរលត់ទៅវិញជាធម្មតា សក្កទេវរាជបានទូលថា ព្រះមានព្រះ-ភាគបានដកកូនសរ គឺសេចក្តីសង្ស័យរបស់ខ្ញុំព្រះអង្គអស់ហើយ បញ្ហាណាដែលសក្កទេវរាជប្រាថ្នាទូលសួរ , ព្រះមានព្រះភាគបានទ្រង់ព្យាករណ៍បញ្ហាទាំងនោះហើយ ទើបឈ្មោះថា **សក្កប្បញ្ហា** ដូច្នេះឯង ។

**មហាលិស្តេចលិច្ឆវី** ទ្រង់ស្តាប់ទេសនាសក្កប្បញ្ហសូត្រ របស់ព្រះសាស្តាហើយ ទ្រង់ត្រិះរិះថា ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្បត្តិរបស់សក្កទេវរាជទុក

យ៉ាងច្រើន ព្រះអង្គទ្រង់ឃើញហើយទើបត្រាស់ ឬមិនទ្រង់ឃើញហើយត្រាស់ ព្រះអង្គទ្រង់ស្គាល់សក្កទេវរាជឬអត់ ហ្ន៎ ?

ទើបស្តេចមហាលិចូលទៅទូលសួរ ព្រះមានព្រះភាគត្រាស់ថា ម្នាលមហាលិ តថាគតស្គាល់ទាំងខ្លួនសក្កទេវរាជ ទាំងធម៌នាំឱ្យបានជាសក្កទេវរាជ ម្នាល មហាលិ សក្កទេវរាជក្នុងកាលមុនកើតជាមនុស្ស បានឱ្យទានដោយគោរព ឱ្យទីស្នាក់អាស្រ័យ សមាទានវត្តបទ ៧ គឺ:

១ ចិញ្ចឹមមាតាបិតាអស់មួយជីវិត

២ ប្រព្រឹត្តឱនលំទោនចំពោះត្រកូលរៀមច្បងអស់មួយជីវិត

៣ និយាយវាចាទន់ភ្លន់អស់មួយជីវិត

៤ មិនពោលវាចាស៊កសៀតអស់មួយជីវិត

៥ មានចិត្តប្រាសចាកសេចក្តីកំណាញ់ ត្រេកអរក្នុងការបរិច្ចាគ និងឱ្យទានអស់មួយជីវិត

៦ និយាយតែពាក្យសត្យអស់មួយជីវិត

៧ ទប់សេចក្តីក្រោធខឹងអស់មួយជីវិត

មឃមាណពសមាទានវត្តបទ ៧ នេះបរិបូណ៌ហើយ ទើបបានជាសក្កទេវរាជ

ក្នុងអដ្ឋកថាសក្កប្បញ្ហសូត្រពោលថា សក្កទេវរាជចុតិចាកអត្តភាពនេះ ហើយ នឹងទ្រង់បានអនាគាមិមគ្គក្នុងអកនិដ្ឋភព ហើយទ្រង់នៅក្នុងជាន់អវិហា មួយពាន់កប្ប ជាន់អតប្បាមួយពាន់កប្ប ជាន់សុទស្សាបួនពាន់កប្ប ជាន់សុទស្សី

៨ ពាន់កប្ប ជាន់អកនិដ្ឋ ១៦ ពាន់កប្ប ទីបំផុតនឹងជាអកនិដ្ឋគាមី ការរិលរល់ស្លាប់កើតក្នុងអាយុស្មើគ្នានេះមានបីនាក់គឺ : **សក្កទេវរាជ អនាថបិណ្ឌិក-សេដ្ឋី និងនាងវិសាខាមហាឧបាសិកា ។**

ក្នុងអដ្ឋកថា **តតិយទេវសូត្រ** ពោលថា មឃមាណព ជាអ្នកស្រុកអចលគ្រាម ដែនមគធៈ ក្នុងអត្តភាពមុនជាមនុស្សឈ្លាសក្នុងកុសល បាននាំមិត្តសម្លាញ់ ៣៣ នាក់ ទៅប្រកបកុសលកម្មដើម្បីប្រយោជន៍ដល់មហាជន នាំគ្នាធ្វើភូមិឱ្យមនោរម្យ កសាងសាលា សាងមណ្ឌប ធ្វើស្ពាន ជីកស្រះ និងដាំដើមឈើផ្កា ឈើម្លប់ជាដើម មឃមាណពបានធ្វើបុណ្យជាច្រើន បំពេញវត្តបទ ៧ អស់មួយជីវិត លុះដល់ស្លាប់ទៅៗ កើតក្នុងភពតាវតឹង្ស ព្រមទាំងសម្លាញ់ ៣៣ នាក់ **មឃមាណពបានជាស្តេចសក្កទេវរាជ ។**

ម្នាលមហាលិ មឃមាណពជាអ្នកមិនប្រមាទយ៉ាងនេះ ទើបបានភាពជាធំទ្រង់សោយរាជ្យក្នុងទេវលោកទាំង ២ បណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើមសរសើរសេចក្តីមិនប្រមាទ ព្រោះថា ការសម្រេចគុណវិសេសដែលជាលោកិយៈនិងលោកុត្តរៈ រមែងមានដោយការមិនប្រមាទ ។ ក្នុងវេលាចប់គាថា ស្តេចលិច្ឆវីមហាលិតាំងនៅក្នុងសោតាបត្តិផល សូម្បីបរិស័ទដែលប្រជុំគ្នាជាច្រើន ក៏បានជាព្រះអរិយបុគ្គលមានព្រះសោតាបន្នបុគ្គល ជាដើម ។

មហាលិទូលសួរព្រះសាស្តាតទៅថា ច្រើនថ្ងៃមកហើយ លិច្ឆវីបុត្រម្នាក់មាននាមថា **សុនក្ខត្តៈ** បានចូលមករកខ្ញុំព្រះអង្គពោលថា កំឡុងពេលដែលចូល

មកបួសក្នុងសំណាក់ព្រះអង្គ បានញ៉ាំងទិព្វចក្ខុឱ្យកើត ខ្ញុំព្រះអង្គបានឃើញរូបទាំងឡាយដែលជាទិព្វ ជាទីគួរត្រេកអរ តែមិនអាចបានឮសំឡេងជាទិព្វនោះទេ ខ្ញុំព្រះអង្គចង់ដឹងថា សំឡេងទិព្វដូចពោលមកមានឬ បើមានព្រោះហេតុអ្វីទើបសុនក្ខត្តៈមិនបានឮ ? ព្រះសាស្ដាត្រាស់តបថា ម្នាលមហាលិ សំឡេងទិព្វមានពិតដែលសុនក្ខត្តៈមិនអាចឮសំឡេងនោះបាន ព្រោះក្នុងអតីតជាតិសុនក្ខត្តៈនេះ បានទះគុម្ពត្រចៀកភិក្ខុអ្នកមានសីលមួយរូបរហូតថ្លង់ ទើបអកុសលកម្មនោះធ្វើឱ្យគេមិនអាចឮសំឡេងដែលជាទិព្វបាន , ម្នាលមហាលិ សូម្បីភិក្ខុក្នុងធម្មវិន័យនេះក៏ដូចគ្នា អ្នកខ្លះមានសមាធិអប់រំហើយត្រឹមមួយចំណែក ដើម្បីនឹងឱ្យឃើញរូបជាទិព្វ ភិក្ខុនោះរមែងឃើញរូបជាទិព្វតែម្យ៉ាង តែមិនអាចឮសំឡេងជាទិព្វបាន ចំណែកភិក្ខុណាមានសមាធិអប់រំហើយទាំងពីរយ៉ាង ភិក្ខុនោះរមែងបានឃើញទាំងរូប និងបានឮទាំងសំឡេងដែលជាទិព្វនោះបាន ។

មហាលិទូលសួរទៀតថា វិធីដើម្បីធ្វើឱ្យជាក់ច្បាស់នូវធម៌ទាំងនោះ មានឬព្រះអង្គ ? ព្រះសាស្ដាត្រាស់ថាមាន នុ៎ះគឺមគ្គមានអង្គ ៨ ដែលជាផ្លូវធ្វើឱ្យដឹងច្បាស់នូវធម៌ទាំងនោះ ។

( ៦ ) ក្នុងគោដាគារសាលាព្រៃមហាវ័ន គ្រានោះ **សីហសេនាបតី** អាមាត្យរបស់ស្ដេចលិច្ឆវីនៃក្រុងវេសាលី ចូលទៅគាល់ព្រះមានព្រះភាគដល់ទីគង់នៅ ថ្វាយបង្គំហើយ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់អាច

សម្តែងផលនៃទាន ដែលគប្បីឃើញបានក្នុងបច្ចុប្បន្នឬហ្ន៎ ? ព្រះសាស្តាទ្រង់ត្រាស់សម្តែងតបថា បានសីហសេនាបតី !

ម្នាលសីហសេនាបតី ទាយកជាទានបតី រមែងជាទីស្រឡាញ់ពេញចិត្តរបស់ពួកជនជាច្រើន សប្បុរសរមែងគប់រកទាយកជាទានបតី កិត្តិស័ព្ទដ៏ល្អរបស់ទាយកជាទានបតី រមែងផ្សាយទៅយ៉ាងឆ្ងាយ ទាយកជាអ្នកឱ្យទានចូលទៅកាន់ទីប្រជុំណា គឺ ទីប្រជុំក្សត្រ ព្រាហ្មណ៍ គហបតី សមណៈ ក៏រមែងជាអ្នកអង់អាចមិនឱនចុះ ម្យ៉ាងទៀត ទាយកជាទានបតី កាលស្លាប់ទៅរមែងចូលដល់សុគតិទេវលោក នេះគឺផលនៃទានគប្បីឃើញបានក្នុងបច្ចុប្បន្ន ។

ព្រះមានព្រះភាគជាម្ចាស់ ត្រាស់អានិសង្សនៃការឱ្យទាន ៥ ប្រការគឺ :

**១ រមែងជាទីស្រឡាញ់នៃជនជាច្រើន**

**២ សប្បុរសអ្នកស្ងប់រម្ងាប់រមែងគប់រកអ្នកឱ្យទាន**

**៣ កិត្តិស័ព្ទដ៏ល្អរបស់អ្នកឱ្យទានរមែងផ្សាយទៅឆ្ងាយ**

**៤ អ្នកឱ្យទានរមែងមិនឃ្លាតឆ្ងាយអំពីធម៌របស់គ្រហស្ថ**

**៥ កាលអស់ជីវិតហើយរមែងទៅកាន់សុគតិទេវលោក ។**

អដ្ឋកថាពោលថា អ្នកណាឱ្យវត្ថុដែលល្អជាងវត្ថុដែលខ្លួនបរិភោគ ឈ្មោះថា **ទានបតី** អ្នកណាឱ្យវត្ថុដែលស្មើនឹងខ្លួនបរិភោគឈ្មោះថា **សហាយទាន** អ្នកណាឱ្យវត្ថុដែលអន់ជាងខ្លួនបរិភោគឈ្មោះថា **ទាសទាន ។**

ក្រោពីនោះព្រះមានព្រះភាគបានត្រាស់ **កាលទាន** នឹងភិក្ខុទាំងឡាយថា

**១ ទាយករមែងឱ្យទានដល់អ្នកមកកាន់ដែនរបស់ខ្លួន**

**២ ទាយករមែងឱ្យទានដល់អ្នកត្រៀមនឹងធ្វើដំណើរ**

**៣ ទាយករមែងឱ្យទានក្នុងសម័យអត់ឃ្លាន**

**៤ ទាយករមែងឱ្យបាយស្រូវថ្មីដល់អ្នកមានសីល**

**៥ ទាយករមែងឱ្យផ្លែឈើទើបតែផ្លែថ្មីដល់អ្នកមានសីល ។**

ម្នាលភិក្ខុទាំងឡាយ **កាលទាន ៥ ប្រការនេះ** អ្នកមានបញ្ញាដឹងបំណង ប្រាសចាកសេចក្តីកំណាញ់ រមែងឱ្យទានក្នុងកាលដែលគួរឱ្យ ព្រោះអ្នកឱ្យទានតាមកាល ក្នុងព្រះអរិយៈទាំងឡាយ អ្នកបដិបត្តិត្រង់ អ្នកមានចិត្តតាំងមាំជាអ្នកមានចិត្តផូរផង់ ទក្ខិណាទានទើបមានផលពេញបរិបូរណ៍ ជនពួកណាអនុមោទនា ឬជួយខ្វល់ខ្វាយក្នុងទក្ខិណាទាននោះ រមែងជាអ្នកមានចំណែកនៃបុណ្យ ព្រោះដូច្នោះ ទើបគួរឱ្យទានក្នុងខេត្តដែលមានផលច្រើន ព្រោះបុណ្យរមែងជាទីពឹងពំនាក់របស់សត្វទាំងឡាយក្នុងបរលោក ។

# ផែនទីផ្លូវធ្វើដំណើររបស់ព្រះអង្គ ក្រោយចេញព្រះវស្សា

## ក្រោយអំពីចេញព្រះវស្សាហើយ

(៧) ស្តេចយាងចារិកទៅកាន់ **ភទ្ទិយនគរ** ដែនអង្គៈ ព្រមដោយភិក្ខុ ១២៥០ រូប ទ្រង់គង់នៅក្នុងជាតិយាវ័ន ក្រោយអំពីទ្រង់ឃើញឧបនិស្ស័យ សោតាបត្តិផលរបស់បុគ្គលទាំងនេះ គឺ **មេណ្ឌកសេដ្ឋី** **នាងចន្ទបទុមា** ភរិយា **ធនញ្ជ័យសេដ្ឋី** បុត្រ **នាងសុមនាទេវី** បុត្រប្រសា **នាងវិសាខា** ចៅស្រី និង ទាសៈឈ្មោះ **នាយបុណ្ណៈ** ។

**មេណ្ឌកសេដ្ឋី** ជ្រាបការយាងមករបស់ព្រះសាស្តា ទើបបញ្ជូនក្មេងស្រី វិសាខាជាចៅ ដែលខណៈនោះមានអាយុត្រឹម ៧ ខួប ចេញទៅថ្វាយបដិ-

សណ្ឋារកិច្ចព្រះសាស្តា ព្រមដោយក្មេងស្រីបរិវារ ៥០០ ព្រះពុទ្ធអង្គទ្រង់សម្តែងធម៌ប្រោស នាងវិសាខាបានសម្រេចសោតាបត្តិផល , ស្អែកឡើង **មេណ្ឌកសេដ្ឋី** ទូលអារាធនា ដើម្បីថ្វាយភត្តាហារនៅផ្ទះរបស់ខ្លួន ក្នុងខណៈដែលទ្រង់គង់នៅក្នុងភទ្ទិយនគរជាប្រចាំ ព្រះពុទ្ធអង្គទ្រង់អនុមោទនាហើយ ទ្រង់សម្តែងអនុបុព្វីកថា ប្រោសមេណ្ឌកសេដ្ឋី ព្រមទាំងគ្រួសារបានសម្រេចសោតាបត្តិផល ។

ខណៈដែលព្រះពុទ្ធអង្គប្រថាប់គង់នៅក្នុងជាតិយាវ៉ន **ឧគ្គហសេដ្ឋី** ជាក្មួយនៃលោកសេដ្ឋីបានចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ក្រាបទូលអារាធនាព្រះពុទ្ធអង្គ ព្រមដោយភិក្ខុសង្ឃ ៣ រូប ដើម្បីសោយភត្តាហារក្នុងថ្ងៃស្អែក ព្រះពុទ្ធអង្គទ្រង់ទទួលដោយតុណ្ហីភាព ។ ថ្ងៃស្អែកឡើង ឧគ្គហសេដ្ឋីអង្គាសព្រះសាស្តានិងព្រះភិក្ខុសង្ឃ ដោយខាទនីយភោជនីយាហារយ៉ាងប្រណីត ក្រោយពីភត្តកិច្ច ឧគ្គហសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កុមារីរបស់ខ្ញុំព្រះអង្គនេះនឹងទៅកាន់ត្រកូលស្វាមី សូមព្រះមានព្រះភាគប្រោសប្រដៅនូវហេតុដែលជាប្រយោជន៍សុខ ដល់កុមារីទាំងនេះអស់កាលដ៏យូរ ព្រះអង្គ ! ព្រះសាស្តាត្រាស់ប្រដៅថា កុមារីជាអ្នកទៅកាន់ត្រកូលនៃស្វាមី គប្បីប្រព្រឹត្តធម៌ ៥ ប្រការដូច្នេះគឺ :

**១. ភ្ញាក់មុន ដេកក្រោយ រង់ចាំបម្រើ ប្រព្រឹត្តខ្លួនជាទីពេញចិត្ត និងប្រើពាក្យពេចន៍ពិរោះចំពោះស្វាមី ។**

**២. ជនឯណា ដែលជាទីគោរពរបស់ស្វាមី ដូចជាមាតាបិតា ឬសមណ-**

ព្រាហ្មណ៍ ជាដើម កាលលោកមកកាន់ផ្ទះ នឹងឱ្យសេចក្តីគោរពរាប់អាន ទទួលបដិសណ្ឋារៈ ។

៣. ជាអ្នកប្រឹងប្រែងមិនខ្ជិលច្រអូសចំពោះការងារ ក្នុងផ្ទះរបស់ ស្វាមី ។

៤. សង្គ្រោះអ្នកជិតខាងរបស់ស្វាមី មើលថែការរស់នៅ និងការឈឺចាប់តាមហេតុដែលគួរ ។

៥. ចេះរក្សា និងគ្រប់គ្រងទ្រព្យដែលស្វាមីរកបានមកមិនឱ្យវិនាសទៅ ។

ម្នាលកុមារីទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះឯង មាតុគ្រាមដែលប្រកបដោយធម៌ ៥ ប្រការនេះ កាលអស់ជីវិតទៅរមែងចូលដល់ភាពជាសម្លាញ់របស់ពួកទេវតា **មនាបកាយិកា** ។

រយៈពេលទ្រង់គង់នៅក្នុង **ជាតិយាវ័ន** ព្រះពុទ្ធអង្គទ្រង់រង់ចាំការចាស់ក្លានៃញាណរបស់ **ភទ្ទិយសេដ្ឋីបុត្រ** ខណៈដែល **ភទ្ទជិ** អង្គុយនៅលើប្រាសាទជាន់លើ បានឃើញមហាជនធ្វើដំណើរទៅស្តាប់ធម៌ ក្នុងសំណាក់របស់ព្រះមានព្រះភាគ មានការចាប់អារម្មណ៍ ទើបនាំបរិវារជាច្រើនទៅកាន់សំណាក់ព្រះសាស្តា ស្តាប់ធម៌ទាំងដែលប្រដាប់ប្រដាដោយអាភរណៈទាំងពួង ញុំាងកិលេសទាំងឡាយឱ្យអស់ទៅ បានសម្រេចព្រះអរហត្ត ទូលសូមបព្វជ្ជាឧបសម្ប័ទ បិតារបស់ភទ្ទជិអនុញ្ញាត ព្រះពុទ្ធអង្គទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ហើយទ្រង់គង់នៅក្នុងភទ្ទិយនគរនោះអស់កន្លះខែ ។

បន្ទាប់ពីភទ្ទិយនគរ ស្ដេចចារិកទៅកាន់ **អង្គុត្តរាបះ** ដែនអង្គៈ មេណ្ឌកសេដ្ឋីជ្រាបដំណឹង ទើបនាំភត្តាហារតាមទៅថ្វាយក្នុងចន្លោះផ្លូវ ហើយទូលសូមអនុញ្ញាតថ្វាយស្បៀងធ្វើដំណើរដល់ពួកភិក្ខុសង្ឃ ព្រះសាស្ដា **ទ្រង់អនុញ្ញាតគោរស ៥ គឺ ទឹកដោះស្រស់ ទឹកដោះជូរ ប្រេង ទឹកដោះខាប់ ទឹកដោះថ្លា ។** បន្ទាប់ពីនោះទ្រង់អនុញ្ញាតឱ្យភិក្ខុស្វែងរកស្បៀង ក្នុងការធ្វើដំណើរ គឺ **អង្ករ សណ្ដែកខៀវ អំបិល ទឹកអំពៅ ប្រេង** និងទ្រង់ **អនុញ្ញាតឱ្យសង្ឃត្រេកអរក្នុងវត្ថុដែលជាកប្បិយៈ** (វត្ថុដែលសមគួរដល់សង្ឃ) **ដែលបានមកពីមាសប្រាក់ ដែលមានអ្នកបវារណាទុកដាក់ក្នុងដៃកប្បិយការកៈ** (អ្នកបម្រើសង្ឃ) **តែមិនមែនឱ្យត្រេកអរ ក្នុងការស្វែងរកមាសប្រាក់ដោយខ្លួនឯងទេ។**

(៨) ចេញពីអង្គុត្តរាបៈ ស្ដេចចារិកដល់ **អាបណនិគម** កេណិយជដិលជ្រាបដំណឹងទើបចូលទៅគាល់ដល់ទីប្រថាប់ ព្រះពុទ្ធអង្គទ្រង់បង្ហាញឱ្យកេណិយជដិលឃើញច្បាស់ ឱ្យសមាទាន ឱ្យអាចហ៊ានដោយធម្មីកថា ហើយ **កេណិយជដិល** បានទូលអារាធនាថា ខ្ញុំព្រះអង្គជ្រះថ្លាក្នុងព្រាហ្មណ៍ទាំងឡាយក៏ពិតមែន ទោះបីដូច្នោះ សូមព្រះគោតមដ៏ចម្រើន ព្រមដោយភិក្ខុសង្ឃមេត្តាទ្រង់ទទួលភត្តាហាររបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះផងចុះ ព្រះអង្គ ! ព្រះពុទ្ធអង្គទ្រង់បដិសេធទាំង ៣ ដង ហើយទើបទទួលនិមន្ត ។

អដ្ឋកថាពោលថា ហេតុដែលព្រះអង្គទ្រង់បដិសេធ ព្រោះកេណិយជដិលនឹងចម្រើនដោយបុណ្យ ចំពោះវត្ថុដែលកេណិយជដិលត្រៀមទុក ដើម្បីភិក្ខុ

១២៥០ រូប ក៏នឹងបានដល់ភិក្ខុ ១៥៥០ រូប ដោយទ្រង់ជ្រាបជាមុនថា សេលព្រាហ្មណ៍ព្រមដោយមាណព ៣០០ នាក់ នឹងបួស ។ សម័យនោះ សេលព្រាហ្មណ៍ព្រមដោយមាណព ៣០០ នាក់ដែលនៅក្នុងអាបណនិគម ដើរឈប់ៗ បានចូលទៅកាន់អាស្រមកេណិយជដិល ឃើញជនទាំងឡាយកំពុងជួយធ្វើការ និងតាក់តែងរោងបារាំ សេលព្រាហ្មណ៍គិតថា នឹងមានកិច្ចអាវាហមង្គល ឬ វិវាហមង្គល ឬនឹងទូលយាងព្រះរាជានៃដែនមគធៈមកសោយក្នុងថ្ងៃស្អែក បានសួរកេណិយជដិលដឹងសេចក្តីថា ព្រះសមណគោតមសក្យបុត្រយាងចារិកមកកាន់អង្គុត្តរាបជនបទ ព្រមដោយភិក្ខុសង្ឃមួយពួកធំ ទើបទូលនិមន្តសោយភត្តក្នុងថ្ងៃស្អែក ។

លំដាប់នោះ សេលព្រាហ្មណ៍គិតថា សូម្បីសំឡេងប្រកាសថា **ពុទ្ធោ** ស្វែងរកបានដោយក្រក្នុងលោក ឥឡូវនេះព្រះអង្គយាងមកដល់ទីនេះ យើងគួរបានជួបព្រះអង្គជាធម្មរាជា ទើបសេលព្រាហ្មណ៍នាំមាណពទាំង ៣០០ នាក់ ចូលទៅគាល់ដល់ទីប្រថាប់គង់ ក្នុងដងព្រៃ ។

សេលព្រាហ្មណ៍ជាអ្នករៀនចប់ត្រៃវេទ ជំនាញក្នុងគម្ពីរលោកាយតៈ និងតម្រាទាយមហាបុរិសលក្ខណៈ បានពិចារណាមើលមហាបុរិសលក្ខណៈ របស់ព្រះអង្គ មិនឃើញលក្ខណៈពីរប្រការគឺ គុយ្ហៈលាក់ក្នុងស្រោម ១[១] ជិវ្ហាអណ្តាតធំ ១ ទើបសង្ស័យមិនទាន់បង្អោនចិត្តជឿ មិនទាន់ជ្រះថ្លា រំពេចនោះឯង

[១] គឺប្រដាប់ភេទ របស់ព្រះអង្គខុសពីមនុស្សធម្មតា គឺលាក់នៅក្នុងស្រោមដូចគោ

ព្រះមានព្រះភាគទ្រង់បណ្ដាលឥទ្ធាភិសង្ខារ ឱ្យសេលព្រាហ្មណ៍ បានឃើញព្រះ-គុយ្ហៈលាក់ក្នុងស្រោម និងទ្រង់លៀនព្រះជិវ្ហាស៊កចូលព្រះការណ៍ទាំង ២ ត្រឡប់ទៅមក ស៊កចូលប្រហោងព្រះនាសិកទាំងពីរត្រឡប់ទៅមក ពង្រីកបិទមណ្ឌលព្រះនលាដ ត្រាស់នឹងសេលព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ អ្នកចូរកម្ចាត់សេចក្ដីសង្ស័យក្នុងតថាគតចេញ ចូរបង្អោនចិត្តជឿ ការបានឃើញព្រះសម្មាសម្ពុទ្ធទាំងឡាយជាការកម្រ ។

សេលព្រាហ្មណ៍ បានសរសើរព្រះសមណគោតមចំពោះព្រះភ័ក្ត្រ ដោយគាថាដ៏ពិរោះ ពោលជាមួយមាណព ៣០០ នាក់ថា ព្រះសាស្ដាជាមហាវីរៈ ដូចរាជសីហ៍បន្លឺក្នុងព្រៃ អ្នកណាបានឃើញព្រះពុទ្ធដ៏ប្រសើរ នឹងមិនគប្បីជ្រះថ្លាមិនមានឡើយ អ្នកណាប្រាថ្នា សូមអ្នកនោះមកតាមយើង ចំណែកអ្នកណាមិនប្រាថ្នាអ្នកនោះទៅចុះ យើងនឹងបួសក្នុងសំណាក់របស់ព្រះមានព្រះភាគ ដែលមានបញ្ញាដ៏ប្រសើរនេះ ។ មាណពទាំងនោះពោលថា សូម្បីខ្ញុំទាំងឡាយក៏នឹងបួស ដូច្នេះហើយមាណពទាំង ៣០០ នាក់ នាំគ្នាប្រណមអញ្ជលីទូលសូមបួស សេលព្រាហ្មណ៍ព្រមទាំងបរិស័ទ បានបព្វជ្ជាឧបសម្បទាហើយក្នុងសំណាក់ព្រះ-សាស្ដា ដោយឯហិភិក្ខុឧបសម្បទា ភិក្ខុនោះទាំងអស់ជាអ្នកទ្រង់បាត្រ និងចីវរ ដូចព្រះថេរៈមានវស្សា ១០០, លុះព្រឹកឡើង កេណិយជដិលបានអង្គាសភិក្ខុទាំង ១៥៥០ រូប មានព្រះពុទ្ធជាម្ចាស់ជាប្រមុខ ក្រោយភត្តកិច្ចព្រះសាស្ដាទ្រង់អនុមោទនាដោយព្រះគាថាថា :

| | |
|---|---|
| យញ្ញទាំងឡាយ | មានការបូជាភ្លើងជាប្រមុខ |
| ឆន្ទៈទាំងឡាយ | មានសាវិត្តិឆន្ទៈជាប្រមុខ |
| ជនទាំងឡាយ | មានព្រះរាជាជាប្រមុខ |
| ស្ទឹងទាំងឡាយ | មានសាគរជាប្រមុខ |
| តារាទាំងឡាយ | មានដួងព្រះច័ន្ទជាប្រមុខ |
| កម្ដៅទាំងឡាយ | មានដួងព្រះអាទិត្យជាប្រមុខ |
| អ្នកប្រាថ្នាបុណ្យ | មានភិក្ខុសង្ឃជាប្រមុខ ។ |

គ្រានោះ ព្រះសេលៈចេញចាកពួកគណៈ ជាអ្នកមិនប្រមាទមានសេចក្ដីព្យាយាម ក្នុងថ្ងៃទី ៨ ក៏បានសម្រេចអរហត្តផល ទើបនាំភិក្ខុ ៣០០ រូប ចូលទៅគាល់ព្រះអង្គក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ប្រោសលាព្រះយុគលបាទ ឱ្យពួកខ្ញុំព្រះអង្គទាំងឡាយបានថ្វាយបង្គំព្រះសាស្ដាផងចុះ ។

ក្នុងវេលាល្ងាច កេណិយជដិលគិតថា ទឹកបានៈរមែងសមគួរដល់អ្នកវៀរចាកការបរិភោគក្នុងវេលាវិកាល ទើបនាំទឹកបានៈដែលរៀបចំយ៉ាងល្អ ៥០០ អម្រែកមកថ្វាយ ដោយមិនប្រាកដក្នុងចិត្តថាវត្ថុនេះគួរដល់សមណៈ ឬអត់ ភិក្ខុបានក្រាបទូលសួរ ព្រោះហេតុនេះ ទើបទ្រង់អនុញ្ញាតទឹកបានៈដល់សង្ឃ ក្នុងគ្រាដំបូង ៨ ប្រភេទគឺ **ទឹកស្វាយ ទឹកព្រីង ទឹកចេកមានគ្រាប់ ទឹកចេកមិនមានគ្រាប់ ទឹកផ្លែស្រគុំ ទឹកផ្លែចន្ទន៍ ទឹកក្រអៅឈូក និងទឹកផ្លែម៉ាកប្រាង។**

តមកទ្រង់អនុញ្ញាតបន្ថែម គឺទឹកផ្លែឈើគ្រប់ប្រភេទ (វៀរធញ្ញជាតិ និងអបរណ្ណជាតិ និងមហាផល ៩) ទឹកស្លឹកឈើគ្រប់ប្រភេទ (វៀរទឹកជ្រក់) ទឹកផ្កាឈើគ្រប់ប្រភេទ (វៀរទឹកផ្កាស្រគុំ) និងទឹកអំពៅស្រស់ ។

កេណិយជដិលទូលអារាធនាព្រះសាស្តា និងសង្ឃសាវ័កទទួលភត្តាហារក្នុងអាស្រមរបស់ខ្លួនក្នុងថ្ងៃស្អែក ព្រះសាស្តាទ្រង់ទទួលដោយតុណ្ហីភាព កេណិយជដិលអង្គាសព្រះពុទ្ធអង្គ និងសង្ឃសាវ័កដោយភត្តាហារដ៏ប្រណីត ក្រោយភត្តកិច្ច ព្រះសាស្តាទ្រង់អនុមោទនា ហើយយាងត្រឡប់វិញ ។ ខណៈដែលព្រះសាស្តាទ្រង់គង់នៅ **ក្នុងអាបណនិគម** ព្រឹកថ្ងៃមួយយាងទៅបិណ្ឌបាតក្នុងអាបណនិគម យាងត្រឡប់អំពីបិណ្ឌបាត ក្រោយភត្តយាងចូលទៅកាន់ដងព្រៃមួយដើម្បីទ្រង់សម្រាកពេលថ្ងៃ ក្បែរគល់ឈើមួយដើម **បោតលិយគហបតី** ចូលទៅគាល់ទូលសូមឱ្យព្រះអង្គទ្រង់សម្តែងធម៌ ។ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ជាគ្រឿងកាត់វោហារ ៨ ប្រការ របស់ព្រះអរិយៈ សេចក្តីថា

**បាណាតិបាត** លះបង់បានព្រោះអាស្រ័យការមិនសម្លាប់

**អទិន្នាទាន** លះបង់បានព្រោះអាស្រ័យការកាន់យកតែរបស់ដែលគេឱ្យ

**មុសាវាទ** លះបង់បានព្រោះអាស្រ័យពាក្យសត្យ

**បិសុណាវាចា** លះបង់បានព្រោះអាស្រ័យវាចាមិនស៊កសៀត

**លោភៈ** លះបង់បានព្រោះអាស្រ័យការមិនលោភដោយតណ្ហា

**ទោសៈ** លះបង់បានព្រោះអាស្រ័យការមិនក្រោធដោយការនិន្ទា

**បដិឃៈ** លះបង់បានព្រោះអាស្រ័យការមិនចង្អៀតចង្អល់ដោយការក្រោធ

**មក្ខៈ** លះបង់បានព្រោះអាស្រ័យការមិនមើលងាយគេ ។

ធម៌ ៨ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីលះបង់ ដើម្បីកាត់ផ្តាច់វោហារក្នុងវិន័យរបស់ព្រះអរិយៈ ម្នាលគហបតី ប្រៀបដូចបុរសដែលកាន់គប់ភ្លើងស្មៅដើរច្រាសខ្យល់ បើបុរសនោះមិនប្រញាប់លែងគប់ភ្លើងស្មៅនោះចេញ ភ្លើងនឹងឆេះប្រអប់ដៃ ឆេះដៃ ឆេះអវយវៈរបស់បុរសនោះ បុរសនោះនឹងដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះគប់ភ្លើងនោះជាហេតុ ។

**បោតលិយគហបតី** ស្តាប់ហើយក្រាបទូលថា កាលមុនខ្ញុំព្រះអង្គសម្គាល់ថា ពួកអន្យតិរ្ថិយ៍ជាអ្នកដឹងទូទៅ គប្បីគប់រក និងលើកតម្កើង ឥឡូវនេះខ្ញុំព្រះអង្គជ្រាបថា ភិក្ខុទាំងឡាយជាអ្នកដឹងទូទៅ ជាអ្នកដឹងហេតុផល គប្បីគប់រកបពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគបានញុំាងខ្ញុំព្រះអង្គ ឱ្យជ្រះថ្លាក្នុងសមណៈ គោរពក្នុងសមណៈ ភាសិតរបស់ព្រះអង្គជាក់ច្បាស់ណាស់ ខ្ញុំព្រះអង្គសូមដល់ព្រះមានព្រះភាគ ព្រះធម៌ និងព្រះសង្ឃជាសរណៈ សូមព្រះអង្គចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់សរណៈអស់មួយជីវិត ពីឥឡូវនេះទៅ ។

ត្រង់អាបណនិគមនេះ ព្រះមានព្រះភាគមានតម្រាស់ឱ្យរកព្រះសារីបុត្រត្រាស់ថា ម្នាលសារីបុត្រ អរិយសាវ័កណាអ្នកមានសទ្ធាមាំ ជ្រះថ្លាក្រៃលែងក្នុងតថាគត អរិយសាវ័កនោះមិនសង្ស័យក្នុងតថាគត ឬក្នុងសាសនារបស់តថាគតនឹងដល់ទីបំផុតនៃទុក្ខបាន ។

**ម្នាលសារីបុត្រ** កាលសទ្ធារបស់អរិយសាវ័កជា **សទ្ធិន្ទ្រិយ៍** អរិយ-សាវ័កនោះ គប្បីសង្ឃឹមថា នឹងជាអ្នកប្រារព្ធសេចក្តីព្យាយាមដើម្បីលះអកុសលធម៌ នឹងញ៉ាំងកុសលធម៌ឱ្យដល់ព្រម មានសេចក្តីព្យាយាមមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។

កាលសេចក្តីព្យាយាមរបស់អរិយសាវ័កជា **វីរិយិន្ទ្រិយ៍** អរិយសាវ័កនោះគប្បីសង្ឃឹមថា នឹងជាអ្នកប្រកបដោយសតិ នឹងតាមរឭកដល់កិច្ចដែលធ្វើ និងពាក្យនិយាយសូម្បីដ៏យូរបាន ។

កាលសតិរបស់អរិយសាវ័កជា **សតិន្ទ្រិយ៍** អរិយសាវ័កនោះគប្បីសង្ឃឹមថា នឹងបានសេចក្តីស្ងប់នៃចិត្ត នឹងបានសមាធិ បានឯកគ្គតាចិត្ត ។

កាលសមាធិរបស់អរិយសាវ័កជា **សមាធិន្ទ្រិយ៍** អរិយសាវ័កនោះគប្បីសង្ឃឹមថា នឹងដឹងច្បាស់ដល់ខាងដើម និងទីបំផុតនៃសង្សារវដ្ត អរិយសាវ័កនោះ នឹងរំលត់ដោយការខ្ចាក់ចោលមិនសល់ នូវគំនរងងឹត គឺអវិជ្ជា និងតណ្ហាដោយបញ្ញា ។

ម្នាលសារីបុត្រ ក៏កាលបញ្ញារបស់អរិយសាវ័កជា **បញ្ញិន្ទ្រិយ៍** អរិយ-សាវ័កនោះ នឹងលះបង់ឧបធិទាំងពួង អស់តណ្ហាប្រាសចាកតម្រេក ដល់ការរលត់ គឺព្រះនិព្វានបានក្នុងទីបំផុត នេះគឺសទ្ធាដែលប្រកបដោយឥន្ទ្រិយ៍ទាំង ៥ ដូច្នេះ ។

( ៩ ) បន្ទាប់មក ព្រះសាស្តាយាងទៅកាន់ **ក្រុងកុសិនារា** រាជមល្លក្សត្រ ថ្វាយការបដិសណ្ឋារៈយ៉ាងសមព្រះកិត្តិគុណ ព្រោះព្រះអានន្ទ និងរាជ-

មល្លៈជាសម្លាញ់នឹងគ្នាតាំងពីមុន ទើបព្រះអានន្ទពោលសរសើរការបដិសណ្ឋារៈនេះ ។ រោជមល្លក្សត្រ ពោលថា ខ្ញុំធ្វើការបដិសណ្ឋារៈយ៉ាងមហោឡារិកដូច្នេះ ព្រោះពួកញាតិតាំងកតិកាទុកថា អ្នកណាមិនទទួលព្រះមានព្រះភាគ នឹងត្រូវពិន័យ ៥០០ កហាបណៈ ខ្ញុំមិនបានធ្វើដោយសទ្ធារបស់ខ្លួនទេ ព្រះអានន្ទមិនស្មានថានឹងបានទទួលពាក្យដូច្នោះ ទើបចូលទៅក្រាបទូលព្រះសាស្តា ដើម្បីនឹងរកឧបាយធ្វើឱ្យរោជមល្លក្សត្រ កើតសេចក្តីជ្រះថ្លាក្នុងព្រះធម្មវិន័យ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ការដែលនឹងធ្វើឱ្យរោជមល្លក្សត្រជ្រះថ្លានោះ តថាគតធ្វើបានមិនលំបាកឡើយ លំដាប់នោះ ព្រះអង្គទ្រង់ផ្សាយមេត្តាចិត្តទៅកាន់រោជៈហើយយាងចូលទៅក្នុងព្រះវិហារ រោជមល្លក្សត្រដែលព្រះមេត្តាចិត្តរបស់ព្រះ-អង្គពាល់ត្រូវហើយ បានត្រាច់តាមរកព្រះសាស្តា ទូទៅគ្រប់បរិវេណដូចមេគោកូនខ្ចីតាមរកកូនរបស់វាដូច្នោះ ។

ពួកភិក្ខុទាំងឡាយថ្វាយព្រះពរថា ព្រះពុទ្ធអង្គគង់នៅក្នុងវិហារ ទ្វារនោះបិទហើយ តែណែនាំឱ្យគោះទ្វារ កាលព្រះមានព្រះភាគបើកទ្វារទទួល ទ្រង់បានសម្តែងអនុបុព្វីកថា ហើយទ្រង់ប្រកាសអរិយសច្ច ៤ រោជមល្លក្សត្របានត្រាស់ដឹងធម៌ ហើយក្រាបទូលសូមប្រទានឱកាសឱ្យព្រះភិក្ខុសង្ឃទទួលចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជបរិក្ខារ របស់ព្រះអង្គតែម្នាក់ មិនត្រូវទទួលរបស់អ្នកដទៃ ។ ព្រះពុទ្ធអង្គទ្រង់បដិសេធត្រាស់ថា ភិក្ខុក្នុងធម្មវិន័យនេះ នឹងទទួលបច្ច័យរបស់អ្នកផង របស់អ្នកដទៃផង ដើម្បីការអនុគ្រោះដល់ជនទាំងឡាយ

ដោយមិនរើសមុខ ។ ខណៈដែលរោជមល្លក្សត្រ រង់ចាំលំដាប់ដើម្បីថ្វាយភត្តាហារ ទើបចូលទៅត្រួតពិនិត្យក្នុងរោងចុងភៅ មិនបានឃើញវត្ថុ ២ យ៉ាងគឺ បន្លែស្រស់ ១ របស់ទំពាដែលធ្វើដោយម្សៅ ១ ទើបចូលទៅរកព្រះអានន្ទសួរថា វត្ថុ ២ យ៉ាងនេះជាគួរឬទេ បើថ្វាយដល់សង្ឃ ? ព្រះអានន្ទក្រាបទូលរឿងនោះដល់ព្រះសាស្តា ទើបព្រះអង្គ **ទ្រង់អនុញ្ញាតបន្លែស្រស់គ្រប់ប្រភេទ និងរបស់គួរទំពាដែលធ្វើដោយម្សៅ** ។

(១០) យាងចារិកត ព្រះសាស្តាគេចចុះទៅគង់ក្នុងចំការស្វាយរបស់នាយចុន្ទកម្មារបុត្រ ជិតដែនបាវា នាយចុន្ទចូលមកគាល់ ព្រះអង្គត្រាស់សួរថា អ្នកពេញចិត្តសេចក្តីស្អាតរបស់អ្នកណាហ្ន៎ នាយចុន្ទទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍អ្នកបច្ឆាភូមិ កាន់ឃ្លោកពាក់ភួងមាល័យសារាយ បម្រើភ្លើងងូតទឹកជាវត្ត ខ្ញុំព្រះអង្គពេញចិត្តសេចក្តីស្អាតរបស់ព្រាហ្មណ៍ទាំងនោះ ព្រះមានព្រះភាគត្រាស់ថា តែសេចក្តីស្អាតក្នុងវិន័យរបស់ព្រះអរិយៈ រមែងមានដោយប្រការដទៃ នាយចុន្ទបានក្រាបទូលសួរ ទើបព្រះអង្គត្រាស់កុសលកម្មបថ ១០ គឺសេចក្តីស្អាតផ្លូវកាយ ៣ ផ្លូវវាចា ៤ និងផ្លូវចិត្ត ៣ អធិប្បាយថា បុគ្គលសូម្បីចាប់ពាល់ផែនដី ចាប់ពាល់ស្មៅ ឬចាប់ពាល់លាមកគោ ប្រសិនបើអ្នកនោះប្រកបដោយកុសលកម្មបថនេះ រមែងទៅកាន់សុគតិពិតប្រាកដ ។ កាលព្រះអង្គត្រាស់ដូច្នេះហើយ នាយចុន្ទក្រាបទូលសូមប្រកាសខ្លួនជាឧបាសក អ្នកដល់ព្រះរតនត្រ័យស្មើដោយជីវិត ទូលអារាធនាឱ្យព្រះសាស្តាទទួលភត្តាហារក្នុងថ្ងៃ

ស្អែក ក្នុងការថ្វាយភត្តនាយចុន្ទសង្កេតឃើញភិក្ខុ ១ រូប លួចលាក់ភាជនៈរបស់ខ្លួនដាក់ក្នុងយាម តែដោយសេចក្ដីគោរពក្នុងព្រះពុទ្ធអង្គ នាយចុន្ទក្លែងធ្វើជាមិនឃើញ ក្រោយពីព្រះអង្គអនុមោទនាហើយ នាយចុន្ទបានថ្វាយចំការស្វាយរបស់ខ្លួនដើម្បីជាទីគង់នៅរបស់សង្ឃ ។ តមកក្នុងវេលារសៀល នាយចុន្ទចូលទៅគាល់ព្រះអង្គ ក្រាបទូលសួរថា ខ្ញុំព្រះអង្គចង់ដឹងថា សមណៈមានប៉ុន្មានប្រភេទ ព្រះអង្គទ្រង់ដឹងភ្លាមថា នាយចុន្ទសួរដូច្នេះ សម្ដៅដល់រឿងរបស់ភិក្ខុនោះជាហេតុ ទើបត្រាស់ថា ចុន្ទសមណៈមាន ៤ ប្រភេទគឺ :

**១ សមណៈ អ្នកឈ្នះកិលេសដោយមគ្គ**

**២ សមណៈ អ្នកសម្ដែងមគ្គដល់ជនដទៃ**

**៣ សមណៈ អ្នកតាំងនៅក្នុងមគ្គ**

**៤ សមណៈ អ្នកប្រទូសរ៉ាយមគ្គ**

ព្រះអង្គទ្រង់ជ្រាបថា នាយចុន្ទអស់សេចក្ដីសង្ស័យក្នុងភិក្ខុនោះបានហើយ

សម័យនោះពួកមល្លក្សត្រនៃដែន **បាវ៉ា** កសាងសាលា ១ ខ្នងថ្មីឈ្មោះ **ឧភតកៈ** បានចូលទៅគាល់ព្រះមានព្រះភាគ ក្នុងសួនរបស់នាយចុន្ទកម្មារបុត្រ ក្រាបទូលអារាធនាព្រះអង្គ ព្រមដោយភិក្ខុសង្ឃឱ្យទៅគង់ក្នុងសាលានោះ ព្រះអង្គទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ទ្រង់ញ៉ាំងពួកមល្លៈនៃនគរបាវ៉ាឱ្យឃើញច្បាស់ ឱ្យសមាទាន ឱ្យអាចហ៊ាន ឱ្យរីករាយដោយធម្មីកថា អស់រាត្រីជាច្រើន ហើយទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា ម្នាលវាសេដ្ឋៈទាំងឡាយ រាត្រីកន្លង

ទៅហើយ ពួកអ្នកចូរសម្គាល់កាលដ៏គួរចុះ ពួកស្តេចមល្លៈទទួលព្រះតម្រាស់នោះ ថ្វាយបង្គំលាធ្វើប្រទក្សិណហើយចៀសចេញទៅ ។ កាលពួកស្តេចមល្លៈចេញទៅមិនយូរ ព្រះអង្គមានតម្រាស់នឹងព្រះសារីបុត្រថា ភិក្ខុសង្ឃប្រាសចាកថីនមិទ្ធៈហើយ អ្នកចូរសម្តែងធម៌ដល់ភិក្ខុទាំងនោះ តថាគតនឹងសម្រាកបន្តិច ហើយត្រាស់ឱ្យក្រាលសំពត់សង្ឃាដិជា ៤ ជាន់ ទ្រង់សម្រេចសីហសេយ្យា (ដំណេករាជសីហ៍តម្រួតព្រះបាទាឆ្វេងលើព្រះបាទាស្តាំ ឱ្យផ្សៀងទៅស្តាំ) ។

គ្រានោះ ព្រះសារីបុត្រពោលនឹងភិក្ខុទាំងឡាយថា ម្នាលអ្នកមានអាយុក្រោយអំពីនិគ្រន្ថនាដបុត្រធ្វើមរណកាលហើយមិនយូរ ក្នុងនគរបាវានេះសាវ័កនិគ្រន្ថបានកើតបែកបាក់ជា ២ ពួក កើតការវិវាទគ្នាថា លោកបដិបត្តិខុសយើងបដិបត្តិត្រូវ ព្រោះធម្មវិន័យដែលពោលទុកមិនល្អ មិនជាធម៌នាំចេញចាកទុក្ខ ។ ម្នាលអ្នកមានអាយុទាំងឡាយ ចំណែកធម៌ដែលព្រះមានព្រះភាគត្រាស់ទុកល្អហើយ ប្រកាសទុកល្អហើយ ជាធម៌នាំចេញចាកទុក្ខបាន ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ពួកយើងមិនគប្បីពោលបែងចែកគ្នាក្នុងធម៌នោះ ដើម្បីព្រហ្មចរិយៈនេះតាំងនៅយឺនយូរបាន ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ទំនុកបម្រុង ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ តពីនោះព្រះសារីបុត្របានសម្តែងស្វាធ្យាយ **សង្គីតិសូត្រ** ពោលអំពីសង្គីតិពួក ១០ ដល់បណ្តាភិក្ខុទាំងនោះ កាលព្រះមានព្រះភាគតើនអំពីបន្ទំហើយ ត្រាស់ជាមួយនឹងសារីបុត្តថា សាធុ សាធុ សារីបុត្រ

អ្នកបានពោលសម្ដីតិបរិយាយដល់ភិក្ខុទាំងឡាយជាការល្អហើយ ព្រះសាស្ដាទ្រង់ពេញព្រះទ័យ ភិក្ខុទាំងនោះរីករាយត្រេកអរក្នុងភាសិតរបស់ព្រះសារីបុត្រនេះ ។

(១១) ចេញពីបាវានគរ ព្រះមានព្រះភាគយាងទៅកាន់ **អាតុមានគរ** ដែលនៅចន្លោះកុសិនារា និងសាវត្ថី ក្នុងទីនេះ **សុភទ្ទ** ជាងកោរកាត់ដែនអាតុមាបួសក្នុងវ័យចាស់ ដឹងដំណឹងយាងមករបស់ព្រះមានព្រះភាគ ព្រមដោយសង្ឃសាវ័ក ១២៥០ រូប ទើបឱ្យកូនប្រុស ២ នាក់ ទៅស៊ីឈ្នួលកាត់សក់អ្នកស្រុក ដោយដូរយកអំបិល ប្រេង អង្ករ ដើម្បីនាំមកចម្អិនយាគូថ្វាយ កាលព្រះអង្គយាងមកដល់ សុភទ្ទភិក្ខុទូលអារាធនាឱ្យទទួលយាគូរបស់ខ្លួន , ព្រះអង្គត្រាស់សួរថា យាគូនេះអ្នកបានមកពីណា សុភទ្ទក្រាបទូលតាមសេចក្ដីពិត ព្រះអង្គទ្រង់តិះដៀលថា កិច្ចនេះមិនគួរដល់សមណៈ បព្វជិតមិនគប្បីដឹកនាំទាយកក្នុងហេតុមិនគួរ បន្ទាប់មកទ្រង់បញ្ញត្តថា **ភិក្ខុអ្នកធ្លាប់ជាជាងកោរកាត់ មិនគប្បីរក្សាគ្រឿងកោរកាត់សក់ជាប់ហ្នឹងខ្លួន ភិក្ខុណារក្សាត្រូវអាបត្តិទុក្កដ។**

(១២) ចេញពីអាតុមានគរ ស្ដេចពុទ្ធដំណើទៅកាន់ **ក្រុងសាវត្ថី** គង់ក្នុងវត្តជេតពន សម័យនោះ ក្នុងក្រុងសាវត្ថីមានផ្លែឈើច្រើន **ទ្រង់មានពុទ្ធានុញ្ញាតឱ្យភិក្ខុឆាន់ផ្លែឈើបានគ្រប់ប្រភេទ** កាលណោះ ភិក្ខុទាំងឡាយកើតសេចក្ដីសង្ស័យថា វត្ថុណាខ្លះដែលគួរ និងមិនគួរដល់សង្ឃ ទើបក្រាបទូលសួរព្រះអង្គទ្រង់សម្ដែង **មហាបទេស ៤** ពោលដោយវត្ថុគួរ និងមិនគួរដល់សង្ឃដូចតទៅនេះ :

១. វត្ថុណាដែលមិនបានហាមទុក បើអនុលោមថា មិនគួរដល់-
សមណៈ វត្ថុនោះ មិនគួរដល់អ្នកទាំងឡាយ ។
២. វត្ថុណាដែលមិនបានហាម តែបើអនុលោមថា គួរដល់សមណៈ
វត្ថុនោះ គួរដល់អ្នកទាំងឡាយ ។
៣. វត្ថុណាដែលមិនបានអនុញ្ញាត បើអនុលោមថា មិនសមគួរដល់
សមណៈ វត្ថុនោះមិនគួរដល់អ្នកទាំងឡាយ ។
៤. វត្ថុណាដែលមិនបានអនុញ្ញាត បើអនុលោមថា សមគួរដល់-
សមណៈ វត្ថុនោះគួរដល់អ្នកទាំងឡាយ ។

(សូមពិនិត្យមើល ក្នុងអដ្ឋកថាបន្ថែមផង ដូចជាពាក្យថា អនុលោម)

( បន្ទាប់ពីនោះ យាងត្រឡប់ទៅដែនមគធៈ រហូតទាល់តែជិតចូលព្រះវស្សា )

# ព្រះវស្សាទី ៦

## ទ្រង់គង់ចាំព្រះវស្សា ក្នុងមកុលបព៌ត ដែនមគធៈ

(១) រាជគហសេដ្ឋី បានពកខ្លឹមចន្ទន៍ក្រហមមានពណ៌អាចម៍ល័ខស្រស់ ដែលកើតត្រង់មាត់ទន្លេគង្គា អណ្តែតតាមទឹកមកជាប់សំណាញ់ ទើបនាំមកក្រឡឹងជាបាត្រ ហើយនាំទៅព្យួរទុកលើចុងឈើខ្ពស់ ប្រកាសថា ក្នុងលោកនេះ បើអ្នកណាជាព្រះអរហន្ត និងមានឫទ្ធិ សូមអ្នកនោះចូរមកដោះបាត្រចន្ទន៍ក្រហម

នេះទៅ យើងនឹងជ្រះថ្លាចំពោះអ្នកនោះ , គ្រានោះ **បូរណកស្សប** ចូលទៅរករាជគហសេដ្ឋីពោលថា ម្នាលគហបតី យើងនេះឯងជាព្រះអរហន្ត និងមានឫទ្ធិ សូមអ្នកចូរឱ្យបាត្រដល់យើងចុះ លោកសេដ្ឋីតបថា បើលោកម្ចាស់ជាព្រះអរហន្ត និងមានឫទ្ធិ ក៏ចូរហោះទៅដោះបាត្រដែលខ្ញុំឱ្យហើយនាំយកទៅចុះ ។ តមក **មក្ខលិគោសាល អជិតកេសកម្ពល បកុធកច្ចាយនៈ សញ្ជ័យវេលដ្ឋបុត្រ និងនិគ្រន្ថនាដបុត្រ** ចូលទៅរកសេដ្ឋី ដោយទំនងដូចគ្នាអស់វេលា ៦ ថ្ងៃ ក៏នៅតែមិនបានបាត្រនោះ អ្នកក្រុងរាជគ្រឹះនាំគ្នាយល់ថា ប្រាកដជាមិនមានព្រះ-អរហន្តក្នុងលោក លុះដល់ថ្ងៃទី ៧ ព្រះមោគ្គល្លាន និងព្រះបិណ្ឌោលភារទ្វាជៈ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ បានឮពាក្យពេចន៍របស់អ្នកដែនប្រកាសដូច្នោះ ទើបព្រះមោគ្គល្លានពោលនឹងព្រះបិណ្ឌោលភារទ្វាជៈថា ពាក្យនោះចម្អកឡកឡឺយញុំាញីព្រះពុទ្ធសាសនា ក៏លោកមានឫទ្ធិច្រើន មានអានុភាពច្រើន លោកចូរហោះឡើងទៅកាន់យកបាត្រនោះមកចុះ ។

(២) **ព្រះបិណ្ឌោលភារទ្វាជៈ** កើតក្នុងត្រកូលព្រាហ្មណ៍មហាសាល នៃក្រុងរាជគ្រឹះ កាលចម្រើនវ័យហើយសិក្សាត្រៃវេទ ទូន្មានមន្តដល់មាណព ៥០០ នាក់ ថ្ងៃមួយបានស្តាប់ធម្មកថារបស់ព្រះសាស្តាកើតសទ្ធា បួសហើយបំពេញវិបស្សនាបានសម្រេចព្រះអរហត្តផល ។

កាលព្រះមោគ្គល្លានពោលដូច្នោះ ព្រះបិណ្ឌោលភារទ្វាជៈ សម្តែងបាដិ-ហារិយ៍ឡើងទៅដោះបាត្រ កាន់បាត្រនោះហោះវិលជុំវិញក្រុងរាជគ្រឹះ ៣ ជុំ

រាជគហសេដ្ឋីឃើញព្រះថេរៈសម្ដែងឫទ្ធិហើយ ទើបនិមន្តឱ្យមកកាន់ផ្ទះឱ្យគង់លើអាសនៈដែលរៀបចំទុក ថ្វាយបង្គំសូមបាត្រមកដាក់ភត្តាហារដ៏មានឱជារសរហូតពេញបាត្រ ហើយប្រគេនចំពោះព្រះថេរៈ ។ ទទួលបាត្រហើយត្រឡប់ទៅព្រះវិហារ អ្នកក្រុងរាជគ្រឹះដែលនៅមិនទាន់បានឃើញហេតុការណ៍នោះ នាំគ្នាមកជួបជុំសូមឱ្យព្រះថេរៈសម្ដែងបាដិហារិយ៍ទៀត . ព្រះអង្គគង់នៅក្នុងវិហារទ្រង់ឮសំឡេងមហាជនជាប់តាមព្រះថេរៈមកទ្រហឹងអឹងកង ទើបត្រាស់សួរព្រះអានន្ទ ទ្រង់ដឹងហើយទើបហៅប្រជុំសង្ឃ ទ្រង់តិះដៀលព្រះថេរៈថា រឿងនោះមិនមែនជារបស់សមណៈ ហេតុដូចម្ដេចទើបអ្នកសម្ដែងបាដិហារិយ៍ដល់គ្រហស្ថព្រោះហេតុនៃបាត្រខ្លឹមចន្ទន៍នេះ ការធ្វើរបស់អ្នកមិនប្រព្រឹត្តទៅដើម្បីសេចក្ដីជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាឡើយ ។

ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទ **ហាមមិនឱ្យភិក្ខុសម្ដែងបាដិហារិយ៍** ដែលជាឧត្តរិមនុស្សធម៌ គឺធម៌ដ៏ក្រៃលែងរបស់មនុស្សដល់គ្រហស្ថ ភិក្ខុណាសម្ដែងត្រូវត្រូវអាបត្តិទុក្កដ ហើយទ្រង់ឱ្យទម្លាយបាត្រខ្លឹមចន្ទន៍នោះ បុកឱ្យល្អិតប្រើជាថ្នាំបន្តក់ភ្នែកដល់ភិក្ខុទាំងឡាយ ។

សម័យតមក ភិក្ខុប្រើបាត្រផ្សេងៗ ដែលធ្វើដោយមាស ប្រាក់ ស័រិទ្ធ និងកែវមណីជាដើម អ្នកស្រុកពោលទោសតិះដៀលថា ដូចគ្រហស្ថអ្នកបរិភោគកាម ទើបព្រះមានព្រះភាគបញ្ញត្ត ហើយ **អនុញ្ញាតបាត្រ ២ យ៉ាងគឺ បាត្រដែក ១ បាត្រដី ១** និងអនុញ្ញាត **ជើងទម្របាត្រ** ។ ពួកតិរ្ថិយ៍បានដឹងសេចក្ដី

ដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តសិក្ខាបទ មិនឱ្យភិក្ខុសម្តែងបាដិហារិយ៍ គិតថា ឥឡូវនេះ ពួកយើងបានឱកាសហើយ ទើបប្រកាសប្រាប់គ្នាដោយទូទៅថា សាវ័ករបស់ព្រះសមណគោតម នឹងមិនឈានកន្លងសិក្ខាបទដែលទ្រង់បញ្ញត្តហើយ សូម្បីព្រោះហេតុនៃជីវិត ព្រះសមណគោតមក៏នឹងរក្សាសិក្ខាបទដែលទ្រង់បញ្ញត្តនោះដូចគ្នា ឥឡូវនេះ ជាឱកាសដែលពួកយើងនឹងសម្តែងបាដិហារិយ៍ហើយ ។

ព្រះបាទពិម្ពិសារស្តាប់ពាក្យនោះ ទើបយាងទៅក្រាបទូលឱ្យព្រះសាស្តាទ្រង់ជ្រាប ហើយទូលសួរថា ឥឡូវនេះ ពួកតិរ្ថិយ៍នាំគ្នាពោលថា ពួកយើងនឹងធ្វើបាដិហារិយ៍ចំពោះមហាជន ព្រះអង្គនឹងទ្រង់ធ្វើដូចម្តេច ព្រះអង្គទ្រង់ត្រាស់ថា កាលតិរ្ថិយ៍ទាំងនោះធ្វើ តថាគតក៏នឹងធ្វើដែរ មហាបពិត្រ ។ ព្រះបាទពិម្ពិសារទូលសួរទៀតថា ក៏ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទហាមហើយមិនមែនឬ ? ព្រះអង្គទ្រង់ត្រាស់តបថា សិក្ខាបទនោះបញ្ញត្តទុកដើម្បីហាមសាវ័ក មិនបានបញ្ញត្តដើម្បីហាមខ្លួនឯងឡើយ ព្រោះថា **យមកបាដិហារិយ៍ ជាការសម្តែងរបស់ព្រះពុទ្ធទាំងឡាយគ្រប់ៗ ព្រះអង្គ** ។

ព្រះរាជាទូលសួរព្រះសាស្តាថា ព្រះអង្គនឹងទ្រង់ធ្វើទីណា ព្រះអង្គ ព្រះពុទ្ធអង្គត្រាស់ថា មហាបពិត្រ តថាគតនឹងធ្វើនាក្រុងសាវត្ថី ព្រោះហេតុថា ក្នុងទីនោះ ជាស្ថានទីដែលធ្វើយមកបាដិហារិយ៍របស់ព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ប្រការមួយទៀត ដើម្បីប្រយោជន៍នឹងឱ្យមហាជនប្រជុំគ្នា , ពួកតិរ្ថិយ៍បានស្តាប់ពាក្យដូច្នោះ ប្រឹក្សាគ្នាថា បានឮថាព្រះសមណគោតមទ្រង់បញ្ញត្តសិក្ខាបទដើម្បីពួក

សាវ័កប៉ុណ្ណោះ មិនទ្រង់បញ្ញត្តទុកដើម្បីព្រះអង្គ ទើបត្រៀមធ្វើបាដិហារិយ៍យ៉ាងមាំ បបួលឧបដ្ឋាកបានទ្រព្យច្រើនហើយ ទៅសាងមណ្ឌបដោយសរសឈើគគីប្រក់ដោយឧប្បលខៀវនិយាយថា ពួកយើងនឹងធ្វើបាដិហារិយ៍ក្នុងទីនេះ ។

## ក្រោយពីចេញព្រះវស្សាទី ៦ ហើយ

(៣) សម័យនោះ នៅក្នុងក្រុងសាវត្ថីលាភសក្ការៈដែលធ្លាប់បរិបូរណ៍ដល់ពួកតិរ្ថិយ៍ បានសាបសូន្យទៅជាលំដាប់ ព្រោះមហាជននាំគ្នារាប់អានព្រះពុទ្ធសាសនាច្រើនឡើង ជាហេតុឱ្យពួកតិរ្ថិយ៍រកឧបាយបំផ្លាញព្រះពុទ្ធសាសនាគ្រប់វិធី ពួកតិរ្ថិយ៍មានទស្សនៈដូចគ្នាថា ដើមហេតុព្រោះសំណាក់របស់ព្រះសមណ-គោតមជាទីតាំងដ៏ល្អ ការទៅមកស្រួលដល់ពួកមហាជន ដែលនឹងទៅស្តាប់ធម៌ទើបលាភសក្ការៈកើតឡើងដល់ព្រះសមណគោតមច្រើន ពួកតិរ្ថិយ៍ទើបគិតសាងសំណាក់របស់ខ្លួនឡើងខាងក្រោយវត្តជេតវន បាននាំគ្រឿងបណ្ណាការទៅថ្វាយដល់ព្រះបាទបសេនទិកោសល ហើយសូមព្រះរាជទានដីដើម្បីសាងសំណាក់របស់ខ្លួន ក្នុងពេលដំណើរការកសាង ព្រះសម្ពុទ្ធទ្រង់ព្រះតម្រិះថា អាចជាចម្រូងចម្រាស់ចំពោះព្រះពុទ្ធសាសនាក្នុងអនាគត ទើបទ្រង់ឱ្យព្រះអានន្ទទៅទូលព្រះ-បាទបសេនទិកោសល ។

ព្រះបាទបសេនទិកោសល បដិសេធមិនព្រមឱ្យចូលជួប មិនថាជាព្រះ-អានន្ទ ព្រះសារីបុត្រ ឬព្រះមោគ្គល្លាន ទើបព្រះសាស្តាត្រូវយាងទៅដោយព្រះ

អង្គឯង ព្រះអង្គយាងទៅហើយមិនត្រាស់សួរដូចម្តេច តែទ្រង់លើក **ភរុជាតក** ជាឧទាហរណ៍ថា ក្នុងអតីតៈមានអ្នកបួស ២ ពួក ស្នាក់នៅក្បែរគល់ជ្រៃ មួយពួកនៅទិសខាងជើងនៃក្រុង មួយពួកទៀតនៅទិសខាងត្បូង តមកដើមជ្រៃនៅទិសខាងត្បូងក្រៀមស្វិតងាប់អស់ ទើបជន្លាសទៅទិសខាងជើង បំណងនឹងទៅនៅក្នុងទីនោះ កើតជម្លោះជាមួយពួកដែលនៅមុន ព្រោះការដណ្តើមទីកន្លែងគ្នា ទើបនាំគ្នាទៅឱ្យព្រះរាជានៃក្រុងភរុវិនិច្ឆ័យក្តី មួយផ្នែកបានថ្វាយទូកសម្រាប់ជារាជយានដល់ព្រះភរុរាជា ។ ព្រះរាជាវិនិច្ឆ័យឱ្យអ្នកដែលថ្វាយទូកជាអ្នកឈ្នះ ដោយសេចក្តីលំអៀង ធ្វើឱ្យទេវតាដែលនៅក្នុងភរុរដ្ឋទាំងអស់ខឹងក្រោធ ព្រោះហេតុដែលព្រះរាជាធ្វើឱ្យអ្នកមានសីលឈ្លោះគ្នា **ដោយអំណាចនៃឆន្ទាគតិ** ទើបទេវតាបណ្តាលឱ្យភរុនគរ លិចចុះទៅក្រោមបាតសមុទ្រ ជួបសេចក្តីវិនាសយ៉ាងធំ លិចចុះទៅទាំងនគរ ។

ព្រះបាទបសេនទិកោសលបានទ្រង់ស្តាប់ដូច្នោះ ទើបមានព្រះរាជបញ្ជាឱ្យបណ្តេញអ្នកបួសទាំងនោះចេញទៅ ហើយទ្រង់សាងទីនោះឱ្យជាអារាមសម្រាប់ភិក្ខុនី ទ្រង់ដាក់នាមថា **រាជការាម** ទើបក្រុងសាវត្ថីមានអារាមកើតឡើងជិតវត្តជេតពនដោយហេតុដូច្នេះ ។

(៤) ព្រះពុទ្ធអង្គយាងទៅកាន់ក្រុងសាវត្ថី ត្រាស់ជាមួយនឹងព្រះបាទបសេនទិកោសលថា ព្រះអង្គមានព្រះបំណងនឹងសម្តែងយមកបាដិហារិយ៍ ក្បែរក្រុងសាវត្ថី ក្នុងថ្ងៃពេញបូណ៌មីខែអាសាឍ ។ ព្រះបាទបសេនទិកោសលត្រាស់

សួរថា ព្រះអង្គនឹងទ្រង់ធ្វើបាដិហារិយ៍ទីណា ព្រះអង្គ ? ព្រះសាស្តាត្រាស់តបថា ត្រង់ដើមឈើ **គណ្ឌាមព្រឹក្ស** (ដើមស្វាយ) មហាបពិត្រ ។ ពួកតិរ្ថិយ៍ដឹងដំណឹងនេះ ឱ្យពួកឧបដ្ឋាកទៅកាត់ និងដកដើមស្វាយ ជុំវិញព្រះនគរចោលរហូតអស់មិនឱ្យមានសល់ ដោយហោចទៅសូម្បីដើមដែលដុះក្នុងថ្ងៃនោះ ដោយបំណងថា កាលមិនមានដើមស្វាយទាំងនោះហើយ ព្រះសាស្តានឹងទ្រង់ធ្វើដូចម្តេច ។

លុះដល់ថ្ងៃពេញបូណ៌មី ខែអាសាឍ ព្រះសាស្តាយាងទៅក្នុងបរិវេណដែលនឹងសម្តែងយមកបាដិហារិយ៍ **នាយគណ្ឌៈ** អ្នករក្សាឧទ្យានរបស់ព្រះរាជាឃើញស្វាយទុំមួយផ្លែធំក្នុងឧទ្យាន ទើបបេះមកដើម្បីថ្វាយព្រះរាជា បានជួបព្រះសាស្តាក្នុងចន្លោះផ្លូវ នាយគណ្ឌៈគិតថា ស្វាយមួយផ្លែនេះបើថ្វាយដល់ព្រះរាជា ក៏គង់ប្រទានកហាបណៈដល់យើងត្រឹម ៨ ឬ ១៦ កហាបណៈ ដែលមិនល្មមចិញ្ចឹមជីវិតក្នុងអត្តភាពនេះ តែបើយើងថ្វាយចំពោះព្រះសាស្តា ទុំនឹងជាបុណ្យនាំប្រយោជន៍សុខមកឱ្យយើងរហូត ទើបនាយគណ្ឌៈបង្អោនផ្លែស្វាយនោះថ្វាយចំពោះព្រះសាស្តា។ ព្រះអង្គទ្រង់ទទួល ហើយសម្តែងអាការដើម្បីនឹងទ្រង់គង់ ព្រះអានន្ទក្រាលសង្ឃាដិថ្វាយ ហើយញីផ្លែស្វាយនោះធ្វើជាទឹកបានៈ ព្រះសាស្តាសោយទឹកបានៈផ្លែស្វាយហើយ ទើបត្រាស់នឹងនាយគណ្ឌៈថា អ្នកចូរជីកដីឱ្យខួងដាំគ្រាប់ស្វាយក្នុងទីនេះចុះ។ ព្រះសាស្តាទ្រង់លាងព្រះហស្តលើគ្រាប់ស្វាយនោះ ខណៈនោះឯងគ្រាប់ក៏ដុះឡើងមក កាលមហាជនកំពុងឃើញនោះឯង ដើមស្វាយនោះក៏ធំឡើងទៅដោយមែក ផ្កា ផ្លែ និងស្លឹកខ្ចី អ្នកជម្ពូទ្វីបបាន

បេះផ្លែស្វាយដែលរុះចុះមកស៊ីមិនចេះអស់ ។ ព្រះរាជាទ្រង់ស្តាប់ថា ដើមស្វាយកើតឡើងដូច្នោះ ទើបទ្រង់តាំងអារក្ខាទុកដោយព្រះតម្រាស់ថា អ្នកណាកុំកាត់ដើមស្វាយនោះ ទើបដើមស្វាយនោះបានឈ្មោះថា **គណ្ឌាមព្រឹក្ស** ព្រោះនាយគណ្ឌៈ ជាអ្នកដាំ ។

( ៥ ) សក្កទេវរាជទ្រង់បញ្ជាវាតវលាហកទេវបុត្រ ឱ្យដកមណ្ឌបរបស់ពួកតិរ្ថិយ៍ដោយខ្យល់ ឱ្យខ្យល់បក់បំបើុងទៅចោលលើផែនដីត្រង់គំនរសម្រាម បញ្ជាសុរិយទេវបុត្រ ឱ្យពង្រីកមណ្ឌលព្រះអាទិត្យញ៉ាំងឱ្យពួកតិរ្ថិយ៍ក្តៅ ហើយបញ្ជាឱ្យវស្សវលាហកទេវបុត្រ ឱ្យដំណក់ទឹកគ្រាប់ធំៗធ្លាក់ចុះមក ពួកតិរ្ថិយ៍ដូចជាមេគោពពាល បែកគ្នាគេចទៅក្នុងទីនោះឯង ។

កាលតិរ្ថិយ៍គេចទៅយ៉ាងនោះ អ្នកស្រែជាឧបដ្ឋាករបស់បូរណកស្សបដើរបញ្ច្រាសផ្លូវមក បំណងនឹងទៅមើលបាដិហារិយ៍របស់ពួកតិរ្ថិយ៍ ទើបបូរណ-កស្សបសូមខ្សែ និងក្អមទឹកដែលអ្នកស្រែកាន់មក ទៅមាត់ស្ទឹងយកខ្សែចងឆ្នាំងរិតជាប់នឹងករបស់ខ្លួន លោតចុះទៅក្នុងអន្លង់ទឹក ស្លាប់ហើយទៅកើតក្នុងអវីចិ។ ក្នុងវេលារសៀល ព្រះមានព្រះភាគយាងចេញចាកព្រះគន្ធកុដិ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ ជាវេលាដែលនឹងធ្វើបាដិហារិយ៍ បានប្រថាប់ឈរនៅខាងមុខ វេលានោះបណ្តាសាវ័ក សាវិកា សូម្បីសាមណេរីអាយុត្រឹម ៧ ខួប ដែលសម្រេចអភិញ្ញាមកទូលសូមធ្វើបាដិហារិយ៍ជំនួស ព្រះសាស្តាត្រាស់ថា តថាគតដឹងអានុ-ភាពរបស់ពួកអ្នក តែភ្នួងផ្កានេះមិនបានចងទុកដើម្បីប្រយោជន៍ដល់ពួកអ្នក ជា

កិច្ចរបស់ព្រះពុទ្ធគ្រប់ៗ ព្រះអង្គ គ្រាត្រាស់ហើយយាងឡើងកាន់ទីចង្រ្កមកែវ ព្រះអង្គទ្រង់សម្តែងយមកបាដិហារិយ៍ ក្នុងកណ្តាលមហាជនត្រង់ដើមស្វាយឈ្មោះថា **គណ្ឌាមព្រឹក្ស ទ្រង់ធ្វើមហាឥទ្ធិបាដិហារិយ៍** ។

(៦) **យមកបាដិហារិយ៍** របស់ព្រះពុទ្ធជាម្ចាស់ គឺបាដិហារិយ៍ដែលសម្តែងព្រមគ្នា ជាគូៗ ដូច្នេះ គឺ :

អណ្តាតភ្លើងផ្សាយចេញចាកព្រះកាយខាងលើ ទឹកចេញពីព្រះកាយខាងក្រោម ។

អណ្តាតភ្លើងផ្សាយចេញចាកព្រះកាយខាងក្រោម ទឹកចេញពីព្រះកាយខាងលើ ។

អណ្តាតភ្លើងផ្សាយចេញចាកព្រះកាយខាងមុខ ទឹកចេញពីព្រះកាយខាងក្រោយ ។

អណ្តាតភ្លើងផ្សាយចេញចាកព្រះកាយខាងក្រោយ ទឹកចេញពីព្រះកាយខាងមុខ ។

អណ្តាតភ្លើងផ្សាយចេញពីព្រះនេត្រខាងស្តាំ ទឹកចេញពីព្រះនេត្រខាងឆ្វេង ។

អណ្តាតភ្លើងផ្សាយចេញពីព្រះនេត្រខាងឆ្វេង ទឹកចេញពីព្រះនេត្រខាងស្តាំ ។

អណ្ដាតភ្លើងផ្សាយចេញពីព្រះកាណ៌ខាងស្ដាំ ទឹកចេញពីព្រះកាណ៌ខាងឆ្វេង ។

អណ្ដាតភ្លើងផ្សាយចេញពីព្រះកាណ៌ខាងឆ្វេង ទឹកចេញពីព្រះកាណ៌ខាងស្ដាំ ។

អណ្ដាតភ្លើងផ្សាយចេញពីព្រះនាសិកៈខាងស្ដាំ ទឹកចេញពីព្រះនាសិកៈខាងឆ្វេង ( ច្រមុះ ) ។

អណ្ដាតភ្លើងផ្សាយចេញពីព្រះនាសិកៈខាងឆ្វេង ទឹកចេញពីព្រះនាសិកៈខាងស្ដាំ ។

ដោយទំនងយ៉ាងនេះ អណ្ដាតភ្លើងនិងខ្សែទឹក[១] ផ្សាយចេញចាកចង្កួយព្រះអង្សា ព្រះហស្ថ ព្រះបិដ្ឋិ ព្រះបាទ ព្រះអង្គុលី រណ្ដៅព្រះលោមាមួយរណ្ដៅៗ ដោយមិនលាយឡំគ្នា អណ្ដាតភ្លើងរមែងផ្សាយចេញដោយអំណាច **តេជោ-កសិណសមាបត្តិ** ខ្សែទឹករមែងផ្សាយចេញដោយអំណាច **អាបោកសិណ-សមាបត្តិ** ។

ព្រះសាស្ដាទ្រង់និម្មិតព្រះពុទ្ធនិម្មិត ដែលដូចគ្នានឹងព្រះអង្គគ្រប់ប្រការ តែនៅក្នុងឥរិយាបថដែលផ្សេងពីព្រះអង្គ គឺកាលព្រះអង្គទ្រង់ចង្ក្រម ព្រះពុទ្ធនិម្មិតរមែងប្រថាប់ឈរ ឬ គង់ ឬ ទ្រង់ផ្ទំ កាលព្រះអង្គទ្រង់ប្រថាប់ឈរ ព្រះពុទ្ធនិម្មិតរមែងទ្រង់ចង្ក្រម ទ្រង់គង់ ឬ ទ្រង់ផ្ទំ កាលព្រះអង្គទ្រង់ប្រថាប់គង់ ព្រះពុទ្ធ

---

[១] ព្រះអង្សា គឺ ស្មា បិដ្ឋិ គឺ ខ្នង

និម្មិត រមែងទ្រង់ចង្ក្រម ទ្រង់ឈរ ឬ ទ្រង់ផ្ទុំ កាលព្រះអង្គទ្រង់ផ្ទុំ ព្រះពុទ្ធនិម្មិត រមែងទ្រង់ចង្ក្រម ទ្រង់ឈរ ឬ ទ្រង់គង់ ។

ធម្មាភិសម័យបានកើតឡើងដល់សត្វជាច្រើនក្នុងសមាគមនោះ ព្រោះបានឃើញមហាបាដិហារិយ៍ និង បានស្តាប់ធម្មកថារបស់ព្រះសាស្តា ។

(លក្ខណៈរបស់យមកបាដិហារិយ៍ ពិស្តារមាននៅក្នុងខុទ្ទកនិកាយពុទ្ធវង្ស)

ខុទ្ទកនិកាយធម្មបទ ក្បាលទី .... ភាគ.... ទំព័រ....

ខុទ្ទកនិកាយឧទាន ក្បាលទី .... ភាគ.... ទំព័រ....

**ភិក្ខុដែលប្រាថ្នានូវសេចក្តីស្ងប់ មិនគប្បីស្វែងរកអ្វីផងក្រៅពី**
**ពោធិបក្ខិយធម៌ទាំងឡាយ មានសតិប្បដ្ឋានជាដើមឡើយ ។**

**( មហាដីកា បរមត្ថមញ្ជូសា )**

## ព្រះវស្សាទី ៧

## ទ្រង់គង់ចាំព្រះវស្សា ក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស

(១) ខណៈដែលព្រះសាស្តាសម្តែងយមកបាដិហារិយ៍ នាក្រុងសាវត្ថីនោះ ទ្រង់ព្រះតម្រិះថា ព្រះពុទ្ធទាំងឡាយក្នុងអតីតៈ ក្រោយពីសម្តែងយមក-បាដិហារិយ៍ហើយ នឹងចាំវស្សាក្នុងទីណា ទ្រង់ជ្រាបថា ចាំវស្សាក្នុងឋានតាវត្តិង្ស

ដើម្បីសម្តែងព្រះអភិធម្មប្រោសពុទ្ធមាតា ។ កាលព្រះអង្គសម្តែងយមកបាដិហារិយ៍ស្រេចហើយ បានយាងឡើងទៅកាន់ឋានតាវត្តិង្ស សក្កទេវរាជទតឃើញព្រះមានព្រះភាគ យាងមកទទួលព្រមដោយពួកទេវតាទាំងឡាយ ។ ពួកមហាជនដែលជាប់តាមមក បានដឹងអំពីព្រះអនុរុទ្ធថា ព្រះអង្គយាងឡើងទៅកាន់ភពតាវត្តិង្ស និងទ្រង់គង់រហូតមួយវស្សា ទើបមហាជននាំគ្នាបោះទីលំនៅរង់ចាំក្នុងទីនោះ ព្រះសាស្តាបានត្រាស់នឹងព្រះមហាមោគ្គល្លានជាមុនថា អ្នកគប្បីសម្តែងធម៌ដល់បរិស័ទនោះ ចុល្លអនាថបិណ្ឌិកនឹងឱ្យគ្រឿងឧបភោគបរិភោគ ដល់ជនទាំងនោះគ្រប់ពេល ទាំងព្រឹកទាំងល្ងាចរហូតត្រៃមាស ។

ព្រះសាស្តាទ្រង់គង់លើបណ្ឌុកម្ពលសិលាសនៈ[១] ឡើបគល់បារិច្ឆត្តកៈកណ្តាលទេវបរិស័ទ ព្រះពុទ្ធមាតាយាងចុះមកអំពីវិមានជាន់តុសិត ។ ព្រះមានព្រះភាគទ្រង់សម្តែងអភិធម្ម ៧ គម្ពីរ គឺ **ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលប្បញ្ញត្តិ កថាវត្ថុ យមកៈ និង មហាបដ្ឋាន** ទ្រង់ផ្តើមតាំងអភិធម្មបិដកថា **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា** ដូច្នេះជាដើម ទ្រង់សម្តែងព្រះអភិធម្មប្រោសព្រះពុទ្ធមាតា ដោយន័យនេះរហូតមួយព្រះវស្សា។ ក្នុងវេលាបិណ្ឌបាតព្រះអង្គទ្រង់និម្មិត **ព្រះពុទ្ធនិម្មិត** ទ្រង់អធិដ្ឋានថា ព្រះពុទ្ធនិម្មិតចូរសម្តែងធម៌ឈ្មោះនេះៗ រហូតទាល់តែតថាគតត្រឡប់មក ហើយយាងទៅព្រៃហិមពាន្ត ទ្រង់ទំពាឈើស្ទន់ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋនាអនោតត្តស្រះ នាំ

---

[១] ជាអាសនៈថ្មតែផតចុះក្នុងពេលអង្គុយ ប៉ោងឡើងពេលក្រោក ពណ៌ក្រហមដូចសំពត់កម្ពល

បិណ្ឌបាតមកពីឧត្តរកុរុទ្វីប ទ្រង់គង់ធ្វើភត្តកិច្ចក្នុងរោងដ៏ធំ ព្រះសារីបុត្រធ្វើវត្ត បដិបត្តិដល់ព្រះសាស្តាក្នុងទីនោះឯង ។

លុះសម្រេចភត្តកិច្ចហើយ ទ្រង់ត្រាស់នឹងព្រះសារីបុត្រថា ថ្ងៃនេះតថាគតសម្តែងធម៌គម្ពីរនេះដល់ព្រះពុទ្ធមាតា អ្នកចូរប្រាប់ធម៌នោះដល់សិស្ស ៥០០ នាក់ របស់អ្នក ហើយយាងត្រឡប់ទៅកាន់ទេវលោក ទ្រង់សម្តែងធម៌តពីព្រះពុទ្ធនិម្មិតសម្តែង ។

ចំណែកព្រះសារីបុត្រ ត្រឡប់ទៅសម្តែងធម៌នោះដល់សិស្សរបស់ខ្លួន ដូច្នេះរាល់ថ្ងៃរហូតអស់ត្រៃមាស ភិក្ខុជាសិស្ស ៥០០ នោះ កាលព្រះសាស្តាគង់ក្នុងទេវលោក បានជាអ្នកជំនាញក្នុងព្រះអភិធម្ម ៧ គម្ពីរ ក្នុងព្រះវស្សានោះមុនភិក្ខុទាំងពួង ។

បានឮមកថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមថាកស្សប ភិក្ខុទាំងនោះជាសត្វប្រចៀវអាស្រ័យនៅក្នុងញកភ្នំមួយកន្លែង បានស្តាប់ព្រះថេរៈ ២ រូប ដើរចង្ក្រមហើយសូធ្យាយព្រះអភិធម្ម ប្រចៀវទាំងនោះមិនដឹងថា ទាំងនេះឈ្មោះថាខន្ធ ទាំងនេះឈ្មោះថាធាតុ ត្រឹមតែកាន់យកនិម្មិតក្នុងសំឡេងនោះជាសញ្ញា ចុតិចាកអត្តភាពនោះកើតក្នុងទេវលោក សោយទិព្វសម្បត្តិអស់មួយពុទ្ធន្តរ ចុតិចាកទេវលោកនោះហើយ កើតក្នុងត្រកូលរបស់អ្នកក្រុងសាវត្ថី បានឃើញព្រះអង្គទ្រង់សម្តែងយមកបាដិហារិយ៍ មានសេចក្តីជ្រះថ្លា សូមបួសក្នុងសំណាក់ព្រះសារីបុត្របានជាអ្នកជំនាញក្នុងបករណ៍ ៧ ដូច្នេះ ។

ព្រះសាស្តា ទ្រង់សម្តែងអភិធម្មដោយទំនងនោះរហូតត្រៃមាស ក្នុងកាលចប់ទេសនា ការត្រាស់ដឹងធម៌ក៏មានដល់ទេវតាច្រើន **ព្រះពុទ្ធមាតាបានតាំងនៅក្នុងសោតាបត្តិផល** គ្រានោះជិតវេលានឹងចេញព្រះវស្សា បរិស័ទទាំងឡាយដែលរង់ចាំទទួលគាល់រហូតអស់ពេល ៣ ខែ បានសូមឱ្យព្រះមោគ្គល្លានឡើងទៅទូលសួរថ្ងៃយាងត្រឡប់ចុះមក ពោលថា ពួកខ្ញុំម្ចាស់ទាំងឡាយមិនឃើញព្រះសាស្តាហើយ នឹងមិនទៅអំពីទីនេះ ព្រះមោគ្គល្លានឡើងទៅក្រាបទូលសួរព្រះអង្គថា ព្រះអង្គនឹងយាងចុះពេលណា ព្រះអង្គ ? ព្រះអង្គត្រាស់សួរដល់ព្រះសារីបុត្រ ទ្រង់ជ្រាបថា នៅសង្កស្សនគរ ទើបត្រាស់នឹងព្រះមោគ្គល្លានថា ក្នុងថ្ងៃទី ៧ ពីថ្ងៃនេះ តថាគតនឹងចុះត្រង់ទ្វារនគរសង្កស្សៈ ក្នុងថ្ងៃមហាបវារណា អ្នកប្រាថ្នានឹងជួបតថាគត ក៏ចូរទៅក្នុងទីនោះចុះ ។

(២) ព្រះអង្គ **យាងចុះចាកតាវត្តិង្សមកកាន់ទ្វារនគរសង្កស្សនគរ** ដែលនៅឆ្ងាយអំពីក្រុងសាវត្ថី ៣០ យោជន៍ ក្នុងថ្ងៃមហាបវារណា ១៥ កើត ខែអស្សុជ ដែលជាពុទ្ធកិច្ច ព្រះពុទ្ធអង្គគ្រប់ព្រះអង្គមិនទ្រង់លះបង់ ផ្ទៃដីដែលទ្រង់ជាន់ព្រះបាទក្នុងសង្កស្សនគរ បាននាមថា **អចលចេតីយ៍** ។ ថ្ងៃដែលព្រះអង្គយាងចុះចាកទេវលោក សក្កទេវរាជបញ្ជាឱ្យវិស្សកម្មទេវបុត្រនិម្មិតជណ្តើរកែវ-មណីត្រង់កណ្តាលសម្រាប់ព្រះសាស្តា ជណ្តើរមាសនៅខាងស្តាំសម្រាប់ពពួកទេវតា និងជណ្តើរប្រាក់នៅខាងឆ្វេងសម្រាប់ពួកមហាព្រហ្ម កាលព្រះអង្គយាងចុះ ស្តេចមហាព្រហ្មបាំងឆ័ត្រ សក្កទេវរាជទទួលបាត្រ ស្តេចសុយាមទេវរាជ

បក់វាលវីជនីជាទិព្វ[១] បញ្ចសិខទេវបុត្រដេញពិណ មាតលីទេវបុត្រកាន់គ្រឿងក្រអូប និងផ្កាឈើដែលជាទិព្វ នមស្ការហែហមដោយពួកទេវតា និងព្រហ្មយាងចុះត្រង់ទ្វារនគរសង្កស្សៈ ។

ព្រះធម្មសេនាបតីសារីបុត្រ ជាអ្នកថ្វាយបង្គំទទួលដំណើរយាងមុនគេ ព្រះឧប្បលវណ្ណាថេរី ចូលមកថ្វាយបង្គំបន្តពីព្រះសារីបុត្រ តមកពួកមហាជនដែលតាមមករង់ចាំគាល់ទទួលដំណើរយាងក្នុងទីនោះ ព្រះពុទ្ធអង្គទ្រង់ព្រះតម្រិះថា ជនទាំងនេះស្គាល់កិត្តិស័ព្ទរបស់មោគ្គល្លាន ក្នុងឋានៈជាកំពូលខាងឫទ្ធិ ដឹងថាព្រះអនុរុទ្ធកំពូលខាងទិព្វចក្ខុ ដឹងថាព្រះបុណ្ណៈកំពូលខាងធម្មកថិក តែបរិស័ទនេះមិនបានស្គាល់ព្រះសារីបុត្រថា ជាកំពូលដោយគុណអ្វី ? ទើបត្រាស់សួរបញ្ហានឹងព្រះថេរៈ ព្រះសារីបុត្រឆ្លើយបញ្ហាបានទាំងអស់ ទាំងបញ្ហារបស់បុថុជ្ជន ព្រះសេក្ខៈ និងព្រះអសេក្ខៈ ។

ក្នុងគ្រានោះ ទើបមហាជនបានស្គាល់ព្រះសារីបុត្រថា ជាកំពូលខាងបញ្ញា ព្រះមានព្រះភាគត្រាស់ថា សារីបុត្រមិនមែនមានបញ្ញាតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតៈក៏ជាអ្នកមានបញ្ញាដ៏កំពូលដែរ ហើយទ្រង់ត្រាស់ **បរោសហស្សជាតក** ដល់មហាជន ។

( ៣ ) ខណៈដែលព្រះសាស្តាទ្រង់គង់នៅ ក្នុងឋានតាវត្តិង្ស លើព្រះ-ទេនបណ្ឌុកម្ពលសិលាសនៈ ព្រះពុទ្ធមាតាយាងចុះមកពីតុសិតវិមាន ទ្រង់គង់នៅ

[១] ប្រែថា ផ្លិតបក់ដែលជាទិព្វ

ខាងស្តាំនៃព្រះសាស្តា **ឥន្ទកទេវបុត្ត** អង្គុយជិតព្រះពុទ្ធមាតា **អង្កុរទេវបុត្ត** អង្គុយនៅខាងឆ្វេង លុះពួកទេវតាអ្នកមានសក្តិធំមកគាល់ **អង្កុរទេវបុត្ត** ថយចេញទៅអង្គុយខាងក្រោយនៃទេវតាទាំងនោះ នៅឆ្ងាយដល់ទៅ ១២ យោជន៍ អំពីទីប្រថាប់គង់របស់ព្រះសាស្តា ចំណែកឥន្ទកទេវបុត្ត នៅអង្គុយកន្លែងដើម ។ ព្រះសាស្តាទតឃើញទេវបុត្តទាំងពីរហើយ មានព្រះបំណងនឹងញុំាងបរិស័ទឱ្យដឹងអានិសង្សទានដែលបុគ្គលថ្វាយហើយដល់ទក្ខិណេយ្យបុគ្គល ជាកុសលដែលមានផលច្រើន ទើបត្រាស់សួរថា ម្នាលអង្កុរៈ ទានដែលអ្នកបានឱ្យហើយដ៏ច្រើនអស់កាលយូរ ឥឡូវនេះអ្នកមកកាន់សមាគមរបស់តថាគត ដូចម្តេចទើបអង្គុយនៅឆ្ងាយម្លេះ ? អង្កុរទេវបុត្តក្រាបទូលថា ទានរបស់ខ្ញុំព្រះអង្គ សូម្បីបានឱ្យមហាទានដ៏ច្រើនដល់មហាជន ឱ្យប្រព្រឹត្តទៅអស់ខែ អស់បក្ស អស់រដូវ អស់ឆ្នាំរហូតកាលដ៏យូរ តែទានរបស់ខ្ញុំព្រះអង្គសូន្យចាកទក្ខិណេយ្យបុគ្គលដ៏ឧត្តម ឥន្ទកទេវបុត្តនោះឱ្យទានបន្តិចបន្តួច រុងរឿងក្រៃលែងជាងខ្ញុំព្រះអង្គ ។ ទើបព្រះសាស្តាត្រាស់ថា ពូជសូម្បីច្រើនដែលបុគ្គលសាបព្រោះហើយក្នុងស្រែទួល រមែងឱ្យផលមិនបរិបូរណ៍ ទាំងមិនញុំាងអ្នកស្រែឱ្យរីករាយចិត្ត យ៉ាងណាមិញ ទានដ៏ ច្រើនដែលបុគ្គលឱ្យហើយក្នុងអ្នកទ្រុស្តសីល រមែងមិនមានផលបរិបូរណ៍ ទាំងមិនញុំាងទាយកឱ្យរីករាយចិត្តដូច្នោះ ចំណែកពូជសូម្បីតិចដែលបុគ្គលសាបព្រោះហើយក្នុងស្រែល្អ កាលភ្លៀងបង្អូរទឹកដោយស្មើ ផលរមែងញុំាងអ្នកស្រែ

ឱ្យរីករាយចិត្ត យ៉ាងណាមិញ ទានសូម្បីតិចដែល បុគ្គលបរិច្ចាគហើយចំពោះអ្នកមានសីល មានគុណធម៌រមែងមានផលច្រើនដូច្នោះ ។

ព្រះសាស្ដាត្រាស់ថា ម្នាលអង្កុរៈ ឈ្មោះថាការជ្រើសរើសឱ្យទានរមែងគួរ ទានរបស់ឥន្ទកៈជាទានមានផលច្រើន ដូចពូជដែលសាបព្រោះល្អហើយក្នុងស្រែល្អ ឥន្ទកៈឱ្យទានដោយបាយត្រឹមតែមួយវែក ដល់ព្រះអនុរុទ្ធជាទក្ខិណេយ្យបុគ្គលប្រាសចាករាគៈ ទោសៈ មោហៈ ទើបមានផលច្រើន ដូចពូជដែលសាបព្រោះក្នុងស្រែល្អដូច្នោះ ។ ក្នុងកាលចប់ទេសនា អង្កុរទេវបុត្ត និងឥន្ទកទេវបុត្តតាំងនៅក្នុងសោតាបត្តិផល ទេសនានោះបានជាប្រយោជន៍ដល់ពួកទេវបុត្ត ដែលមកប្រជុំគ្នាក្នុងទីនោះដ៏ច្រើន ។

## ក្រោយពីចេញព្រះវស្សាទី ៧ ហើយ

(៤) តពីនោះយាងទៅក្រុងសាវត្ថី គង់នៅវត្តជេតពន ថ្ងៃមួយព្រះអង្គទ្រង់ប្រារព្ធស្រីម្នាក់ឈ្មោះ **បតិបូជិកា** ជារឿងដែលកើតឡើងក្នុងស្ថានតាវត្តិង្សទេវលោកដល់ភិក្ខុទាំងឡាយថា ទេវបុត្តនាមថា **មាលាភារី** មាននាងទេពអប្សរមួយពាន់ហែហមព្រមដោយទេពធីតា ៥០០ នាក់ ទៅកាន់សួននន្ទវ័ន ពួកទេពធីតានាំគ្នាឡើងដើមឈើ បេះផ្កាឈើមកដើម្បីប្រដាប់ទេវបុត្ត ទេពធីតាមួយអង្គចុតិលើមែកឈើនោះ បដិសន្ធិក្នុងត្រកូលមួយនៅក្រុងសាវត្ថី ។

កាលនាងមានអាយុ ១៦ ឆ្នាំ បានទៅកាន់ត្រកូលរបស់ស្វាមី រៀងរាល់ពេលនាងថ្វាយទាន ស្ដាប់ធម៌ បូជាដោយផ្កាឈើគ្រឿងក្រអូប រក្សាសិក្ខាបទ

ហើយអធិដ្ឋានសូមឱ្យចំណែកនៃបុណ្យដែលនាងធ្វើនោះ ចូរជាបច្ច័យដើម្បីកើតក្នុងសំណាក់របស់មាលាភារីទេវបុត្តទៀត វេលាកន្លងទៅនាងមានកូនទាំងអស់ ៤ នាក់ ថ្ងៃមួយនាងធ្វើមរណកាលដោយរោគម្យ៉ាង ហើយទៅកើតក្នុងសំណាក់របស់មាលាភារីទេវបុត្តដូចប្រាថ្នា ។ ទេវបុត្តសួរថា នាងបាត់មុខតាំងពីព្រឹក នាងទៅណាមកណា ? កាលបានដឹងថា នាងចុតិទៅកើតក្នុងក្រុងសាវត្ថី ទើបទេវបុត្តសួរថា អាយុរបស់មនុស្សមានប្រមាណប៉ុនណា ? ទេពធីតាតបថា មានប្រមាណជា ១០០ ឆ្នាំ មាលាភារីទេវបុត្តកើតសេចក្តីសង្វេគក្រៃលែង កាលដឹងថាពួកមនុស្សមានអាយុតិចត្រឹមមួយរយឆ្នាំ ថែមទាំងមានសេចក្តីប្រមាទ កាលណាទើបនឹងផុតទុក្ខបាន ! ។

ក៏មួយរយឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃរបស់ទេវតាជាន់តាវត្តិង្ស ព្រោះដូច្នោះ នាងទេពធីតាដែលចុតិទៅ ក៏ត្រឹមតែមួយស្របក់ក្នុងឋានតាវត្តិង្ស ទើបមាលាភារីសួរថា នាងបាត់ទៅណា? ទាំងដែលទេពធីតាទាំងនោះនៅកំពុងបេះផ្កាឈើនៅឡើយ ។ ក្នុងក្រុងសាវត្ថី ពួកភិក្ខុបុថុជ្ជនរឭកដល់ឧបការៈរបស់នាងបតិបូជិកាដឹងថា នាងចុតិហើយ ទើបនាំគ្នាទៅទូលសួរព្រះសាស្តាថា នាងបតិបូជិកាអង្គាសពួកខ្ញុំព្រះអង្គ ក្នុងពេលព្រឹកនេះឯង ឥឡូវនាងស្លាប់ហើយដោយព្យាធិដែលកើតឡើង ឥឡូវនេះនាងទៅកើតទីណា ព្រះអង្គ ? ព្រះសាស្តាត្រាស់តបថា នាងកើតក្នុងសំណាក់មាលាភារីទេវបុត្ត ជាស្វាមីនោះឯង ហើយត្រាស់តទៅទៀតថា **ជីវិតរបស់សត្វទាំងឡាយតិច មច្ចុរាជញាំងសត្វអ្នកមិន**

**ផ្អែតក្នុងកាម ឱ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ហើយនាំទៅកាន់សេចក្តីស្លាប់ ដូច្នេះ ។**

(៥) ខណៈដែលព្រះមានព្រះភាគគង់នៅវត្តជេតពន **ព្រះមហាបជាបតិគោតមីថេរី** ព្រមដោយភិក្ខុនី ៥០០ រូប ចូលគាល់ព្រះសាស្តាសូមប្រទានឱវាទ និងស្តាប់ព្រះធម្មទេសនា សម័យនោះភិក្ខុមានវារៈដែលនឹងឱ្យឱវាទភិក្ខុនី ព្រះអង្គត្រាស់សួរព្រះអានន្ទថា ថ្ងៃនេះជាវារៈរបស់ភិក្ខុណា ព្រះអានន្ទទូលថា របស់ **ព្រះនន្ទកៈ** , ទើបព្រះអង្គត្រាស់ឱ្យព្រះនន្ទកៈឱ្យឱវាទភិក្ខុនី ។ លុះវេលាព្រឹកត្រឡប់ពីបិណ្ឌបាត ក្រោយភត្ត **ព្រះនន្ទកៈ** ចូលទៅកាន់រាជការាមវិហារតែមួយអង្គឯង ភិក្ខុនីទាំងនោះថ្វាយអភិវាទហើយ និមន្តព្រះថេរៈឱ្យគង់លើអាសនៈដែលត្រៀមទុក ព្រះនន្ទកៈពោលនឹងភិក្ខុនីទាំងឡាយថា ម្នាលប្អូនស្រីទាំងឡាយ យើងនឹងសួរ នៅក្នុងការសាកសួរនោះ បើប្អូនស្រីទាំងឡាយដឹងគប្បីឆ្លើយថាដឹង មិនដឹងគប្បីឆ្លើយថាមិនដឹង បើមានសេចក្តីសង្ស័យដូចម្តេចគប្បីសាកសួរ ។

**ព្រះនន្ទកត្ថេរ** ឱ្យឱវាទទាក់ទងអាយតនៈ ១២ និង វិញ្ញាណ ៦ ឧបមាដោយសាច់គោថា សាច់ខាងក្នុងជាឈ្មោះរបស់អាយតនៈខាងក្នុង ៦ ចំណែកស្បែកខាងក្រៅជាឈ្មោះ របស់អាយតនៈខាងក្រៅ ៦ សាច់ក្នុងចន្លោះ សរសៃក្នុងចន្លោះ គ្រឿងចងក្នុងចន្លោះ ជាឈ្មោះនន្ទិរាគៈ កាំបិតដ៏មុតដែលប្រើពន្លះគោជាឈ្មោះបញ្ញាដ៏ប្រសើរដែលប្រើពន្លះ និងសំពោងកិលេស ។ ក្រោយពីព្រះនន្ទកៈ

ឱ្យឱវាទដូច្នេះហើយ បានសម្ដែងពោជ្ឈង្គៈទាំង ៧ ភិក្ខុនីទាំង ៥០០ រូប បានសម្រេចសោតាបត្តិផល សកទាគាមិផល អនាគាមិផល ព្រះនន្ទកៈត្រឡប់ទៅក្រាបទូលសេចក្ដីឱ្យព្រះសាស្ដាទ្រង់ជ្រាប ព្រះអង្គទ្រង់ត្រាស់ថា ម្នាលនន្ទកៈ សូម្បីថ្ងៃស្អែក អ្នកចូរពោលទូន្មានភិក្ខុនីដោយឱវាទនេះមួយគ្រាទៀត ។

លុះព្រឹកឡើង ព្រះនន្ទកៈទូន្មានពួកភិក្ខុនីដោយឱវាទនោះទៀត ក្រោយពីចប់ឱវាទ ភិក្ខុនីទាំង៥០០រូប បានសម្រេចអរហត្តផល ព្រមដោយអភិញ្ញា៦។

(៦) ខណៈដែលព្រះមានព្រះភាគ គង់នៅវត្តជេតពនក្រុងសាវត្ថី ព្រះបាទបសេនទិកោសលចូលគាល់ ទ្រង់ថ្វាយបង្គំហើយ បានទូលសួរសេចក្ដីសង្ស័យទាក់ទងបុគ្គលក្នុងលោកថា មានប៉ុន្មានប្រភេទ ? ព្រះអង្គទ្រង់ត្រាស់ថា មហាបពិត្រ ឈ្មោះថាបុគ្គលក្នុងលោកនេះមាន ៤ ប្រភេទ គឺ **បុគ្គលអ្នកមកងងឹតទៅវិញងងឹត** បានដល់បុគ្គលដែលកើតក្នុងត្រកូលថោកទាប មានការរស់នៅខ្វះខាត សូម្បីដូច្នោះក៏នៅតែប្រព្រឹត្តទុច្ចរិតទាំងកាយ វាចា និងចិត្ត បុគ្គលដូច្នេះកាលអស់ជីវិតហើយរមែងទៅកាន់អបាយ បុគ្គលនេះហៅថា មកងងឹតទៅវិញងងឹត ។ **បុគ្គលអ្នកមកភ្លឺទៅងងឹត** បានដល់បុគ្គលដែលកើតក្នុងត្រកូលខ្ពស់ មានភោគសម្បត្តិច្រើន តែត្រឡប់ប្រព្រឹត្តទុច្ចរិតទាំងកាយ វាចា និងចិត្ត បុគ្គលដូច្នេះកាលអស់ជីវិតហើយរមែងទៅកាន់អបាយ បុគ្គលនេះហៅថា មកភ្លឺទៅវិញងងឹត ។ **បុគ្គលអ្នកមកងងឹតទៅភ្លឺ** បានដល់បុគ្គលដែលកើតក្នុងត្រកូលថោកទាបក្រខ្សត់មានការរស់នៅខ្វះខាតមុខក្រោយលំបាក តែមានការប្រព្រឹត្តសុចរិត

ទាំងកាយ វាចា និងចិត្ត បុគ្គលដូច្នេះកាលអស់ជីវិតទៅហើយ រមែងចូលកាន់សុគតិទេវលោកដោយកុសលកម្មរបស់ខ្លួន បុគ្គលនេះហៅថា អ្នកមកងងឹតទៅវិញភ្លឺ ។ **បុគ្គលអ្នកមកភ្លឺទៅភ្លឺ** បានដល់បុគ្គលដែលកើតក្នុងត្រកូលខ្ពង់ខ្ពស់មានភោគទ្រព្យច្រើន និងបានប្រព្រឹត្តធម៌សុចរិតទាំងកាយ វាចា និងចិត្ត បុគ្គលដូច្នេះកាលអស់ជីវិតហើយ រមែងចូលកាន់សុគតិទេវលោកដោយកុសលកម្មរបស់ខ្លួន បុគ្គលនេះហៅថា អ្នកមកភ្លឺទៅវិញភ្លឺដូច្នេះ ។

( ៧ ) រយៈពេលនោះ ព្រះសាវ័ករបស់ព្រះមានព្រះភាគមានច្រើនឡើង ព្រះគុណរបស់ព្រះសាស្តាបានផ្សាយទៅយ៉ាងទូលំទូលាយ លាភសក្ការៈកើតឡើងច្រើន ចំណែកពួកតិរ្ថិយត្រឡប់សាបសូន្យលាភសក្ការៈ ទើបរកមធ្យោបាយធ្វើឱ្យព្រះសាស្តាសាបសូន្យ ក្នុងកាលនោះក្រុងសាវត្ថីមាននាងបរិព្វាជិកាឈ្មោះ **ចិញ្ចមាណវិកា** (ហៅចិញ្ចា) មានលម្អដ៏ក្រៃលែងដូចនាងទេពអប្សរ ទទួលអាសាពួកតិរ្ថិយ បង្កការយល់ខុសឱ្យកើតឡើងដល់ពួកមហាជន ដោយការធ្វើដំណើរចេញចាកក្រុងពេលល្ងាច កាលត្រូវគេសួរថាទៅទីណា នាងតបថាយើងទៅវត្តជេតពនហើយ វិលងទៅដេកពេលយប់ក្នុងសំណាក់តិរ្ថិយដែលនៅជិតនោះ, ក្នុងវេលាព្រឹក ឧបាសក ឧបាសិកាចេញចាកព្រះនគរពីព្រឹកដើម្បីទៅគាល់ព្រះសាស្តានៅវត្តជេតពន នាងក៏ធ្វើដូចជាចេញចាកវត្តជេតពនចូលទៅកាន់ព្រះនគរ ពេលកន្លងទៅ ១-២ ខែ កាលត្រូវគេសួរ នាងក៏ពោលថា ខ្ញុំនៅក្នុងព្រះគន្ធកុដិតែមួយជាមួយនឹងព្រះសមណគោតម ដោយកាលកន្លងទៅ ៣-៤ ខែទៀត នាងយក

កំណាត់សំពត់ព័ន្ធពោះធ្វើដូចជាស្រីមានគភ៌ កន្លងទៅ ៧-៨ ខែ នាងចងឈើមូលទុកត្រង់ពោះដណ្តប់សំពត់គ្របពីលើ ចូលទៅកាន់វត្តជេតពន ក្នុងខណៈដែលព្រះសាស្តាកំពុងសម្តែងព្រះធម្មទេសនា ពោលថា មហាសមណៈ ព្រះអង្គចេះតែសម្តែងធម៌ដល់មហាជន ចំណែកខ្ញុំម្ចាស់អាស្រ័យព្រះអង្គ រហូតកើតមានគភ៌គ្រប់ខែហើយ ព្រះអង្គបែរជាមិនយកចិត្តទុកដាក់ នាងបានពោលជេរព្រះសាស្តាកណ្តាលបរិស័ទ ព្រះសាស្តាទ្រង់បញ្ឈប់ធម្មកថា ត្រាស់ថា ម្នាលប្អូនស្រី ពាក្យដែលនាងពោលហើយពិត ឬកុហក តថាគតនិងនាងតែ ២ នាក់ ប៉ុណ្ណោះទេដែលដឹង ។ ហេតុនេះធ្វើឱ្យក្តៅដល់សក្កទេវរាជទ្រង់ត្រិះរិះថា យើងនឹងជម្រះរឿងនេះឱ្យបរិសុទ្ធ ទើបបញ្ជាឱ្យទេវបុត្តមួយអង្គ និម្មិតជាកណ្តុរខាំខ្សែដែលចងកំណាត់ឈើឱ្យដាច់ ទេវបុត្តមួយអង្គទៀត បណ្តាលឱ្យខ្យល់ផាត់សំពត់ដែលគ្របប៉ោងឡើង កំណាត់ឈើដែលចងរបូតធ្លាក់ចុះលើខ្នងជើង របស់នាងចិញ្ចមាណវិកាខ្នងជើងទាំង ២ បែក ពុទ្ធបរិស័ទឃើញដូច្នោះ នាំគ្នាក្រោធចំពោះអំពើរបស់នាងនាំគ្នាអូសនាងចេញទៅអំពីវិហារ ខណៈដែលផុតចាកគន្លងព្រះនេត្រ របស់ព្រះ-សាស្តា ផែនដីក៏ញែកចេញ អណ្តាតភ្លើងឆួលឡើងមកអំពីអវីចិ លេបត្របាក់រូបនាងចិញ្ចា ចុះកាន់មហានរកក្នុងពេលនោះឯង ។

លុះព្រឹកឡើង ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា នាងចិញ្ចាជេរព្រះសាស្តាដោយពាក្យមិនពិត ទើបដល់សេចក្តីវិនាសដ៏ធំ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងអតីតកាលនាងចិញ្ចាក៏ដល់

នូវសេចក្តីវិនាសយ៉ាងនេះដូចគ្នា ទើបត្រាស់មហាបទុមជាតកក្នុង **ទ្វាទសក-និបាត** ជាធម្មិកថាក្នុងពេលនោះ ។

## ព្រះវស្សាទី ៨

### ទ្រង់គង់ចាំព្រះវស្សា ក្នុងភេសកឡាវ័ន ភគ្គជនបទ

(១) ខណៈដែលព្រះសាស្តាទ្រង់គង់ក្នុងភេសកឡាវ័ន **ព្រះអនុរុទ្ធ** ស្នាក់នៅក្នុងបាចីនវង្សទាយវ័ន ព្រះអង្គទ្រង់ជ្រាបបរិវិតក្ករបស់ព្រះអនុរុទ្ធ ខណៈ

ដែលកំពុងពិចារណាធម៌ ទើបយាងទៅប្រាកដចំពោះមុខព្រះអនុរុទ្ធ ក្នុងវិហារបាចីនវង្ស ត្រាស់ថា ល្អហើយអនុរុទ្ធដែលអ្នកត្រិះរិះ **មហាបុរិសវិតក្ក** ថា **ធម៌នេះជាធម៌របស់បុគ្គលអ្នកមានសេចក្ដីប្រាថ្នាតិច ១ របស់អ្នកសន្ដោស ១ របស់អ្នកស្ងប់ស្ងាត់ ១ របស់អ្នកប្រារព្ធព្យាយាម ១ របស់អ្នកមានសតិតាំងមាំ ១ របស់អ្នកមានចិត្តតាំងមាំ ១ របស់អ្នកមានបញ្ញា ១** នោះត្រឹមត្រូវហើយ ។

អ្នកគប្បីពិចារណាធម៌ទី ៨ បានដល់ **ធម៌មិនជាហេតុឱ្យយឺតយូរ** គឺ **ព្រះនិព្វាន** បន្ថែមឡើងមួយប្រការទៀត និងជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន រួចត្រាស់ថា អនុរុទ្ធអ្នកគប្បីនៅចាំវស្សាក្នុងបាចីនវង្សនេះហើយ ។ បន្ទាប់មកព្រះអង្គយាងត្រឡប់មកភេសកឡាវ័ន ហើយទ្រង់សម្ដែងមហាបុរិសវិតក្ក ៨ ប្រការ ដល់ភិក្ខុទាំងឡាយម្ដងទៀត ព្រះអនុរុទ្ធគេចចេញចាកពួកតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាម មិនយូរប៉ុន្មានក៏បានធ្វើឱ្យជាក់ច្បាស់នូវអរហត្តផលក្នុងបាចីនវង្សនោះឯង ។

(២) **បិតារបស់សិង្គាលកបុត្រ** លះចំណងក្នុងផ្ទះ ចេញបួសក្នុងព្រះ-ពុទ្ធសាសនា ព្រះសាស្ដាទ្រង់ជ្រាបអធ្យាស្រ័យ ទ្រង់ប្រទានអដ្ឋិកសញ្ញាកម្មដ្ឋាន, **ឱ្យសិង្គាលបិតាភិក្ខុ** ទទួលកម្មដ្ឋានហើយ ចូលមកស្នាក់នៅក្នុងភេសកឡាវ័ន ទេវតានៅក្នុងព្រៃនេះ ប្រាថ្នានឹងសង្គ្រោះភិក្ខុនោះឱ្យមានឧស្សាហ៍ ដើម្បីនឹងបានសម្រេចអរហត្តផលក្នុងកាលមិនយូរ ទើបពោលគាថា ដូច្នេះថា :

**ភិក្ខុនៅក្នុងភេសកឡាវ័ន ពិចារណាផែនដីនេះដោយសេចក្តីថា ឆ្អឹងទាំងអស់ជាអារម្មណ៍ នឹងបានជាទាយាទរបស់ព្រះពុទ្ធជាម្ចាស់ ហើយនឹងលះបង់កាមរាគៈបានដោយឆាប់រហ័ស ។**

**សិង្គាលបិតាភិក្ខុ** បានស្តាប់គាថារបស់ទេវតាដូច្នេះហើយ អធិដ្ឋានសេចក្តីព្យាយាម រុលទៅមុខមិនថយក្រោយ ចម្រើនវិបស្សនាបានសម្រេចអរហត្តហើយក្នុងវេលាមិនយូរ ។

(៣) ក្នុងចន្លោះវស្សានេះ ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ច ប្រោសវេនេយ្យសត្វទាំងឡាយឱ្យសម្រេចមគ្គផល ដោយព្រះធម្មទេសនាដ៏ច្រើន ដូចជាត្រាស់ **ពោធិរាជកុមារសូត្រ** ចំពោះពោធិរាជកុមារថា គប្បីរក្សាខ្លួនទុកឱ្យល្អក្នុងវ័យទាំង ៣ មិនគួរប្រមាទក្នុងកុសលទាំងបឋមវ័យ មជ្ឈិមវ័យ និងបច្ឆិមវ័យ បើមិនអាចធ្វើបានទាំង ៣ វ័យ **ចូរតម្កល់ខ្លួនទុកក្នុងកុសលចំពោះវ័យណាមួយក៏បាន** ។ ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកពោលថា ព្រះអង្គត្រាស់ដល់អ្នកមានព្យាយាម ៥ ប្រការ ថានឹងត្រូវប្រកបដោយ **សទ្ធា ១ ប្រាសចាករោគ ១ មិនអួតអាង ១ មានព្យាយាមលះអកុសល ១ មានបញ្ញា ១** បើអ្នកណាប្រកបដោយអង្គ ៥ នេះហើយ នឹងសម្រេចគុណវិសេសបានដោយឆាប់ ចប់ព្រះធម្មទេសនា ពោធិរាជកុមារបានសម្រេចសោតាបត្តិផល ។

(៤) **សិរិមណ្ឌៈ** ជាបុត្រព្រាហ្មណ៍ ក្នុងសុង្សុមារគីរីនគរ ខណៈដែលព្រះមានព្រះភាគទ្រង់គង់នៅភេសកឡាវ័ន ចូលទៅគាល់ព្រះសាស្តា ស្តាប់ធម៌

ហើយកើតសទ្ធា បួសហើយធ្វើសមណធម៌ ក្នុងថ្ងៃឧបោសថមួយ អង្គុយនៅក្នុងទីសម្តែងបាតិមោក្ខ ពិចារណាខ្លឹមសាររបស់បាលីថា « **ភិក្ខុបើកនូវអាបត្តិហើយ រមែងមានសេចក្តីសុខ ភិក្ខុណាបិទបាំងអាបត្តិទុក ត្រូវអាបត្តិថែមទៀត ភិក្ខុនោះរមែងនៅមិនសុខ ក៏ភិក្ខុបើកនូវអាបត្តិហើយ សម្តែងអាបត្តិតាមធម៌ រមែងមានសេចក្តីសុខ** »។

សិរិមណ្ឌៈ កើតសេចក្តីជ្រះថ្លាថា ពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាបរិសុទ្ធពិត ទើបគ្របសង្កត់បីតិដែលកើតឡើងយ៉ាងនោះហើយ ចម្រើនវិបស្សនាបានសម្រេចព្រះអរហត្ត ពិចារណាការបដិបត្តិរបស់ខ្លួនហើយ មានចិត្តជ្រះថ្លាកាលឱ្យឱវាទដល់ភិក្ខុទាំងឡាយ ទើបពោលគាថាយ៉ាងនេះថា :

**សត្វលោកត្រូវមច្ចុកម្ទាត់ ត្រូវជរារួបរិត ត្រូវកូនសរ គឺតណ្ហាចាក់ដោត ត្រូវសេចក្តីប្រាថ្នាដុតរោលគ្រប់កាល មិនមានអ្វីជាពឹងពាក់បាន រមែងក្តៅក្រហាយជានិច្ច ។**

**ជរា ព្យាធិ និងមរណៈ ដូចជាគំនរភ្លើងតាមគ្របសង្កត់ សេចក្តីស្លាប់រមែងរុកទន្ទ្រានចូលទៅជិតបុគ្គល គ្រប់ឥរិយាបថ, មិនគួរបណ្តោយពេលវេលាឱ្យកន្លងទៅឥតប្រយោជន៍ រាត្រីកន្លងទៅប៉ុនណា ជីវិតរបស់សត្វក៏អស់ទៅប៉ុណ្ណោះ ទើបមិនគួរធ្វេសប្រហែសពេលវេលាឡើយ ។**

គួរដាក់ចិត្តក្នុងវិបស្សនា ច្រើនខ្លះ តិចខ្លះ មិនឱ្យថ្ងៃកន្លងទៅដោយឥតប្រយោជន៍ ព្រោះថា កាលកន្លងទៅប៉ុនណា ជីវិតរបស់សត្វក៏អស់ទៅប៉ុណ្ណោះ

ទើបលោកសម្ដែងថា ការអស់ទៅនៃរាត្រី ជាការអស់ទៅនៃអាយុ ព្រោះរាត្រីនោះមិនងាកត្រឡប់មកវិញ អ្នកមិនប្រមាទទូន្មានខ្លួនយ៉ាងនេះហើយ គប្បីធ្វើសេចក្ដីព្យាយាមក្នុងសិក្ខាទាំង ៣ ចុះ ។

(៥) អដ្ឋកថាអង្គុត្តរនិកាយ ឯកនិបាត ឯតទគ្គបាលីពោលទុកថា កាលព្រះសាស្ដាទ្រង់គង់ក្នុងភេសកឡាវ៉ន **នកុលបិតាគហបតី** បានចូលមកគាល់ព្រមដោយពួកអ្នកដែនសុង្សុមារគិរីនគរ ដោយការចូលគាល់លើកដំបូងប៉ុណ្ណោះ គេនិងភរិយាក៏តាំងសេចក្ដីសម្គាល់ថា ព្រះទសពលជាបុត្ររបស់ខ្លួន ទើបក្រាបចុះក្បែរព្រះយុគលបាទហើយក្រាបទូលថា កូនអើ្ហយ ! កូនឯងចោលពុកម៉ែអស់វេលាប៉ុណ្ណេះត្រាច់ទៅណា? ដោយសេចក្ដីស្រឡាញ់ដែលជាប់តាមមករហូតអស់កាលយូរ លុះបានជួបក៏សម្គាល់ថាបុត្រ ទើបអ្នកទាំងពីរបានពោលវាចាដូច្នោះ តែព្រះសាស្ដាក៏មិនបានត្រាស់ពាក្យពេចន៍អ្វីឡើយ ព្រោះជ្រាបសេចក្ដីដែល **នកុលបិតា** ធ្លាប់ជាប់ជាបិតា ជាឪពុកមា ជាតា ជាអ៊ុំ ចំណែក **នកុលមាតា** ក៏ធ្លាប់ជាមាតា ជាម្ដាយមីង ជាយាយ ជាអ៊ុំស្រី មកពីក្នុងអតីតៈដ៏ច្រើន ។

កាលនកុលៈទាំងពីរ ត្រឡប់មានសតិដូចដើមហើយ ទើបព្រះសាស្ដាទ្រង់សម្ដែង **នកុលបិតុសូត្រ** កាលចប់ទេសនា ទាំងពីរនាក់ក៏តាំងនៅក្នុងសោតាបត្តិផល ព្រះអង្គបានត្រាស់សម្ដែងព្រះគាថានេះថា :

**សេចក្ដីស្រឡាញ់កើតឡើងព្រោះធ្លាប់នៅរួមគ្នាមកពីមុន ឬព្រោះសង្គ្រោះគ្នាក្នុងបច្ចុប្បន្ន ដូចផ្កាឈូកកើតឡើងអាស្រ័យទឹក និងភក់ដូច្នោះ ។**

តមក ក្នុងវេលាដែលព្រះមានព្រះភាគទ្រង់ព្រះជរា បានយាងទៅកាន់ដែនភគ្គៈទៀត អ្នកទាំងពីរនោះជ្រាបថាព្រះសាស្ដាយាងមក ទើបទូលអារាធនាដើម្បីទទួលភត្ត លុះព្រឹកឡើងក៏អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយភោជនមានរសដ៏ប្រណីតផ្សេងៗ ក្នុងនិវេសន៍របស់ខ្លួន ទូលព្រះអង្គថា ខ្ញុំព្រះអង្គប្រាថ្នាឱ្យជួបគ្នា ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងភពខាងមុខ ព្រះអង្គ !

ទើបព្រះសាស្ដាទ្រង់ទូន្មានថា ម្នាលគហបតី និងគហបតានី បើស្វាមីភរិយាប្រាថ្នាឱ្យបានជួបគ្នាទាំងក្នុងជាតិនេះ និងជាតិមុខសោត អ្នកទាំងពីរ **គប្បីជាអ្នកមានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា មានបញ្ញាស្មើគ្នា** ក៏នឹងបានជួបគ្នាទាំងក្នុងជាតិនេះ និងជាតិមុខ ។ តមកខាងក្រោយ ខណៈដែលគង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់សរសើរនកុលបិតា និងនកុលមាតាទាំងពីរថា ជាកំពូលជាងឧបាសក និងឧបាសិកាអ្នកស្និទ្ធស្នាលនឹងព្រះអង្គ ។

## ក្រោយអំពីចេញព្រះវស្សាហើយ

(៦) ព្រះពុទ្ធអង្គទ្រង់គង់នៅក្នុងភេសកឡាវ័ន ខណៈនោះចូលកាន់រដូវរងា ភិក្ខុទាំងឡាយបង្កាត់ភ្លើង ដោយកំណាត់ឈើមានប្រហោងមួយដុំ ដើម្បីអាំងភ្លើង ពស់វែកក្នុងប្រហោងឈើត្រូវភ្លើងរោលក្តៅ ទើបលូនចេញមកដេញពួកភិក្ខុ ពួកភិក្ខុរត់គេចទៅក្នុងទីផ្សេងៗ ព្រះមានព្រះភាគជាម្ចាស់ជ្រាបសេចក្តីនោះ ទ្រង់តិះដៀល ហើយបញ្ញត្តសិក្ខាបទថា **ភិក្ខុណាប្រាថ្នាការអាំងភ្លើង បង្កាត់ភ្លើងក្តី ឱ្យគេបង្កាត់នូវភ្លើងក្តី ត្រូវអាបត្តិបាចិត្តិយៈ** តែទ្រង់អនុញ្ញាតដល់ភិក្ខុអាពាធអាំងភ្លើងបាន ។

បន្ទាប់មកទៀត ស្តេចយាងត្រឡប់ទៅគង់នៅនាវត្តជេតវ័ន ទ្រង់សម្តែងធម៌ប្រោសពុទ្ធបរិស័ទទាំង ៤ ឱ្យតាំងនៅក្នុងធម៌ តាមសមគួរដល់អធ្យាស្រ័យ ។

(៧) គ្រានោះ ព្រាហ្មណ៍ ២ នាក់ ចាស់ជរាកន្លងបច្ឆិមវ័យ មានអាយុ ១២០ ឆ្នាំ ចូលមកគាល់ព្រះមានព្រះភាគ ក្រាបទូលថា ខ្ញុំព្រះអង្គជាព្រាហ្មណ៍កន្លងកាលមករហូតដល់បច្ឆិមវ័យហើយ មិនទាន់បានធ្វើសេចក្តីល្អ មិនទាន់បានសាងកុសល មិនទាន់បានធ្វើគ្រឿងការពារភ័យ សូមព្រះគោតមដ៏ចម្រើនប្រោសមេត្តាទ្រង់ឱ្យឱវាទប្រៀនប្រដៅខ្ញុំព្រះអង្គ ដែលនឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គ អស់កាលដ៏យូរអង្វែងផងចុះ ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់សម្តែងថា **សត្វលោកនេះត្រូវជាតិនាំទៅកាន់ជរា ត្រូវជរានាំទៅកាន់ព្យាធិ ត្រូវព្យាធិនាំទៅកាន់មរណៈ ត្រូវ**

**មរណៈនាំទៅកាន់ជាតិ** គឺការកើតទៀត **គប្បីសង្រួមកាយ វាចា ចិត្ត ឱ្យជាទីពឹងក្នុងភពខាងមុខចុះ** កាលផ្ទះត្រូវភ្លើងឆេះ ម្ចាស់ផ្ទះជញ្ជូនវត្ថុណាចេញបាន វត្ថុនោះក៏នឹងបានជាប្រយោជន៍ដល់ម្ចាស់ផ្ទះ ដូចសត្វលោកដែលជរាមរណៈឆេះយ៉ាងនេះ សត្វលោកគប្បីជញ្ជូនចេញដោយការឱ្យទានចុះ វត្ថុណាដែលឱ្យជាទានទៅហើយ ឈ្មោះថា បានជញ្ជូនចេញយ៉ាងល្អហើយ ព្រោះហេតុដែលព្រាហ្មណ៍នោះ សូម្បីបួសហើយក៏មិនអាចបំពេញវត្តឱ្យបរិបូរណ៍បាន ព្រោះជរាណាស់ទៅហើយ ទើបព្រះមានព្រះភាគជាម្ចាស់ទ្រង់ឱ្យសមាទានសីល ៥។ ព្រាហ្មណ៍នោះសមាទានសីល ៥ រក្សាសីល ៥ ឱ្យបរិបូរណ៍អស់មួយជីវិត បានកើតហើយក្នុងសួគ៌ា ព្រោះការសង្រួមកាយ វាចា និងចិត្ត ដែលតាំងចិត្តសមាទានទុកដោយប្រពៃ បុណ្យរមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសុខដល់គេ ដែលលះលោកនេះទៅហើយ ដូច្នេះ ។

(៨) ខណៈដែលព្រះពុទ្ធអង្គទ្រង់គង់នៅក្នុងព្រះជេតវនវិហារ ក្នុងវេលាជិតភ្លឺទ្រង់ឃើញឧបនិស្ស័យព្រះអរហត្តនៃ **មាគន្ទិយព្រាហ្មណ៍** ពីរនាក់ស្វាមីភរិយា អ្នកស្រុកកម្មាសទម្មនិគម **ដែនកុរុ** ទើបយាងទៅប្រថាប់គង់នៅនាដងព្រៃមួយក្នុងនិគមនោះ ។ មាគន្ទិយព្រាហ្មណ៍ទៅកាន់ដងព្រៃនោះ បានឃើញព្រះវស្នីពណ៌មាសរបស់ព្រះសាស្ដា ក៏សប្បាយចិត្តដោយបំណងនឹងលើកធីតាឱ្យ ទើបប្រញាប់ត្រឡប់ទៅផ្ទះដើម្បីប្រាប់នាងព្រាហ្មណី ហើយនាំធីតាមក ខណៈនោះ ព្រះពុទ្ធអង្គចូលទៅបិណ្ឌបាតក្នុងកម្មាសទម្មៈ នាងព្រាហ្មណីឃើញ

ស្មាមព្រះបាទហើយពោលថា សមណៈនេះមិនបរិភោគកាមដោយពិត ។

ព្រាហ្មណ៍ជាបិតាដឹកដៃធីតាចូលទៅហើយពោលថា បព្វជិតដ៏ចម្រើន លោកមានសម្បុរដូចមាស ទារិកានេះក៏មានសម្បុរដូចមាស ទើបទារិកានេះសមគួរដល់លោក ។ ព្រះពុទ្ធអង្គត្រាស់ថា តថាគតមិនមានការពេញចិត្តក្នុងមេថុន សូម្បីព្រោះឃើញធីតារបស់មារទៀបគល់អជបាលនិគ្រោធ ដូចម្ដេចនឹងមានការពេញចិត្ត ព្រោះឃើញធីតារបស់អ្នកដែលពេញទៅដោយមូត្រ និងករីសដូច្នេះ ។ ក្នុងទីបំផុតនៃគាថា ព្រាហ្មណ៍ និងព្រាហ្មណីតាំងនៅក្នុងអនាគាមិផល ចំណែកធីតារបស់មាគន្ទិយព្រាហ្មណ៍ក្រោធខឹង ចងអាឃាតជាមួយនឹងព្រះពុទ្ធអង្គតាំងពីនោះមក ។ មាគន្ទិយព្រាហ្មណ៍ទូលសួរថា ធម្មតាបព្វជិតលះបង់កាមដែលជារបស់មនុស្ស ហើយបួសដើម្បីកាមដែលជារបស់ទិព្វ តែសមណៈនេះមិនប្រាថ្នាកាមសូម្បីជារបស់ទិព្វ អ្វីហ្ន៎ជាទិដ្ឋិរបស់សមណៈនេះ ? ព្រះអង្គត្រាស់ថា បុគ្គលលះបង់ធម៌ដែលជាផ្នែកខ្មៅ ដោយការដកចេញ មិនប្រកាន់មាំ ឈ្មោះថា ជាអ្នកស្ងប់ ព្រោះស្ងប់ចាកកិលេសខាងក្នុង ស្ងប់ចាកតណ្ហា ស្ងប់ចាកទិដ្ឋិ មិនគប្បីប្រាថ្នាភពណាៗ នេះជាសេចក្ដីស្ងប់ក្នុងខាងក្នុងនៃបុគ្គលអ្នកលះតណ្ហា មានះ ទិដ្ឋិបាន ឈ្មោះថា រួចផុតហើយចាកកិលេសទាំងពួង មិនញុំាងអត្តភាពឱ្យកើតទៀត កាលចប់ទេសនា មាគន្ទិយព្រាហ្មណ៍ទាំងពីរនាក់សូមបួស ហើយបានសម្រេចអរហត្តផល នាំធីតាទៅផ្ញើទុកជាមួយនឹងចូឡមាគន្ទិយាដែលជាឪពុកមាហើយទៅកាន់សំណាក់ព្រះសាស្ដា ។

(៩) ក្នុងកុរុរដ្ឋនេះ ខណៈដែលព្រះពុទ្ធអង្គយាងដល់ថុល្លកោដ្ឋិតនិគម កុលបុត្រឈ្មោះ **រដ្ឋបាល** បានស្តាប់ព្រះធម៌ទេសនាហើយ កើតសទ្ធាជ្រះថ្លាចង់បួស ធ្វើការអត់នូវអាហារអស់ ៧ ថ្ងៃ ទើបមាតាបិតាអនុញ្ញាតឱ្យបួស បានចូលទៅគាល់ព្រះពុទ្ធអង្គ បួសហើយក្នុងសំណាក់នៃព្រះថេរៈមួយរូប តាមព្រះបញ្ជារបស់ព្រះសាស្តា។ ព្រះពុទ្ធអង្គទ្រង់ប្រថាប់នៅនា ថុល្លកោដ្ឋិតគ្រាម អស់កន្លះខែ ហើយយាងត្រឡប់ទៅក្រុងសាវត្ថី ព្រមដោយព្រះរដ្ឋបាល, ព្រះថេរៈធ្វើកិច្ចក្នុងយោនិសោមនសិការ ចម្រើនវិបស្សនាសម្រេចអរហត្ត ហើយបានទូលសូមការអនុញ្ញាតពីព្រះសាស្តា ត្រឡប់ទៅសួរសុខទុក្ខមាតាបិតានាថុល្លកោដ្ឋិតគ្រាម ទៅសម្រាកនៅក្នុងសួនរបស់ព្រះរាជានៃដែនកុរុ ព្រឹកឡើងទៅបិណ្ឌបាតឯផ្ទះ ជួបនាងទាសីកំពុងចាក់នំកុម្មាសផ្អូមចោល ទើបចូលទៅសូមបិណ្ឌបាតនំនោះពីនាងទាសី នាងទាសីចាំសំឡេងបាន ទើបប្រគេននំនោះ ហើយចូលទៅប្រាប់ដល់មាតាបិតា បិតាចេញមកឃើញលោកកំពុងឆាន់នំផ្អូមស្រេចហើយ បាននិមន្តចូលទៅក្នុងផ្ទះ តែព្រះថេរៈមិនព្រមចូលទៅ ។ ស្អែកឡើងព្រះរដ្ឋបាលចូលទៅបិណ្ឌបាតឯផ្ទះទៀត បិតាព្យាយាមប្រលោមចិត្តដោយភោគទ្រព្យ ព្រោះត្រូវការឱ្យបុត្រត្រឡប់មកជាឃរាវាសដូចដើម ព្រះថេរៈបានឃើញអតីតភរិយាតែងខ្លួនយ៉ាងស្រស់ស្អាត កើតអសុភសញ្ញាក្នុងស្ត្រីនោះ សម្រេចអភិញ្ញាហោះទៅកាន់ **មិគាចិរៈ** ឧទ្យានរបស់ព្រះបាទកោរព្យៈ ដែលជាព្រះរាជានៃដែនកុរុ ឈរសម្តែងធម៌ដែលប្រកបដោយសេចក្តីជ្រះថ្លា ៤ ប្រការ ដល់ព្រះរាជាដែលមកសួរសុខទុក្ខ

ក្នុងឧទ្យាននោះថា :

**១-ឧបនីយតិ លោកោ អទ្ធុវោ** សត្វលោកដែលជរានាំទៅ មិនតាំងនៅយូរ ។

**២-អតាណោ លោកោ អនភិស្សរោ** សត្វលោកមិនមានទីពឹងពួន មិនជាឥស្សរៈលើខ្លួនឯង ។

**៣-អស្សកោ លោកោ សព្វំ បហាយ គមនីយំ** សត្វលោកមិនមានវត្ថុណាជារបស់ខ្លួន ត្រូវលះបង់នូវវត្ថុគ្រប់យ៉ាងហើយទៅ ។

**៤-ឩនោ លោកោ អតិត្តោ តណ្ហាទាសោ** សត្វលោកខ្វះកន្លះជានិច្ច មិនចេះឆ្អែតជាទាសៈរបស់តណ្ហា ។ ព្រះរដ្ឋបាលចារិកទៅដោយលំដាប់ ត្រឡប់ទៅគាល់ព្រះសាស្តានាក្រុងសាវត្ថីទៀត តមក ព្រះអង្គទ្រង់សរសើរព្រះរដ្ឋបាលថា ជាកំពូលជាងភិក្ខុទាំងឡាយអ្នកបួសដោយសទ្ធា ។

(១០) សម័យនោះតាបស ៥០០ នាក់ដែលស្នាក់នៅក្នុងព្រៃហិមពាន្តចូលមកភិក្ខាចារក្នុងក្រុងកោសម្ពីជាប្រចាំ សេដ្ឋីក្រុងកោសម្ពី ៣ នាក់ គឺ **ឃោសកៈ កុក្កុដៈ** និង **បាវារិកៈ** ឃើញតាបសទាំងនោះហើយ កើតសេចក្តីជ្រះថ្លាទើបនិមន្តឱ្យទទួលភិក្ខានៅផ្ទះរបស់ខ្លួនទាំង ៣ ជាប្រចាំ ។ មុនដល់រដូវភ្លៀងគ្រាមួយពួកតាបសធ្វើដំណើរពីព្រៃហិមពាន្ត ដើម្បីមកកាន់ក្រុងកោសម្ពី ក្នុងចន្លោះផ្លូវឆ្មៀងចុះសម្រាកក្បែរគល់ជ្រៃធំមួយដើម រុក្ខទេវតាដែលស្ថិតនៅត្រង់ដើមជ្រៃនោះ សម្តែងកាយចេញមកឱ្យទឹកភេសជ្ជៈ, ពួកតាបសឃើញរុក្ខទេវតាប្រដាប់ដោយអាភរណៈទិព្វដ៏ស្រស់ស្អាត ទើបសួរថា អ្នកបានសម្បត្តិនេះដោយ

ផលបុណ្យណា រុក្ខទេវតាពោលឱ្យស្តាប់ថា ជាផលពីការដែលខ្ញុំបានអធិដ្ឋានអង្គ ឧបោសថកន្លះថ្ងៃ កាលដែលខ្ញុំចាប់កំណើត ជាបរិវាររបស់លោកអនាថបិណ្ឌិក សេដ្ឋី ហើយបានធ្វើកាលកិរិយាក្នុងល្ងាចថ្ងៃនោះ មកកើតជារុក្ខទេវតាក្នុងទីនេះ សេដ្ឋីនោះជាអ្នកដែលមានសទ្ធាខ្លាំង ចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះធម៌ និង ព្រះសង្ឃ ។ ពួកតាបសបានស្តាប់ពាក្យថា **ព្រះសម្មាសម្ពុទ្ធ** កើតសេចក្តីជ្រះថ្លា តាំងចិត្តធ្វើដំណើរទៅគាល់ព្រះសាស្តា លុះដល់ក្រុងកោសម្ពី ក៏ចូលទៅប្រាប់ បំណងដល់សេដ្ឋីទាំងបី សេដ្ឋីពោលថា ពួកយើងខ្ញុំនឹងសូមទៅតាមលោកផង តាបសធ្វើដំណើរទៅមុន កាលចូលគាល់ព្រះសាស្តានៅជេតវនវិហារ ស្តាប់ធម៌ ទេសនាហើយ តាបសទាំង ៥០០ បានសម្រេចអរហត្តព្រមដោយបដិសម្ភិទា ទាំងអស់ ទើបទូលសូមបព្វជ្ជាឧបសម្បទា ព្រះសាស្តាទ្រង់ប្រទានឯហិភិក្ខុឧប-សម្បទា ។ សេដ្ឋីទាំង ៣ ព្រមដោយរទេះផ្ទុកគ្រឿងទេយ្យធម៌ជាចំនួនច្រើន តាមមកខាងក្រោយ តាំងទីស្នាក់នៅក្បែរវត្តជេតពន បានថ្វាយទានក្នុងទីនោះ ប្រមាណកន្លះខែ កាលទទួលស្តាប់ព្រះធម៌ទេសនាហើយ បានសម្រេចសោតា-បត្តិផល ទូលអារាធនាព្រះពុទ្ធអង្គ ឱ្យស្តេចទៅគង់នៅក្នុងក្រុងកោសម្ពី ។

(១១) សេដ្ឋីទាំង ៣ ត្រឡប់មកដល់ក្រុងកោសម្ពីវិញ ម្នាក់ៗ កសាង អារាមមួយៗ ម្នាក់ ឃោសកសេដ្ឋីកសាង **ឃោសិតារាម** បាវារិកសេដ្ឋីសាង **បាវារិការាម** កុក្កុដសេដ្ឋីសាង **កុក្កុដារាម** ក្រោយពីសាងវិហារស្រេច ទើបទៅអារាធនាព្រះពុទ្ធអង្គ ។

កាលព្រះសាស្ដាយាងមកដល់ ទើបសេដ្ឋីថ្វាយវិហារដល់ភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ ដែលមានព្រះពុទ្ធជាប្រធាន ព្រះសាស្ដាអនុមោទនា និងទ្រង់គង់ក្នុងអារាមទាំង ៣ នោះ សេដ្ឋីម្នាក់ៗ ក៏ផ្លាស់ប្ដូរគ្នាឧបដ្ឋាកព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងភិក្ខុសង្ឃតាមវារៈរបស់ខ្លួន ។

# ព្រះវស្សាទី ៩

## ទ្រង់គង់ចាំព្រះវស្សា ក្នុងឃោសិតារាម ក្រុងកោសម្ពី

មជ្ឈិមនិកាយ មូលបណ្ណាសក អដ្ឋកថា កោសម្ពិយសូត្រ ពោលថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងឃោសិតារាម ។

(១) **នាងសមាវតី** ជាធីតារបស់ភទ្ទវតីសេដ្ឋី នៅភទ្ទវតីនគរ ដែលជាសម្លាញ់នឹងឃោសកសេដ្ឋី នៃក្រុងកោសម្ពី កាលនោះកើតរោគរាតត្បាតក្នុងស្រុករបស់ភទ្ទវតី សេដ្ឋីម្នាក់ៗ នាំគ្នាភៀសខ្លួនគេចភ័យដែលកើតឡើង ទ្រព្យសម្បត្តិដែលមានក៏ខ្ចាត់ខ្ចាយទៅទាំងអស់ ទើបសេដ្ឋី ភរិយា និងធីតា ភៀសខ្លួនទៅកាន់ក្រុងកោសម្ពី អាស្រ័យរោងទានឃោសកសេដ្ឋីដើម្បីនាំអាហារមកបរិភោគ ថ្ងៃដំបូងនាងទៅសូមចំណែកអាហារ ៣ ចំណែក សម្រាប់ ឪពុកម្ដាយកូន យប់នោះសេដ្ឋីជាបិតាស្លាប់ទៅ ស្អែកឡើងនាងទៅសូមអាហារតែ ២ ចំណែក ក្នុងយប់នោះមាតាក៏ដល់នូវកាលកិរិយាម្នាក់ទៀត ថ្ងៃទី ៣ ទើបនាងទៅទទួលយកអាហារ ត្រឹមតែមួយចំណែកប៉ុណ្ណោះ ។

នាយមិត្តៈអ្នកចែកអាហារសង្ស័យ នាងរៀបរាប់សេចក្ដីពិតឱ្យស្ដាប់ ទើបនាយមិត្តៈទទួលនាងជាកូនធម៌ កាលនាងទៅនៅឯរោងទានបានឮសំឡេងគឹកកងក្នុងរោងទាន ទើបប្រាប់ឪពុកធម៌ឱ្យធ្វើរបងដើម្បីឱ្យចូលចេញបានម្ដងម្នាក់ សំឡេងគឹកកងទើបស្ងប់ស្ងាត់ទៅ តមកឃោសកសេដ្ឋីម្ចាស់នៃរោងទានសង្ស័យថា ហេតុអីសំឡេងរបស់មនុស្សទើបស្ងប់ស្ងាត់ទៅ ដឹងថាជាការគិតរបស់

នាងសមាវតី ដែលជាធីតារបស់សម្លាញ់នៃខ្លួន ទើបទទួលនាងទុកជាធីតា ។ **ព្រះបាទឧទេន** ព្រះរាជាក្រុងកោសម្ពីទតឃើញនាង **សមាវតី** ក្នុងថ្ងៃបុណ្យនក្ខត្តឫក្ស ខណៈដែលនាង និងបរិវារចេញមកទស្សនាការលេង ទ្រង់ពេញព្រះទ័យ ទើបសូមនាងអំពីឃោសកសេដ្ឋី ហើយអភិសេកនាងទុកក្នុងឋានៈជាអគ្គមហេសី ។

គ្រានោះ **នាយសុមនៈ** ដែលជាអ្នកក្រងផ្កាឈើរបស់សេដ្ឋីទាំង ៣ បានសូមឱកាសពីសេដ្ឋី ដើម្បីថ្វាយទានដល់ព្រះសាស្ដា និងភិក្ខុសង្ឃតែមួយថ្ងៃ សេដ្ឋីអនុញ្ញាត ទើបនាយសុមនៈនិមន្តព្រះសាស្ដា និងត្រៀមគ្រឿងសក្ការៈដើម្បីការថ្វាយទានក្នុងថ្ងៃស្អែកឡើង ។

ជាប្រក្រតី **នាងខុជ្ជុត្តរា** ទាសីរបស់ព្រះនាងសមាវតី មាននាទីមកទទួលផ្កាឈើអំពីនាយសុមនៈជាប្រចាំ ក្នុងថ្ងៃនោះសុមនមាលាការពោលនឹងនាងខុជ្ជុត្តរាថា ថ្ងៃនេះខ្ញុំនឹងថ្វាយទាន និងបូជាព្រះសាស្ដាដោយផ្កាឈើដ៏លើស សូមនាងចូររង់ចាំជួយក្នុងការងារនេះ និងស្ដាប់ធម៌សិនហើយសឹមទទួលផ្កាឈើទៅ នាងយល់ព្រម ។ ក្រោយភត្តកិច្ច ព្រះសាស្ដាទ្រង់អនុមោទនា ហើយបានសម្ដែងធម៌ដល់ជនទាំងនោះ នាងខុជ្ជុត្តរាស្ដាប់ព្រះធម៌ទេសនាហើយ តាំងនៅក្នុងសោតាបត្តិផល លុះត្រឡប់មកកាន់ព្រះរាជនិវេសន៍វិញ ទើបនាងប្រាប់សេចក្ដីនោះឱ្យព្រះនាងសមាវតីដឹង ទើបព្រះនាងសុំឱ្យនាងខុជ្ជុត្តរាសម្ដែងធម៌នោះដល់ខ្លួន និងបរិវារ ៥០០ នាក់ទៀត កាលចប់ការសម្ដែងធម៌ ជនទាំងនោះ

ក៏បានសម្រេចសោតាបត្តិផល លើកនាងទុកក្នុងឋានៈជាអាចារ្យ សូមឱ្យនាងទៅស្តាប់ធម៌ពីព្រះសាស្តា ហើយនាំមកសម្តែងដល់ពួកខ្លួនរាល់ៗ ថ្ងៃ ។

(២) **ព្រះនាងវាសុលទត្តា** ជាធីតារបស់ព្រះបាទចណ្ឌបជោតិ ព្រះរាជានៃក្រុងឧជ្ជេនី ថ្ងៃមួយព្រះបាទចណ្ឌបជោតិ ទ្រង់ឃើញថាសម្បត្តិរបស់ព្រះបាទឧទេននៃក្រុងកោសម្ពីមានច្រើន ទើបគិតចាប់ព្រះបាទឧទេន អាមាត្យទូលថា បើចាប់ឱ្យបានក៏ត្រូវប្រើកិច្ចកលបញ្ឆោត ព្រោះស្តេចទ្រង់ស្រវឹងក្នុងរឿងដំរី ទ្រង់រាយមន្តហើយដេញពិណហត្ថីកណ្ណនឹងឱ្យដំរីគេចទៅក៏បាន នឹងចាប់យកក៏បាន ព្រះអង្គគួរនឹងប្រើជាងសាងដំរីយន្តជាដំរីឈើក ហើយឱ្យមនុស្សលាក់ខ្លួននៅខាងក្នុងពោះដំរីនោះ ដើម្បីបញ្ជាគ្រឿងយន្ត បន្ទាប់ពីនោះក៏នាំកម្លាំង ពួនស្ទាក់នៅក្បែរផ្លូវ កាលព្រះបាទឧទេនលង់ខ្លួនចូលមក ក៏នឹងចាប់ខ្លួនបានដោយពិត ។

ព្រះរាជាធ្វើតាមគំនិតរបស់ពួកអាមាត្យ ទើបចាប់ព្រះបាទឧទេនបាន ព្រះរាជាបញ្ជាឱ្យនាំមកឃុំឃាំងទុកក្នុងព្រះរាជវាំង ដោយបំណងនឹងរៀនមន្តសួរព្រះបាទឧទេនថា ល្បីថា លោកមានមន្តឈ្មោះ **ហត្ថីកណ្ណ:** សម្រាប់ហៅដំរី លោកនឹងបង្រៀនមន្តបទនោះ ដល់យើងបានឬទេ ? ព្រះបាទឧទេនឆ្លើយថា បាន ប្រសិនបើព្រះអង្គថ្វាយបង្គំខ្ញុំសិន ព្រះបាទចណ្ឌបជោតិឆ្លើយថា យើងមិនអាចធ្វើបានទេ ទើបព្រះបាទឧទេនពោលថា បើដូច្នោះខ្ញុំក៏មិនអាចបង្រៀនមន្តនេះដល់ព្រះអង្គបានដែរ ។ ព្រះបាទចណ្ឌបជោតិត្រិះរិះថា យើងចង់បានមន្តបទនេះ តែក៏មិនអាចឱ្យអ្នកដទៃចេះមន្តនេះបាន យើងនឹងឱ្យធីតារបស់យើងរៀនពីព្រះបាទ

ឧទេន ហើយយើងនឹងទទួលមន្តបទនោះពីធីតារបស់យើង ទើបត្រាស់នឹងព្រះបាទឧទេនថា ក្នុងព្រះរាជវាំងមានស្ត្រីគមម្នាក់ ដែលចង់រៀនមន្តបទនេះ តែមិនអាចឱ្យអ្នកដទៃឃើញរាងកាយរបស់នាងបាន អ្នកចូរឈរនៅខាងក្រៅវាំង-នន ហើយប្រាប់មន្តដល់ស្ត្រីដែលអង្គុយក្នុងវាំងននោះ ។ ព្រះបាទឧទេនត្រាស់ថា សូម្បីនាងជាអ្នកពិការក៏ដោយ បើនាងថ្វាយបង្គំខ្ញុំបាន ក៏នឹងឱ្យមន្ត ព្រះបាទចណ្ឌបជោតិត្រាស់ប្រាប់ព្រះរាជធីតាថា ឥឡូវនេះមានបុរសកើតរោគ-ឃ្លង់ម្នាក់ ចេះមន្តហត្ថីកណ្ឌៈដែលកាត់ថ្លៃមិនបាន តែបិតាមិនអាចឱ្យអ្នកដទៃចេះមន្តនោះ នាងចូរទៅអង្គុយក្នុងវាំងនន ថ្វាយបង្គំសម្តែងសេចក្តីគោរពបុរសនោះ ហើយសូមរៀនមន្ត បុរសនោះនឹងប្រាប់មន្តដល់នាង ។ ក្រោយមកព្រះបាទចណ្ឌបជោតិក្រែងអ្នកទាំងពីរ នឹងធ្វើសន្ថវៈជាមួយគ្នា ទើបប្រាប់ព្រះ-បាទឧទេនថា ចូរបង្រៀនមន្តនោះដល់ស្ត្រីគមដែលនៅខាងក្រោយវាំងនន ប្រាប់នឹងធីតាថា ចូររៀនមន្តពីបុរសគម្លង់ មួយថ្ងៃកន្លងមកព្រះធីតាក៏មិនអាចរៀនមន្តនោះចាំ ព្រះបាទឧទេនក្រោធត្រាស់ថា មីស្រីគមចូរថាយ៉ាងនេះ ព្រះធីតាខ្ញាល់ ត្រាស់ថា អាគម្លង់ ហើយទ្រង់បើកវាំងនន ព្រះបានឧទេនឃើញហើយសួរថា នាងជានរណា នាងត្រាស់តបថា យើងឈ្មោះ **វាសុលទត្តា** ជាធីតារបស់ស្តេចផែនដីនេះ ។ ចាប់ផ្តើមពីថ្ងៃនោះ ក៏មិនមានការរៀនមន្តបន្ត តមកព្រះបាទឧទេនបាននាំនាងវាសុលទត្តាគេចចេញទៅពីនគរឧជ្ជេនី ទ្រង់អភិសេកទុកជាព្រះមហេសីនៃក្រុងកោសម្ពីមួយអង្គទៀត ។

(៣) **មាគន្ទិយា** ធីតារបស់ព្រាហ្មណ៍ឈ្មោះមាគន្ទិយៈ ក្នុងដែនកុរុ ក្រោយពីមាតា បិតានាំទៅផ្ញើទុកជាមួយនឹង **ចូឡមាគន្ទិយា** ជាឪពុកមាហើយ ឪពុកមានោះគិតថា ក្មួយរបស់យើងគួរដល់ព្រះរាជាតែម្នាក់គត់ ទើបនាំនាងទៅកាន់ក្រុងកោសម្ពី ហើយថ្វាយដល់ព្រះរាជា ព្រះបាឧទេនទតឃើញនាង ក៏កើតសេចក្តីស្នេហា ទើបប្រទានការអភិសេកឱ្យជាព្រះមហេសីអង្គទីបី ។ ដោយការគុំកួនដែលព្រះនាងមាគន្ទិយាមានចំពោះព្រះសាស្តាពីដើម ទើបជួលឱ្យពួកមិច្ឆាទិដ្ឋិតាមទៅបរិភាសព្រះសាស្តា ក្នុងវេលាស្តេចយាងចូលទៅបិណ្ឌបាតក្នុងក្រុង ព្រះអានន្ទស្តាប់ពាក្យជេរនោះហើយ ទើបទូលនិមន្តព្រះសាស្តាស្តេចយាងទៅកាន់ក្រុងដទៃ ។ ព្រះពុទ្ធអង្គត្រាស់ថា រឿងកើតក្នុងទីណា គួរឱ្យស្ងប់ក្នុងទីនោះហើយទើបទៅ ហើយត្រាស់គាថាថា **អ្នកណាអត់ធន់ចំពោះពាក្យទ្រគោះបាន អ្នកនោះឈ្មោះថាហ្វឹកហាត់ខ្លួន ហើយជាអ្នកប្រសើរខ្ពង់ខ្ពស់** ម្នាលអានន្ទ ពួកនោះនឹងជេរបានត្រឹម ៧ ថ្ងៃ ព្រោះអធិករណ៍ដែលកើតឡើងដល់ព្រះពុទ្ធទាំងឡាយ រមែងមិនហួសពី ៧ ថ្ងៃ ។ ព្រះនាងមាគន្ទិយា កាលមិនអាចធ្វើឱ្យព្រះសាស្តាញាប់ញ័របាន ទើបគិតរកឧបាយបំផ្លាញព្រះនាងសមាវតី និងស្ត្រីបរិវារអ្នកឧបដ្ឋាកព្រះពុទ្ធអង្គជាការសងសឹកជំនួស បានរកឧបាយកលច្រើនប្រការ រហូតព្រះបាទ ឧទេនវង្វេងជឿ ដាក់ទោសព្រះនាងសមាវតី និងពួកទាសី ដោយឱ្យឈររៀបជាជួរហើយទ្រង់ប្រើធ្នូបាញ់ ។ ដោយអំណាចនៃចិត្តមេត្តារបស់ព្រះនាងសមាវតី កូនសរត្រឡប់មករកព្រះអង្គវិញ ព្រះបាទឧទេនស្លុតចិត្តបោះធ្នូ

ចោល ហើយឱនចុះថ្វាយបង្គំសុំទោសព្រះនាង សូមយកព្រះនាងជាទីពឹងដោយសេចក្ដីកោតក្រែង ព្រះនាងពោលថា ខ្ញុំម្ចាស់មានព្រះពុទ្ធជាទីពឹង ដូច្នោះព្រះអង្គក៏ចូរកាន់យកព្រះសាស្ដាជាទីពឹងជាទីពំនាក់ចុះ ។

(៤) ព្រះបាទឧទេនចូលទៅគាល់ព្រះសាស្ដា ទូលសូមព្រះពុទ្ធអង្គជាសរណៈ ទ្រង់និមន្តថ្វាយទានដល់ព្រះសង្ឃអស់ ៧ ថ្ងៃ ហើយនិមន្តព្រះពុទ្ធអង្គព្រមទាំងភិក្ខុសង្ឃ ៥០០ រូប ស្ដេចទទួលភត្តាហារ ហើយស្ដាប់ព្រះធម៌ទេសនាក្នុងប្រាសាទរបស់ព្រះនាងសមាវតីជាប់ជានិច្ច ព្រះសាស្ដាត្រាស់ថា មហាបពិត្រធម្មតាការមកកាន់ត្រកូលតែមួយជាប្រចាំ រមែងមិនគួរដល់ព្រះពុទ្ធជាម្ចាស់ទាំងឡាយឡើយ ព្រោះមហាជនសង្ឃឹមក្នុងព្រះពុទ្ធ ។ ទើបព្រះអង្គមានតម្រាស់ឱ្យព្រះអានន្ទ នាំភិក្ខុមកកាន់រាជត្រកូលជំនួស ព្រះទេវីទាំងនោះព្រមទាំងបរិវារបានអង្គាសព្រះថេរៈ និងស្ដាប់ធម៌រហូត ។ ព្រះនាងសមាវតី និងស្ដ្រីបរិវារទាំងនោះធ្វើការបូជាព្រះធម៌ដោយឧត្តរាសង្គៈ ៥០០ ផ្ទាំង ព្រះរាជាត្រាស់សួរព្រះអានន្ទថា សំពត់ឧត្តរាសង្គៈដែលថ្វាយ មិនច្រើនលើសពេកទេឬ លោកនឹងធ្វើអ្វីដោយសំពត់ចំនួនច្រើនទាំងនេះ ? *(ឧត្តរាសង្គៈ គឺស្បង់លោក)*

ព្រះអានន្ទតបថា នឹងប្រគេនសំពត់ដែលសល់ដល់ភិក្ខុអ្នកមានចីវរចាស់

ព្រះរាជា ភិក្ខុនឹងធ្វើចីវរចាស់របស់ខ្លួនឱ្យជាអ្វី ?

ព្រះថេរៈ លោកនឹងធ្វើឱ្យជាសំពត់កម្រាលដំណេក !

ព្រះរាជា លោកនឹងធ្វើសំពត់កម្រាលដំណេកចាស់ឱ្យជាអ្វី ?

ព្រះថេរៈ លោកនឹងធ្វើឱ្យជាសំពត់កម្រាលឥដ្ឋ !

ព្រះរាជា លោកនឹងធ្វើសំពត់កម្រាលឥដ្ឋចាស់ឱ្យជាអ្វី ?

ព្រះថេរៈ លោកនឹងធ្វើឱ្យជាសំពត់ជូតជើង !

ព្រះរាជា លោកនឹងធ្វើសំពត់ជូតជើងចាស់ឱ្យជាអ្វី ?

ព្រះថេរៈ លោកនឹងច្របល់ឱ្យល្អិតចូលគ្នាផ្សំដោយដីស្អិត ហើយបូកលាបជញ្ជាំង ព្រះរាជាទ្រង់ជ្រះថ្លា បញ្ជាឱ្យនាំសំពត់ ៥០០ ផ្ទាំង ថ្វាយទុកទៀបព្រះបាទាទាំងមូលរបស់ព្រះថេរៈ ។

( ៥ ) ព្រះនាងមាគន្ទិយាសូម្បីធ្វើដោយប្រការណា ក៏មិនអាចយកឈ្នះនាងសមាវតីបាន ទើបប្រើឱ្យមាគន្ទិយៈដែលជាឪពុកមា បើកឃ្លាំងសំពត់ និងឃ្លាំងប្រេង ធ្វើការដុតប្រាសាទរបស់នាងសមាវតី បិទទ្វារស្រ្តីទាំងឡាយទុកខាងក្នុងទាំងអស់ ។ កាលតំណាក់ត្រូវភ្លើងឆេះ ព្រះនាងសមាវតីឱ្យឱវាទដល់ស្រ្តីបរិវារ ៥០០ នាក់ ថាចូរជាអ្នកមិនប្រមាទ មនសិការនូវ **វេទនាបរិគ្គហកម្មដ្ឋាន** ( កំណត់វេទនាជាអារម្មណ៍ ) ពួកខ្លះបានសម្រេចសកទាគាមី ពួកខ្លះបានសម្រេចអនាគាមី ហើយធ្វើកាលកិរិយាទៅ ។

ព្រះបាទឧទេនទ្រង់ជ្រាបដំណឹង ស្តេចមកសាកសួរបានជ្រាបហេតុ ទើបបញ្ជាដាក់ទោសព្រះនាងមាគន្ទិយា ដោយមានបញ្ជាឱ្យជីករណ្តៅជម្រៅប្រមាណត្រឹមចង្កេះ ត្រង់ព្រះលានហ្លួង ឱ្យអ្នកទាំងនោះអង្គុយចុះក្នុងរណ្តៅ កប់ដោយចម្បើងដុតភ្លើង ហើយបញ្ជាឱ្យភ្ជួរដោយនង្គ័លដែក រហូតដាច់ជាចំណិតតូចៗ

ចំណែកព្រះនាងមាគន្ទិយា ព្រះរាជាបញ្ជាឱ្យចៀរសាច់ របស់ព្រះនាងចម្អិនក្នុងប្រេងក្តៅ ហើយឱ្យនាងទំពាស៊ីសាច់របស់ខ្លួនឯង ។

ព្រះភិក្ខុទាំងឡាយត្រឡប់ពីបិណ្ឌបាត ចូលទៅក្រាបទូលសួរព្រះមានព្រះភាគថា គតិរបស់ព្រះនាងសមាវតី និងបរិវារដែលត្រូវភ្លើងដុតរោលនោះដូចម្តេច ព្រះអង្គ ? ព្រះអង្គត្រាស់ថា ឧបាសិកាទាំងអស់នោះមិនជាអ្នកឥតផលធ្វើកាលកិរិយា ឧបាសិកាទាំងនោះ អ្នកខ្លះបានសម្រេចសោតាបន្ន ខ្លះសកទាគាមី និង អ្នកខ្លះបានសម្រេចជាព្រះអនាគាមី ។

( ៦ ) ភិក្ខុទាំងនោះទូលសួរដល់កម្មដែលស្ត្រីទាំងនោះធ្វើទុកក្នុងកាលមុន ព្រះពុទ្ធអង្គត្រាស់ដល់បុព្វកម្មរបស់ព្រះនាងសមាវតីថា ក្នុងអតីតៈព្រះរាជាទ្រង់នាំស្ត្រីទាំងនេះទៅងូតទឹកក្នុងស្ទឹង ឡើងពីស្ទឹងហើយ ត្រូវសេចក្តីរងាបៀតបៀនប្រាថ្នានឹងអាំងភ្លើង ឃើញបរិវេណមួយកន្លែងពាសពេញដោយស្មៅ ទើបឈរព័ទ្ធបង្កាត់គំនរភ្លើង យល់ថាជាគំនរស្មៅ កាលស្មៅឆេះភ្លើងហើយទ្រោមចុះទើបឃើញព្រះបច្ចេកពុទ្ធគង់ចូលនិរោធសមាបត្តិ ពួកនាងខ្លាចខុស ទើបជួយគ្នាដុតភ្លើងដដែល ដោយការតាំងចិត្តឱ្យឆេះអស់ ព្រោះកម្មដែលនាង និងបរិវារធ្វើយ៉ាងនេះទើបត្រូវភ្លើងឆេះ ។

ចំណែកព្រះបច្ចេកពុទ្ធជាម្ចាស់នោះ ចេញពីនិរោធសមាបត្តិក្នុងថ្ងៃទី ៧ បានក្រោកឡើងទៅតាមសប្បាយ ព្រោះថាសូម្បីនឹងនាំឧស ១០០០ រទេះមកក៏មិនអាចធ្វើឱ្យព្រះបច្ចេកពុទ្ធដែលចូលសមាបត្តិដឹង សូម្បីត្រឹមតែកម្តៅបាន-

ឡើយ ។ ព្រះអង្គត្រាស់បុព្វកម្មរបស់ព្រះនាងសមាវតីចប់ហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះនាងមាគន្ទិយាស្លាប់ហើយបានឈ្មោះថាស្លាប់តែម្យ៉ាង ចំណែក **ព្រះនាងសមាវតីសូម្បីស្លាប់ហើយ ក៏ឈ្មោះថាជាអ្នករស់នៅ ព្រោះថា អ្នកមិនប្រមាទ ឈ្មោះថា រមែងមិនស្លាប់** ។

ភិក្ខុទាំងឡាយទូលសួរបុព្វកម្មរបស់នាងខុជ្ជុត្តរាថា ព្រោះកម្មអ្វីទើបនាងកើតមកជាទាសីមានខ្នងគម តែជាអ្នកមានបញ្ញាច្រើន ព្រះពុទ្ធអង្គត្រាស់ថា ក្នុងអតីតជាតិ នាងធ្លាប់ប្រើអរហន្តីភិក្ខុនីមួយរូប ឱ្យយកកន្ទ្រកដាក់ត្រល់ដេរឱ្យនាង ក្នុងជាតិនេះទើបនាងកើតមកជាទាសី ចំណែកឯនាងខ្នងគមនោះ នាងធ្លាប់សម្តែងអាការៈត្រាប់តាមព្រះបច្ចេកពុទ្ធមួយអង្គដែលមានខ្នងគម ដោយផលនៃកម្មនោះ ទើបនាងកើតមកជាស្ត្រីគម ចំណែកការដែលនាងមានបញ្ញាច្រើន ព្រោះនាងធ្លាប់ថ្វាយជើងទម្រ ៨ វង់ ដើម្បីឱ្យព្រះបច្ចេកពុទ្ធ ៨ អង្គ ទ្របាត្រ ដែលពេញដោយបាយបាយាសក្តៅដែលព្រះរាជាថ្វាយ ទើបនាងមានបញ្ញាច្រើនដូច្នេះ ។ ចំណុចដែលនាងមិនត្រូវបានឆេះជាមួយនឹងព្រះនាងសមាវតី និងបរិវារក្នុងប្រាសាទនោះ មកពីនាងមិនធ្លាប់រួមធ្វើបុព្វកម្មនោះជាមួយនឹងព្រះនាងសមាវតី ទើបធ្វើឱ្យនាងមិនបាននៅក្នុងព្រះរាជវាំងខណៈដែលកើតហេតុ ។ ក្រោយពីនាងសមាវតីអស់ព្រះជន្មហើយ នាងក៏ឧទ្ទិសខ្លួនដល់ព្រះសាសនា ព្រះពុទ្ធអង្គទ្រង់សរសើរនាងខុជ្ជុត្តរាថា ជាកំពូលជាងឧបាសិកាទាំងឡាយដែលជាពហូសូត ។

## ក្រោយអំពីចេញព្រះវស្សាទី ៩ ហើយ

( ៧ ) គ្រាមួយ ព្រះមានព្រះភាគជាម្ចាស់យាងទៅគង់ក្នុងសីសបាវ័នជិតក្រុងកោសម្ពី ព្រះអង្គទ្រង់កាន់ស្លឹកធ្នង់ ២-៣ សន្លឹកដោយបាទព្រះហស្ថហើយត្រាស់ហៅភិក្ខុទាំងឡាយមកសួរថា ម្នាលភិក្ខុទាំងឡាយ ស្លឹកធ្នង់ ២-៣ សន្លឹកដែលនៅក្នុងដៃតថាគត និងស្លឹកដែលនៅលើដើម ណាច្រើនជាង ភិក្ខុទាំងឡាយក្រាបទូលថា ស្លឹកលើដើមមានច្រើនជាង ព្រះអង្គ ! ព្រះពុទ្ធអង្គត្រាស់ថា យ៉ាងណាមិញ វត្ថុដែលតថាគតត្រាស់ដឹងហើយ មិនបានប្រាប់អ្នកទាំងឡាយនៅមានច្រើនទៀត ព្រោះវត្ថុណាមិនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក សេចក្តីរលត់សេចក្តីស្ងប់ ការត្រាស់ដឹង និព្វាន ទើបតថាគតមិនសម្តែងប្រាប់ ។

ម្នាលភិក្ខុទាំងឡាយ វត្ថុណាដែលតថាគតសម្តែងប្រាប់ហើយថា **នេះទុក្ខ នេះសមុទយៈ នេះនិរោធ នេះមគ្គ** វត្ថុនោះប្រកបដោយប្រយោជន៍ជាព្រហ្មចរិយៈខាងដើម រមែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ការរួចផុតនិងព្រះនិព្វាន ព្រោះហេតុដូច្នោះ ទើបតថាគតដាស់តឿនដល់អ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាម ដើម្បីឱ្យត្រាស់ដឹងនូវសេចក្តីពិតថា **នេះទុក្ខ នេះសមុទ័យ នេះនិរោធ នេះមគ្គ** ។

( ៨ ) ពោលដល់ **នាយឆន្នៈ** ដែលជាសហជាតិរបស់ព្រះសិទ្ធត្ថក្នុងគ្រាដែលព្រះសិទ្ធត្ថចេញមហាភិនេស្ក្រមណ៍ បានចេញទៅជាមួយនឹងព្រះអង្គ

រហូតដល់ស្ទឹងអនោមា និងបំណងសម្តែងសេចក្តីសូមបព្វជ្ជាដែរ តែព្រះអង្គមិនព្រម បានបញ្ជាឱ្យនាយឆន្នៈត្រឡប់ទៅផ្តល់ដំណឹងរបស់ព្រះអង្គ ដល់ព្រះរាជ-បិតាសិន ទើបនាយឆន្នៈចាំបាច់ធ្វើដំណើរត្រឡប់ទៅក្រុងកបិលពស្តុ ។ តមក កាលព្រះសិទ្ធត្ថត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធហើយ ទើបស្តេចយាងទៅក្រុងកបិលពស្តុដើម្បីប្រោសពុទ្ធបិតាជាគ្រាដំបូង ទើបនាយឆន្នៈទូលសូមបួស លុះបួសហើយ ដោយការប្រកាន់ខ្លួនថា ជាអ្នកស្និទ្ធស្នាលជាមួយនឹងព្រះសាស្តា ទើបធ្វើឱ្យព្រះឆន្នៈរឹងត្អឹងមិនព្រមស្តាប់ពាក្យដាស់តឿនទូន្មានរបស់ពួកភិក្ខុ ដោយគិតថា នេះគឺព្រះពុទ្ធរបស់យើង នេះគឺព្រះធម៌របស់យើង ជាដើម ។ ក្នុងខណៈដែលព្រះសាស្តា ទ្រង់គង់នៅវត្តឃោសិតារាម ព្រះឆន្នៈប្រព្រឹត្តខុសព្រះវិន័យ តែមិនព្រមទទួលកំហុស ជាហេតុឱ្យព្រះសាស្តាដាក់ទោសដោយវិធី **ឧក្ខេបនីយកម្ម** គឺការលើកទោសមិនឱ្យព្រះឆន្នៈឆាន់ភត្តាហារ និងនៅរួមជាមួយនឹងភិក្ខុសង្ឃទាំងឡាយ ទោះបីព្រះឆន្នៈនឹងទៅក្នុងទីណាក៏ដោយ សង្ឃទាំងពួងក៏នាំគ្នាបដិ-សេធមិនព្រមអើពើជាមួយ ព្រះឆន្នៈបានភ្ញាក់រឭក ទើបត្រឡប់មកគាល់ព្រះ-សាស្តា ក្រាបទូលសូមខមាទោស ព្រះអង្គទ្រង់អត់ទោសឱ្យ ធ្វើឱ្យព្រះឆន្នៈប្តូរនិស្ស័យបានមួយរយៈ តមក ព្រះឆន្នៈប្រព្រឹត្តមិនសមរម្យដល់ខ្លួនជាសមណៈ ហើយត្រូវដេញដោលសួរ ព្រោះត្រូវអាបត្តិក្នុងកណ្តាលសង្ឃ ត្រឡប់យករឿងដទៃមកនិយាយត្រឡប់ត្រឡិនថា នរណាត្រូវ ត្រូវអ្វី ត្រូវព្រោះរឿងអ្វី ត្រូវដូចម្តេច លោកទាំងឡាយថានរណា ថារឿងអី ? ។

ព្រះសាស្តាទ្រង់តិះដៀល ហើយទ្រង់សម្តែងធម្មីកថាត្រាស់នឹងភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយ សង្ឃចូរលើក **អញ្ញវាទកកម្ម** គឺសង្ឃសូធ្យប្រកាសសេចក្តីនោះដោយ ញត្តិទុតិយកម្ម កាលសង្ឃប្រកាសដូច្នេះហើយ ភិក្ខុនោះនៅតែចចេសធ្វើដូចដើមទៀត ត្រូវ **អាបត្តិបាចិត្តិយៈ** ។

ទោះបីដូច្នោះ ព្រះឆន្នៈក៏នៅតែប្រព្រឹត្តមិនសមគួរ ដល់ភាវៈជាសមណៈដូចដើម ពួកភិក្ខុបានពោលដាស់តឿនថា អាវុសោឆន្នៈ លោកកុំធ្វើដូច្នេះ ការធ្វើដូច្នេះមិនគួរ ព្រះឆន្នៈក៏នៅតែមិនអើពើចំពោះព្រះវិន័យ នៅចចេសដូចដើម ភិក្ខុទើបក្រាបទូលសេចក្តីនោះ ចំពោះព្រះមានព្រះភាគ (វិន័យបិដកមហាវិភង្គ ទុតិ-យភាគ ពោលការប្រព្រឹត្តិដែលមិនសមគួរ ដល់សមណៈដូចជា ការរៀនតិរច្ឆានវិជ្ជាជាដើម) ។

ព្រះសាស្តាទ្រង់សាកសួរ ព្រះឆន្នៈទូលទទួលថា ធ្វើដូច្នោះមែន ព្រះអង្គទ្រង់តិះដៀលថា ម្នាលមោឃបុរស ដូចម្តេចទើបអ្នកមិនអើពើចំពោះព្រះវិន័យនៅតែធ្វើ ការធ្វើរបស់អ្នកមិនប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លា របស់ជនដែលមិនទាន់ជ្រះថ្លា ទើបព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុណាមិនអើពើក្នុងព្រះ-វិន័យ ត្រូវអាបត្តិបាចិត្តិយៈ ។

(៩) គ្រានោះ **ព្រះសាគតត្ថេរ** ចេញទៅស្នាក់នៅឯអម្ពតិត្ថៈ ដែនចេតីជិតក្រុងកោសម្ពី បានបង្ក្រាបនាគកំណាចមួយក្នុងទីនោះ បានដោយឫទ្ធិ ហើយធ្វើដំណើរត្រឡប់មកកាន់ក្រុងកោសម្ពី អ្នកក្រុងកោសម្ពីដឹងថា ព្រះសាគតៈ

បង្ក្រាបនាគបានសម្រេចហើយ ទើបគិតនឹងតបគុណព្រះថេរៈ ដោយប្រការផ្សេងៗ តែព្រះថេរៈមិនចេញស្ដីអ្វី ទើបភិក្ខុឆព្វគ្គីយ៍ណែនាំឱ្យជនទាំងនោះ ប្រគេនសុរាដល់ព្រះសាគតៈ ក្នុងខណៈដែលចេញបិណ្ឌបាត គ្រានោះ ព្រះសាស្ដាមិនទាន់បញ្ញត្តិហាមផឹកសុរា ព្រះសាគតៈផឹកសុរារហូតស្រវឹងដួលជ្រប់នៅហ្នឹងមាត់ទ្វារក្រុងកោសម្ពី ពួកភិក្ខុជួយសែងមកគាល់ព្រះសាស្ដានៅព្រះវិហារ ព្រះសាគតៈសម្ដែងកិរិយាមិនសមគួរ ចំពោះព្រះសាស្ដាដោយសេចក្ដីស្រវឹង ព្រះសាស្ដាត្រាស់ទោសនៃការផឹកសុរា និងទ្រង់បញ្ញត្តមិនឱ្យភិក្ខុផឹកសុរា និងមេរ័យ ភិក្ខុណាផឹក ត្រូវអាបត្តិបាចិត្តិយៈ ។

សុរា ៥ ប្រភេទ គឺ ធ្វើដោយនំ ធ្វើដោយម្សៅ ធ្វើដោយបាយ ធ្វើដោយពូជ
ធ្វើដោយគ្រឿងផ្សំ

មេរ័យ ៥ ប្រភេទ គឺ ទឹកត្រាំផ្កាឈើ ទឹកត្រាំផ្លែឈើ ទឹកត្រាំទឹកឃ្មុំ ទឹកត្រាំទឹកអំពៅ
ទឹកត្រាំដែលផ្សំដោយគ្រឿងផ្សំ

(១០) ព្រះអង្គទ្រង់គង់នៅក្រុងកោសម្ពី ក្នុងចន្លោះនោះព្រះសង្ឃក្នុងឃោសិតារាមបែកសាមគ្គីគ្នា ដោយព្រះវិន័យធរ និងព្រះធម្មកថិក ជៀមដាមគ្នាទាក់ទងដោយវិន័យ ភិក្ខុនោះមានបរិវារ ១ រូបៗ ៥០០ កាលភិក្ខុពីររូបមានការយល់មិនដូចគ្នា បរិវារក៏បែកជាពីរពួក ព្រះសាស្ដាត្រាស់ហាមថា ម្នាលភិក្ខុទាំងឡាយ ការបែកបាក់គ្នា ការឈ្លោះទាស់ទែងគ្នា និងការវិវាទគ្នា រមែងធ្វើសេចក្ដីវិនាសសាបសូន្យដូចសត្វចៀបកប្បាស អាស្រ័យការឈ្លោះគ្នា អាចធ្វើឱ្យស្ដេចដរិ

បាត់បង់ជីវិតបាន និងត្រាស់ **វដ្តកជាតក** ទ្រង់លើករឿងចាបចៀបកប្បាសទាំងឡាយវិវាទគ្នា រហូតដល់អស់ជីវិត ។

ទោះបីព្រះអង្គព្យាយាមឱ្យសង្ឃព្រមព្រៀងគ្នា ដោយសម្តែង សារាណីយធម៌ ៦ ប្រការ ធម៌ជាហេតុឱ្យរឭកដល់គ្នា គឺ **ធ្វើសេចក្តីរាប់អានគ្នា ១ ធ្វើសេចក្តីគោរពគ្នា ១ ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ១ ដើម្បីការមិនវិវាទគ្នា ១ ដើម្បីការព្រមព្រៀងគ្នា ១ ដើម្បីការរស់នៅជាពួកតែមួយ ១** ក្រៅពីនោះ ទ្រង់សម្តែងទោសនៃការបែកបាក់សាមគ្គី និងអានិសង្សនៃការសាមគ្គីគ្នាក៏មិនសម្រេច ភិក្ខុនៅក្រុងកោសម្ពីរឹងត្អឹងមិនព្រមស្តាប់ហេតុផល ទោះបីទ្រង់ឱ្យឱវាទយ៉ាងណា ក៏មិនអាចផ្សះផ្សាភិក្ខុទាំងនោះបាន ។ ចាប់ផ្តើមពីកាលនោះមក សូម្បីពួកឧបដ្ឋាកអ្នកប្រគេនបច្ច័យរបស់ភិក្ខុ ២ រូបនោះ ក៏បែកជា ២ ផ្នែក ពួកភិក្ខុនីអ្នកទទួលឱវាទក្តី ពួកអារក្ខទេវតាដែលគ្រប់គ្រងក្តី ក៏បែកជា ២ កាលត្រាស់ទូន្មានដូចម្តេចក៏មិនស្តាប់ ទើបព្រះអង្គទ្រង់ព្រះតម្រិះគេចចេញចាកពួកយាងទៅតែមួយព្រះអង្គឯង ។

(១១ ) លុះអរុណរះឡើង ព្រះអង្គយាងចូលទៅបិណ្ឌបាតក្នុងក្រុងកោសម្ពីតែមួយព្រះអង្គឯង ត្រឡប់អំពីបិណ្ឌបាត ក្រោយភត្តកិច្ច ទ្រង់រៀបចំសេនាសនៈ កំពុងប្រថាប់ឈរនោះឯង បានត្រាស់ព្រះគាថា មានសេចក្តីសង្ខេបថា កាលសង្ឃបែកគ្នា ម្នាក់ៗ ក៏មិនបានសម្គាល់ថា ខ្លួនខុស ប្រាថ្នានឹងសម្តែងថ្វីមាត់និយាយទៅតាមបំណង រមែងមិនដឹងថា ពួកយើងនឹងវិនាសក្នុងទីនេះ

ដូច្នោះការត្រាច់ទៅតែម្នាក់ឯងប្រសើរជាង ភាពជាមិត្តជាមួយនឹងមនុស្សពាលរមែងមិនមាន គប្បីត្រាច់ទៅតែម្នាក់ឯង មិនគប្បីធ្វើអំពើបាប ដូចដំរីមាតង្គៈដែលបំណងត្រាច់ទៅក្នុងព្រៃតែម្នាក់ឯងដូច្នោះ ។

ព្រះសាស្តាស្តេចយាងចារិកទៅតាមលំដាប់ស្រុកនិគម ទ្រង់ព្រះតម្រិះថា តថាគតនឹងសួរសុខទុក្ខភិក្ខុអ្នកនៅតែម្នាក់ឯងជាមុនសិន ទើបយាងទៅកាន់ស្រុក **ពាលកលោណការាម** ទ្រង់ជួប **ព្រះភគ្គុថេរៈ** ត្រង់ពាលកលោណការាម ទ្រង់សរសើរដល់ការនៅតែម្នាក់ឯង និងទ្រង់សម្តែងអានិសង្សនៃការនៅតែម្នាក់ឯងដល់ព្រះថេរៈ រហូតបច្ឆាភត្ត និងរហូតរាត្រីទាំង ៣ យាមថា ការត្រាច់ទៅតែម្នាក់ឯងប្រសើរជាង ព្រោះភាពជាមិត្តជាមួយនឹងមនុស្សពាលរមែងមិនមាន គួរត្រាច់ទៅតែម្នាក់ឯង ហើយមិនគួរធ្វើបាប ដូចដំរីមាតង្គៈត្រាច់ទៅក្នុងព្រៃតែម្នាក់ឯងដូច្នោះ ។ ព្រះមានព្រះភាគត្រាស់សួរថា អ្នកជាអ្នកមិនប្រមាទឬ ? ព្រះភគ្គុក្រាបទូលថា ខ្ញុំព្រះអង្គត្រូវថីនមិទ្ធៈគ្របសង្កត់ បានចេញចាកវិហារទៅកាន់ទីចង្ក្រម ហើយដួលចុះត្រង់ផែនដី ក្នុងទីជិតជណ្តើរចង្ក្រមនោះឯង ខ្ញុំព្រះអង្គស្ទាបអង្អែលខ្លួន ហើយឡើងកាន់ទីចង្ក្រមទៀត លំដាប់នោះ ចិត្តរបស់ខ្ញុំព្រះអង្គរួចផុតចាកអាសវៈទាំងពួង ខ្ញុំព្រះអង្គបានសម្រេចវិជ្ជា ៣ បានធ្វើកិច្ចក្នុងព្រះពុទ្ធសាសនាចប់ហើយ ព្រះអង្គ ! ។

( ១២ ) លុះព្រឹកឡើង ព្រះសាស្តាមានព្រះភគ្គុត្ថេរជាបច្ឆាសមណៈត្រាច់ទៅបិណ្ឌបាត ព្រះអង្គទ្រង់ឱ្យព្រះភគ្គុត្រឡប់ក្នុងទីនោះឯង ហើយទ្រង់ព្រះ

តម្រិះថានឹងទៅសួរសុខទុក្ខព្រះថេរៈ ៣ រូប ទើបយាងទៅកាន់បាចីនវង្សមិគ-ទាយវ័ន ក្នុងទីនេះបានជួបព្រះអនុរុទ្ធ ព្រះនន្ទិយៈ និងព្រះកិម្ពិលៈ ព្រះមានព្រះភាគត្រាស់សួរព្រះថេរៈដល់ការរស់នៅថា ពួកអ្នកនៅមានការព្រមព្រៀងគ្នា មិនវិវាទគ្នា នៅសម្លឹងមើលនូវគ្នានិងគ្នា ដោយភ្នែកដែលគួរឱ្យស្រឡាញ់ឬ ? ព្រះអនុរុទ្ធក្រាបទូលថា ពួកខ្ញុំព្រះអង្គគិតថា ជាលាភរបស់យើងហើយ ហ្ន៎ ! ដែលបាននៅជាមួយនឹងមិត្តសព្រហ្មចារីរួមគ្នាដូច្នេះ ពួកខ្ញុំព្រះអង្គនោះ ចូលទៅតាំងកាយកម្ម វចីកម្ម និងមនោកម្ម ដែលប្រកបដោយមេត្តាចំពោះគ្នានិងគ្នា ទាំងក្នុងទីចំពោះមុខ និងទីកំបាំងមុខ ពួកខ្ញុំព្រះអង្គផ្សេងគ្នាតែកាយប៉ុណ្ណោះ ចំណែកចិត្តតែមួយ នៅសម្លឹងមើលគ្នានិងគ្នាដោយភ្នែកដែលគួរឱ្យស្រឡាញ់ ព្រះអង្គត្រាស់ថា សាធុ ប្រពៃហើយ ពួកអ្នកជាអ្នកមិនប្រមាទ មានព្យាយាម មានខ្លួនបញ្ជូនទៅយ៉ាងនេះ រមែងមានគុណវិសេស គឺញាណទស្សនៈ ពោលគឺមគ្គញ្ញាណដ៏ប្រសើរ ជាគ្រឿងនៅជាសុខ ទ្រង់សម្តែងអានិសង្សក្នុងការដែល-កុលបុត្រទាំងនោះ នៅដោយការព្រមព្រៀងគ្នា រហូតមួយយប់ទាល់ភ្លឺ ទ្រង់ឱ្យព្រះថេរៈទាំង ៣ ស្នាក់នៅក្នុងទីនោះ ហើយយាងទៅកាន់ព្រៃបាលិលេយ្យកៈតែមួយព្រះអង្គឯង ។

(ព្រះនន្ទិយត្ថេរជាបុត្រក្នុងសក្យត្រកូល ក្រុងកបិលពស្តុ បួសក្នុងសំណាក់របស់ព្រះសាស្តា ក្នុងថ្ងៃដែលសក្យរាជ ៦ អង្គបួសក្នុងអនុបិយអម្ពវ័ន កាលសម្រេចព្រះអរហត្តហើយ បានមកនៅបាចីនវង្សមិគទាយវ័ន រួមជាមួយនឹងព្រះអនុរុទ្ធ និងព្រះកិម្ពិលៈ) ។

(១៣) ព្រះមានព្រះភាគ យាងទៅកាន់ដងព្រៃរក្ខិតៈ ដែលជាទីនៅរបស់ដំរីឈ្មោះ **បាលិលេយ្យកៈ** គង់នៅទៀបគល់សាលព្រឹក្សមួយដើមធំឈ្មោះ **ភទ្ទសាលៈ** ក្នុងដងព្រៃរក្ខិតៈនោះ ពួកឧបាសកឧបាសិកាអ្នកក្រុងកោសម្ពីទៅកាន់វិហារដើម្បីស្តាប់ធម៌ លុះមិនឃើញព្រះសាស្តា ទើបសួរភិក្ខុទាំងឡាយថា ឥឡូវនេះព្រះសាស្តាគង់នៅក្នុងទីណា ភិក្ខុទាំងនោះឆ្លើយថា ព្រះសាស្តាយាងទៅអំពីពួកយើងហើយ ឧបាសកឧបាសិកាទាំងនោះសួរថា ព្រះអង្គយាងទៅដោយហេតុអ្វី ពួកភិក្ខុឆ្លើយថា ដោយហេតុដែលព្រះអង្គទ្រង់ព្យាយាមនឹងធ្វើឱ្យពួកយើងសាមគ្គីគ្នា តែពួកអាត្មាក៏មិនស្តាប់ឱវាទរបស់ព្រះអង្គ។ ជនទាំងនោះកាលដឹងហើយ នាំគ្នាគិតថា ពួកភិក្ខុនេះបួសក្នុងសំណាក់របស់ព្រះសាស្តា សូម្បីដូច្នោះក៏នៅមិនព្រមស្តាប់ឱវាទរបស់ព្រះអង្គ ពួកយើងមិនបានឃើញព្រះសាស្តាក៏ព្រោះភិក្ខុទាំងនេះ ពួកយើងនឹងមិនថ្វាយបង្គំ មិនប្រគេនភត្តាហារ ភិក្ខុនៅក្រុងកោសម្ពីស្គាំងស្គមព្រោះអត់អាហារ កាលដឹងខ្លួនថាខុស ទើបព្រមសាមគ្គីគ្នា តែសូម្បីដូច្នោះ ឧបាសកឧបាសិកាក៏នៅមិនព្រមទំនុកបម្រុង រហូតទាល់តែភិក្ខុទាំងនោះ ទៅសូមខមាទោសចំពោះព្រះសម្មាសម្ពុទ្ធជាមុនសិន ។

# ព្រះវស្សាទី ១០

## គង់គង់ចាំព្រះវស្សា ក្បែរគល់សាលព្រឹក្ស ព្រៃបាលិលេយ្យកៈ

## ព្រៃបាលិលេយ្យកៈ (រក្ខិតវ័ន) នៅក្នុងដែនកោសល

## ចន្លោះនគរកោសម្ពី និងសាវត្ថី

(១) ក្នុងទីនោះ **ដំរីបាលិលេយ្យកៈ** ដែលគេចចេញចាកហ្វូងមកនៅក្នុងព្រៃនេះដូចគ្នា លុះឃើញព្រះអង្គគង់នៅក្បែរគល់សាលព្រឹក្ស ទើបប្រើជើងពង្រាបផ្ទៃដីឱ្យស្មើ ប្រើប្រមោយចាប់មែកឈើបោសសម្អាតផ្ទៃដីជុំវិញដើមសាលព្រឹក្សឱ្យស្អាត បន្ទាប់មកទើបប្រើប្រមោយចាប់ឆ្នាំងទឹក ដងទឹកប្រើ-ប្រាស់ និងទឹកឆាន់មកតាំងទុក ហើយចូលទៅកាន់ព្រៃរកផ្លែឈើមកថ្វាយ ។ ថ្ងៃណាដែលព្រះអង្គយាងចេញទៅបិណ្ឌបាត ថ្ងៃនោះដំរីបាលិលេយ្យកៈ ក៏នឹងនាំបាត្រដាក់ត្រង់ពោង ដើរទៅព្រមជាមួយនឹងព្រះអង្គ លុះជិតចូលកាន់ស្រុក ក៏ថ្វាយបាត្រ ចីវរ កាលព្រះអង្គត្រឡប់អំពីបិណ្ឌបាតក៏រង់ចាំទទួលបាត្រ នាំមកទុកដាក់ក្នុងទីដែលព្រះអង្គទ្រង់គង់ ហើយធ្វើវត្តបដិបត្តិ ដូចជាបេះស្លឹកឈើមកបក់ថ្វាយព្រះអង្គ វេលាយប់ ក៏រង់ចាំរក្សាការពារដោយការដើរទៅមកជុំវិញៗ ទីគង់នៅរហូតទាល់ភ្លឺ កាលភ្លឺហើយក៏ថ្វាយទឹក ជម្រះព្រះភក្ត្រ ថ្វាយទឹកខ្ពុរព្រះឱស្ឋ ឈើសម្រាប់ជម្រះព្រះទន្ត ។

ក្នុងវេលាទ្រង់ស្រង់ទឹក ស្តេចដំរីនោះយកប្រមោយជញ្ជូនឈើមកកួតឱ្យកើតជាភ្លើង ធ្វើឱ្យឈើឆេះសន្ធោសន្ធៅ ដុតដុំថ្មក្នុងទីនោះឱ្យក្តៅ ប្រើឈើ

ប្រមៀលដុំថ្មនោះចុះទៅក្នុងទឹក ដឹងថាទឹកក្តៅហើយ ទើបចូលទៅឈរ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាបថា ដំរីនិមន្តតថាគតឱ្យស្រង់ទឹក ទើបយាងទៅហើយធ្វើការស្រង់ព្រះកាយ ដំរីបាលិលេយ្យកៈបានបដិបត្តិចំពោះព្រះពុទ្ធអង្គយ៉ាងនេះជាប្រចាំ មិនបានខ្វះចន្លោះរហូតមួយព្រះវស្សា ។

(២) មានស្វាមួយ ឃើញដំរីបាលិលេយ្យកៈឧបដ្ឋាកព្រះសម្មាសម្ពុទ្ធ គិតថា យើងគួរធ្វើកិច្ចការណាមួយ តមក ស្វានោះឃើញសំបុកឃ្មុំមិនមានមេមួយផ្អិតលើមែកឈើ ទើបកាច់មែកឈើនោះហើយ បេះស្លឹកឈើធំមួយសន្លឹក ដាក់ផ្លិតឃ្មុំលើស្លឹកឈើនោះ នាំចូលទៅថ្វាយចំពោះព្រះសាស្តា ព្រះអង្គទ្រង់ទទួលហើយគង់នៅស្ងៀម ទើបស្វាចូលមកចាប់ផ្លិតឃ្មុំនោះត្រឡប់មើល ឃើញមានមេឃ្មុំខ្ចីនៅខាងក្នុងផ្លិត ទើបនាំមេឃ្មុំខ្ចីចេញរហូតអស់ ហើយបង្អោនចូលទៅថ្វាយព្រះអង្គម្តងទៀត ព្រះសាស្តាទ្រង់ទទួលហើយសោយ ។ ស្វាសប្បាយចិត្ត ខណៈដែលលោតវាំលើដើមឈើ មែកឈើក៏បាក់ធ្លាក់ចុះមកជង់ត្រូវដង្គត់ឈើក៏ស្លាប់ទៅ ដោយចិត្តជ្រះថ្លាក្នុងព្រះពុទ្ធអង្គ បានទៅកើតក្នុងភពតាវត្តិង្សមាននាងទេពអប្សរ ១000 ជាបរិវារ ។

## ក្រោយអំពីចេញព្រះវស្សាទី ១០ ហើយ

(៣) អនាថបិណ្ឌិកសេដ្ឋី និងនាងវិសាខាមហាឧបាសិកា នាំគ្នាបញ្ជូនដំណឹងពីក្រុងសាវត្ថី សូមឱ្យព្រះអានន្ទដែលគង់នៅក្នុងឃោសិតារាម ទៅក្រាបទូលនិមន្តព្រះពុទ្ធអង្គ សូមឱ្យព្រះអង្គយាងត្រឡប់មកក្រុងសាវត្ថីវិញ ខណៈព្រម

គ្នានោះភិក្ខុអំពីទិសផ្សេងៗ ប្រមាណជា ៥០០ រូប លុះចេញព្រះវស្សាហើយ នាំគ្នាចូលមករក និងអង្វរសូមព្រះអានន្ទ ដោយបំណងនឹងស្តាប់ធម៌ ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ទើបព្រះអានន្ទនាំភិក្ខុទាំងនោះទៅ កាន់ដងព្រៃរក្ខិតៈ ចូលទៅគាល់ព្រះសម្មាសម្ពុទ្ធមុនគេតែម្នាក់ឯង ។

(៤) ដំរីបាលិលេយ្យកៈឃើញព្រះអានន្ទ ក៏បោលចូលមកនឹងបៀតបៀន ព្រះអង្គទ្រង់ហាមថា នោះជាពុទ្ធុប្បដ្ឋាករបស់តថាគត បាលិលេយ្យកៈ ទើបចូលមកសូមទទួលបាត្រ តែព្រះអានន្ទដាក់បាត្ររបស់លោកលើផែនដី ថ្វាយបង្គំហើយក្រាបទូលរឿងឱ្យទ្រង់ជ្រាប ព្រះសាស្តាត្រាស់ឱ្យនាំភិក្ខុ ៥០០ រូបចូលមក ភិក្ខុទាំងនោះថ្វាយបង្គំ ហើយក្រាបទូលសួរដល់អ្នកធ្វើវត្តថ្វាយក្នុងព្រះវស្សា ។ ព្រះពុទ្ធអង្គទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងភិក្ខុទាំងនោះ ហើយត្រាស់សរសើរដំរីបាលិលេយ្យកៈថា **ម្នាលភិក្ខុទាំងឡាយ ដំរីបាលិលេយ្យកៈធ្វើកិច្ចគ្រប់យ៉ាងដល់តថាគតអស់មួយវស្សា ការមានសម្លាញ់ដូច្នេះ ជាការប្រសើរណាស់ បើមិនបានសម្លាញ់ដូច្នេះទេ គួរត្រាច់ទៅតែម្នាក់ឯង** ដូចដំរីមាតង្គៈលះបង់ហ្វូង ហើយត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង ដូច្នោះ ។

ការត្រាច់ទៅនៃបព្វជិតអ្នកត្រេកអរក្រៃលែង ក្នុងកាលតែម្នាក់ឯង តាំងពីកាលដែលខ្លួនបួស ឈ្មោះថា តែម្នាក់ឯងប៉ុណ្ណោះប្រសើរ ព្រោះមានគុណធម៌នេះ គឺចុល្លសីល មជ្ឈិមសីល និងមហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ និងព្រះនិព្វានជាសម្លាញ់

បុគ្គលគប្បីជាមនុស្សតែម្នាក់ឯងប៉ុណ្ណេះត្រាច់ទៅតាមសប្បាយ ក្នុងទីដែលខ្លួនប្រាថ្នាហើយក្នុងព្រៃនេះ ដោយឥរិយាបថទាំងពួង ។ ក្នុងវេលាចប់ទេសនា ភិក្ខុ ៥០០ រូប បានសម្រេចអរហត្តផល ។ ដំរីបាលិលេយ្យកៈ បំណងនឹងប្រគេនភិក្ខាដល់ពួកភិក្ខុ ទើបចូលព្រៃប្រមែប្រមូលនូវផ្លែឈើច្រើនប្រភេទមកគរទុក ដើម្បីប្រគេនភិក្ខុក្នុងថ្ងៃស្អែក ។ ថ្ងៃតមក ក្រោយពីសម្រេចភត្តកិច្ចហើយ ព្រះអង្គព្រមទាំងភិក្ខុសង្ឃ ក៏ផ្ដើមចេញធ្វើដំណើរយាងត្រឡប់ ដំរីបាលិលេយ្យកៈដើរទៅឈររាំងដំណើរព្រះសាស្ដា ពួកភិក្ខុឃើញហេតុការណ៍នោះ ទើបទូលសួរព្រះសាស្ដាថា ដំរីធ្វើអាការៈដូច្នេះព្រោះហេតុដូចម្ដេច ? ព្រះសាស្ដា ត្រាស់ថា ដំរីមិនប្រាថ្នាឱ្យ តថាគតទៅអំពីទីនេះឡើយ !

ព្រះសាស្ដាទ្រង់ត្រាស់ថា នេះជាការទៅមិនត្រឡប់របស់តថាគត ឈានវិបស្សនា ឬសូម្បីតែមគ្គផល ក៏នឹងមិនទាន់កើតដល់អ្នកក្នុងអត្តភាពនេះ អ្នកចូរឈប់ចុះបាលិលេយ្យកៈ ដំរីបាលិលេយ្យកៈ កាលមិនអាចនឹងឃាត់ឱ្យព្រះអង្គនៅបាន ទើបដើរតាមទៅរហូតព្រះមានព្រះភាគត្រាស់ថា តពីនេះទៅ ជាដែនដីមនុស្ស មានអន្តរាយច្រើន សូមអ្នកឈប់ត្រង់នេះចុះ ដំរីបាលិលេយ្យកៈឈរស្រក់ទឹកភ្នែកនៅក្នុងទីនោះ លុះព្រះអង្គព្រមទាំងភិក្ខុសង្ឃ ផុតកន្ទុយភ្នែកទៅ ក៏បែកទ្រូងស្លាប់ទីនោះឯង ដោយសេចក្ដីអាល័យយ៉ាងក្រៃលែងក្នុងព្រះសាស្ដា ទៅកើតក្នុងវិមានមាសជាន់តាវត្តិង្សទេវលោក កណ្ដាលហ្វូងនាងទេពអប្សរមាននាមថា **បាលិលេយ្យកទេវបុត្ត** ។

( ៥ ) ភិក្ខុនៅក្រុងកោសម្ពីបានសម្រួបខ្លួនហើយ មិនអាចនឹងធ្វើដំណើរទៅគាល់ព្រះអង្គក្នុងព្រៃបាលិលេយ្យកៈបាន ព្រោះនៅក្នុងរដូវវស្សាត្រូវនាំគ្នាអត់ធន់ចំពោះទុក្ខទណ្ឌ រហូតអស់មួយវស្សាក្នុងវត្តឃោសិតារាមនោះឯង លុះចេញវស្សាដឹងថា ព្រះមានព្រះភាគ យាងត្រឡប់ទៅក្រុងសាវត្ថីហើយ ទើបនាំគ្នាធ្វើដំណើរទៅ ដើម្បីសូមខមាទោសព្រះអង្គ ។

( ៦ ) **ព្រះសារីបុត្ត** បានស្តាប់ដំណឹងថា ភិក្ខុក្រុងកោសម្ពីកំពុងនាំគ្នាមកកាន់នគរសាវត្ថី ទើបចូលទៅទូលសួរព្រះសាស្តាថា ខ្ញុំព្រះអង្គនឹងបដិបត្តិក្នុងភិក្ខុទាំងនោះដូចម្តេច ព្រះអង្គ ? ព្រះអង្គត្រាស់ថា ម្នាលសារីបុត្ត អ្នកចូរតាំងនៅដោយធម៌ អ្នកគប្បីដឹងថា **អធម្មវាទីភិក្ខុ ១៨ ប្រការ និងធម្មវាទី ១៨ ប្រការ** ហើយបដិបត្តិតាមធម៌នោះ (វិន័យបិដកមហាវគ្គ ) ព្រះថេរានុត្ថេរៈក៏បាននាំគ្នាចូលគាល់ទូលសួរ កិច្ចដែលនឹងបដិបត្តិចំពោះភិក្ខុកោសម្ពី ដូចព្រះសារីបុត្តដែរ ។

**ព្រះរាហុល** ឮដំណឹងហើយចូលទៅទូលសួរ ព្រះអង្គត្រាស់ថា ម្នាលរាហុល អ្នកចូរតាំងនៅតាមធម៌ **ព្រះមហាបជាបតិគោតមីថេរី** បានចូលទៅទូលសួរដោយន័យដូចព្រះថេរៈទាំងឡាយ ព្រះមានព្រះភាគត្រាស់តបថា នាងចូរស្តាប់ធម៌ក្នុងភិក្ខុទាំងពីរខាង ភិក្ខុណាជាធម្មវាទី នាងចូរពេញចិត្តក្នុងការឃើញ ចូរដាក់ចិត្ត និងកាន់យកក្នុងភិក្ខុជាធម្មវាទីនោះចុះ ។

**សូម្បីអនាថបិណ្ឌិកសេដ្ឋី និងនាងវិសាខាមិគារមាតា** ក៏ចូលទៅក្រាប

ទូលសួរដូចគ្នា ព្រះអង្គត្រាស់តបថា អ្នកចូរថ្វាយទានក្នុងភិក្ខុទាំងពីរខាង លុះឱ្យទានក្នុងភិក្ខុទាំងពីរពួកហើយ ចូរស្តាប់ធម៌ក្នុងភិក្ខុទាំងពីរពួក ភិក្ខុពួកណាជាធម្មវាទី អ្នកចូរពេញចិត្តក្នុងការឃើញ ការគាប់ចិត្ត និងកាន់យកក្នុងភិក្ខុពួកធម្មវាទីនោះ ។

លុះធ្វើដំណើរមកដល់វត្តជេតពន ភិក្ខុកោសម្ពីទាំងនោះ ក្រាបចុះទៀបព្រះបាទា ពោលពាក្យព្រមទទួលថា ពួកខ្លួនបានកន្លងល្មើសសិក្ខាបទ ហើយក្រាបទូលសូមខមាទោសចំពោះព្រះសាស្តា ព្រះមានព្រះភាគត្រាស់ថា អ្នកទាំងឡាយជាបុត្ររបស់តថាគត ធម្មតាបុត្រមិនគួរទម្លាយឱវាទដែលបិតាឱ្យ បានត្រាស់ **ទីឃីតិកោសលជាតក** សេចក្តីសង្ខេបថា ទីឃាវុកុមារនោះចាប់ព្រះមូលីព្រះបាទពារាណសី ដែលផ្ទុំលក់លើភ្លៅរបស់ខ្លួនក្នុងព្រៃ ងារដាវឡើងដោយតាំងចិត្តថា យើងនឹងផ្តាច់ជីវិតឃាតក អ្នកសម្លាប់មាតាបិតារបស់យើង ខណៈនោះរឭកដល់ឱវាទដែលមាតាបិតាផ្តាំទុកថា **ក្នុងកាលណាក៏ដោយ ពៀរក្នុងលោកនេះ រមែងមិនរម្ងាប់ដោយពៀរឡើយ តែរមែងរម្ងាប់បានដោយការមិនចងពៀរ** ទើបគិតថា យើងសូម្បីលះជីវិតក៏មិនទម្លាយឱវាទរបស់លោកឡើយ ក្នុងកាលចប់គាថា ភិក្ខុទាំងនោះតាំងនៅក្នុងអរិយផល មានសោតាបត្តិផលជាដើម ។ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវអាបត្តិហើយ ត្រូវលើកហើយ សម្តែងអាបត្តិចេញហើយ និងសង្ឃទទួលចូលពួកហើយ បើដូច្នោះសង្ឃចូរធ្វើ **សង្ឃសាមគ្គីឧបោសថ** ដើម្បីរម្ងាប់រឿងនោះ

(សេចក្ដីលម្អិតអំពីធ្វើសង្ឃសាមគ្គី មានក្នុងវិន័យបិដកមហាវគ្គ)

(៧) ក្នុងសម័យនោះ អ្នកក្រុងសាវត្ថី វេលាចូលទៅកាន់វត្តជេតពន ក៏នាំផ្កាឈើគ្រឿងក្រអូបជាដើម ទៅដើម្បីបូជាព្រះសាស្ដា តែក្នុងគ្រាខ្លះព្រះពុទ្ធអង្គស្ដេចចារិកទៅតាមជនបទ ដើម្បីសង្គ្រោះវេនេយ្យសត្វ អ្នកស្រុកក៏នាំគ្រឿងបូជាទៅដាក់ទុកត្រង់ទ្វារព្រះគន្ធកុដិ អនាថបិណ្ឌិកសេដ្ឋីឃើញហេតុនោះ ទើបក្រាបទូលព្រះអានន្ទឱ្យរកទីកន្លែងដែលសមគួរមួយ ដើម្បីឱ្យជនទាំងឡាយដាក់គ្រឿងសក្ការបូជាព្រះសាស្ដា ក្នុងវេលាដែលព្រះអង្គទ្រង់មិនបានគង់នៅនាព្រះជេតពនវិហារ ។

ទើបព្រះអានន្ទទៅទូលសួរព្រះសាស្ដាថា កាលព្រះអង្គស្ដេចយាងទៅកាន់ចារិក ខ្ញុំព្រះអង្គអាចធ្វើចេតីយ៍ទុកដើម្បីឱ្យជនទាំងឡាយសក្ការបូជាបានឬទេ ព្រះអង្គ ? ព្រះសាស្ដាត្រាស់សម្ដែងថា :

ម្នាលអានន្ទចេតីយ៍មាន ៣ ប្រភេទ គឺ

**១. ធាតុចេតីយ៍** សម្រាប់បញ្ចុះព្រះសារីរិកធាតុ

**២. បរិភោគចេតីយ៍** គឺវត្ថុ ឬទីដែលព្រះពុទ្ធជាម្ចាស់ទ្រង់ធ្លាប់ប្រើប្រាស់

**៣. ឧទ្ទេសិកចេតីយ៍** បានដល់ព្រះពុទ្ធរូប គឺរូបប្រៀបព្រះពុទ្ធជាម្ចាស់

ម្នាលអានន្ទ ធាតុចេតីយ៍អ្នកមិនអាចធ្វើបានទេ ព្រោះធាតុចេតីយ៍នឹងមានក្នុងកាលដែលព្រះពុទ្ធជាម្ចាស់បរិនិព្វានហើយ តែដើមមហាពោធិព្រឹក្សដែលតថាគតអាស្រ័យជាកន្លែងត្រាស់ដឹង សូម្បីតថាគតនៅមានជីវិត ឬបរិនិព្វាន

ហើយក្តី ក៏កាន់យកជាចេតិយ៍បានដូចគ្នា ចំណែកឧទ្ទេសិកចេតិយ៍មិនមានវត្ថុប្រាកដ (ព្រោះសម័យនោះមិនមានអ្នកណាសាងឡើង) ទើបព្រះអានន្ទក្រាបទូលសូមនាំដើមពោធិព្រឹក្សមកដាំទុកក្បែរផ្លូវចូលវត្តជេតពន ព្រះអង្គទ្រង់យល់ព្រមត្រាស់ថា ល្អហើយអានន្ទ អ្នកធ្វើដូច្នោះវត្តជេតពននឹងដូចតថាគតនៅប្រចាំជានិច្ច ទើបព្រះអានន្ទពោលជាមួយនឹងព្រះមោគ្គល្លានថា ខ្ញុំនឹងដាំដើមពោធិ៍ក្បែរផ្លូវចូលវត្តជេតពន សូមលោកម្ចាស់ជួយនាំគ្រាប់ពោធិ៍ទុំ អំពីដើមមហាពោធិ៍ដែលព្រះអង្គត្រាស់ដឹងមកឱ្យខ្ញុំផង ព្រះមហាមោគ្គល្លាន បានទៅកាន់ពោធិ-មណ្ឌល យកចីវរទទួលផ្លែពោធិ៍ទុំដែលរុះចាកទង តែមិនទាន់ដល់ផែនដីនាំមកឱ្យព្រះអានន្ទ កាលបានគ្រាប់ពោធិ៍មកហើយ ព្រះអានន្ទបានថ្វាយព្រះបាទបសេន-ទិកោសលឱ្យទ្រង់ដាំ ព្រះរាជាទ្រង់ព្រះតម្រិះថា ភាពជាព្រះរាជាមិនបានតាំងនៅរហូតទេ គួរនឹងឱ្យអនាថបិណ្ឌិកសេដ្ឋីដាំដើមពោធិ៍នេះ ទើបដាក់ផ្លែពោធិ៍ទុំនោះក្នុងដៃរបស់សេដ្ឋី ។ កាលអនាថបិណ្ឌិកសេដ្ឋីដាក់គ្រាប់ពោធិ៍ចុះក្នុងរណ្តៅក៏ដុះធំធាត់ជាដើមឈើធំមួយរំពេច មានមែកសាខាផ្សាយចេញទៅដោយជុំវិញព្រះរាជាទ្រង់ស្រោចពោធិ៍នោះដោយសុគន្ធរស ក្រោយអំពីនោះ ព្រះអានន្ទទូលសូមឱ្យព្រះសាស្តាគង់ចូលសមាបត្តិទៀបគល់ពោធិ៍នោះ ដើម្បីប្រយោជន៍អនុ-គ្រោះដល់មហាជន ព្រះសាស្តាទ្រង់គង់ក្បែរគល់ពោធិ៍នោះ ដោយសេចក្តីសុខកើតពីសមាបត្តិរហូតមួយរាត្រី ទើបដើមពោធិ៍នោះបានឈ្មោះថា **អានន្ទពោធិ៍** ដែលតាំងនៅប្រាកដដរាបដល់សព្វថ្ងៃនេះ ។

(៨) គ្រាមួយ អនាថបិណ្ឌិកសេដ្ឋីចូលទៅគាល់ព្រះអង្គដល់ទីប្រថាប់ ព្រះមានព្រះភាគត្រាស់ **អាទិយសូត្រ គឺ គោលការណ៍ក្នុងការចាយវាយភោគទ្រព្យឱ្យជាប្រយោជន៍ ៥ ប្រការ** ដល់អនាថបិណ្ឌិកសេដ្ឋីថា អរិយសាវ័កក្នុងធម្មវិន័យនេះ រមែងចាយវាយភោគទ្រព្យដែលខ្លួនរកមកបានដោយសេចក្ដីប្រឹងប្រែង សន្សំឡើងដោយកម្លាំងដៃបែកញើសហូរញើស បានមកដោយធម៌ គឺ :

**១. ចិញ្ចឹមខ្លួន ចិញ្ចឹមមាតាបិតា បុត្រភរិយា ទាសកម្មករឱ្យជាសុខឆ្អែតឆ្អន់ ។**

**២. ចិញ្ចឹមមិត្តសម្លាញ់ឱ្យជាសុខឆ្អែតឆ្អន់ ។**

**៣. ដើម្បីការពារអន្តរាយអំពីភ្លើង ទឹក ព្រះរាជា ចោរ និងទាយាទមិនជាទីស្រឡាញ់ ។**

**៤. ធ្វើពលី ៥ យ៉ាង គឺ ញាតិពលី** ទំនុកបម្រុងញាតិ **អតិថិពលី** ទទួលភ្ញៀវ **បុព្វបេតពលី** ធ្វើបុណ្យឧទ្ទិសឱ្យអ្នកស្លាប់ **រាជពលី** ចរិច្ចាគទ្រព្យជួយជាតិ **ទេវតាពលី** ធ្វើបុណ្យឧទ្ទិសឱ្យទេវតា ។

**៥. បំពេញទក្ខិណាទាន គឺ ការឱ្យទាន ដើម្បីផលជាសុខក្នុងភពខាងមុខ ។**

កាលអរិយសាវ័កនោះ កាន់យកប្រយោជន៍អំពីការចាយវាយទ្រព្យ ៥ ប្រការនេះហើយ សូម្បីភោគទ្រព្យនឹងអស់ទៅ រមែងមិនស្ដាយក្រោយ បើធ្វើយ៉ាងនេះហើយ ភោគទ្រព្យចម្រើនឡើង ក៏រមែងមិនមានសេចក្ដីក្ដៅក្រហាយ

ទាំងពីរប្រការ បណ្ឌិតទាំងឡាយរមែងសរសើរក្នុងលោកនេះ កាលលះលោកនេះទៅហើយ រមែងរីករាយក្នុងស្ថានសួគ៌ ។

( ៩ ) ព្រះសាស្តាកាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះពិឡាលបទកៈ ( សេដ្ឋីជើងឆ្មា ) នៅក្រុងសាវត្ថី បានថ្វាយទាន កាលនឹងទ្រង់ធ្វើអនុមោទនា ព្រះអង្គត្រាស់ថា បុគ្គលពួកខ្លះ **ឱ្យទានដោយខ្លួនឯង តែមិនបបួលអ្នកដទៃ** គេរមែងបានភោគសម្បត្តិ តែមិនបានបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ ។ បុគ្គលពួកខ្លះ **មិនឱ្យទានដោយខ្លួនឯង បបួលតែអ្នកដទៃ** គេរមែងបានបរិវារសម្បត្តិ តែមិនបានទ្រព្យសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ។ បុគ្គលពួកខ្លះ **មិនឱ្យទានដោយខ្លួនឯង មិនបបួលអ្នកដទៃ** គេរមែងមិនបានទាំងភោគសម្បត្តិ និងបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ ។ បុគ្គលពួកខ្លះ **ឱ្យទានដោយខ្លួនឯងផង បបួលអ្នកដទៃផង** គេរមែងបានទាំងភោគសម្បត្តិ និងបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ ។

ឧបាសកម្នាក់ ស្តាប់ព្រះធម្មទេសនានោះហើយ ក្រាបទូលអារាធនាឱ្យព្រះពុទ្ធអង្គ ព្រមដោយភិក្ខុសង្ឃទាំងអស់ ទទួលបិណ្ឌបាតរបស់ខ្លួនក្នុងថ្ងៃស្អែក ហើយចេញដើរប្រកាសប្រាប់អ្នកជិតខាងឱ្យព្រមព្រៀងគ្នាមកថ្វាយទាន ក្នុងពេលនោះឯង សេដ្ឋីម្នាក់ខឹងក្រោធថា ហេតុអ្វីទើបមិននិមន្តត្រឹមតែកម្លាំងទ្រព្យរបស់ខ្លួន ចាំបាច់មកបបួលអ្នកស្រុក កាលដែលឱ្យវត្ថុសេដ្ឋីយកម្រាមដៃត្រឹមតែ ៣ ច្បិចអង្ករ និងសណ្តែកជាដើម សូម្បីកាលនឹងឱ្យភេសជ្ជៈ មានទឹកដោះថ្លា និងស្ករ

អំពៅ ក៏ផ្សៀងមាត់ដបបង្ហូរចុះមួយដំណក់ៗ បានឱ្យបន្តិចៗប៉ុណ្ណោះ ដោយសេចក្តីកំណាញ់ ទើបសេដ្ឋីនេះបានឈ្មោះថា **សេដ្ឋីកញ្ចុំជើងឆ្មា** ។

ឧបាសកនោះ បានរំលែកយកនូវវត្ថុទានរបស់សេដ្ឋីនេះទុកដោយឡែក កាលសេដ្ឋីឃើញដូច្នេះ ទើបបញ្ជូនមនុស្សរបស់ខ្លួនឱ្យតាមទៅមើលព្រឹត្តិការណ៍របស់ឧបាសកនោះ កាលឧបាសកត្រឡប់ទៅហើយ បាននាំយកអង្ករ ២-៣ គ្រាប់ដាក់ចុះក្នុងចំណែកដែលធ្វើយាគូ ភត្ត និងនំគ្រប់យ៉ាង មនុស្សសម្ងាត់ឃើញដូច្នោះហើយ ត្រឡប់មកប្រាប់សេដ្ឋីវិញ លុះព្រឹកឡើងសេដ្ឋីនោះសៀតកាំបិតស្នៀតទុកក្នុងសំពត់ គិតថា បើឧបាសកបង្អាប់ឈ្មោះយើង យើងនឹងប្រហារវាឱ្យស្លាប់ ។

ក្នុងវេលាថ្វាយទាន ឧបាសកនោះក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបបួលមហាជនថ្វាយទាននេះ តាមតិចតាមច្រើនរបស់មនុស្សម្នាក់ៗ សូមផលដ៏ពេញបរិបូរណ៍ចូរមានដល់មហាជនទាំងនោះស្មើៗ គ្នា សេដ្ឋីបានស្តាប់ពាក្យជូនបុណ្យរបស់ឧបាសកនោះហើយ ក្រាបចុះទៀបបាទជើងរបស់ឧបាសកនោះពោលថា សូមលោកអត់ទោសឱ្យខ្ញុំផង ហើយប្រាប់រឿងទាំងអស់ដល់ឧបាសកនោះ ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីនោះ ត្រាស់ព្រះគាថាថា :

**បុគ្គលមិនគួរមើលងាយបុណ្យ ថាបុណ្យមានប្រមាណតិច**
**ក្អមទឹកពេញដោយដំណក់ទឹក ដែលធ្លាក់ចុះមកម្តងមួយដំណក់ៗ**
**យ៉ាងណាមិញ ជនអ្នកមានបញ្ញា សន្សំបុណ្យសូម្បីម្តងបន្តិចៗ**
**រមែងពេញដោយបុណ្យបានដូច្នោះដែរ ។**

ក្នុងកាលចប់ធម្មទេសនា សេដ្ឋីនោះសម្រេចសោតាបត្តិផល ហើយព្រះ-ធម្មទេសនាមានប្រយោជន៍ដល់មហាជន ដែលមកប្រជុំគ្នាក្នុងទីនោះទាំងអស់ ។

( ១០ ) គ្រាមួយ ព្រះមានព្រះភាគជាម្ចាស់ទ្រង់គង់នៅវត្តជេតពន **ព្រះគិរីមានន្ទ** អាពាធធ្ងន់ ព្រះអានន្ទបានចូលទៅទូលសូមប្រទានព្រះវរោ-កាស ឱ្យព្រះអង្គយាងទៅសួរសុខទុក្ខគិរីមានន្ទ នៅក្នុងសំណាក់របស់ព្រះថេរៈ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ម្នាលអានន្ទ អ្នកគប្បីចូលទៅរកហើយសម្ដែងសញ្ញា ១០ ប្រការ ដល់គិរីមានន្ទ អាពាធរបស់គិរីមានន្ទភិក្ខុនឹងជាសះស្បើយដោយឆាប់រហ័ស ព្រោះបានស្ដាប់សញ្ញា ១០ ប្រការនោះ ជាឋានៈអាចប្រព្រឹត្តទៅបាន សញ្ញា ១០ ប្រការនោះគឺ **អនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ សព្វលោកេអនភិរតសញ្ញា ១ សព្វសង្ខារេសុ អនិច្ឆ-សញ្ញា ១ អានាបានស្សតិ ១** ។

អធិប្បាយសញ្ញា ១០ ប្រការ មានក្នុងអង្គុត្តរនិកាយទសកនិបាត ភាគ..........ទំ..........

គ្រានោះ ព្រះអានន្ទបានរៀនសញ្ញា ១០ ប្រការអំពីព្រះមានព្រះភាគជាម្ចាស់ហើយ ចូលទៅរកគិរីមានន្ទភិក្ខុ សម្ដែងសញ្ញា ១០ ប្រការនោះ អាពាធរបស់គិរីមានន្ទស្ងប់រម្ងាប់ដោយឆាប់រហ័ស ព្រោះកិលេសមានរាគៈជាដើមស្ងប់កាលបានស្ដាប់សញ្ញា ១០ ប្រការនេះ ។

( ១១ ) សម័យមួយ ក្នុងវត្តជេតពន ព្រះមានព្រះភាគជាម្ចាស់ត្រាស់ជា

មួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតឆាន់អាហារមួយថ្ងៃត្រឹមតែមួយពេល រមែងដឹងច្បាស់ គឺជាអ្នកមានអាពាធតិច មានរោគស្រាលស្តើង មានកាយស្រាលរហ័ស មានកម្លាំង និងនៅជាសុខ សូម្បីអ្នកទាំងឡាយក៏ចូរឆាន់អាហារមួយថ្ងៃមួយពេលនឹងនៅជាសុខ ។

**ព្រះភទ្ទាលិ** បានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចឆាន់អាហារត្រឹមតែមួយពេលបានទេ ព្រោះនឹងកើតសេចក្តីរំខាន សេចក្តីក្រហល់ក្រហាយដល់រាងកាយរបស់ខ្ញុំព្រះអង្គ ។ ព្រះអង្គត្រាស់ថា ភទ្ទាលិ បើដូច្នោះអ្នកទទួលនិមន្តក្នុងទីណាហើយ គប្បីឆាន់ក្នុងទីនោះមួយចំណែក ហើយនាំមួយចំណែកមកឆាន់ទៀតក៏បាន កាលអ្នកឆាន់បានយ៉ាងនេះ ក៏នឹងញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅជាប្រក្រតីបាន ។

សូម្បីព្រះសាស្តាត្រាស់យ៉ាងនេះហើយ ព្រះភទ្ទាលិនៅប្រកាសការធន់មិនបាន ដែលនឹងបដិបត្តិតាម ក្នុងកាលព្រះពុទ្ធអង្គទ្រង់បញ្ញត្តសិក្ខាបទ និងកាលពួកសង្ឃសមាទាននូវសិក្ខាបទនេះ ព្រះភទ្ទាលិគេចចេញទៅ មិនឱ្យបានជួបព្រះ-ភក្ត្រព្រះមានព្រះភាគ រហូតត្រៃមាសនោះ ។ សម័យនោះ ភិក្ខុទាំងឡាយជួយគ្នាធ្វើចីវរកម្មសម្រាប់ព្រះមានព្រះភាគ ដើម្បីយាងចារិកទៅក្នុងពេលចេញព្រះវស្សា ព្រះភទ្ទាលិចូលទៅរកភិក្ខុទាំងនោះ ត្រូវបានដាស់តឿនថា លោកចូរពិចារណានូវកំហុសនោះចុះ កុំឱ្យមានសេចក្តីក្តៅក្រហាយកើតឡើងក្នុងកាលជាខាងក្រោយឡើយ ។ ទើបព្រះភទ្ទាលិ ចូលទៅគាល់ព្រះមានព្រះភាគជាម្ចាស់

ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទោសបានគ្របសង្កត់ខ្ញុំព្រះអង្គជាមនុស្សពាល ជាមនុស្សវង្វេង មិនឆ្លាត មិនសមាទានសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្ត សូមព្រះមានព្រះភាគប្រោសអត់នូវទោសនោះ ដោយជាទោសពិតដល់ខ្ញុំព្រះអង្គ ដើម្បីសេចក្ដីសង្រួមតទៅ ។

ព្រះសាស្តាត្រាស់ថា ព្រោះអ្នកឃើញទោសដោយពិត ហើយសម្តែងចេញតាមធម៌ ទើបតថាគតអត់ទោសឱ្យអ្នក បុគ្គលដែលឃើញទោសថាជាទោសពិត ហើយសម្តែងចេញតាមធម៌ ដល់សេចក្ដីសង្រួមតទៅ នេះជាសេចក្ដីចម្រើនក្នុងវិន័យរបស់ព្រះអរិយៈ ។

បន្ទាប់ពីនោះ ព្រះមានព្រះភាគត្រាស់ទូន្មានថា អ្នកដែលធ្វើឱ្យបរិបូរណ៍ក្នុងសិក្ខាបទដែលទ្រង់បញ្ញត្តហើយ រមែងមានសេចក្ដីត្រិះរិះថា យើងនឹងសេពសេនាសនៈដ៏ស្ងាត់ ធ្វើនូវសេចក្ដីព្យាយាម គប្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេសរបស់ព្រះអរិយៈ កាលលោកគេចចេញដោយប្រការនោះ ព្រះសាស្តាក៏នឹងមិនទ្រង់តិះដៀល មិត្តសព្រហ្មចារីក៏មិនតិះដៀល ទេវតាក៏មិនតិះដៀល សូម្បីខ្លួនក៏តិះដៀលខ្លួនឯងមិនបាន អ្នករមែងធ្វើឱ្យច្បាស់នូវគុណវិសេស ។

ម្នាលភទ្ទាលិ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកប្រកបដោយធម៌ ១០ ប្រការ គឺ **សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មា-វាយាមៈ សម្មាសតិ សម្មាសមាធិ សម្មាញាណៈ សម្មាវិមុត្តិ** ដែលជារបស់ព្រះអសេក្ខៈ រមែងជាអ្នកគួរដល់ទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលីកម្ម ជាស្រែ

បុណ្យនៃសត្វលោក មិនមានស្រែបុណ្យដទៃក្រៃលែងជាង ដូច្នេះ ។

( ១២ ) ព្រះមានព្រះភាគជាម្ចាស់ត្រាស់ដូច្នោះហើយ បានត្រាស់ **បារសូត្រ** ពោលអំពីធម៌ជាគ្រឿងឆ្លងដល់ត្រើយ គឺ **ព្រះនិព្វាន** ដល់ភិក្ខុទាំងឡាយទៀតថា :

**ក្នុងពពួកមនុស្ស ជនអ្នកដល់ត្រើយមានចំនួនតិច ពួកសត្វក្រៅពីនេះរមែងរត់ទៅតាមក្រសែទឹក ចំណែកពួកជនណាប្រព្រឹត្តតាម ក្នុងធម៌ដែលព្រះមានព្រះភាគ ត្រាស់ល្អហើយ ជនពួកនោះ នឹងឆ្លងផុតអន្ទាក់មច្ចុដែលឆ្លងបានដ៏សែនលំបាក ទៅដល់ច្រាំងបាន ។ បណ្ឌិតគប្បីលះធម៌ខ្មៅចេញ គប្បីចម្រើនធម៌ស ប្រាសចាកកិលេសជាគ្រឿងកង្វល់ ប្រឹងប្រែងព្យាយាមដើម្បីចេញចាកវដ្តៈ ប្រាថ្នាសេចក្តីត្រេកអរក្នុងវិវេក ដែលសត្វត្រេកអរបានដោយកម្រ ។ បណ្ឌិតគប្បីញ៉ាំងខ្លួនឱ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត ជនពួកណាអប់រំចិត្តល្អហើយដោយប្រពៃ ក្នុងធម៌ជាគ្រឿងត្រាស់ដឹង រមែងមិនប្រកាន់មាំ ។**

ត្រេកអរក្នុងការលះបង់សេចក្តីប្រកាន់មាំ នឹងជាអ្នកអស់អាសវៈ បរិ-និព្វានក្នុងលោកនេះ ម្នាលភិក្ខុទាំងឡាយ ធម៌សដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីដល់ច្រាំង គឺព្រះនិព្វានដូច្នេះ ។

# ព្រះវស្សាទី ១១

## ទ្រង់គង់ចាំព្រះវស្សា ក្នុងស្រុកព្រាហ្មណ៍ឈ្មោះ ឯកនាលា ដែនមគធៈ

ព្រះពុទ្ធអង្គទ្រង់ត្រួតមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញ **កសិភារទ្វាជព្រាហ្មណ៍** អ្នកដល់ព្រមដោយឧបនិស្ស័យនៃព្រះអរហត្ត ទ្រង់ជ្រាបថា កាលព្រះអង្គទ្រង់សម្តែងធម៌ក្នុងព្រាហ្មណគ្រាម ក្នុងវេលាចប់កថា ព្រាហ្មណ៍នោះស្តាប់ព្រះធម្មទេសនា បួសហើយនឹងសម្រេចព្រះអរហត្ត ទើបយាងទៅកាន់ឯកនាលា ដែលជាស្រុកជិតទក្ខិណាគិរីជនបទ ទិសខាងត្បូងនៃក្រុងរាជគ្រឹះ ។

(១) មុននឹងដល់ឯកនាលា ព្រះពុទ្ធអង្គយាងឆ្លង **បញ្ចសាលគាម** ស្រុកព្រាហ្មណ៍ ក្នុងដែនមគធៈ ហើយស្នាក់នៅបញ្ចសាលគ្រាម សម័យនោះមានបុណ្យនក្ខត្តឫក្សក្នុងស្រុក ព្រះមានព្រះភាគចូលទៅបិណ្ឌបាត យាងត្រឡប់មកដោយបាត្រទទេ ព្រោះមារបណ្តាលចិត្តអ្នកស្រុក ដោយបំណងមិនឱ្យព្រះសមណគោតមបានអាហារបិណ្ឌបាត មារចូលមករកដល់ទីប្រថាប់ ពោលថា សមណៈលោកបានបិណ្ឌបាតខ្លះឬទេ ? ព្រះមានព្រះភាគត្រាស់ថា ម្នាលមារមានចិត្តបាបអ្នកបានធ្វើមិនឱ្យតថាគតបានបិណ្ឌបាតមិនមែនឬ ? មារក្រាបទូលថា បើដូច្នោះសូមព្រះអង្គចូលទៅបិណ្ឌបាតម្តងទៀតចុះ ខ្ញុំព្រះអង្គនឹងធ្វើឱ្យព្រះអង្គបានបិណ្ឌបាត ព្រះអង្គទ្រង់បដិសេធ ។ គ្រានោះមារមានចិត្តបាប កើតទុក្ខតូចចិត្តថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ស្គាល់យើង ព្រះសុគតទ្រង់ស្គាល់យើង ទើបបាត់ទៅក្នុងទីនោះឯង ដើមហេតុដែលមារបណ្តាលចិត្តអ្នកស្រុក ព្រោះមារគិតថា

ជនទាំងនោះកាលស្តាប់នូវព្រះធម្មទេសនារបស់ព្រះសាស្តាហើយ នឹងកន្លងផុតអំណាចរបស់ខ្លួន ។ **តពីនោះ ព្រះមានព្រះភាគយាងទៅគង់នៅក្នុងស្រុកព្រាហ្មណ៍ឈ្មោះឯកនាលា ។**

( ២ ) សម័យនោះ **កសិភារទ្វាជព្រាហ្មណ៍** ត្រៀមការភ្ជួរក្នុងរដូវកាលសាបព្រោះក្នុងវេលាព្រឹក ខណៈដែលកំពុងលៀងអាហាររួមគ្នា ឃើញព្រះមានព្រះភាគយាងមកប្រថាប់ឈរដើម្បីបិណ្ឌបាត ទើបព្រាហ្មណ៍ក្រាបទូលព្រះមានព្រះភាគថា បពិត្រសមណៈ ខ្ញុំព្រះអង្គរមែងភ្ជួរ និងសាបព្រោះ លុះភ្ជួរ និងសាបព្រោះហើយ រមែងបានផលនោះបរិភោគ សូម្បីព្រះអង្គក៏ចូរភ្ជួរ និងសាបព្រោះ ហើយបរិភោគចុះ ។

ព្រះមានព្រះភាគត្រាស់តបថា ម្នាលព្រាហ្មណ៍ សូម្បីតថាគតក៏ភ្ជួរ និងសាបព្រោះហើយទើបបរិភោគដូចជាអ្នកដែរតើ ព្រាហ្មណ៍ក្រាបទូលថា ខ្ញុំព្រះអង្គមិនឃើញនឹម នង្គ័ល ផាល ជន្លួញ ឬគោទាំងឡាយរបស់ព្រះគោតមឡើយ ព្រះអង្គត្រាស់ថាជាអ្នកស្រែ តែខ្ញុំព្រះអង្គមិនឃើញការភ្ជួររបស់ព្រះអង្គ ដូចម្តេចខ្ញុំព្រះអង្គនឹងស្គាល់ការធ្វើស្រែរបស់ព្រះអង្គបាន ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់សម្តែងតបថា

**សទ្ធារបស់តថាគតជាពូជ សេចក្តីព្យាយាមរបស់តថាគតជាភ្លៀង**
**បញ្ញារបស់តថាគតជានឹម និងនង្គ័ល ហិរិរបស់តថាគតជាយាមនង្គ័ល**
**ចិត្តរបស់តថាគតជាខ្សែ សតិរបស់តថាគតជាផាល និងជន្លួញ**

**ផលដែលច្រូតបាន គឺ ព្រះនិព្វាន បុគ្គលធ្វើស្រែយ៉ាងនេះហើយ រមែងផុតចាកទុក្ខទាំងពួង ។**

ម្នាលព្រាហ្មណ៍ អ្នកណាមួយជាគ្រហស្ថក្តី ជាបព្វជិតក្តី មានការសង្រួមឥន្ទ្រិយ៍ គ្រប់គ្រងកាយ គ្រប់គ្រងវាចាដូច្នេះហើយ រមែងផុតចាកទុក្ខទាំងពួងបាន ។ កសិភារទ្វាជព្រាហ្មណ៍ បានស្តាប់ទេសនាដែលមានសេចក្តីជ្រៅដូច្នេះហើយ កើតសេចក្តីជ្រះថ្លា បង្អោនថ្វាយបាយបាយាសដល់ព្រះពុទ្ធអង្គ ក្រាបទូលថា សូមព្រះគោតមសោយបាយាសចុះ ព្រះអង្គជាអ្នកស្រែ រមែងភ្ជួរស្រែដែលមានផលជាអមតៈ ។

ព្រះសាស្តាទ្រង់បដិសេធត្រាស់ថា តថាគតមិនគួរទទួលទានវត្ថុដែលដូចជាថ្លៃឈ្នួលអំពីការសម្តែងធម៌ សេចក្តីនេះមិនមែនជាឋានៈរបស់ព្រះពុទ្ធទាំង-ឡាយទេ អ្នកចូរបម្រុងព្រះខីណាស្រពដែលបរិបូរណ៍ដោយគុណទាំងពួងដោយបាយ និងទឹកដទៃចុះ ព្រោះថាស្រែនោះជាស្រែរបស់បុគ្គលអ្នកប្រាថ្នាបុណ្យ ព្រាហ្មណ៍ទូលសួរថា បើដូច្នោះខ្ញុំព្រះអង្គនឹងថ្វាយដល់អ្នកណា ព្រះសាស្តាត្រាស់ថា អ្នកចូរចាក់បាយាសនោះចុះក្នុងទឹកដែលមិនមានសត្វចុះ ព្រោះក្រៅអំពីតថាគត និងសាវ័កតថាគតហើយ មិនអ្នកណាក្នុងលោកនេះបរិភោគបាយាសដែលអ្នកថ្វាយហើយដល់តថាគត នឹងគប្បីឱ្យរលាយទៅដោយល្អបាន (ព្រោះទេវតាបានដាក់ឱជារសក្នុងបាយាសនោះហើយ) ទើបកសិភារទ្វាជព្រាហ្មណ៍ចាក់បាយាសនោះចុះក្នុងទឹក រំពេចនោះ កើតជាផ្សែងឆួលឡើងដោយជុំវិញដូចចោល

ដុំដែកដែលដុតឱ្យក្រហមចុះទៅដូច្នោះ ។

កសិភារទ្វាជព្រាហ្មណ៍ អស្ចារ្យក្នុងព្រះពុទ្ធានុភាព ក្រាបចុះទៀបព្រះយុគលបាទរបស់ព្រះមានព្រះភាគដោយសិរសា ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គជាក់ច្បាស់ណាស់ ព្រះគោតមទ្រង់ប្រកាសធម៌ដោយអនេកបរិយាយ ប្រៀបដូចផ្ងាររបស់ដែលផ្កាប់ បើករបស់ដែលបិទ ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬទ្រោលប្រទីបក្នុងទីងងឹត ដោយបំណងថា អ្នកមានចក្ខុនឹងឃើញរូបបាន ខ្ញុំព្រះអង្គនេះសូមដល់ព្រះគោតមដ៏ចម្រើន ព្រមទាំងព្រះធម៌ និងភិក្ខុសង្ឃជាសរណៈ សូមព្រះគោតមដ៏ចម្រើនទ្រង់ចាំទុកនូវព្រះអង្គថាជាឧបាសក អ្នកដល់ព្រះរតនត្រ័យស្មើដោយជីវិត តាំងពីថ្ងៃនេះទៅ សូមឱ្យខ្ញុំព្រះអង្គបានចេញបួស ក្នុងសំណាក់របស់ព្រះអង្គផងចុះ ។

កសិភារទ្វាជព្រាហ្មណ៍ បានបព្វជ្ជាឧបសម្ប័ទក្នុងសំណាក់របស់ព្រះមាន-ព្រះភាគហើយ គេចចេញចាកពួកគណៈទៅតែម្នាក់ឯង ដោយសេចក្តីមិនប្រមាទ មានសេចក្តីព្យាយាម មានចិត្តបញ្ជូនទៅ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តផល ជាព្រះអរហន្តមួយអង្គក្នុងព្រះពុទ្ធសាសនា ។

( ៣ ) ក្រៅពីនោះ ព្រះពុទ្ធអង្គទ្រង់ដោះស្រាយបញ្ហារបស់ទេវតាដ៏ច្រើន មានជាដើមដូចជា **វនរោបសូត្រ** ពោលអំពីបុណ្យចម្រើនបានគ្រប់កាល ទេវតាទូលសួរថា ជនពួកណាមានបុណ្យចម្រើនគ្រប់កាល ទាំងថ្ងៃទាំងយប់ ជន-ពួកណាតាំងនៅក្នុងធម៌ បរិបូរណ៍ដោយសីល ជាអ្នកទៅកាន់ឋានសួគ៌ ព្រះអង្គ ?

ត្រាស់តបថា ជនពួកណាសាងអារាម សួនឈើផ្កា ឈើផ្លែ ដាំឈើម្លប់ឱ្យជាម្លប់ សាងស្ពាន ជនពួកណាសាងស្រះទឹក និងអណ្តូងទឹកជាទាន សាងទីស្នាក់អាស្រ័យ ជនពួកនោះរមែងមានបុណ្យចម្រើនគ្រប់កាល ទាំងថ្ងៃទាំងយប់ ជនទាំងនោះតាំងនៅក្នុងធម៌ បរិបូរណ៍ដោយសីល ជាអ្នកទៅកាន់ស្ថានសួគ៌ ។

**លោកសូត្រ** ពោលអំពីអាយតនៈ ៦ ទេវតាទូលសួរថា កាលអ្វីកើតឡើង ទើបសត្វលោកកើត សត្វលោករមែងត្រេកអរនឹងអ្វី ប្រកាន់មាំអ្វី សត្វលោករមែងក្តៅក្រហាយព្រោះអ្វី ? ព្រះពុទ្ធអង្គត្រាស់តបថា កាលអាយតនៈ ៦ កើតឡើង សត្វលោកឈ្មោះថាកើតឡើង សត្វលោករមែងត្រេកអរក្នុងអាយ-តនៈ ៦ សត្វលោកប្រកាន់មាំអាយតនៈ ៦ សត្វលោករមែងក្តៅក្រហាយព្រោះអាយតនៈ ៦ ។

**កុដិកាសូត្រ** ពោលអំពីមាតាដូចជាខ្ទម ទេវតាទូលសួរថា ខ្ទមរបស់ព្រះអង្គមិនមានឬ ? សំបុករបស់ព្រះអង្គមិនមានឬ ? គ្រឿងតរបស់ព្រះអង្គមិនមានឬ ? ព្រះអង្គជាអ្នកផុតហើយចាកគ្រឿងចងឬ ?

ព្រះពុទ្ធអង្គត្រាស់តបថា ពិតមែន ខ្ទមរបស់តថាគតមិនមាន សំបុករបស់តថាគតមិនមាន គ្រឿងតរបស់តថាគតមិនមាន តថាគតជាអ្នកផុតហើយចាកគ្រឿងចងទាំងពួង ។

ទេវតាទូលសួរថា អ្វីជាខ្ទម អ្វីជាសំបុក អ្វីជាគ្រឿងត អ្វីជាគ្រឿងចង ?

ព្រះអង្គត្រាស់តបថា មាតាជាខ្ទម ភរិយាជាសំបុក បុត្រជាគ្រឿងត និង

តណ្ហាជាគ្រឿងចង ។ ទេវតាទូលសរសើរថា សាធុ ! ខ្ទមរបស់ព្រះអង្គមិនមាន សំបុករបស់ព្រះអង្គមិនមាន គ្រឿងតរបស់ព្រះអង្គមិនមាន ព្រះអង្គជាអ្នកផុតហើយចាកគ្រឿងចងទាំងពួង ។

**ឧបនេយ្យសូត្រ** ទេវតាក្រាបទូលថា ជីវិតគឺអាយុមានប្រមាណតិច ត្រូវជរានាំចូលទៅរកសេចក្តីស្លាប់ បុគ្គលកាលត្រូវជរានាំចូលទៅហើយ រមែងមិនមានអ្វីការពារ បុគ្គលកាលឃើញភ័យនេះក្នុងមរណៈ គប្បីធ្វើបុណ្យទាំងឡាយដែលនាំសេចក្តីសុខមកឱ្យ ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ជីវិត គឺអាយុមានប្រមាណតិច កាលបុគ្គលត្រូវជរានាំចូលទៅហើយ រមែងមិនមានអ្វីការពារ បុគ្គលកាលឃើញភ័យនេះក្នុងមរណៈ គប្បីលះអាមិស ជាគ្រឿងនាំឱ្យជាប់នៅក្នុងលោកចេញ គប្បីស្វែងរកសន្តិបទចុះ ។

**ជរាសូត្រ** ទេវតាទូលសួរថា អ្វីញុំាងប្រយោជន៍ឱ្យសម្រេច ដរាបដល់ជរា ?

អ្វីតាំងមាំហើយ ញុំាងប្រយោជន៍ឱ្យសម្រេច ? អ្វីជារតនៈរបស់មនុស្សទាំងឡាយ ?

ព្រះអង្គត្រាស់តបថា សីលញុំាងប្រយោជន៍ឱ្យសម្រេច រហូតដល់ជរា

សទ្ធាតាំងមាំហើយ ញុំាងប្រយោជន៍ឱ្យសម្រេច បញ្ញាជារតនៈរបស់មនុស្សទាំងឡាយ ។

( បញ្ហារបស់ទេវតា ព្រះពុទ្ធអង្គទ្រង់ព្យាករណ៍ក្នុងវេលាជិតភ្លឺ )

## ក្រោយអំពីចេញព្រះវស្សាទី ១១ ហើយ

យាងទៅកាន់ចារិកទៅប្រោសវេនេយ្យសត្វ ក្នុងដែនផ្សេងៗ តែមិនបាន បញ្ជាក់ថាទីណា លុះជិតចូលព្រះវស្សា យាងទៅកាន់ស្រុកវេរញ្ជា ។

**អាសវៈទាំងឡាយ របស់បុគ្គលដែលភ្ញាក់ឡើងគ្រប់ពេលវេលា**

**ជាអ្នកតាមសិក្សា ទាំងយប់ទាំងថ្ងៃ មានចិត្តបង្អោនចិត្តចូល**

**ព្រះនិព្វាន រមែងដល់នូវការតាំងនៅមិនបាន**

# ព្រះវស្សាទី ១២

## គង់គង់ចាំព្រះវស្សា នៅជិតគល់ស្ដៅ ស្រុកវេរញ្ជា

(១) គ្រានោះ **វេរញ្ជព្រាហ្មណ៍** ចូលទៅទូលសួរព្រះសាស្ដាថា ខ្ញុំព្រះអង្គបានឮមកថា ព្រះសមណគោតមមិនថ្វាយបង្គំ មិនក្រោកទទួលពួកព្រាហ្មណ៍ចាស់ព្រឹទ្ធាចារ្យ មិនអញ្ជើញដោយអាសនៈ ពិតឬទេ ? បើពិតដូច្នោះមែនសេចក្ដីនេះមិនសមគួរឡើយ ។

ព្រះអង្គត្រាស់ថា ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្ស តថាគតមិនឃើញបុគ្គលណាដែលតថាគតគួរថ្វាយបង្គំ គួរក្រោកទទួល ឬគួរអញ្ជើញដោយអាសនៈ ព្រោះបើតថាគតធ្វើដូច្នោះ ក្បាលរបស់អ្នកនោះក៏នឹងបែកជាជម្រៀក៧ ។

ព្រាហ្មណ៍សួរថា បានឮគេថា **ព្រះសមណគោតមមិនត្រេកអរចំពោះវត្ថុទាំងឡាយ** ព្រះអង្គត្រាស់ថា សេចក្ដីនេះគេពោលត្រូវ ព្រោះរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈទាំងនោះ តថាគតលះបង់បានអស់ហើយ កាត់ឫសគល់ដាច់ហើយ មិនមានការកើតតទៅទៀតទេ ។

ព្រាហ្មណ៍សួរថា បានឮគេថា **ព្រះសមណគោតមជាអ្នកមិនមានភោគៈ** ព្រះអង្គត្រាស់ថា សេចក្ដីនេះគេពោលពិត ព្រោះភោគៈ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈទាំងនោះ តថាគតបានលះបង់អស់ហើយ កាត់ឫសគល់ដាច់ហើយ មិនមានការកើតតទៅទៀតទេ ។

ព្រាហ្មណ៍សួរថា បានឮគេថា **ព្រះសមណគោតមពោលដល់ការមិនធ្វើ** ព្រះអង្គត្រាស់ថា សេចក្ដីនេះគេពោលត្រូវ តថាគតពោលការមិនធ្វើកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត តថាគតពោលការមិនធ្វើនូវធម៌ដែលជាបាបអកុសលទាំងពួង ។

ព្រាហ្មណ៍សួរថា បានឮគេថា **ព្រះសមណគោតមពោលដល់ការដាច់សូន្យ** ព្រះអង្គត្រាស់ថា សេចក្ដីនេះគេពោលត្រូវ ព្រោះតថាគតពោលដល់ការដាច់សូន្យនៃ រាគៈ ទោសៈ មោហៈ និងធម៌ដែលជាបាបអកុសលទាំងពួង ។

ព្រាហ្មណ៍សួរថា បានឮគេថា **ព្រះសមណគោតមជាអ្នកមានសេចក្ដីរង្កៀស** ព្រះអង្គត្រាស់ថា សេចក្ដីនេះពិត ព្រោះតថាគតរង្កៀសកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត និងរង្កៀសដល់ធម៌ដែលជាបាបអកុសលទាំងពួង ។

ព្រាហ្មណ៍សួរថា បានឮគេថា **ព្រះសមណគោតមជាអ្នកកម្ចាត់** ព្រះអង្គត្រាស់ថា សេចក្ដីនេះពិត ព្រោះតថាគតសម្ដែងធម៌ដើម្បីកម្ចាត់ រាគៈ ទោសៈ មោហៈ សម្ដែងធម៌ដើម្បីកម្ចាត់បង់នូវធម៌ ដែលជាបាបអកុសលទាំងពួង ។

ព្រាហ្មណ៍សួរថា បានឮគេថា **ព្រះសមណគោតមជាអ្នកដុតបំផ្លាញ** ព្រះអង្គត្រាស់ថា សេចក្ដីនេះពិត ព្រោះតថាគតពោលធម៌ជាអកុសល គឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត គួរដុតបំផ្លាញ ព្រោះជាបាបអកុសល ។

ព្រាហ្មណ៍សួរថា បានឮគេថា **ព្រះសមណគោតមជាអ្នកមិនកើតទៀត** ព្រះអង្គត្រាស់ថា សេចក្ដីនេះពិត ព្រោះការដេកក្នុងគភ៌ ការកើតក្នុងភពថ្មី ដែល

អ្នកណាលះបង់បានហើយ កាត់ឫសគល់ដាច់ហើយ ធ្វើឱ្យដូចជាត្នោតកំបុតចុង ធ្វើឱ្យមិនមាន មិនឱ្យកើតតទៅទៀត តថាគតហៅអ្នកនោះថា ជាអ្នកមិនកើតទៀត

ប្រៀបដូចសំបកពង ៨ ពង ដែលមេមាន់ក្រាបល្អហើយ អប់ល្អហើយ កូនមាន់ណាទម្លាយសំបកពងចេញមកបានមុន យ៉ាងណាមិញ តថាគតស្ងប់ចាក អកុសលធម៌ បានសម្រេច **បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន** មិនមានកិលេស មិនញាប់ញ័រ បង្អោនចិត្តទៅដើម្បី **បុព្វេនិវាសានុស្សតិញ្ញាណ ចុតូបបាតញាណ អាសវក្ខយញ្ញាណ** កាលចិត្តរួចផុតហើយ កិច្ចដែលគួរធ្វើ តថាគតបានធ្វើស្រេចហើយ ដូចទម្លាយសំបកពងដូច្នោះ ។

កាលព្រះមានព្រះភាគត្រាស់ធម្មទោសនា ដល់នូវសេចក្ដីចម្រើនបំផុត ប្រសើរបំផុត ដោយការសម្រេចវិជ្ជា ៣ ដូចពោលហើយ វេរញ្ជព្រាហ្មណ៍កើត បីតិ ក្រាបទូលថា ព្រះគោតមជាអ្នកចម្រើនបំផុត ព្រះគោតមជាអ្នកប្រសើរ បំផុតក្នុងលោក ព្រះគោតមកើតមុនដោយអរិយជាតិ គឺជាការកើតដ៏ប្រសើរ ព្រោះមិនមានអ្នកប្រៀបផ្ទឹមដោយគុណទាំងពួង វេរញ្ជព្រាហ្មណ៍បានតិះដៀល ខ្លួនឯងថា ជាអ្នកពោលបង្អាច់អគ្គបុគ្គលក្នុងលោក ។

វេរញ្ជព្រាហ្មណ៍ បានក្រាបទូលពាក្យនេះជាមួយនឹងព្រះមានព្រះភាគថា ភាសិតរបស់ព្រះអង្គជាក់ច្បាស់ណាស់ ខ្ញុំព្រះអង្គសូមដល់ព្រះគោតម ព្រមទាំង ព្រះធម៌ និងព្រះភិក្ខុសង្ឃជាសរណៈ សូមព្រះអង្គទ្រង់ចាំខ្ញុំព្រះអង្គថា ជាឧបា-សកដល់នូវសរណៈស្មើដោយជីវិតតាំងពីថ្ងៃនេះតទៅ ។ វេរញ្ជព្រាហ្មណ៍ បាន

អារាធនាព្រះពុទ្ធអង្គ ព្រមទាំងភិក្ខុសង្ឃឱ្យចាំព្រះវស្សា ក្នុងដែនវេរញ្ជារហូតត្រៃមាស ក្នុងវេរញ្ជកណ្ឌវណ្ណនាពោលថា កាលព្រះសាស្តាទ្រង់ទទួលពាក្យអារាធនាហើយ វេរញ្ជព្រាហ្មណ៍ថ្វាយបង្គំហើយធ្វើប្រទក្សិណ ថ្វាយបង្គំដោយកាយ វាចា និងចិត្ត ច្រើនគ្រា ច្រើនដង ក៏នៅតែមិនឆ្អែតចិត្ត បានប្រណមដៃលើកឡើងទុកលើក្បាល ដើរថយក្រោយ ងាកមុខទៅរកព្រះមានព្រះភាគ រហូតផុតទស្សនវិស័យ ទើបគេចចេញទៅ ។

សម័យនោះ ដែនវេរញ្ជាកើតទុព្ភិក្ខភ័យ ប្រជាជនត្រូវអត់ឃ្លានព្រោះមិនមានអាហារបរិភោគ រហូតដល់សេចក្តីស្លាប់ជាច្រើន ភិក្ខុដែលចាំព្រះវស្សាចេញទៅបិណ្ឌបាតក៏មិនបានអាហារមកឡើយ គ្រានោះមានឈ្មួញសេះអ្នកស្រុកឧត្តរាបថៈ នាំសេះ ៥០០ ទៅលក់ក្នុងដែនផ្សេងៗ ធ្វើដំណើរឆ្លងកាត់មកដល់ស្រុកវេរញ្ជា មិនអាចធ្វើដំណើរទៅទៀតបាន ព្រោះជារដូវភ្លៀង ទើបបានឱ្យជាងសាងរោងសំណាក់សម្រាប់ពួកខ្លួន និងរោងសេះទុកក្នុងទីដែលទឹកជន់លិចមិនដល់ ក្រៅក្រុងវេរញ្ជា ។

ក្នុងវេលាព្រឹកពួកឈ្មួញសេះទាំងនោះ ចូលទៅក្នុងក្រុងដោយករណីយកិច្ចខ្លះ បានជួបភិក្ខុ ៧-៨ រូប បរិបូរណ៍ដោយឥរិយាបថ ត្រាច់បិណ្ឌបាតគ្រប់ច្រកល្ហកក៏មិនបានភត្តណាៗឡើយ រហូតអស់ ២-៣ ថ្ងៃ ទើបពួកឈ្មួញទាំងនោះបានគិតថា ព្រះមានព្រះភាគជាម្ចាស់ អាស្រ័យក្រុងនេះគង់ចាំព្រះវស្សា ឆាតកភ័យក៏កំពុងប្រព្រឹត្តទៅ ពួកយើងជាអាគន្តុកៈ រមែងមិនអាចត្រៀមអាហារប្រគេន

ភិក្ខុទាំងឡាយគ្រប់ថ្ងៃបាន យើងនឹងរំលែកបាយក្រៀមអំពីអាហាររបស់សេះប្រគេនដល់ភិក្ខុមួយរូបៗ ១ នាឡិ លោកម្ចាស់ទាំងឡាយនឹងមិនលំបាក ទាំងសេះក៏នឹងល្មមញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅបាន គិតដូច្នេះហើយ ទើបចូលទៅទូលដល់ភិក្ខុទាំងឡាយ ហើយរៀបចំត្រៀមបាយក្រៀមទុករាល់ថ្ងៃ ។

ភិក្ខុទាំងឡាយ បានអាស្រ័យនូវបាយក្រៀមដែលជាអាហាររបស់សេះដែលពួកឈ្មួញសេះរំលែកឱ្យមកបរិភោគ ដោយការកិនហើយយកទៅត្រាំទឹកឱ្យរីក ចែកគ្នាឆាន់រហូតត្រៃមាស បំពេញសមណធម៌ ក្នុងចំណែករបស់ព្រះសម្មុទ្ធ ពួកឈ្មួញសេះថ្វាយបាយក្រៀមមួយនាឡិៗ និងទឹកដោះថ្លា ទឹកឃ្មុំស្ករដុំ ដែលគួរដល់បាយក្រៀមនោះ ព្រះអានន្ទនាំបាយក្រៀម នោះមកបុកផ្សំដោយគ្រឿងផ្សំមានទឹកដោះថ្លាជាដើម ហើយបង្អោនទៅថ្វាយព្រះមានព្រះភាគសោយ ហើយក៏ទ្រង់ញ៉ាំងកាលឱ្យកន្លងទៅដោយផលសមាបត្តិ ។

ម្យ៉ាងទៀត វេរញ្ជព្រាហ្មណ៍ និងអ្នកស្រុកវេរញ្ជា ត្រូវមារបណ្ដាលចិត្តធ្វើឱ្យភ្លាំងភ្លេចថា បានអារាធនាឱ្យព្រះអង្គគង់ចាំព្រះវស្សា ក្នុងដែនរបស់ខ្លួន ព្រោះមារបានចងអាឃាតនឹងព្រះអង្គរហូតមក ព្រះអង្គទ្រង់ជ្រាបថា សូម្បីនឹងទៅគង់ចាំព្រះវស្សាក្នុងដែនណា ក៏នឹងត្រូវជួបហេតុការណ៍ដូច្នេះដែរ ចំណែកក្នុងដែនវេរញ្ជានេះព្រះអង្គទ្រង់ជ្រាបថា ពួកឈ្មួញសេះនឹងធ្វើការសង្គ្រោះពួកភិក្ខុទាំងឡាយ ទើបយាងមកចាំព្រះវស្សាទីនេះ ។

ម្យ៉ាងទៀត ព្រោះវិបាកកម្មរបស់ព្រះអង្គដែលនៅសេសសល់ តាំងពី

សម័យព្រះពុទ្ធជាម្ចាស់ព្រះនាមថា ផុស្សៈតាមមកឱ្យផល គ្រានោះដោយភាពជាបុគ្គលអន្ធពាល ព្រះអង្គបានជេរបណ្ដាព្រះសាវ័ករបស់ព្រះពុទ្ធផុស្សៈ ដែលឆាន់ភោជនាហារប្រណីតថា ពួកសមណៈត្រងោល លោកចូរស៊ីបាយក្រៀមតែម្យ៉ាងចុះ កុំស៊ីអាហារដែលមានរសដ៏ប្រណីតឡើយ ទើបព្រះអង្គត្រូវសោយតែបាយក្រៀមរហូតអស់ ៣ ខែ ដូច្នេះឯង ។

(២) គ្រាមួយ ខណៈដែលព្រះអង្គទ្រង់គង់ទៀបគល់ស្ដៅ ត្រង់នឡេរុយក្ខស្ថិតនៅជិតក្រុងវេរញ្ជា **ស្ដេចអសុរបហារាធៈ** ចូលទៅគាល់ដល់ទីប្រថាប់ ព្រះអង្គត្រាស់សួរថា ពួកអសុររមែងរីករាយក្នុងមហាសមុទ្រខ្លះឬ ? បហារាធៈក្រាបទូលថា ក្នុងមហាសមុទ្រ មានធម៌ដែលគួរអស្ចារ្យ ៨ យ៉ាង ដែលពួកអសុរឃើញហើយរមែងរីករាយក្រៃលែង , កាលបហារាធៈទូលដល់វត្ថុដែលគួររីករាយ ៨ យ៉ាងរបស់អសុរហើយ សួរព្រះអង្គថា តើក្នុងធម្មវិន័យនេះមានធម៌ដែលគួរអស្ចារ្យមិនធ្លាប់មានមកពីមុន ដែលភិក្ខុទាំងឡាយឃើញហើយរីករាយក្រៃលែងដែរឬ ? ទើបព្រះអង្គត្រាស់ធម៌ ៨ ប្រការ ដែលគួររីករាយរបស់ភិក្ខុថា :

១. ក្នុងធម្មវិន័យនេះ **មានការសិក្សា** ប្រព្រឹត្តទៅតាមលំដាប់ **មានការបដិបត្តិ** តាមលំដាប់ មិនមែនមានការត្រាស់ដឹងនូវព្រះអរហត្តដោយត្រង់តែម្ដងទេ ។

២. ក្នុងធម្មវិន័យនេះ **សាវ័កមិនប្រព្រឹត្តកន្លងសិក្ខាបទ** ដែលបញ្ញត្តទុក

សូម្បីព្រោះហេតុនៃជីវិត ។

៣. ក្នុងធម្មវិន័យនេះ **សង្ឃរមែងមិននៅរួមជាមួយបុគ្គលទ្រុស្តសីល** មានសមាចារគួររង្កៀស បិទបាំងកម្មអាក្រក់ ព្រោះមិនមែនជាសមណៈប្តេជ្ញាថាជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ តែប្តេជ្ញាថាជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ សង្ឃនឹងប្រជុំគ្នាលើកវត្តលោកភ្លាម **សូម្បីអង្គុយក្នុងកណ្តាលសង្ឃក៏ឈ្មោះថានៅឆ្ងាយពីសង្ឃ** ។

៤. បុគ្គលអ្នកចេញបួសជាបព្វជិត រមែងលះនាម និងគោត្រដើម មិនថាជាក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ **ធម្មវិន័យនេះរាប់ថាជាសមណសក្យបុត្តស្មើគ្នាទាំងអស់** ។

៥. សូម្បីភិក្ខុជាច្រើន នឹងបរិនិព្វានដោយសឧបាទិសេសនិព្វាន ឬអនុបាទិសេសនិព្វាន **និព្វានធាតុក៏មិនបានប្រាកដថា នឹងខ្វះឬពេញដោយពួកភិក្ខុនោះឡើយ** ។

៦. ធម្មវិន័យមានរសតែមួយ គឺ **វិមុត្តិរស** ។

៧. ក្នុងធម្មវិន័យនេះ មានរតនៈច្រើនយ៉ាង គឺ **សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ៍ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨** ។

៨. ធម្មវិន័យនេះ ជាទីស្នាក់អាស្រ័យរបស់បុគ្គលពួកនេះ គឺ

**ព្រះសោតាបន្ន** អ្នកបដិបត្តិដើម្បីធ្វើឱ្យច្បាស់នូវ **សោតាបត្តិផល**

**ព្រះសកទាគាមី** អ្នកបដិបត្តិដើម្បីធ្វើឱ្យច្បាស់នូវ **សកទាគាមិផល**

**ព្រះអនាគាមី** អ្នកបដិបត្តិដើម្បីធ្វើឱ្យច្បាស់នូវ **អនាគាមិផល**

**ព្រះអរហន្ត** អ្នកបដិបត្តិដើម្បីធ្វើឱ្យច្បាស់នូវ **អរហត្តផល**

ម្នាលបហារាធៈ ក្នុងធម្មវិន័យនេះ មានធមិដែលគួរអស្ចារ្យ មិនធ្លាប់មានមក ៨ ប្រការនេះ ដែលភិក្ខុឃើញហើយ ទើបរីករាយក្រៃលែង ។ ក្នុងអដ្ឋកថាពោលថា រាប់ពីថ្ងៃដែលព្រះសាស្តាត្រាស់ដឹងហើយ ស្តេចអសុរបហារាធៈគិតថា ថ្ងៃនេះយើងនឹងទៅគាល់ ព្រឹកនេះយើងនឹងទៅគាល់ រហូតកន្លងទៅ ១១ ឆ្នាំ លុះដល់ឆ្នាំទី ១២ ក្នុងវេលាដែលព្រះសាស្តាមកប្រថាប់គង់ក្នុងដែនវេរញ្ជា គិតបំណងថា នឹងទៅគាល់ដើម្បីសួរបញ្ហានឹងព្រះតថាគត ហើយស្តាប់ធម្មិកថា បហារាធៈគិតថាយើងចាំពេលនេះពេលនោះ រហូតវេលាកន្លងទៅដល់ ១២ ឆ្នាំហើយ យើងនឹងទៅឥឡូវនេះឯង ទើបចេញចាកភពអសុរព្រមដោយពួកអសុរហែហមចូលទៅគាល់ព្រះសាស្តា ។

( ៣ ) ក្នុងព្រះវស្សានេះ ព្រះពុទ្ធអង្គត្រាស់ដល់រឿងហេតុដែលធ្វើឱ្យព្រះពុទ្ធសាសនាតាំងនៅបានយូរ និងមិនយូរ ក្នុងសម័យព្រះពុទ្ធជាម្ចាស់ព្រះអង្គមុនៗ សេចក្តីសង្ខេបថា ពួកសាវ័កក្មេងទាន់ឃើញព្រះសាស្តា នៅទ្រង់ព្រះជន្មនៅឡើយ ម្នាក់ៗក៏ចេញបួសដោយសទ្ធាពិតៗ ទើបនាំគ្នាតាំងព្រះធមិវិន័យរបស់ព្រះពុទ្ធអង្គទុកក្នុងបែបផែនតែមួយ តែសាវ័កថ្មីតមក ដែលបួសក្រោយពីព្រះសាស្តាបរិនិព្វានហើយ នាំគ្នាប្រព្រឹត្តធូរលុងក្នុងធម្មវិន័យ ជាហេតុឱ្យព្រះសាសនាអន្តរធានទៅដោយឆាប់រហ័ស ទើបសាសនាតាំងនៅមិនបានយូរ ។

ព្រះសារីបុត្តបានស្តាប់ដូច្នោះហើយ ទើបក្រាបទូលសូមឱ្យព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទដល់ភិក្ខុសង្ឃ ព្រះអង្គទ្រង់បដិសេធត្រាស់ថា ម្នាលសារីបុត្តចូររង់ចាំសិន ខណៈនេះនៅមិនមែនជាកាលបញ្ញត្តិសិក្ខាបទទេ ព្រោះបណ្តាសាវ័កក្នុងពេលនេះ យ៉ាងហោចក៏ជាអរិយបុគ្គលថ្នាក់សោតាបន្ន រមែងមានការមិនធ្លាក់ចុះជាធម្មតា ជាអ្នកដែលនឹងត្រាស់ដឹងតទៅក្នុងខាងមុខ ។ ព្រះមានព្រះ-ភាគជាម្ចាស់ ទ្រង់ឱ្យហេតុផលដល់ព្រះធម្មសេនាបតីសារីបុត្តដូច្នេះ លុះក្នុងថ្ងៃមហាបវារណា ព្រះអង្គមានព្រះបំណងនឹងយាងចារិកទៅកាន់ក្រុងវេសាលី ។

## ក្រោយអំពីចេញព្រះវស្សាទី ១២ ហើយ

(៤) ព្រះសាស្តាទ្រង់ព្រះតម្រិះថា ការដែលតថាគតនឹងចេញធ្វើដំណើរតទៅដោយមិនលាអ្នកដែលនិមន្តតថាគតទុកនោះ ជាការមិនសមគួរ ទើបយាងទៅកាន់និវេសន៍របស់វេរញ្ជព្រាហ្មណ៍ ដើម្បីប្រាប់សេចក្តីបំណងដែលនឹងយាងទៅកាន់ក្រុងវេសាលី។ ចំណែកវេរញ្ជព្រាហ្មណ៍នោះ ការបណ្តាលចិត្តរបស់មារបាត់ទៅក្នុងថ្ងៃបវារណា រឭកឡើងបានថា ខ្លួនឯងបាននិមន្តឱ្យព្រះពុទ្ធអង្គ និងពួកភិក្ខុសង្ឃចាំវស្សាក្នុងទីនេះ តែមិនធ្លាប់បានថ្វាយទេយ្យធម៌រហូត ៣ ខែ ។

វេរញ្ជព្រាហ្មណ៍ ទើបចូលទៅថ្វាយបង្គំក្រាបទូលសូមឱ្យទ្រង់អត់ទោសដោយហេតុផលថាយភាវាសមានកិច្ចច្រើន មានការរវល់ច្រើន ហើយទូលអារា-ធនាដើម្បីសោយភត្តាហារក្នុងថ្ងៃស្អែក ព្រះមានព្រះភាគទ្រង់ទទួលពាក្យអារា-

ធនាហើយ ត្រាស់ដាស់តឿនវេរញ្ជព្រាហ្មណ៍ថា មិនគួរកង្វល់តែការគ្រប់គ្រងផ្ទះទេ ទ្រង់ចង្អុលបង្ហាញឱ្យឃើញប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍លោកខាងមុខ ឱ្យមានឧស្សាហ៍ក្នុងកុសលធម៌ តាមដែលខ្លួនសមាទាននោះ ហើយទ្រង់លួងលោមវេរញ្ជព្រាហ្មណ៍ឱ្យរីករាយដោយធម្មីកថា ។

( ៥ ) ក្នុងថ្ងៃស្អែកឡើង វេរញ្ជព្រាហ្មណ៍ព្រមទាំងបុត្រ និងភរិយាថ្វាយមហាទានចំពោះព្រះសាស្ដា និងភិក្ខុសង្ឃ ក្រោយភត្តកិច្ចព្រាហ្មណ៍បានថ្វាយត្រៃចីវរ សំពត់សាច់ដ៏ល្អចំពោះព្រះមានព្រះភាគ និងថ្វាយសំពត់សាដកដល់ភិក្ខុ ៥០០ រូប ព្រមដោយបរិក្ខារគ្រប់យ៉ាងដែលគួរដល់សមណៈគ្រប់រូប ។

ព្រះពុទ្ធអង្គទ្រង់អនុមោទនាហើយ យាងចេញចាកដែនវេរញ្ជាទៅកាន់ក្រុងវេសាលីប្រើផ្លូវត្រង់ ឆ្លងកាត់ដែនផ្សេងៗដោយមិនបានគេចវាង ពីព្រោះព្រះអង្គទ្រង់ជ្រាបថាភិក្ខុទាំងឡាយនៅខ្សោយកម្លាំង ដោយសារឆាន់ត្រឹមតែបាយក្រៀមរហូតមួយព្រះវស្សា ទ្រង់ឆ្លងស្ទឹងគង្គាតាមកំពង់ក្រុង **បយាគៈ** ។

# ផែនទីក្រោយចេញព្រះវស្សា

( ៦ ) ខណៈដែលឆ្លងកាត់ ក្រុងពារាណសី ព្រះអង្គគេចទៅគង់នៅត្រង់ដើមឈើ..... ទ្រង់ប្រារព្ធស្តេចនាគឈ្មោះ **ឯរកបត្ត** ដល់ភិក្ខុទាំងឡាយថា ក្នុងសាសនារបស់ព្រះកស្សបសម្មាសម្ពុទ្ធ ក្នុងកាលមុនស្តេចនាគនេះជាភិក្ខុកម្លោះ ចុះទូកទៅក្នុងស្ទឹងគង្គា ចាប់គុម្ពវៃទឹកមួយគុម្ពទុក កាលទូករត់ទៅដោយរហ័សក៏មិនលែង ស្លឹកវៃទឹកដាច់ទៅហើយ ភិក្ខុកម្លោះនោះមិនសម្តែងអាបត្តិ ដោយគិតថានេះជាអាបត្តិតូចតាច ក្នុងកាលមរណភាព និមិត្តប្រាកដដូចស្លឹកវៃទឹកមកខ្ទាស់បំពង់ក សូម្បីប្រាថ្នានឹងសម្តែងអាបត្តិក៏មិនឃើញភិក្ខុដទៃ កើតសេចក្តីក្តៅក្រហាយថាសីលរបស់យើងមិនបរិសុទ្ធ ចុតិចាកអត្តភាពរបស់ភិក្ខុកម្លោះ កើតជាស្តេចនាគឈ្មោះ **ឯរកបត្ត** ។ ស្តេចនាគនោះ សម្លឹងមើលអត្តភាពខ្លួនឯងហើយរន្ធត់ចិត្តថា យើងធ្វើសមណធម៌រហូតពីរម៉ឺនឆ្នាំ ត្រឡប់មកកើតក្នុងកំណើតអហេតុកសត្វ ដែលមានកង្កែបជាអាហារ កាលតមក ស្តេចនាគបានធីតាម្នាក់ទើបបើកពពារធំដាក់ធីតាទុកលើពពារ ឱ្យធីតានោះរាំច្រៀងនៅកណ្តាលស្ទឹងគង្គា ដោយបទចម្រៀងដែលទាក់ទងនឹងធម៌ ដូចជា :

**អ្នកជាធំដូចម្តេច ឈ្មោះថា ព្រះរាជា**
**ព្រះរាជាដូចម្តេច ឈ្មោះថា មានធុលីលើក្បាល**
**បុគ្គលដូចម្តេច ឈ្មោះថា ប្រាសចាកធុលី ជាដើម ។**

យ៉ាងនេះ ជាឧបាយដើម្បីស្តាប់ដំណឹងការត្រាស់ដឹងឡើងរបស់ព្រះពុទ្ធជាម្ចាស់ រហូតវេលាកន្លងទៅមួយចន្លោះព្រះពុទ្ធ ។ សម័យនោះ កាលព្រះសាស្តា

កើតឡើងហើយក្នុងលោក ទ្រង់ជ្រាបក្នុងបណ្តាញញាណថា **ឧត្តរមាណព** រៀនយកបទចម្រៀងសម្រាប់ឆ្លើយដែលព្រះអង្គទ្រង់បង្រៀនហើយ នឹងបានជាសោតាបន្ន នាគរាជកាលដឹងថាព្រះពុទ្ធជាម្ចាស់ទ្រង់ឧប្បត្តិឡើងហើយ នឹងមកកាន់សំណាក់របស់តថាគត កាលនាគរាជមកហើយ តថាគតនឹងសម្តែងធម៌ក្នុងសមាគមធំ សត្វចំនួនច្រើននឹងត្រាស់ដឹងនូវធម៌ ។

ទើបព្រះពុទ្ធអង្គស្តេចគេចចុះ ប្រថាប់គង់ក្បែរដើមឈើ..........មួយដើមដែលមិនឆ្ងាយអំពីក្រុងពារាណសី ឧត្តរមាណពបានរៀនបទចម្រៀងសម្រាប់ឆ្លើយអំពីព្រះសាស្តាហើយ ច្រៀងឆ្លើយតបនាងនាគមាណវិកា ដែលឈររាំនៅលើពពាររបស់បិតាថា :

**អ្នកដែលជាធំក្នុងទ្វារ ៦ ឈ្មោះថា ជាព្រះរាជា**
**ព្រះរាជាអ្នកមានរាគៈ ឈ្មោះថា មានធុលីលើក្បាល**
**អ្នកប្រាសចាកតម្រេក ឈ្មោះថា ប្រាសចាកធុលី ជាដើម ។**

ស្តេចនាគរាជស្តាប់បទចម្រៀងនោះហើយ ក៏ជ្រាបថាព្រះពុទ្ធជាម្ចាស់កើតឡើងហើយក្នុងលោក ព្រោះមិនធ្លាប់ស្តាប់បទធម៌នេះមកអស់មួយចន្លោះព្រះពុទ្ធ សប្បាយចិត្តយកកន្ទុយវាយទឹកកើតជារលកធំ ច្រាំងទាំងពីរបាក់ចុះនាគរាជលើកមហាជនទាំងនោះដាក់លើពពារចូលទៅសួរឧត្តរមាណពថា **ព្រះពុទ្ធជាម្ចាស់នៅទីណា ?**

ស្តេចនាគនាំមហាជនទាំងនោះទៅគាល់ ថ្វាយបង្គំព្រះសាស្តាហើយស្រែក

យំរៀបរាប់ថា ខ្ញុំព្រះអង្គបានបំពេញសមណធម៌អស់ពីរម៉ឺនឆ្នាំ ខ្ញុំព្រះអង្គធ្វើស្លឹករៃទឹកឱ្យដាច់ត្រឹមតែបន្តិច ត្រឡប់កាន់បដិសន្ធិក្នុងអហេតុកសត្វ កើតក្នុងទីដែលត្រូវលូនទៅដោយទ្រូង មិនបានភាពជាមនុស្ស មិនបានស្តាប់ព្រះធម៌ មិនបានឃើញព្រះពុទ្ធរហូតមួយពុទ្ធន្តរ ។

ព្រះសាស្តាទ្រង់ស្តាប់ពាក្យពេចន៍របស់នាគរាជនោះហើយ ត្រាស់ថា :

**ការបានអត្តភាពជាមនុស្ស ជាការក្រ**

**ជីវិតតរបស់សត្វទាំងឡាយ រស់នៅបានដោយកម្រ**

**ការបានស្តាប់ព្រះសទ្ធម្ម ជារបស់កម្រ**

**ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាការក្រក្រៃលែង ។**

ក្នុងកាលចប់ទេសនា ជនទាំងឡាយបានត្រាស់ដឹងធម៌ជាច្រើន ឧត្តរ-មាណពសម្រេចសោតាបត្តិផល ក្នុងខណៈដែលកំពុងរៀនបទចម្រៀងអំពីព្រះសាស្តា ស្តេចនាគសូម្បីគួរនឹងតាំងនៅក្នុងសោតាបត្តិផលក្នុងថ្ងៃនោះក៏ពិតមែន តែក៏មិនអាចត្រាស់ដឹងបាន ព្រោះខ្លួនជាសត្វតិរច្ឆាន ។

( ៧ ) ព្រះមានព្រះភាគ យាងចេញចាកពារាណសីទៅកាន់ **ក្រុងវេសា-លី** ខណៈដែលទ្រង់គង់នៅ ក្នុងគោដាគារសាលា ព្រៃមហាវ៉ន **ព្រះមហាបជាបតិគោតមីថេរី** ព្រមទាំងពួកភិក្ខុនីសាកិយានី ដែលស្នាក់នៅក្នុងសំណាក់ភិក្ខុនីក្រុងវេសាលី ចូលទៅគាល់ព្រះពុទ្ធអង្គ ដើម្បីទូលលាបរិនិព្វាន ក្រាបទូលថា :

**បពិត្រព្រះសុគត ខ្ញុំម្ចាស់ជាព្រះមាតារបស់ព្រះអង្គ**

បពិត្រព្រះធីរៈ ព្រះអង្គជាព្រះបិតារបស់ខ្ញុំម្ចាស់
បពិត្រព្រះលោកនាថ ព្រះអង្គជាអ្នកប្រទានព្រះសទ្ធម្មដល់ខ្ញុំម្ចាស់
បពិត្រព្រះគោតម ខ្ញុំព្រះអង្គដែលព្រះអង្គឱ្យឆ្លងសាគរគឺភពហើយ
បពិត្រព្រះឱរស ខ្ញុំម្ចាស់ប្រាថ្នានឹងចោលរាងកាយនេះដើម្បីបរិនិព្វាន
បពិត្រព្រះមហាវីរៈ សូមព្រះអង្គទ្រង់ប្រោសអនុញ្ញាតដល់ខ្ញុំម្ចាស់ចុះ

ព្រះមហាបជាបតិគោតមីថេរី បានឱនព្រះសិរសាចុះទៀបព្រះបាទាក្រាបទូលថា ខ្ញុំម្ចាស់សូមនមស្ការ ខ្ញុំម្ចាស់នឹងមរណៈគ្រាចុងក្រោយបំផុត ខ្ញុំម្ចាស់នឹងមិនបានឃើញព្រះអង្គទៀត ប្រសិនបើទោសណាៗ របស់ខ្ញុំម្ចាស់មាន សូមព្រះអង្គទ្រង់ករុណាប្រោសអត់ទោសនោះដល់ខ្ញុំម្ចាស់ផងចុះ ។

លំដាប់នោះ ព្រះមហាបជាបតិគោតមីថេរី ប្រកាសក្នុងពួកសង្ឃហើយថ្វាយបង្គំព្រះរាហុល ព្រះអានន្ទ និងព្រះនន្ទ ត្រាស់ថា កូនអើយ ! ម៉ែនឿយណាយក្នុងរាងកាយ ដែលស្មើដោយទីនៅរបស់អសិរពិស ជាសំបុកនៃរោគ ជាផ្ទះរបស់ទុក្ខ ជាទីគោចររបស់ជរា និងមរណៈ ដេរដាសដោយមន្ទិលផ្សេងៗ ប្រាសចាកខ្លឹមសារ ទើបម៉ែប្រាថ្នានឹងបរិនិព្វាន ។

ព្រះពុទ្ធអង្គត្រាស់ថា ម្នាលគោតមី មនុស្សពាលពួកណា សង្ស័យក្នុងការត្រាស់ដឹងធម៌របស់សត្វទាំងឡាយ នាងចូរសម្ដែងឥទ្ធិឫទ្ធិដើម្បីឱ្យមនុស្សពាលទាំងនោះលះបង់ទិដ្ឋិចោល ។

ព្រះមហាបជាបតិគោតមី ព្រមដោយភិក្ខុនីទាំងអស់ ថ្វាយបង្គំហើយ

បានសម្តែងបាដិហារិយ៍ ដ៏វិចិត្រច្រើនយ៉ាងតាមព្រះពុទ្ធានុញ្ញាត ហើយនាំគ្នាចុះចាកនភាកាស ក្រាបចុះទៀបព្រះយុគលបាទរបស់ព្រះសាស្តា ក្រាបទូលថា នេះជាការថ្វាយបង្គំគ្រាចុងក្រោយរបស់ខ្ញុំម្ចាស់ ហើយត្រាស់នឹងព្រះនន្ទត្ថេរ ព្រះរាហុល និងព្រះអានន្ទថា **កូនចូររក្សាព្រះពុទ្ធសាសនាទុក ម៉ែឃើញកូនគ្រានេះ ជាគ្រាចុងក្រោយ** ហើយត្រឡប់ទៅកាន់សំណាក់ភិក្ខុនី ដើម្បីបរិនិព្វាន ។

ព្រះសាស្តាព្រមដោយពួកជនជាច្រើន បានយាងជូនដំណើរព្រះមាតុច្ឆារហូតដល់ក្លោងទ្វារ គ្រានោះបានកម្រើកផែនដីដ៏ធំអស្ចារ្យ ពួកទេវតានាំគ្នាទួញយំ ភ្លៀងផ្កាឈើធ្លាក់ចុះមកអំពីអាកាស ស្តេចភ្នំសិនេរុបានលាន់ឮ កម្រើកញាប់ញ័រ មហាសាគរក៏កម្រើករញ្ជួយ ។

ព្រះពុទ្ធអង្គត្រាស់បញ្ជាព្រះអានន្ទ ឱ្យប្រកាសដល់ពួកភិក្ខុ ឱ្យជ្រាបនូវការបរិនិព្វានរបស់ព្រះថេរី ពួកភិក្ខុសង្ឃក៏មកប្រជុំគ្នាដើម្បីថ្វាយព្រះភ្លើង ក្រោយពីការថ្វាយព្រះភ្លើង ព្រះអានន្ទ បាននាំព្រះអដ្ឋិធាតុរបស់ព្រះមហាបជាបតិ-គោតមីថេរី ដាក់ចុះក្នុងបាត្ររបស់ព្រះថេរី នាំមកថ្វាយព្រះសម្ពុទ្ធ ព្រះអង្គទ្រង់ដាក់ព្រះធាតុទុកក្នុងព្រះហស្ថ ត្រាស់ថា **សង្ខារមានសភាពមិនទៀង** សូម្បីគោតមីជាធំជាងភិក្ខុនីទាំងពួង ក៏នៅត្រូវបរិនិព្វាន ប្រៀបដូចដើមឈើ សូម្បីធំប៉ុនណាក៏ត្រូវមានកាលពុកផុយទៅ ព្រះពុទ្ធអង្គត្រាស់បញ្ជាឱ្យ **តម្កល់ព្រះអដ្ឋិធាតុរបស់ព្រះនាងមហាបជាបតិគោតមីថេរី ទុកក្នុងទីថ្វាយព្រះភ្លើងនោះ ។**

( ៨ ) ខណៈដែលព្រះសាស្តាប្រថាប់គង់នៅ ក្នុងគោជាគារសាលា **ឧគ្គ-**

**គហបតី** អ្នកក្រុងវេសាលី ចូលទៅទូលសួរព្រះពុទ្ធអង្គថា ខ្ញុំព្រះអង្គបានស្តាប់មកចំពោះព្រះភក្ត្រថា អ្នកឱ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្ត ដូច្នោះខ្ញុំព្រះអង្គសូមថ្វាយបាយនៃស្រូវសាលីដ៏សស្អាត ព្រមដោយខាទនីយាហារមានរសដ៏ប្រណីត សំពត់យ៉ាងល្អធ្វើក្នុងដែនកាសី គ្រែធ្វើដោយឈើចន្ទន៍ជាដើម ជារបស់ដែលខ្ញុំព្រះអង្គពេញចិត្តគ្រប់យ៉ាង សូមព្រះមានព្រះភាគជាម្ចាស់ទ្រង់អនុគ្រោះដល់ខ្ញុំព្រះអង្គផងចុះ ។ ព្រះសាស្តាទ្រង់ទទួល ហើយអនុមោទនាឧគ្គគហបតីតាំងនៅក្នុងសោតាបត្តិផល ដោយការចូលគាល់ព្រះអង្គលើកទី ១ តមកបានធ្វើឱ្យច្បាស់នូវមគ្គ និងផល ៣ ព្រះអង្គទ្រង់សរសើរថា ឧគ្គគហបតីជាកំពូលជាងឧបាសកទាំងពួង អ្នកថ្វាយទេយ្យធម៌ដែលខ្លួនគាប់ចិត្ត។

បន្ទាប់មកមិនយូរ ឧគ្គគហបតីបានធ្វើមរណកាលបដិសន្ធិហើយក្នុងពួកទេពឈ្មោះ **មោនេយ្យៈ** តមកក្នុងសម័យដែលព្រះសម្ពុទ្ធយាងទៅគង់នៅវត្តជេតពន បឋមយាមកន្លងទៅហើយ **ឧគ្គទេវបុត្ត** មានវណ្ណៈភ្លឺរុងរឿងចូលមកគាល់ព្រះអង្គ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនវត្ថុដែលខ្ញុំព្រះអង្គប្រាថ្នានោះសម្រេចហើយព្រះអង្គ ទើបព្រះមានព្រះភាគត្រាស់ព្រះគាថាថា :

**អ្នកឱ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្ត**
**អ្នកឱ្យរបស់ដ៏លើស រមែងបានរបស់ដ៏លើស**
**អ្នកឱ្យរបស់ល្អ រមែងបានរបស់ល្អ**
**អ្នកឱ្យទីឋានដ៏ប្រសើរ រមែងចូលដល់ទីស្ថានដ៏ប្រសើរ**

**នរជនណាឱ្យរបស់ដ៏លើស ឱ្យរបស់ដ៏ល្អនិងឱ្យ**
**ទីស្ថានដ៏ប្រសើរ នរជននោះកើតក្នុងទីណាៗ**
**រមែងមានអាយុវែង មានយសក្នុងទីនោះៗ**

(៩) លុះយាងត្រឡប់មកក្រុងសាវត្ថីហើយ ខណៈដែលគង់នៅវត្តជេតពន ព្រឹកថ្ងៃមួយព្រះមានព្រះភាគយាងចេញបិណ្ឌបាត ក្នុងក្រុងសាវត្ថី សាមណេររាហុលកាន់បាត្រដើរតាមព្រះមានព្រះភាគ ទៅខាងក្រោយព្រះអង្គ ព្រះអង្គទ្រង់បែរព្រះភក្ត្រទៅត្រាស់នឹងសាមណេរថា ម្នាលរាហុល រូបណាមួយជាអតីតៈ អនាគត និងបច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ប្រណីតក្តី នៅក្នុងទីឆ្ងាយក្តី ទីជិតក្តី រូបទាំងពួងនេះ អ្នកគប្បីឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា នោះមិនមែនជារបស់យើង នោះមិនមែនជាយើង នោះមិនមែនជាតួខ្លួនរបស់យើង ។ សាមណេររាហុលទូលសួរថា បពិត្រព្រះសុគត រូបប៉ុណ្ណោះឬ ព្រះអង្គ ?

ព្រះមានព្រះភាគត្រាស់ថា ទាំងរូប ទាំងវេទនា ទាំងសញ្ញា ទាំងសង្ខារ ទាំងវិញ្ញាណ អ្នកចូរអប់រំចិត្ត ឱ្យដូចជាផែនដី ទឹក ភ្លើង ខ្យល់ និងអាកាសចុះ កាលអ្នកចម្រើនភាវនា ដែលស្មើដោយធាតុទាំង ៥ នោះ ផស្សៈដែលជាទីគាប់ចិត្ត និងមិនជាទីគាប់ចិត្តកើតឡើងហើយ នឹងមិនគ្របសង្កត់ចិត្តអ្នកបានឡើយ ។

អ្នកចូរភាវនាធម៌ ៦ យ៉ាងទៀតគឺ ចម្រើន **មេត្តាភាវនា** ដើម្បីលះព្យាបាទ ចម្រើន **ករុណាភាវនា** ដើម្បីលះវិហឹង្សា (ការបៀតបៀន) ចម្រើន

**មុទិតាភាវនា** ដើម្បីលះអរតិ (ការច្រណែន) ចម្រើន **ឧបេក្ខាភាវនា** ដើម្បីលះបដិឃៈ (សេចក្តីក្រោធ) ចម្រើន **អសុភភាវនា** ដើម្បីលះរាគៈ ចម្រើន **អនិច្ចសញ្ញា** ដើម្បីលះអស្មិមានះ (ការប្រកាន់ខ្លួន) ។

សាមណេររាហុលគិតថា ថ្ងៃនេះព្រះមានព្រះភាគទ្រង់ប្រទានឱវាទដូច្នេះ ទ្រង់ដាស់តឿនយ៉ាងនេះ អ្នកមានជាតិជាបណ្ឌិតមិនគួរធ្វើកិច្ចដទៃទៀត ទើបលោកត្រឡប់ពីទីនោះមិនទៅបិណ្ឌបាត ចូលទៅអង្គុយទ្បេបគល់ឈើមួយដើម ព្រះអង្គសូម្បីទ្រង់ឃើញរាហុលត្រឡប់ ក៏មិនបានឃាត់ព្រោះទ្រង់ព្រះតម្រិះថា ថ្ងៃនេះរាហុលចូរបរិភោគអមតភោជន គឺ **កាយគតាសតិ** ចុះ ។

ព្រះសារីបុត្ត មិនចេញបិណ្ឌបាតពីព្រឹកដូចភិក្ខុដទៃ កាលភិក្ខុទាំងពួងទៅហើយ ក៏ដើរត្រួតមើលតាមលំដាប់ទូទាំងសង្ឃារាម បោសទីដែលមិនបានបោស ចោលសម្រាមដែលនៅមិនទាន់បានចោល រក្សាគ្រឿងប្រើប្រាស់ដែលរក្សាទុកមិនរៀបរយក្នុងសង្ឃារាម ព្រោះក្រែងតិរ្ថិយ៍ឃើញនឹងតិះដៀលបានថា សាវ័ករបស់ព្រះសមណគោតមជាអ្នកមិនមានរបៀប ក្រៅពីនោះទៅមើលថែភិក្ខុអាពាធ សួរសេចក្តីត្រូវការរបស់ភិក្ខុអាពាធ ស្វែងរកភេសជ្ជៈ កាលឱ្យភេសជ្ជៈហើយ ក៏ឱ្យឱវាទដាស់តឿនភិក្ខុថា ពួកលោកកុំជាអ្នកប្រមាទស្រេចហើយខ្លួនឯង ទើបចេញបិណ្ឌបាត ឬធ្វើភត្តកិច្ចក្នុងត្រកូលឧបដ្ឋាក ហើយទើបទៅកាន់វិហារ ព្រះសារីបុត្តបដិបត្តិដូច្នេះជានិច្ច ។ ថ្ងៃនោះ កាលព្រះសារីបុត្តចេញបិណ្ឌបាត បានឃើញព្រះរាហុលអង្គុយស្ងឹងស្ងាធទ្បេបគល់ឈើមួយដើម ទើបពោលណែនាំឱ្យព្រះរា-

ហុលចម្រើនអានាបានស្សតិ ដោយបំណងថា អានាបានស្សតិភាវនាដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ដោយមិនបានគិតថា ព្រះពុទ្ធអង្គទ្រង់ប្រទានរូបកម្មដ្ឋានទុកមុន ទើបណែនាំសាមណេររាហុលក្នុងអានាបានស្សតិ ចម្រើនវិបស្សនាដើម្បីព្រះអរហត្តផល ។ រឿងនេះ ព្រោះព្រះមានព្រះភាគទ្រង់ជ្រាបថា ឆន្ទរាគៈកើតឡើងដល់រាហុលព្រោះអាស្រ័យអត្តភាព គឺគិតថា យើងល្អ ពណ៌សម្បុររបស់យើងផូរផង់ រាហុលកំពុងរត់ចេញទៅក្រៅផ្លូវ ត្រាច់ទៅកាន់ទិសដែលមិនគួរទៅ ដូចមនុស្សធ្វើដំណើរវង្វេងទិស ទើបសម្តែង **មហារាហុលោវាទសូត្រ** ។

សាមណេររាហុល មនសិការកម្មដ្ឋានដែលព្រះមានព្រះភាគត្រាស់ ទាំងក្នុងវេលាមុនភត្ត និងខាងក្រោយភត្តថា **រូបមិនទៀងយ៉ាងនេះ ជាទុក្ខយ៉ាងនេះ ជាអនត្តាយ៉ាងនេះ** ជាដើម ។

ក្នុងវេលារសៀល សាមណេររាហុលគិតថា ព្រះឧបជ្ឈាយ៍ប្រាប់យើងឱ្យចម្រើន អានាបានស្សតិ កាលមិនជឿស្តាប់ និងធ្វើតាមពាក្យរបស់អាចារ្យ មិនសមគួរដល់យើង ទើបចម្រើនអានាបានស្សតិកម្មដ្ឋានមួយទៀតផង សាមណេររាហុលចូលទៅគាល់ព្រះសាស្តា ដើម្បីទូលសួរវិធីចម្រើនអានាបានស្សតិ សេចក្តីលម្អិតរបស់កម្មដ្ឋានភាវនា ព្រមដោយអានិសង្សកថា លោកពោលទុកហើយក្នុងអនុស្សតិនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

(១០) **អឌ្ឍកាសី** ធីតាសេដ្ឋីក្នុងក្រុងពារាណសីចម្រើនវ័យហើយ មាន

ឋានៈធ្លាក់ចុះ ក្លាយជាស្រីពេស្យាក្នុងក្រុងរាជគ្រឹះ ព្រោះផលនៃវិចិទុច្ចរិតក្នុងអតីតជាតិ នាងបានស្តាប់ធម៌ដែលព្រះពុទ្ធអង្គសម្តែង កើតការនឿយណាយក្នុងរូប ឃើញថារូបមិនទៀង រូបនេះជាទុក្ខ រូបនេះមិនល្អ ជាដើម ទើបចេញបួសក្នុងសំណាក់ភិក្ខុនីនគរវេសាលី អឌ្ឍកាសីភិក្ខុនីធ្វើដំណើរមកដើម្បីសូមឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគជាម្ចាស់នៅវត្តជេតពន ក្រុងសាវត្ថី (ភិក្ខុនីត្រូវបួសដោយសង្ឃពីរពួក) ជ្រាបថា មានអ្នកបំណងនឹងបៀតបៀនខ្លួន ក្នុងចន្លោះផ្លូវ ទើបបញ្ជូនភិក្ខុនីទៅក្រាបទូលសួរព្រះអង្គថា នឹងគប្បីឱ្យបដិបត្តិដូចម្តេច ព្រះអង្គទ្រង់ជ្រាបហេតុនោះហើយ ទើបអនុញ្ញាតឱ្យភិក្ខុនីជាទូត គឺអ្នកជំនួសពោលពាក្យសូមបួសចំពោះភិក្ខុសង្ឃ ជំនួសភិក្ខុនីដែលមកមិនបាន ។

ព្រះសាស្តាទ្រង់អនុញ្ញាតឱ្យឧបសម្ប័ទ **អឌ្ឍកាសី** ដោយការឱ្យភិក្ខុនីនោះ ពោលសូមឧបសម្បទាជំនួស វិធីឧបសម្បទាដូច្នេះ ហៅថា **ទូតេនឧបសម្បទា** ជាវិធីឧបសម្បទា ដែលព្រះអង្គទ្រង់ប្រទានជាពិសេស ព្រោះហេតុការណ៍ដែលសមគួររបស់បុគ្គលម្នាក់ៗ ។

### វិធីឧបសម្បទាក្នុងព្រះពុទ្ធសាសនាមាន ៨ យ៉ាង គឺ :

១. **ឯហិភិក្ខុឧបសម្បទា** បួសដោយ ព្រះអង្គត្រាស់ឱ្យបួស គឺសម្រេចដោយឫទ្ធិ ។

២. **តិសរណគមនូបសម្បទា** បួសដោយ ការដល់ព្រះរតនត្រៃជាសរណៈ

៣. **ញត្តិចតុត្ថកម្មឧបសម្បទា** បួសដោយ ញត្តិជាគម្រប់ ៤ អំពីសង្ឃគណៈ

( វិធីនេះទ្រង់អនុញ្ញាតរហូតមកដល់សព្វថ្ងៃនេះ ហៅថា ញត្តិចតុត្ថកម្មវាចាឧបសម្បទា )

**៤. ឱវាទបដិគ្គហណូបសម្បទា** បួសដោយ ការទទួលឱវាទ

( ទ្រង់អនុញ្ញាតចំពោះព្រះមហាកស្សប)

**៥. បញ្ហាព្យាករណូឧបសម្បទា** បួសដោយ ការឆ្លើយតបបញ្ហារបស់-ព្រះអង្គ ( ទ្រង់អនុញ្ញាតចំពោះសោបាកសាមណេរ)

**៦. គរុធម្មបដិគ្គហណូបសម្បទា** បួសដោយ ការទទួលគរុធមិ ៨ ប្រការ

( ទ្រង់អនុញ្ញាតចំពោះព្រះនាងមហាបជាបតិគោតមី )

**៧. ទូតេន ឧបសម្បទា** បួសដោយទូត ( ទ្រង់អនុញ្ញាតដល់អឌ្ឍកាសីភិក្ខុនី )

**៨. អដ្ឋវាចិកាឧបសម្បទា** បួសដោយញត្តិចតុត្ថកម្មអំពីសង្ឃ ២ ផ្នែក

( ទ្រង់អនុញ្ញាតដល់ភិក្ខុនីទាំងឡាយ ) ។

( ១១ ) គ្រានោះ ក្នុងស្រុកឈ្មោះកលន្ទកៈ ជិតក្រុងវេសាលី **សុទិន្ន-កលន្ទបុត្ត** ជាបុត្រគហបតីម្នាក់ បានចូលមកកាន់ក្រុងវេសាលីនឹងសម្លាញ់ ដោយកិច្ចការខ្លះ ឃើញព្រះសាស្តាកំពុងសម្តែងធមិដល់ពួកជន គិតថា យើងគួរនឹងចូលទៅស្តាប់ធមិដែរ ទើបដើរចូលទៅអង្គុយក្នុងទីដ៏សមគួរមួយ ។ ក្រោយពីព្រះសាស្តាបញ្ចប់ព្រះធម្មទេសនា និងជនទាំងឡាយត្រឡប់ទៅហើយ សុទិន្ន បានចូលទៅគាល់ព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គធ្វើដូចម្តេច ទើបនឹងដឹងទូទៅដល់ធមិដែលព្រះអង្គសម្តែង ខ្ញុំព្រះអង្គប្រាថ្នានឹងកោរសក់ និងពុកមាត់ គ្រងសំពត់កាសាវៈចេញចាកផ្ទះបួសជាបព្វជិត សូមព្រះអង្គមេត្តាឱ្យខ្ញុំព្រះអង្គបានបួសផងចុះ ព្រះអង្គ ។

ព្រះសាស្ដាត្រាស់សួរថា មាតាបិតារបស់អ្នកអនុញ្ញាតហើយឬ ? សុទិន្ន-កលន្ទបុត្ត ក្រាបទូលថា នៅទេព្រះអង្គ ! ទើបព្រះសាស្ដាឱ្យត្រឡប់ទៅសូមអនុញ្ញាតសិន មាតាបិតាមិនព្រមដោយហេតុថា ខ្លួនមានបុត្រតែម្នាក់ បើចេញបួសប្រព្រឹត្តព្រហ្មចរិយធម៌ នឹងមិនមានអ្នកណាបន្តទ្រព្យមតិក របស់ត្រកូលតទៅ សុទិន្ននៅតែមិនលះបង់បំណងរបស់ខ្លួនដដែល ទើបមាតាបិតាប្រាប់សម្លាញ់ឱ្យជួយឃាត់ តែទោះបីលើកហេតុផលប្រការណាមកប្រាប់ ក៏មិនព្រមផ្លាស់ប្ដូរគំនិត សម្លាញ់ទាំងនោះយល់ថា បើសុទិន្នមិនបានបួសនឹងត្រូវស្លាប់ ប្រយោជន៍អ្វីនឹងកើតដល់មាតាបិតា ដែលត្រូវបាត់បង់បុត្ររបស់ខ្លួនទៅ ។ ទើបពោលនឹងមាតាបិតាថា សុទិន្នធ្លាប់មានជីវិតរស់នៅក្នុងគំនរសុខ បើអនុញ្ញាតឱ្យបួស នឹងអត់ធន់ចំពោះការបដិបត្តិខ្លួនក្នុងភេទបព្វជិតមិនបានយូរ ពេលនោះ ក៏នឹងត្រឡប់មកវិញដោយខ្លួនឯង លោកចូរអនុញ្ញាតឱ្យបួសចុះ ទើបមាតាបិតាយល់ព្រម ។

សុទិន្នត្រឡប់មកគាល់ព្រះសាស្ដា ទូលសេចក្ដីដែលមាតាបិតាអនុញ្ញាតឱ្យបួស កាលជ្រាបហើយ ព្រះសាស្ដាត្រាស់ឱ្យប្រជុំសង្ឃជាអ្នកបំបួស ។ សុទិន្ន-កលន្ទបុត្រ បួសហើយប្រព្រឹត្តធុតង្គគុណ នៅជិតស្រុកវជ្ជីមួយកន្លែង ដោយ-សមាទានការបិណ្ឌបាតជាវត្ត ថ្ងៃមួយចូលទៅបិណ្ឌបាតនៅស្រុកកំណើត មាតា-បិតានិមន្តឱ្យចូលទៅទទួលភត្តាហារ ព្រះសុទិន្នទទួលការនិមន្ត ដោយតាំងចិត្តអនុគ្រោះមាតាបិតា និងញាតិទាំងឡាយ ។

មាតាបិតា បានព្យាយាមអង្វរករឱ្យសឹកចេញមកគ្រប់គ្រងផ្ទះដូចដើម

កាលព្រះសុទិន្នមិនព្រម ទើបឱ្យអតីតភរិយាមកអង្វរករសុំកូនប្រុស ដើម្បីនឹងបានតាំងវង្សត្រកូលបន្តទៅ ព្រះសុទិន្នគិតថា បើយើងធ្វើឱ្យបំណងរបស់មាតា-បិតា សម្រេចផលហើយ លោកគង់នឹងឈប់ពាក់ព័ន្ធក្នុងខ្លួនយើង ទើបយល់ព្រមនៅរួមជាមួយនឹងអតីតភរិយារហូតនាងតាំងគភ៌ និងប្រសូតិកូនប្រុសមួយដាក់ នាមថា **ពីជកៈ** ។

ភិក្ខុទាំងឡាយដឹងរឿង ទើបចូលទៅក្រាបទូលព្រះសាស្ដាឱ្យទ្រង់ជ្រាប ទ្រង់ប្រជុំសង្ឃត្រាស់សួររឿងដែលកើតឡើង ព្រះសុទិន្នព្រមទទួលថាពិត ព្រះសាស្ដាទ្រង់តិះដៀល ហើយទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុណាសេពមេថុនធម្ម **ត្រូវអាបត្តិបារាជិក** ដែលជា **បឋមបញ្ញត្ត** នៃសិក្ខាបទត៧ មក ។

ក្រោយមក ទាំងពីជកៈ និងមាតា បានចេញចាកផ្ទះបួសជាបព្វជិត ប្រារព្ធព្យាយាមមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផលទាំងពីរនាក់ម៉ែកូន ។

# ព្រះវស្សាទី ១៣

## ទ្រង់គង់ចាំព្រះវស្សា ក្នុងចាលិកបព៌ត ក្រុងចាលិកា

(១) ក្នុងវស្សានេះ **ព្រះមេឃិយៈ** ជាឧបដ្ឋាករបស់ព្រះពុទ្ធអង្គ ព្រះមេឃិយៈចូលទៅបិណ្ឌបាតឯជន្តុគ្រាម ឃើញព្រៃស្វាយប្របមាត់ស្ទឹងកិមិកាឡា គួរឱ្យរីករាយ ពេញចិត្តដើម្បីនឹងប្រារព្ធព្យាយាមសម្រាប់ខ្លួន ទើបចូលទៅទូលលាព្រះអង្គត្រាស់ថា អ្នកចូររង់ចាំសិន រហូតទាល់តែភិក្ខុដទៃនឹងមកឧបដ្ឋាកជំនួស ត្រាស់ហាមដល់ ៣ ដង ព្រះមេឃិយៈក៏មិនបានស្តាប់ ទើបព្រះអង្គត្រាស់ថា មេឃិយៈ អ្នកចូរស្គាល់កាលដ៏គួររបស់អ្នកចុះ ព្រះមេឃិយៈថ្វាយបង្គំ ហើយធ្វើដំណើរទៅ ទុកឱ្យព្រះពុទ្ធអង្គទ្រង់គង់នៅតែមួយព្រះអង្គឯង ។

កាលព្រះមេឃិយៈចូលទៅកាន់ព្រៃស្វាយនោះហើយ កើតអកុសលវិតក្ក ៣ គឺ **កាមវិតក្ក ព្យាបាទវិតក្ក** និង **វិហិង្សាវិតក្ក** គ្របសង្កត់ មិនអាចប្រារព្ធព្យាយាមតាមដែលប្រាថ្នាបាន ទើបត្រឡប់ទៅគាល់ព្រះអង្គក្រាបទូលថា កុលបុត្រចេញបួសជាបព្វជិតដោយសទ្ធា ហេតុអ្វី ទើបត្រូវអកុសលវិតក្កដ៏លាមកគ្របសង្កត់ ។

ព្រះពុទ្ធអង្គទ្រង់ឱវាទថា មេឃិយៈ អ្នកដែលមានចិត្តមិនទាន់រួចផុតចាកអាសវៈ គួរស្វែងរកធម៌ ៥ ប្រការសិន គឺ **ត្រូវមានមិត្តល្អ ១ ជាអ្នកមានសីល សង្រួមរវាំងក្នុងព្រះបាតិមោក្ខ ដល់ព្រមដោយអាចារៈ និងគោចរៈ មានប្រក្រតីឃើញភ័យក្នុងទោស សូម្បីមានប្រមាណតិច ១ មានសេចក្តី**

**សន្តោស ១ មានព្យាយាមដើម្បីលះអកុសលធម៌ ដើម្បីការដល់ព្រមនៃកុសលធម៌ ១ និងជាអ្នកប្រកបដោយបញ្ញាពិចារណាការកើត និងការរលត់ បំផ្លាញកិលេសឱ្យដល់ទីបំផុតទុក្ខដោយប្រពៃ ១ ។**

ធម៌ ៥ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីចាស់ក្លានៃចេតោវិមុត្តិដែលមិនទាន់ចាស់ក្លា អ្នកតាំងនៅក្នុងធម៌ ៥ ប្រការនេះហើយ គប្បីចម្រើនធម៌ ៤ ប្រការ គឺ :

ចម្រើន **អសុភៈ** ដើម្បីលះរាគៈ ១ ចម្រើន **មេត្តា** ដើម្បីលះព្យាបាទ ១

ចម្រើន **អានាបានស្សតិ** ដើម្បីលះវិតក្ក ១ ចម្រើន **អនិច្ចសញ្ញា** ដើម្បីដកអស្មិមានះ ១ ។

ម្នាលមេឃិយៈ **អនត្តសញ្ញា** រមែងប្រាកដដល់ភិក្ខុអ្នកបាន **អនិច្ចសញ្ញា** អ្នកដែលបានអនត្តសញ្ញារមែងសម្រេចព្រះនិព្វាន ដែលដកចេញនូវអស្មិមានះក្នុងបច្ចុប្បន្ន ។ ក្រៅពីនោះ ព្រះអង្គទ្រង់ត្រាស់ទូន្មានព្រះមេឃិយៈទៀតថា **អ្នកមានបញ្ញា គប្បីធ្វើចិត្តដែលរើបម្រាស់ត្រឡប់ត្រឡិន រក្សាបានដោយកម្រ ហាមបានដោយកម្រ ឱ្យត្រង់ដូចជាងសរ ពត់កូនសរ ដូច្នោះ ។** ព្រះមេឃិយៈកាលតាំងនៅក្នុងព្រះឱវាទនោះហើយ ផ្តើមចម្រើនវិបស្សនា បានសម្រេចអរហត្តផល ក្នុងវេលាតមកមិនយូរ ។

## ក្រោយអំពីចេញព្រះវស្សាទី ១៣ ហើយ

(២) ព្រះពុទ្ធអង្គយាងទៅកាន់ចារិកក្នុងទីផ្សេងៗ ដើម្បីប្រោសវេនេយ្យសត្វ ដែលជាពុទ្ធកិច្ច តែមិនបានកំណត់ទុកថា ទៅទីណាខ្លះទេ ក្រោយមកទៀត យាងត្រឡប់មកកាន់ក្រុងសាវត្ថីវិញ ។ ក្នុងព្រះជេតវនវិហារ កាលបឋមយាមកន្លងទៅហើយ សក្កទេវរាជឱ្យទេវតាមួយអង្គ មកក្រាបទូលសួរព្រះអង្គថា ទេវតា និងមនុស្សជាច្រើន ប្រាថ្នានូវសិរីសួស្តី បាននាំគ្នាគិតរកមង្គលទាំងឡាយអស់ ១២ ឆ្នាំ ក៏នៅមិនទាន់ចុះសម្រុងគ្នា សូមព្រះអង្គទ្រង់ត្រាស់មង្គលដ៏ឧត្តមតើដូចម្តេច? ដើម្បីនាំប្រយោជន៍ និងសេចក្តីសុខឱ្យដល់សត្វលោកទាំងពួង ។

**ព្រះមានព្រះភាគត្រាស់សម្តែងព្រះគាថាតបថា :**

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជា ១ ។

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាតម្កល់ខ្លួនដោយប្រពៃ ១ ។

ភាវៈនៃបុគ្គលបានស្តាប់បានរៀនហើយដោយច្រើន ១ សិល្បសាស្ត្រ គឺ សេចក្តីឆ្លៀវឈ្លាសក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាហើយដោយល្អ ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ ១ ។

កិរិយាបម្រើនូវមាតា ១ កិរយាបម្រើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រ និងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ ។

កិរិយាបរិច្ចាគទាន ១ កិរយាប្រព្រឹត្តនូវធម៌ ១ សេចក្ដីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ ។

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១ សេចក្ដីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ ១

សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន ១ សេចក្ដីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន ១ កិរិយាស្ដាប់នូវធម៌តាមកាល ១,

សេចក្ដីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ ១ កិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ ។

សេចក្ដីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ កិរិយា ឃើញនូវអរិយសច្ចទាំងឡាយ ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ។

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្ដីសោក ១ មានធុលី គឺរាគៈទៅប្រាសហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ។

ទាំងអស់ ៣៨ ប្រការនេះ ជាមង្គលដ៏ឧត្តម ទេវតា និងមនុស្សទាំង-ឡាយ ប្រព្រឹត្តមង្គលដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់

នូវសិរីសួស្តីក្នុងទីទាំងពួង ។

(៣) សម័យនោះ ភិក្ខុនៅក្រុងផ្សេងៗជាច្រើនចូលមកគាល់ព្រះមានព្រះភាគដើម្បីរៀនកម្មដ្ឋានដែលសមគួរដល់ចរិតរបស់ខ្លួន ដើម្បីទៅចាំវស្សា គ្រានោះភិក្ខុ ៥០០ រូប រៀនកម្មដ្ឋានហើយ គេចទៅស្នាក់នៅក្បែរភ្នំជាទីរីករាយមួយ ព្រឹកឡើងចូលទៅបិណ្ឌបាតក្នុងភូមិ ដែលមិនឆ្ងាយអំពីភ្នំនោះ ពួកអ្នកស្រុកមានសទ្ធាជ្រះថ្លា ព្រោះក្នុងជនបទមិនងាយបានជួបបព្វជិត ទើបនិមន្តឱ្យភិក្ខុទាំងនោះស្នាក់នៅរហូត ៣ ខែ ។ ភិក្ខុទាំងនោះទទួលនិមន្តហើយ ចូលទៅអាស្រ័យគល់ឈើក្នុងដងព្រៃ ប្រារព្ធព្យាយាមអស់យប់ និងថ្ងៃ រុក្ខទេវតាទាំង-ឡាយ នៅលើដើមឈើត្រូវចុះចាកទីនៅរបស់ខ្លួន ស្មានថាលោកម្ចាស់នឹងទៅកាលសន្និដ្ឋានក្នុងចិត្តថា ភិក្ខុទាំងនេះនៅចាំវស្សាក្នុងទីនេះ ទើបនាំគ្នាសម្តែងរូបនិងបញ្ចេញសំឡេងគួរឱ្យខ្លាច រួមទាំងក្លិនផ្សេងៗ ដើម្បីបណ្តេញភិក្ខុទាំងនោះ ភិក្ខុទាំងឡាយមិនអាចធ្វើចិត្តឱ្យស្ងប់ជាសមាធិបាន កើតការញាប់ញ័រ មានវណ្ណៈសៅហ្មង កើតរោគស្គមលឿង ឈឺក្បាលខ្លាំង វង្វេងភ្លេចស្មារតី ។ កាលភិក្ខុគ្រប់អង្គមកប្រជុំគ្នាដោយហេតុនេះ ព្រះថេរៈពោលថា អាវុសោ ព្រះមានព្រះភាគទ្រង់អនុញ្ញាតការចាំវស្សាទី ២ ក៏កាលសេនាសនៈនេះមិនជាទីសប្បាយ ពួកយើងនឹងទៅកាន់សំណាក់ព្រះមានព្រះភាគ ទើបភិក្ខុទាំងអស់រៀបចំសេនាសនៈកាន់បាត្រ និងចីវរ មិនលាត្រកូលទាំងឡាយធ្វើដំណើរទៅគាល់ព្រះសាស្តានៅក្រុងសាវត្ថី ។

ព្រះមានព្រះភាគជ្រាបហេតុនោះហើយ ត្រាស់ថា ពួកអ្នកចូរអាស្រ័យសេនាសនៈនោះឯង នឹងគប្បីអស់ទៅនៃអាសវៈបាន ពួកអ្នកចូររៀន **ករណីយមេត្តបរិត្ត** គឺការចម្រើនមេត្តា នឹងជាគ្រឿងការពារផង ជាកម្មដ្ឋានរបស់អ្នកផង អ្នកគប្បីបដិបត្តិព្រហ្មវិហារ ៤ គឺ ចម្រើន **មេត្តា ករុណា មុទិតា ឧបេក្ខា** ក្នុងសត្វគ្រប់ប្រភេទ ទាំងដោយចំពោះ និងមិនចំពោះគប្បីមានចិត្តអនុគ្រោះផ្សាយទៅកាន់សត្វដែលមានចិត្តល្អ និងមិនល្អ ទាំងដែលមានអារម្មណ៍ជាកណ្តាល កាលធ្វើយ៉ាងនេះ សូម្បីមិនបាន **មគ្គ** ឬ **ផល** ក៏នៅមានព្រហ្មលោកជាទីទៅក្នុងខាងមុខ ។

ព្រះអង្គត្រាស់តទៅទៀតថា ពួកអ្នកចូរទៅនៅក្នុងដងព្រៃនោះ កាន់យកសូត្រនេះហើយ ចូរគោះរគាំងប្រជុំគ្នាក្នុងថ្ងៃស្តាប់ធម៌ហើយសូធ្យ **មេត្តាសូត្រនេះ** ចូរធ្វើធម្មីកថា សម្តែងធម៌ សន្ទនាធម៌ អនុមោទនា ធ្វើឱ្យច្រើនឡើងនូវកម្មដ្ឋាននេះ អមនុស្សទាំងនោះនឹងមិនសម្តែងអារម្មណ៍គួរឱ្យខ្លាចដល់អ្នកទាំងឡាយ និងជាអ្នកមានបំណងល្អ ប្រាថ្នាប្រយោជន៍ដល់ពួកអ្នកពិត ។ ពួកភិក្ខុត្រឡប់ទៅកាន់ដងព្រៃនោះ ក្រោយអំពីចម្រើនមេត្តាតាមដែលព្រះអង្គទ្រង់ទូន្មានហើយ ទេវតាទាំងឡាយកើតបីតិសោមនស្សថា លោកម្ចាស់មានមេត្តាចិត្តមានសេចក្តីប្រាថ្នាល្អចំពោះពួកយើង ទើបមិនរុកកួនភិក្ខុទាំងនោះទៀត ទាំងជួយមើលថែឱ្យស្រួលដោយប្រការផ្សេងៗ ភិក្ខុទាំងឡាយចម្រើនមេត្តាកម្មដ្ឋានប្រារព្ធវិបស្សនា គ្រប់រូបបានសម្រេចព្រះអរហត្តផលក្នុងវស្សានោះឯង ។

ក្នុងអង្គុត្តរនិកាយ ឯកាទសកនិបាត មេត្តាសូត្រ ព្រះមានព្រះភាគ ត្រាស់អានិសង្សរបស់មេត្តាទុក ១១ ប្រការ គឺ **ដេកលក់ជាសុខ ១ ភ្ញាក់ឡើងជាសុខ ១ មិនយល់សប្តិអាក្រក់ ១ ជាទីស្រឡាញ់របស់មនុស្ស ១ ជាទីស្រឡាញ់របស់អមនុស្ស ១ ទេវតាតែងរក្សា ១ មិនមានអន្តរាយដោយភ្លើង ថ្នាំពិស ឬ សស្ត្រា ១ ចិត្តជាសមាធិដោយរហ័ស ១ ទឹកមុខថ្លូវផង់ ១ មិនវង្វេងក្នុងពេលធ្វើមរណៈ ១ បើមិនទាន់សម្រេចអរហត្តផល រមែងទៅកាន់ព្រហ្មលោក ១** លោកពោលថា ចុតិចាកអត្តភាពនោះហើយ ទៅកើតក្នុងព្រហ្មលោក ដូចដេកលក់ហើយភ្ញាក់ឡើងដូច្នោះ ។

(៤) ក្រុងសាវត្ថី ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែង **បរិយេសនា-សូត្រ** ដល់ភិក្ខុទាំងឡាយ **ពោលអំពីការស្វែងរកដ៏ប្រសើរ ៤ ប្រការ** គឺ :

បុគ្គលពួកខ្លះក្នុងលោកនេះ ខ្លួនឯងជាអ្នកមានជរាជាធម្មតា ដឹងទោសក្នុងវត្ថុដែល មានជរាជាធម្មតាហើយ **រមែងស្វែងរកព្រះនិព្វានដែលមិនមានជរា ១ ។**

បុគ្គលពួកខ្លះក្នុងលោកនេះ ខ្លួនឯងជាអ្នកមានព្យាធិជាធម្មតា ដឹងទោសក្នុងវត្ថុដែលមានព្យាធិជាធម្មតាហើយ **រមែងស្វែងរកព្រះនិព្វានដែលមិនមានព្យាធិ ១ ។**

បុគ្គលពួកខ្លះក្នុងលោកនេះ ខ្លួនឯងជាអ្នកមានមរណៈជាធម្មតា ដឹងទោស ក្នុងវត្ថុដែលមានមរណៈជាធម្មតាហើយ **រមែងស្វែងរកព្រះនិព្វានដែល**

**មិនមានមរណៈ ១ ។**

បុគ្គលពួកខ្លះក្នុងលោកនេះ ខ្លួនឯងជាអ្នកមានសៅហ្មងជាធម្មតា ដឹងទោស ក្នុងវត្ថុដែលមានសៅហ្មងជាធម្មតាហើយ **រមែងស្វែងរកព្រះនិព្វានដែលមិនមានសៅហ្មង ១ ។**

(៥) ខណៈដែលព្រះពុទ្ធអង្គគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធរឿងរបស់ **ព្រះបូតិគ្គត្តតិស្សត្ថេរថា** កុលបុត្រក្នុងសាវត្ថីម្នាក់ ស្ដាប់ធម៌ក្នុងសំណាក់ព្រះសាស្ដា ថ្វាយជីវិតក្នុងព្រះសាសនា បានបព្វជ្ជាឧបសម្បទហើយ មានឈ្មោះថា **ព្រះតិស្សត្ថេរ** ។

កាលកន្លងទៅ ពកទាំងឡាយប្រមាណប៉ុនគ្រាប់ស្ពៃ កើតឡើងតាមសរីរៈរបស់លោក ពកនោះគ្រាប់ធំឡើងតាមលំដាប់ ប្រមាណប៉ុនគ្រាប់សណ្ដែកខៀវ គ្រាប់សណ្ដែកខ្មៅ គ្រាប់កន្ទួតព្រៃ និងប៉ុនផ្លែភ្នៅ ពកទាំងនោះបែកហើយក្លាយជាដំបៅស្អុយ ទើបមានឈ្មោះថា ព្រះបូតិគ្គត្តតិស្សត្ថេរអ្នកមានកាយស្អុយស្បង់ និងចីវរប្រឡាក់ដោយឈាម និងខ្ទុះ មិនមាននរណាថែរក្សា បោះបង់ឱ្យនៅដេកម្នាក់ឯងគត់ ។

ព្រះពុទ្ធអង្គទ្រង់ជ្រាបដោយព្រះញាណ ទ្រង់ឃើញឧបនិស្ស័យដែលនឹងបានសម្រេចព្រះអរហត្តនៃព្រះថេរៈ ទើបទ្រង់យាងទៅកាន់រោងភ្លើង ទ្រង់លាងឆ្នាំងដាក់ទឹកលើកតាំងលើចង្ក្រាន រង់ចាំឱ្យទឹកក្ដៅ ហើយយាងទៅចាប់ចុងគ្រែដែលភិក្ខុដេក ទ្រង់ឱ្យភិក្ខុដែលជាប់តាមនាំស្នូកមក ទ្រង់ចាក់ទឹកក្ដៅចុះឱ្យ

ហូរទៅតាមស្នូក ទ្រង់ត្រាស់ឱ្យភិក្ខុទាំងនោះដោះចីវរដែលដណ្តប់ទៅបោកគក់ដោយទឹកក្តៅ ព្រះអង្គទ្រង់ស្រោចសរីរៈនោះដោយទឹកក្តៅឧណ្ហៗ ដុសសរីរៈរបស់ព្រះថេរៈឱ្យងូតទឹក កាលចីវរស្ងួត ព្រះសាស្តាទ្រង់ជួយលោកឱ្យដណ្តប់ចីវរ ទ្រង់ញីស្បង់ដែលព្រះថេរៈស្លៀកហើយហាលថ្ងៃ កាលទឹកជាប់កាយស្ងួត ស្បង់ក៏ស្ងួត លោកស្លៀកសំពត់កាសាវៈមួយផ្ទាំង ដណ្តប់មួយផ្ទាំង ជាអ្នកមានសរីរៈស្រាល មានចិត្តជាសមាធិ ។

ព្រះសាស្តាប្រថាប់ឈរលើសិរសារបស់ព្រះថេរៈ ត្រាស់សម្តែងថា :

**កាយនេះមិននៅយូរប៉ុន្មានឡើយ តែវិញ្ញាណទៅប្រាស**
**ហើយ ជាកាយគឺគេបោះបង់ចោល ក៏នឹងដេកសង្កត់**
**នៅលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។**

វេលាចប់ទេសនា ព្រះតិស្សត្ថេរ សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា សូម្បីពួកជនដទៃជាច្រើនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្ន ជាដើម ព្រះថេរៈសម្រេចព្រះអរហត្តហើយក៏បរិនិព្វាន ព្រះសាស្តាទ្រង់ចាត់ឱ្យធ្វើឈាបនកិច្ចសរីរៈរបស់លោក ទ្រង់រើសអដ្ឋិធាតុ ហើយប្រោសឱ្យសាងស្តូបតម្កល់ទុក ។ ភិក្ខុទាំងឡាយទូលសួរដល់ហេតុនៃកាយស្អុយ និងហេតុដែលបានសម្រេចព្រះអរហត្ត ព្រះសាស្តាត្រាស់សម្តែងដល់បុព្វកម្មរបស់ព្រះថេរៈថា ផលនៃកាយស្អុយ និងឆ្អឹងបែក ដោយផលនៃការកាច់ឆ្អឹងបក្សីទាំងឡាយ, ដែលព្រះថេរៈសម្រេចព្រះអរហត្តក៏ដោយផលនៃការថ្វាយបិណ្ឌបាត ដែលមានរសដ៏ឆ្ងាញ់ដល់

ព្រះខីណាស្រព ហើយតាំងសេចក្តីប្រាថ្នាថា ខ្ញុំម្ចាស់សូមដល់ទីបំផុតនៃធម៌ដែលលោកម្ចាស់បានឃើញហើយចុះ ដូច្នេះ ។

( ៦ ) កុលបុត្រ ឈ្មោះ **ពាហិយទារុចីរិយ:** អាស្រ័យនៅកំពង់សុប្បារកៈ ក្បែរមាត់សមុទ្រ ជាអ្នកដែលមហាជនសក្ការបូជា គោរពកោតក្រែង ដោយយល់ថា ជាព្រះអរហន្ត ទេវតាដែលជាញាតិសាលោហិត ក្នុងកាលមុនរបស់កុលបុត្រនោះ ចូលមកពោលថា អ្នកមិនមែនព្រះអរហន្តទេ និងមិនមានបដិបទាដែលនឹងឱ្យជាព្រះអរហន្ត ក៏ឥឡូវនេះ ក្នុងជនបទខាងជើងមាននគរឈ្មោះសាវត្ថី ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ គង់នៅក្នុងព្រះនគរនោះ ព្រះអង្គជាព្រះអរហន្តពិតប្រាកដ ទាំងទ្រង់សម្តែងធម៌ដើម្បីបានជាព្រះអរហន្តផង កុលបុត្របានឮហើយស្លុតចិត្ត គេចចេញចាកកំពង់សុប្បារកៈ ធ្វើដំណើរទៅគាល់ព្រះសាស្តានៅឯព្រះជេតវនវិហារភ្លាម ដោយការសម្រាកផ្លូវត្រឹមតែមួយរាត្រីប៉ុណ្ណោះ ។

ព្រះជេតវនវិហារ កុលបុត្រឃើញភិក្ខុជាច្រើនចង្ក្រមក្នុងទីវាល ទើបចូលទៅសួររកព្រះសាស្តា ភិក្ខុប្រាប់ថា ព្រះសាស្តាយាងចូលកាន់ចន្លោះស្រុកដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី កុលបុត្រនោះប្រញាប់ទៅតាម បានឃើញព្រះពុទ្ធអង្គកំពុងទ្រង់ត្រាច់បិណ្ឌបាត មានឥន្ទ្រីយ៍ស្ងប់ មានឥន្ទ្រីយ៍សង្រួម ទើបចូលទៅក្រាបចុះទៀបព្រះបាទា លើផ្លូវក្រាបទូលសូមឱ្យព្រះពុទ្ធអង្គទ្រង់សម្តែងធម៌ ។

ព្រះអង្គត្រាស់ថា ពាហិយៈ វេលានេះមិនមែនជាកាលដ៏សមគួរឡើយ ព្រោះតថាគតនៅបិណ្ឌបាត ពាហិយៈ បានក្រាបទូលអង្វរសូមជាលើកទី ២ ទៀត

យ៉ាងនេះព្រោះព្រះសាស្ដាទ្រង់ឃើញថា បីតិដ៏មានកម្លាំងខ្លាំងរបស់កុលបុត្រនេះ សូម្បីបានស្ដាប់ធម៌ហើយក៏មិនអាចសម្រេចបាន ព្រះអង្គបំណងនឹងឱ្យសម្រាក ដើម្បីបន្ធូរការនឿយហត់អំពីការធ្វើដំណើរសិន ព្រោះពាហិយៈធ្វើដំណើរអស់ផ្លូវ ១២០ យោជន៍ គឺមួយរាត្រីប៉ុណ្ណោះ សូម្បីដូច្នោះ ពាហិហៈក៏អង្វរសូមជាលើក ទី ៣ ទៀត ។ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ម្នាលពាហិយៈ អ្នកគប្បីសិក្សាយ៉ាងនេះថា កាលឃើញ **ត្រឹមតែជាការឃើញ** កាលឮ **ត្រឹមតែជាការឮ** កាលជ្រាប **ត្រឹមតែជាការជ្រាប** កាលដឹងច្បាស់ **ត្រឹមតែជាការដឹងច្បាស់** ក្នុងកាលនោះអ្នករមែងមិនមាន ក្នុងកាលណាអ្នកមិនមាន ក្នុងកាលនោះអ្នករមែងមិនមានក្នុងលោកនេះ រមែងមិនមានក្នុងលោកខាងមុខ រមែងមិនមានក្នុងចន្លោះលោកទាំងពីរ ! នេះឯង **ជាទីបំផុតនៃសេចក្ដីទុក្ខ** ។

ខណៈនោះ ពាហិយទារុចីរិយៈ បញ្ជូនញាណទៅតាមក្រសែទេសនា ចិត្តក៏រួចផុតហើយចាកអាសវៈ សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ៤ ដោយព្រះឱវាទដ៏សង្ខេបក្នុងចន្លោះផ្លូវនុ៎ះឯង ពាហិយទារុចីរិយៈ ទូលសូមបព្វជ្ជាឧបសម្ប័ទ ព្រះមានព្រះភាគត្រាស់សួរថា បាត្រ និងចីវររបស់អ្នកមានគ្រប់ហើយឬ ពាហិយៈក្រាបទូលថា មិនទាន់គ្រប់ទេ ព្រះអង្គ ! ទើបព្រះសាស្ដាត្រាស់ថា អ្នកចូរទៅស្វែងរកបាត្រ និងចីវរមកសិនចុះ ហើយព្រះអង្គក៏គេចចេញទៅ ។

ខណៈដែលពាហិយៈកំពុងស្វែងរកអដ្ឋបរិក្ខារ អមនុស្សដែលមានពៀរ

នឹងគ្នាក្នុងកាលមុន ចូលសណ្ឋិតក្នុងកាយរបស់មេគោកូនខ្ចី ជល់ត្រូវចំគល់ភ្លៅខាងឆ្វេង ពាហិយៈដល់នូវសេចក្ដីស្លាប់ភ្លាម ។ ព្រះសាស្ដាត្រឡប់ពីបិណ្ឌបាតទ្រង់ចេញពីក្រុងសាវត្ថីព្រមដោយភិក្ខុទាំងឡាយ ទតឃើញពាហិយទារុចីរិយៈដួលចុះត្រង់គំនរសម្រាមក្នុងចន្លោះផ្លូវ ព្រះអង្គទ្រង់ឱ្យភិក្ខុទាំងឡាយជួយគ្នានាំសរីរៈរបស់ពាហិយទារុចីរិយៈទៅធ្វើឈាបនកិច្ច ត្រាស់ឱ្យរើសអដ្ឋិធាតុ ហើយប្រោសឱ្យសាងស្តូបទុកត្រង់ផ្លូវបែកជា ៤ ។

ភិក្ខុទាំងឡាយ ក្រាបទូលសួរដល់គតិរបស់ពាហិយៈ ព្រះអង្គត្រាស់ថា ពាហិយទារុចីរិយៈជាបណ្ឌិត បដិបត្តិធម៌សមគួរដល់ធម៌ ទាំងមិនធ្វើឱ្យតថាគតលំបាកក្នុងការសម្ដែងធម៌ ពាហិយទារុចីរិយៈ បរិនិព្វានហើយដោយអនុបាទិសេសនិព្វាន ។ ភិក្ខុសង្ស័យថា ពាហិយៈសម្រេចកាលណា ព្រះអង្គត្រាស់ថា ក្នុងកាលដែលស្ដាប់ធម៌របស់តថាគតក្នុងចន្លោះផ្លូវ ភិក្ខុទូលសួរទៀតថា ព្រះសាស្ដាទ្រង់មិនបានសម្ដែងធម៌ច្រើនឡើយ ព្រោះហេតុអ្វី ទើបពាហិយៈបានសម្រេចព្រះអរហត្តផល ព្រះអង្គត្រាស់ថា ធម៌តិច ឬច្រើនមិនមែនជាហេតុ ហើយទ្រង់ត្រាស់សម្ដែងគាថា ថា :

**គាថាតែមួយបទ ស្ដាប់ហើយស្ងប់រម្ងាប់ រមែងប្រសើរ**
**ជាងគាថាទាំងពាន់ តែមិនប្រកបដោយប្រយោជន៍ ។**

ចប់ទេសនា មានអ្នកសម្រេចធម៌ដ៏ច្រើន តមកខាងក្រោយ ព្រះសាស្ដាទ្រង់សរសើរ ពាហិយទារុចីរិយៈ កណ្ដាលជំនុំសង្ឃថា លោកជា **ខិប្បាភិញ្ញា**

(កំពូលជាងភិក្ខុទាំងពួង អ្នកត្រាស់ដឹងយ៉ាងឆាប់រហ័ស) ។

អដ្ឋកថាពោលថា ពាហិយទារុចីរិយៈបានបំពេញសមណធម៌ ក្នុងសម័យនៃព្រះកស្សបសម្ពុទ្ធជាម្ចាស់ តែមិនធ្លាប់ធ្វើការសង្គ្រោះភិក្ខុដទៃ ដោយបាត្រ ឬចីវរឡើយ ព្រោះហេតុនោះ បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ទើបមិនបានកើតឡើងដល់លោក ព្រះសាស្ដាទ្រង់ជ្រាបទើបមិនបានប្រទាន **ឯហិភិក្ខុឧបសម្បទា** ដល់ពាហិយទារុចីរិយៈឡើយ ។

(៧) បន្ទាប់ពីនោះ ព្រះពុទ្ធអង្គទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះ **ព្រះអញ្ញាកោណ្ឌញ្ញៈ** ដែលទូលលាទៅនៅជាសុខដោយវិហារធម៌ឯស្រះមណ្ឌាកិណីព្រៃឆទ្ទន្តហិមវ័នអស់វេលា ១២ ឆ្នាំ ត្រឡប់មកគាល់ព្រះពុទ្ធអង្គនៅវេឡុវ័នវិហារ ដើម្បីក្រាបទូលលាបរិនិព្វាន ។ ព្រះពុទ្ធអង្គត្រាស់សួរថា អ្នកនឹងបរិនិព្វានទីណា ព្រះអញ្ញាកោណ្ឌញ្ញៈក្រាបទូលថា បរិនិព្វាននៅព្រៃឆទ្ទន្ត ព្រះអង្គ កាលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ធ្វើប្រទក្សិណក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការឃើញគ្រាមុនជាការឃើញគ្រាដំបូងរបស់ខ្ញុំព្រះអង្គ គ្រានេះ ជាការឃើញចុងក្រោយបំផុតរបស់ខ្ញុំព្រះអង្គ ថ្វាយបង្គំលាព្រះសាស្ដាហើយចេញមកឈរត្រង់ស៊ុំទ្វារ ទូន្មានមហាជនថា អ្នកទាំងឡាយកុំសោយសោកឡើយ **សង្ខារដែលកើតឡើងហើយ ឈ្មោះថា មិនបែកធ្លាយរមែងមិនមាន** កាលមហាជនកំពុងឃើញនោះឯង ហោះឡើងទៅកាន់វេហាស៍ ចុះត្រង់មាត់ស្រះមណ្ឌាកិណី ស្រង់ទឹកក្នុងស្រះបោក្ខរណី ស្លៀកស្បង់ដណ្ដប់ចីវរហើយ រៀបចំ

សេនាសនៈ ចូលផលសមាបត្តិកន្លង ៣ យាម បរិនិព្វានក្នុងវេលាជិតភ្លឺ ។

ដំរីឧបដ្ឋាកមិនដឹងថាព្រះថេរៈបរិនិព្វាន រៀបចំទឹកខ្ពុរមាត់ និងឈើស្ទន់ ធ្វើវត្តបដិបត្តិពីព្រឹកព្រហាម នាំរបស់គួរទំពា និងផ្លែឈើមកឈរនៅចុងបំផុត នៃទីចង្រ្កម ដំរីនោះមិនឃើញព្រះថេរៈចេញមកពីបណ្ណសាលា ក៏ប្រើប្រមោយ បើកទ្វារ ឃើញព្រះថេរៈកំពុងគង់ ទើបលាប្រមោយចេញស្ទាបមើលខ្យល់ដង្ហើម ដឹងថាព្រះថេរៈបរិនិព្វានហើយ ក៏លើកប្រមោយឡើងបញ្ចេញសំឡេងកោញ្ច-នាទឮលាន់រំពង ពួកដំរីទាំងឡាយក្នុងព្រៃហិមពាន្តមកប្រជុំគ្នា លើកព្រះថេរៈឡើងផ្តេកលើពោងរបស់មេហ្វូងដំរី ប្រើប្រមោយកាច់ឈើមានផ្ការីកស្គុះស្គាយ ហែហម ដង្ហែទៅគ្រប់ទិសក្នុងព្រៃហិមពាន្ត ហើយត្រឡប់មកកាន់បណ្ណសាលា ដូចដើម ។ សក្កទេវរាជ បញ្ជាឱ្យវេស្សកម្មទេវបុត្រនិម្មិតផ្ទះកំពូល ឱ្យព្រះថេរៈដេកក្នុងផ្ទះកំពូលនោះ ហើយដង្ហែប្រទក្សិណភ្នំហិមពាន្ត ពួកទេវតាលើកផ្ទះកំពូលឡើងកាន់ជើងថ្ករ ព្រះអនុរុទ្ធត្ថេរសម្តែងធម៌ ភិក្ខុសង្ឃប្រមាណ ៥០០ រូប ហោះមកស្វាធ្យាយធម៌រហូតមួយរាត្រី ធ្វើឈាបនកិច្ចហើយ ព្រះអនុរុទ្ធត្ថេរ បាននាំអដ្ឋិធាតុរបស់លោកមកថ្វាយព្រះសាស្តា ព្រះពុទ្ធអង្គត្រាស់ឱ្យបញ្ចុះ អដ្ឋិធាតុរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ ក្នុងស្តូបប្រាក់ដែលផុសឡើងអំពីផែនដី ក្នុង វត្តវេឡុវ័ន ក្រុងរាជគ្រឹះ ។

# ព្រះវស្សាទី ១៤

## ទ្រង់គង់ចាំព្រះវស្សា ក្នុងវត្តជេតពន ក្រុងសាវត្ថី

(១) ក្នុងវស្សានេះ **សាមណេររាហុលមានអាយុ ២០ ឆ្នាំ គ្រប់បរិបូរណ៍** បានទទួលការឧបសម្បទជាភិក្ខុ **ដោយព្រះសារីបុត្តត្ថេរជាព្រះឧបជ្ឈាយ៍ ព្រះមោគ្គល្លានត្ថេរជាព្រះកម្មវាចា** ក្នុងវិន័យមហាវិភង្គ វិនិច្ឆ័យថា អ្នកណានៅក្នុងផ្ទៃរបស់មាតាដល់ ១២ ខែ ប្រសូតិក្នុងថ្ងៃមហាបវារណា តាំងពីថ្ងៃមហាបវារណានោះទៅរហូតដល់ថ្ងៃ មហាបវារណាឆ្នាំទី ១៩ គប្បីឱ្យអ្នកនោះឧបសម្បទក្នុងថ្ងៃ ១ រោច រម្លងថ្ងៃមហាបវារណានោះទៅ គប្បីជ្រាបការបន្ថយ និងបន្ថែមឡើងដោយឧបាយនេះ ។ តមក ព្រះពុទ្ធអង្គទ្រង់ជ្រាបថា ព្រះរាហុលមានធមិចាស់ក្លាហើយ ទើបណែនាំព្រះរាហុលក្នុងធមិជាទីអស់អាសវកិលេសក្រៃលែងឡើង ។

គ្រានោះ ព្រះអង្គចូលទៅបិណ្ឌបាតក្នុងនគរសាវត្ថី ខាងក្រោយភត្តាហារហើយទ្រង់ត្រាស់ឱ្យព្រះរាហុលកាន់សំពត់អង្គុយ យាងចូលទៅកាន់ព្រៃអន្ធវ័នដែលនៅទិសខាងត្បូងនៃក្រុងសាវត្ថី ដើម្បីសម្រាកពេលថ្ងៃ ពួកទេវតាជាច្រើនជាប់តាមទៅដោយដឹងថា ថ្ងៃនេះ ព្រះសាស្តានឹងណែនាំព្រះរាហុលក្នុងធមិជាទីអស់អាសវៈ ។ ព្រះពុទ្ធអង្គទ្រង់សម្តែង **ចូឡរាហុលោវាទសូត្រ** ពោលអំពីការមិនទៀងរបស់ខន្ធ ៥ និងការលះបង់អនុស័យ គឺមានះដែលជាធមិបន្ទុំវិមុត្តិ កាលចប់ព្រះសុភាសិតនេះហើយ ចិត្តរបស់ព្រះរាហុលរួចផុតហើយចាកអាសវៈទាំង

ឡាយ សម្រេចអរហត្តផលព្រមដោយបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ។ ក្នុងអដ្ឋកថាពោលថា ព្រះរាហុលធ្លាប់តាំងសេចក្តីប្រាថ្នាទៀបព្រះបាទារបស់ព្រះពុទ្ធជាម្ចាស់ **បទុមុត្តរៈ** ក្នុងអត្តភាពដែលជាស្តេចនាគឈ្មោះបាលិតៈ ព្រមជាមួយទេវតាទាំងនេះ ក្នុងថ្ងៃនេះបណ្តាទេវតាពួកនោះ ពួកខ្លះបានសម្រេចជាសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះខីណាស្រព ។

(២) ក្នុងវស្សានេះ ***ភិក្ខុភទ្ទវគ្គីយ៍ ៣០ រូប*** សុទ្ធតែសមាទានការនៅព្រៃ និងកាន់បិណ្ឌបាតជាវត្ត នាំគ្នាធ្វើដំណើរមកកាន់ក្រុងសាវត្ថី ដើម្បីចូលគាល់ព្រះពុទ្ធអង្គ តែព្រោះពេលជិតចូលព្រះវស្សា មិនអាចធ្វើដំណើរមកឱ្យទាន់ថ្ងៃចូលព្រះវស្សា ទើបត្រូវចាំវស្សាក្នុងនគរសាកេត ដែលនៅឆ្ងាយពីក្រុងសាវត្ថីប្រមាណ ៧ យោជន៍ ។ សម័យនោះភិក្ខុដែលចាំព្រះវស្សាក្នុងវត្តជេតពនកាលត្រឡប់ពីបិណ្ឌបាតឆាន់ភត្តាហារហើយ អង្គុយប្រជុំគ្នាក្នុងរោងឆាន់ សន្ទនាដល់រឿងផ្សេងៗ ដែលជាតិរច្ឆានកថា ដោយសំឡេងដ៏ឮ និយាយដល់ **រឿងព្រះរាជា រឿងចោរ មហាមាត្យ កងទ័ព រឿងភ័យ រឿងចម្បាំង រឿងបាយ ទឹក សំពត់ ទីដំណេក ផ្កាឈើ គ្រឿងក្រអូប រឿងញាតិ រឿងយានស្រុកនិគម ជនបទ នគរ ស្ត្រី បុរស ការផឹកសុរា ច្រកល្ហក កំពង់ទឹករឿងអ្នកដែលស្លាប់ទៅហើយ រឿងលោក រឿងសមុទ្រ រឿងសេចក្តីចម្រើន រឿងសេចក្តីវិនាស រឿងមនុស្សភ្លាហាន និងរឿងកំប៉ិកកំប៉ុកផ្សេងៗ** ព្រះពុទ្ធអង្គត្រាស់ថា មិនសមគួរដល់អ្នកទាំងឡាយជាកុលបុត្រចេញ

បួសជាបព្វជិតដោយសទ្ធាឡើយ ហើយត្រាស់កថាវត្ថុ គឺរឿងដែលគួរនិយាយ ១០ ប្រការថា ពួកអ្នកគប្បីពោលតែពាក្យដែល :

១. ដឹកនាំឱ្យមានសេចក្ដីប្រាថ្នាតិច

២. ដឹកនាំឱ្យសន្ដោស ត្រេកអរដោយបច្ច័យតាមមានតាមបាន

៣. ដឹកនាំឱ្យកើតសេចក្ដីស្ងប់

៤. ដឹកនាំមិនឱ្យច្របូកច្របល់ដោយពួកគណៈ

៥. ដឹកនាំឱ្យប្រារព្ធសេចក្ដីព្យាយាម

៦. ដឹកនាំឱ្យតាំងនៅក្នុងសីល

៧. ដឹកនាំឱ្យមានចិត្តតាំងមាំ គឺ សមាធិ

៨. ដឹកនាំឱ្យកើតបញ្ញា

៩. ដឹកនាំឱ្យត្រេកអរក្នុងការរួចផុតចាកកិលេស

១០. ដឹកនាំឱ្យកើតការដឹងដល់ផលល្អ របស់ការលះកិលេស

កថាវត្ថុទាំង ១០ ប្រការនេះ កាលនាំមកសន្ទនាគ្នា រមែងកើតកុសល-ធម៌ច្រើនឡើង ទាំងផ្លូវកាយ វាចា និងចិត្ត ។ រួចហើយត្រាស់ **សចិត្តសូត្រ** ពោលអំពីអ្នកឆ្លាតក្នុងវារៈចិត្ត អប់រំទូន្មានភិក្ខុឱ្យចេះកំណត់វារៈចិត្តរបស់ខ្លួនឯង ប្រឹងពិចារណាត្រួតមើលថា នីវរណៈ ៥ មាននៅក្នុងខ្លួនឬទេ បើមានភិក្ខុគប្បីព្យាយាម ប្រឹងប្រែងឱ្យមានសតិសម្បជញ្ញៈ លះធម៌ជាបាបអកុសលទាំងនោះ ដូចបុគ្គលភ្លើងឆេះក្បាល ប្រញាប់រួសរាន់រំលត់ភ្លើងនោះដោយរហ័ស ភិក្ខុគប្បី

ប្រារព្ធសេចក្តីព្យាយាមក្នុងកុសលធម៌ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

(៣) សម័យមួយ ក្នុងព្រះវិហារជេតពន ព្រះមានព្រះភាគត្រាស់ទូន្មានរឿង **បុគ្គលមានរាត្រីមួយដ៏ចម្រើន** (ភទ្ទេករត្តិសូត្រ) ដល់ភិក្ខុទាំងឡាយ សេចក្តីសង្ខេបថា :

**អតីតំ នាន្វាគមេយ្យ នប្បដិកង្ខេ អនាគតំ**
**យទតីតម្បហីនន្តំ អប្បត្តញ្ច អនាគតំ ។**

បុគ្គលមិនគប្បីអាឡោះអាល័យ នូវខន្ធជាអតីតៈ មិនគប្បី
ប្រាថ្នានូវខន្ធជាអនាគត ព្រោះថា ខន្ធណាដែលជាអតីតៈ
ខន្ធនោះកន្លងហួសទៅហើយ ខន្ធណា ដែលជាអនាគត
ខន្ធនោះក៏មិនទាន់មកដល់ដែរ ។

**បច្ចុប្បន្នញ្ច យោ ធម្មំ តត្ថ តត្ថ វិបស្សតិ**
**អសំហិរំ អសំកុប្បំ តំ វិទ្វា មនុព្រូហយេ ។**

បុគ្គលណាឃើញច្បាស់នូវធម៌ ជាបច្ចុប្បន្នក្នុងទីនោះៗ បុគ្គលនោះ
លុះដឹងច្បាស់នូវព្រះនិព្វាន មិនរសេមរសាម និងមិនកម្រើក គប្បី
ចម្រើននូវផលសមាបត្តិ ដែលមានព្រះនិព្វាននោះជាអារម្មណ៍ឱ្យរឿយៗ

**អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ**
**ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។**

ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលត្រូវតែធ្វើក្នុងថ្ងៃនេះឯង

អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ ។

**ឯវំ វិហារិមាតាបឹ អហោរត្តមតន្ទិតំ**
**តំ វេ ភទ្ទេករត្តោតិ សន្តោ អាចិក្ខតេ មុនិ**

អ្នកប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់យប់ និងថ្ងៃនោះឯងថា ជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

( ៣ ) ទ្រង់សម្តែង **ចូឡកម្មវិភង្គសូត្រ ដល់សុភមាណពតោទេយ្យបុត្រ** ដែលចូលទៅគាល់ទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីហ្ន៎ ជាហេតុ ជាបច្ច័យ ឱ្យពួកសត្វដែលកើតជាមនុស្ស **មានអាយុខ្លី អាយុវែង មានរោគច្រើន មានរោគតិច មានពណ៌សម្បុរអាក្រក់ មានពណ៌សម្បុរល្អ មានយសសក្តិតូច មានយសសក្តិធំ មានទ្រព្យតិច មានទ្រព្យច្រើន កើតក្នុងត្រកូលទាប កើតក្នុងត្រកូលខ្ពស់ អត់បញ្ញា មានបញ្ញា** ប្រាកដជាថោកទាប និងប្រណីតជាងគ្នា ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលសុភមាណព សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្ម

ជាទីពឹង កម្មរមែងបែងចែកសត្វឱ្យថោកទាប និងប្រណីតផ្សេងគ្នា ។ តពីនោះ ព្រះសាស្ដាទ្រង់ចែកសេចក្ដី និងបដិបទាដើម្បីជាអ្នកមានអាយុខ្លី អាយុវែង មានភោគៈច្រើន មានភោគៈតិច មានរោគច្រើន មានរោគតិច មានពណ៌សម្បុរអាក្រក់ មានពណ៌សម្បុរល្អ មានយសសក្ដិតូច មិនមានយសសក្ដិធំ មានទ្រព្យតិច មានទ្រព្យច្រើន កើតក្នុងត្រកូលទាប កើតក្នុងត្រកូលខ្ពស់ អត់បញ្ញា មានបញ្ញាដោយលំដាប់ ។ ( សេចក្ដីពិស្ដារក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) សុភមាណពស្ដាប់ដូច្នោះហើយ ថ្វាយខ្លួនជាឧបាសកដល់រតនត្រ័យជាសរណៈស្មើដោយជីវិត ។

( ៥ ) ថ្ងៃមួយ **ជាណុស្សោណិព្រាហ្មណ៍** ចូលទៅទូលសួរព្រះពុទ្ធអង្គនូវការឧទ្ទិសទាន ឱ្យដល់អ្នកដែលស្លាប់ទៅហើយថា ទាននោះនឹងសម្រេចដល់ញាតិសាលោហិត ទាំងនោះឬទេ ព្រះមានព្រះភាគត្រាស់ថា ក្នុងបណ្ដាសត្វទាំងឡាយ មានសត្វនរក សត្វតិរច្ឆាន មនុស្ស ទេវតា និងប្រេត មានតែប្រេតមួយពួកអាចទទួលទានបាន ដែលញាតិឧទ្ទិសទៅឱ្យ ព្រោះវិស័យរបស់ប្រេត រមែងញ៉ាំងជីវិតឱ្យរស់នៅ ដោយទានដែលពួកញាតិឧទ្ទិសឱ្យ អំពីលោកនេះប៉ុណ្ណោះ ចំណែកសត្វដទៃ មិនបានទទួល ព្រោះហេតុថា :

**សត្វនរក** មានកម្មជាអាហារ មានកម្មជាគ្រឿងឧបត្ថម្ភឱ្យជីវិតរស់នៅ

**សត្វតិរច្ឆាន** មានជីវិតរស់នៅដោយបាយ ទឹក ស្មៅ និងសាច់សត្វជាដើម

**មនុស្ស** មានជីវិតរស់នៅដោយអាហារ មានបាយ និងនំ ជាដើម

**ទេវតា** មានអាហារទិព្វ មិនបានបរិភោគអាហារដូចជាមនុស្ស

សម្រាប់ **ប្រេតនោះ** មិនមានការធ្វើស្រែចំការ មិនមានការជួញដូរជាដើម ប្រេតមានជីវិតរស់នៅដោយការឱ្យរបស់អ្នកដទៃតែម្យ៉ាង ដូច្នោះប្រេតទើបនៅក្នុងឋានៈទទួលទានដែលមានអ្នកឧទ្ទិសទៅឱ្យប៉ុណ្ណោះ ។ ជាណុស្សោ-ណិព្រាហ្មណ៍ទូលសួរទៀតថា បើញាតិសាលោហិតដែលស្លាប់ទៅហើយមិននៅក្នុងឋានៈនោះ នរណាទៅនឹងបានបរិភោគទាននោះ ព្រះអង្គត្រាស់តបថា ក្នុងសង្សារវដ្ដដ៏យូរលង់ រមែងត្រូវមានញាតិសាលោហិតខ្លះពុំខាន តែសូម្បីមិនមាននរណាសោះ អ្នកឱ្យទាននោះឯងនឹងបានទទួលផលខ្លួនឯង សូម្បីទាយកនោះ បើកាន់យកកំណើតជាដំរី ក៏នឹងបានដំណែងជាដំរីមង្គល ឬកាន់យកកំណើតសត្វតិរច្ឆានដទៃ ក៏នឹងបានទទួលការលើកតម្កើង ដោយន័យដូចគ្នានេះ ។

( ៦ ) ក្នុងក្រុងសាវត្ថី កុដុម្ពិកៈម្នាក់មានទ្រព្យច្រើន មានចិត្តប្រាសចាកមន្ទិល គឺសេចក្ដីកំណាញ់ ថ្ងៃមួយខណៈដែលកំពុងថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ព្រះរាជាមានព្រះបំណងនឹងជួប ទ្រង់ព្រះបញ្ជាឱ្យរាជបុរសទៅអញ្ជើញកុដុម្ពិកៈមក ខណៈនោះកុដុម្ពិកៈកំពុងអង្គាសភិក្ខុសង្ឃ ទើបពោលនឹងរាជបុរសនោះថា ទៅមុនចុះលោក ខ្ញុំនឹងកប់កំណប់ទ្រព្យក្នុងខណៈនេះសិនហើយនឹងទៅតាមក្រោយ ។ ក្រោយភត្តកិច្ច ព្រះសាស្ដាទ្រង់សម្ដែង **និធិ-កណ្ឌសូត្រ** ដើម្បីអនុមោទនាក្នុងបុញ្ញសម្បទារបស់កុដុម្ពិកៈនោះ ត្រាស់ថា :

បុរសរមែងកប់ **កំណប់ទ្រព្យ** ទុកក្នុងដី ដោយគិតថា កាលមានកិច្ចចាំ

បាច់កើតឡើង ទ្រព្យនឹងជាប្រយោជន៍ដល់យើង ដើម្បីដកខ្លួនចាករាជភ័យខ្លះ ដើម្បីជួយខ្លួនឱ្យផុតចោរភ័យខ្លះ ដើម្បីដោះបំណុលខ្លះ ក្នុងគ្រាកើតទុព្ភិក្ខភ័យខ្លះ ក្នុងគ្រាអត់ឃ្លានខ្លះ កំណប់ទ្រព្យដែលបុគ្គលកប់ទុកក្នុងលោក ក៏ដើម្បីប្រយោជន៍នេះតែប៉ុណ្ណោះឯង ។

**កំណប់ទ្រព្យនោះ** មិនបានសម្រេចប្រយោជន៍ដល់គេ គ្រប់កាលបាន ព្រោះកំណប់ទ្រព្យឃ្លាតចាកទីទៅខ្លះ ការចងចាំរបស់គេភ្លាំងភ្លេចខ្លះ នាគទាំងឡាយលួចទៅខ្លះ យក្សទាំងឡាយលួចទៅខ្លះ អ្នកទទួលមតិកមិនជាទីស្រឡាញ់ជីកយកទៅ កាលគេមិនឃើញខ្លះ ក្នុងវេលាដែលគេអស់បុណ្យ កំណប់ទ្រព្យទាំងនោះរមែងសូន្យបង់ទៅខ្លះ ។

**កំណប់ទ្រព្យ** គឺបុណ្យរបស់អ្នកណា ជាស្រ្តីក៏ដោយ ជាបុរសក៏ដោយ កប់ទុកល្អហើយដោយទាន សីល សញ្ញមៈការសង្រួម ទមៈការទូន្មានខ្លួន ចំពោះចេតិយ៍ក្តី ចំពោះសង្ឃក្តី ចំពោះបុគ្គលក្តី ចំពោះអាគន្តុកៈក្តី ចំពោះមាតាក្តី ចំពោះបិតាក្តី ចំពោះបងប្រុសស្រីក្តី កំណប់ទ្រព្យនោះ ឈ្មោះថា កប់ទុកល្អហើយ នរណា១ មិនអាចបំផ្លាញបាន ជារបស់ជាប់តាមខ្លួនទៅបាន បណ្តាភោគៈទាំងឡាយដែលគេលះហើយទៅ គេក៏នាំកំណប់ទ្រព្យ គឺបុណ្យនោះទៅផង ។ **កំណប់ទ្រព្យ** គឺបុណ្យមិនជាសាធារណៈដល់ជនដទៃ ចោរក៏លួចមិនបាន បុញ្ញ-និធិឯណាជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញគប្បីធ្វើបុញ្ញនិធិនោះ **បុញ្ញនិធិ** នោះ-ឱ្យផលដែលគួរប្រាថ្នាគ្រប់យ៉ាង ដល់ទេវតានិងមនុស្សទាំងឡាយ ការមានវណ្ណៈ

ល្អ សំឡេងពិរោះ ទ្រង់ទ្រាយល្អ រូបល្អ ភាពជាធំ មានបរិវារ ទេវតា និងមនុស្ស ប្រាថ្នានូវឥដ្ឋផលណាៗ ឥដ្ឋផលទាំងអស់នោះ រមែងបានដោយបុញ្ញនិធិ នេះឯង ។

ភាពជាព្រះរាជា សម្បត្តិរបស់មនុស្ស សេចក្ដីត្រេកអរក្នុងទេវលោក និង សម្បត្តិ គឺព្រះនិព្វានឯណា ឥដ្ឋផលទាំងអស់នោះ រមែងបានដោយបុញ្ញនិធិនេះ សេចក្ដីប្រាថ្នា វិជ្ជា វិមុត្តិ បដិសម្ភិទា វិមោក្ខ សាវ័កបារមី បច្ចេកពោធិ និងពុទ្ធ-ភូមិឯណា ឥដ្ឋផលទាំងអស់នោះ រមែងបានដោយបុញ្ញនិធិនេះ ។

**បុញ្ញសម្បទា** ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ធំយ៉ាងនេះ ព្រោះហេតុ ដូច្នោះ បណ្ឌិតអ្នកមានបញ្ញា រមែងសរសើរនូវភាពនៃបុគ្គលអ្នកមានបុណ្យធ្វើ ទុកហើយ ដូច្នេះ ។

ចប់ទេសនា កុដុម្ពិកៈនោះ តាំងនៅក្នុងសោតាបត្តិផល ព្រមដោយជន ជាច្រើន ហើយទើបចូលទៅគាល់ព្រះបាទបសេនទិកោសល ក្រាបទូលសេចក្ដី នោះ ព្រះរាជាទ្រង់ពេញព្រះទ័យក្រៃលែង ពោលសរសើរថា សាធុ គហបតី សាធុ គហបតី លោកកប់កំណប់ទ្រព្យទុកល្អហើយ ។

## ក្រោយពីចេញព្រះវស្សាទី ១៤ ហើយ

( ៧ ) ភិក្ខុភទ្ទវគ្គីយ៍ ៣០ រូប ដែលព្រះមានព្រះភាគទ្រង់ប្រទានឯហិភិក្ខុ កាលវស្សាដំបូងនៅឯព្រៃកប្បាស ចន្លោះឧរុវេលា និងពារាណសី បាននាំគ្នាទៅបំពេញព្យាយាមនៅបាថេយ្យរដ្ឋ ក្នុងដែនមល្លៈ និងបាវ៉ា សុទ្ធតែសមាទានអារញ្ញិកធុតង្គ បិណ្ឌបាតិកធុតង្គ និងតេចីវរិកធុតង្គ ព្រះភទ្ទវគ្គីយ៍ទាំង ៣០ រូបនោះ ភិក្ខុដែលខ្ពស់បំផុតត្រឹមព្រះអនាគាមី ភិក្ខុដែលទាបបំផុតត្រឹមសោតាបន្ន មិនមានអង្គណាជាព្រះអរហន្ត ឬជាបុថុជ្ជនឡើយ ។

កាលជិតចូលព្រះវស្សា បាននាំគ្នាធ្វើដំណើរទៅគាល់ព្រះពុទ្ធអង្គនៅក្រុងសាវត្ថី តែមិនអាចធ្វើដំណើរទៅឱ្យទាន់ថ្ងៃចូលវស្សាបាន ទើបនាំគ្នាចាំវស្សាក្នុងដែនសាកេត គ្រាចេញវស្សាធ្វើបវារណាស្រេចហើយ ទើបធ្វើដំណើរទៅគាល់ព្រះសាស្តា ព្រះមានព្រះភាគត្រាស់ទូន្មាន **អនមតគ្គធម្មទេសនា** ពោលអំពីពួកសត្វនៅមានអវិជ្ជារារាំង មានតណ្ហាជាគ្រឿងប្រកប ខាងដើមខាងចុងនៃសង្សារវដ្តរមែងមិនមានទីបំផុត ភិក្ខុទាំង ៣០ រូបបានសម្រេចអរហត្តផល ក្នុងអដ្ឋកថាពោលថា ក្នុងវេលាចប់ធម្មកថាព្រះថេរៈទាំង ៣០ រូបបានសម្រេចព្រះអរហត្តហើយបានហោះទៅក្នុងអាកាស អំពីទីដែលខ្លួនអង្គុយនោះឯងតែម្តង ។

( ៨ ) ខណៈនោះនៅមានភ្លៀងធ្លាក់ជោគជាំ ផ្ទៃដីពេញទៅដោយទឹក ការធ្វើដំណើរជួបសេចក្តីលំបាកជាច្រើន ទើបព្រះពុទ្ធអង្គលើកយករឿងរបស់ភិក្ខុភទ្ទវគ្គីយ៍ ៣០ រូបនេះ ជាដើមហេតុនៃការអនុញ្ញាតឱ្យភិក្ខុនៅចាំវស្សាគ្រប់

៣ ខែ ក្រាលកឋិនបាន ដោយបានអានិសង្ស ៥ ប្រការគឺ **ត្រាច់ទៅណាមិនបាច់លាភិក្ខុផងគ្នា ១ មិនចាំបាច់យកត្រៃចីវរជាប់ខ្លួនឱ្យគ្រប់ ១ ឆាន់-គណភោជនបាន ១ ទុកអតិរេកចីវរបានតាមត្រូវការ ១ ចីវរដែលកើតឡើងក្នុងទីនោះនឹងបានដល់ពួកលោក ១** ទើបវិធីក្រាលកឋិនមានតមករហូតបច្ចុប្បន្នសម័យនេះឯង ។

ទ្រង់បំពេញពុទ្ធកិច្ចក្នុងក្រុងសាវត្ថី តាមពុទ្ធបំណងហើយ យាងទៅកាន់ក្រុងកបិលពស្តុ **ដែនសក្កៈ** ដែលនៅផ្នែកខាងកើតនៃដែនកោសល ។

( ៩ ) ក្នុងគ្រាដែលព្រះយសត្ថេរបួសហើយ បាននាំសម្លាញ់ស្និទ្ធស្នាល ៤ នាក់ គឺ **គវម្បតិ បុណ្ណជិ វិមល សុពាហុ** ទៅគាល់ព្រះសាស្តា ដើម្បីទូលសូមបព្វជ្ជាឧបសម្បទា ព្រះពុទ្ធអង្គទ្រង់ប្រទានឯហិភិក្ខុឧបសម្បទា ក្នុងវេលាចប់ព្រះធម្មទេសនា លោកគ្រប់រូបតាំងនៅក្នុងព្រះអរហត្ត **ព្រះគវម្បតិត្ថេរ** កាលសម្រេចអរហត្តផលហើយ ខាងក្រោយមក ទៅសោយវិមុត្តិសុខនៅក្នុង អញ្ជន-វ័ន **ដែនសាកេត** ។ គ្រានោះ ព្រះមានព្រះភាគស្ដេចឆ្លងមក កាន់ដែនសាកេតព្រមដោយភិក្ខុសង្ឃមួយពួកធំ ទ្រង់គង់នៅក្នុង អញ្ជនវ័នវិហារ សេនាសនៈមិនគ្រប់គ្រាន់ ភិក្ខុជាច្រើននាំគ្នាដេកលើឆ្នេរខ្សាច់មាត់ស្ទឹងសរភូ ជិតព្រះវិហារ ។ សម័យនោះ ទឹកខុសរដូវកាលជន់មកក្នុងវេលាយប់ ពួកសាមណេរជាដើមស្រែកព្ញអឺងកង ព្រះមានព្រះភាគទ្រង់ជ្រាបហេតុនោះហើយ ត្រាស់ឱ្យព្រះ-គវម្បតិទៅរារាំងក្រសែទឹកនោះ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ហើយ ឃាត់ទឹក

ឱ្យឈប់ដោយកម្លាំងនៃឫទ្ធិ អន្លង់ទឹកបានឈប់តាំងនៅ ដូចកំពូលភ្នំពីចម្ងាយ តែម្តង ធ្វើឱ្យភិក្ខុ និងសាមណេរទាំងឡាយផុតចាកទឹកជំនន់ អានុភាពរបស់ព្រះថេរៈបានប្រាកដហើយក្នុងលោក ។

ថ្ងៃមួយ ព្រះពុទ្ធអង្គទតឃើញព្រះថេរៈសម្តែងធម៌ កណ្តាលបរិស័ទជាច្រើន ទ្រង់បានសរសើរ និងប្រកាសគុណរបស់ព្រះគវម្បតិ ដើម្បីអនុគ្រោះសត្វលោក ត្រាស់ព្រះគាថាថា **ទេវតា និងមនុស្សទាំងឡាយនាំគ្នានមស្ការព្រះគវម្បតិ អ្នកហាមស្ទឹងសរភូឱ្យឈប់ហូរបានដោយឫទ្ធិ មិនជាប់នៅក្នុងកិលេស និងតណ្ហាណាៗ ជាមហាមុនី ជាអ្នកដល់ច្រាំងនៃភពហើយ** ដូច្នេះ ។ ក្នុងវេលាចប់ព្រះគាថា ធម្មាភិសម័យបានកើតដល់មហាជនជាច្រើន ។

( ១០ ) ក្រោយមក ព្រះអង្គយាងបន្តទៅកាន់ក្រុងកបិលពស្តុ សក្កជនបទ ទ្រង់គង់ក្នុងនិគ្រោធារាម **ស្តេចសក្យមហានាម** មានភេសជ្ជៈច្រើន ទើបចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា ខ្ញុំព្រះអង្គបំណងនឹងបវារណាចំពោះសង្ឃ ដោយភេសជ្ជប្បច្ច័យរហូត ៤ ខែ ព្រះអង្គ ។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ល្អមហានាម ! អ្នកចូរបវារណាចំពោះសង្ឃ ដោយភេសជ្ជប្បច្ច័យរហូត ៤ ខែចុះ គ្រានោះភិក្ខុទាំងឡាយមិនទទួលការបវារណា បានក្រាបទូលសេចក្តីនោះចំពោះព្រះសាស្តា ទើបព្រះសាស្តាទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតឱ្យត្រេកអរនូវការបវារណាដោយបច្ច័យ ៤ រហូត ៤ ខែបាន ។

ក្នុងសម័យនោះ ភិក្ខុទាំងឡាយសូមបច្ច័យពីមហានាមសក្យៈ ត្រឹមតែ

បន្តិចបន្តួចប៉ុណ្ណោះ បច្ច័យរបស់សក្យមហានាមក៏នៅសល់ច្រើនដូចដើម សក្យមហានាមបានចូលទៅក្រាបទូលព្រះមានព្រះភាគថា ខ្ញុំព្រះអង្គប្រាថ្នានឹងបវារណាត ៤ ខែទៀតព្រះអង្គ សូម្បីដូច្នោះ ភេសជ្ជប្បច្ច័យក៏នៅមានច្រើន ក្នុងគ្រាទី ៣ ទើបសូមបវារណារហូតមួយជីវិត ព្រះមានព្រះភាគទ្រង់អនុញ្ញាត ឱ្យត្រេកអរក្នុងការបវារណាភេសជ្ជប្បច្ច័យជានិច្ចបាន ។

( ១១ ) ក្រៅពីនោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្ដែង **អប្បមាទសូត្រ** ដល់ភិក្ខុទាំងឡាយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដានជើងរបស់សត្វទាំងពួងត្រាច់ទៅលើផែនដីឯណាមួយ ដានជើងទាំងអស់នោះ រមែងរួមចុះក្នុងដានជើងដំរី ព្រោះដានជើងដំរី ធំជាងបណ្ដាដានជើងរបស់សត្វទាំងពួងក្នុងលោកយ៉ាងណាមិញ កុសលធម៌ពួកណាមួយ កុសលធម៌ទាំងអស់នោះរមែងរួមចុះក្នុងសេចក្ដីមិនប្រមាទដូច្នោះឯង បណ្ឌិតពោលថា ការមិនប្រមាទជាកំពូលរបស់កុសលធម៌ទាំងអស់ ។

**ឫសក្រឹស្នា** ជាកំពូលនៃក្លិនក្រអូប ក្នុងបណ្ដាក្លិនដែលកើតអំពីឫសឈើទាំងឡាយ យ៉ាងណាមិញ កុសលធម៌ណាមួយក៏ដូច្នោះ រមែងរួមចុះក្នុងសេចក្ដីមិនប្រមាទ ។

**ចន្ទន៍ក្រហម** ជាកំពូលនៃក្លិនក្រអូប ក្នុងបណ្ដាក្លិនដែលកើតអំពីខ្លឹមឈើទាំងឡាយ យ៉ាងណាមិញ កុសលធម៌ពួកណាមួយក៏ដូច្នោះ រមែងរួមចុះក្នុងសេចក្ដីមិនប្រមាទ ។

**ផ្កាម្លិះ** ជាកំពូលនៃក្លិនក្រអូប ក្នុងបណ្ដាក្លិនដែលកើតអំពីផ្កាឈើទាំងឡាយ យ៉ាងណាមិញ កុសលធម៌ណាមួយក៏ដូច្នោះ រមែងរួមចុះក្នុងសេចក្ដីមិនប្រមាទ ។

**មហាសមុទ្រ** ជាកំពូលនៃស្ទឹងទាំងឡាយ សូម្បីស្ទឹងធំច្រើនខ្សែ គឺស្ទឹងគង្គា យមុនា អចិរវតី សរភូ មហី សូម្បីស្ទឹងទាំងអស់នោះ រមែងហូរទៅកាន់មហាសមុទ្រ យ៉ាងណាមិញ កុសលធម៌ណាមួយក៏ដូច្នោះ រមែងរួមចុះក្នុងសេចក្ដីមិនប្រមាទ បណ្ឌិតពោលថា សេចក្ដីមិនប្រមាទជាកំពូលនៃកុសលធម៌ទាំងអស់ ។

អដ្ឋកថាពោលថា **ព្រះបាទភាតិយមហារាជ** ទ្រង់ស្ដាប់ព្រះសូត្រនេះហើយ បំណងនឹងសាកល្បង ទើបដាក់ផ្កាម្លិះទុកកណ្ដាលមួយបន្ទប់ៗ ១ ហើយនាំយកផ្កាឈើក្រអូបដទៃ ៤ ប្រភេទទៀតដាក់ជុំវិញផ្កាម្លិះនោះ ទ្រង់បិទទ្វារហើយយាងចេញទៅខាងក្រៅ ឈប់ខាងក្រៅមួយស្របក់ បើកទ្វារយាងចូលទៅក្នុងបន្ទប់ ក្លិនក្រអូបរបស់ផ្កាម្លិះប៉ះខ្ទប់ព្រះនាសិកមុនក្លិនផ្កាឈើដទៃ ព្រះបាទភាតិយមហារាជទ្រង់បែរព្រះភក្ត្រទៅរកព្រះមហាចេតិយ ទ្រង់ថ្វាយបង្គំព្រះចេតិយព្រមទទួលថា ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ត្រាស់ថា ផ្កាម្លិះជាកំពូលនៃគន្ធជាតិនោះ **ទ្រង់ត្រាស់ទុកដោយប្រពៃហើយ។**

# ព្រះវស្សាទី ១៥

## ទ្រង់គង់ចាំព្រះវស្សា ក្នុងនិគ្រោធារាម ក្រុងកបិលពស្តុ

(១) ពួកស្តេចសក្យៈ កសាងសាលាថ្មីមួយខ្នង ថ្វាយចំពោះព្រះពុទ្ធអង្គឱ្យទ្រង់ប្រើប្រាស់ជាមុន ព្រះពុទ្ធអង្គទ្រង់ទទួលដោយតុណ្ហីភាព ទ្រង់ប្រោសពួកស្តេចសក្យៈឱ្យឃើញច្បាស់ ឱ្យសមាទាន ឱ្យអាចហ៊ាន ឱ្យរីករាយដោយធម្មីកថាអស់រាត្រីជាច្រើន ហើយត្រាស់អានិសង្សរបស់ការថ្វាយអាវាសទានថា ម្នាលមហាបពិត្រ ការថ្វាយទីសំណាក់អាស្រ័យ ជាទានធំ សេនាសនៈរបស់ពួកមហាបពិត្រ តថាគតក៏បានប្រើប្រាស់ហើយ ព្រះភិក្ខុសង្ឃប្រើប្រាស់ហើយ ព្រះធម្មរតនៈក៏ប្រើប្រាស់ហើយដូចគ្នា ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ព្រះរតនៈទាំង ៣ ប្រើប្រាស់ហើយ ក៏កាលពួកអ្នកថ្វាយអាវាសទានហើយ ទានទាំងពួង ក៏ឈ្មោះថា ថ្វាយហើយដូចគ្នា អានិសង្សរបស់បណ្ណសាលាដែលតាំងនៅលើផ្ទៃដីក្តី មណ្ឌបដែលតាំងនៅលើដើមឈើក្តី រមែងជាប្រយោជន៍ទាំងអស់ ព្រោះថា :

**វិហាររមែងកាពារ រងា ក្តៅ ភ្លៀង ខ្យល់ និងកំដៅថ្ងៃ**
**ឱ្យធូរស្រាល រមែងការពារឱ្យផុតចាកពស់ របោមមូស**
**និង សត្វកាចទាំងឡាយ ការថ្វាយវិហារដល់សង្ឃ ដើម្បី**
**នៅសម្ងំ ដើម្បីពិចារណាឈាន ដើម្បីចម្រើនវិបស្សនា**
**ព្រះពុទ្ធទាំងឡាយសរសើរថា ជាទានដ៏កំពូល ។**

ទ្រង់មានតម្រាស់ឱ្យព្រះអានន្ទសម្តែង សេក្ខបដិបទា តអំពីព្រះអង្គ

ដើម្បីព្រះអង្គទ្រង់សម្រេចសីហសេយ្យា ដោយមានពុទ្ធបំណងនឹងប្រើប្រាស់សាលានេះដោយឥរិយាបថទាំង ៤ អដ្ឋកថាពោលថា ទ្រង់ប្រគល់ភារៈឱ្យព្រះ-អានន្ទ ព្រោះទ្រង់ជ្រាបអធ្យាស្រ័យរបស់ស្តេចសក្យៈទាំងនោះថា ប្រាថ្នាក្នុងធម្មិកថារបស់ព្រះអានន្ទជាពហូសូត្រ ដែលពោលធម្មិកថាបានពិរោះ មានបទព្យញ្ជនៈដ៏ល្អល្អះ ។ ម្យ៉ាងទៀត ទ្រង់ព្រះតម្រិះថា ស្តេចសក្យៈទាំងនេះប្រាថ្នាមង្គលសេក្ខបដិបទាជា **មង្គលបដិបទា** ដែលព្រះអានន្ទក៏សម្រេចសេក្ខបដិបទារមែងអាចធ្វើឱ្យសក្យៈទាំងនោះ យល់បានដោយមិនលំបាក ទើបទ្រង់កំណត់ឱ្យព្រះអានន្ទជាអ្នកសម្តែងបដិបទានេះ ។

ព្រះអានន្ទ ទើបសម្តែងសេក្ខបដិបទានឹងព្រះមហានាម ក្នុងឋានៈជា-ប្រធាននៃពួកសក្យៈថា **អរិយសាវ័កក្នុងធម្មវិន័យនេះ ជាអ្នកដល់ព្រមដោយសីល គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ៍ទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបព្យាយាមជាគ្រឿងភ្ញាក់រឭក ប្រកបដោយសប្បុរិសធម៌ ៧ ប្រការ ជាអ្នកបានឈាន ៤ ជាគ្រឿងនៅ និងជាសុខក្នុងធម៌ដែលឃើញហើយដោយមិនលំបាក ។**

**សប្បុរិសធម៌ ៧ ប្រការ** បានដល់ សទ្ធា ហិរិ ឱត្តប្បៈ ពហុស្សុតៈ វិរិយៈ សតិ និងបញ្ញា កាលព្រះអានន្ទសម្តែងចប់ ព្រះពុទ្ធអង្គទ្រង់ត្រេកអរ ត្រាស់ថា សាធុ សាធុ អានន្ទ អ្នកបានពោលសេក្ខបដិបទា ដល់ពួកស្តេចសក្យៈត្រឹមត្រូវល្អហើយ ស្តេចសក្យៈរីករាយក្នុងធម្មិកថារបស់ព្រះអានន្ទ ថ្វាយបង្គំលា

ព្រះសាស្តា ហើយយាងត្រឡប់ទៅ ។

កាលស្តេចសក្យៈ យាងត្រឡប់ទៅមិនយូរ ព្រះអង្គត្រាស់ឱ្យព្រះមហាមោគ្គល្លានសម្តែង **អវស្សុតសូត្រ** និង **អនវស្សុតសូត្រ** ដល់ភិក្ខុទាំងឡាយ អធិប្បាយអាយតនៈខាងក្នុង ៦ អាយតនៈខាងក្រៅ ៦ ឱ្យភិក្ខុសង្រួមរវាំងទ្វារ ៦ ជាអ្នកមានចិត្តមិនជ្រុបក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ កុំបើកឱកាសឱ្យមារបានផ្លូវ បានហេតុ បានឱកាស ព្រោះហេតុដែលភិក្ខុសង្រួមហើយ ក្នុងអាយតនៈទាំងឡាយ រមែងដឹងច្បាស់នូវបញ្ហាដែលជាទីរលត់ទៅនៃអកុសលធម៌ កាលព្រះមហាមោគ្គល្លានពោលភាសិតនេះចប់ ព្រះអង្គត្រាស់ថា សាធុ សាធុ មោគ្គល្លាន អ្នកពោលបរិយាយដល់ភិក្ខុទាំងឡាយល្អហើយ ។

(២) គ្រាត្រឡប់មក ទ្រង់គង់ក្នុងនិគ្រោធារាម ហើយព្រះអង្គទ្រង់ប្រារព្ធដល់ស្តេចសក្យៈ ព្រះនាមថា **សុប្បពុទ្ធ** ដែលជាព្រះបិតារបស់ព្រះនាងពិម្ពាយសោធរាមាតាព្រះរាហុល ។ ក្នុងធម្មបទពោលទុកថា ព្រះបាទសុប្បពុទ្ធចងអាឃាតជាមួយនឹងព្រះអង្គដោយហេតុ ២ ប្រការគឺ **១. ព្រះសមណគោតមបោះបង់ចោលកូនស្រីយើងហើយចេញបួស ២. ព្រះសមណគោតមឱ្យកូនប្រុសយើង (ទេវទត្ត) បួសហើយ ត្រឡប់តាំងខ្លួនចងពៀរចំពោះកូនប្រុសរបស់យើង ។**

ថ្ងៃមួយព្រះបាទសុប្បពុទ្ធត្រិះរិះថា យើងនឹងមិនឱ្យព្រះសមណគោតមទៅបិណ្ឌបាត ទើបបញ្ជាឱ្យរាំងផ្លូវដែលព្រះអង្គទ្រង់យាងឆ្លងកាត់ ហើយអង្គុយ

សោយទឹកចំណ្អកក្នុងចន្លោះផ្លូវនោះ កាលព្រះពុទ្ធអង្គយាងមកដល់ មិនមានផ្លូវ-ទៅ ព្រោះត្រូវបិទរាំង ទើបយាងត្រឡប់វិញ ត្រាស់នឹងព្រះអានន្ទថា ព្រះបាទសុប្បពុទ្ធមិនឱ្យផ្លូវដល់ព្រះពុទ្ធជាម្ចាស់ ឈ្មោះថា ធ្វើកម្មធ្ងន់ណាស់ ក្នុងថ្ងៃទី ៧ រាប់ពីថ្ងៃនេះទៅ ទ្រង់នឹងត្រូវធរណីស្រូបនៅជិតជើងជណ្ដើរខាងក្នុងប្រាសាទរបស់ទ្រង់នុ៎ះឯង ។

ព្រះបាទសុប្បពុទ្ធបញ្ជូនមនុស្សទៅសឹបការ បានទទួលស្ដាប់ពាក្យរបស់បុរសនោះហើយ ទើបប្រុងប្រយ័ត្នព្រះអង្គយ៉ាងតឹងរឹងបំផុត ឡើងទៅនៅលើប្រាសាទជាន់ទី ៧ ហើយដោះជណ្ដើរចេញ បិទទ្វារ ចាត់មនុស្សមាំៗ ចាំត្រង់ទ្វារ មួយទ្វារពីរនាក់ៗ ទ្រង់គង់តែក្នុងបន្ទប់លើប្រាសាទជាន់ទី ៧ ។ លុះដល់ថ្ងៃទី ៧ ជាវេលាស្មើគ្នានឹងការបិទផ្លូវព្រះពុទ្ធអង្គ សេះមង្គលរបស់ព្រះបាទសុប្បពុទ្ធ ស្រែកកញ្ជ្រោលលើកជើងប្រាយជញ្ជាំង ព្រះបាទសុប្បពុទ្ធបំណងនឹងចាប់សេះនោះឱ្យបាន ទើបចេញចាកទីគង់នៅ ឈានព្រះបាទមករកទ្វារដែលបិទយ៉ាងណែននោះ តែព្រោះកម្មអាក្រក់នឹងឱ្យផល ទ្វារប្រាសាទជាន់ទី ៧ ក៏របើកឯង ជណ្ដើរដែលដោះចេញក៏ត្រឡប់មកតាំងនៅដូចដើម កាលព្រះបាទសុប្បពុទ្ធឈានព្រះបាទចុះដល់ផែនដី ផែនដីក៏បើកចន្លោះទទួលយកទៅ ស្រូបលិចចុះទៅកើតក្នុងអវិចិមហានរក ។

ព្រះសាស្ដាទ្រង់ស្ដាប់រឿងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទសុប្បពុទ្ធមិនថា អង្គុយនៅលើប្រាសាទប៉ុណ្ណោះទេ សូម្បីតែហោះទៅកាន់លើ

អាកាសក្តី ទៅកាន់មហាសមុទ្រដោយទូកក្តី ចូលទៅសម្ងំនៅក្នុងរូងភ្នំក្តី ទ្រង់ក៏នឹងត្រូវធរណីស្រូបក្នុងទីនោះៗ ហើយត្រាស់ព្រះគាថាថា :

**បុគ្គលដែលធ្វើកម្មអាក្រក់ទុកហើយ នឹងគេចទៅក្នុងអាកាស**
**គេចទៅក្នុងកណ្តាលមហាសមុទ្រ គេចទៅកាន់ញកភ្នំ សូម្បី**
**នឹងនៅក្នុងផែនដីណា ក៏មិនអាចផុតចាកកម្មអាក្រក់បាន ។**

(៣) សម័យនោះ **ស្តេចសរកានិសក្យៈ** អស់ព្រះជន្ម ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ព្យាករថា ស្តេចសរកានិជាព្រះសោតាបន្ន ជាអ្នកទៀងតែនឹងត្រាស់ដឹងក្នុងខាងមុខ ពួកស្តេចសក្យៈមកប្រជុំគ្នា សង្ស័យថា ស្តេចសរកានិសក្យៈជាអ្នកទ្រុស្តសីល សោយទឹកច័ណ្ឌ ហេតុអ្វីទើបព្រះអង្គព្យាករណ៍ថា បានជាព្រះសោតាបន្ន ? ស្តេចសក្យមហានាមចូលទៅគាល់ព្រះសាស្តា ក្រាបទូលសួរសេចក្តីនេះ ព្រះពុទ្ធអង្គត្រាស់ថា មហាបពិត្របុគ្គលពួកខ្លះក្នុងលោកនេះមិនជ្រះថ្លាក្នុងព្រះរតនត្រ័យ មិនមានបញ្ញា មិនប្រកបដោយវិមុត្តិ តែគេមានសទ្ធាមានសេចក្តីស្រឡាញ់ក្នុងតថាគត បុគ្គលសូម្បីនេះក៏មិនបានទៅកាន់នរកអាបាយ ទុគ្គតិ វិនិបាត ចំណែកសរកានិសក្យៈ ក្រៅពីមានសទ្ធាចំពោះ តថាគតហើយ **គេបានធ្វើឱ្យបរិបូរណ៍ក្នុងសិក្ខា ក្នុងវេលានឹងអស់ព្រះជន្ម** ទៀតផង ទើបតថាគតព្យាករណ៍ថា **សរកានិសក្យៈ ជាព្រះសោតាបន្នបុគ្គល ។**

(៤) កាលគង់នៅនិគ្រោធារាម ព្រះមានព្រះភាគទ្រង់ប្រារព្ធរឿងរបស់**ព្រះនាងរោហិណី** ថា ក្នុងសម័យមួយ ព្រះអនុរុទ្ធបានមកទីក្រុងកបិលពស្តុ

ព្រមដោយភិក្ខុ ៥០០ ទើបពួកព្រះញាតិរបស់លោក បានមកកាន់សំណាក់ព្រះថេរៈ វៀរតែព្រះនាងរោហិណីជាព្រះភគិនី ហេតុដែលព្រះនាងមិនមក ព្រោះរោគស្រែងកើតត្រង់សរីរៈរបស់ព្រះនាង ។

ទើបព្រះអនុរុទ្ធត្ថេរណែនាំឱ្យព្រះនាងសាងរោងឆាន់ ព្រះនាងបានលក់គ្រឿងប្រដាប់ដើម្បីសាងរោងឆាន់ ព្រះថេរៈ និងពួកញាតិបានជួយគ្នាមើលការកសាង ព្រះថេរៈណែនាំឱ្យព្រះនាងរោហិណីធ្វើរោងឆាន់ជា ២ ជាន់ ឱ្យក្រាលអាសនៈទុកត្រង់ជាន់ក្រោម តាំងឆ្នាំងទឹកផឹក ហើយបោសផ្ទៃសាលាជានិច្ច ។ ព្រះនាងបោសសាលាធ្វើឱ្យស្អាតជានិច្ច រោគស្រែងរបស់ព្រះនាងក៏បាត់ទៅ កាលរោងឆាន់ស្រេចហើយ ព្រះនាងនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ ហើយបានថ្វាយខាទនីយភោជនីយាហារដ៏ប្រណីត ចំពោះភិក្ខុពេញរោងឆាន់ កាលសម្រេចភត្តកិច្ចហើយ ព្រះពុទ្ធអង្គត្រាស់សួរថា នេះជាទានរបស់អ្នកណា ព្រះថេរៈទូលថា ជារបស់រោហិណី ព្រះនាងជាប្អូនរបស់ខ្ញុំព្រះអង្គ ទើបព្រះសាស្ដាទ្រង់ត្រាស់ឱ្យហៅព្រះនាងមក សូម្បីមិនចង់មកក៏ដោយ លុះមកគាល់តាមដែលព្រះអង្គឱ្យហៅមក ព្រះសាស្ដាត្រាស់សួរថា នាងដឹងទេថា រោគនោះអាស្រ័យកម្មអ្វីរបស់នាង ព្រះនាងទូលថាមិនដឹងទេ ព្រះអង្គត្រាស់ថា រោគរបស់នាងកើតឡើងព្រោះសេចក្ដីក្រោធ ហើយយកខ្ទេរទៅដាក់លើអ្នកដទៃ ដែលជាស្រីរួមប្ដីជាមួយគ្នា ហើយត្រាស់សម្ដែងព្រះគាថាថា :

**បុគ្គលគប្បីលះសេចក្ដីក្រោធ លះការប្រកាន់ខ្លួន កន្លង-**

**បង់ សំយោជនៈទាំងអស់បាន ទុក្ខទាំងឡាយ រមែងមិន**

**ពាល់ត្រូវបុគ្គលនោះ ជាអ្នកមិនមានកិលេសជាគ្រឿងកង្វល់ ។**

ក្នុងកាលចប់ទេសនា ជនទាំងឡាយសម្រេចអរិយផលដ៏ច្រើន មានសោតាបត្តិផលជាដើម ព្រះនាងរោហិណីតាំងនៅហើយក្នុងសោតាបត្តិផល សរីរៈរបស់ព្រះនាងក៏មានវណ្ណៈដូចមាស ក្នុងខណៈនោះឯង ព្រះនាងចុតិចាកអត្តភាពនោះហើយ ទៅកើតក្នុងស្ថានតាវត្តិង្ស ។

(៥) ថ្ងៃមួយ ខណៈដែលព្រះមានព្រះភាគគង់នៅនិគ្រោធារាម **ស្តេចសក្យមហានាម** ទៅទូលសួរថា បុគ្គលដូចម្តេច ទើបឈ្មោះថា **ឧបាសក** ព្រះ-មានព្រះភាគត្រាស់ថា អ្នកដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាសរណៈ ឈ្មោះថា **ឧបាសក** ស្តេចសក្យមហានាមទូលសួរតទៅថា ឧបាសកអ្នកមានសីលដូចម្តេច ? ព្រះអង្គត្រាស់ថា ឧបាសកជាអ្នកវៀរចាក បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ និងវៀរចាកការផឹកទឹកស្រវឹង **ឧបាសកនោះឈ្មោះថា ជាអ្នកមានសីល** ។ ទូលសួរទៀតថា ឧបាសកត្រូវបដិបត្តិដូចម្តេចទើបឈ្មោះថា ជាអ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួន ព្រះមានព្រះភាគត្រាស់ថា អ្នកដល់ព្រមដោយ សទ្ធា ១ អ្នកដល់ព្រមដោយសីល ១ អ្នកដល់ព្រមដោយចាគៈ ១ ជាអ្នកប្រាថ្នាក្នុងការស្តាប់ព្រះសទ្ធម្ម ១ ជាអ្នកចងចាំធម៌ដែលខ្លួនស្តាប់ហើយ ១ ជាអ្នកពិចារណាអត្ថនៃធម៌ដែលខ្លួនស្តាប់ ១ ខ្លួនឯងដឹងច្បាស់នូវអត្ថនិងធម៌ហើយបដិបត្តិធម៌សមគួរដល់ធម៌ ១ ឈ្មោះថា **ជាឧបាសកអ្នកបដិបត្តិ-**

**ដើម្បីប្រយោជន៍ខ្លួនឯង ។**

ចំណែកអ្នកដែលខ្លួនឯងដល់ព្រមដោយសីល សទ្ធា ចាគៈ ។ល។ ដឹកនាំអ្នកដទៃឱ្យដឹងផង ប្រព្រឹត្តផង ឈ្មោះថា **ឧបាសកជាអ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួន និងដើម្បីប្រយោជន៍អ្នកដទៃ ។**

ក្រៅពីនោះ ស្ដេចមហានាមសក្យៈនៅបានទូលសួរដល់ធម៌ដែលលះមិនបានថា បពិត្រព្រះអង្គដ៏ចម្រើន **លោភធម៌ ទោសធម៌ មោហធម៌** នៅគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គបានម្ដងម្កាល ខ្ញុំព្រះអង្គសូមក្រាបទូលសួរថា ធម៌អ្វីទៅដែលខ្ញុំព្រះអង្គនៅលះមិនបានដាច់ ដែលជាហេតុឱ្យអកុសលធម៌ពួកនោះ នៅគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គបានម្ដងម្កាល ? ព្រះអង្គត្រាស់ថា មហាបពិត្រ **កាមគុណ ៥ នោះឯង** ជាហេតុឱ្យព្រះអង្គត្រូវលោភៈ ទោសៈ និងមោហៈគ្របសង្កត់ចិត្តបានម្ដងម្កាល ដូច្នេះព្រោះព្រះអង្គនៅលះធម៌ទាំងនោះមិនទាន់បានដាច់ស្រឡះ ។ ថែមទាំងសម្ដែងទោសរបស់កាមដែលមានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ត្រាស់ថា ពួកជនដែលប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត បន្ទាប់ពីស្លាប់ ព្រោះកាយបែកទៅ ជនទាំងនោះរមែងទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក ទោសរបស់កាមទាំងឡាយជាទុក្ខក្នុងសម្បរាយិក-ភព មានកាមជាដើមហេតុ មានកាមនាំឱ្យកើត ។

ម្នាលមហានាម សេចក្ដីសុខ សោមនស្សណា អាស្រ័យកាមគុណ ៥ គឺរូបគប្បីដឹងច្បាស់ដោយចក្ខុ សំឡេងគប្បីដឹងច្បាស់ដោយសោតៈ ក្លិនគប្បីដឹង

ច្បាស់ដោយឃានៈ រសគប្បីដឹងច្បាស់ដោយជិវ្ហា ផោដ្ឋព្វៈគប្បីដឹងច្បាស់ដោយកាយ ទាំងអស់នេះកើតឡើង នេះជាគុណរបស់កាមទាំងឡាយ ។ ម្នាលមហានាម អរិយសាវ័ករមែងពិចារណាឃើញដោយបញ្ញា ដោយប្រពៃតាមពិត មិនប្រកបខ្លួនឱ្យជាប់ជំពាក់ដោយសុខក្នុងកាមជាទីបំផុត និងមិនប្រកបខ្លួនឱ្យលំបាកជាទីបំផុត សាសនារបស់តថាគតផុតចាកទីបំផុតទាំងពីរយ៉ាងនេះ ហើយទ្រង់លើករឿងរបស់និគ្រន្ថជាឧទាហរណ៍ក្នុង **ចូឡទុក្ខខន្ធសូត្រ** ស្ដេចសក្យមហានាម ទ្រង់មានព្រះទ័យរីករាយត្រេកអរ ចំពោះភាសិតរបស់ព្រះមានព្រះភាគជាម្ចាស់ ដូច្នេះ ។

ជិតចេញព្រះវស្សា ព្រះមហានាមទ្រង់ជ្រាបដំណឹងថា ព្រះមានព្រះភាគនឹងយាងចារិក ទើបចូលទៅគាល់ ក្រាបទូលសួរដល់វិហារធម៌ ក្នុងចន្លោះពេលដែលព្រះអង្គយាងចារិក ទៅប្រោសវេនេយ្យសត្វតាមស្រុកនិគមផ្សេងៗ ។ ព្រះមានព្រះភាគត្រាស់ថា មហាបពិត្រ ទ្រង់តាំងនៅក្នុងធម៌ ៥ ប្រការគឺ **សទ្ធា វិរិយៈ សតិ សមាធិ និង បញ្ញា** ហើយគប្បីចម្រើន ធម៌ ៦ ប្រការឱ្យក្រៃលែងឡើងទៅ គឺទ្រង់ចម្រើន **ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ ចាគានុស្សតិ សីលានុស្សតិ និងទេវតានុស្សតិ** ។

ម្នាលមហាបពិត្រ ធម៌ទាំងនេះ សូម្បីព្រះអង្គនឹងយាង ទ្រង់ឈរ ទ្រង់អង្គុយ ទ្រង់ផ្ទំ ឬទ្រង់ប្រកបភារកិច្ចក៏ដោយ រមែងចម្រើនបានគ្រប់ពេលវេលា ។

# ក្រោយអំពីចេញព្រះវស្សាទី ១៥ ហើយ

## មិនមានសម្តែងលំអិតថា

## ព្រះអង្គយាងចារិកទៅកាន់ទីណាខ្លះឡើយ

# ព្រះវស្សាទី ១៦

## ទ្រង់គង់ចាំព្រះវស្សានៅ ក្នុងអគ្គាឡវចេតិយ៍ ដែនអាឡវី

(១) គ្រានោះ ព្រះពុទ្ធអង្គទ្រង់ប្រមើលមើលសត្វលោក បំណងនឹងប្រោសអាឡវកយក្ខ ទើបយាងទៅកាន់លំនៅរបស់យក្ខ គទ្រភៈដែលយាមទ្វារឃើញព្រះអង្គទើបទូលនិមន្តចូលទៅខាងក្នុងលំនៅ ឱ្យគង់លើបល្ល័ង្ករបស់អាឡវកយក្ខ ហើយទៅប្រាប់ឱ្យអាឡវកយក្ខជ្រាប អាឡវកយក្ខខឹងក្រោធ ប្រញាប់ត្រឡប់មកកាន់សំណាក់របស់ខ្លួន ព្យាយាមអារាធនាឱ្យព្រះអង្គចុះចាកបល្ល័ង្ក តែទោះបីធ្វើយ៉ាងណាក៏មិនសម្រេច ទើបអារាធនាឱ្យព្រះអង្គចេញទៅចាកអាសនៈ ហើយនិមន្តឱ្យត្រឡប់ចេញចូលដល់ ៣ ដង ព្រះអង្គទ្រង់បដិបត្តិតាមទាំង ៣ ដង ក្នុងលើកទី ៤ ទ្រង់បដិសេធ ។

អាឡវកយក្ខក្រាបទូលថា ម្នាលសមណៈ ខ្ញុំនឹងសួរបញ្ហា បើលោកមិនព្យាករណ៍ដល់ខ្ញុំសោត ខ្ញុំនឹងច្របាច់បេះដូងរបស់លោក ឬនឹងចាប់ជើងទាំងពីររបស់លោកហើយគ្រវែងទៅត្រើយម្ខាងនៃស្ទឹងគង្គា ។ ព្រះពុទ្ធអង្គត្រាស់ថា ម្នាលអាឡវកយក្ខ ក្នុងលោកនេះ គ្មានអ្នកណាអាចបៀតបៀនតថាគតបានឡើយ តែបើអ្នកប្រាថ្នានឹងសួរបញ្ហាណា ក៏ចូរសួរមកចុះ ។ ទើបអាឡវកយក្ខទូលសួរបញ្ហា ដែលបិតារបស់ខ្លួនធ្លាប់ទូលសួរព្រះកស្សបសម្មាសម្ពុទ្ធ និងព្រះកស្សបសម្មាសម្ពុទ្ធបានឆ្លើយទុកហើយតាំងពីអតីតៈ សេចក្តីនោះ អាឡវកៈបានចារិកទុកលើផ្ទាំងមាស ដើម្បីការពារកុំឱ្យភ្លេច និងរក្សាទុកក្នុងសំណាក់របស់ខ្លួន

រហូតមក បញ្ហាទាំងនោះគឺ :

អ្វីជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោក

អ្វីដែលបុគ្គលប្រព្រឹត្តល្អហើយនាំសុខមកឱ្យ

អ្វីជារសដ៏ឆ្ងាញ់ជាងរសទាំងឡាយ

ជីវិតដូចម្តេច ប្រសើរបំផុត

អ្នកឆ្លងឱឃៈបាន ដោយអ្វី

អ្នកឆ្លងអណ្ណវៈ គឺសង្សារសាគរបានដោយអ្វី

អ្នកឈានកន្លងទុក្ខបាន ដោយអ្វី

អ្នកបរិសុទ្ធបាន ដោយអ្វី

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ឆ្លើយបញ្ហាអាឡវកយក្ខ ត្រូវនឹងព្រះ-កស្សបសម្ពុទ្ធជាម្ចាស់ឆ្លើយទុកគ្រប់ចំណុច ដូច្នេះគឺ :

សទ្ធា ជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោក

ធម្មៈ ជាវត្ថុដែលប្រព្រឹត្តហើយនាំសុខមកឱ្យ

សច្ចៈ ជារសដ៏ឆ្ងាញ់ជាងរសទាំងឡាយ

បញ្ញា ជាការប្រសើរបំផុតរបស់ជីវិត

បុគ្គលឆ្លងឱឃៈបានដោយសទ្ធា

បុគ្គលកន្លងទុក្ខបានដោយការព្យាយាម

បុគ្គលឆ្លងអណ្ណវៈបានដោយការមិនប្រមាទ

## បុគ្គលបរិសុទ្ធបានដោយបញ្ញា

ចប់ការសម្តែងរបស់ព្រះពុទ្ធអង្គ អាឡវកយក្ខបានសម្រេចសោតាបត្តិ-ផល ក្រាបទូលព្រះពុទ្ធអង្គថា ថ្ងៃនេះខ្ញុំព្រះអង្គបានជ្រាបច្បាស់នូវប្រយោជន៍ដែលនឹងប្រព្រឹត្តទៅក្នុងភពខាងមុខ ព្រះអង្គទ្រង់យាងមកកាន់ក្រុងអាឡវី ក៏ដើម្បីប្រយោជន៍ដល់ខ្ញុំព្រះអង្គដោយពិត ថ្ងៃនេះខ្ញុំព្រះអង្គបានជ្រាបច្បាស់នូវទក្ខិណេយ្យបុគ្គលដ៏កំពូល ដែលបុគ្គលថ្វាយទានហើយ ជាទានមានផលច្រើន មានអានិសង្សច្រើន ខ្ញុំព្រះអង្គសូមនមស្ការព្រះស្មាសម្ពុទ្ធជាម្ចាស់ ព្រះធម៌ និងព្រះសង្ឃ តាំងពីឥឡូវនេះជាដើមទៅ ។

ក្រៅពីនោះ អាឡវកយក្ខក៏បានទូលសួរដល់បញ្ហាដទៃៗ ទៀតច្រើនចំណុច កាលព្រះសាស្តាទ្រង់ទូន្មានអាឡវកយក្ខហើយ បានប្រទានបាត្រ និងចីវរទុកក្នុងដៃរបស់អាឡវកយក្ខ ទ្រង់យាងចូលនគរអាឡវីព្រមដោយអាឡវយក្ខនោះ ។

(២) គ្រានោះ ទារិកាឈ្មោះ **សេលា** ជាព្រះរាជធីតារបស់ព្រះរាជាក្រុងអាឡវី បានចូលទៅគាល់ព្រះសាស្តាជាមួយនឹងព្រះរាជបិតា ស្តាប់ធម៌ហើយក៏កើតសទ្ធា បានសូមថ្វាយខ្លួនជាឧបាសិកា ក្នុងកាលតមក នាងបានបួសក្នុងសំណាក់ភិក្ខុនី ធ្វើកិច្ចខាងដើម ផ្តើមចម្រើនវិបស្សនាពិចារណាសង្ខារទាំងឡាយមិនយូរក៏បានសម្រេចអរហត្តផល ។ លុះសម្រេចអរហត្តផលហើយ ព្រះថេរីស្នាក់នៅក្រុងសាវត្ថី ថ្ងៃមួយពេលបច្ឆាភត្ត បានចេញចាកក្រុងសាវត្ថី ចូលកាន់ព្រៃអន្ធវ័ន ដើម្បីសម្រាកពេលថ្ងៃ អង្គុយទៀបគល់ឈើមួយដើម គ្រានោះមារ

បំណងនឹងកម្ចាត់ព្រះថេរីនោះឱ្យផុតចាកវិវេក ទើបក្លែងរូបចូលទៅរកព្រះថេរី ពោលថា នាងចូរបរិភោគសេចក្ដីត្រេកអរក្នុងកាមទាំងឡាយ ចូរត្រឡប់មក សោយសេចក្ដីត្រេកអរក្នុងការលេង ដែលអាស្រ័យវត្ថុកាម និងកិលេសកាមចុះ នាងតាំងនៅក្នុងបឋមវ័យដ៏ល្អ នឹងធ្វើប្រយោជន៍អ្វីដោយកាយវិវេកនេះ នាងប្រព្រឹត្តព្រហ្មចរិយៈដើម្បីនិព្វានណា និព្វាននោះមិនមានឡើយ ព្រោះហេតុនោះឯង ទើបនាងមិនបានសម្រេចនិព្វាននោះ ថែមទាំងសាបសូន្យចាកកាមភោគៈផង ។

ព្រះថេរីបានស្ដាប់ដូច្នោះ គិតថា មារនេះរារាំងព្រះនិព្វាន ដែលជាក់ច្បាស់ដល់យើង និងអញ្ជើញយើងក្នុងកាមទាំងឡាយ មារនេះល្ងង់ណាស់ មិនដឹងថា យើងជាអ្នកមានអាសវៈអស់ហើយ ទើបពោលគាថា ថា :

**កាមទាំងឡាយប្រៀបដូចលំពែង និងស្នូ គ្របសង្កត់**
**ខន្ធទាំងឡាយទុក យើងមិនមានសេចក្ដីត្រេកអរក្នុង**
**កាមនោះ ហើយយើងទម្លាយគំនរនៃងងឹតបានហើយ**
**ម្នាលមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ ខ្លួនអ្នក**
**ត្រូវយើងកម្ចាត់ហើយ ។**

មារត្រូវព្រះថេរីគំរាមយ៉ាងនេះហើយ បានអន្តរធានទៅក្នុងទីនោះឯង សូម្បីព្រះថេរី ក៏សម្រាកនៅក្នុងព្រៃអន្ធវ័ន ដោយសេចក្ដីសុខដែលកើតពីផលសមាបត្តិ វេលាល្ងាចទើបត្រឡប់ទៅកាន់ទីលំនៅ ដូច្នេះ ។

( ៣ ) ខណៈដែលព្រះពុទ្ធអង្គគង់នៅនា អគ្គាឡវចេតិយ៍ ក្រុងអាឡវី

ទ្រង់មានពុទ្ធានុញ្ញាតក្នុងរឿងទាក់ទងនឹង **ផាតិកម្ម** គឺការផ្លាស់ប្តូរគុរុភណ្ឌដែលអន់ៗ យករបស់ដែលល្អជាងថ្វាយសង្ឃ ឬយករបស់ខ្លួនថ្វាយសង្ឃ ជាការជំនួសដែលខ្លួនធ្វើរបស់សង្ឃឱ្យខូចខាត ឬរុះរើរបស់ដែលទ្រុឌទ្រោមហើយធ្វើជាថ្មីឱ្យល្អ ជាមួយនឹងភិក្ខុទាំងឡាយ ។

គ្រានោះ ភិក្ខុក្រុងអាឡវីនិយាយសុំសូត្រអំពីអ្នកស្រុកមកធ្វើសន្ថត ព្រះសាស្តាទ្រង់ជ្រាប ទ្រង់តិះដៀលហើយបញ្ញត្តសិក្ខាបទថា ភិក្ខុណាធ្វើសន្ថតលាយដោយសូត្រត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។ សម័យនោះ ពួកឧបាសកនាំគ្នាមកកាន់អារាមដើម្បីស្តាប់ធម៌ កាលព្រះធម្មកថិកសម្តែងព្រះធម៌ចប់ហើយ ភិក្ខុថ្នាក់ព្រះថេរៈត្រឡប់ទៅកាន់ទីនៅហើយ ឯភិក្ខុបួសថ្មីនាំគ្នាដេករួមជាមួយពួកឧបាសក នៅក្នុងសាលាដែលស្តាប់ធម៌នោះឯង ភិក្ខុទាំងនោះភ្លេចស្មារតីដេកស្រមុក ភិក្ខុណាប្រាថ្នាចំពោះសិក្ខា ពោលទោសតិះដៀល ហើយក្រាបទូលរឿងនោះចំពោះព្រះសាស្តា ទើបព្រះមានព្រះភាគបញ្ញត្តសិក្ខាបទថា ភិក្ខុណាដេករួមជាមួយនឹងអនុបសម្បន្នឱ្យលើសពី ២ ឬ ៣ យប់ ត្រូវអាបត្តិបាចិត្តិយៈ ។

( ៤ ) តមក ភិក្ខុក្រុងអាឡវីនាំគ្នាធ្វើនវកម្ម ដោយការជីកដី ជីកខ្លួនឯងខ្លះ ឱ្យអ្នកដទៃជីកខ្លះ មនុស្សទាំងឡាយនាំគ្នាពោលទោសតិះដៀលថា ដូចម្តេចក៏ពួកសមណសក្យបុត្រជីកដី ព្រោះការជីកដីរមែងបៀតបៀនឥន្ទ្រិយ៍មួយដែលមានជីវៈ ព្រះមានព្រះភាគត្រាស់សួរ ទ្រង់តិះដៀលហើយបញ្ញត្តសិក្ខាបទថា ភិក្ខុណាជីកដីខ្លួនឯងក្តី ប្រើឱ្យអ្នកដទៃជីកក្តីត្រូវអាបត្តិបាចិត្តិយៈ ។ ខណៈដែលភិក្ខុ

ក្រុងអាឡវីនាំគ្នាធ្វើនវកម្ម ភិក្ខុមួយរូបកាត់ដើមឈើ ទេវតាដែលនៅត្រង់ដើមឈើនោះ អង្វរករថា បពិត្រលោកដ៏ចម្រើន លោកត្រូវការធ្វើទីនៅរបស់ខ្លួនកុំទម្លាយទីនៅរបស់ខ្ញុំម្ចាស់ឡើយ ឯភិក្ខុនោះមិនអើពើចំពោះពាក្យពេចន៍របស់ទេវតានៅតែកាត់តទៅ ចៃដន្យកាំបិតទៅត្រូវដៃរបស់កូនទេវតានោះ ទេវតាត្រិះរិះថានឹងសម្លាប់ភិក្ខុនោះ តែគិតទាន់ថា ការសម្លាប់ភិក្ខុមិនគួរ ទើបទៅក្រាបទូលព្រះសាស្តាឱ្យទ្រង់ជ្រាប ព្រះអង្គត្រាស់ថា សាធុ សាធុ ទេវតាអ្នកគិតត្រូវ ដែលមិនផ្តាច់ជីវិតភិក្ខុនោះ បើអ្នកធ្វើទៅហើយ អ្នកនឹងជួបបាបជាច្រើន ទុំះដើមឈើនោះនៅទំនេរ អ្នកចូររស់នៅក្នុងដើមឈើនោះចុះ ។

ដើម្បីនឹងកម្ចាត់សេចក្តីក្រោធ ដែលកើតឡើងហើយដល់ទេវតានោះ ទើបព្រះអង្គត្រាស់ថា អ្នកណាទប់ស្កាត់សេចក្តីក្រោធដែលកើតឡើងបាន អ្នកនោះដូចបុគ្គលដែលអាចបញ្ឈប់រថដែលរត់ទៅយ៉ាងរហ័សបាន ។ ទើបព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុណាផ្តាច់ភូតគាម គឺកាប់ដើមឈើត្រូវអាបត្តិបាចិត្តិយៈ ហើយសម្តែងធម៌ដល់ភិក្ខុទាំងឡាយដែលមកក្នុងទីនោះ ត្រាស់ថា :

ភិក្ខុណា កម្ចាត់សេចក្តីក្រោធដែលកើតឡើងហើយ
ដូចគ្រូពស់ កម្ចាត់ពិសពស់ដែលផ្សាយទៅ ដោយឱសថ
អ្នកដែលមិនក្រោធតបចំពោះអ្នកដែលក្រោធចំពោះខ្លួន
ឈ្មោះថា រមែងឈ្នះសង្គ្រាមដែលគេឈ្នះបានដោយកម្រ
និងឈ្មោះថា ប្រព្រឹត្តដើម្បីជាប្រយោជន៍ខ្លួន និងអ្នកដទៃ ។

គ្រានោះ បណ្ដាភិក្ខុក្នុងក្រុងអាឡវីទាំងដែលដឹងថា ក្នុងទឹកមានសត្វ យកទឹកនោះ ស្រោចស្មៅខ្លះ ស្រោចដីខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យស្រោចខ្លះ ព្រះសាស្ដាទ្រង់ជ្រាប ទ្រង់សាកសួរហើយទ្រង់តិះដៀល រួចបញ្ញត្ត-សិក្ខាបទថា ភិក្ខុណាមួយកាលដឹងថា ទឹកមានសត្វហើយ ស្រោចខ្លួនឯង ឬប្រើគេឱ្យស្រោចនូវស្មៅ ឬដី **ត្រូវអាបត្តិបាចិត្តិយៈ** ។

សម័យនោះ ភិក្ខុក្នុងក្រុងអាឡវីធ្វើការកសាងសេនាសនៈ សាងកុដិ ព្រះសាស្ដាទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុណាសាងកុដិផ្ទាល់ខ្លួន ឬសូមឱ្យអ្នកដទៃសាង ដោយមិនឱ្យសង្ឃសម្ដែងទីឱ្យ និងមិនមានឧបចារៈជុំវិញ **ត្រូវអាបត្តិសង្ឃាទិ-សេស និងទុក្កដ** ។

(៥) ថ្ងៃមួយ ពួកអ្នកក្រុងអាឡវីទូលនិមន្តថ្វាយទាន ក្រោយពីសម្រេចភត្តកិច្ចហើយ ទ្រង់អនុមោទនា និងត្រាស់ថា អ្នកទាំងឡាយចូរចម្រើនមរណ-ស្សតិយ៉ាងនេះថា ជីវិតរបស់យើងមិនយឺនយូរ សេចក្ដីស្លាប់របស់យើងពិតប្រាកដ ជីវិតរបស់យើងមានសេចក្ដីស្លាប់ជាទីបំផុត ជីវិតរបស់យើងមិនទៀង សេចក្ដីស្លាប់ទៀង អ្នកដែលចម្រើនមរណស្សតិ រមែងមិនខ្លាចស្លាប់ ដូចបុរសមិនខ្លាចអសិរពិស អ្នកទាំងឡាយគប្បីចម្រើនមរណស្សតិ យ៉ាងនេះឯង ។

ធីតាជាងតម្បាញអាយុ ១៦ ឆ្នាំ អ្នកក្រុងអាឡវីបានស្ដាប់ហើយគិតថា ធម្មតាពាក្យពេចន៍របស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ សុទ្ធតែប្រព្រឹត្តទៅដើម្បីប្រយោជន៍ទាំងអស់ ទើបនាងចម្រើនមរណស្សតិតែម្យ៉ាង ទាំងថ្ងៃទាំងយប់

តាំងពីនោះរហូតមក ។

## ក្រោយពីចេញព្រះវស្សាទី ១៦ ហើយ

( ៦ ) ព្រះពុទ្ធអង្គយាងចារិកទៅកាន់ក្រុងរាជគ្រឹះ ក្នុងចន្លោះផ្លូវទ្រង់គង់លើអាសនៈ ស្លឹកឈើដែលរុះរោយចុះមកគរនៅក្នុងព្រៃ តាមផ្លូវគោ ក្នុងសឹង្សបាវ៌ន ជិតក្រុងអាឡវី ខណៈនោះ **ហត្ថករាជកុមារ** ឱរសរបស់ព្រះរាជានៃក្រុងអាឡវី ព្រមដោយរាជបរិវារ ៥០០ នាក់ហែហម កំពុងត្រាច់ដើរលេង ឃើញព្រះពុទ្ធអង្គគង់នៅទីនោះ ទើបចូលទៅថ្វាយបង្គំ ហើយក្រាបទូលសួរថា បពិត្រព្រះអង្គ រាត្រីរដូវហេមន្តនោះរងា ជារដូវធ្លាក់សន្សើម ផ្ទៃដីក៏មានដានជើងគោក្រឡិកក្រឡុក កម្រាលស្លឹកឈើក៏ស្តើង ស្លឹកលើដើមក៏ស្រឡះ សំពត់កាសាវៈក៏ត្រជាក់ ទាំងខ្យល់រងាក៏ផាត់មក ព្រះតថាគតនៅផ្ទុំជាសុខឬ ព្រះអង្គ ? ព្រះមានព្រះភាគជាម្ចាស់ត្រាស់តបថា តថាគតផ្ទុំជាសុខ ព្រោះសេចក្តីក្តៅក្រហាយដែលកើតឡើងអាស្រ័យរាគៈ ទោសៈ មោហៈនោះ តថាគតលះបង់ហើយ មិនកើតឡើងតទៅទៀតជាធម្មតា ព្រោះហេតុនោះ ទើបតថាគតផ្ទុំជាសុខ ហើយត្រាស់សម្តែងព្រះគាថា ថា :

**អ្នករំលត់កិលេសបានហើយ ជាអ្នកមិនជាប់ក្នុងកាម**
**ទាំងឡាយ ជាអ្នកត្រជាក់ អស់ឧបធិ កាត់គ្រឿងចង**
**ទាំងពួង សម្រេចសេចក្តីស្ងប់ចិត្ត រមែងនៅសប្បាយ**
**រស់នៅជាសុខគ្រប់កាល ។**

លុះព្រះអង្គសម្តែងធម៌ប្រោសដូច្នេះហើយ ហត្ថករាជកុមារបានសម្រេចអនាគាមិផល ។

(៧) បន្ទាប់ពីនោះ យាងទៅប្រោសបុរសកំសត់ម្នាក់ ដែលអាស្រ័យនៅក្នុងដែនអាឡវី កំពុងទៅតាមគោដែលបាត់ ព្រឹកថ្ងៃនោះ អ្នកដែនអាឡវីធ្វើការថ្វាយអាហារបិណ្ឌបាត ដល់ព្រះពុទ្ធជាម្ចាស់ និងភិក្ខុសង្ឃ ក្រោយភត្តកិច្ចបានឱកាសដែលនឹងអនុមោទនា ព្រះអង្គក៏ទ្រង់គង់ស្ងៀម ព្រោះរង់ចាំការមករបស់បុរសកំសត់នោះ ដោយសារទ្រង់ជ្រាបនូវការដល់ព្រមដោយឧបនិស្ស័យដែលបុរសម្នាក់នោះនឹងបានសម្រេចធម៌ ។ បុរសនោះកាលបានគោមកហើយគិតថា សូម្បីយើងគ្មានវត្ថុអ្វី ក៏បានត្រឹមការថ្វាយបង្គំព្រះសាស្តាដែរ ទើបឆ្ពោះមុខទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយឈរនៅក្នុងទីដ៏សមគួរ ។

ព្រះអង្គត្រាស់សួរអ្នកដែលថ្វាយទានថា នៅមានអាហារណាសល់ខ្លះទេ ទ្រង់ជ្រាបថានៅមានសល់ ទើបត្រាស់ថា ពួកអ្នកចូរនាំអាហារនោះមកឱ្យបុរសនេះបរិភោគចុះ ក្រោយពីបុរសនោះបរិភោគរៀបរយហើយ ទើបព្រះអង្គត្រាស់អនុបុព្វីកថា និងទ្រង់សម្តែងអរិយសច្ច ៤ ដល់ជនទាំងឡាយ ក្នុងទីបំផុតនៃព្រះធម៌ទេសនា បុរសនោះបានសម្រេចសោតាបត្តិផល ព្រះអង្គទ្រង់ធ្វើអនុមោទនាដល់មហាជន ត្រាស់នឹងភិក្ខុទាំងឡាយថា **សេចក្តីស្រេកឃ្លានជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយជាទុក្ខយ៉ាងក្រៃលែង** ។ បណ្ឌិតដឹងច្បាស់សេចក្តីនេះតាមពិតហើយ **គប្បីធ្វើឱ្យច្បាស់នូវព្រះនិព្វាន ព្រោះព្រះនិព្វានជាសុខ**

**យ៉ាងក្រៃលែង** តពីនោះមកទ្រង់យាងចារិកទៅកាន់ក្រុងរាជគ្រឹះ ។

(៨) ព្រឹកថ្ងៃមួយ ខណៈដែលព្រះអង្គទ្រង់គង់នៅក្នុងវេឡុវនវិហារ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទតឃើញ **សិង្គាលកបុត្រ** កំពុងនមស្ការទិសទាំងឡាយ ព្រះអង្គទ្រង់ព្រះតម្រិះថា ថ្ងៃនេះតថាគតនឹងសម្តែងវិន័យរបស់គ្រហស្ថ ដល់សិង្គាលកបុត្រ ពាក្យពេចន៍នោះនឹងមានផលដល់ជនច្រើន ទើបយាងចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទតឃើញសិង្គាលកបុត្រ ត្រាស់សួរថា អ្នកធ្វើអ្វីហ្នំ ? ។

ក្នុងអដ្ឋកថាពោលថា មាតាបិតារបស់សិង្គាលកៈជាឧបាសក និងឧបាសិកា ទាំងជាសោតាបន្ន មានសទ្ធាមាំទាំក្នុងព្រះមានព្រះភាគ ព្យាយាមឱ្យបុត្រដែលមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា ឱ្យបានចូលទៅគាល់ព្រះសាស្តា តែក៏មិនសម្រេច ។ បុត្រនោះពោលថា ការចូលទៅរកសមណៈទាំងឡាយ រមែងមិនមានដល់ខ្ញុំ ព្រោះការចូលទៅរកសមណៈក៏ត្រូវថ្វាយបង្គំ កាលឱនចុះថ្វាយបង្គំខ្នងក៏ឈឺ ជង្គង់ក៏ចុករោយ ចាំបាច់ត្រូវអង្គុយលើផែនដី កាលអង្គុយលើផែនដីសំពត់ក៏នឹងប្រឡាក់ ចាប់ផ្តើមតាំងពីអង្គុយជិតរមែងមានការសន្ទនា កាលមានការសន្ទនារមែងកើតសេចក្តីស្និទ្ធស្នាល តមករមែងត្រូវនិមន្ត ហើយថ្វាយចីវរបិណ្ឌបាតជាដើម កាលបើដូច្នោះ ប្រយោជន៍រមែងសាបសូន្យ ។

សូម្បីមាតាបិតាទូន្មានរហូតមួយជីវិត ក៏មិនអាចនឹងនាំឱ្យបុត្រចូលជិតព្រះសាសនាបាន មុននឹងអស់ជីវិត បិតាឱ្យឱវាទថា កូនគួរក្រោកពីព្រឹក ហើយ

ចូរនមស្ការទិសទាំងឡាយ ធ្វើដូច្នេះព្រោះបិតាបំណងថា ប្រសិនបើព្រះពុទ្ធអង្គ ឬសាវ័កទាំងឡាយចូលទៅបិណ្ឌបាត ឃើញការធ្វើដូច្នោះហើយ នឹងបានចង្អុលប្រាប់ឱ្យបុត្រកើតការយល់ដឹង គោលបំណងរបស់ការថ្វាយបង្គំទិសក្នុងផ្លូវដែលត្រឹមត្រូវ សិង្គាលកបុត្រនឹងបានកើតសទ្ធាជ្រះថ្លាក្នុងព្រះសាសនា ។ សិង្គាល-កបុត្រមិនយល់ និងមិនដឹងចំណុចបំណងរបស់បិតា បានផ្គងអញ្ជលី មានសំពត់សើម មានសក់ទទឹក នមស្ការទិសទាំងឡាយរាល់ព្រឹក តាមពាក្យបង្គាប់របស់បិតារហូតមក ។

កាលព្រះមានព្រះភាគជាម្ចាស់ ត្រាស់សួរដំណើរមកនៃការធ្វើដូច្នោះសិង្គាលកបុត្រ ទើបទូលដល់ពាក្យបង្គាប់របស់បិតាឱ្យទ្រង់ជ្រាប ហើយទូលសូមប្រទានឱកាស ឱ្យព្រះមានព្រះភាគសម្ដែងការនមស្ការទិសទាំងឡាយ ក្នុងវិន័យរបស់ព្រះអរិយៈ ។ ព្រះសាស្ដាទ្រង់សម្ដែងការលះ **កម្មកិលេស ៤ ប្រការ** គឺ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆារ និងមុសាវាទ **មិនគប់រកផ្លូវសាប-សូន្យនៃភោគៈ ៦** គឺ អបាយមុខទាំង ៦ បានដល់ ជាអ្នកលេងសុរា ១ ចូលចិត្តដើរលេងពេលយប់ ១ ចូលចិត្តមើលល្បែងរបាំ ១ លេងល្បែងស៊ីសង ១ គប់រកមិត្រអាក្រក់ ១ និងខ្ជិលច្រអូសក្នុងការងារ ១ ហើយទ្រង់ត្រាស់ការនមស្ការទិសទាំងឡាយថា :

**មាតាបិតាជាទិសខាងមុខ គឺទិសខាងកើត**

**អាចារ្យជាទិសខាងស្ដាំ គឺទិសខាងត្បូង**

**បុត្រភរិយាជាទិសខាងក្រោយ គឺទិសខាងលិច**

**មិត្តអាមាត្យជាទិសខាងឆ្វេង គឺទិសខាងជើង**

**ទាសកម្មករជាទិសខាងក្រោម**

**សមណព្រាហ្មណ៍ជាទិសខាងលើ ។**

នេះគឺទិសទាំងឡាយក្នុងវិន័យរបស់ព្រះអរិយៈ ដែលគួរគោរពនមស្ការ គ្រហស្ថក្នុងត្រកូលអ្នកមិនប្រមាទ គួរនមស្ការទិសទាំងនេះ នឹងមានតែសេចក្ដីចម្រើន មិនមានសេចក្ដីសាបសូន្យឡើយ ។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ដូច្នេះហើយ សិង្គាលកបុត្រសូមថ្វាយខ្លួនជាឧបាសក អ្នកដល់ព្រះរតនត្រ័យជាសរណៈស្មើដោយជីវិត តពីនោះ ទើបព្រះអង្គយាងចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ។

( ៩ ) ខណៈដែលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងរាជគ្រឹះ **នាងសិរិមា** ធីតារបស់នាងសាលវតីស្រីផ្កាមាស ដែលជាប្អូនស្រីរបស់ពេទ្យជីវកកោមារភត្ត ស្ដាប់ព្រះធម៌ទេសនារបស់ព្រះពុទ្ធអង្គហើយ បានសម្រេចជាសោតាបន្ន នាងបាននិមន្តភិក្ខុប្រគេននិច្ចភត្តក្នុងផ្ទះជាប្រចាំ ភិក្ខុមួយរូបបានឮភិក្ខុដទៃទៅទទួលនិច្ចភត្ត សន្ទនាដល់លម្អរបស់នាងសិរិមា កើតរាគៈទាំងដែលមិនធ្លាប់ឃើញនាង លុះបានឃើញក៏មិនអាចបំពេញសមណធម៌បាន តមកមិនយូរប៉ុន្មាន នាងសិរិមាក៏ស្លាប់ទៅ ទៅកើតជាទេវីរបស់ស្ដេចសុយាមៈក្នុងជាន់ទី ៣ ។

ព្រះរាជាបញ្ជូនអាមាត្យទៅទូលប្រាប់ អំពីនាងសិរិមាស្លាប់ដល់ព្រះ-

សាស្តា ព្រះអង្គសូមឱ្យផ្អាកឈាបនកិច្ចសរីរៈរបស់នាងទុកសិន ដោយបំណង នឹងសម្តែងអសុភកម្មដ្ឋានដល់ភិក្ខុទាំងឡាយ ក្នុងថ្ងៃទី ៤ កាលរាងកាយរបស់ នាងចាប់ហើមប៉ោងឡើង ទើបព្រះរាជាប៉ាវប្រកាសឱ្យពពួកជនទៅមើលរូបរាង របស់នាងសិរិមា តាំងតម្លៃថា បើអ្នកណាឱ្យទ្រព្យ ៥០០ កហាបណៈ ក៏ចូរយក រូបរាងរបស់នាងទៅ មិនមានអ្នកព្រមទទួលសូម្បីលើកឱ្យទទេ ។

ព្រះសាស្តា នាំភិក្ខុទៅមើលសរីរៈរបស់នាងសិរិមា ហើយទ្រង់ឱ្យឱវាទ ដល់ភិក្ខុទាំងនោះដោយកម្មដ្ឋានដែលធ្វើឱ្យរួចផុត ដោយការសម្តែងត្រៃលក្ខណ៍ និងទ្រង់ប្រារព្ធអាការៈ ៣២ ថា រាងកាយនេះប្រកបដោយឆ្អឹង សរសៃ លាបបូក ដោយសាច់ និងស្បែក ជាដើម ក៏កាលណាអស់ជីវិតប្រាសចាកភ្លើងធាតុ និង វិញ្ញាណ ត្រូវបោះចោលក្នុងព្រៃដូចអង្កត់ឧសរកប្រយោជន៍គ្មាន ញាតិទាំង- ឡាយរមែងមិនហួងហែង បុថុជ្ជនល្ងង់ខ្លៅប្រាសចាកចក្ខុ គឺបញ្ញា រមែងមិនឃើញ កាយនោះតាមពិត ។ ក្នុងពេលចប់ទេសនា មានអ្នកត្រាស់ដឹងធម៌ជាច្រើន **សិរិមាទេពកញ្ញា** បានសម្រេច **អនាគាមិផល** ចំណែក **ភិក្ខុរូបនោះ** តាំងនៅ ក្នុងសោតាបត្តិផល ។

( ១០ ) សម័យនោះ **ព្រះមហាកស្សបៈ** អាពាធធ្ងន់សម្រាកនៅល្អាង បិប្ផលិ ក្នុងវេលាល្ងាច ព្រះមានព្រះភាគទ្រង់ចេញចាកទីសម្រាកពេលថ្ងៃ យាង ទៅសួរសុខទុក្ខព្រះមហាកស្សប ត្រាស់សួរថា កស្សបអ្នកល្មមអត់ធន់បានឬទេ ល្មមញុំាងអត្តភាពឱ្យប្រព្រឹត្តទៅបានឬទេ ទុក្ខវេទនាស្រាលចុះមិនកម្រើកឡើងឬ?

ព្រះមហាកស្សប ក្រាបទូលថា ខ្ញុំព្រះអង្គធន់មិនបានទេ ខ្ញុំព្រះអង្គមានទុក្ខវេទនាយ៉ាងខ្លាំងក្លា នៅកម្រើកឡើងមិនស្រាកឡើយ ព្រះអង្គ! ព្រះពុទ្ធអង្គត្រាស់ថា កស្សប **ពោជ្ឈង្គ ៧** បានដល់ **សតិពោជ្ឈង្គ ធម្មវិចយសម្ពោជ្ឈង្គ វិរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ** ដែលតថាគតសម្តែងទុកប្រពៃហើយ ធ្វើឱ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីដឹងក្រៃលែង ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

ព្រះមហាកស្សបស្តាប់ហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពោជ្ឈង្គល្អពិត ពោជ្ឈង្គល្អពិត ព្រះអង្គ ព្រះមហាកស្សបរីករាយចំពោះភាសិតរបស់ព្រះអង្គ បានស្បើយចាកអាពាធនោះហើយ ដោយការចម្រើនពោជ្ឈង្គ ៧ នោះឯង ។

តមក កាលព្រះមហាកស្សបស្បើយចាកអាពាធហើយ បានចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទើបសក្កទេវរាជមានព្រះតម្រាស់ដល់នាងអប្សរ ៥០០ ថា ពួកនាងចូរទៅថ្វាយអាហារបិណ្ឌបាតដល់លោកម្ចាស់ មហាកស្សបត្ថេរ ដោយគិតថា បើព្រះថេរៈទទួលបិណ្ឌបាត អំពីដៃរបស់នាងអប្សរ សូម្បីត្រឹមតែម្នាក់ ការទទួលនោះនឹងជាប្រយោជន៍ដល់ពួកនាងរហូតអស់កាលដ៏យូរ ។ ទើបពួកនាងអប្សរត្រៀមបិណ្ឌបាត ៥០០ ដែលដាក់ភាជនមាស ទៅឈរនៅត្រង់ចន្លោះផ្លូវដែលព្រះថេរៈនឹងឆ្លងមក កាលព្រះថេរៈមកដល់ទើបនិមន្តថា លោក-ម្ចាស់ សូមលោកចូរទទួលបិណ្ឌបាតនេះ ដើម្បីសង្គ្រោះពួកនាងខ្ញុំផងចុះ ។

ព្រះមហាកស្សបហាមថា ពួកនាងបានធ្វើបុណ្យទុកហើយ មានភោគៈច្រើនហើយ ចូរចៀសចេញទៅចុះ អាត្មានឹងសង្គ្រោះដល់មនុស្សក្រខ្សត់ ហើយចូលទៅបិណ្ឌបាតក្នុងភូមិរបស់មនុស្សទុគិត ដែលជាភូមិរបស់ជាងតម្បាញក្នុងចន្លោះស្រុកនោះ ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់គង់ក្នុងវត្តវេឡុវ័ន ទ្រង់រំពឹងថា កស្សបបុត្ររបស់តថាគតជាស្មើយចាកអាពាធហើយ ធ្វើអ្វីហ្ន៎ ទ្រង់ឃើញដោយទិព្វចក្ខុថា ព្រះមហាកស្សប ហាមបិណ្ឌបាតជាទិព្វ មានសូបព្យញ្ជនៈច្រើន ដែលនាងអប្សរ ៥០០ នាំមកថ្វាយហើយ ធ្វើការសង្គ្រោះដល់ទុគិតជន ព្រះអង្គទ្រង់សរសើរក្នុងបដិបទាដ៏មាំទាំ មានភាពជាអ្នកប្រាថ្នាតិចរបស់ព្រះមហាកស្សបត្ថេរដូច្នេះ ។

# ព្រះវស្សាទី ១៧

## ទ្រង់គង់ចាំព្រះវស្សា ក្នុងវត្តវេឡុវ័ន ក្រុងរាជគ្រឹះ

(១) ព្រះរាជឱរសរបស់ព្រះបាទពិម្ពិសារព្រះនាមថា **អភ័យរាជកុមារ** ជាសិស្សរបស់និគ្រន្ថនាដបុត្រ ចូលទៅគាល់ក្រាបទូលនិមន្តព្រះសម្មាសម្ពុទ្ធ ឱ្យសោយភត្តាហារក្នុងនិវេសន៍របស់ខ្លួន ដើម្បីទូលសួរបញ្ហាតាមដែលនិគ្រន្ថនាដ-បុត្រញុះញង់ ដោយសង្ឃឹមថា ព្រះសមណគោតមនឹងមិនអាចឆ្លើយបាន អភ័យ-រាជកុមារទូលសួរថា ខ្ញុំព្រះអង្គចង់ដឹងថា ព្រះអង្គធ្លាប់ត្រាស់វាចាដែលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អ្នកដទៃខ្លះឬទេ ?

**ព្រះអង្គត្រាស់ថា បញ្ហានេះតថាគតឆ្លើយថាធ្លាប់ ឬមិនធ្លាប់ដោយចំណែកមួយក៏ទេ ព្រោះថា:**

១. វាចាណាមិនពិត មិនប្រកបដោយប្រយោជន៍ មិនជាទីពេញចិត្តរបស់បុគ្គលដទៃ **តថាគតមិនពោលនូវវាចានោះឡើយ ។**

២. វាចាណាមិនពិត មិនប្រកបដោយប្រយោជន៍ តែជាទីពេញចិត្តរបស់បុគ្គលដទៃ **តថាគតមិនពោលនូវវាចានោះឡើយ ។**

៣. វាចាណាពិត ដែលប្រកបដោយប្រយោជន៍ តែមិនជាទីពេញចិត្តរបស់បុគ្គលដទៃ **តថាគតដឹងកាលដែលនឹងពោលនូវវាចានោះ ។**

៤. វាចាណាពិត ដែលប្រកបដោយប្រយោជន៍ និងជាទីពេញចិត្តរបស់បុគ្គលដទៃ **ទើបតថាគតពោលនូវវាចានោះ ។**

កាលព្រះអង្គត្រាស់ដូច្នោះហើយ អភ័យរាជកុមារ បានថ្វាយខ្លួនជាឧបាសកសូមដល់ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាសរណៈស្មើដោយជីវិតតាំងពីថ្ងៃនេះតទៅ ។

( ២ ) សម័យមួយ ព្រះពុទ្ធអង្គគង់ក្នុងវេឡុវនារាម **ព្រះទព្វមល្លបុត្រ** ចូលមកគាល់ ទូលលាថា ឥឡូវនេះជាកាលបរិនិព្វាននៃខ្ញុំព្រះអង្គហើយ ព្រះអង្គព្រះមានព្រះភាគត្រាស់ថា ទព្វៈ អ្នកចូរសម្គាល់កាលដ៏សមគួរក្នុងកាលឥឡូវនេះចុះ ព្រះទព្វមល្លបុត្រ ថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណហើយ ចូលសមាបត្តិមានតេជោធាតុជាអារម្មណ៍នៅក្នុងលំហអាកាស ចេញចាកសមាបត្តិហើយបរិនិព្វាន សរីរៈត្រូវភ្លើងឆេះ ផេះក៏មិនប្រាកដ ម្រេញភ្លើងក៏មិនប្រាកដ ដូចប្រេងដែលត្រូវភ្លើងឆេះដូច្នោះ ព្រះមានព្រះភាគទ្រង់បន្លឺឧទានក្នុងវេលានោះថា:

**រូបកាយបានរលាយបាត់ហើយ វេទនាទាំងពួងស្ងប់ហើយ**
**សញ្ញារលត់ហើយ សង្ខារទាំងឡាយស្ងប់ហើយ**
**វិញ្ញាណមានការតាំងនៅមិនបានហើយ ។**

ព្រះសាស្ដាទ្រង់បន្លឺឧទាន ព្រោះខន្ធ ៥ របស់ទព្វមល្លបុត្តត្ថេររលត់អស់ហើយ មិនមានបដិសន្ធិថ្មី ដូចប្រទីបដែលអស់ប្រេងដូច្នោះ ។

( ៣ ) **សោបាកៈ** កាន់យកកំណើត និងចម្រើនលូតលាស់ក្នុងព្រៃខ្មោចក្នុងក្រុងរាជគ្រឹះ កាលសោបាកៈអាយុបាន ៤ ខែ ឪពុកក៏អស់ជីវិតទៅ ឪពុកមាក៏ចិញ្ចឹមរក្សារហូតអាយុបាន ៧ ខួប ថ្ងៃមួយឪពុកមាខឹងក្រោធ ព្រោះឈ្លោះ

ជាមួយកូនរបស់ខ្លួន ទើបនាំទៅកាន់ព្រៃខ្មោច ចងដៃរបស់សោបាកៈភ្ជាប់នឹងសាកសពមនុស្សស្លាប់ ដោយបំណងឱ្យឆ្កែចចកខាំស៊ី តែព្រោះផលបុណ្យរបស់ក្មេងតូចជាអ្នកមានភពចុងក្រោយ ទើបមិនមានអ្វីធ្វើអន្តរាយបានក្នុងវេលាកណ្តាលអាធ្រាត្រសោបាកៈរៀបរាប់ថា ៈ

**គតិរបស់យើងអ្នកមិនមានគតិ នឹងជាយ៉ាងណា ផៅពង្ស**
**របស់យើងអ្នកមិនមានផៅពង្ស នឹងជាយ៉ាងណា អ្នកណា**
**នឹងជួយយើងដែលត្រូវចងនៅក្នុងកណ្តាលព្រៃស្មសាននេះ ។**

ក្នុងវេលានោះ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យព្រះអរហត្តរបស់សោបាកៈ ទើបទ្រង់ផ្សាយឱភាសទៅកាន់ក្មេងនោះ ត្រាស់ថា ៈ

**មកចុះសោបាកៈ កុំខ្លាចឡើយ អ្នកចូរសម្លឹងមើលតថាគត**
**តថាគតនឹងញុំាងអ្នកឱ្យឆ្លងផុតទៅ ដូចព្រះច័ន្ទផុតចាក-**
**មាត់រាហូ ដូច្នោះ ។**

ក្នុងវេលាចប់ព្រះគាថា សោបាកៈសម្រេចជាព្រះសោតាបន្ន បានទៅឈរចំពោះមុខព្រះគន្ធកុដិ មាតារបស់សោបាកៈកាលមិនឃើញបុត្ររបស់ខ្លួន ទើបសួរបងប្រុស កាលសួរហើយបងប្រុសមិនព្រមប្រាប់ហេតុការណ៍របស់បុត្រ ទើបនាងទៅកាន់សំណាក់ព្រះសាស្តាដើម្បីទូលសួរ ព្រះមានព្រះភាគ ទ្រង់បិទបាំងសោបាកៈទុកដោយពុទ្ធានុភាព កាលនាងសួរដល់បុត្រ ព្រះអង្គទ្រង់ត្រាស់ ថា ៈ

**បុត្រក្តី បិតាក្តី ផៅពង្សក្តី ញាតិក្តី កាលបើសេចក្តីស្លាប់**

**មកដល់ហើយ រមែងមិនមានអ្នកណាពឹងពាក់បានឡើយ ។**

នាងស្ដាប់ធម៌នោះហើយ បានជាព្រះសោតាបន្ន សោបាកៈបានសម្រេចព្រះអរហត្តផល ព្រះអង្គទ្រង់រំសាយឫទ្ធិ ម្ដាយបានឃើញកូនក៏សប្បាយចិត្ត ជ្រាបថាបុត្រនោះជាព្រះខីណាស្រព ទើបអនុញ្ញាតឱ្យបួស ហើយនាងក៏ចាកចេញទៅ ។ សោបាកៈចូលទៅគាល់ព្រះសាស្ដា ដែលកំពុងយាងចង្ក្រម ក្រោមម្លប់នៃព្រះគន្ធកុដិ ថ្វាយបង្គំហើយចង្ក្រមតាមព្រះអង្គ ព្រះមានព្រះភាគបំណងនឹងអនុញ្ញាតឱ្យឧបសម្បទាដល់គេ (ខណៈនោះសោបាកៈមានអាយុត្រឹម ៧ ខួប ) ទើបមានព្រះតម្រាស់សួរបញ្ហា ១០ ចំណុច ដែលហៅថា **កុមារបញ្ហា** ព្រះសាស្ដាទ្រង់ពេញព្រះទ័យក្នុងការព្យាករណ៍របស់សោបាកៈ ទើបទ្រង់អនុញ្ញាតការឧបសម្ប័ទដល់សាមណេរ ព្រះអង្គត្រាស់ថា ម្នាលសោបាកៈ ការវិសជ្ជនាបញ្ហានេះជាការឧបសម្ប័ទរបស់អ្នក ឧបសម្បទាកម្មនោះ ឈ្មោះថា **បញ្ហាព្យាករណូបសម្បទា** គឺ ឧបសម្ប័ទដោយការព្យាករណ៍បញ្ហា ឬដែលហៅថា **កុមារបញ្ហា ១០ យ៉ាង** ព្រះអង្គត្រាស់សួរថា :

អ្វីឈ្មោះថា ១ សោបាកៈទូលថា សត្វទាំងពួងរស់បានដោយអាហារ

អ្វីឈ្មោះថា ២ សោបាកៈទូលថា នាម និងរូប

អ្វីឈ្មោះថា ៣ សោបាកៈទូលថា វេទនា ៣

អ្វីឈ្មោះថា ៤ សោបាកៈទូលថា អរិយសច្ច ៤

អ្វីឈ្មោះថា ៥ សោបាកៈទូលថា ឧបាទានក្ខន្ធ ៥

អ្វីឈ្មោះថា ៦ សោបាកៈទូលថា អាយតនៈខាងក្នុង ៦

អ្វីឈ្មោះថា ៧ សោបាកៈទូលថា ពោជ្ឈង្គ ៧

អ្វីឈ្មោះថា ៨ សោបាកៈទូលថា អរិយមគ្គមានអង្គ ៨

អ្វីឈ្មោះថា ៩ សោបាកៈទូលថាសត្តាវាស ៩ ( ទីនៅរបស់សត្វ )

អ្វីឈ្មោះថា ១០ សោបាកៈទូលថា អ្នកប្រកបដោយអង្គ ១០ ហៅថា ព្រះអរហន្ត ។

អ្នកប្រកបដោយអង្គ ១០ គឺ **សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សម្មាញាណៈ សម្មាវិមុត្តិ** ដែលជាព្រះអសេក្ខៈ ។

សាមណេរសោបាកៈ បានឧបសម្ប័ទហើយដោយ **បញ្ហាព្យាករណូបសម្បទា** ដូច្នេះ ។

( ៤ ) សម័យនោះ នាងព្រាហ្មណីឈ្មោះ **ធនញ្ជានី** ជាអ្នកជ្រះថ្លាក្រៃលែង ក្នុងព្រះពុទ្ធជាម្ចាស់ ថ្ងៃមួយព្រាហ្មណ៍ភារទ្វាជគោត្តជាស្វាមី អញ្ជើញពួកព្រាហ្មណ៍ទាំងឡាយមកបរិភោគអាហារ ខណៈដែលនាងព្រាហ្មណីនាំភត្តចូលទៅលៀងព្រាហ្មណ៍ទាំងនោះ នាងដើរជម្ពប់ជើង ទើបបន្លឺឧទាន ៣ ដងថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ព្រាហ្មណ៍ជាស្វាមីពោលថា មេស្រីថោកទាបនេះ ពោលសរសើរគុណរបស់សមណៈត្រងោលយ៉ាងនេះ មិនរើសកន្លែង យើងនឹងទៅចោទសួរព្រះសាស្តានោះរបស់នាងឯង ។

នាងព្រាហ្មណីពោលថា បពិត្រព្រាហ្មណ៍ ខ្ញុំពុំដែលឃើញបុគ្គលណា

អាចតទល់វាទៈចំពោះព្រះសាស្តាអង្គនោះបាន ទាំងទេវលោក មារលោក ព្រហ្ម-លោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្ស បពិត្រព្រាហ្មណ៍ លោកចូរទៅចុះ កាលលោកទៅជួបព្រះសាស្តារបស់យើងហើយ លោកនឹងបានដឹងខ្លួនឯង ព្រាហ្មណ៍ជាស្វាមីស្តាប់ហើយ ខឹងក្រោធចំពោះនាងខ្លាំងឡើង ទើបព្រាហ្មណ៍ភារទ្វាជគោត្ត ចូលទៅគាល់ព្រះមានព្រះភាគដល់ទីគង់ប្រថាប់ គឺក្នុងវត្តវេឡុវ័ន ក្រាបទូលសួរថា :

**បុគ្គលសម្លាប់អ្វីបាន ទើបដេកជាសុខ សម្លាប់អ្វីបាន**
**ទើបមិនសោយសោក បពិត្រព្រះគោតម ព្រះអង្គ**
**រមែងពេញចិត្តក្នុងការសម្លាប់ធម៌អ្វី ?**

ព្រះអង្គត្រាស់ឆ្លើយតបបញ្ហាថា :

**បុគ្គលសម្លាប់សេចក្តីក្រោធបានទើបដេកជាសុខ សម្លាប់**
**សេចក្តីក្រោធបាន ទើបមិនសោយសោក ម្នាលព្រាហ្មណ៍**
**ព្រះអរិយៈទាំងឡាយ រមែងសរសើរការសម្លាប់សេចក្តីក្រោធ**
**ដែលមានឫសជាពិស មានចុងផ្អែម ព្រោះសម្លាប់សេចក្តី**
**ក្រោធនោះបានហើយ រមែងមិនសោយសោក ។**

កាលបានស្តាប់ព្រះអង្គត្រាស់ដូច្នេះហើយ ព្រាហ្មណ៍ភារទ្វាជគោត្ត បានសម្រេចសោតាបត្តិផល ក្រាបទូលសូមបួសក្នុងសំណាក់ព្រះមានព្រះភាគ លុះបួសហើយមិនយូរ គេចចេញទៅតែម្នាក់ឯងមិនប្រមាទ ប្រារព្ធសេចក្តីព្យាយាម

មានចិត្តតាំងមាំ មិនយូរប៉ុន្មាន ព្រះភារទ្វាជៈបានជាព្រះអរហន្តមួយរូបក្នុងបណ្ដាព្រះអរហន្តទាំងឡាយ ។

(៥) ព្រះសាស្ដាកាលទ្រង់គង់នៅវេឡុវ័នវិហារ ទ្រង់ប្រារព្ធរឿង **នាងប្រេត ធ្លាប់ជាមាតារបស់ព្រះសារីបុត្រ** ក្នុងអតីតជាតិ ដែលបានសោយទុក្ខសមគួរដល់វិចីទុច្ចរិតរបស់ខ្លួន បច្ចុប្បន្នមានប្រាថ្នានឹងមកកាន់សំណាក់ព្រះ-សារីបុត្រ ទេវតាបិតនៅត្រង់ទ្វារវិហារហាម ដែលនាងអង្វរករដើម្បីសូមសួរសុខទុក្ខព្រះថេរៈ គ្រាចូលទៅហើយបានឈរនៅចុងបំផុតនៃទីចង្ក្រមរបស់ព្រះថេរៈ បង្ហាញខ្លួនឱ្យព្រះថេរៈឃើញពោលថា ។ កាលមុននាងខ្ញុំជាមាតារបស់លោក នាងខ្ញុំមកកាន់បេត្តិវិស័យ ប្រកបព្រមទៅដោយសេចក្ដីស្រេកឃ្លាន កាលត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ រមែងស៊ីទឹកមាត់ ទឹកសំបោរ ស្លេស្ម និងខ្លាញ់រាវរបស់សាកសព ដែលគេដុតហើយត្រង់ជើងថ្ករ ស៊ីលោហិតរបស់ពួកស្រីប្រសូតិកូន និងលោហិតរបស់ពួកបុរសដែលត្រូវកាត់ដៃជើង និងក្បាល ស៊ីសាច់ សរសៃខ្ទុះ និងឈាមរបស់បសុសត្វ និងមនុស្សទាំងឡាយដែលមិនមានទីពឹង ដេកលើគ្រែសម្រាប់អ្នកស្លាប់ ដែលគេបោះចោលក្នុងព្រៃខ្មោច កូនអើយ ! សូមកូនចូរឱ្យទាន ហើយឧទ្ទិសចំណែកបុណ្យឱ្យដល់ម៉ែខ្លះផង ធ្វើដូចម្ដេច ម៉ែនឹងផុតចាកការស៊ីខ្ទុះ និងឈាមបាន ។

ព្រះសារីបុត្របានឮដូច្នោះ ក្នុងថ្ងៃទី ២ ទើបបបួលព្រះមោគ្គល្លានត្ថេរ និងភិក្ខុដទៃ ពីររូបទៀតចូលទៅបិណ្ឌបាត្រក្នុងក្រុងរាជគ្រឹះ ព្រះមោគ្គល្លានត្ថេរ

បានទូលរឿងនោះដល់ ព្រះបាទពិម្ពិសារ ព្រះរាជាទ្រង់មានព្រះរាជបញ្ជាឱ្យសាងកុដិ ៤ ខ្នង មិនឆ្ងាយអំពីក្រុងរាជគ្រឹះ ក្នុងទីដែលសម្បូរដោយម្លប់ និងទឹក កាលកុដិស្រេចហើយ ចាត់ត្រៀមពលិកម្មទាំងអស់ មានបាយ ទឹក សំពត់ និងបរិក្ខារគ្រប់យ៉ាងដ៏សមគួរ ដល់ភិក្ខុសង្ឃដែលមកពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ហើយប្រគេនវត្ថុទាំងអស់នោះដល់ព្រះសារីបុត្រ ។ លំដាប់នោះព្រះ-សារីបុត្រ បានថ្វាយវត្ថុនោះចំពោះភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ មានព្រះ-ពុទ្ធជាប្រធាន ដើម្បីឧទ្ទិសឱ្យដល់នាងប្រេតនោះ ។ នាងប្រេតបានអនុមោទនាចំណែកបុណ្យនោះហើយ ទៅកើតក្នុងទេវលោក ជាអ្នកប្រកបព្រមដោយវត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ក្នុងថ្ងៃតមក នាងបានចូលទៅរកព្រះមោគ្គល្លាន មានរាងកាយបរិសុទ្ធស្អាត ស្លៀកដណ្ដប់សំពត់មានតម្លៃក្រៃលែងជាងសំពត់ដែនកាសីប្រដាប់ដោយអាភរណៈដ៏ល្អវិចិត្រ សម្ដែងឱ្យឃើញការផុតចាកកំណើតរបស់នាងហើយ ។

ព្រះមហាមោគ្គល្លានបានក្រាបទូលសេចក្ដីនោះ ចំពោះព្រះសាស្ដា ព្រះ-អង្គទ្រង់ធ្វើរឿងនោះ ឱ្យជាដើមហេតុក្នុងកាសម្ដែងធមិដល់បរិស័ទទាំងឡាយទេសនានោះមានប្រយោជន៍ ដល់មហាជនជាច្រើន ។

## ក្រោយអំពីចេញព្រះវស្សាទី ១៧ ហើយ

(៦) សម័យនោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័នវិហារ គ្រានោះ **ព្រះបាទពិម្ពិសារ** យាងទៅកាន់ស្ទឹងតបោទា ដោយព្រះបំណងនឹងស្រង់ជម្រះព្រះវរកាយ ខណៈនោះ ពួកភិក្ខុកំពុងស្រង់ទឹកក្នុងស្ទឹងតបោទា ទើបព្រះរាជាប្រថាប់នៅក្នុងទីដ៏សមគួរមួយ ដោយតាំងព្រះទ័យថា ទ្រង់នឹងស្រង់ជម្រះ កាលដែលលោកម្ចាស់ស្រង់ទឹកស្រេចហើយ ។

ពួកភិក្ខុសូម្បីឃើញព្រះរាជាយាងមក ក៏នៅតែស្រង់ទឹកតទៅ ធ្វើឱ្យព្រះរាជាត្រូវរង់ចាំអស់ពេលដ៏យូរ រហូតទាល់តែបានស្រង់ជម្រះព្រះវរកាយតាមព្រះបំណង ។ ព្រឹកឡើង ព្រះរាជាយាងទៅគាល់ព្រះមានព្រះភាគពីព្រឹកព្រលឹម ព្រះអង្គត្រាស់សួរដល់ហេតុដែលមកគាល់តាំងពីព្រឹកព្រលឹម ព្រះរាជាបានក្រាបទូលរឿងភិក្ខុស្រង់ទឹកចំពោះព្រះសាស្តា ព្រះអង្គទ្រង់ចង្អុលបង្ហាញឱ្យព្រះរាជាឃើញច្បាស់ សមាទាន អាចហ៊ាន ឱ្យរីករាយដោយធម្មីកថាហើយ ព្រះរាជាថ្វាយបង្គំធ្វើប្រទក្សិណចៀសចេញទៅ ។

ព្រះមានព្រះភាគ ត្រាស់ឱ្យប្រជុំសង្ឃ អាស្រ័យដោយហេតុនោះ ទើបទ្រង់តិះដៀលហើយបញ្ញត្តសិក្ខាបទថា ភិក្ខុណាមួយងូតទឹកហើយនៅមិនទាន់ដល់កន្លះខែ ងូតទឹកទៀតត្រូវអាបត្តិបាចិត្តិយៈ វៀរលែងតែភិក្ខុអាពាធ ភិក្ខុធ្វើនវកម្ម ភិក្ខុដើរផ្លូវឆ្ងាយ ឬក្នុងគ្រាអាកាសធាតុក្តៅ ទ្រង់អនុញ្ញាតឱ្យងូតទឹកបាន ។

(៧) **វក្កលិ** ជាបុត្ររបស់ត្រកូលព្រាហ្មណ៍ក្នុងក្រុងសាវត្ថី រៀនចប់ត្រៃ-

វេទ ឃើញព្រះពុទ្ធអង្គយាងចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី រីករាយក្នុងព្រះរូបឆោម ដែលប្រកបដោយមហាបុរិសលក្ខណៈរបស់ព្រះសាស្ដា ទើបទូលសូមបួសដោយគិតថា យើងនឹងបានឃើញព្រះពុទ្ធអង្គជាប់ជានិច្ច រហូតមិនបំពេញសមណធម៌ សូម្បីក្នុងការបដិបត្តិទាក់ទងនឹងសរីរកិច្ចរបស់ខ្លួនក៏មិនយកចិត្តទុកដាក់ គាល់ជាប់តាមពិនិត្យព្រះលក្ខណៈរបស់ព្រះអង្គគ្រប់ពេលវេលា ។ តមក ព្រះសាស្ដាជ្រាបថា ញាណរបស់ព្រះវក្កលិចាស់ក្លាហើយ ទើបត្រាស់ថា :

**អ្នកណាឃើញធម៌ អ្នកនោះឈ្មោះថាឃើញតថាគត**

**អ្នកណាឃើញតថាគត អ្នកនោះឈ្មោះថាឃើញធម៌**

សូម្បីដូច្នោះ ព្រះវក្កលិក៏មិនលះការមើលព្រះរូបឆោម ទើបព្រះសាស្ដាយាងទៅកាន់ក្រុងរាជគ្រឹះ ទ្រង់បណ្ដេញដោយព្រះតម្រាស់ថា វក្កលិអ្នកចូរចេញទៅ ព្រះវក្កលិខូចចិត្ត ទៅចាំវស្សាក្នុងកាឡសិលា ឯភ្នំឥសិគិលិ លុះចេញវស្សាទើបចូលមកគាល់ព្រះអង្គ នៅវត្តវេឡុវ័ន សំយុត្តនិកាយ ខន្ធវារវគ្គ ពោលថា ខណៈដែលធ្វើដំណើរមកដល់ក្រុងរាជគ្រឹះ លោកមានអាពាធធ្ងន់ ភ្លៅទាំងពីរខាងឈានមិនបាន ពួកអ្នកស្រុកនាំគ្នាជួយយកលោកទៅដាក់ត្រង់រោងជាងឆ្នាំង ព្រះវក្កលិឱ្យភិក្ខុជាឧបដ្ឋាក ទៅក្រាបទូលសូមការអនុគ្រោះ ឱ្យព្រះសាស្ដាយាងមកកាន់ទីនៅរបស់ខ្លួន គ្រានោះព្រះមានព្រះភាគ យាងទៅរកព្រះវក្កលិដល់ទីលំនៅ ត្រាស់សួរដល់អាពាធ ព្រះវក្កលិក្រាបទូលថា ខ្ញុំព្រះអង្គធន់មិនបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គខ្លាំងក្លា មានតែចម្រើនឡើង មិនថយចុះឡើយ

ខ្ញុំព្រះអង្គមិនអាចនឹងចូលទៅគាល់ព្រះអង្គដល់ទីប្រថាប់បាន ។

ព្រះសាស្ដាត្រាស់ថា រាងកាយដ៏ស្អុយដែលអ្នកឃើញនេះនឹងមានប្រយោជន៍អ្វី ម្នាលវក្កលិ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច **រូបទៀង ឬមិនទៀង** ព្រះវក្កលិទូលថា **មិនទៀងទេ** ព្រះអង្គ ព្រះសាស្ដាត្រាស់ថា **វត្ថុណាមិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជាធម្មតាគួរឬ ដែលនឹងឃើញវត្ថុនោះថា នុ៎ះរបស់យើង នុ៎ះជាយើង នុ៎ះជាខ្លួនរបស់យើង ។**

**វេទនា សញ្ញា សង្ខារ វិញ្ញាណ ទៀងឬមិនទៀង ...។ ល ។** ព្រះមានព្រះភាគ ត្រាស់ទូន្មានព្រះវក្កលិដោយឱវាទនេះ ហើយយាងចេញទៅកាន់ភ្នំគិជ្ឈកូដ កាលព្រះមានព្រះភាគចៀសចេញទៅហើយមិនយូរ ព្រះវក្កលិសូមឱ្យភិក្ខុឧបដ្ឋាកសែងទៅកាន់កាឡសីលា ភ្នំឥសិគិលិ ។ រាត្រីនោះទេវតាពីរអង្គ ចូលទៅគាល់ព្រះមានព្រះភាគនៅភ្នំគិជ្ឈកូដ ក្រាបទូលព្រះមានព្រះភាគជាម្ចាស់ថា បពិត្រព្រះអង្គ វក្កលិភិក្ខុកើតគំនិត ដើម្បីការរួចផុត ទេវតាមួយអង្គទៀត ក្រាបទូលថា វក្កលិភិក្ខុនោះរួចផុតល្អហើយ នឹងរួចផុតបានពិតប្រាកដ ។

លុះវេលាព្រឹកឡើង ព្រះអង្គត្រាស់ឱ្យភិក្ខុចូលទៅរកព្រះវក្កលិ ប្រាប់ថាលោកចូរស្ដាប់ ព្រះតម្រាស់របស់ព្រះមានព្រះភាគជាម្ចាស់ និងទេវតាពីរអង្គ ។ ព្រះវក្កលិប្រាប់ភិក្ខុឧបដ្ឋាកឱ្យគ្រាហ៍ចុះចាកគ្រែ ដើម្បីទទួលព្រះតម្រាស់របស់ព្រះសាស្ដា ដែលផ្ដាំមកថា ម្នាលវក្កលិ កុំខ្លាចឡើយ អ្នកនឹងមានសេចក្ដីស្លាប់មិនអន់ថយទេ ។

ព្រះវក្កលិទទួលព្រះតម្រាស់ហើយ ផ្ដាំឱ្យភិក្ខុក្រាបទូលព្រះមានព្រះភាគថា ខ្ញុំព្រះអង្គមិនមានមន្ទិលសង្ស័យថា រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណទៀង ឬមិនទៀង ការពេញចិត្តក្ដី សេចក្ដីត្រេកអរក្ដីក្នុងវត្ថុនោះ មិនមានដល់ខ្ញុំព្រះអង្គទៀតទេ ។ កាលភិក្ខុទាំងនោះត្រឡប់ទៅ ព្រះវក្កលិគិតថា ឥឡូវនេះខ្លួនបានសម្រេចហើយ ទើបនាំសស្ត្រាមកផ្ដាច់ជីវិតខ្លួនឯង ព្រះវក្កលិបានសម្រេចជាព្រះអរហន្ត ហើយបរិនិព្វានក្នុងខណៈជាមួយគ្នានោះឯង ។

គ្រានោះ ព្រះមានព្រះភាគយាងទៅកាន់កាឡសិលា ព្រមដោយភិក្ខុសង្ឃជាច្រើន ទតឃើញព្រះវក្កលិ ដេកមួលកលើគ្រែពីចម្ងាយ ខណៈនោះ ប្រាកដដុំពពកផ្សែងអណ្ដែតទៅគ្រប់ទិស ទើបពួកភិក្ខុក្រាបទូលសួរដល់មូលហេតុ ព្រះមានព្រះភាគត្រាស់នឹងភិក្ខុថា នុ៎ះឯងគឺមារចិត្តបាប កំពុងស្វែងរកវិញ្ញាណរបស់វក្កលិត្ថេរ ម្នាលភិក្ខុទាំងឡាយ វក្កលិបរិនិព្វានហើយ ។ ចំណែកក្នុងខុទ្ទកនិកាយ ថេរគាថា និងខុទ្ទកនិកាយ អបទាន និងអង្គុត្តរនិកាយ ឯកនិបាត ពោលថា ក្រោយពីត្រូវព្រះសាស្ដាបណ្ដេញ ព្រះវក្កលិគិតថា នឹងមានប្រយោជន៍អ្វីដោយជីវិតរបស់យើង ទើបឡើងទៅឈរនៅលើមាត់ជ្រោះលើភ្នំគិជ្ឈកូដ ព្រះសាស្ដាទ្រង់ជ្រាបទ្រង់ត្រិះរិះថា ភិក្ខុនេះបើមិនបានលួងលោមចិត្តអំពីតថាគត ក៏នឹងទម្លាយឧបនិស្ស័យនៃមគ្គផលចោល ទើបទ្រង់ផ្សាយឱភាសទៅសម្ដែងព្រះអង្គឱ្យប្រាកដត្រាស់គាថាថា : **ភិក្ខុអ្នកច្រើន ទៅដោយបាមោជ្ជៈ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា នឹងសម្រេចសន្តិបទ ជាការរម្ងាប់សង្ខារឱ្យជាសុខបាន**

ហើយលាព្រះហស្ថប្រទានដល់ព្រះវក្កលិ ត្រាស់ថា មកចុះវក្កលិ ។

ព្រះវក្កលិកើតបីតិសោមនស្សយ៉ាងខ្លាំងថា យើងឃើញព្រះទសពល ហើយ ទើបលោតចុះទៅព្រមជាមួយការគ្របសង្កត់បីតិ កណ្ដាលអាកាសនុ៎ះឯង សម្រេចអរហត្តផលព្រមទាំងបដិសម្ភិទា ហើយចុះមកថ្វាយបង្គំព្រះសាស្ដា ។ តមក ខណៈដែលព្រះសាស្ដា ទ្រង់គង់កណ្ដាលភិក្ខុសង្ឃ ត្រាស់សរសើរព្រះវក្កលិត្ថេរថា ជាកំពូលជាងភិក្ខុទាំងពួង អ្នកបង្អោនទៅក្នុងសទ្ធា ។ (រឿងនេះមានសេចក្ដីខុសគ្នាបន្តិច សូមអ្នកសិក្សាពិចារណាផង)

បន្ទាប់ពីនោះ ព្រះអង្គយាងចារិកទៅប្រោសវេនេយ្យសត្វ ក្នុងទីផ្សេងៗ តែមិនបានប្រាប់ថា យាងទៅគង់ក្នុងទីណាខ្លះ លុះជិតចូលព្រះវស្សាទើបយាងទៅកាន់ភ្នំចាលិកា ។

# ព្រះវស្សាទី ១៨

## ទ្រង់គង់ចាំព្រះវស្សា ក្នុងចាលិកបព៌ត ដែនចាលិកា

(១) ក្នុងចន្លោះចាំព្រះវស្សាទី ១៨ នេះ មិនមានទីអាងដែលពោល ថា ព្រះពុទ្ធអង្គទ្រង់សម្តែងធម៌ប្រោសអ្នកណាខ្លះ ទើបនាំយករឿងក្នុងខុទ្ទក-និកាយ **វិមានវត្ថុ** ដែលជារឿងទាក់ទងជាមួយបុគ្គលក្នុងសម័យពុទ្ធកាល ដែលសាងសន្សំបុណ្យដោយសទ្ធា ធ្វើមរណកាលហើយទៅកើតក្នុងទេវលោក ដើម្បីឱ្យជាក់ច្បាស់ក្នុងផលនៃកុសលកម្ម ដូចតទៅនេះ :

សម័យនោះ ព្រះមហាមោគ្គល្លានត្រិះរិះថា បណ្តាមនុស្សទាំងឡាយមានព្រមដោយទេយ្យធម៌ និងទក្ខិណេយ្យបុគ្គល ព្រមទាំងចិត្តជ្រះថ្លា នាំគ្នាបំពេញកុសលបានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិដ៏វិសេសវិសាល គួរយើងនឹងចារិកទៅទេវលោក ដើម្បីនាំដំណឹងជាផលនៃកុសលដែលជនទាំងឡាយសាងសន្សំទុកហើយ មកក្រាបទូលព្រះសាស្តា ដើម្បីបានទ្រង់ប្រកាសនូវកុសលកម្មទាំងឡាយដែលគេធ្វើ សូម្បីមានប្រមាណតិច ក៏នៅតែបានទៅកាន់ទេវ-លោក ព្រះធម្មទេសនានោះនឹងជាប្រយោជន៏ដល់ជនជាច្រើន ទើបទៅក្រាបទូលសេចក្តីត្រិះរិះនោះដល់ព្រះសាស្តា ។

ព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ព្រះមហាមោគ្គល្លានថ្វាយបង្គំធ្វើប្រទក្សិណហើយចូលចតុត្ថជ្ឈានជាបាទនៃអភិញ្ញា ចេញចាកចតុត្ថជ្ឈាននោះហើយ ឡើងទៅកាន់ទេវលោក សាកសួរដល់បុញ្ញកម្មតាមដែលទេវតានោះៗ

សាងសន្ទំទុកហើយ កាលត្រឡប់អំពីទេវលោកមកកាន់មនុស្សលោកវិញ ក្រាបទូលរឿងទាំងអស់ថ្វាយព្រះសាស្តា ព្រះអង្គទ្រង់ធ្វើរឿងនោះឱ្យជាហេតុ ហើយទ្រង់សម្តែងធម៌ប្រោសបរិស័ទទាំងឡាយដែលមកប្រជុំគ្នា ដូចមានរឿងតទៅនេះ :

**កញ្ជិកទាយិកាវិមាន** សម័យនោះ ព្រះមានព្រះភាគជាម្ចាស់ប្រឈួនដោយរោគខ្យល់ក្នុងព្រះនាភី (ផ្ចិត) ទ្រង់បំណងត្រូវការទឹកបាយដើម្បីធ្វើថ្នាំ ព្រះអានន្ទទៅបិណ្ឌបាត ត្រង់ផ្ទះពេទ្យជាឧបដ្ឋាក ភរិយាគ្រូពេទ្យជាអ្នកមានបញ្ញា ឃើញថាបាត្រនេះជាបាត្ររបស់ព្រះពុទ្ធអង្គ សង្កេតដឹងថាព្រះថេរៈមិនមែនមកដើម្បីចង្ហាន់ កាលព្រះថេរៈប្រាប់ថាត្រូវការទឹកបាយ នាងគិតថា នឹងតាក់តែងទឹកបាយដ៏សមគួរដល់ព្រះពុទ្ធអង្គ ទើបចម្អិនយាគូដោយផ្លែពុទ្រា និងវត្ថុដទៃៗ ដាក់ពេញបាត្រ ហើយរៀបចំភោជនយ៉ាងដទៃ ជាបរិក្ខាររបស់យាគូ បញ្ជូនទៅថ្វាយ លុះព្រះមានព្រះភាគសោយយាគូនោះ អាពាធក៏ជាសះស្បើយ ។

តមក នាងធ្វើមរណកាល ហើយបានទៅកើតក្នុងភពតាវត្តិង្ស ព្រះមហាមោគ្គល្លានបានជួបនាងទេពធីតា សួរនាងថា នាងមានវណ្ណៈល្អពន្លឺស្វាងស្វៃទៅគ្រប់ទិស ដូចជាផ្កាយព្រឹក អាត្មាសូមសួរថា កាលកើតជាមនុស្សនាងបានធ្វើបុណ្យអ្វីទើបមានអានុភាពរុងរឿងដូច្នេះ ព្រោះបុណ្យអ្វី ទើបផលនេះសម្រេចដល់នាង ។ នាងទេពធីតាឆ្លើយថា នាងខ្ញុំបានថ្វាយទឹកបាយដែលតាក់តែងដោយផ្លែពុទ្រា អប់ដោយប្រេង ផ្សំដោយដីប្លី និងខ្ទឹមជាដើម អប់យ៉ាងល្អ ឱ្យយាគូនោះមានក្លិនម្រេច ហើយដាក់ចុះក្នុងបាត្ររបស់ព្រះតថាគត បាន

ថ្វាយចំពោះព្រះសាស្ដា ដោយចិត្តជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ វិមាន និងភោគៈទាំងឡាយនេះ នាងខ្ញុំបានមកដោយផលនៃបុណ្យនោះ ។ កាលទេពធីតាប្រកាសប្រាប់ដល់កម្មដែលនាងបានសន្សំទុកហើយ ព្រះមហាមោគ្គល្លានបានសម្ដែងធម៌ ដល់នាងព្រមទាំងបរិវារ ហើយត្រឡប់មកកាន់មនុស្សលោក ក្រាបទូលរឿងនោះថ្វាយចំពោះព្រះពុទ្ធអង្គ ។

**តតិយនាគវិមាន** សម័យនោះ ព្រះមានព្រះភាគជាម្ចាស់គង់នៅក្នុងវត្តវេឡុវ័ន ក្រុងរាជគ្រឹះ មានព្រះថេរៈខីណាស្រព ៣ អង្គ ចាំវស្សាក្នុងអាវាសជិតភូមិ ១ លុះចេញព្រះវស្សាបវារណាហើយ ព្រះថេរៈទាំងនោះប្រាថ្នានឹងថ្វាយបង្គំព្រះសាស្ដា ទើបធ្វើដំណើរឆ្ពោះទៅក្រុងរាជគ្រឹះ តាមចន្លោះផ្លូវបានឆ្លងកាត់ចំការអំពៅរបស់ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់ ខណៈនោះ ជាវេលាល្ងាចហើយ ព្រះ-ថេរៈសួរអ្នកយាមចំការអំពៅថា ថ្ងៃនេះអាចធ្វើដំណើរដល់ក្រុងរាជគ្រឹះទេ អ្នកយាមឆ្លើយថា មិនអាចទេទាន ! ក្រុងរាជគ្រឹះនៅឆ្ងាយពីទីនេះកន្លះយោជន៍ និមន្តលោកម្ចាស់សម្រាកទីនេះសិន ស្អែកឡើងសឹមនិមន្តទៅ ខ្ញុំករុណានឹងរៀបចំទីសម្រាកប្រគេន ទើបព្រះថេរៈទាំង ៣ ស្នាក់នៅក្នុងទីនោះ តាមពាក្យនិមន្ត ។

អ្នកយាមចំការអំពៅនោះ ចងកំណាត់ឈើជាប់ដើមអំពៅ យកស្លឹកអំពៅប្រក់ខាងលើ ក្រាលចំបើងខាងក្រោម ប្រគេនព្រះថេរៈមួយអង្គ ហើយមួយអង្គទៀត យកអំពៅបីដើមចងទល់ជាសសរបី ហើយប្រក់ដោយស្មៅ ក្រាលផ្ទៃដោយស្មៅ ប្រគេនព្រះថេរៈអង្គទីពីរ ហើយនាំយកឈើពីរបីកំណាត់ក្នុងខ្ទម

របស់ខ្លួន និងមែកឈើទាំងឡាយ គ្របដោយចីវរក្លស់ (ដូចឆ័ត្រ) ប្រគេនដល់ព្រះថេរៈអង្គទីបី ។

លុះអរុណរះឡើង អ្នកយាមចំការនោះបានដាំបាយ ប្រគេនឈើស្ទន់ទឹកលប់មុខ ហើយប្រគេនភត្តាហារព្រមដោយទឹកអំពៅ ព្រះថេរៈទាំងនោះឆាន់ហើយ ក៏អនុមោទនា កាលព្រះថេរៈរៀបនឹងចេញដំណើរ ទើបបានប្រគេនអំពៅមួយអង្គមួយដើមៗ ជូនដំណើរ ព្រះថេរៈល្មមសមគួរហើយក៏ត្រឡប់វិញ ម្ចាស់របស់ចំការជាមនុស្សមិច្ឆាទិដ្ឋិ ដើរបញ្ច្រាសផ្លូវមក សួរភិក្ខុថា បានអំពៅពីទីណា កាលភិក្ខុឆ្លើយថា អ្នកយាមចំការប្រគេន ព្រាហ្មណ៍ខឹងសម្បាយកដំបងវាយអ្នកយាមរហូតដល់ស្លាប់ អ្នកយាមចំការនឹកដល់បុណ្យដែលខ្លួនធ្វើ ក្នុងព្រះថេរៈទាំងបី បានទៅកើតក្នុង **សុធម្មាទេវសភា** មានដំរីទិព្វកើតឡើងដោយបុញ្ញានុភាពរបស់ខ្លួន ។ មាតាបិតា និងញាតិមិត្រដឹងដំណឹងមរណកាល នាំគ្នាមកធ្វើឈាបនកិច្ចក្នុងទីនោះឯង ខណៈនោះ ទេវបុត្រនោះជិះដំរីទិព្វ ចុះចាកទេវលោកហែហមដោយបរិវារជាច្រើន ដោយទេវឫទ្ធិ ប្រាកដកាយឱ្យឃើញក្នុងទីប្រជុំនោះ គ្រានោះ បណ្ដាញាតិមិត្រទាំងឡាយ បានសួរដល់បុញ្ញកម្មរបស់ទេវបុត្រ ។

ទេវបុត្រឆ្លើយថា ខ្ញុំបានប្រគេនខ្ទមអំពៅ ខ្ទមស្មៅ និងខ្ទមសំពត់ សម្បត្តិនេះខ្ញុំបានមកដោយបុណ្យនោះ ហើយប្រកាសគុណរបស់ព្រះរតនត្រៃ រីករាយជាមួយមាតាបិតាហើយ ត្រឡប់ទៅកាន់ទេវលោកវិញ ។ មនុស្សទាំងឡាយ កាលស្ដាប់ពាក្យរបស់ទេវបុត្រនោះហើយ កើតសេចក្ដីជ្រះថ្លាជាច្រើន ក្នុងព្រះមាន

ព្រះភាគជាម្ចាស់ និងភិក្ខុសង្ឃ ត្រៀមទេយ្យធម៌ជាច្រើនរទេះ នាំគ្នាទៅកាន់វេឡុវ័នវិហារ ថ្វាយទានដល់ភិក្ខុសង្ឃដែលមានព្រះពុទ្ធអង្គជាប្រធាន ព្រះមោគ្គល្លានត្ថេរ បានក្រាបទូលរឿងនោះដល់ព្រះសាស្តា ព្រះអង្គសម្តែងធម៌ដោយមានរឿងនោះជាហេតុ ឱ្យមនុស្សទាំងឡាយតាំងនៅក្នុងសរណៈ និងសីល ជនទាំងនោះមានសទ្ធាតាំងមាំ ថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់ ត្រឡប់ទៅផ្ទះហើយ នាំគ្នាកសាងវិហារ ត្រង់ទីដែលអ្នកយាមចំការអំពៅធ្វើមរណកាលនោះ ។

**វិហារវិមាន** កាលព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន ក្រុងសាវត្ថី មហាឧបាសិកាវិសាខា សាងមិគារមាតុប្រាសាទ ក្នុងបុព្វារាម កាលមិគារមាតុប្រាសាទសម្រេចរៀបរយហើយ នាងព្រមដោយស្រីជាសម្លាញ់ ៥០០ នាក់ឡើងទៅទស្សនាប្រាសាទ នាងពោលជាមួយសម្លាញ់ថា នាងទាំងឡាយចូរអនុមោទនាបុណ្យ ខ្ញុំសូមឱ្យចំណែកបុណ្យដល់ពួកនាង សូមពួកនាងចូរមានចំណែកនៃបុណ្យ ដែលខ្ញុំខ្វល់ខ្វាយនេះផង ស្រីជាសម្លាញ់ទាំងអស់មានចិត្តជ្រះថ្លាធ្វើអនុមោទនាថា សាធុ សាធុ ល្អណាស់ ។ តមក មិនយូរសម្លាញ់ម្នាក់ស្លាប់ទៅទៅកើតក្នុងភពតាវត្តិង្ស មានវិមានធំដ៏ល្អស្កឹមស្កៃ អណ្តែតនៅលើអាកាសផ្សាយរស្មីទៅឆ្ងាយ ដោយបុញ្ញានុភាពរបស់នាង ។

គ្រានោះ ព្រះអនុរុទ្ធត្ថេរ ត្រាច់ចារិកទៅក្នុងភពតាវត្តិង្ស ឃើញសម្លាញ់របស់នាងវិសាខាហើយ សួរថា នាងធ្វើកម្មអ្វីទើបបានវិមានដ៏វិចិត្រនេះ នាងឆ្លើយថា វិមានដ៏អស្ចារ្យគួរឱ្យទស្សនានេះ នាងខ្ញុំបានមកដោយផលនៃ ការអនុ-

មោទនាដ៏បរិសុទ្ធក្នុងកុសលរបស់សម្លាញ់ ឈ្មោះវិសាខា កាលនាងកសាងប្រាសាទស្រេច កំពុងវេរថ្វាយដល់សង្ឃ នាងឱ្យចំណែកបុណ្យដល់នាងខ្ញុំ សូម្បីនាងខ្ញុំមិនមានការបរិច្ចាគទេយ្យធម៌ឡើយ តែនាងខ្ញុំជ្រះថ្លាក្នុងកុសលរបស់សម្លាញ់ កើតសទ្ធាក្នុងព្រះរតនត្រៃ និងជឿផលនៃកម្ម ទើបអនុមោទនាដោយចិត្តបរិសុទ្ធ ព្រះអនុរុទ្ធពោលថា នាងបានវិមានដ៏អស្ចារ្យគួរឱ្យ ទស្សនានេះ ដោយអនុមោទនាដ៏បរិសុទ្ធនោះឯង នាងចូរប្រាប់គតិរបស់នាងវិសាខាដែលបានថ្វាយទាននោះថាទៅកើតទីណា ។

នាងទេពធីតាឆ្លើយថា បពិត្រលោកម្ចាស់ វិសាខាមហាឧបាសិកាមរណៈហើយទៅកើតក្នុងស្ថានសួគ៌ជាន់និម្មានរតី ជាមហេសីរបស់ស្តេចសុនិម្មិតទេវរាជ ព្រោះនាងជាម្ចាស់របស់ទាន និងមានសទ្ធាពេញបរិបូរណ៍ ព្រះអនុរុទ្ធត្រឡប់ចាកទេវលោកហើយ ក្រាបទូលសេចក្តីនោះថ្វាយព្រះសាស្តា ។

**មណ្ឌូកទេវបុត្តវិមាន** សម័យមួយ ព្រះមានព្រះភាគគង់នៅមាត់ស្រះបោក្ខរណី ឈ្មោះគគ្គរា ក្នុងនគរចម្បា វេលាជិតភ្លឺទ្រង់ចេញចាកសមាបត្តិហើយត្រួតមើលពួកវេនេយ្យសត្វដែលអាចនឹងណែនាំបាន ទ្រង់ឃើញថា វេលាល្ងាចថ្ងៃនេះ ខណៈដែលតថាគតកំពុងសម្តែងធម៌ កង្កែបមួយនឹងកាន់យកនិមិត្តក្នុងសំឡេងរបស់តថាគត នឹងស្លាប់ដោយសេចក្តីព្យាយាមរបស់អ្នកដទៃ ហើយនឹងទៅកើតក្នុងទេវលោក ព្រះអង្គបំណងនឹងឱ្យមហាជន ឃើញកង្កែបនោះព្រមដោយទេពបរិវារ ទើបយាងចូលទៅបិណ្ឌបាតក្នុងនគរចម្បា ព្រមដោយភិក្ខុសង្ឃជាច្រើន ។

ក្រោយភត្តកិច្ច កាលភិក្ខុទាំងឡាយធ្វើវត្តបដិបត្តិហើយ ទៅកាន់ទីសម្រាកពេលថ្ងៃរៀង១ខ្លួន ចំណែកព្រះអង្គយាងចូលព្រះគន្ធកុដិ ទ្រង់ប្រើពេលកន្លះថ្ងៃឱ្យអស់ទៅដោយសេចក្ដីសុខក្នុងផលសមាបត្តិ លុះវេលាល្ងាច យាងចូលមណ្ឌបសាលាប្រជុំសម្ដែងធម៌ត្រង់មាត់ស្រះបោក្ខរណី ។ ក្នុងខណៈនោះ កង្កែបមួយឡើងពីស្រះបោក្ខរណី ក្រាបនៅចុងបំផុតបរិស័ទ កាន់យកនិមិត្តក្នុងព្រះសូរសៀងរបស់ព្រះពុទ្ធអង្គថា សំឡេងនេះឈ្មោះថា ធម៌ ក្នុងវេលាជាមួយគ្នានោះមនុស្សចិញ្ចឹមគោម្នាក់មកកាន់ទីនោះ ឃើញព្រះពុទ្ធអង្គកំពុងសម្ដែងធម៌ ក្នុងជំនុំបរិស័ទដែលកំពុងស្ដាប់ធម៌យ៉ាងស្ងៀមស្ងាត់ មនុស្សចិញ្ចឹមគោឈរពិចារណាទៅតាមព្រះធម៌មិនបានឃើញកង្កែប បានច្រត់ដំបងដែលគៀងគោចុះទៅចំក្បាលកង្កែប កង្កែបដែលមានចិត្តជ្រះថ្លាដោយធម្មសញ្ញា ធ្វើមរណកាលក្នុងពេលនោះឯង ទៅកើតក្នុងវិមានមាស នៅភពតាវត្តិង្សដូចដេកលក់ហើយភ្ញាក់ឡើងដូច្នោះ ។

**មណ្ឌូកទេវបុត្ត** ឃើញខ្លួនឯងត្រូវពួកទេពអប្សរហែហម ទើបពិចារណាមើលដឹងថា យើងបានកើតក្នុងទីនេះ មានសម្បត្តិដូច្នេះ ព្រោះការកាន់យកនិមិត្តក្នុងព្រះសូរសៀងរបស់ព្រះសាស្ដា ទើបចុះចាកវិមានទាំងដែលមហាជនឃើញនោះឯង ចូលទៅថ្វាយបង្គំព្រះយុគលបាទរបស់ព្រះមានព្រះភាគដោយសិរសា ហើយឈរផ្គងអញ្ជលីនមស្ការ ដោយអានុភាពទេវសម្បត្តិព្រមទាំងបរិវារ ។

ព្រះមានព្រះភាគទ្រង់ជ្រាបរឿងទេវបុត្តនោះ ដើម្បីធ្វើផលនៃកម្ម និងពុទ្ធានុភាពឱ្យប្រចក្សច្បាស់ដល់មហាជន ទើបត្រាស់សួរទេវបុត្តថា នរណាហ្ន៎

រុងរឿងដោយឫទ្ធិ ដោយយស មានវណ្ណៈល្អ មានពន្លឺភ្លឺស្វាងគ្រប់ទិស កំពុងថ្វាយបង្គំបាទារបស់តថាគត ទេវបុត្តទូលថា កាលជាតិមុន ខ្ញុំព្រះអង្គជាកង្កែប ពេលកំពុងស្តាប់ព្រះធម៌របស់ព្រះអង្គ អ្នកចិញ្ចឹមគោច្រត់ដំបងចំលើក្បាល ធ្វើឱ្យខ្ញុំព្រះអង្គដល់នូវសេចក្តីស្លាប់ បពិត្រព្រះគោតម ជនពួកណាបានស្តាប់ធម៌របស់ព្រះអង្គ សូម្បីក្នុងវេលាដ៏ខ្លី អានិសង្សអំពីការស្តាប់ធម៌ នឹងធ្វើឱ្យជនទាំងនោះបានទៅកើតក្នុងទេវលោក ដូចជាខ្ញុំព្រះអង្គនេះឯង ។ ព្រះសាស្តាសម្តែងធម៌ប្រោសមណ្ឌូកទេវបុត្តបានសម្រេចសោតាបត្តិផល ព្រមទាំងពួកជនជាច្រើនក្នុងទីនោះឯង ។

ព្រះវិន័យមហាវិភង្គ បឋមភាគ វេរញ្ជកណ្ឌវណ្ណនា អធិប្បាយព្រះ-ពុទ្ធគុណ បទថា **ទេវមនុស្សានំ** ព្រះមានព្រះភាគទ្រង់ជាសាស្តាសូម្បីរបស់ពួកសត្វតិរច្ឆាន ព្រោះទ្រង់ប្រទានអនុសាសនីឱ្យដូចគ្នា ពិតមែន សត្វតិរច្ឆានទាំងនោះ សូម្បីមិនអាចសម្រេចមគ្គផលបានក្នុងអត្តភាពនោះ តែមានឱកាសសម្រេចបានក្នុងអត្តភាពទី ២ ឬទី ៣ ព្រោះជាអ្នកមានឧបនិស្ស័យសម្បត្តិ គឺ សេចក្តីល្អជាបាទនៅក្នុងចិត្តដែលសត្វនោះសន្សំមកពីអតីតៈ ជាធម៌ដាស់តឿនទំនុកបម្រុងឱ្យសម្រេចមគ្គផលបាន ។

## ក្រោយពីចេញព្រះវស្សាទី ១៨ ហើយ

(២) ព្រះពុទ្ធអង្គយាងទៅដែនអាឡវីជាលើកទី ២ ទៀត ដើម្បីទ្រង់ប្រោសធីតាជាងតម្បាញ ព្រោះទ្រង់ជ្រាបក្នុងសំណាញ់ញាណថា កុមារិកានេះបានចម្រើនមរណស្សតិមកអស់ ៣ ឆ្នាំហើយ ចាប់តាំងពីបានស្តាប់ព្រះធម៌ទេសនាក្នុងដែនអាឡវី ពេលដែលព្រះអង្គយាងមកចាំព្រះវស្សាទី ១៦ ព្រះអង្គទ្រង់ជ្រាបថា កាលសម្តែងព្រះធម្មទេសនាប្រោសកុមារីនេះ ទេសនានោះនឹងបានជាប្រយោជន៍ដល់មហាជនជាច្រើន ទើបនាំភិក្ខុប្រមាណ ៥០០ រូប យាងចារិកមកកាន់ដែនអាឡវី ។ ពួកអ្នកក្រុងអាឡវី ដឹងដំណឹងយាងមករបស់ព្រះពុទ្ធអង្គ នាំគ្នាមកទូលអារាធនាដើម្បីថ្វាយភត្តាហារ ដល់ព្រះពុទ្ធអង្គព្រមដោយភិក្ខុសង្ឃ ធីតាជាងតម្បាញត្រេកអរយ៉ាងក្រៃលែង ដែលបានឃើញ និងស្តាប់ព្រះធម៌ពីព្រះសាស្តាទៀត ។

គាប់ជួនបិតាបានបញ្ជាឱ្យនាងរវៃអំបោះ ដើម្បីត្បាញសំពត់ឱ្យស្រេចក្នុងថ្ងៃនោះ ទើបនាងសម្រេចចិត្តថា រវៃអំបោះឱ្យឪពុកជាស្រេចសិន ហើយនឹងទៅស្តាប់ព្រះធម៌ ។ ក្រោយពីថ្វាយភត្តាហារដល់ព្រះពុទ្ធអង្គ និងភិក្ខុសង្ឃហើយ អ្នកក្រុងអាឡវីក៏រង់ចាំដើម្បីទទួលការអនុមោទនា ព្រះអង្គទ្រង់គង់ស្ងៀមដោយព្រះតម្រិះថា តថាគតតាំងចិត្តនឹងមកប្រោសនាងកុមារិកា ធីតាជាងតម្បាញ ដូច្នោះ ទើបសមគួររង់ចាំសិន ។ កាលនាងរវៃអំបោះស្រេច ទើបនាំអំបោះដែល រវៃហើយយកទៅឱ្យឪពុកនៅរោងតម្បាញ ផ្លូវដែលទៅនោះត្រូវ

ឆ្លងកាត់រោងបុណ្យ ដែលព្រះសាស្តាទ្រង់គង់នៅ កណ្តាលពួកបរិស័ទដែលកំពុងអង្គុយរង់ចាំស្តាប់ព្រះធម៌ទេសនា នាងសម្លឹងឃើញព្រះសាស្តាទតព្រះនេត្រមកចំនាង ទើបដាក់កន្ត្រកអំបោះចុះ ហើយចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរ ។

មានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះសាស្តារង់ចាំការមករបស់កុមារិកានោះ ?

ឆ្លើយថា បានឮថា ព្រះអង្គទ្រង់ជ្រាបថា ក្នុងថ្ងៃនេះកុមារីកាលទៅអំពីទីនេះនឹងស្លាប់ ហើយនឹងមានគតិមិនទៀងទាត់ តែបើនាងបានស្តាប់ធម៌ទេសនាសម្រេចសោតាបត្តិផលហើយទើបទៅ នាងនឹងមានគតិទៀងទាត់ នឹងបានទៅកើតក្នុងតុសិតវិមាន ខណៈដែលកុមារីចូលមកគាល់ និងថ្វាយបង្គំហើយព្រះ-អង្គត្រាស់សួរនាងថា **នាងមកពីណា ?** កុមារិកាទូលថា **ខ្ញុំម្ចាស់មិនដឹងទេ ព្រះអង្គ** , ព្រះអង្គសួរថា **នាងនឹងទៅទីណា ?** កុមារិកាទូលថា **ខ្ញុំម្ចាស់មិនដឹងទេ ព្រះអង្គ** , ព្រះអង្គសួរថា **នាងមិនដឹងឬ ?** កុមារិកាទូលថា **ខ្ញុំម្ចាស់ដឹង ព្រះអង្គ** , ព្រះអង្គសួរថា **នាងដឹងឬ ?** កុមារិកាទូលថា **ខ្ញុំម្ចាស់មិនដឹងទេ ព្រះអង្គ** ។

ប្រជាជនក្នុងទីប្រជុំនាំគ្នាពោលថា ធីតាជាងតម្បាញនេះ ចរចាលេងសើចជាមួយព្រះពុទ្ធអង្គ អ៊ីចឹង ។ ព្រះអង្គទ្រង់ប្រាថ្នាឱ្យជនទាំងឡាយយល់នាងកុមារីនោះ ទើបត្រាស់សួរនាងថា កាលតថាគតសួរនាងថា មកពីណា ព្រោះហេតុអី

ទើបនាងឆ្លើយថា មិនដឹង ?

នាងក្រាបទូលថា ខ្ញុំម្ចាស់យល់ថាព្រះអង្គត្រាស់សួរដោយ **អំណាចនៃបដិសន្ធិ** ថា មកពីណា ខ្ញុំម្ចាស់មិនដឹងថា មកពីនរក ឬទេវលោក ទើបខ្ញុំម្ចាស់ទូលឆ្លើយថា មិនដឹង ។

ព្រះអង្គត្រាស់សួរទៀតថា កាលតថាគតសួរថា នាងនឹងទៅទីណា ហេតុអ្វីទើបឆ្លើយថា មិនដឹង នាងក្រាបទូលថា ខ្ញុំម្ចាស់យល់ថា ព្រះអង្គត្រាស់សួរ **ដោយអំណាចនៃចុតិ** ថា នឹងទៅទីណា ព្រោះខ្ញុំម្ចាស់មិនដឹងថានឹងទៅនរក ឬទេវលោក ទើបខ្ញុំម្ចាស់ឆ្លើយថា មិនដឹង ។ ព្រះអង្គត្រាស់សួរថា កាលតថាគតសួរថា នាងមិនដឹងឬ ហេតុអ្វីនាងត្រឡប់ឆ្លើយថា ដឹង ។ នាងឆ្លើយថា ខ្ញុំម្ចាស់រមែងដឹងថា **ដោយអំណាចនៃសេចក្តីស្លាប់** សត្វទាំងឡាយទាំងពួងត្រូវតែស្លាប់ពិតប្រាកដ ទើបខ្ញុំម្ចាស់ក្រាបទូលថា ដឹង ។ ព្រះអង្គត្រាស់សួរទៀតថា កាលតថាគតសួរថា នាងដឹងឬ ហេតុអ្វីនាងត្រឡប់ឆ្លើយថាមិនដឹង ។ នាងឆ្លើយថា ខ្ញុំម្ចាស់ដឹងថា **ត្រូវតែស្លាប់ តែមិនដឹងដល់កាល** ថា ខ្ញុំម្ចាស់ត្រូវស្លាប់ពេលណា ថ្ងៃនេះ ឬស្អែក ទើបខ្ញុំម្ចាស់ក្រាបទូលថា មិនដឹង ។

ព្រះសាស្តាទ្រង់អនុមោទនាបញ្ហា ដែលកុមារិកានោះវិសជ្ជនាយថា សាធុ សាធុ ៗ ទារិកានេះជាបណ្ឌិត ចូរចាំទុកថាជនពួកណាមិនមានបញ្ញា ជនពួកនោះដូចជាមានភ្នែកខ្វាក់ ហើយត្រាស់គាថាថា :

**លោកនេះងងឹត ក្នុងលោកនេះតិចគ្នាណាស់នឹងឃើញបាន**

**តិចនាក់ណាស់ដែលទៅស្ថានសួគ៌ ដូចជាបក្សីជាប់សំណាញ់ តិចណាស់ដែលនឹងរួចផុតចាកសំណាញ់បាន ដូច្នោះឯង ។**

កាលចប់ព្រះធម៌ទេសនា កុមារិកានោះបានសម្រេច **សោតាបត្តិផល** ថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់ ហើយកាន់កន្ត្រកអំបោះឡើតទៅកាន់រោងតម្បាញរបស់ឪពុក ឪពុកឃើញនាងក៏ខឹងឆេវថា មកយឺតណាស់ ទើបគប់ត្រល់ទៅយ៉ាងខ្លាំង ត្រល់អំបោះនោះបុកត្រង់ពោះរបស់នាងកុមារិកា អស់ជីវិតក្នុងទីនោះឯង នាងកុមារិកាទៅកើតក្នុងស្ថានសួគ៌ជាន់តុសិត ។

( ៣ ) **ជាងតម្បាញជាបិតា** ខូចចិត្តខ្លាំងណាស់ គិតថា ជនទាំងឡាយនឹងយល់ថា យើងសម្លាប់ធីតា សូម្បីព្រះរាជាក៏នឹងដាក់អាជ្ញាយ៉ាងធ្ងន់ ទើបរត់គេចទៅស្នាក់ក្នុងព្រៃជាមួយនឹងភិក្ខុទាំងឡាយ សូមបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនា ភិក្ខុទាំងនោះ ទាំងឧបជ្ឈាយ៍ និងអាចារ្យឱ្យរៀនកម្មដ្ឋានពួក ៥ ប្រកបព្យាយាមមិនយូរប៉ុន្មាន ក៏សម្រេចអរហត្តផល ។

តមក ក្នុងថ្ងៃមហាបវារណា ភិក្ខុទាំងអស់ចូលមកគាល់ព្រះអង្គ ក្នុងក្រុងអាឡវី ដោយគិតថា នឹងបវារណាវិសុទ្ធិបវារណា អ្នកក្រុងអាឡវីឃើញភិក្ខុជាបិតាហើយ នាំគ្នានិយាយស៊កសៀតថា លោកសម្លាប់ធីតាហើយ ឥឡូវនេះមកដើម្បីសម្លាប់អ្នកណា ព្រះមានព្រះភាគត្រាស់ថា ភិក្ខុនេះមិនបានសម្លាប់ធីតាទេ ធីតានោះស្លាប់តាមកម្មរបស់ខ្លួន ។

ដើម្បីប្រកាសភិក្ខុជាងតម្បាញនោះ ជាព្រះខីណាស្រពហើយ ព្រះអង្គត្រាស់ **មុនិសូត្រ** ដើម្បីសម្ដែងធម៌ដល់ភិក្ខុទាំងឡាយថា អ្នកណាសង្រួមខ្លួនដោយការសង្រួមសីលក្នុងកាយទ្វារ វចីទ្វារ និងមនោទ្វារ រមែងមិនធ្វើបាបក្នុងកាលណាៗ ព្រោះមានចិត្តឆ្ងាយចាកបាបទាំងពួង ដោយសមុច្ឆេទវិរតិ ។ ភិក្ខុនេះជាខីណាស្រពមិនខឹងក្រោធ មិនគួរពោលបៀតបៀន និងចាក់ដោតស៊កសៀតដោយកាយ ឬ វាចា ភិក្ខុនេះជាបុគ្គលគួរគោរពនមស្ការដោយពិត ។

(៤) ក្នុងសម័យដែលគង់នៅក្នុង **អគ្គាឡវចេតិយ** ព្រះអង្គត្រាស់នឹងភិក្ខុទាំងឡាយថា អ្នកទាំងឡាយចូរចងចាំ **ហត្ថកឧបាសក** ថា ជាអ្នកប្រកបដោយធម៌គួរឱ្យអស្ចារ្យ ដែលមិនធ្លាប់មានមក ៧ ប្រការ គឺ : **ជាអ្នកមានសទ្ធា ១ មានសីល ១ មានហិរិ ១ មានឱត្តប្បៈ ១ ជាពហុស្សូត ១ មានចាគៈ ១ និងមានបញ្ញា ១** កាលមានព្រះតម្រាស់ ដូច្នេះហើយ យាងចុះចាកអាសនៈចូលទៅកាន់ព្រះវិហារ ។

ព្រឹកឡើង ភិក្ខុមួយរូបចូលទៅបិណ្ឌបាតឯគេហដ្ឋានរបស់ហត្ថកឧបាសក បានពោលនឹងហត្ថកឧបាសកថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់សរសើរថា លោកជាអ្នកដែលប្រកបដោយធម៌ ៧ ប្រការ គួរអស្ចារ្យដែលមិនធ្លាប់មានមក ។ ហត្ថកឧបាសកសួរភិក្ខុនោះថា គ្រហស្ថជាអ្នកស្លៀកស ពាក់ស មិនមានតំណែងដែលព្រះអង្គទ្រង់ព្យាករនេះឬ ភិក្ខុនោះ ឆ្លើយថា មិនមានទេអ្នកដ៏មានអាយុ ។

ភិក្ខុរូបនោះត្រឡប់ពីបិណ្ឌបាតវិញ វេលាក្រោយភត្តចូលទៅគាល់ព្រះ

អង្គ ក្រាបទូលរឿងនោះឱ្យទ្រង់ជ្រាប ព្រះអង្គត្រាស់ថា ត្រូវហើយ ឧបាសក នោះជាអ្នកដល់ព្រមដោយ **អរិយទ្រព្យ ៧ ប្រការ** តែជាអ្នកមានសេចក្តីប្រាថ្នាតិច មិនប្រាថ្នាឱ្យអ្នកដទៃដឹងកុសលធម៌ ដែលមានក្នុងខ្លួន ។

( ៥ ) **ហត្ថកឧបាសក** ព្រមដោយបរិវារ ៥០០ នាក់ដឹងថា ខណៈនេះ ព្រះអង្គយាងមកគង់នៅក្នុងអគ្គាឡវចេតិយ ទើបនាំគ្នាចូលមកគាល់ដល់ទីប្រ-ថាប់ ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះអង្គទ្រង់បដិសណ្ឋារៈ ជាមួយនឹងហត្ថករាជកុមារ ត្រាស់សួរថា ហត្ថកៈ អ្នកមានបរិវារច្រើនដូច្នេះ អ្នកសង្គ្រោះគេដូចម្តេច ហត្ថកឧបាសកក្រាបទូលថា ខ្ញុំព្រះអង្គសង្គ្រោះបរិវារទាំងនេះដោយ **សង្គហវត្ថុ ៤ ប្រការ** តាមដែលព្រះអង្គទ្រង់សម្តែងទុក គឺសង្គ្រោះ **ដោយទាន ដោយវាចា ដោយប្រព្រឹត្តវត្ថុជាប្រយោជន៍ ដោយការដាក់ខ្លួនឱ្យស្មើគ្នាក្នុងបុគ្គលដែលសមគួរ** ព្រះអង្គ ។

តមកខាងក្រោយ ព្រះសាស្តាទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់សរសើរហត្ថកឧបាសកថា ជាកំពូលជាងពួកឧបាសក អ្នកសង្គ្រោះបរិស័ទដោយសង្គហវត្ថុ ៤ ។ តពីនោះ ទ្រង់យាងចារិកទៅប្រោសវេនេយ្យសត្វ តាមស្រុកនិគមផ្សេងៗ ដែលមិនបានរៀបរាប់ថា ទីណាខ្លះ លុះជិតចូលព្រះវស្សា ព្រះអង្គយាងត្រឡប់មកកាន់ចាលិកបព៌តម្តងទៀត ។

# ព្រះវស្សាទី ១៩

## ទ្រង់គង់ចាំព្រះវស្សា ក្នុងចាលិកបព៌ត ក្រុងចាលិកា

ក្រោយពីចាំព្រះវស្សាទី ១៨ ក្នុងដែនអាឡវី ពេលចេញព្រះវស្សាបវារណាហើយ ព្រះអង្គយាងចេញទៅប្រោសវេនេយ្យសត្វ តាមនិគមផ្សេង១ ដែលជាពុទ្ធកិច្ចក្នុងការបំពេញប្រយោជន៍ដល់ពពួកសត្វលោកទាំងឡាយ ជិតដល់ថ្ងៃចូលព្រះវស្សាជាថ្មី ទើបយាងចារិកទៅកាន់ដែនចាលិកា ។

ការយាងមកកាន់ដែនចាលិកាក្នុងគ្រាទី ៣ នេះ គង់យាងទៅដើម្បីទ្រង់ប្រោសនូវវេនេយ្យសត្វដូចគ្នា តែមិនបានចារបញ្ជាក់ថា ព្រះអង្គទ្រង់សម្តែងព្រះធម្មទេសនាប្រោសអ្នកណាខ្លះ បានព្យាយាមស្វែងរកទាំងក្នុងព្រះវិន័យបិដក ព្រះសុត្តន្តបិដកយ៉ាងល្អិតល្អន់ ក៏មិនបានជួបសេចក្តីណា ដែលមានការពោលអាងលើកឡើងជាគោលឡើយ ។

ទើបយើងខ្ញុំអ្នករៀបចំ **លើកយកការយាងចារិករបស់ព្រះអង្គ ព្រះពុទ្ធប្បវេណី ភ័យក្នុងអនាគត ៥ ប្រការ និងហេតុបច្ច័យដែលធ្វើឱ្យព្រះពុទ្ធសាសនាសាបសូន្យ** មកសម្តែងទុកក្នុងព្រះវស្សានេះ ។

### ការយាងចារិករបស់ព្រះពុទ្ធអង្គ

(១) ក្នុងវិន័យបិដក មហាវិភង្គ បឋមភាគ ពោលទុកថា ការយាងចារិករបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ជាពុទ្ធប្បវេណី កាលយាងចារិកទៅក្នុងជនបទ រមែងយាងទៅក្នុងមណ្ឌលទាំង ៣ នេះ គឺ មហាមណ្ឌល មជ្ឈិមមណ្ឌល

អន្តិមមណ្ឌល ការយាងនេះ ឈ្មោះថា ការយាងចារិកមិនរួសរាន់ ។ ក្នុងកាលណាដែលមានព្រះបំណងយាងចារិកទៅក្នុង មហាមណ្ឌល ក្នុងកាលនោះ ទ្រង់បវារណាក្នុងថ្ងៃមហាបវារណា ( ថ្ងៃពេញបូរមី ខែអស្សុជ ) ហើយ មានភិក្ខុសង្ឃដ៏ច្រើនជាបរិវារ យាងចេញក្នុងថ្ងៃបាដិបទ ( ថ្ងៃ ១ រោច ខែអស្សុជ ) ដើម្បីទ្រង់អនុគ្រោះពួកមហាជនតាមស្រុកនិគម ដោយការទទួលអាមិសជាទេយ្យទាន និងទ្រង់កពូនកុសលដល់មហាជនដោយធម្មទាន យាងចារិកទៅក្នុងមណ្ឌលធំ ចម្ងាយផ្លូវប្រមាណ ៩០០ យោជន៍ ឱ្យចប់ខាងក្នុងរយៈ ៩ ខែ ។ កាលណាមានព្រះបំណងយាងចារិកទៅក្នុងមជ្ឈិមមណ្ឌល ព្រោះអាស្រ័យក្នុងព្រះវស្សា សមថៈ និងវិបស្សនារបស់ភិក្ខុទាំងឡាយនៅខ្ចី ទើបទ្រង់ពន្យាពេលយាងចារិកឱ្យយឺត ១ ខែ ដោយបន្ថយថ្ងៃមហាបវារណាទៅធ្វើក្នុងថ្ងៃពេញបូរមី ខែកត្តិក ហើយផ្ដើម យាងចេញក្នុងថ្ងៃ ១ រោច ខែកត្តិក ចម្ងាយផ្លូវយាងចារិកប្រមាណជា ៦០០ យោជន៍ ប្រើរយៈពេលយាងចារិកឱ្យចប់ខាងក្នុង ៨ ខែ ។

ក្នុងកាលណាដែលមានព្រះបំណងនឹងយាងចារិកទៅក្នុង អន្តិមមណ្ឌល ( មណ្ឌលតូច ) នេះ សូម្បីទ្រង់ចេញវស្សាហើយ តែបណ្ដាវេនេយ្យសត្វទាំងឡាយនៅមានឥន្ទ្រីយ៍មិនទាន់ចាស់ក្លា ក៏នឹងទ្រង់សម្រេចឥរិយាបថនៅក្នុងទីនោះ ដើម្បីរង់ចាំពេលវេលា ឱ្យវេនេយ្យសត្វទាំងនោះមានឥន្ទ្រីយ៍ចាស់ក្លាសិន ហើយទើបទ្រង់យាងចារិក ដោយចាប់ផ្ដើមចេញទៅក្នុង ថ្ងៃ ១ រោច ខែមិគសិរ ចម្ងាយផ្លូវ ទ្រង់យាងចារិកប្រមាណ ៣០០ យោជន៍ ប្រើពេលក្នុងការយាង

ចារិកឱ្យចប់ខាងក្នុង ៧ ខែ ។

ទាំងនេះជាការចារិកទៅ ដើម្បីប្រយោជន៍ដល់សេចក្ដីសុខរបស់សរីរៈ ១ ដើម្បីកាន់យករឿងដែលកើតឡើង ជាដើមហេតុមកសម្ដែងធម៌ទេសនា ១ និង ដើម្បីប្រយោជន៍ក្នុងការបញ្ញត្តិសិក្ខាបទដល់ភិក្ខុទាំងឡាយ ១ ។ ការចារិកម្យ៉ាងទៀត ឈ្មោះថា ចារិកប្រញាប់ ការចារិកដូច្នេះសម្ដៅយក ប្រញាប់យាងទៅ ដើម្បីប្រោសបុគ្គលដែលគួរបានត្រាស់ដឹង ជាការចោះចំពោះ ដោយមិនបានគិតដល់ចម្ងាយផ្លូវថា ជិត ឬឆ្ងាយត្រឹមណា ដូចជាការយាងទៅទទួលបិប្ផលិមាណព (ព្រះមហាកស្សប) ពេលកំពុងធ្វើដំណើរមកដើម្បីសូមបួស ក្នុងចន្លោះផ្លូវនាលន្ទា និងក្រុងរាជគ្រឹះ ចារិកទៅដើម្បីប្រោសអាឡវកយក្ខដែនអាឡវី ដើម្បីប្រោស អង្គុលីមាល ក្នុងព្រៃជាលិនីដែនកោសល ដើម្បីប្រោសព្រះបាទមហាកប្បិន ត្រង់មាត់ស្ទឹង **ចន្ទភាគា** និងដើម្បីប្រោសបុក្កុសាតិ នៅផ្ទះជាងឆ្នាំងឈ្មោះភគ្គវៈ ក្នុងក្រុងរាជគ្រឹះ ជាដើម ។

# ពុទ្ធប្បវេណី

(២) ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់មានប្រក្រតីបដិសណ្ឋារៈជាមួយភិក្ខុអាគន្តុកៈដែលជាពុទ្ធប្បវេណី ដោយការត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាងកាយរបស់ពួកអ្នកល្មមអត់ធន់បានឬ ល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបានឬ ពួកអ្នកជាអ្នកព្រមព្រៀងគ្នា ស្រុះស្រួលគ្នា មិនវិវាទគ្នា នៅចាំវស្សាជាសុខ និងមិនលំបាកដោយអាហារបិណ្ឌបាតទេឬ ជាដើម ។

ព្រះពុទ្ធជាម្ចាស់ទាំងឡាយ :

**ទាំងដែលទ្រង់ជ្រាប រមែងត្រាស់សួរក៏មាន រមែងមិនត្រាស់សួរក៏មាន ទ្រង់ជ្រាបកាលហើយត្រាស់សួរ ទ្រង់ជ្រាបកាលហើយមិនត្រាស់សួរ ក៏មាន ។**

ព្រះពុទ្ធជាម្ចាស់ទាំងឡាយ :

**រមែងត្រាស់សួរក្នុងរឿងដែលប្រកបដោយប្រយោជន៍**

**មិនត្រាស់សួរក្នុងរឿងដែលមិនប្រកបដោយប្រយោជន៍ ។**

ព្រះពុទ្ធជាម្ចាស់ទាំងឡាយ រមែងទ្រង់អប់រំភិក្ខុទាំងឡាយដោយអាការៈ ២ យ៉ាង គឺ :

~ដោយការសម្តែងធម៌ ១ ដោយការបញ្ញត្តិសិក្ខាបទដល់សាវ័កទាំងឡាយ ១

នេះជាពុទ្ធប្បវេណី របស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ។

# ភ័យក្នុងអនាគត៥ប្រការ

(៣) ព្រះមានព្រះភាគ ទ្រង់ត្រាស់ភ័យក្នុងអនាគត ដែលជាសេចក្ដីសាបសូន្យរបស់ព្រះសាសនាទុកក្នុង អង្គុត្តរនិកាយ បញ្ចកនិបាត **ចតុត្ថអនាគតសូត្រ** ដូច្នេះថា:

ម្នាលភិក្ខុទាំងឡាយ ភ័យក្នុងអនាគត ៥ ប្រការ **ដែលមិនទាន់កើតឡើងក្នុងកាលឥឡូវនេះ តែនឹងកើតក្នុងកាលអនាគត** ភ័យទាំងនោះដែលអ្នកទាំងឡាយគប្បីដឹងជាមុន កាលដឹងហើយ អ្នកគប្បីព្យាយាមដើម្បីលះភ័យទាំងនោះចេញ ភ័យ ៥ ប្រការនោះ គឺ:

ក្នុងអនាគត ភិក្ខុទាំងឡាយ **នឹងជាអ្នកពេញចិត្តចីវរល្អ** កាលពេញចិត្តចីវរល្អ **ក៏នឹងលះការសមាទានបង្សុកូលជាវត្ត** នឹងប្រជុំគ្នានៅតាមស្រុកនិគម និងរាជធានី មានការស្វែងរកមិនសមគួរ មិនត្រូវទំនងផ្សេងៗ ព្រោះហេតុនៃចីវរ ។

ក្នុងអនាគត ភិក្ខុទាំងឡាយ **នឹងជាអ្នកពេញចិត្តបិណ្ឌបាតល្អ** កាលពេញចិត្តបិណ្ឌបាតល្អ **ក៏នឹងលះការត្រាច់បិណ្ឌបាតជាវត្ត** នឹងប្រជុំគ្នានៅតាមស្រុកនិគម និងរាជធានី ស្វែងរកបិណ្ឌបាតដែលមានរសឆ្ងាញ់ដោយចុងអណ្ដាត នឹងមានការស្វែងរកមិនសមគួរ មិនត្រូវទំនងផ្សេងៗ ព្រោះហេតុនៃបិណ្ឌបាត ។

ក្នុងអនាគត ភិក្ខុទាំងឡាយ **នឹងជាអ្នកពេញចិត្តសេនាសនៈល្អ** កាលពេញចិត្តសេនាសនៈល្អ **ក៏នឹងលះការនៅព្រៃជាវត្ត** លះសេនាសនៈស្ងាត់ គឺព្រៃ

និងព្រៃស្មសាន នឹងប្រជុំគ្នានៅតាមស្រុកនិគម និងរាជធានី នឹងមានការស្វែងរកមិនសមគួរ មិនត្រូវទំនងផ្សេងៗ ព្រោះហេតុនៃសេនាសនៈ ។

ក្នុងអនាគត ភិក្ខុទាំងឡាយ **នឹងជាអ្នកច្រឡូកច្របល់ដោយភិក្ខុនី សាមណេរី និងសាមណេរ** កាលមានការច្រឡូកច្របល់ដោយភិក្ខុនី សាមណេរី និងសាមណេរ គប្បីដឹងចុះថា **អ្នកទាំងនោះនឹងមិនជាអ្នកត្រេកអរប្រព្រឹត្ត ព្រហ្មចរិយៈ នឹងត្រូវអាបត្តិសៅហ្មងប្រការខ្លះ ឬនឹងពោលលាសិក្ខា វិលត្រឡប់មកជាគ្រហស្ថ** ព្រោះហេតុនៃការច្រឡូកច្របល់នោះ ។

ក្នុងអនាគត ភិក្ខុទាំងឡាយ **នឹងជាអ្នកនៅច្រឡូកច្រឡំដោយពួកអារាមិកជន** កាលមានការនៅច្រឡូកច្រឡំដោយអារាមិកជន គប្បីដឹងចុះថា **អ្នកទាំងនោះ នឹងជាអ្នកប្រកបតែការបរិភោគរបស់ដែលសន្សំទុក មានប្រការផ្សេងៗ នឹងធ្វើនិមិត្តសូម្បីយ៉ាងគ្រោតគ្រាត ក្នុងផែនដីខ្លះ ត្រង់ចុងរបស់ខៀវខ្លះ** ។

ម្នាលភិក្ខុទាំងឡាយ ភ័យក្នុងអនាគតទាំង ៥ ប្រការ ដែលនៅមិនទាន់កើតឡើងក្នុងកាលឥឡូវនេះ តែនឹងកើតក្នុងកាលអនាគត ភ័យនោះអ្នកទាំងឡាយគប្បីដឹងយ៉ាងនេះចុះ ហើយគប្បីព្យាយាមលះភ័យនោះ ដើម្បីការពារសេចក្តីសាបសូន្យរបស់ព្រះសាសនាក្នុងអនាគត ។

# ហេតុបច្ច័យដែលធ្វើឱ្យព្រះពុទ្ធសាសនាសាបសូន្យ

(៤) សម័យមួយ ខណៈដែលព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន ព្រះកិម្ពិលៈ ចូលទៅក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុជាបច្ច័យឱ្យ **ព្រះសទ្ធម្មមិនតាំងនៅយូរ** ក្រោយពីព្រះតថាគតបរិនិព្វានហើយ ?

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិម្ពិលៈ កាលតថាគតបរិនិព្វានហើយ បើពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាក្នុងធម្មវិន័យនេះ ជាអ្នកដែល :

**មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងព្រះសាស្តា**

**មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងព្រះធម៌**

**មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងព្រះសង្ឃ**

**មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងសិក្ខាបទ**

**មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងចំពោះគ្នានឹងគ្នា។**

ម្នាលកិម្ពិលៈ បដិបទានេះឯង ជាហេតុជាបច្ច័យឱ្យ **ព្រះសទ្ធម្មមិនតាំងនៅយូរ** ព្រះកិម្ពិលៈទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអ្វីជាហេតុជាបច្ច័យឱ្យ **ព្រះសទ្ធម្មតាំងនៅយូរ** ក្រោយពីព្រះតថាគតបរិនិព្វានហើយ ?

ព្រះពុទ្ធអង្គត្រាស់ថា ម្នាលកិម្ពិលៈ កាលតថាគតបរិនិព្វានហើយ បើពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាក្នុងធម្មវិន័យនេះ ជាអ្នកដែល :

**មានសេចក្តីគោរព មានសេចក្តីកោតក្រែងក្នុងព្រះសាស្តា**

**មានសេចក្តីគោរព មានសេចក្តីកោតក្រែងក្នុងព្រះធម៌**

**មានសេចក្តីគោរព មានសេចក្តីកោតក្រែងក្នុងព្រះសង្ឃ**
**មានសេចក្តីគោរព មានសេចក្តីកោតក្រែងក្នុងសិក្ខាបទ**
**មានសេចក្តីគោរព មានសេចក្តីកោតក្រែងចំពោះគ្នានឹងគ្នា ។**

ម្នាលកិម្ពិលៈ បដិបទានេះឯង ជាហេតុជាបច្ច័យឱ្យ **ព្រះសទ្ធម្មតាំងនៅយូរ**

## ក្រោយពីចេញព្រះវស្សាទី ១៩ ហើយ

( ៥ ) ព្រះសាស្តាយាងចារិកទៅប្រោសសត្វក្នុងទីផ្សេងៗ ហើយយាងទៅក្រុងសាវត្ថិ **បុណ្ណមាណព** ជាឈ្មួញនៅដែនសុណាបរន្តៈ ប្រមូលរទេះនាំទំនិញមកលក់នៅក្រុងសាវត្ថិ ឃើញពួកមហាជនកាន់គ្រឿងសក្ការៈ ដើរទៅរកវត្តជេតពនក៏ដើរតាមទៅ ខណៈនោះព្រះសាស្តាកំពុងសម្តែងធម៌ បុណ្ណមាណពកើតសេចក្តីជ្រះថ្លា ទើបហៅប្រធានបរិវារមក បញ្ជាឱ្យនាំយកទ្រព្យសម្បត្តិទាំងអស់ត្រឡប់ទៅប្រគល់ឱ្យប្អូនប្រុស ខ្លួនឯងបានបួសហើយក្នុងសំណាក់ព្រះសាស្តា ចម្រើនសមណធម៌ក្នុងជេតវ័នវិហារ ។

ថ្ងៃមួយ ព្រះបុណ្ណៈចូលគាល់ក្រាបទូលសូមប្រទានឱកាសដោយខ្លី ដើម្បីនឹងត្រឡប់ទៅកាន់សុណាបរន្តជនបទ ព្រះមានព្រះភាគត្រាស់ **បុណ្ណោវាទសូត្រ** សម្តែងពីរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ដែលជាហេតុនៃទុក្ខ ។ ព្រះបុណ្ណៈទៅកាន់សុណាបរន្តជនបទ សម្រាកនៅក្នុង **អម្ពហដ្ឋបព៌ត** ប្រារព្ធព្យាយាមដោយសមថៈ និងវិបស្សនាធ្វើវិជ្ជា ៣ ឱ្យជាក់ច្បាស់ សម្រេចអរហត្តផលហើយ ។

ចំណែកប្អូនប្រុសព្រមដោយឈ្មួញរទេះ ៥០០ នាក់ ទៅជួញដូរផ្លូវទឹក ជួបនឹង អមនុស្សកណ្តាលសមុទ្រ អធិដ្ឋានសូមឱ្យព្រះបុណ្ណត្ថេរជាបងប្រុសជួយ បានរួចចាកភ័យន្តរាយ ហើយកើតសេចក្តីជ្រះថ្លា ទើបថ្វាយខ្លួនជាឧបាសកឧបា-សិកា រួមគ្នាសាងព្រះគន្ធកុដិក្នុង សុណាបរន្តជនបទ ដោយឈើចន្ទន៍ក្រហមដែលពួកខ្លួននាំមក ដើម្បីថ្វាយចំពោះព្រះសាស្តា ឈ្មោះថា **ចន្ទនសាលា** ។ លុះសាងស្រេចហើយ ព្រះបុណ្ណត្ថេរទៅអារាធនាព្រះពុទ្ធអង្គនៅឯក្រុងសាវត្ថី ដោយអានុ-ភាពនៃឫទ្ធិ ព្រះសាស្តាទ្រង់យាងព្រមដោយភិក្ខុសង្ឃ ៥០០ រូប ទ្រង់មកទទួលព្រះគន្ធកុដិ ជនទាំងនោះសមាទានឧបោសថសីលហើយថ្វាយទាន ទ្រង់អនុ-មោទនា និងសម្តែងធម្មីកថា ការរួចផុតចាកកិលេសបានកើតដល់ជនទាំងនោះ ព្រះសាស្តាទ្រង់គង់នៅក្នុងព្រះគន្ធកុដិនោះ ២-៣ ថ្ងៃ ទើបយាងត្រឡប់ទៅវិញ។

ខណៈធ្វើដំណើរដល់ស្ទឹងនម្មទា ពួកនាគរាជនាំគ្នាមកទទួលបដិសណ្ឋារៈ ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសនាគរាជទាំងឡាយ កាលនឹងយាងដំណើរតទៅ ពួកនាគរាជ ក្រាបទូលសូមឱ្យប្រទានវត្ថុសម្រាប់សក្ការបូជា ព្រះអង្គទ្រង់ប្រតិ-ស្ឋានស្នាមព្រះបាទទុកត្រង់មាត់ស្ទឹងនម្មទានោះ បន្ទាប់មក ទ្រង់យាងត្រឡប់ទៅកាន់វត្តជេតពនឯក្រុងសាវត្ថីវិញ ។

( ៦ ) គ្រានោះ បុរោហិតរបស់ព្រះបាទបសេនទិកោសលបញ្ជូនកូនប្រុសរបស់ខ្លួន នាមថា **អហិង្សកៈ** ទៅសិក្សាសិល្បវិទ្យាជាមួយអាចារ្យទិសាបាមោក្ខនៅឯក្រុងតក្កសិលា អហិង្សកៈជាអ្នកមានការប្រព្រឹត្តរៀបរយ មិនបៀតបៀន

អ្នកណា តាំងចិត្តសិក្សាសិល្បវិទ្យាដោយល្អ ទើបជាទីស្រឡាញ់រាប់អានរបស់អាចារ្យ ពួកសិស្សដទៃនាំគ្នាច្រណែនឥស្សា មិនត្រូវការឱ្យអហិង្សកៈបានល្អជាងពួកខ្លួន បានប្រើឧបាយច្រើនប្រការដែលធ្វើឱ្យអាចារ្យ កើតការរង្កៀសក្នុងអហិង្សកៈ ។ គ្រាដំបូង អាចារ្យនៅមិនទាន់ដាក់ចិត្តជឿពាក្យពេចន៍របស់សិស្សទាំងនោះ តែកាលបានទទួលដំណឹងថា អហិង្សកៈគិតនឹងបៀតបៀនខ្លួនញយៗច្រើនដង ទើបផ្តើមកើតការរង្កៀស គិតនឹងផ្តាច់ជីវិតរបស់អហិង្សកៈ មុនពេលដែលខ្លួនត្រូវបៀតបៀន តែគិតថា បើខ្លួនជាអ្នកធ្វើដោយខ្លួនឯង តទៅក៏នឹងមិនមានអ្នកណាហ៊ានបញ្ជូនកូនចៅ ឱ្យមកសិក្សាក្នុងសំណាក់របស់ខ្លួន ទើបគិតរកឧបាយឱ្យអ្នកដទៃជាអ្នកធ្វើជំនួស ។ អាចារ្យទិសាបាមោក្ខ ហៅអហិង្សកៈចូលមកប្រាប់ឱ្យដឹងថា សិល្បវិទ្យាដែលបានរៀនសូត្រមកនោះ ជិតសម្រេចហើយ តែចង់ឱ្យសម្រេចបរិបូរណ៍បាន អហិង្សកៈត្រូវសម្លាប់មនុស្ស ឱ្យគ្រប់មួយពាន់នាក់សិន ទើបសម្រេចផលបាន យ៉ាងនេះដោយសង្ឃឹមថា នឹងត្រូវមានអ្នកណាមួយអាចផ្តាច់ជីវិតអហិង្សកៈ បានយ៉ាងពិតប្រាកដ ។

អហិង្សកៈ ជាអ្នកគោរព និងកាន់យកពាក្យសម្តីរបស់អាចារ្យ គិតថាប្រាកដជាពិតតាមពាក្យដែលអាចារ្យពោល ទើបត្រៀមរៀបចំអាវុធធ្វើដំណើរទៅកាន់ព្រៃ **ជាលិនី** ក្នុងដែនកោសល លាក់ខ្លួនរង់ចាំបៀតបៀនអ្នកធ្វើដំណើរឆ្លងកាត់ទៅមក ដូចជាសម្លាប់ពួកមនុស្សហើយ កាត់យកម្រាមដៃមកដោតក្រងជាមាល័យពាក់ក ទើបអហិង្សកៈបាននាមថា **ចោរអង្គុលិមាល** ប្រែថា អ្នកមាន

ម្រាមដៃជាភួងមាល័យតាំងពីនោះមក ។

ពួកជនតាមស្រុកនិគមក្រៅក្រុងសាវត្ថី ជ្រាបហេតុការណ៍របស់ចោរ-អង្គុលិមាល នាំគ្នាលះបង់ចោលទីលំនៅ ភៀសខ្លួនទៅស្នាក់នៅក្នុងក្រុងសាវត្ថី ហើយក្រាបទូលរឿងនោះ ឱ្យព្រះបាទបសេនទិកោសលទ្រង់ជ្រាប ទើបព្រះរាជាមានព្រះរាជបញ្ជា ឱ្យត្រៀមរេហ៍ពលដើម្បីនឹងចេញទៅបង្ក្រាបចោរអង្គុលិមាល ។ ពេលអរុណរះថ្ងៃនោះ ព្រះពុទ្ធអង្គទ្រង់ប្រមើលឃើញឧបនិស្ស័យ អរហត្តផលរបស់ **អង្គុលិមាល** ទ្រង់ជ្រាបដោយព្រះពុទ្ធញាណថា អង្គុលិមាលនេះជា **បច្ឆិម-ភវិកសត្វ** (សត្វកើតក្នុងភពចុងបំផុត ) ខណៈនេះកំពុងស្វែងរកបុគ្គលចុងបំផុតដើម្បីសម្លាប់ហើយកាត់ម្រាមដៃឱ្យគ្រប់មួយពាន់ បើតថាគតទៅប្រោស សិរីសួស្តីនឹងមានដល់អង្គុលិមាល គេនឹងឈរស្តាប់ពាក្យទូន្មានរបស់តថាគតក្នុងព្រៃនោះហើយ នឹងត្រឡប់ដឹងខ្លួនសូមបួស កាលបួសហើយមិនយូរក៏នឹងធ្វើឱ្យច្បាស់នូវអភិញ្ញា ៦ តែបើតថាគតមិនទៅ អង្គុលិមាលកាលជួបមាតារបស់ខ្លួន នឹងប្រទូសរ៉ាយ ធ្វើអនន្តរិយកម្មចំពោះមាតា អាចនឹងឱ្យផលភ្លាម តថាគតគប្បីសង្គ្រោះចោរអង្គុលិមាលនោះ ។

កាលយាងត្រឡប់ពីបិណ្ឌបាត ព្រះអង្គប្រាប់ឱ្យភិក្ខុទាំងឡាយដឹង ការដែលនឹងយាងចារិកទៅកាន់ជនបទមួយគ្រា ដោយមិនមានបច្ឆាសមណៈ ហើយយាងដំណើរទៅកាន់ទិសដែលអង្គុលិមាលនៅពួនសម្ងំ កាលឃើញព្រះអង្គយាង

មកពីចម្ងាយ អង្គុលិមាលអស្ចារ្យក្នុងចិត្តយ៉ាងក្រៃលែង ដែលឃើញថាសមណៈនេះហ៊ានមកតែម្នាក់ឯង សម្លុតទៅថា ឈប់សិន១ សមណៈ ។ ព្រះអង្គត្រាស់ថា តថាគតឈប់ហើយ អង្គុលិមាល ! នៅតែអ្នកទេដែលមិនទាន់ឈប់ អង្គុលិមាលមិនយល់សេចក្តីបំណង គិតថា ពួកសមណៈមានប្រក្រតីមិនពោលពាក្យកុហក តែហេតុអ្វីទាំងដែលលោកកំពុងដើរ ត្រឡប់ជាពោលថា តថាគតឈប់ហើយ ឯចំណែកយើងដែលកំពុងតែឈរ លោកពោលថាមិនទាន់ឈប់ ។ ទីបំផុតនៃការឆ្លើយតប ព្រះអង្គត្រាស់ថា តថាគតឈ្មោះថា ឈប់ គឺ **ឈប់ហើយចាកការបៀតបៀនសត្វទាំងឡាយ** ចំណែកអ្នកឈ្មោះថា **នៅមិនទាន់ឈប់ ព្រោះនៅបៀតបៀនបំផ្លាញជីវិតសត្វដទៃ** ។

កាលព្រះអង្គត្រាស់ដូច្នេះ អង្គុលិមាលត្រឡប់បានស្មារតី បោះចោលសស្ត្រាវុធ និងកម្រងម្រាមដៃចេញពីករបស់ខ្លួន ចោលទៅក្នុងជ្រោះជ្រៅ រួចចូលទៅទូលសូមបួស ក្នុងសំណាក់ព្រះពុទ្ធអង្គក្នុងទីនោះឯង ព្រះអង្គទ្រង់ប្រទាន **ឯហិភិក្ខុឧបសម្បទា** ហើយយាងត្រឡប់មកកាន់វត្តជេតពនវិញ ដោយមានព្រះអង្គុលិមាលជាបច្ឆាសមណៈ ។ ព្រឹកឡើង ព្រះអង្គត្រាស់ឱ្យព្រះអង្គុលិមាលចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ភិក្ខុអង្គុលិមាលត្រឡប់មកដោយបាត្រទទេ មានលោហិតហូរជោគកាយ ក្រាបទូលព្រះអង្គថា ខណៈដែលខ្ញុំព្រះអង្គបិណ្ឌបាត បណ្តាឥដ្ឋ ដុំថ្ម កំណាត់ឈើ មិនដឹងថាគប់អំពីទីណា មកត្រូវខ្ញុំព្រះអង្គយ៉ាងខ្លាំង

ធ្វើឱ្យខ្ញុំព្រះអង្គបែកឈាមមានទុក្ខវេទនាដូច្នេះ ព្រះអង្គត្រាស់ថា ម្នាលអង្គុលិ-មាល អ្នកចូរអត់ធន់ចុះ ផលនៃកម្មដែលអ្នកបានធ្វើគួរនឹងទទួលក្នុងអបាយភូមិ អ្នកបានទទួលសោយហើយក្នុងបច្ចុប្បន្ននេះ ។

សម័យនោះព្រះអង្គុលិមាល សមាទានការនៅព្រៃជាវត្ត ត្រាច់បិណ្ឌបាតជាវត្ត កាន់ការបង្សុកូលជាវត្ត គេចចេញទៅបំពេញសមណធម៌តែម្នាក់ឯង មិនយូរក៏បានសម្រេចព្រះអរហត្តព្រមដោយវិជ្ជា ៣ គឺ **បុព្វេនិវាសានុស្សតិវិជ្ជា ចតូបបាតវិជ្ជា និងអាសវក្ខយវិជ្ជា** ។

តមក ខណៈដែលព្រះអង្គុលិមាលចូលទៅបិណ្ឌបាត ឃើញស្រីមានគភ៌ចាស់ម្នាក់ឈររង់ចាំប្រគេនអាហារបិណ្ឌបាត ទើបលោកដើរចូលទៅរក ស្រីនោះលុះឃើញថាជាអង្គុលិមាលក៏តក់ស្លុតខ្លាច បោះចោលទេយ្យធម៌សម្រាប់ប្រគេនរត់គេចទៅចាល់នឹងរបងផ្ទះរបស់នាង ព្រះអង្គុលិមាលចូលតាមទៅពោលសច្ច-វាចាថា ម្នាលប្អូនស្រី តាំងពីយើងកើតហើយក្នុងអរិយជាតិ យើងមិនដែលក្លែងផ្តាច់ជីវិតសត្វទាំងដឹងខ្លួនឡើយ ដោយសច្ចវាចានេះ សូមសិរីសួស្តីចូរមានដល់នាង និងទារកក្នុងគភ៌របស់នាងចុះ បានឮថា ស្រីនោះប្រសូតិបុត្របានងាយបំផុត ។ តាំងពីនោះមក ព្រះអង្គុលិមាលក៏ជាទីគោរពរាប់អានរបស់អ្នកស្រុក ជនទាំង-ឡាយប្រាសចាកការភ័យខ្លាចក្នុងព្រះថេរៈតទៅទៀត ។

គ្រានោះ ព្រះអង្គុលិមាលទៅកាន់ទីពួនសម្ងំ សោយវិមុត្តិសុខបន្លឺឧទានថា :

**អ្នកណាប្រមាទហើយក្នុងកាលមុន ខាងក្រោយជាអ្នកមិន**

**ប្រមាទ អ្នកនោះរមែងញ៉ាំងលោកនេះឱ្យភ្លឺស្វាង ដូចដួងច័ន្ទផុតចាកពពក ។**

លុះបន្លឺឧទាននេះហើយ ក៏បរិនិព្វានដោយអនុបាទិសេសនិព្វាន ភិក្ខុទាំង-ឡាយទូលសួរដល់គតិរបស់ព្រះអង្គុលិមាល ព្រះអង្គត្រាស់ថា បុត្ររបស់តថាគតបរិនិព្វានហើយ ត្រាស់សម្តែងព្រះគាថា ថា :

**បុគ្គលណាលះបាបកម្ម ដែលខ្លួនធ្វើទុកហើយដោយកុសល បុគ្គលនោះ រមែងញ៉ាំងលោកនេះឱ្យភ្លឺស្វាង ដូចដួងច័ន្ទផុតហើយចាកពពក ដូច្នោះ ។**

( ៧ ) ខណៈដែលព្រះសាស្តាគង់នៅ ក្នុងវត្តជេតពនទ្រង់ប្រារព្ធរឿង **សន្តតិមហាអាមាត្យ** ដល់ភិក្ខុទាំងឡាយថា សម័យមួយ ពួកជនក្នុងបច្ចន្តជនបទបង្កការបះបោ ព្រះបាទបសេនទិកោសល ត្រាស់បញ្ជាឱ្យសន្តតិមហាមាត្យនាំកម្លាំងចេញទៅបង្ក្រាប កាលហេតុការណ៍ស្ងប់ និងមហាមាត្យត្រឡប់មកហើយ ព្រះបាទបសេនទិកោសលទ្រង់ពេញព្រះទ័យ ទើបព្រះរាជទានរាជសម្បត្តិឱ្យសន្តតិមហាមាត្យគ្រប់គ្រងអស់រយៈ ៧ ថ្ងៃ ព្រមទាំងប្រទានស្រីដែលជំនាញក្នុងការរាំ និងច្រៀងម្នាក់ដល់មហាមាត្យ ។ កាលបានគ្រងរាជសម្បត្តិ មហាមាត្យក៏សេពសុរារហូតស្រវឹងទាំង ៧ ថ្ងៃ ។

ក្នុងថ្ងៃទី ៧ មហាមាត្យតែងខ្លួនដោយគ្រឿងអលង្ការគ្រប់យ៉ាង ឡើងដំរីរបស់ព្រះរាជា ទៅកាន់កំពង់ងូតទឹក ខណៈឆ្លងកាត់ទ្វារនគរ ឃើញព្រះសាស្តា

កំពុងយាងចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ដោយការស្រវឹងស្រវៀង១ សន្តតិ-មហាមាត្យងក់ក្បាលថ្វាយបង្គំ នៅលើកដំរីនោះឯង ។ ព្រះមានព្រះភាគទ្រង់ធ្វើការញញឹម ត្រាស់ថា ម្នាលអានន្ទ អ្នកចូរមើលសន្តតិមហាមាត្យ ដែលតែងកាយដោយអាភរណៈដ៏ល្អ គេនឹងមកកាន់សំណាក់តថាគតក្នុងថ្ងៃនេះឯង ក្រោយពីស្តាប់ព្រះធម្មទេសនារបស់តថាគត គេនឹងបានសម្រេចព្រះអរហត្តផល ហើយនឹងសម្តែងអានុភាពឡើងទៅឈរនៅក្នុងអាកាស ៧ ជួរត្នោត ក្រោយពីសម្តែងបុព្វកម្មរបស់ខ្លួនហើយ គេនឹងអង្គុយលើបល្ល័ង្ក កណ្តាលលំហអាកាសនោះ ចូលតេជោធាតុ ហើយបរិនិព្វានខាងលើអាកាសនោះឯង មហាជនបានស្តាប់ព្រះតម្រាស់របស់ ព្រះសាស្តានោះព្រមគ្នាទាំងអស់ ។

បណ្តាជនទាំងនោះ **ពួកមិច្ឆាទិដ្ឋិគិតថា** ព្រះសមណគោតមល្អតែមាត់ ពួកយើងនឹងចាប់កំហុសព្រះសមណគោតមដោយមុសាវាទ **ពួកសម្មាទិដ្ឋិគិតថា** គួរអស្ចារ្យណាស់ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ មានអានុភាពច្រើន ក្នុងថ្ងៃនេះយើងទាំងឡាយនឹងបានឃើញ អានុភាពនៃព្រះអង្គ និងការសម្រេចធមិរបស់សន្តតិមហាមាត្យ ។

ក្នុងថ្ងៃនោះ ស្រីដែលបានទទួលព្រះរាជទានមក កំពុងសម្តែងកាយវិការរាំ និងច្រៀងក្នុងកណ្តាលវេទិកា បានស្លាប់ដោយខ្យល់មានពិសដែលកើតឡើងក្នុងពោះ ព្រោះអាស្រ័យនាងជាអ្នកបរិភោគអាហារតិចរហូត ៧ ថ្ងៃ ដើម្បីរក្សារាងរៅឱ្យស្អាត មហាមាត្យត្រូវសេចក្តីសោកយ៉ាងខ្លាំងក្លាគ្របសង្កត់ គិតថា វៀរ

ចាកព្រះតថាគត មិនមានអ្នកណាអាចញ៉ាំងសេចក្ដីសោករបស់យើងឱ្យស្ងប់បាន ទើបទៅកាន់សំណាក់ព្រះសាស្ដា ថ្វាយបង្គំហើយ ក្រាបទូលរឿងនោះពោលថា សូមព្រះអង្គចូរជាទីពឹងរបស់ខ្ញុំព្រះអង្គផងចុះ ។

ព្រះសាស្ដាត្រាស់ថា តាមពិតទឹកភ្នែកដែលហូរចេញ ព្រោះអ្នកយំ ក្នុងវេលាដែលស្រីនេះស្លាប់ មានច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ហើយត្រាស់សម្ដែងព្រះគាថា ថា :

**កិលេសជាគ្រឿងកង្វល់ណា មាននៅក្នុងកាលមុន**
**អ្នកចូរញ៉ាំងកិលេសជាគ្រឿងកង្វល់នោះ ឱ្យហួតហែងទៅ**
**កិលេសជាគ្រឿងកង្វល់ ចូរកុំមានដល់អ្នកជាខាងក្រោយ**
**បើអ្នកនឹងមិនប្រកាន់មាំនូវខន្ធ និងជាអ្នកស្ងប់រម្ងាប់ត្រាច់ទៅ ។**

ក្នុងកាលចប់ព្រះគាថា សន្តតិមហាមាត្យ បានសម្រេចព្រះអរហត្ត ពិចារណាអាយុសង្ខាររបស់ខ្លួនជ្រាបហើយ ទើបក្រាបទូលលាបរិនិព្វាន ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ជ្រាបវាទៈរបស់មហាជនទាំងនោះ ដើម្បីកាត់បង់សេចក្ដីសង្ស័យរបស់ពួកមិច្ឆាទិដ្ឋិឱ្យជាក់ស្ដែង ទើបត្រាស់ថា អ្នកចូរឡើងទៅឈរលើអាកាសកំពស់ ៧ ដូរត្នោត ហើយប្រកាសកម្មដែលអ្នកធ្វើហើយដល់តថាគត ។

សន្តតិមហាមាត្យសម្ដែងបាដិហារិយ៍ ឡើងទៅឈរលើអាកាស ក្រាបទូលបុព្វកម្មរបស់ខ្លួនដល់ព្រះពុទ្ធអង្គ អង្គុយលើបល្ល័ង្កកណ្ដាលអាកាសនោះ ចូលតេជោធាតុហើយនិព្វាន អណ្ដាតភ្លើងកើតឡើងក្នុងសរីរៈ ដុតឆេះរហូតសល់ត្រឹម

តែធាតុទាំងឡាយដូចផ្កាម្លិះ កាលព្រះសាស្តា ទ្រង់លាសំពត់សទទួល ធាតុទាំង-ឡាយក៏ធ្លាក់ចុះលើសំពត់នោះ ព្រះសាស្តាទ្រង់ខ្ចប់ធាតុទាំងនោះហើយ បញ្ជាឱ្យសាងស្តូបទុកត្រង់ផ្លូវធំបែកជា ៤ ដោយព្រះបំណងថា មហាជនថ្វាយបង្គំហើយនឹងជាអ្នកមានចំណែកនៃបុណ្យ ។

ក្រោយពីសន្តតិមហាមាត្យនិព្វានហើយ ភិក្ខុទាំងឡាយនាំគ្នាសួរថា ក្នុងកាលសន្តតិមហាមាត្យ នៅមិនបានបួស ពួកយើងគួរនឹងហៅលោកថា ជាសមណៈ ឬជាព្រាហ្មណ៍ ? ព្រះសាស្តាទ្រង់ជ្រាបសេចក្តីសង្ស័យរបស់ភិក្ខុទាំងនោះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនឹងហៅសន្តតិមហាមាត្យថាសមណៈក៏គួរ ហៅថា ព្រាហ្មណ៍ក៏គួរដូចគ្នា ហើយត្រាស់សម្តែងព្រះគាថា ថា :

**បុគ្គលណា ប្រដាប់ខ្លួនដោយគ្រឿងអលង្ការ**
**ប្រព្រឹត្តខ្លួនឱ្យស្មើដោយកាយ វាចា និងចិត្ត**
**មានប្រក្រតីប្រព្រឹត្តប្រសើរ បុគ្គលនោះ ឈ្មោះថា ជាអ្នកស្ងប់**
**បុគ្គលនោះ រមែងឈ្មោះថា ព្រាហ្មណ៍ ថាសមណៈ ថាភិក្ខុ ។**

ក្នុងកាលចប់ព្រះគាថា ជនទាំងឡាយបានសម្រេចអរិយផល មានសោ-តាបត្តិផលជាដើម ជាច្រើន ។ នៅចុងព្រះវស្សានេះ សន្និដ្ឋានថា នាងវិសាខាប្រហែលជាចាប់ផ្តើមកសាងមិគារមាតុប្រាសាទ ក្នុងឧទ្យានបុព្វារាម ដូចខសន្និ-ដ្ឋានមាននៅចុងបំផុតក្នុងវស្សាទី ២០ ។ បន្ទាប់ពីនោះ ព្រះពុទ្ធអង្គយាងចារិក-ទៅកាន់ក្រុងរាជគ្រឹះ ។

# ព្រះវស្សាទី ២០

## ទ្រង់គង់ចាំព្រះវស្សា ក្នុងវត្តវេឡុវ័ន ក្រុងរាជគ្រឹះ

(១) ក្នុងវស្សានេះ ព្រះអានន្ទបានទទួលតែងតាំងឱ្យជា **ពុទ្ធុបដ្ឋាក-ប្រចាំ** ដែលមុននេះ សូម្បីព្រះអានន្ទធ្វើនាទីជាឧបដ្ឋាក តែក៏មិនបានធ្វើជាប្រចាំ ព្រះអង្គទ្រង់មិនទាន់បានតែងតាំងភិក្ខុរូបណា ឱ្យធ្វើនាទីនេះដោយចំពោះ ជួនកាល **ព្រះនាគសមាលៈ ព្រះនាគិតៈ ព្រះឧបវាណៈ ព្រះចុន្ទៈ ព្រះសាគតៈ ព្រះរាធៈ ព្រះមេឃិយៈ** ប្តូរគ្នាទទួលនាទីឧបដ្ឋាក ។

ព្រះអង្គទ្រង់ប្រារព្ធថា ឥឡូវនេះតថាគតជរាហើយ ពួកអ្នកចូរជ្រើស-រើសភិក្ខុមួយរូប ដើម្បីជាឧបដ្ឋាកប្រចាំរបស់តថាគត ព្រះសារីបុត្របានស្តាប់ព្រះតម្រាស់ដូច្នោះ ទើបក្រោកចាកអាសនៈ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមទទួលនាទីជាឧបដ្ឋាក ព្រះអង្គទ្រង់ត្រាស់ថា កុំឡើយសារីបុត្រ អ្នកនៅក្នុងទិសណា ទិសនោះមិនសោះសូន្យទេ អ្នកមិនត្រូវធ្វើនាទីឧបដ្ឋាកតថាគតទេ ។ បន្ទាប់ពីនោះ ព្រះសាវ័កអង្គដទៃៗ ក៏ក្រោកឡើងពោលដោយទំនងដូចគ្នា ព្រះអង្គទ្រង់ហាមសាវ័កទាំងអស់នោះ មានព្រះអានន្ទតែមួយរូបដែលអង្គុយនៅស្ងៀម ទើបពួកភិក្ខុពោលថាអានន្ទ លោកក្រាបទូលសូមតំណែង ឧបដ្ឋាកព្រះអង្គចុះ ។ ព្រះអានន្ទ ទើបក្រាបទូលសូមពរ ៨ ប្រការ ដូច្នេះ :

**ពរដែលជាចំណុចសូមហាម ៤ ប្រការ គឺ :**

**នឹងមិនប្រទានចីវរដែលព្រះអង្គទ្រង់បានមក ដល់ខ្ញុំព្រះអង្គ**

**នឹងមិនប្រទានបិណ្ឌបាត ដល់ខ្ញុំព្រះអង្គ**

**នឹងមិនប្រទានឱ្យខ្ញុំព្រះអង្គនៅរួមក្នុងព្រះគន្ធកុដិ**

**នឹងមិនទ្រង់នាំខ្ញុំព្រះអង្គទៅកាន់ទីទទួលនិមន្តទុក ។**

ព្រះសាស្តាត្រាស់សួរថា អានន្ទ អ្នកឃើញទោសដូចម្តេច ព្រះអានន្ទក្រាបទូលថា ព្រោះអ្នកខ្លះអាចគិតថា ព្រោះតែខ្ញុំព្រះអង្គបានទទួលចីវរ បានទទួលបិណ្ឌបាត បាននៅរួមកុដិ បានទៅកាន់ទីនិមន្តព្រមជាមួយព្រះអង្គ ទើបព្រមទទួលជាឧបដ្ឋាក ដោយប្រាថ្នាលាភសក្ការៈប៉ុណ្ណោះ ។

**ពរដែលជាចំណុចសូមអនុគ្រោះ ៤ ប្រការ គឺ :**

**សូមព្រះអង្គយាងទៅកាន់ទីនិមន្តដែលខ្ញុំព្រះអង្គទទួលជំនួស**

**សូមឱ្យខ្ញុំព្រះអង្គនាំអាគន្តុកៈដែលមកអំពីទីផ្សេងៗ ចូលគាល់បាន**

**សូមឱ្យខ្ញុំព្រះអង្គចូលគាល់ដើម្បីទូលសួរសេចក្តីសង្ស័យបានគ្រប់ពេល**

**សូមទ្រង់សម្តែងធម៌ដែលខ្ញុំព្រះអង្គមិនបានស្តាប់ម្តងទៀត ។**

ព្រះសាស្តាត្រាស់សួរថា អានន្ទ អ្នកឃើញអានិសង្សដូចម្តេចក្នុងការសូមពរទាំងនេះ ព្រះអានន្ទក្រាបទូលថា ពួកជនអ្នកមានសទ្ធា កាលមិនមានឱកាសជួបព្រះអង្គ រមែងនឹងសូមឱ្យខ្ញុំព្រះអង្គទទួលនិមន្តជំនួស ដើម្បីខ្ញុំព្រះអង្គបានទូលឱ្យព្រះអង្គទ្រង់ជ្រាប បើព្រះអង្គមិនយាងទៅ ក៏នឹងពោលថា ខ្ញុំព្រះអង្គឧបដ្ឋាកព្រះអង្គដូចម្តេច ទើបមិនឱ្យការអនុគ្រោះ សូម្បីក្នុងកិច្ចនិមន្តដូច្នេះ ។ សម្រាប់អាគន្តុកៈដែលត្រូវការចូលគាល់ព្រះអង្គ ជួនកាលធ្វើដំណើរ មកពីទីឆ្ងាយ បើមិន

មានឱកាសបានចូលគាល់ រមែងពោលថា ពួកយើងប្រឹងប្រែងបោះបង់ចោលការងារអាជីព ធ្វើដំណើរមកប្រាថ្នាដើម្បីបានគាល់ព្រះសាស្តា តែភិក្ខុឧបដ្ឋាកត្រឡប់រារាំងមិនឱ្យចូលគាល់ ក៏នឹងធ្វើឱ្យសទ្ធារបស់អ្នកទាំងនោះ សាបសូន្យថយចុះ ។

ចំណែកពររបស់ខ្ញុំព្រះអង្គផ្ទាល់ ក៏ដើម្បីបានកម្ចាត់សេចក្ដីសង្ស័យ ដែលអាចជាបន្ទាចំពោះការបដិបត្តិធម៌ ឱ្យប្រព្រឹត្តទៅក្នុងផ្លូវត្រូវ ។ម្យ៉ាងទៀត បើមានអ្នកសួរថា ព្រះសូត្រនេះ ជាតកនេះ ព្រះអង្គទ្រង់សម្ដែងក្នុងទីណា មានខ្លឹមសារដូចម្ដេច បើខ្ញុំព្រះអង្គមិនដឹង ជនទាំងឡាយក៏នឹងគិតថា សូម្បីការសម្ដែងធម៌របស់ព្រះសាស្តា អ្នកឧបដ្ឋាកក៏មិនដឹង ហេតុអ្វីទើបជាប់តាមព្រះសាស្តាបានអស់កាលយូរម្ល៉េះ ខ្ញុំព្រះអង្គត្រូវការនឹងសម្ដែងធម៌ទាំងនោះ ដល់អ្នកត្រូវការចង់ដឹងម្ដងទៀត ទើបសូមប្រទានពរដូចពោលមកនេះ ។

ព្រះសាស្តាកាលទ្រង់ស្ដាប់ហេតុផលហើយ ទើបប្រទានពុទ្ធានុញ្ញាត ព្រះអានន្ទកាលបានទទួលពុទ្ធានុញ្ញាតហើយ ក៏បដិបត្តិនាទីជាឧបដ្ឋាកប្រចាំចាប់តាំងពីនោះមក រហូតទាល់តែព្រះអង្គបរិនិព្វាន ។ អដ្ឋកថាពោលថា ក្នុងកាលមុនព្រះអានន្ទធ្លាប់ជាឧបដ្ឋាក របស់ព្រះបច្ចេកពុទ្ធជាម្ចាស់មកអស់កាលយូរ បានថ្វាយទានជានិច្ច តាំងសេចក្ដីប្រាថ្នាសូមឱ្យបានជាពុទ្ធុបដ្ឋាកក្នុងអនាគត រហូតទៅកើតក្នុងស្ថានសួគ៌ជាន់តុសិត ព្រមជាមួយព្រះសាស្តារបស់យើងនេះ ចុតិចាកទេវលោកចុះមកកើតក្នុងវាំងរបស់ព្រះបាទសុក្កោទនៈ ជាសហជាតវត្ថុមួយ ក្នុងបណ្ដាសហជាតវត្ថុ ៧ របស់ព្រះសាស្តា ពួកព្រះញាតិជ្រើសរើសនាមថា អានន្ទ

ផលនៃបារមីដែលបានបំពេញមក ក៏សម្រេចសេចក្តីប្រាថ្នា បានជាឧបដ្ឋាកប្រចាំរបស់ព្រះសាស្តា សមតាមសេចក្តីប្រាថ្នា ។

ក្រោយពីបានទទួលតំណែងឧបដ្ឋាកប្រចាំហើយ ព្រះអានន្ទបានឧបដ្ឋាកព្រះសាស្តាដោយកិច្ចផ្សេងៗ ដូចជា ថ្វាយទឹកស្រង់ ថ្វាយឈើជម្រះព្រះទន្ត ច្របាច់ព្រះបិដ្ឋិ (ខ្នង) និងបោសសម្អាតព្រះគន្ធកុដិជាដើម ក្នុងរាត្រីក៏កាន់ប្រទីបធំដើរត្រួតពិនិត្យជុំវិញបរិវេណព្រះគន្ធកុដិរហូតទាំង ៣ យាម ។ ដោយហេតុនៅជិតដិតជាមួយព្រះពុទ្ធអង្គ បានស្តាប់ធម៌ដែលព្រះអង្គទ្រង់សម្តែងដល់ខ្លួនឯងនិងអ្នកដទៃ មានសតិចងចាំទុកបានមិនភ្លាំងភ្លាត់ មានសេចក្តីព្យាយាមយកចិត្តទុកដាក់ក្នុងការស្វាធ្យាយ ទើបជាអ្នកឆ្លាតក្នុងការសម្តែងធម៌ ព្រះមានព្រះភាគទ្រង់តែងតាំងព្រះអានន្ទថា ជាកំពូលជាងភិក្ខុទាំងឡាយ ៥ ប្រការ គឺ **ជាពហូសូត មានសតិ មានគតិ មានសេចក្តីព្យាយាម និងជាពុទ្ធុប្បដ្ឋាក ។**

ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទជាអ្នកប្រកបដោយ **អព្ភុតធម៌ ៤ ប្រការ** ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា កាលបានចូលជិតអានន្ទហើយរមែងរីករាយ :

**ដោយការដែលបានជួបបានឃើញព្រះអានន្ទ**

**ដោយការដែលបានស្តាប់ព្រះធម៌អំពីព្រះអានន្ទ**

**ដោយធម៌ដែលអានន្ទសម្តែងហើយ**

**ដោយការមិនឆ្អែតក្នុងធម៌ដែលអានន្ទសម្តែង ។**

ម្នាលភិក្ខុទាំងឡាយ អព្ភូតធម៌គួរឱ្យអស្ចារ្យ ៤ ប្រការនេះឯង មានព្រម ក្នុងព្រះអានន្ទ ព្រោះហេតុនោះ កាលព្រះបរមសាស្ដាបរិនិព្វានហើយ គ្រាព្រះមហាកស្សបសង្គាយនា ព្រះធម្មវិន័យគ្រាដំបូង ទើបពួកសង្ឃជ្រើសរើសព្រះ-អានន្ទឱ្យជាអ្នកវិសជ្ជនា ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

## ក្រោយពីចេញព្រះវស្សាទី ២០ ហើយ

សេចក្ដីសន្និដ្ឋាន :

- ក្រោយពីចេញព្រះវស្សាទី ១៩ ហើយ ព្រះអង្គយាងត្រឡប់មកក្រុងសាវត្ថី
- នាងវិសាខាផ្ដើមកសាងមិគារមាតុប្រាសាទ ក្នុងបុព្វារាម
- ទ្រង់យាងចារិកត ហើយចាំព្រះវស្សាទី ២០ ក្នុងវត្តវេឡុវ័ន
- ទ្រង់ត្រាស់ឱ្យព្រះមហាមោគ្គល្លាននៅជួយមើលការកសាង
- ក្រោយពីចេញព្រះវស្សាទី ២០ ការកសាងក៏រួចស្រេចបរិបូរណ៍
- ព្រះពុទ្ធអង្គយាងត្រឡប់មកកាន់ក្រុងសាវត្ថីវិញ
- នាងវិសាខានិមន្តព្រះអង្គឱ្យគង់ក្នុងប្រាសាទ ៤ ខែ ដើម្បីធ្វើការឆ្លង
- ព្រះអង្គទ្រង់គង់ចាំព្រះវស្សាទី ២១ នៅក្រុងសាវត្ថី ។

**បុព្វារាម** ជាឧទ្យានក្រៅក្រុងសាវត្ថី នៅទិសខាងកើត មានមកតាំងពីកាលណា មិនមានប្រវត្តិបញ្ជាក់ មានត្រឹមតែថា បុព្វារាមជាទីដែលព្រះអង្គទ្រង់ប្រើប្រាស់ ដើម្បីសម្រាកព្រះឥរិយាបថ ក្រោយពីសោយភត្តាហារក្នុងផ្ទះ របស់អនាថបិណ្ឌិកសេដ្ឋីហើយជាប្រចាំសម័យមួយ ព្រះអង្គទ្រង់ត្រាស់ឱ្យសាមណេរមួយរូបឈ្មោះ សុមនៈ បានដងទឹកអំពីអនោតត្ត-ស្រះ មកប្រើព្យាបាលរោគរបស់ព្រះអនុរុទ្ធដែលអាពាធ ។

តមក ក្រោយពីនាងវិសាខាភ្លេចគ្រឿងប្រដាប់មហាលតាបសាធន៍ ក្នុងវត្តជេតវន និងដឹងថាព្រះអានន្ទចាប់ពាល់កញ្ចប់គ្រឿងប្រដាប់ ដោយរក្សាទុករហូតទាល់តែម្ចាស់របស់មកទទួលយកទៅវិញ ទើបនាងមិនព្រមយកគ្រឿងប្រដាប់នោះមកប្រើប្រាស់ទៀត បានប្រកាសលក់ តែមិនមានអ្នកណាអាចមានលទ្ធភាពទិញ ទើបនាងទិញខ្លួនឯងវិញ ដោយប្រាក់ ៩ កោដិ ហើយយកទៅទិញដីមួយចំណែកនៃឧទ្យានបុព្វារាម ដើម្បីកសាងប្រាសាទថ្វាយ តាមការណែនាំរបស់ព្រះសម្មាសម្ពុទ្ធ ។

**មិគារមាតុប្រាសាទ** ជាប្រាសាទដែលនាងវិសាខាកសាងថ្វាយ ដោយប្រាក់ចំនួន ៩ កោដិទៀត ក្នុងរយៈពេលកសាង ព្រះពុទ្ធអង្គត្រាស់ឱ្យព្រះមោគ្គលាន និងភិក្ខុ ៥០០ រូបទៀត ជាអ្នកណែនាំលក្ខណៈ ជាប្រាសាទ ២ ជាន់ មានបន្ទប់សម្រាកមួយជាន់ៗ ៥០០ បន្ទប់ លើដំបូលប្រាសាទ សាងអាងរក្សាទឹក ធ្វើដោយមាសសុទ្ធ ផ្ទុកទឹកបាន ៦០ ឡាំង កាលសម្រេចហើយ នាងធ្វើបុណ្យឆ្លងអស់ប្រាក់ ៩ កោដិទៀត ។

## ចំណុចវិភាគពិចារណា តាមហេតុផល

រឿងនាងវិសាខាកសាងមិគារមាតុប្រាសាទ មិនមានបញ្ជាក់ច្បាស់ថា កសាងក្នុងវស្សាណា បើគិតប្រៀបធៀបនឹងរយៈពេលនៃវស្សាទី ៥ ដែលព្រះអង្គយាងទៅភទ្ទិយនគរ ដែនអង្គៈ ដើម្បីប្រោសត្រកូលរបស់នាងឱ្យបានសម្រេចជាសោតាបន្ន និងប្រោសភទ្ទជិ ក្មួយប្រុសមេណ្ឌកសេដ្ឋី ឱ្យសម្រេចព្រះអរហត្តនោះ នាងទើបតែមានអាយុត្រឹម ៧ ខួប បន្ទាប់ពីនោះ ក្រុមគ្រួសាររបស់នាងដោយមានធនញ្ជ័យសេដ្ឋីជាបិតា នាងសុមនាទេវីជាមាតា និងខ្លួននាងព្រមទាំងពួកបរិវារ ក៏បានដូរទីតាំងមកស្នាក់នៅក្នុងដែន សាកេត តាមព្រះរាជបញ្ជារបស់ព្រះបាទបសេនទិកោសល ជាស្ដេចនៃដែនកោសល តមក កាលនាងមានអាយុ ១៦ ឆ្នាំ ទើបមានក្រុមគ្រួសារ គឺមានប្ដី ។

ក្រោយពីនាងមានបុត្រហើយ ពេលទៅស្តាប់ព្រះធម៌ទេសនានៅវត្តជេតពន នាងភ្លេចគ្រឿងប្រដាប់មហាលតាបសាធន៍ក្នុងវិហារ ក្នុងវេលានោះនាងមានអាយុយ៉ាងតិចប្រមាណជា ២១ ឆ្នាំហើយ ។ ១៤ ឆ្នាំកន្លងទៅ រាប់ពីថ្ងៃដែលនាងសម្រេចសោតាបន្ន ទើបនាងផ្តើមកសាងប្រាសាទ ប៉ាន់ស្មានថា ក្នុងរវាងវស្សាទី ១៩-២០ ។

## ចប់ព្រះពុទ្ធកិច្ចក្នុងបឋមពោធិកាល
## ព្រះវស្សាទី ១-២០

# ព្រះពុទ្ធកិច្ច

## ទីកន្លែងដែលទ្រង់គង់ចាំព្រះវស្សាទី ២១ - ៤៤

**ក្នុងបឋមពោធិកាល គឺវស្សាទី ១-២០** ព្រះអង្គទ្រង់មិនបានគង់នៅកន្លែងណាមួយជាប្រចាំទេ ដោយទ្រង់ជ្រាបថា អ្នកណាមានឧបនិស្ស័យនឹងសម្រេចមគ្គផល សូម្បីនៅក្នុងទីដ៏សែនឆ្ងាយ និងត្រូវជួបឧបសគ្គយ៉ាងណាក៏ដោយ ព្រះអង្គក៏យាងទៅដើម្បីអនុគ្រោះដល់បណ្តាជនទាំងនោះ ឱ្យផុតចាកទុក្ខភ័យទាំងពួង ព្រះពុទ្ធកិច្ចរបស់ព្រះអង្គមិនជ្រើសរើសបុគ្គល មិនជ្រើសរើសពេលវេលា មិនជ្រើសរើសឱកាស និងមិនជ្រើសរើសទីកន្លែង ។

( ១ ) **វស្សាទី ២១ - ៤៤** ទ្រង់គង់ជាប្រចាំ ក្នុងក្រុងសាវត្ថី គឺវត្តជេតពន និងមិគារមាតុប្រាសាទវត្តបុព្វារាម ឆ្លាស់គ្នាតែមិនបានបញ្ជាក់ថា វស្សាណាគង់ក្នុងវត្តជេតពន និងវស្សាណាគង់ក្នុងមិគារមាតុប្រាសាទ ឧទ្យានបុព្វារាមទេ ។

ក្រោយអំពីចេញព្រះវស្សាហើយ ព្រះអង្គក៏យាងចារិកទៅកាន់ស្រុកនិគមផ្សេងៗ ដើម្បីប្រោសវេនេយ្យសត្វដូចមុន ដូចជាយាងទៅ **ក្រុងកោសម្ពី អាតុមា ចម្បា វេសាលី នាលន្ទា ភទ្ទិយៈ** និងតាមជនបទប្របជើងភ្នំហិមាល័យជាដើម លុះវេលាជិតចូលព្រះវស្សា ក៏យាងត្រឡប់មកគង់ចាំព្រះវស្សាក្នុងក្រុងសាវត្ថីវិញ ។ ព្រះពុទ្ធជាម្ចាស់ ទោះបីព្រះអង្គយាងទៅកាន់ទីណាក៏ដោយ ក៏ទ្រង់ប្រកបវេនេយ្យសត្វទាំងនោះទុក ដោយសីល សមាធិ បញ្ញា និង

អរិយមគ្គអរិយផល មានសោតាបត្តិមគ្គសោតាបត្តិផលជាដើម ។

ដូចបានពោលហើយ មិគារមាតុប្រាសាទ ដែលវិសាខាមហាឧបាសិកាកសាងក្នុងបុព្វារាម ជាប្រាសាទពីរជាន់ មាន ១០០០ បន្ទប់ សម្រាប់ជាទីគង់នៅរបស់ព្រះសាស្តា និងជាទីអាស្រ័យរបស់ព្រះថេរៈ ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន និងមិគារមាតុប្រាសាទវត្តបុព្វារាម ឆ្លាស់គ្នា គឺ បើវេលាយប់ **ទ្រង់គង់ក្នុងវត្តជេតពន** ព្រឹកឡើងយាងចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយទ្រង់សម្រាកពេលថ្ងៃក្នុងវត្តបុព្វារាម ។ បើក្នុងវេលាយប់ ទ្រង់គង់ក្នុងវត្តបុព្វារាម ព្រឹកឡើងយាងចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ក៏នឹងទ្រង់សម្រាកពេលថ្ងៃក្នុងវត្តជេតពន ។

ហេតុដែលព្រះអង្គទ្រង់គង់ក្នុងក្រុងសាវត្ថី ដែនកោសល យូរជាទីបំផុតក្នុងការបំពេញព្រះពុទ្ធកិច្ច ព្រោះក្រុងសាវត្ថីជានគរសុខស្ងប់ ចម្រើនស្តុកស្តម្ភភិក្ខាហារសម្បូណ៌ មានដងព្រៃជាទីសមគួរដល់ការបំពេញសមណធម៌ ទាំងមានព្រះរាជា គឺព្រះបាទបសេនទិកោសល ដែលជ្រះថ្លាក្នុងព្រះពុទ្ធសាសនា មានសេចក្តីគោរពកោតក្រែងក្នុងព្រះពុទ្ធអង្គយ៉ាងក្រៃលែង មានត្រកូលឧបាសកឧបាសិកាអ្នកមានសទ្ធាក្នុងព្រះរតនត្រៃ ដូចជា ត្រកូលរបស់អនាថបិណ្ឌិកសេដ្ឋី និងត្រកូលរបស់មហាឧបាសិកាវិសាខា ដែលធ្លាប់យកចិត្តទុកដាក់ មើលថែរក្សាឧបដ្ឋាកព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងភិក្ខុសង្ឃយ៉ាងលើសលប់ ត្រកូលទាំងពីររមែងទៅកាន់ទីឧបដ្ឋាកព្រះតថាគតជាម្ចាស់ មួយថ្ងៃពីរដងជាប្រចាំ ក្នុងផ្ទះ

របស់អ្នកទាំងពីរនោះ ត្រៀមអាសនៈទុកដើម្បីភិក្ខុក្នុងមួយផ្ទះៗ មួយពាន់រូប ភិក្ខុរូបណាត្រូវការបច្ច័យណា ទោះជាបាយ ទឹក ឬភេសជ្ជប្បច្ច័យក៏ដោយ ក៏សម្រេចដល់ភិក្ខុរូបនោះ តាមសេចក្តីត្រូវការភ្លាម ។

ក្រៅពីនោះ កិច្ចរបស់ឧបាសកឧបាសិកានៅក្រុងសាវត្ថី គឺពេលព្រឹកនាំគ្នាទៅថ្វាយទាន ក្រោយភត្តកាលក៏ត្រៀមគ្រឿងសក្ការបូជា មានផ្កាឈើគ្រឿងក្រអូប ព្រមទាំងទេយ្យធម៌មានសំពត់ ភេសជ្ជៈ និងទឹកបានៈជាដើម ទៅកាន់វត្តជេតពនដើម្បីស្តាប់ព្រះធម៌ជាប្រចាំ ជនទាំងនោះ កាលស្តាប់ព្រះធម្មទេសនាហើយ បានសម្រេចធម៌ជាអរិយបុគ្គលដ៏ច្រើន ការបញ្ញត្តិសិក្ខាបទដោយច្រើន ព្រះអង្គក៏ទ្រង់បញ្ញត្ត ខណៈដែលគង់នៅក្នុងក្រុងសាវត្ថីនេះឯង ។

## ព្រះរាជាព្រះបាទបសេនទិកោសល

(២) **ព្រះបាទបសេនទិកោសល** ព្រះរាជារបស់ដែនកោសល ជាព្រះមហាក្សត្រ ដែលមានសេចក្តីគោរពរាប់អានក្នុងព្រះពុទ្ធអង្គយ៉ាងខ្លាំង សម័យមួយ មកគាល់ព្រះអង្គ បានចូលមកក្រាបទៀបព្រះបាទាព្រះពុទ្ធជាម្ចាស់ ព្រះមានព្រះភាគត្រាស់សួរថា មហាបពិត្រមានហេតុអ្វីទៅ ទើបសម្តែងសេចក្តីគោរពស្រឡាញ់ ចំពោះតថាគតយ៉ាងខ្លាំងក្លាដូច្នេះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គ មានសេចក្តីជ្រះថ្លាក្នុងព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ដឹងប្រពៃ

ដោយព្រះអង្គឯង ជ្រះថ្លាក្នុងព្រះធម៌ ដែលព្រះមានព្រះភាគសម្តែងល្អហើយ ជ្រះថ្លាក្នុងសង្ឃសាវ័ករបស់ព្រះមានព្រះភាគ ជាអ្នកបដិបត្តិល្អហើយ ព្រះអង្គបានទ្រង់បំពេញប្រយោជន៍ដ៏ធំក្រៃលែង ដល់ជនក្នុងក្រុងសាវត្ថី ព្រះអង្គទ្រង់ធ្វើមហាជនឱ្យតាំងនៅក្នុងកុសល និងមានគុណធម៌ ។

មិនត្រឹមតែប៉ុណ្ណោះ ព្រះបាទបសេនទិកោសលបានក្រាបទូល នូវសេចក្តីជ្រះថ្លាក្នុងព្រះធម៌ លើកតម្កើងព្រះបញ្ញាដ៏កំពូល និងសេចក្តីគោរពដែលមានចំពោះព្រះមានព្រះភាគយ៉ាងក្រៃលែងច្រើនប្រការទៀត ក្នុងទីបំផុតក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មួយប្រការទៀត ព្រះមានព្រះភាគជាក្សត្រ ខ្ញុំព្រះអង្គក៏ជាក្សត្រ ព្រះជន្មាយុរបស់ព្រះមានព្រះភាគ ក៏ស្មើអាយុរបស់ខ្ញុំព្រះអង្គ ដោយហេតុនេះឯង ទើបខ្ញុំព្រះអង្គមានសេចក្តីស្រឡាញ់ សេចក្តីគោរពកោតក្រែងយ៉ាងក្រៃលែង ចំពោះព្រះមានព្រះភាគ ទើបសម្តែងសេចក្តីស្និទ្ធស្នាលដូច្នេះ ត្រាស់យ៉ាងនេះហើយ ក្រាបទូលលាចៀសចេញទៅ ។

កាលព្រះបាទបសេនទិកោសល យាងទៅហើយមិនយូរ ព្រះអង្គមានព្រះតម្រាស់ឱ្យរកភិក្ខុទាំងឡាយមក ត្រាស់ថា ព្រះបាទបសេនទិកោសលអង្គនេះត្រាស់ **ធម្មចេតីយ៍** គឺព្រះវាចាគោរពធម៌ អ្នកទាំងឡាយចូររៀនធម្មចេតីយ៍នេះ ម្នាលភិក្ខុទាំងឡាយ **ធម្មចេតីយ៍នេះ ប្រកបដោយប្រយោជន៍ ជាខាងដើម របស់ព្រហ្មចរិយៈ** ។

ព្រះបាទបសេនទិកោសល កាលមានឱកាសក៏យាងមកគាល់ញយ ៗ

ព្រោះសេចក្ដីគោរពស្រឡាញ់ក្នុងព្រះពុទ្ធអង្គ បំណងនឹងសន្ទនាផង ជួនកាលព្រះមានព្រះភាគទ្រង់អនុគ្រោះព្រះបាទបសេនទិកោសល ជារឿងផ្ទាល់ខ្លួនព្រះអង្គ ដូចក្នុង **ទោណបាកសូត្រ** សម្ដែងទុកថា ព្រះបាទបសេនទិកោសលនោះសោយហួសប្រមាណ ទើបទ្រង់មានព្រះកាយធ្ងន់ ពេលទ្រង់គង់ក៏មិនស្រួល ទ្រង់ឈរក៏មិនរហ័សរហួន កាលចូលមកគាល់ក៏មានអាការទីងទាង ទើបព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ព្រះគាថាថា :

**មនុស្សអ្នកមានសតិសព្វកាល ស្គាល់ប្រមាណក្នុងភោជន**
**រមែងមានវេទនាស្រាលស្តើង កម្រចាស់ និងមានអាយុវែង**

ព្រះបាទបសេនទិកោសលមានសតិ ឱ្យសុទស្សនកុមារ ព្រះនត្តាដែលយាងមកតាមព្រះអង្គ រៀនព្រះគាថានេះ វេលាដែលព្រះបាទបសេនទិកោសលសោយពេលណា សុទស្សនកុមារក៏ពោលគាថានេះ ធ្វើឱ្យសោយតែល្មមប្រមាណតមក ព្រះបាទបសេនទិកោសលទ្រង់មានព្រះវរកាយស្រាល រហ័សរហួនឡើង ទ្រង់រឭកដល់ព្រះគុណរបស់ព្រះពុទ្ធអង្គ ត្រាស់ថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់អនុគ្រោះយើង ដោយប្រយោជន៍ទាំងពីរយ៉ាង គឺប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍បរលោក ( លោកខាងមុខ ) ។

សម័យមួយ ខណៈដែលព្រះមានព្រះភាគគង់នៅវត្តជេតពន អារាមរបស់អនាថបិណ្ឌិកសេដ្ឋី ព្រះបាទបសេនទិកោសលយាងចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គទ្រង់ប្ដេជ្ញាបានទេ

ថា ព្រះអង្គបានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏កំពូល ។ ព្រះមានព្រះភាគត្រាស់ឆ្លើយថា មហាបពិត្រ កាលមហាបពិត្រត្រាស់ដោយប្រពៃ ក៏គប្បីត្រាស់ថា តថាគតបានត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណដោយប្រពៃ ព្រោះតថាគតបានត្រាស់ដឹងធម៌ដ៏ប្រពៃនោះ ដោយព្រះអង្គឯងហើយ ។

ព្រះបាទបសេនទិកោសលទូលសួរថា សមណព្រាហ្មណ៍ពួកខ្លះជាគណាចារ្យ ជាមេលទ្ធិ មានកិត្តិគុណ មានឈ្មោះល្បី ជនជាច្រើនលើកតម្កើងថាល្អ គឺ **បូរណកស្សបៈ មក្ខលិគោសាល អជិតកេសកម្ពល បកុធកច្ចាយនៈ សញ្ជ័យវេលដ្ឋបុត្រ និងនិគ្រន្ថនាដបុត្រ** សមណព្រាហ្មណ៍ទាំងនោះ កាលត្រូវខ្ញុំព្រះអង្គសួរ ក៏មិនហ៊ានប្ដេជ្ញាខ្លួនទេថា ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ចំណែកព្រះគោតមដ៏ចម្រើន នៅមានព្រះជន្មក្នុងវ័យកម្លោះ និងជាអ្នកថ្មីក្នុងបព្វជ្ជា ហេតុអ្វីទើបហ៊ានប្ដេជ្ញាបានហ្ន៎ ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ឆ្លើយថា មហាបពិត្រ វត្ថុ ៤ ប្រការនេះ មិនគួរមើលងាយថា តូច ឬតិចតួច គឺ :

**១. ក្សត្រ មិនគួរមើលងាយថា នៅព្រះជន្មក្មេង**

**២. ពស់ មិនគួរមើលងាយថា នៅតូច**

**៣. ភ្លើង មិនគួរមើលងាយថា គំនរតូច**

**៤. សមណៈ មិនគួរមើលងាយថា នៅថ្មីចំពោះបព្វជ្ជា ។**

ដូច្នេះព្រោះថា ក្សត្រ បានសោយរាជ្យសម្បត្តិហើយ កាលពិរោធរមែង

ទ្រង់ដាក់អាជ្ញា យ៉ាងធ្ងន់ដល់បុរសស្ត្រីបាន ព្រោះហេតុដូច្នេះ អ្នករក្សាជីវិតរបស់ខ្លួន គប្បីវៀរការមើលងាយ តេជានុភាពរបស់ក្សត្រ ។

**ពស់** ក្នុងស្រុក ឬព្រៃក៏ដោយ មិនគប្បីមើលងាយថា ខ្លួនតូច ព្រោះពស់ជាសត្វមានពិស ព្រមទាំងអាចចឹកខាំបៀតបៀនបុរសស្ត្រីល្ងង់ខ្លៅ ព្រោះហេតុដូច្នោះ អ្នករក្សាជីវិតរបស់ខ្លួន គប្បីវៀរការមើលងាយពស់នោះថា ខ្លួនតូច ។

**ភ្លើង** សូម្បីគំនរតូច តែកាលបានឧសរមែងឆេះជាគំនរធំ ឆេះរាលបៀតបៀនបុរសស្ត្រីល្ងង់ខ្លៅក្នុងគ្រាខ្លះ ព្រោះហេតុដូច្នោះ អ្នករក្សាជីវិតរបស់ខ្លួន គប្បីវៀរការមើលងាយភ្លើងនោះថា គំនរតូច ។

**សមណៈ** អ្នកណាមើលងាយសមណៈអ្នកបួសថ្មីក្នុងភេទបព្វជិត តែខ្ពង់ខ្ពស់ដោយគុណធម៌ តេជៈនៃសីលរបស់សមណៈរមែងធ្វើសេចក្តីវិនាសឱ្យដល់អ្នកនោះ ទាំងទាយាទ នឹងមិនបានទទួលទ្រព្យមតិកទៀតផង បុគ្គលនោះនឹងប្រាសចាកផៅពង្សដូចត្នោតកំបុតចុង ។

ព្រោះហេតុដូច្នោះ បុគ្គលជាបណ្ឌិតពិចារណាឃើញក្សត្រអ្នកទ្រង់យស ពស់ ភ្លើង និងសមណៈអ្នកមានសីល ថាជាភ័យដល់ខ្លួន គប្បីប្រព្រឹត្តចំពោះវត្ថុទាំងនោះដោយប្រពៃចុះ ។

កាលព្រះមានព្រះភាគត្រាស់ចប់ ព្រះបាទបសេនទិកោសល ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងព្រះរតនត្រៃដោយទេសនានេះ ក្រាបទូលព្រះមានព្រះភាគជាម្ចាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់លើកខ្ញុំព្រះអង្គដែលធ្លាក់ទៅក្នុង

អសទ្ធម្ម ឱ្យតាំងនៅក្នុងសទ្ធម្ម ដូចបុគ្គលផ្ងាររបស់ដែលផ្កាប់ ទ្រង់បើកព្រះសាសនាដែលមិច្ឆាទិដ្ឋិបិទទុក ទ្រង់ធ្វើផ្លូវសួគ៌ និងនិព្វាន ឱ្យជាក់ច្បាស់ដល់ខ្ញុំព្រះអង្គ ដូចទ្រង់ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ទ្រង់ទ្រោលប្រទីប គឺព្រះធម៌ទេសនាដែលកម្ចាត់ងងឹត គឺអវិជ្ជាដល់ខ្ញុំព្រះអង្គ ជាអ្នកមិនឃើញព្រះរតនត្រៃ ដូចទ្រង់ទ្រោលប្រទីបក្នុងទីងងឹត ទ្រង់ប្រកាសធម៌ដល់ខ្ញុំព្រះអង្គដោយអនេកបរិយាយ ខ្ញុំព្រះអង្គសូមដល់ព្រះមានព្រះភាគជាម្ចាស់ ព្រះធម៌ និងព្រះភិក្ខុសង្ឃ ជាទីពឹងទីរឭក សូមព្រះមានព្រះភាគទ្រង់ចាំខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់សរណគមន៍អស់មួយជីវិត ។

## អនាថបិណ្ឌិកសេដ្ឋី

### ជាកំពូលឧបាសកក្នុងការថ្វាយទាន

(៣) **អនាថបិណ្ឌិក** ជាបុត្ររបស់សុមនសេដ្ឋី នៃក្រុងសាវត្ថី ដែនកោសល កាលប្រសូតិបិតាជ្រើសរើសនាមថា **សុទត្តៈ** ហេតុដែលមានឈ្មោះថា អនាថបិណ្ឌិក ព្រោះជាអ្នកពេញចិត្តធ្វើទានដល់មនុស្សកំព្រា រហូតបាននាមដែលខ្លួនប្រាថ្នាទុកតាំងពីអតីតជាតិ កាលបិតាអស់ជីវិតក៏បានគ្រប់គ្រងទ្រព្យសម្បត្តិជាគហបតីតមក ភរិយារបស់អនាថបិណ្ឌិកឈ្មោះនាង **បុញ្ញលក្ខណា** មានកូនប្រុសម្នាក់ឈ្មោះ **កាឡៈ** មានធីតា ៣ នាក់ឈ្មោះ **មហាសុភទ្ទា ចូឡសុភទ្ទា និងសុមនាទេវី ។**

ក្រោយអំពីប្រោសព្រះបិតា និងព្រះញាតិវង្សហើយ ព្រះសាស្តាយាងត្រឡប់មកកាន់ក្រុងរាជគ្រឹះ គង់នៅក្នុងព្រៃសីតវ័ន ពេលនោះអនាថបិណ្ឌិកប្រមូលកងរទេះធ្វើដំណើរចូលមកជួញដូរនៅក្រុងរាជគ្រឹះ កាលធ្វើដំណើរមកដល់ ក៏ទៅស្នាក់នៅឯផ្ទះរាជគហសេដ្ឋីដែលជាបងថ្លៃ ឃើញគេកំពុងចាត់ចែងអាហារផ្សេងៗជាច្រើនគិតថា គេត្រៀមការងាររមង្គល បើមិនដូច្នោះទេ ព្រះរាជាក៏នឹងយាងមក ទើបសាកសួរមើលដឹងថា រាជគហសេដ្ឋីបាននិមន្តព្រះសម្មាសម្ពុទ្ធព្រមទាំងភិក្ខុសង្ឃឱ្យសោយភត្តាហារក្នុងថ្ងៃស្អែក គ្រាន់តែបានឮពាក្យថា **ពុទ្ធោ** អនាថបិណ្ឌិកសេដ្ឋីកើតបីតិ ប្រាថ្នានឹងទៅគាល់ព្រះពុទ្ធអង្គភ្លាម ទើបសួររាជគហសេដ្ឋីថា ពេលនេះព្រះពុទ្ធអង្គទ្រង់គង់នៅក្នុងទីណា ខ្ញុំនឹងអាចទៅគាល់ពេលនេះបានឬទេ ? រាជគហសេដ្ឋីឆ្លើយថា ព្រះពុទ្ធអង្គគង់នៅក្នុងព្រៃសីតវ័ន វេលានេះមិនសមគួរចូលទៅគាល់ គួររង់ចាំទាល់តែពេលថ្ងៃស្អែក ។

នៅវេលាទៀបភ្លឺ អនាថបិណ្ឌិកសេដ្ឋីប្រញាប់រួសរាន់ទៅកាន់ព្រៃសីតវ័នតាំងពីនៅមិនទាន់ភ្លឺ ឃើញព្រះសាស្តាកំពុងយាងចង្ក្រម ព្រះសាស្តាឃើញអនាថបិណ្ឌិកដើរមកពីចម្ងាយ ទើបទ្រង់មកប្រថាប់គង់លើអាសនៈ កាលទៅដល់ព្រះអង្គត្រាស់ថា **មកចុះសុទត្តៈ** លោកសេដ្ឋីស្តាប់ហើយព្រឺព្រួចក្នុងចិត្តថា ព្រះមានព្រះភាគត្រាស់ហៅឈ្មោះពិតរបស់យើង ចូលទៅថ្វាយបង្គំហើយ ក្រាបក្បាលចុះទៀបព្រះបាទាទូលសួរថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់គង់នៅជាសុខឬ ព្រះអង្គ ?

ព្រះសាស្តាត្រាស់តបថា **ព្រាហ្មណ៍ដែលរំលត់ទុក្ខបានហើយ រមែងនៅជាសុខគ្រប់ពេល** ហើយត្រាស់អនុបុព្វីកថា និងទ្រង់សម្តែងអរិយសច្ច ៤ ។

អនាថបិណ្ឌិកសេដ្ឋីស្តាប់ធម៌នោះហើយ បានធម្មចក្ខុសម្រេចជាព្រះសោតាបន្ន ទូលថ្វាយខ្លួនដល់ព្រះរតនត្រ័យជាសរណៈ ប្រកាសខ្លួនជាឧបាសកអ្នកដល់សរណៈស្មើដោយជីវិត ក្រាបទូលអារាធនាព្រះសាស្តា ឱ្យទទួលភត្តាហាររបស់ខ្លួនក្នុងថ្ងៃស្អែក ព្រះអង្គទ្រង់ទទួលដោយតុណ្ហីភាព សេដ្ឋីថ្វាយបង្គំធ្វើប្រទក្សិណហើយចៀសចេញទៅ ។

**រាជគហសេដ្ឋី** ដឹងថា អនាថបិណ្ឌិកសេដ្ឋីនិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធានដើម្បីឆាន់ក្នុងថ្ងៃស្អែក ទើបចេញស្តីថានឹងឱ្យទ្រព្យជាតម្លៃចាយវាយក្នុងពិធីបុណ្យនេះ សូម្បីតែព្រះរាជាព្រះបាទពិម្ពិសារក៏សម្តែងព្រះបំណងនឹងជួយដោយទ្រង់ឃើញថា ជាអាគន្តុកៈអ្នកមកពីស្រុកឆ្ងាយ តែអនាថបិណ្ឌិកសេដ្ឋីក៏អរគុណក្នុងការអើពើនោះ ព្រមដោយការបដិសេធប្រាប់ថា ទ្រព្យរបស់ខ្លួនមានល្មមអាចប្រើប្រាស់បានហើយ ។

ព្រឹកឡើង ក្រោយភត្តកិច្ចព្រះសាស្តាទ្រង់អនុមោទនាហើយ អនាថបិណ្ឌិកទើបទូលអារាធនាឱ្យយាងទៅប្រោសប្រជាជនក្នុងក្រុងសាវត្ថី ព្រះសាស្តាទ្រង់ទទួលដោយតុណ្ហីភាព ។ កាលសម្រេចភារកិច្ចក្នុងក្រុងរាជគ្រឹះហើយ អនាថបិណ្ឌិកធ្វើដំណើរត្រឡប់មកក្រុងសាវត្ថី តាមផ្លូវបានសាងសេនាសនៈសម្រាប់ជាទីសម្រាករបស់សង្ឃទុកជាចន្លោះៗ ព្រមទាំងបរិច្ចាគទានដល់ពួកជនតាមផ្លូវ

រហូតដល់ក្រុងសាវត្ថី អស់កហាបណៈជាច្រើន ។

លុះដល់ក្រុងសាវត្ថី អនាថបិណ្ឌិកទៅពិនិត្យទីកន្លែងដែលសមគួរសម្រាប់កសាងវត្តអារាម ឃើញផ្ទៃដីរបស់ **ស្តេចជេត** ឱរសរបស់ព្រះបាទបសេនទិកោសល ដែលនៅទិសខាងត្បូងនៃក្រុង មានផ្ទៃដីទំហំធំទូលាយងាយស្រួលដល់ការទៅមក ទើបទៅចរចាសុំទិញពីស្តេចជេត ស្តេចជេតវាយតម្លៃថា ប្រសិនបើលោកនាំកហាបណៈ មកក្រាលឱ្យពេញផ្ទៃដីបាន ក៏នឹងលក់ឱ្យ ទើបអនាថបិណ្ឌិក បញ្ជាឱ្យបរិវារជញ្ជូនកហាបណៈដាក់រទេះចំនួន ១៨ កោដិ ហើយនាំមកក្រាលក្នុងផ្ទៃដីនោះ ក្រាលរៀបបានពាក់កណ្តាលនៃផ្ទៃដី កហាបណៈដែលនាំយកមកក៏អស់ ។

អនាថបិណ្ឌិកបញ្ជាឱ្យបរិវារ ទៅជញ្ជូនកហាបណៈមកបំពេញបន្ថែមទៀត ស្តេចជេតឃើញដូច្នោះ ទើបពោលថា ទីដែលលោកក្រាលកហាបណៈនោះល្មមហើយ ចំណែកដែលទំនេរនោះយើងប្រគល់ឱ្យ អនាថបិណ្ឌិកសេដ្ឋីពិចារណាឃើញថា គួរថ្វាយទីទំនេរនោះដល់ស្តេចជេត ទើបស្តេចជេតបញ្ជាឱ្យសាងក្លោងទ្វារអារាមក្នុងទីទំនេរនោះ ដោយប្រើកហាបណៈដែលក្រាលទុកជាតម្លៃប្រើប្រាស់ ។

បន្ទាប់ពីនោះ ទើបកសាងព្រះគន្ធកុដិ វិហារ សេនាសនៈព័ទ្ធជុំវិញព្រះគន្ធកុដិនោះ ដើម្បីព្រះថេរៈជាធំនិងសង្ឃសាវ័កទាំងឡាយ កសាងសាលា ស្រះបោក្ខរណី ទីចង្ក្រម ទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ និងអ្វីដទៃៗ ទៀតដែលចាំបាច់ដល់ការប្រើប្រាស់គួរដល់សមណៈដោយកហាបណៈ ១៨ កោដិទៀត ។

ព្រះមានព្រះភាគជាម្ចាស់ គង់នៅឯក្រុងរាជគ្រឹះសមល្មមព្រះទ័យហើយ ទ្រង់យាងទៅក្រុងវេសាលី ដែនវជ្ជីតាមពាក្យអារាធនារបស់ស្តេចលិច្ឆវីមហាលិ ហើយយាងត្រឡប់មកកាន់ក្រុងរាជគ្រឹះ ក្នុងអំឡុងចុងវស្សាទី ២ ដើមវស្សាទី ៣ ការកសាងវិហារក៏សម្រេចរៀបរយ ដាក់ឈ្មោះថា **ជេតវនវិហារ** ដើម្បីជាកិត្តិយសដល់ស្តេចជេតជាម្ចាស់ដី ទើបគេហៅថា **ព្រះជេតវនវិហារ អារាមរបស់អនាថបិណ្ឌិកសេដ្ឋី** គ្រប់៧ គ្នា ។

**អនាថបិណ្ឌិកសេដ្ឋី** លោកទៅអារាធនាព្រះសាស្តា ដើម្បីថ្វាយព្រះវិហារជេតវនដោយខ្លួនឯង ទន្ទឹមគ្នានោះក៏ចាត់ត្រៀមពិធីការយ៉ាងមហោឡារិកក្រៃលែង មានការថ្វាយភត្តាហារដល់ភិក្ខុសង្ឃ ខាងក្នុងផ្ទះរបស់ខ្លួនក៏ចាត់ត្រៀមទាន និងទេយ្យធមិចំនួនច្រើនថ្វាយជាប្រចាំរាល់ថ្ងៃ ។

កាលព្រះសាស្តាយាងមកដល់ អនាថបិណ្ឌិកសេដ្ឋីក្រាបទូលអារាធនាព្រះអង្គឱ្យចូលទៅក្នុងវិហារ កាលព្រះអង្គទ្រង់គង់លើពុទ្ធាសនៈហើយ អនាថ-បិណ្ឌិកទូលសួរថា នឹងឱ្យខ្ញុំព្រះអង្គបដិបត្តិចំពោះព្រះវិហារនេះដូចម្តេច ព្រះសាស្តាត្រាស់ថា ម្នាលគហបតី អ្នកចូរថ្វាយដល់ភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ ទាំងដែលមកហើយ និងមិនទាន់មក ។

អនាថបិណ្ឌិក ទើបនាំគុណ្ឌីមាសស្រោចទឹកចុះលើព្រះហស្តរបស់ព្រះ-សាស្តា ពោលពាក្យឧទ្ទិសថា **ខ្ញុំព្រះអង្គសូមថ្វាយវត្តជេតពននេះ ចំពោះព្រះពុទ្ធអង្គ និងបណ្តាសង្ឃដែលមកអំពីទិសទាំង ៤ ទាំងដែលមកហើយ និង**

មិនទាន់មក តាំងពីពេលនេះតទៅ ។

ព្រះមានព្រះភាគ ទ្រង់ធ្វើអនុមោទនា បានត្រាស់អានិសង្សរបស់ការថ្វាយវិហារថា :

សេនាសនៈរមែងការពារនូវរងា ក្តៅ ខ្យល់ និងកំដៅថ្ងៃ
រមែងប្រាសទៅ ក្រៅពីនោះ រមែងការពារសត្វកាច
ទឹកសន្សើម និងភ្លៀង ការថ្វាយវិហារដើម្បីជាទីនៅ
របស់សង្ឃ ដើម្បីជាទីពួនសម្ងំ ដើម្បីពិចារណា
ដើម្បីឃើញច្បាស់ ព្រះពុទ្ធទាំងឡាយសរសើរថា
ជាទានដ៏កំពូល បណ្ឌិតកាលឃើញប្រយោជន៍របស់ខ្លួន
គប្បីសាងវិហារជាទីរីករាយឱ្យភិក្ខុជាពហូសូតស្នាក់នៅចុះ
គប្បីថ្វាយបាយទឹក សំពត់ និងគិលានភេសជ្ជៈដល់ពួកលោក
កាលលោកដឹងច្បាស់ធម៌ណាហើយ លោករមែងសម្តែងធម៌
នោះ មហាជននឹងជាអ្នកមិនមានអាសវៈ ចូលដល់ព្រះនិព្វាន ។

ពិធីបុណ្យឆ្លងវត្តជេតពនយូរដល់ទៅ ៩ ខែ អស់ទ្រព្យក្នុងការឆ្លង ១៨ កោដិ អនាថបិណ្ឌិកសេដ្ឋីបរិច្ចាគទ្រព្យទាំងអស់ ៥៤ កោដិ ដើម្បីព្រះសាសនា ព្រះសាស្តាទ្រង់គង់ក្នុងវត្តជេតពនមួយរយៈ ទើបយាងត្រឡប់ទៅក្រុងរាជគ្រឹះ។

ថ្ងៃដែលព្រះសាស្តាទទួលវត្តជេតពន សុភូតិ ជាប្អូនប្រុសពៅរបស់អនាថបិណ្ឌិកសេដ្ឋីក៏បានទៅជាមួយនឹងបងប្រុស ស្តាប់ព្រះធម៌ទេសនាហើយ

មានសទ្ធា ទូលសូមបួសក្នុងសំណាក់ព្រះសាស្ដា រៀនកម្មដ្ឋានហើយ ទៅបំពេញវិបស្សនាក្នុងព្រៃ ចម្រើនវិបស្សនាដែលមានមេត្តាឈានជាបាទ បានសម្រេចជាព្រះអរហន្ត ក្នុងវេលាសម្ដែងធម៌ លោកចម្រើនមេត្តាដោយមិនចំពោះ កាលត្រាច់បិណ្ឌបាតក៏ចូលឈានផ្សាយមេត្តាទៅគ្រប់៧ផ្ទះ ចេញចាកឈានហើយទើបទទួលភិក្ខារ លោកគិតថាវិធីនេះ ទានរបស់ទាយកនឹងមានផលច្រើន ។

ដោយហេតុនេះ ទើបព្រះមានព្រះភាគត្រាស់ថា សុភូតិជាកំពូលជាងភិក្ខុសាវ័កអ្នកមានប្រក្រតីនៅដោយមិនមានកិលេស ជាកំពូលទក្ខិណេយ្យបុគ្គល ក្រោយពីសម្រេចព្រះអរហត្តហើយ លោកត្រាច់ចារិកទៅតាមជនបទ ដើម្បីបំពេញប្រយោជន៍ដល់ពួកជន បានធ្វើដំណើរទៅដល់ក្រុងរាជគ្រឹះ ។ ព្រះបាទពិម្ពិសារ ទ្រង់ដឹងការនិមន្តមករបស់ព្រះថេរៈ ទ្រង់និមន្តឱ្យគង់នៅក្នុងក្រុងរាជ-គ្រឹះ មានព្រះតម្រិះថា នឹងសាងកុដិប្រគេន ស្ដេចចៀសចេញទៅ ហើយក៏ភ្លេចព្រះថេរៈកាលមិនមានសេនាសនៈក៏គង់នៅកណ្ដាលវាល ដោយអានុភាពនៃព្រះថេរៈភ្លៀងមិនធ្លាក់ឡើយ ជនទាំងឡាយត្រូវបៀតបៀនដោយការរាំងស្ងួត ទើបនាំគ្នាទៅស្រែកយំនៅទ្វាររាជវាំង ព្រះរាជារឭកដល់ព្រះថេរៈបានថា ព្រោះលោកនៅកណ្ដាលវាល ទើបភ្លៀងមិនធ្លាក់ ទ្រង់មានព្រះរាជបញ្ជាឱ្យសាងកុដិប្រក់ដោយស្លឹក និមន្តព្រះថេរៈឱ្យគង់នៅក្នុងកុដិនោះ ។ លុះព្រះថេរៈចូលទៅកាន់កុដិអង្គុយដុសខាត់សមាធិលើអាសនៈដែលក្រាលដោយស្មៅ ភ្លៀងក៏ធ្លាក់ចុះមកព្រះសុភូតិប្រាថ្នានឹងប្រកាសការផុតអំពីភ័យព្រោះភ្លៀងរាំង ទើបពោលគាថាថា

**ខ្ទមរបស់យើងប្រក់ហើយ ជាទីសប្បាយប្រាសចាកខ្យល់ ម្នាលភ្លៀង ចិត្តរបស់យើងតាំងមាំហើយ រួចផុតហើយ យើងមានសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ម្នាលភ្លៀង សូមអ្នកធ្លាក់ចុះមកចុះ ។**

ព្រះថេរៈសម្តៅយកខ្ទមគឺអត្តភាពនេះ ភ្លៀងគឺកិលេស ដែលព្រះថេរៈបានបិទដោយបញ្ញាប្រកបដោយគុណធម៌ដ៏មាំទាំ បន្លឺឧទានដោយកម្លាំងនៃបីតិ។

**កាឡៈ** កូនប្រុសតែមួយរបស់អនាថបិណ្ឌិកសេដ្ឋី ជាអ្នកមិនមានសទ្ធាក្នុងព្រះពុទ្ធសាសនា ទើបបិតារកឧបាយឱ្យទៅវត្ត សមាទានឧបោសថ និងស្តាប់ធម៌ បើចងចាំព្រះធម៌របស់ព្រះសាស្តាបានសូម្បីត្រឹមតែមួយបទ ក៏នឹងឱ្យប្រាក់មួយពាន់ កាឡៈទៅស្តាប់ធម៌ ព្រះសាស្តាទ្រង់ធ្វើឱ្យគេចាំមិនបាន ត្រូវស្តាប់បន្តទៅដោយគិតថា យើងនឹងរៀនឱ្យចេះ កាលតាំងចិត្តដូច្នោះ ក៏បានធម្មចក្ខុសម្រេចជាព្រះសោតាបន្ន ។

ព្រឹកឡើង ក្រោយពីព្រះសាស្តាសម្រេចភត្តកិច្ចហើយ លោកសេដ្ឋីឱ្យមនុស្សនាំប្រាក់មកឱ្យកូន កាឡៈបដិសេធមិនព្រមទទួលប្រាក់នោះ ដោយសេចក្តីខ្មាស់ ព្រះសាស្តាត្រាស់ថា បុត្ររបស់អ្នកបានសម្រេចសោតាបត្តិផលហើយ និងបានត្រាស់គាថា ថា :

**សោតាបត្តិផលនោះប្រសើរជាងភាពជាស្តេចចក្រពត្តិ និងដំណើរទៅកាន់ស្ថានសួគ៌ និងភាពជាធំក្នុងលោកទាំងពួង ។**

ព្រោះព្រះសោតាបន្នបិទទ្វារអបាយបានហើយ សូម្បីត្រូវកើតទៀតក៏មិនហួសពី ៧ ជាតិ ។

**មហាសុភទ្ទា** ធីតាច្បងរបស់អនាថបិណ្ឌិកសេដ្ឋី បានទទួលភារៈអំពីបិតា ឱ្យជាអ្នកមើលថែទំនុកបម្រុងភិក្ខុសង្ឃពីរពាន់អង្គ ដែលមកឆាន់ក្នុងផ្ទះរាល់ថ្ងៃ នាងបានបំពេញកុសលដោយការអង្គាសភិក្ខុសង្ឃ និងស្តាប់ព្រះធម៌-ទេសនាជាប្រចាំ រហូតបានសម្រេចសោតាបត្តិផល ហើយក៏ទៅកាន់ត្រកូលរបស់ស្វាមី ស្វាមីរបស់នាងជាគហបតីក្នុងឧគ្គនគរ ជាមនុស្សមិច្ឆាទិដ្ឋិ នាងបានទូលអារាធនាសូមឱ្យព្រះសាស្តា យាងទៅទទួលភត្តាហារនៅផ្ទះរបស់នាង ដើម្បីប្រោសក្រុមគ្រួសាររបស់ស្វាមី ហើយចុងក្រោយក៏បានសម្រេចធម៌ផងដែរ ។

**ចូឡសុភទ្ទា** ធីតាទី ២ បានទទួលភារៈឱ្យទំនុកបម្រុងភិក្ខុសង្ឃក្នុងផ្ទះតអំពីនាងមហាសុភទ្ទា ដោយនាទីនេះឯង នាងបានសម្រេចសោតាបត្តិផលដូចជាបងស្រី ក្នុងវេលាតមក នាងមានក្រុមគ្រួសារ បានជាភរិយារបស់កូនកាឡក-សេដ្ឋីនៃនគរសាកេត ដែលជាសាវ័ករបស់ពួកនិគ្រន្ថ មុននឹងទៅកាន់ត្រកូលស្វាមី នាងចូលទៅក្រាបទូលលាព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅមានស្វាមីក្នុងត្រកូលរបស់មនុស្សមិច្ឆាទិដ្ឋិ សូមព្រះអង្គប្រោសនឹកដល់ខ្ញុំម្ចាស់ផង កាលបានទទួលការធានារ៉ាប់រងហើយ នាងក៏ក្រាបទូលលា ។

សម័យមួយ សេដ្ឋីអញ្ជើញពួកនិគ្រន្ថមកកាន់ផ្ទះ នាងបដិសេធមិនព្រមថ្វាយបង្គំ មុននឹងត្រូវបណ្តេញចេញចាកផ្ទះរបស់ស្វាមី សេដ្ឋីសួរនាងថា សមណៈ

របស់នាងដូចម្តេច ទើបនាងសរសើរខ្លាំងម្ល៉េះ នាងឆ្លើយថា សមណៈរបស់នាងខ្ញុំ ជាអ្នកមានឥន្ទ្រីយ៍ស្ងប់ តាំងនៅក្នុងមគ្គ មានគុណដ៏ស្ងប់ សមណៈទាំងនោះកាត់ចំណងចូលព្រៃតែម្នាក់ឯងមិនមានគ្នា សមណៈរបស់នាងខ្ញុំដូច្នេះ ។

លុះពោលយ៉ាងនេះហើយ ចូឡសុភទ្ទា បានឈរពោលគុណរបស់ព្រះ-រតនត្រ័យចំពោះមុខសេដ្ឋី សេដ្ឋីស្តាប់ពាក្យរបស់នាងហើយពោលថា បើដូច្នោះ នាងចូរនាំសមណៈរបស់នាងមកធ្វើមង្គលក្នុងថ្ងៃស្អែក ។ ក្នុងវេលាល្ងាច នាងកាន់ភាជនៈផ្កាយ៉ាងធំ ឡើងទៅប្រាសាទជាន់លើ រឭកដល់គុណរបស់ព្រះសាស្តា ហើយបាចផ្កា ៨ ក្តាប់ទៅដើម្បីបូជាព្រះទសពល ឈរនមស្ការផ្គងអញ្ជលីពោលថា ស្អែកសូមព្រះអង្គប្រោសទទួលភិក្ខារបស់ខ្ញុំម្ចាស់ ព្រមដោយភិក្ខុសង្ឃ ៥០០ រូប ផ្កាទាំង ៨ ក្តាប់បានទៅប្រតិស្ឋានជាពិដានខាងលើអាសនៈរបស់ព្រះសាស្តា ក្នុងវត្តជេតពន ។ ខណៈនោះ អនាថបិណ្ឌិកសេដ្ឋីស្តាប់ធម៌ក្នុងវត្តជេតពនចប់ ទូលអារាធនាព្រះសាស្តា និងភិក្ខុសង្ឃ ៥០០ រូប ឱ្យទទួលភិក្ខា ក្នុងថ្ងៃស្អែក ព្រះសាស្តាត្រាស់ថា ម្នាលសេដ្ឋី តថាគតទទួលនិមន្តនាងចូឡសុភទ្ទារួចហើយ អនាថបិណ្ឌិកទូលថា មិនឃើញអ្នកណាមកនិមន្តសោះ ទាំងធីតារបស់ខ្ញុំព្រះអង្គក៏នៅឆ្ងាយ ព្រះសាស្តាត្រាស់ថា ត្រូវហើយគហបតី **តែសប្បុរសសូម្បីនៅឆ្ងាយរាប់ពាន់យោជន៍ ក៏រមែងប្រាកដបាន** ទើបអនាថបិណ្ឌិកក្រាបទូល ថា សូមព្រះអង្គទ្រង់សង្គ្រោះធីតារបស់ខ្ញុំព្រះអង្គចុះ ព្រះអង្គ ។

លុះព្រឹកឡើង ព្រះសាស្តាព្រមទាំងភិក្ខុដែលបានអភិញ្ញា ៥០០ រូប

យាងទៅកាន់នគរសាកេត នាងចូឡសុភទ្ទាថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយបង្គំព្រះសាស្តាទូលថា បិតាក្មេករបស់ខ្ញុំព្រះអង្គជាមនុស្សមិច្ឆាទិដ្ឋិ សូមព្រះអង្គប្រោសសម្តែងធម៌ដ៏សមគួរដល់ជនទាំងនោះផងចុះ ព្រះអង្គ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ហើយ **កាឡកសេដ្ឋី** បានសម្រេចសោតាបត្តិផល ទើបថ្វាយឧទ្យានរបស់ខ្លួនចំពោះព្រះទសពល សាងវិហារក្នុងទីនោះ ហើយស្រោចទឹកទក្ខិណោទកថ្វាយដល់សង្ឃ វិហារនោះឈ្មោះថា **កាឡការាម** ។

សុមនាទេវីធីតាពៅ ក្រោយពីបងស្រីទាំងពីរជាព្រះសោតាបន្នហើយ ក៏ទៅកាន់ត្រកូលរបស់ប្តីអស់ ទើបអនាថបិណ្ឌិកតាំងឱ្យនាងជាអ្នកទំនុកបម្រុងព្រះសង្ឃជំនួស កាលស្តាប់ធម៌ហើយ នាងបានសម្រេចសកទាគាមិផលតាំងពីនៅជំទង់ តមកនាងកើតជម្ងឺខ្យល់ដួលចុះ ចង់ជួបឪពុក ។ ខណៈនោះ អនាថ-បិណ្ឌិកកំពុងនៅក្នុងរោងទានមួយកន្លែង កាលដឹងដំណឹងប្រញាប់រួសរាន់ត្រឡប់មក សួរថាកូនយ៉ាងម៉េចហើយ សុមនាទេវីត្រឡប់សួរបិតាថា អ្វីទៅប្អូនប្រុស បិតាស្តាប់ហើយយល់ថា នាងរវើរវាយមិនដឹងខ្លួន ទើបសួរថា នាងរវើរវាយឬ នាងឆ្លើយថា មិនមែនទេប្អូនប្រុស បិតាគិតថានាងខ្លាចស្លាប់ ទើបសួរថា នាងខ្លាចស្លាប់ឬ នាងឆ្លើយថាមិនខ្លាចទេប្អូនប្រុស បន្ទាប់ពីនោះក៏អស់ជីវិតទៅ ។

អនាថបិណ្ឌិកសេដ្ឋី សូម្បីជាព្រះសោតាបន្នបុគ្គល ក៏មិនអាចអត់សង្កត់សេចក្តីសោកបាន លុះរៀបចំសពធីតាស្រេចហើយ ស្រែកយំទៅគាល់ព្រះសាស្តាក្រាបទូលថា សុមនាទេវីធីតារបស់ខ្ញុំព្រះអង្គធ្វើមរណកាលហើយ ក៏នាងជាអ្នក

ដល់ព្រមដោយហិរិឱត្តប្បៈដូច្នេះ ក្នុងវេលាជិតស្លាប់មិនអាចតាំងសតិបាន វវើ-វវាយវៀបរាប់រហូតស្លាប់ ព្រះសាស្ដាសួរថា សេដ្ឋី នាងនិយាយអ្វីខ្លះ អនាថ-បិណ្ឌិកក្រាបទូលថា នាងហៅខ្ញុំព្រះអង្គថា ប្អូនប្រុស ព្រះអង្គ ។

ព្រះសាស្ដាត្រាស់ថា ម្នាលគហបតី នាងមិនបានវវើវវាយទេ តែព្រោះនាងជាសកទាគាមី ខ្ពស់ជាងអ្នកដោយគុណធម៌ ទើបនាងហៅអ្នកថាប្អូនប្រុស អនាថបិណ្ឌិកទូលសួរថា ធីតារបស់ខ្ញុំព្រះអង្គរីករាយក្នុងពពួកញាតិក្នុងលោកនេះ សូម្បីទៅពីលោកនេះហើយ ក៏កើតក្នុងទីរីករាយដូចគ្នាឬ ព្រះអង្គ ?

ព្រះសាស្ដាត្រាស់នឹងអនាថបិណ្ឌិកសេដ្ឋីថា :

**អ្នកមានបុណ្យធ្វើទុកហើយ រមែងរីករាយក្នុងលោកនេះ**
**សូម្បីលះលោកនេះទៅហើយរមែងរីករាយថា យើងបាន**
**ធ្វើបុណ្យទុកហើយ កាលទៅកាន់សុគតិ រមែងរីករាយក្នុង**
**លោកទាំងពីរ ។**

**នាងបុណ្ណា** ជាទាសីរបស់អនាថបិណ្ឌិកសេដ្ឋី សម័យមួយ ព្រះមានព្រះភាគជាម្ចាស់យាងចេញចាកព្រះជេតវនវិហារ ដើម្បីចារិកទៅទីដទៃ ព្រះបាទបសេនទិកោសល និងលោកអនាថបិណ្ឌិកសេដ្ឋី ឬសូម្បីអ្នកណាៗក៏មិនអាចធ្វើឱ្យព្រះមានព្រះភាគយាងត្រឡប់បានឡើយ គ្រប់គ្នាគិតថាយើងមិនបានស្ដាប់ធម៌ និងថ្វាយទានអស់វេលាច្រើនខែជាពិតប្រាកដ ។

នាងបុណ្ណាទាសីពោលថា បពិត្រសេដ្ឋី នាងខ្ញុំនឹងនាំព្រះសាស្ដាត្រឡប់មក

សេដ្ឋីពោលថា បើនាងអាចនាំព្រះសាស្ដាត្រឡប់មកបាន យើងនឹងឱ្យនាងផុតចាកភាពជាទាសី ទើបនាងបុណ្ណាចូលទៅគាល់ព្រះសាស្ដា ក្រាបចុះទៀបព្រះបាទទូលថា សូមព្រះអង្គប្រោសយាងត្រឡប់ចុះ ព្រះអង្គ ។ ព្រះសាស្ដាត្រាស់ថា នាងនឹងធ្វើអ្វីឱ្យតថាគត នាងបុណ្ណាទូលថា ខ្ញុំម្ចាស់អាស្រ័យគេចិញ្ចឹមជីវិត មិនមានសូម្បីតែទេយ្យធម៌នឹងថ្វាយឡើយ តែបើព្រះអង្គយាងត្រឡប់ ខ្ញុំម្ចាស់នឹងតាំងនៅក្នុងសរណៈ ៣ និងសីល ៥ ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ឱ្យសាធុការថា **សាធុ បុណ្ណា** ហើយយាងត្រឡប់មកវត្តជេតវនវិញ ដោយព្រះអង្គមានសេចក្ដីគោរពក្នុងធម៌ ។

អនាថបិណ្ឌិកសេដ្ឋីសប្បាយចិត្តខ្លាំងណាស់ ទើបព្រមឱ្យនាងជាអ្នកជាហើយតាំងនាងទុកក្នុងឋានៈជាធីតា នាងសូមអនុញ្ញាតបួស កាលបួសហើយចម្រើនវិបស្សនា ព្រះអង្គទ្រង់ជ្រាបទើបផ្សាយឱភាសទៅ ហើយត្រាស់ព្រះគាថាថា **ម្នាលនាងបុណ្ណា នាងចូរបំពេញព្រះសទ្ធម្មឱ្យពេញ ដូចព្រះច័ន្ទក្នុងថ្ងៃពេញបូរមី នឹងធ្វើទីបំផុតទុក្ខដោយបញ្ញា ដែលបរិបូណ៌បាន ។** ចប់ព្រះគាថា នាងក៏សម្រេចជាព្រះអរហន្ត បានជាសាវិកាដែលមានឈ្មោះល្បីមួយរូបក្នុងព្រះពុទ្ធសាសនា ។

ថេរីគាថាពោលថា នាងបុណ្ណាកាន់យកកំណើតជាទាសី ក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី បានស្ដាប់ព្រះធម្មទេសនាឈ្មោះ **សីហនាទសូត្រ** បានសម្រេចសោតាបត្តិផល ណែនាំសោត្ថិយព្រាហ្មណ៍ថា **បុគ្គលនឹងស្អាតដោយទឹក**

**ក៏ទេ សច្ចៈ និងធម្មៈមានក្នុងអ្នកណា អ្នកនោះឈ្មោះថា ជាអ្នកស្អាត ។**

**សោត្ថិយព្រាហ្មណ៍** ស្តាប់ហើយមានសទ្ធា សូមបួសក្នុងសំណាក់ព្រះមានព្រះភាគ បានសម្រេចជាព្រះអរហន្តក្នុងទីបំផុត អនាថបិណ្ឌិកសេដ្ឋីសរសើរនាង ហើយដោះលែងនាងឱ្យជាអ្នកជា អនុញ្ញាតឱ្យនាងបួស មិនយូរប៉ុន្មានបុណ្ណាភិក្ខុនី ក៏បានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។

អនាថបិណ្ឌិកសេដ្ឋីនោះ កាលព្រះសាស្ដាគង់នៅវត្តជេតពន មើលថែទំនុកបម្រុងព្រះសាស្ដា សង្ឃសាវ័កទាំងអស់ គឺក្នុងវេលាព្រឹកនាំភត្តាហារទៅថ្វាយ ក្នុងវេលាល្ងាចក៏នាំភេសជ្ជៈទាំងឡាយ មានទឹកដោះថ្លា ទឹកដោះខាប់ជាដើម ព្រមទាំងគ្រឿងសក្ការៈផ្សេងៗទៅកាន់វិហារ អនាថបិណ្ឌិកសេដ្ឋីថ្វាយទាន រក្សាសីលយ៉ាងនេះរាល់ថ្ងៃជានិច្ច ។

កាលតមក សេដ្ឋីធ្លាក់ខ្លួនក្រ ព្រោះសម្បត្តិរបស់ត្រកូលដែលកប់ទុកក្បែរច្រាំងស្ទឹង កាលច្រាំងបាក់ចុះក៏លិចទៅក្នុងផ្ទៃទឹក ថែមទាំងត្រូវឈ្មួញជាមិត្របោកទៀត ធ្វើឱ្យសម្បត្តិសាបសូន្យជាច្រើន ក្នុងទីបំផុតទ្រព្យក៏មានការអស់ទៅដោយលំដាប់ តែទោះបីដូច្នោះ អនាថបិណ្ឌិកក៏នៅតែមិនឈប់ឱ្យទាន ទេវតាដែលឋិតនៅក្នុងក្លោងទ្វារផ្ទះអត់ទ្រាំមិនបាន ចេញមកអង្វរឱ្យសេដ្ឋីឈប់បរិច្ចាគទាន សួរថា លោកត្រូវការអ្វីពីព្រះសមណគោតម សេដ្ឋីខឹងក្រោធដេញឱ្យទេវតាទៅនៅទីដទៃ ទេវតាបានទៅអង្វរស្ដេចសក្កទេវរាជឱ្យជួយ សក្កទេវរាជណែនាំឱ្យទេវតានោះ ទៅយកប្រាក់ដែលមិត្តភក្តិបោកយកទៅ រួមទាំងដែលលិច

នៅក្រោមផ្ទៃទឹកត្រឡប់មកវិញ សេដ្ឋីទើបអត់ទោសឱ្យ ។

ទេវតាបានធ្វើឱ្យពួកឈ្មួញទាំងនោះ ប្រគល់ទ្រព្យដល់លោកសេដ្ឋីវិញ និងទ្រព្យដែលលិចចុះក្នុងផ្ទៃទឹក ទាំងទ្រព្យដទៃដែលមិនមានម្ចាស់ថែមទៀត មកឱ្យវិញដោយអានុភាពរបស់ខ្លួននាំមកដាក់ក្នុងឃ្លាំងដែលទំនេរ ហើយមកសូមខមាទោសចំពោះសេដ្ឋី អនាថបិណ្ឌិកសេដ្ឋីនាំទេវតានោះ ទៅកាន់សំណាក់របស់ព្រះសាស្ដា ក្រាបទូលអំពើរបស់ទេវតាទាំងអស់ ដល់ព្រះមានព្រះភាគជាម្ចាស់។ ព្រះអង្គទ្រង់ឱ្យឱវាទសេដ្ឋី និងទេវតានោះថា ម្នាលគហបតី **បុគ្គលអ្នកធ្វើបាបក្នុងលោកនេះ រមែងឃើញថាបាបល្អ ដរាបណាដែលបាបនៅមិនទាន់ឱ្យផល តែកាលណាបាបរបស់គេឱ្យផល កាលនោះគេរមែងឃើញបាបថាអាក្រក់ពិត១** ក្នុងកាលចប់ទេសនា ទេវតានោះតាំងនៅក្នុងសោតាបត្តិផល ។

ប្រក្រតីក្នុងវេលាចូលគាល់ព្រះមានព្រះភាគ អនាថបិណ្ឌិកមិនធ្លាប់ទូលសួរបញ្ហាអ្វី១ ឡើយ ដោយសេចក្ដីគោរពស្រឡាញ់ក្នុងព្រះសាស្ដាយ៉ាងក្រៃលែងក្រែងព្រះអង្គទ្រង់នឿយហត់ព្រះកាយ ព្រះអង្គទ្រង់ព្រះតម្រិះថា **សេដ្ឋីនេះរក្សាតថាគតក្នុងទីមិនគួររក្សា** តែទោះបីដូច្នោះ ព្រះមានព្រះភាគក៏ត្រាស់ព្រះធម្មទេសនាមួយក័ណ្ឌជានិច្ច ជាចំណែកច្រើនព្រះអង្គត្រាស់ពីទានកថាដល់ឧបាសកថា **ទាននេះជាផ្លូវដើររបស់ព្រះពោធិសត្វ ជាផ្លូវដើររបស់តថាគត តថាគតបានឱ្យទានមកអស់កាល ៤ អសង្ខេយ្យ ក្រៃលែងដោយសែនមហាកប្ប អ្នកក៏ឈ្មោះថា បានដើរតាមផ្លូវដែលតថាគតមកហើយដោយពិត**

ដូច្នេះជាដើម ។

តមក អនាថបិណ្ឌិកគហបតីឈឺធ្ងន់ បានបញ្ជូនមនុស្សទៅក្រាបទូលព្រះសាស្ដា និងអារាធនាព្រះសារីបុត្តមកសម្ដែងធមិប្រោស ទើបព្រះសារីបុត្តទៅកាន់និវេសន៍របស់គហបតី ព្រមដោយព្រះអានន្ទ សួរថា ម្នាលគហបតី អ្នកល្មមអត់ធន់បានឬទេ ល្មមប្រព្រឹត្តទៅបានទេ ទុក្ខវេទនាមិនចម្រើនឡើងឬទេ ? អនាថបិណ្ឌិកសេដ្ឋីទូលថា បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំមានការចម្រើនឡើង មិនធូរស្រាលឡើយ ។

ព្រះសារីបុត្តសម្ដែង **អនាថបិណ្ឌិកោវាទសូត្រ** សេចក្ដីថា ម្នាលគហបតី អ្នកគប្បីសិក្សាយ៉ាងនេះថា យើងនឹងមិនប្រកាន់មាំអាយតនៈខាងក្នុងគឺ **ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ មនោ និងវិញ្ញាណ** ដែលអាស្រ័យអាយតនៈទាំងនោះ ។

នឹងមិនប្រកាន់មាំអាយតនៈខាងក្រៅ គឺ **រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ និងវិញ្ញាណ** ដែលអាស្រ័យអាយតនៈទាំងនោះ ជាដើម

ចប់ **អនាថបិណ្ឌិកោវាទសូត្រ** អនាថបិណ្ឌិកសេដ្ឋីស្រែកយំ ព្រះសារីបុត្រសួរថា អ្នកស្រែកយំព្រោះខ្លាចស្លាប់ឬ អនាថបិណ្ឌិកពោលថា មិនខ្លាចស្លាប់ទេ តែស្រែកយំព្រោះស្ដាយមិនធ្លាប់បានស្ដាប់ធមិជ្រាលជ្រៅ ដោយពាក្យពេចន៍ដែលយល់ងាយដូច្នេះឡើយ បន្ទាប់ពីនោះ ប្រគេនចង្ហាន់ដល់ព្រះសារីបុត្រ និងព្រះ

អានន្ទ ដោយរំលែកអំពីភាជនៈរបស់ខ្លួន តមកមិនយូរប៉ុន្មានក៏ធ្វើមរណកាលទៅកើតក្នុងស្ថានសួគ៌ជាន់តុសិត ។

ក្នុងយប់នោះ **អនាថបិណ្ឌិកទេវបុត្ត** ចុះមកគាល់ព្រះសាស្ដានៅវត្តជេតពន បានក្រាបទូលព្រះមានព្រះភាគជាម្ចាស់ថា ៖

**វត្តជេតពននេះមានប្រយោជន៍ ជាទីគង់នៅរបស់ព្រះធម្មរាជា និងពួកសង្ឃស្វែងរកបុណ្យ ជាទីកើតបីតិដល់ខ្ញុំព្រះអង្គយ៉ាងក្រៃលែង ។**

រួចបានពោលសរសើរព្រះសារីបុត្រថា ៖

**ព្រះសារីបុត្រជាអ្នកបរិសុទ្ធដោយបញ្ញា សីល និងសេចក្ដីស្ងប់ ភិក្ខុណាសូម្បីសម្រេចដល់ច្រាំងហើយ ក៏មិនមាននរណាក្រៃលែងជាងព្រះថេរៈ**

តមក ខណៈដែលគង់នៅក្នុងវត្តជេតពន ព្រះសាស្ដាទ្រង់សរសើរអនាថបិណ្ឌិកសេដ្ឋីថា **ជាកំពូលជាងឧបាសកទាំងឡាយផ្នែកអ្នកឱ្យទាន ។**

# វិសាខា មហាឧបាសិកា

## ជាកំពូលជាងឧបាសិកាទាំងពួងខាងឱ្យទាន

(៤) **វិសាខា** ជាធីតារបស់ធនញ្ជ័យសេដ្ឋី និងនាងសុមនាទេវី នៃភទ្ទិយនគរ ដែនអង្គៈ ដែលជាប់នឹងដែនមគធៈរបស់ព្រះបាទពិម្ពិសារ តា និងយាយរបស់នាងវិសាខា គឺមេណ្ឌកសេដ្ឋី និងនាងចន្ទបទុមា ។

វស្សាទី ៥ ក្រោយអំពីព្រះសាស្តាត្រាស់ដឹង ព្រះអង្គឃើញឧបនិស្ស័យសោតាបត្តិផលរបស់ក្រុមគ្រួសារមេណ្ឌកសេដ្ឋី ទើបយាងចារិកទៅកាន់ភទ្ទិយនគរ ។ មេណ្ឌកសេដ្ឋីដឹងដំណឹងថា ព្រះសាស្តាយាងមកកាន់ផ្ទះរបស់ខ្លួន ទើបឱ្យក្មេងស្រីវិសាខាដែលពេលនោះមានអាយុត្រឹម ៧ ខួប ព្រមទាំងក្មេងស្រីជាបរិវារចេញទៅទទួលព្រះអង្គដល់ទីប្រថាប់ កាលទៅដល់វិសាខាក្រាបថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏សមគួរ ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោស ដោយអំណាចនៃកុសលដែលបានបំពេញមក កុមារីវិសាខាបានសម្រេចសោតាបត្តិផល ព្រមទាំងក្មេងស្រីជាបរិវារក្នុងទីនោះឯង ។

**មេណ្ឌកសេដ្ឋី** ត្រៀមចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ តាមចន្លោះផ្លូវពួកតិរ្ថិយ៍មកហាម តែសេដ្ឋីក៏មិនបានជឿពាក្យពេចន៍ពួកតិរ្ថិយ៍ទាំងនោះ កាលទៅដល់ព្រះសាស្តាត្រាស់សម្តែងអនុបុព្វីកថា និងអរិយសច្ច ៤ ដល់សេដ្ឋីនោះ មេណ្ឌកសេដ្ឋីបានសម្រេចសោតាបត្តិផល ហើយក្រាបទូលសេចក្តីដែលតិរ្ថិយ៍ពោលទោសហើយហាមខ្លួន ឱ្យព្រះសាស្តាទ្រង់ជ្រាប ។ គ្រានោះព្រះសាស្តា

ត្រាស់នឹងសេដ្ឋីថា ម្នាលគហបតី ឈ្មោះថា សត្វទាំងឡាយរមែងមិនឃើញទោស របស់ខ្លួនសូម្បីមានច្រើន រមែងប្រកាសទោសរបស់ជនដទៃ សូម្បីមិនមានធ្វើឱ្យមាន ប្រៀបដូចបុគ្គលបាចអង្កាមចុះក្នុងទីនោះ ហើយត្រាស់ព្រះគាថាថា :

**ទោសរបស់បុគ្គលដទៃឃើញបានងាយ ទោសរបស់ខ្លួនឯងឃើញបានកម្រ បុគ្គលរមែងពោលទោសរបស់អ្នកដទៃ ដូចបាចអង្កាម តែបិទបាំងទោសរបស់ខ្លួន ដូចព្រានលាក់ខ្លួនដូច្នោះ ។**

ចប់ព្រះគាថា ជនទាំងឡាយសម្រេចអរិយផលជាច្រើន មេណ្ឌកសេដ្ឋីអារាធនាព្រះសាស្តា និងភិក្ខុសង្ឃដើម្បីថ្វាយភត្តាហារក្នុងថ្ងៃស្អែក ។

ក្នុងវេលាព្រឹកឡើង ព្រះមានព្រះភាគព្រមដោយសង្ឃសាវ័ក យាងមកកាន់ផ្ទះរបស់មេណ្ឌកសេដ្ឋី សម្រេចភត្តាហារហើយ ព្រះអង្គទ្រង់អនុមោទនា ហើយទ្រង់សម្តែងធម៌ប្រោស នាងចន្ទបទុមា នាងសុមនាទេវី និងនាយបុណ្ណៈ ឱ្យបានសម្រេចសោតាបត្តិផល សេដ្ឋីក្រាបទូលអារាធនាដើម្បីថ្វាយមហាទានដោយទំនងនេះអស់កន្លះខែទៀត ព្រះសាស្តាទ្រង់គង់ក្នុងភទ្ទិយនគរតាមពុទ្ធអធ្យាស្រ័យ ហើយយាងចារិកតទៅ ។

គ្រានោះ ព្រះបាទបសេនទិកោសលជាស្តេចនៃដែនកោសលត្រិះរិះថា ដែនកោសលសូម្បីជាដែនធំ តែក៏មានត្រកូលគហបតីត្រឹមតែពីរ គឺអនាថបិណ្ឌិក និងមិគារសេដ្ឋីប៉ុណ្ណោះ ខុសពីដែនមគធៈដែលមានគហបតីច្រើនត្រកូល ជាហេតុសម្តែងដល់ការរុងរឿងចម្រើនរបស់នគរ ទើបទ្រង់យាងទៅរកព្រះបាទពិម្ពិសារ

ជាស្តេចនៃដែនមគធៈ ដែលជាទីស្និទ្ធស្នាលនឹងព្រះអង្គ នៅឯក្រុងរាជគ្រឹះ ត្រាស់សូមគហបតីឱ្យទៅតាំងលំនៅឋាន ក្នុងដែនកោសលបន្ថែមមួយត្រកូលទៀត ។ **ព្រះបាទពិម្ពិសារ** ទ្រង់ប្រឹក្សាជាមួយពួកអាមាត្យ ក៏ព្រមព្រៀងគ្នាថា ធនញ្ជ័យសេដ្ឋីជាអ្នកសមគួរ ទើបមានព្រះតម្រាស់ឱ្យសេដ្ឋីចូលគាល់ និងប្រាប់សេចក្តីបំណងរបស់ព្រះបាទបសេនទិកោសលឱ្យដឹង សេដ្ឋីយល់ព្រមតាមព្រះបំណង ទូលសូមពេលដើម្បីត្រឡប់ទៅចាត់ចែងការងារឱ្យសព្វគ្រប់ សម្រាប់ការធ្វើដំណើរ។

កាលដល់ពេលកំណត់ ព្រះបាទបសេនទិកោសលយាងទៅទទួលធនញ្ជ័យសេដ្ឋី នៅឯភទ្ទិយនគរដោយព្រះអង្គឯង ពេលធ្វើដំណើរមកដល់កន្លែងដ៏សម្បូរបែបមួយ ព្រះបាទបសេនទិកោសលបញ្ជាឱ្យឈប់សម្រាក ធនញ្ជ័នសេដ្ឋីបានទូលសួរថា ទីនេះក្នុងអាណាខេត្តរបស់ព្រះរាជាអង្គណា ព្រះរាជាត្រាស់ឆ្លើយថា ជាដែនរបស់យើងហ្នឹងឯង សេដ្ឋីទូលថា បើដូច្នោះទ្រង់ប្រោសអនុញ្ញាតឱ្យខ្ញុំព្រះអង្គ តាំងលំនៅឋានក្នុងទីនេះចុះ ព្រោះបរិវាររបស់ខ្ញុំព្រះអង្គមានច្រើន ខ្លាចក្រែងធ្វើ សេចក្តីក្តៅក្រហាយដល់អ្នកដទៃ បើឱ្យតាំងលំនៅក្នុងក្រុងសាវត្ថី ព្រះរាជាទ្រង់យល់ព្រម ត្រាស់បញ្ជាឱ្យកសាងនគរឡើងក្នុងទីនោះ ព្រះរាជទាននាមថា **នគរសាកេត** ទ្រង់ប្រគល់ឱ្យជាលំនៅឋានរបស់ធនញ្ជ័យសេដ្ឋី និងបរិវារ ។

តមក **បុញ្ញវឌ្ឍនៈ** បុត្តរបស់មិគារសេដ្ឋីនៃក្រុងសាវត្ថី ចម្រើនវ័យដល់កាលដែលនឹងគ្រប់គ្រងផ្ទះ អត់ធន់នឹងការបង្ខិតបង្ខំរបស់មាតាបិតាទាក់ទងការគ្រប់គ្រងផ្ទះមិនបាន ទើបពោលថា បើកាលណាជួបស្ត្រីដែលល្អ និងមានគុណ

សម្បត្តិសមជាស្ត្រីមេផ្ទះ ខ្លួននឹងធ្វើតាមសំណូមពរ ។

**មិគារសេដ្ឋីជាបិតា** អញ្ជើញពួកព្រាហ្មណ៍ដែលចេះដឹងមកផ្ទះរបស់ខ្លួន ប្រាប់សេចក្តីប្រាថ្នារបស់បុត្រឱ្យពួកព្រាហ្មណ៍ជ្រាប ហើយប្រគល់មាល័យមាសឱ្យ ពោលថា បើពួកអ្នកជួបស្ត្រីមានលម្អ និងមានគុណសម្បត្តិតាមបំណងរបស់បុត្រយើង ចូរប្រគល់មាល័យមាសនេះដល់នាង ហើយចូរនាំមក ។ ពួកព្រាហ្មណ៍ចេញធ្វើដំណើរទៅរហូតដល់នគរសាកេត ចូលទៅអង្គុយនៅក្នុងសាលាមួយ ក្នុងកាលនោះ នគរសាកេតកំពុងមានបុណ្យនក្ខត្តឫក្សប្រចាំឆ្នាំ (ខ្មែរថាបុណ្យចូលឆ្នាំថ្មី) វិសាខាដែលពេលនោះនាងចម្រើនវ័យហើយ ព្រមដោយស្រីបរិវារ នាំគ្នាដើរមើលបុណ្យ គាប់ជួនភ្លៀងធ្លាក់ គ្រប់គ្នាប្រញាប់រត់ទៅរកទីជ្រកភ្លៀង មានតែវិសាខាម្នាក់នៅដើរជាធម្មតា មិនបានរត់ដូចអ្នកដទៃ លុះដល់សាលាសំណាក់ពួកព្រាហ្មណ៍សួរថា ព្រោះហេតុអ្វី ទើបនាងមិនរត់ជ្រកភ្លៀងដូចអ្នកដទៃ ?

វិសាខាឆ្លើយថា អ្នកទាំងឡាយ ជន ៤ ពួកកាលរត់រមែងមិនល្អ គឺ **ព្រះរាជា** បានអភិសេកហើយ កាលរត់ទៅក្នុងផ្ទៃព្រះលានរមែងមិនល្អ **ដំរីមង្គល** របស់ព្រះរាជារត់ក៏មិនល្អ **បព្វជិត** កាលរត់ក៏មិនល្អ ស្ត្រីកាលរត់ក៏មិនល្អ ក្រៅពីនោះហេតុដទៃនៅមានទៀត ក្នុងកាលដែលខ្ញុំរត់បើរអិលដួលលើផែនដី ដៃឬជើងក៏អាចបាក់ ខ្ញុំក៏នឹងជាភារៈធ្ងន់ដល់ត្រកូល ចំណែកគ្រឿងតែងខ្លួន កាលទទឹកហើយក៏នឹងស្អុត នាងខ្ញុំគិតយ៉ាងនេះទើបមិនរត់ទៅ ។

ពួកព្រាហ្មណ៍ បានស្តាប់បដិភាណវោហាររបស់នាង ថែមទាំងឃើញ

លក្ខណៈស្ត្រីល្អព្រមទៀត ទើបទុកចិត្តថា ស្ត្រីនេះសមតាមសេចក្ដីប្រាថ្នារបស់បុណ្ណវឌ្ឍនៈ ហើយប្រគល់មាល័យមាសឱ្យ. វិសាខាសង្ស័យ ទើបពួកព្រាហ្មណ៍ប្រាប់សេចក្ដីបំណង និងការមករបស់ត្រកូលមិគារសេដ្ឋីឱ្យនាងដឹងទាំងអស់ ។ នាងវិសាខានាំព្រាហ្មណ៍ត្រឡប់មកកាន់ផ្ទះ ហើយប្រាប់ឱ្យបិតាជ្រាប ធនញ្ជ័យសេដ្ឋីសាកសួរពួកព្រាហ្មណ៍ដឹងសេចក្ដីអស់ហើយ ពិចារណាឃើញថា ត្រកូលប្រហាក់ប្រហែលគ្នាទើបព្រមទទួល អញ្ជើញឱ្យព្រាហ្មណ៍ស្នាក់នៅក្នុងផ្ទះ តាមសមគួរ ហើយបញ្ជូនឱ្យត្រឡប់ទៅវិញ ។

កាលពួកព្រាហណ៍ត្រឡប់ដល់ក្រុងសាវត្ថី ក៏ប្រាប់សេចក្ដីនោះដល់មិគារសេដ្ឋី សេដ្ឋីគិតថា ត្រកូលរបស់វិសាខាជាត្រកូលធំ គួរប្រញាប់ទៅទទួល ទើបក្រាបទូលព្រះបាទបសេនទិកោសលឱ្យទ្រង់ជ្រាប ព្រះរាជាត្រាស់ថា សូម្បីយើងក៏នឹងទៅផង ព្រោះត្រកូលនេះយើងជាអ្នកនាំមកកាន់អាណាខេត្តរបស់យើង ។ មិគារសេដ្ឋី បញ្ជូនដំណឹងឱ្យធនញ្ជ័យសេដ្ឋីជ្រាបថា កាលខ្ញុំមកសូម្បីព្រះរាជាក៏ស្ដេចយាងមកដែរ ទើបធនញ្ជ័យសេដ្ឋីត្រៀមទទួលព្រះរាជា ឱ្យសមតាមព្រះកិត្តិគុណ ។

ក្រោយអំពីបញ្ជូនព្រាហ្មណ៍ឱ្យត្រឡប់ ធនញ្ជ័យសេដ្ឋីហៅជាងមាសមកឱ្យធ្វើគ្រឿងប្រដាប់ឈ្មោះ **មហាលតាបសាធន៍** ដើម្បីជាចំណងដៃដល់ធីតាដែលនឹងចេញទៅមានប្ដី គ្រឿងប្រដាប់នេះមានតម្លៃ ៩ កោដិ ប្រើពេលធ្វើ ៤ ខែទើបរួចស្រេច លោកសេដ្ឋីឱ្យតម្លៃឈ្នួល មួយសែនកហាបណៈដល់ជាង ក្រៅ

ពីនោះ បានចាត់ចែងត្រៀមគ្រឿងឧបភោគបរិភោគទាំងពួង ដែលត្រូវប្រើប្រាស់ឱ្យបានសព្វគ្រប់ ដោយគិតថា ធីតារបស់យើងនឹងមិនត្រូវរំខានអ្នកណាក្នុងទីនោះ លុះដល់ថ្ងៃកំណត់ ព្រះបាទបសេនទិកោសលយាងទៅកាន់នគរសាកេត ព្រមដោយមិគារសេដ្ឋី និងពួករាជបរិវារទាំងពួង ដើម្បីទទួលនាងមកកាន់ត្រកូលរបស់ខ្លួន នៅឯក្រុងសាវត្ថី ។

មុននឹងទៅកាន់ត្រកូលស្វាមី ធនញ្ជ័យសេដ្ឋីបានឱ្យឱវាទ ១០ យ៉ាងដល់ធីតា ដោយជាគោលការណ៍សម្រាប់គ្រប់គ្រងផ្ទះថា កូនអើយ ធម្មតាស្ត្រីនៅក្នុងត្រកូលរបស់ស្វាមី **មិនគប្បីនាំភ្លើងក្នុងចេញក្រៅ មិនគប្បីនាំភ្លើងក្រៅចូលក្នុង គប្បីឱ្យដល់អ្នកដែលគួរឱ្យ មិនគប្បីឱ្យដល់អ្នកដែលមិនគួរឱ្យ គប្បីឱ្យដល់អ្នកគួរឱ្យ និងមិនគួរឱ្យ គប្បីអង្គុយជាសុខ គប្បីដេកជាសុខ គប្បីបរិភោគជាសុខ គប្បីមើលថែមិនឱ្យភ្លើងឆេះផ្ទះ គប្បីនមស្ការទេវតាក្នុងផ្ទះ** ហើយចាត់ឱ្យកុដុម្ពិក៍ ៨ នាក់ ជាអ្នកមើលការខុសត្រូវនាង ។

ស្អែកឡើង ធនញ្ជ័យសេដ្ឋីតាក់តែងធីតាដោយគ្រឿងអលង្ការ ធ្វើសក្ការៈព្រះរាជាព្រះបាទបសេនទិកោសល និងមិគារសេដ្ឋី ហើយជូនធីតាទៅ, ប្រកាសដល់អ្នកនគរសាកេតថា អ្នកណាចង់ទៅជាមួយធីតាយើង ក៏ចូរទៅចុះ មានពួកជនជាប់តាមនាងទៅជាច្រើន រហូតមិគារសេដ្ឋីហាមថា ល្មមហើយសម្រាប់អ្នកទៅតាម ។ ក្នុងថ្ងៃដែលនាងមកដល់ក្រុងសាវត្ថី អ្នកនគរបានបញ្ជូនបណ្ណាការមកទទួល នាងបានពោលពាក្យពេចន៍ជាទីស្រឡាញ់ដល់អ្នករាល់គ្នា ហើយបញ្ជូន

បណ្ណាការនោះទៅចែកចាយក្នុងត្រកូលដទៃៗ ធ្វើអ្នកនគរទាំងអស់ឱ្យដូចជាញាតិដូច្នោះ ។

ក្នុងថ្ងៃពិធីអាវាហមង្គល មិគារសេដ្ឋីមិនបាននឹកនាដល់ព្រះសាស្តាទេ ដែលពេលនោះកំពុងគង់នៅវត្តជេតពនថ្មី ៗ ព្រោះខ្លួនឯងមានសទ្ធាចំពោះពួកនិគ្រន្ថថាជាព្រះអរហន្ត ទើបអញ្ជើញពួកនិគ្រន្ថមកចូលរួមពិធីមង្គល និងឱ្យវិសាខាចូលទៅគោរព វិសាខាគិតថា អ្នកដែលប្រាសចាកសេចក្តីខ្មាស់អៀនដូច្នេះជាព្រះអរហន្តបានដូចម្តេចទៅ ទើបមិនព្រមធ្វើសេចក្តីគោរព ពួកនិគ្រន្ថឃើញអាការរបស់នាងក៏ខឹងក្រោធ ពោលនឹងមិគារសេដ្ឋីថា ស្រីនេះជា កាឡកិណី ចូរបណ្តេញនាងចេញទៅ មុនពេលដែលនាងនាំសេចក្តីក្តៅក្រហាយមកកាន់ត្រកូល មិគារសេដ្ឋីមិនបានពោលពាក្យយ៉ាងណាមួយឡើយ ។

ព្រឹកថ្ងៃមួយ ព្រះថេរៈមួយរូបចេញបិណ្ឌបាត មកឈប់ឈរមុខផ្ទះ មិគារសេដ្ឋីកំពុងបរិភោគអាហារ ក្លែងធ្វើជាមិនឃើញ ទើបនាងពោលជាមួយព្រះថេរៈថា និមន្តលោកម្ចាស់ទៅខាងមុខចុះទាន ពេលនេះឪពុកក្មេកនាងខ្ញុំកំពុងបរិភោគអាហារចាស់ សេដ្ឋីបានឮដូច្នោះ ក៏ខឹងក្រោធ បញ្ជាឱ្យបរិវារដេញនាងចេញពីផ្ទះបរិវារទាំងនោះសុទ្ធតែជាមនុស្សរបស់នាង ទើបមិនមានអ្នកណាធ្វើតាម ។

នាងពោលថា លោកឪពុកបណ្តេញនាងខ្ញុំដោយយល់ដូច្នោះមិនបានទេ នាងខ្ញុំជាកូនមានឪពុកម្តាយ មុននឹងមកកាន់ផ្ទះនេះ លោកបានផ្តាំផ្ញើរនាងខ្ញុំនឹងកុដុម្ពិក៍ ៨ នាក់ថា បើមានទោសកើតឡើងដល់នាងខ្ញុំ ក៏សូមឱ្យអ្នកទាំង ៨ នាក់

នោះជាអ្នកជម្រះក្តីសិន បើខុសពិតនាងខ្ញុំនឹងព្រមចេញអំពីផ្ទះនេះទៅ ទើបមិគារសេដ្ឋី ឱ្យបរិវារទៅអញ្ជើញកុដុម្ពីក៏ទាំងនោះមកពិចារណាកំហុស ទាំង ៨ នាក់ សូមឱ្យសេដ្ឋីនិយាយឱ្យស្តាប់ ហើយសួរនាងថា នាងនិយាយដូច្នោះបំណងដូចម្តេច នាងឆ្លើយថា សម្តៅដល់បិតាក្មេករបស់នាងខ្ញុំមិនសន្សំបុណ្យក្នុងជាតិនេះឡើយ មានតែបរិភោគបុណ្យចាស់ប៉ុណ្ណោះ ក្រៅពីនោះ នាងបានកាត់សេចក្តីសង្ស័យក្នុងចិត្តរបស់សេដ្ឋី ដែលយល់ខុសចំពោះនាងគ្រប់យ៉ាងរហូតច្បាស់លាស់ នាងបានផុតទោសគ្រប់ប្រការពីការចោទប្រកាន់ ។

មិគារសេដ្ឋីសូមទោសនាង ព្រោះសេចក្តីល្ងង់ខ្លៅរបស់ខ្លួន នាងពោលថា ទោសរបស់លោកឪពុកនាងខ្ញុំអត់ឱនឱ្យបាន តែនាងខ្ញុំកើតក្នុងត្រកូលរបស់អ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា នាងខ្ញុំបើវៀរចាកភិក្ខុសង្ឃហើយរស់នៅមិនបាន បើបានទំនុកបម្រុងភិក្ខុសង្ឃតាមគាប់ចិត្ត ទើបនាងខ្ញុំនៅក្នុងផ្ទះនេះតទៅទៀត សេដ្ឋីពោលថា នាងចូរធ្វើទានដល់សមណៈរបស់នាងតាមគាប់ចិត្តចុះ ។ ទើបនាងវិសាខាឱ្យមនុស្សទៅទូលនិមន្តព្រះសាស្តា ទទួលភត្តាហារនៅផ្ទះរបស់នាងក្នុងថ្ងៃស្អែក ពួកនិគ្រន្ថដឹងដំណឹងទើបនាំគ្នាទៅឡោមព័ទ្ធផ្ទះ វិសាខារៀបចំគ្រឿងបូជាទាំងពួងហើយ អញ្ជើញមិគារសេដ្ឋីឱ្យអង្គាសព្រះសាស្តា ពួកនិគ្រន្ថហាមឃាត់ ក្រោយភត្តកិច្ច នាងឱ្យមនុស្សមកអញ្ជើញសេដ្ឋីទៅស្តាប់ធម៌ទេសនាទៀត ពួកនិគ្រន្ថពោលថា ពេលនេះលោកសមគួរទៅ តែឱ្យអង្គុយនៅខាងក្នុងវាំងនន ដែលពួកយើងបាំងទុក ។

ព្រះសាស្តាទ្រង់ជ្រាប ត្រិះរិះថា តថាគតរមែងធ្វើឱ្យមនុស្សគ្រប់គ្នាបាន ឮសំឡេងរបស់តថាគតបាន មិនថានៅក្នុងទីណា ខណៈដែលសម្តែងព្រះធម៌-ទេសនា ទើបជនក្នុងទីនោះមានការដឹងថា ទ្រង់សម្តែងធម៌ប្រោសចំពោះខ្លួនប៉ុណ្ណោះ ។ កាលចប់ព្រះធម្មទេសនា មិគារសេដ្ឋីបានសម្រេចសោតាបត្តិផល ទើបលើកជាយវាំងននឡើង ថ្វាយបង្គំព្រះសាស្តា ហើយក្រាបទូលថា ខ្ញុំព្រះអង្គមិនធ្លាប់ដឹងឡើយថា ទានដែលបុគ្គលធ្វើក្នុងព្រះពុទ្ធសាសនានេះ មានអានិសង្សច្រើនយ៉ាងនេះ ឥឡូវនេះ ខ្ញុំព្រះអង្គបានដឹងក៏ព្រោះការដឹកនាំរបស់កូនប្រសារៗស្រីនេះមកដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខរបស់ខ្ញុំព្រះអង្គដោយពិត ។

មិគារសេដ្ឋីពោលនឹងនាងចំពោះព្រះភក្ត្រព្រះសាស្តាថា វិសាខានាងចូរជាមាតារបស់យើងតាំងពីឥឡូវនេះតទៅ ទើបនាងបាននាមថា **វិសាខាមិគារមាតា** តាំងពីនោះមក។ បន្ទាប់ពីនោះ រៀងរាល់ថ្ងៃក្នុងវេលាព្រឹក ផ្ទះរបស់នាងក៏រុងរឿងដោយសំពត់ពណិកាសាវៈ ពេញទៅដោយអ្នកស្វែងរកបុណ្យ ខាងក្នុងផ្ទះត្រៀមទេយ្យទានទុកសព្វគ្រប់ ក្រោយភត្តកាល ក៏នាំភេសជ្ជៈ និងទឹកអដ្ឋបានទៅថ្វាយដល់សង្ឃ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ហើយទើបត្រឡប់មកកាន់ផ្ទះ ដូច្នេះជាកិច្ចវត្ត ។

ក្នុងថ្ងៃមួយចុងព្រះវស្សា នាងវិសាខាក្រាបទូលអារាធនាព្រះអង្គ ព្រមទាំងភិក្ខុសង្ឃ ទៅទទួលភត្តាហារនៅផ្ទះរបស់នាងក្នុងថ្ងៃស្អែក ពេលរាត្រីជិតភ្លឺភ្លៀងធ្លាក់ខ្លាំងព្រះសាស្តាត្រាស់នឹងភិក្ខុទាំងឡាយថា ពួកអ្នកចូរស្រង់ជម្រះកាយ

ចុះ ព្រោះភ្លៀងនេះជាភ្លៀងចុងបំផុតនៃរដូវវស្សា ទើបពួកភិក្ខុនាំគ្នាស្រាតសំពត់ស្រង់ទឹកភ្លៀង ។ គ្រានោះនាងវិសាខា បញ្ជាទាសីឱ្យទៅទូលភត្តកាលដល់ព្រះអង្គ នាងទាសីទៅដល់អារាម ឃើញពួកភិក្ខុនាំគ្នាអាក្រាតកាយងូតទឹកភ្លៀង យល់ថា ពួកអចេលកឹរឹបយកអារាមជេតពនទៅហើយ ទើបត្រឡប់ទៅប្រាប់សេចក្តីដែលខ្លួនបានជួបប្រទះ ។ នាងវិសាខាជាមនុស្សឆ្លាត ដឹងបានភ្លាមថា ប្រហែលជាពួកភិក្ខុ អាក្រាតសំពត់ងូតទឹកពិតប្រាកដ ទើបនាងទាសីនេះសម្គាល់ថា មិនមានភិក្ខុក្នុងវត្ត នាងបញ្ជាទាសីនោះទៀតថា នាងចូរត្រឡប់ទៅទូលព្រះសាស្តាថា ឥឡូវនេះ ភត្តាហារសម្រេចរៀបរយហើយ ។

កាលពួកភិក្ខុស្រង់ទឹកស្រេចហើយ នាំគ្នាស្លៀកដណ្តប់ចីវរ ហើយចូលទៅកាន់ទីសម្រាកដូចដើម នាងទាសីត្រឡប់មកឃើញអារាមស្ងាត់ឈឹង ទើបត្រឡប់ទៅប្រាប់ទៀតថា មិនមានភិក្ខុក្នុងអារាមឡើយ ទើបនាងវិសាខាបញ្ជាជាលើកទី ៣ ទៀតថា នាងចូរទៅទូលថា ភត្តាហារសម្រេចហើយ ព្រះសាស្តាយាងព្រមដោយភិក្ខុសង្ឃទៅកាន់ផ្ទះរបស់នាង ។

នាងវិសាខាបានអង្គាសព្រះពុទ្ធអង្គ និងភិក្ខុសង្ឃដោយភោជនាហារដ៏ប្រណីត ក្រោយពីសម្រេចភត្តកិច្ចហើយ នាងបានក្រាបទូលព្រះសាស្តាថា ខ្ញុំម្ចាស់សូមពរ ៨ ប្រការ គឺ :

**១. សូមប្រគេនវស្សិកសាដក ដល់ពួកភិក្ខុទាំងឡាយ** (សំពត់ងូតទឹកភ្លៀង)

**២. សូមប្រគេនភត្តាហារ ដល់ភិក្ខុអាគន្តុកៈ** ( អាគន្តុកភត្ត )

**៣. សូមប្រគេនភត្តាហារ ដល់ភិក្ខុត្រូវធ្វើដំណើរឆ្ងាយ** (គមិកភត្ត)

**៤. សូមប្រគេនភត្តាហារ ដល់ភិក្ខុអាពាធ**

**៥. សូមប្រគេនភត្តាហារ ដល់ភិក្ខុព្យាបាលភិក្ខុអាពាធ**

**៦. សូមប្រគេនភេសជ្ជៈ ដល់ភិក្ខុអាពាធ**

**៧. សូមប្រគេនយាគូ ដល់ពួកភិក្ខុជាប្រចាំ**

**៨. សូមប្រគេនវស្សិកសាដិកា ដល់ភិក្ខុនីទាំងឡាយ** (សំពត់ងូតទឹក)

ព្រះអង្គទ្រង់អនុញ្ញាត តាមពាក្យក្រាបទូលរបស់នាងវិសាខា ហើយទ្រង់អនុញ្ញាតពរ ៨ ប្រការនោះ ទុកជាដើមបញ្ញត្តិនៃការប្រគេនសំពត់ងូតទឹកភ្លៀង និងបច្ច័យផ្សេងៗ ធ្វើឱ្យងាយស្រួលដល់ពួកភិក្ខុ និងភិក្ខុនីតមក ។

ក្រោពីនោះ នៅមានទ្រង់អនុញ្ញាតភេសជ្ជៈ ដើម្បីបំបាត់អាពាធរបស់ភិក្ខុ ៥ ប្រភេទ គឺៈ **ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ** អនុញ្ញាតឱ្យបរិភោគបានទាំងក្នុងភត្តកាល និងក្រោយភត្តកាល ។ តមកមិគារសេដ្ឋីគិតថា កូនប្រសាររបស់យើងមានឧបការច្រើន គួរធ្វើគ្រឿងប្រដាប់ឱ្យដល់នាង ព្រោះមហាលតាបសាធន៍មានទម្ងន់ធ្ងន់ណាស់ មិនអាចប្រើប្រដាប់តាក់តែងបានគ្រប់ពេល ទើបឱ្យជាងធ្វើគ្រឿងប្រដាប់ឈ្មោះ **ឃនមដ្ឋកបសាធន៍** មានទម្ងន់ស្រាលឱ្យដល់នាង ។

ក្នុងថ្ងៃមង្គលមួយ មហាជននាំគ្នាទៅកាន់វត្តជេតពន ដើម្បីស្តាប់ធម៌ នាងវិសាខា និងបរិវារតាំងចិត្តទៅស្តាប់ធម៌ដូចគ្នា នាងតែងកាយដោយមហា

លតាបសាធន៍ ហើយដើរតាមជនទាំងនោះទៅ លុះដល់វត្តជេតពននាងគិតថា ការតែងកាយដោយគ្រឿងប្រដាប់ដូច្នេះ ចូលទៅកាន់វិហារ ជាការមិនសមគួរទេ ទើបដោះគ្រឿងប្រដាប់ចេញ ខ្ចប់ឱ្យរៀបរយបញ្ជូនឱ្យបរិវារកាន់ ហើយចូលទៅក្នុងវិហារដើម្បីស្តាប់ព្រះធម្មទេសនា ។ កាលចប់ព្រះធម៌ទេសនា នាងចេញមកព្រមជាមួយបរិវារតាំងចិត្តថា នឹងទៅសួរសុខទុក្ខភិក្ខុអាគន្តុកៈ ភិក្ខុត្រៀមធ្វើដំណើរឆ្ងាយ និងភិក្ខុសាមណេរអាពាធ កាលចប់ហើយក៏ត្រឡប់វិញ នាងសូមគ្រឿងប្រដាប់មកវិញ ទើបបរិវារដឹងថាខ្លួនភ្លេចក្នុងវិហារ ប្រញាប់ត្រឡប់ទៅដើម្បីយកកញ្ចប់គ្រឿងប្រដាប់មកវិញ ។

ជាប្រក្រតីកាលពួកជនត្រឡប់ទៅហើយ ព្រះអានន្ទ ត្រូវមើល និងរក្សាវត្ថុផ្សេងៗ ដែលមានអ្នកភ្លេចទុកឱ្យរៀបរយ លុះឃើញស្រីបរិវារត្រឡប់មកទើបពោលថា អាត្មារក្សាកញ្ចប់របស់នោះទុកត្រង់ជើងជណ្តើរ នាងចូរនាំទៅចុះ ស្រីនោះនាំត្រឡប់មក និងប្រាប់ឱ្យនាងវិសាខាដឹងថា ព្រះអានន្ទរក្សាកញ្ចប់ទុកឱ្យ ។ នាងគិតថា គ្រឿងប្រដាប់នេះ លោកម្ចាស់ប៉ះពាល់ហើយ មិនគួរយើងនាំមកប្រើប្រាស់តាក់តែងទៀត យើងនឹងលក់គ្រឿងប្រដាប់នេះ ដើម្បីនាំបច្ច័យមកទំនុកបម្រុងព្រះពុទ្ធសាសនា ទើបឱ្យប្រកាសរកអ្នកទិញ តែមិនមានអ្នកណាហ៊ានឱ្យតម្លៃ ព្រោះថ្លៃពេក ដូច្នោះទើបនាងទិញគ្រឿងប្រដាប់នោះខ្លួនឯង ហើយឱ្យជញ្ជូនកហាបណៈដាក់រទេះ នាំទៅកាន់វត្តជេតពន ក្រាបទូលព្រះសាស្តាថា ឥឡូវនេះ ខ្ញុំម្ចាស់នាំកហាបណៈដែលបានមកពីការលក់គ្រឿងអលង្ការ មហា

លតាបសាធនីមកថ្វាយ សមគួរនឹងថ្វាយទុកក្នុងបច្ច័យណាព្រះអង្គ ។

ព្រះសាស្តាទ្រង់ណែនាំថា នាងគួរនាំទៅសាងទីស្នាក់អាស្រ័យសម្រាប់សង្ឃ ដោយតម្លៃលក់គ្រឿងប្រដាប់ចំនួន ៩ កោដិ និងផ្ដើមកសាងប្រាសាទ ដើម្បីឱ្យជាទីគង់នៅនៃព្រះមានព្រះភាគជាម្ចាស់ និងជាទីគង់នៅរបស់ភិក្ខុសង្ឃ លើផ្ទៃដីនោះ ដោយតម្លៃប្រាក់កសាងចំនួន ៩ កោដិ ។

ពេលចេញព្រះវស្សា ព្រះមានព្រះភាគមានព្រះបំណងយាងចារិក កាលនាងវិសាខាដឹង ទើបប្រញាប់មកក្រាបទូលថា ខ្ញុំម្ចាស់សាងវិហារនេះដើម្បីថ្វាយចំពោះព្រះអង្គ សូមប្រោសយាងត្រឡប់មកវិញចុះ ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា នេះជាការចេញចារិករបស់តថាគត នាងវិសាខាគិតថា ព្រះមានព្រះភាគប្រាកដជាទ្រង់ឃើញបុគ្គលដែលគួរប្រោស ទើបទូលសូមភិក្ខុដែលយល់ក្នុងការកសាងទុកមួយរូប ព្រះអង្គត្រាស់ថា នាងពេញចិត្តភិក្ខុរូបណា ចូរទទួលបាត្រភិក្ខុរូបនោះចុះ ។ សូម្បីនាងពេញចិត្តព្រះអានន្ទត្ថេរក៏ពិត តែគិតថា ការងារនេះ នឹងសម្រេចបានក៏ដោយអាស្រ័យព្រះមហាមោគ្គល្លាន ទើបទទួលបាត្រព្រះថេរៈទុក ។

ព្រះមានព្រះភាគ ត្រាស់ឱ្យព្រះមោគ្គល្លាន នាំភិក្ខុសង្ឃជាបរិវារត្រឡប់វិញ ព្រះថេរៈបានជួយឱ្យការកសាងសម្រេចទៅដោយសុវត្ថិភាព សូម្បីដូច្នោះក៏ត្រូវប្រើពេលវេលាកសាងអស់ ៩ ខែ ទើបសម្រេច ។ តមក នាងវិសាខាដឹងថា ខណៈនេះព្រះសាស្តាយាងត្រឡប់ពីចារិកមកដល់ក្រុងសាវត្ថីហើយ ទើប

ទៅគាល់នៅវត្តជេតពន ទូលអារាធនាឱ្យព្រះអង្គយាងទៅគង់ ក្នុងមិគារមាតុប្រាសាទអស់វេលា ៤ ខែ ដើម្បីធ្វើការឆ្លង ព្រះសាស្តាទ្រង់ ទទួលដោយតុណ្ហីភាព ។ តាំងពីនោះមក នាងក៏ថ្វាយទានចំពោះព្រះសាស្តា និងសង្ឃសាវ័ករហូត ៤ ខែ ថ្ងៃចុងបំផុត នាងបានប្រគេនសំពត់សាដកដល់ភិក្ខុថ្មីដើម្បីធ្វើចីវរ និងប្រគេនភេសជ្ជៈដល់ភិក្ខុគ្រប់រូប ការឆ្លងពេលនេះអស់ទ្រព្យ ៩ កោដិទៀត រួមទាំងអស់ ២៧ កោដិ ។

ក្រោយការឆ្លង នាងវិសាខាធ្វើប្រទក្សិណជុំវិញមិគារមាតុប្រាសាទ បន្លឺឧទានដោយសេចក្តីសោមនស្សថា យើងធ្លាប់ប្រាថ្នាថា :

**នឹងថ្វាយប្រាសាទថ្មីជាវិហារទាន**

**នឹងថ្វាយគ្រែ តាំង ជាដើម ជាសេនាសនៈទាន**

**នឹងថ្វាយសលាកភត្ត ជាភោជនាហារទាន**

**នឹងថ្វាយសំពត់កាសិកពស្ត្រ ជាចីវរទាន**

**នឹងថ្វាយទឹកដោះថ្លា ទឹកឃ្មុំ ជាដើម ជាភេសជ្ជទាន ។**

**ក៏ឥឡូវនេះ សេចក្តីប្រាថ្នានោះបានសម្រេចបរិបូរណ៍ហើយ**

ភិក្ខុទាំងឡាយកើតសេចក្តីសង្ស័យ ព្រោះមិនធ្លាប់ឃើញនាងធ្វើដូច្នោះ នាំគ្នាយល់ថា ប្រហែលជានាងវិកលចរិត ទើបចូលទៅក្រាបទូលសួរព្រះសាស្តា ព្រះអង្គត្រាស់ថា នោះជាការបន្លឺឧទានដោយសេចក្តីសប្បាយចិត្ត ដែលសេចក្តីប្រាថ្នារបស់នាងសម្រេចបរិបូរណ៍ហើយ ទើបព្រះអង្គត្រាស់អតីតជាតិរបស់នាង

ថា នាងធ្លាប់ថ្វាយទានដល់ភិក្ខុសង្ឃ ៧ ថ្ងៃ ក្នុងថ្ងៃទីបំផុតបានតាំងសេចក្ដីប្រាថ្នាថា ដោយផលនៃទាននេះ ខ្ញុំម្ចាស់មិនបានប្រាថ្នាភាពជាធំក្នុងទេវលោក សូមត្រឹមតែឱ្យតាំងនៅក្នុងឋានៈជាមាតា និងជាកំពូលរបស់ឧបាសិកាអ្នកទំនុកបម្រុងសង្ឃដោយបច្ច័យ ៤ ។

ព្រះសាស្ដាទ្រង់សរសើរនាងវិសាខាថា **ជាកំពូលជាងឧបាសិកាទាំងឡាយអ្នកថ្វាយទាន ។**

អាស្រ័យត្រកូលទាំងពីរក្នុងក្រុងសាវត្ថី ជាអ្នកមានគុណធម៌ ព្រោះហេតុដូច្នោះ កាលមនុស្សគ្រប់គ្នាប្រាថ្នាថ្វាយទាន ទើបអ្នកទាំងពីរត្រូវទទួលអញ្ជើញឱ្យជាប្រធានជានិច្ច រហូតមិនមានពេលនឹងបានអង្គាសភិក្ខុទាំងឡាយ ក្នុងផ្ទះរបស់ខ្លួន អនាថបិណ្ឌិកសេដ្ឋីបានតាំងធីតាទាំង ៣ របស់ខ្លួនឱ្យជាអ្នករង់ចាំមើលថែភិក្ខុសង្ឃ ចំណែកនាងវិសាខាក៏អប់រំកូនចៅ ឱ្យទទួលនាទីរបស់ខ្លួនក្នុងផ្ទះ និងបានប្រគល់តួនាទីឱ្យចៅស្រីឈ្មោះ **សុទត្តី** ជាអ្នកមើលថែភិក្ខុសង្ឃដែលមកកាន់ផ្ទះ។

តមក ចៅស្រីអស់ជីវិតទៅ នាងវិសាខាឱ្យធ្វើការបូជាសពចៅស្រីហើយមិនអាចអត់ទ្រាំសេចក្ដីសោយសោកបាន ចូលទៅគាល់ព្រះសាស្ដាដោយទឹកភ្នែកជោគមុខ ស្រែកយំពណ៌នាដល់សេចក្ដីអាឡោះអាល័យ ដែលមានចំពោះចៅស្រី ព្រះសាស្ដាត្រាស់ថា វិសាខា ក្នុងក្រុងសាវត្ថីនេះ ជនមានប្រមាណប៉ុនណា នាងវិសាខាទូលឆ្លើយហើយ ព្រះអង្គត្រាស់ថា បើជនក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ ៧ ថ្ងៃ នាងគប្បីស្រែកយំសោយសោកទាំងថ្ងៃទាំងយប់ដូច្នេះឬ ? ម្នាល

វិសាខា នាងកុំសោយសោកពេកឡើយ ហើយត្រាស់ព្រះគាថាថា :

**សេចក្តីសោកកើតពីសេចក្តីស្រឡាញ់ ភ័យកើតពីសេចក្តីស្រឡាញ់ បើមិនមានសេចក្តីស្រឡាញ់ ភ័យ និងសេចក្តីសោកមានមកពីណា ។**

ក្នុងកាលចប់ទេសនា នាងវិសាខាក្រាបទូលថា ខ្ញុំម្ចាស់ជ្រាបច្បាស់ហើយព្រះអង្គ ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ខណៈដែលព្រះសាស្តាទ្រង់គង់នៅក្នុងបុព្វារាម នាងវិសាខាចូលទៅរកឧបាសិកាអ្នករក្សាឧបោសថក្នុងវិហារ សួរថា នាងទាំងឡាយ តើពួកនាងរក្សាឧបោសថដើម្បីអ្វី ?

~**ស្រីវ័យចាស់ឆ្លើយថា** ពួកយើងរក្សាឧបោសថ ព្រោះប្រាថ្នាទិព្វសម្បត្តិ ។

~**ស្រីវ័យកណ្តាលឆ្លើយថា** ពួកយើងរក្សាឧបោសថ ព្រោះមិនប្រាថ្នាស្ត្រីរួមប្តី ។

~**ស្រីវ័យក្រមុំឆ្លើយថា** ពួកយើងរក្សាឧបោសថ ព្រោះចង់បានកូនប្រុសក្នុងគភ៌ដំបូង ។

~**ស្រីវ័យក្មេងឆ្លើយថា** ពួកយើងរក្សាឧបោសថ ព្រោះត្រូវទៅកាន់ត្រកូលស្វាមីក្នុងវ័យក្មេង ។ នាងវិសាខានាំស្រីទាំងនោះ ទៅកាន់ទីគង់នៅរបស់ព្រះសាស្តាក្រាបទូលសេចក្តីប្រាថ្នាផ្សេងៗគ្នារបស់ស្រីទាំងនោះឱ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលវិសាខា ធម្មតាសង្ខារធម៌ទាំងឡាយ **មានជាតិ** គឺការកើតបញ្ជូនឱ្យជរា ជរានាំទៅកាន់ព្យាធិ ព្យាធិនាំទៅ កាន់មរណៈ មរណៈរមែងផ្តាច់ជីវិតសត្វ ដូចគេកាត់ដើមឈើដោយពូថៅ សត្វទាំងឡាយប្រាថ្នាតែវដ្តៈ មិនប្រាថ្នា

ព្រះនិព្វាន ហើយត្រាស់ព្រះគាថាថា :

**គង្វាលគោកៀងគោទាំងឡាយ ទៅកាន់ទីគោចរដោយអាជ្ញា គឺដំបង ឬរំពាត់យ៉ាងណាមិញ ជរា និងមច្ចុក៏កៀងទៅនូវអាយុរបស់សត្វទាំងឡាយយ៉ាងនោះឯង ។**

ចប់ព្រះគាថា

ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

# ព្រះវស្សាទី ២១

(៥) ព្រះវិន័យបិដក មហាវិភង្គ និងខុទ្ទកនិកាយ ឧទាន សម្តែងទុកថា ខណៈដែលព្រះអង្គគង់នៅក្នុងមិគារមាតុប្រាសាទ វត្តបុព្វារាម ទ្រង់ព្រះតម្រិះថា ឥឡូវនេះអព្វមង្គលកើតឡើងក្នុងពួកភិក្ខុសង្ឃហើយ បុគ្គលមិនបរិសុទ្ធមកធ្វើឧបោសថ ព្រះតថាគតទាំងឡាយរមែងមិនសម្តែងឧបោសថ ដល់បរិស័ទមិនបរិសុទ្ធឡើយ ។

កាលព្រះតថាគតមិនសម្តែងឧបោសថ ឧបោសថរបស់ភិក្ខុក៏នឹងដាច់ ទើបព្រះអង្គត្រាស់នឹងភិក្ខុទាំងឡាយថា តាំងពីឥឡូវនេះទៅ តថាគតនឹងមិនធ្វើឧបោសថ មិនសម្តែងបាតិមោក្ខ ពួកអ្នកប៉ុណ្ណោះគប្បីធ្វើឧបោសថ គប្បីសម្តែងបាតិមោក្ខដល់គ្នាក្នុងសង្ឃ ព្រោះមិនមែនជាឋានៈ មិនមែនជាឱកាសដែលតថាគតគប្បីធ្វើឧបោសថ ឬសម្តែងបាតិមោក្ខក្នុងបរិស័ទមិនបរិសុទ្ធដោយកាយវាចា និងចិត្តឡើយ ។

## ពាក្យថា បាតិមោក្ខ

**បាតិមោក្ខមាន ២ យ៉ាង គឺ ឱវាទបាតិមោក្ខ និងអាណាបាតិមោក្ខ**

**ឱវាទបាតិមោក្ខ** គឺ បាតិមោក្ខដែលព្រះអង្គទ្រង់សម្តែងដោយព្រះអង្គឯងប្រ-កបដោយឱវាទ ៣ គាថាកន្លះ ទ្រង់សម្តែងដល់ព្រះអរហន្ត ១២៥០ រូប ជាគ្រាដំបូងក្នុង **ចតុរង្គសន្និបាត** នៅវត្តវេឡុវ័ន ក្រុងរាជគ្រឹះ និងទ្រង់សម្តែងក្នុងទី

ប្រជុំសង្ឃរាល់៧កន្លះខែ រហូតមកដល់វស្សាទី ២០ ទើបត្រាស់ឱ្យសង្ឃធ្វើឧបោ-សថ និងសម្ដែងបាតិមោក្ខគ្នាឯង ។

**អាណាបាតិមោក្ខ** គឺ បាតិមោក្ខដែលសង្ឃសម្ដែងគ្នាឯង ក្នុងទីប្រជុំសង្ឃរៀងរាល់កន្លះខែ ព្រះអង្គទ្រង់ឱ្យសង្ឃសម្ដែងអាណាបាតិមោក្ខ ផ្ដើមតាំងពីវស្សាទី ២១ ជាប់តមក រហូតដល់បច្ចុប្បន្ន ជាវិន័យរបស់សង្ឃប្រកបដោយសិក្ខាបទទាំងអស់ ២២៧ សិក្ខាបទ គឺ : **បារាជិក ៤ សង្ឃាទិសេស ១៣ អនិយត ២ និស្សគ្គិយបាចិត្តិយ ៣០ សុទ្ធិកបាចិត្តិយ ៩២ បាដិទេសនីយ ៤ សេក្ខិយវត្ត ៧៥ និងអធិករណសមថ: ៧ ។**

ការកន្លងល្មើសសិក្ខាបទ ហៅថា អាបត្តិ មាន ៧ កង គឺ **បារាជិក សង្ឃាទិសេស ថុល្លច្ច័យ បាចិត្តិយ: បាដិទេសនិយ: ទុក្កដ ទុព្ភាសិត** ចែកជា ២ ប្រភេទ គឺ :

**គរុកាបត្តិ** អាបត្តិធ្ងន់ បារាជិក និងសង្ឃាទិសេស

**លហុកាបត្តិ** អាបត្តិស្រាល គឺអាបត្តិ ៥ កងដ៏សេសទៀត ។

ការសម្ដែងអាណាបាតិមោក្ខ ឬការធ្វើឧបោសថ មានការហៅដោយសង្ខេបច្រើនយ៉ាងគឺ **សង្ឃុបោសថ** ភិក្ខុតាំងពី ៤ រូបឡើងទៅប្រជុំគ្នា ត្រូវសម្ដែងបាតិមោក្ខ **បារិសុទ្ធិឧបោសថ ឬ គណឧបោសថ** ភិក្ខុ ២ ឬ ៣ រូប ប្រជុំគ្នា មិនត្រូវសម្ដែងបាតិមោក្ខ ត្រឹមតែប្រាប់សេចក្ដីបរិសុទ្ធដល់គ្នានិងគ្នា ។ **បុគ្គលឧបោសថ ឬ អធិដ្ឋានឧបោសថ** ភិក្ខុត្រឹមតែ ១ រូប ឱ្យកំណត់អធិដ្ឋាន

ខ្លួនឯងថា ថ្ងៃនេះជាថ្ងៃឧបោសថ ។

ថ្ងៃធ្វើឧបោសថមាន ៣ ថ្ងៃ គឺ :

**ចាតុទ្ទសី** ឧបោសថដែលធ្វើក្នុងថ្ងៃ ១៤ រោច

**បណ្ណរសី** ឧបោសថដែលធ្វើក្នុងថ្ងៃ ១៥ កើត ឬ ១៥ រោច

**សាមគ្គីឧបោសថ** ឧបោសថដែលធ្វើក្នុងថ្ងៃដែលសង្ឃបែកបាក់គ្នា ត្រឡប់ស្រុះស្រួលគ្នាវិញ ។

## សេចក្តីសន្និដ្ឋាន ប្រហែលជាក្នុងវស្សាទី ២៦

(៦) ក្រោយពី **ព្រះរាហុល** ឧបសម្បទា និងសម្រេចអរហត្តផលហើយ ក្នុងវស្សាទី ១៤ តអំពីនោះ មិនមានសេចក្តីណាពោលបញ្ជាក់ដល់ព្រះរាហុលទៀតឡើយ ក្រៅអំពីវគ្គដែលព្រះសារីបុត្រទូលលាបរិនិព្វាន លោករំពឹងថា ព្រះរាហុលបរិនិព្វាននៅតាវត្តិង្ស ព្រះអញ្ញាកោណ្ឌញ្ញៈបរិនិព្វាននៅស្រះឆទ្ទន្ត មានត្រឹមតែប៉ុណ្ណេះ ។

ក្នុងទីឃនិកាយមហាវគ្គ ពោលទុកថា ព្រះរាហុលត្ថេរ មិនធ្លាប់ជាន់លើផ្ទៃគ្រែឡើយរហូតអស់ ១២ ឆ្នាំ ក្រោយពីសម្រេចអរហត្តផល ធ្វើឱ្យយល់បានថា ប្រហែលជា លោកបរិនិព្វានក្នុងខណៈដែលមានព្រះជន្មាយុ ៣២ ព្រះវស្សា ទើបសន្និដ្ឋានថាព្រះរាហុលបរិនិព្វាន ក្នុងវស្សាទី ២៦ ។

ក្នុងថេរគាថា ពោលថា ព្រះរាហុលត្ថេរ កាលព្យាករណ៍ ព្រះអរហត្តផលបានពោលគាថា ថា :

-យើងជាឱរសរបស់ព្រះពុទ្ធជាម្ចាស់ បរិបូរណ៍ដោយជាតិសម្បត្តិ
-និងបដិបត្តិសម្បត្តិ ជាអ្នកមានបញ្ញាឃើញអមតធម៌
-ផុតចាកសំណាញ់ គឺតណ្ហាគ្រប់គ្រងហើយ ដកឫស គឺអវិជ្ជាហើយ
-ជាអ្នកមានសេចក្ដីក្សេម រំលត់អស់ដោយសស្រ្តា គឺអរិយមគ្គ ។

ព្រះរាហុលត្ថេរ បរិនិព្វានដោយអនុបាទិសេសនិព្វាន អដ្ឋិធាតុរបស់លោកក៏មិនមានពោលថា តម្កល់ទុកក្នុងទីណាឡើយ ។

## សេចក្ដីសន្និដ្ឋាន ប្រហែលជាក្នុងវស្សាទី ៣៧

(៧) ព្រះពុទ្ធអង្គ និងសង្ឃសាវ័ក យាងទៅគង់ក្នុងវត្តឃោសិតារាម ក្រុងកោសម្ពី ភិក្ខុទេវទត្តជាប់តាមព្រះអង្គទៅដែរ ពេលដែលគង់នៅក្រុងកោសម្ពី ពួកជនទៅស្ដាប់ធម៌ នាំគ្នាយកគ្រឿងសក្ការៈទៅប្រគេនព្រះថេរៈទាំងឡាយ ជនទាំងនោះសួរគ្នាថា ព្រះថេរៈឈ្មោះនេះៗ នៅក្នុងទីណា មិនមានអ្នកណាចាប់អារម្មណ៍ចំពោះទេវទត្តឡើយ ទេវទត្តកើតសេចក្ដីច្រណែន ព្រោះឃើញដល់លាភសក្ការៈ ទើបគិតថា នឹងរកអ្នកណាមកឧបត្ថម្ភខ្លួន ឃើញតែអជាតសត្រូវ ឱរសរបស់ព្រះបាទពិម្ពិសារតែម្នាក់គត់ ដែលអាចនឹងលួងលោមបាន ព្រោះអជាតសត្រូវនៅក្មេង មិនទាន់ដឹងខុសត្រូវល្អអាក្រក់ ទើបទេវទត្តធ្វើដំណើរពីក្រុងកោសម្ពី ព្រមទាំងពួកភិក្ខុជាបរិវាររបស់ខ្លួនទៅស្នាក់នៅ ក្នុងគយាសីសៈ ជិតក្រុងរាជគ្រឹះ ។

ទេវទត្តសម្ដែងឫទ្ធិឱ្យអជាតសត្រូវជឿជាក់ អជាតសត្រូវជ្រះថ្លា កសាងទីនៅឱ្យដល់ទេវទត្ត និងពួកភិក្ខុជាបរិវារដែលជាប់តាមមកគយាសីសៈ អជាតសត្រូវទៅកាន់ទីបម្រើរបស់ទេវទត្តទាំងពេលព្រឹក និងពេលល្ងាច ឧបត្ថម្ភទេវទត្តដោយលាភសក្ការៈផ្សេងៗ ជាប្រចាំ ។

ពួកភិក្ខុដឹងសេចក្ដីនេះ ទើបត្រឡប់មកក្រាបទូលឱ្យព្រះអង្គទ្រង់ជ្រាប ព្រះពុទ្ធអង្គត្រាស់ថា អ្នកកុំពេញចិត្តក្នុងលាភសក្ការៈ និងការសរសើររបស់ទេវទត្តឡើយ ព្រោះទេវទត្តមានការសាបសូន្យកុសលធម៌តែម្យ៉ាង មិនមានសេចក្ដីចម្រើនទេ ប្រៀបដូច **ផ្លែចេករមែងសម្លាប់ដើមចេក ផ្លែឫស្សីរមែងសម្លាប់ដើមឫស្សី សក្ការៈរមែងសម្លាប់មនុស្សអាក្រក់** ដូច្នោះ ។

**កកុធៈ** អ្នកនគរកោលិយៈ ធ្លាប់ជាឧបដ្ឋាករបស់ព្រះមោគ្គល្លាន កាលអស់ជីវិតទៅ កើតក្នុងព្រហ្មលោកជាអ្នកមានឫទ្ធិផ្លូវចិត្តអាចកំណត់ដឹងចិត្តអ្នកដទៃ បានចុះមករកព្រះមោគ្គល្លានពោលថា លោកម្ចាស់ ភិក្ខុទេវទត្តលាភសក្ការៈគ្របសង្កត់ហើយ តទៅនឹងកើតសេចក្ដីប្រាថ្នាថា នឹងគ្រប់គ្រងភិក្ខុសង្ឃដោយខ្លួនឯង ។ ព្រះមោគ្គល្លាន នាំសេចក្ដីនោះទៅក្រាបទូលព្រះមានព្រះភាគតាមសេចក្ដីដែលកកុធទេវបុត្ត មកប្រាប់ឱ្យដឹង និងទូលថា រឿងដែលទេវបុត្តពោលនោះ នឹងត្រូវកើតឡើងជាពិតប្រាកដ ។

ព្រះសាស្ដាត្រាស់ថា ម្នាលមោគ្គល្លាន អ្នកចូររក្សាវាចានេះទុក តទៅទេវទត្តនឹងធ្វើកម្មនោះឱ្យប្រាកដខ្លួនឯង ។ តមក ទេវទត្តកើតគំនិតថា យើងនឹង

គ្រប់គ្រងភិក្ខុសង្ឃ ដូច្នេះហើយទេវទត្តបានសាបសូន្យចាកឫទ្ធិ ព្រមដោយចិត្ត-ប្បាទនោះ ចូលទៅថ្វាយបង្គំព្រះសាស្តា ក្នុងវត្តវេឡុវ័នក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ជរាហើយ មានវ័យកន្លងទៅហើយ សូមព្រះមាន-ព្រះភាគទ្រង់ខ្វល់ខ្វាយតិច ប្រកបតែទិដ្ឋធម្មសុខវិហារធម៌ចុះ សូមប្រគល់ភិក្ខុសង្ឃដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងគ្រប់គ្រងភិក្ខុសង្ឃខ្លួនឯង ។

ព្រះអង្គត្រាស់ថា ម្នាលទេវទត្ត អម្បាលសារីបុត្រ និងមោគ្គល្លាន តថាគតមិនប្រគល់ភិក្ខុសង្ឃផង តើឱ្យតថាគតប្រគល់ឱ្យអ្នកដូចម្តេចទៅ ព្រោះអ្នកបរិភោគបច្ច័យដូចជាទឹកមាត់ ទេវទត្តគិតថា ព្រះសាស្តាមិនយល់មុខយើងដែលជាវង្សក្សត្រដូចគ្នាឡើយ ទើបចងអាឃាតនឹងព្រះអង្គតាំងពីពេលនោះមក ។

ព្រះសាស្តាត្រាស់ឱ្យព្រះសារីបុត្រធ្វើ **បកាសនីយកម្ម** គឺប្រកាសឱ្យអ្នកក្រុងរាជគ្រឹះដឹងថា ប្រក្រតីរបស់ទេវទត្តពីមុនផ្សេង ឥឡូវនេះផ្សេង ដូច្នោះភិក្ខុទេវទត្តធ្វើយ៉ាងណា ដោយកាយ វាចា មិនគប្បីយល់ឃើញថា ព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃទាំងឡាយ ធ្វើយ៉ាងនោះដែរ គប្បីដឹងថា ជាការធ្វើចំពោះខ្លួនរបស់ទេវទត្តតែប៉ុណ្ណោះ ។ អជាតសត្រូវ បានទទួលពាក្យញុះញង់ចាក់ដោតអំពីទេវទត្ត ឱ្យដណ្តើមរាជសម្បត្តិពីព្រះបាទពិម្ពិសារជាព្រះរាជបិតា ហើយឱ្យតាំងខ្លួនជាព្រះរាជា ចំណែកទេវទត្តនឹងផ្តាច់ព្រះជន្មព្រះសាស្តា ហើយតាំងខ្លួនជាព្រះពុទ្ធដោយខ្លួនឯង ។

អជាតសត្រូវ បានប្រើឧបាយផ្តាច់ព្រះជន្មព្រះបាទពិម្ពិសារសម្រេច បាន

ជាក្សត្រគ្រងរាជ្យដែនមគធៈ កាលព្រះបាទអជាតសត្រូវគ្រងរាជ្យសម្បត្តិហើយ ទើបទេវទត្តសូមកម្លាំងពីព្រះបាទអជាតសត្រូវ បញ្ជូនមនុស្សទៅធ្វើគតព្រះសាស្តា ជាអំពើអាក្រក់ចំពោះព្រះពុទ្ធអង្គលើកដំបូង មនុស្សទាំងនោះត្រឡប់មានសទ្ធា ជ្រះថ្លាក្នុងព្រះពុទ្ធអង្គ ថ្វាយខ្លួនជាឧបាសកទាំងអស់ ។ លើកទី ២ ក្រោយពីផែនការណ៍ដំបូងមិនសម្រេច ទើបទេវទត្តអនុវត្តខ្លួនឯង ដោយឡើងទៅលើភ្នំគិជ្ឈកូដ ប្រមៀលដុំថ្មធំចុះមក ក្នុងខណៈដែលព្រះអង្គយាងចង្រ្កម ដោយតាំងចិត្តថា យើងនឹងផ្តាច់ព្រះជន្មព្រះសមណគោតម តែថ្មនោះរមៀលទៅប៉ះខ្ទប់នឹងដុំថ្មដទៃ បែកជាបំណែកតូចៗ មកបុកព្រះបាទា ធ្វើឱ្យជាំពងព្រះលោហិត ពួកភិក្ខុដែលជាប់តាមទៅនាំគ្នាធ្វើគ្រែសែងព្រះអង្គ ទៅសម្រាកត្រង់មទ្ទកុច្ឆិជើងភ្នំគិជ្ឈកូដ បន្ទាប់ពីនោះ នាំព្រះអង្គទៅកាន់ជីវកម្ពវនារាម ពេទ្យជីវកធ្វើការវះកាត់ យកព្រះលោហិតដែលពុរពងចេញចាកម្រាមព្រះបាទ ។

ទេវទត្តមិនទាន់លះសេចក្តីព្យាយាម លើកទី ៣ ចូលទៅរកហ្មដំរី អះអាងខ្លួនថា យើងតម្លើងសក្តិដកងារអ្នកឯងក៏បាន ហើយបញ្ជាឱ្យលែង **ដំរីនាឡាគីរី** ចេញទៅប្រទុសរ៉ាយព្រះអង្គ ដែលកំពុងយាងបិណ្ឌបាត កាលដំរីមើលឃើញព្រះពុទ្ធអង្គក៏បោលចូលទៅបៀតបៀន ព្រះអានន្ទចេញទៅឈរវាំងមុខដំរី ដោយសេចក្តីស្រឡាញ់ភក្តី តាំងចិត្តលះជីវិត ដើម្បីការពារព្រះពុទ្ធអង្គ ។ ដោយអំណាចនៃមេត្តាចិត្ត ដែលព្រះសាស្តាទ្រង់ផ្សាយចំពោះដំរីនាឡាគីរី ធ្វើឱ្យដំរីនោះពាល់ត្រូវដោយមេត្តាចិត្តរបស់ព្រះអង្គ ក៏ដាក់ប្រមោយចុះចូលទៅក្រាបចំពោះ

ព្រះភក្ត្រ ព្រះអង្គទ្រង់លើកព្រះហស្ថឡើងអង្អែលពោងដំរី ( ក្បាលដំរី ) ពោលថា ម្នាលនាឡាគីរី អ្នកកុំប្រមាទ ព្រោះបើអ្នកប្រមាទមិនអាចទៅកាន់សុគតិបានឡើយ ។

ដំរីនាឡាគីរី យកប្រមោយជញ្ជក់លំអងធូលីព្រះបាទរបស់ព្រះមានព្រះភាគរោយចុះលើពោងរបស់ខ្លួន រំកិលថយទៅរហូតផុតគន្លងចក្ខុ ហើយត្រឡប់ទៅកាន់រោងដំរីដូចដើម ។ ហេតុការណ៍លើកនេះ កើតឡើងក្នុងក្រុងរាជគ្រឹះ ជនទាំងអស់ឃើញហេតុការណ៍នោះទូទៅ ម្នាក់ៗ នាំគ្នាពោលថា ទេវទត្តនេះបាបធ្ងន់ណាស់ ព្រោះគិតផ្ដាច់ព្រះជន្មព្រះសម្ពុទ្ធ ហេតុអ្វីព្រះរាជារបស់យើងនៅឧបត្ថម្ភទៀត អជាតសត្រូវទ្រង់ជ្រាបរឿងដូច្នោះ ត្រិះរិះថា ព្រោះទេវទត្តនេះឯង ដែលធ្វើឱ្យព្រះបិតារបស់យើងសុគត ទ្រង់បញ្ជាឱ្យបញ្ឈប់ការឧបត្ថម្ភទេវ-ទត្តទាំងអស់ និងហាមមិនឱ្យទេវទត្តចូលគាល់តទៅទៀតឡើយ ។

ភិក្ខុទេវទត្ត កាលព្យាយាមផ្ដាច់ព្រះជន្មព្រះសាស្ដាអស់ ៣ ដង មិនបានសម្រេច ចូលទៅបបួលកោកាលិកភិក្ខុ កតមោរកតិស្សកភិក្ខុ ខណ្ឌទេវីបុត្តភិក្ខុ សមុទ្ទទត្តភិក្ខុថា ពួកយើងនឹងបំបែកសង្ឃ ហើយនាំគ្នាចូលទៅទូលសូមវត្ត-បដិបត្តិ ៥ ប្រការ ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច គឺ :

**ភិក្ខុគប្បីសមាទានការនៅព្រៃជាវត្តអស់មួយជីវិត ១**

**ភិក្ខុគប្បីសមាទានការដើរបិណ្ឌបាតជាវត្តអស់មួយជីវិត ១**

**ភិក្ខុគប្បីសមាទានការបង្សុកូលជាវត្តអស់មួយជីវិត ១**

**ភិក្ខុមិនគប្បីឆាន់ត្រី និងសាច់អស់មួយជីវិត ១**

**ភិក្ខុគប្បីសមាទានការនៅក្បែរគល់ឈើជាវត្តអស់មួយជីវិត ១ ។**

កោកាលិកភិក្ខុពោលថា ពួកយើងអាចដើម្បីបំបែកចក្រ របស់ព្រះសមណគោតម ដោយវត្ថុ ៥ ប្រការនេះពិតប្រាកដ ព្រោះមនុស្សទាំងឡាយជ្រះថ្លាក្នុងការបដិបត្តិសៅហ្មង ។

ព្រះអង្គមិនទ្រង់អនុញ្ញាត ទ្រង់ត្រាស់ថា ភិក្ខុគប្បីសមាទានវត្តបដិបត្តិបានតាមការពេញចិត្ត អាចឆាន់សាច់បរិសុទ្ធដោយហេតុបីយ៉ាងបាន និងប្រការចុងបំផុត តថាគតអនុញ្ញាតគល់ឈើជាសេនាសនៈបានត្រឹម ៨ ខែ ក្រៅរដូវភ្លៀង ។ ទើបទេវទត្តទៅប្រកាស ឱ្យប្រជាជនដឹងថា ព្រះមានព្រះភាគមិនទ្រង់អនុញ្ញាតវត្តបដិបត្តិ ដែលខ្លួនសមាទាន និងប្រព្រឹត្តបដិបត្តិ ធ្វើឱ្យពួកជនដែលឥតបញ្ញាយល់ថា ទេវទត្តជាអ្នកប្រព្រឹត្តដុសខាត់កិលេស ចំណែកព្រះសាស្ដាជាអ្នកមានសេចក្ដីប្រាថ្នាច្រើន ទេវទត្តអាងថាពាក្យប្រៀនប្រដៅរបស់ខ្លួនប្រសើរជាងពួកភិក្ខុបួសថ្មីដែលមិនទាន់ស្គាល់ធម៌ ស្គាល់វិន័យ នាំគ្នាជឿស្ដាប់ព្រមចូលខ្លួនជាសាវ័ករបស់ទេវទត្តជាច្រើន ប្រមាណជា ៥០០ រូប ។

ព្រះអង្គទ្រង់ជ្រាប ត្រាស់ឱ្យហៅទេវទត្តមកគាល់ មានតម្រាស់សួរទេវទត្តឆ្លើយថា ពិត ទើបព្រះអង្គត្រាស់ថា ម្នាលទេវទត្ត អ្នកកុំពេញចិត្តនឹងការបំបែកសង្ឃ ព្រោះមានទោសធ្ងន់ណាស់ អ្នកណាបំបែកសង្ឃរមែងឆេះនៅក្នុងនរកអស់មួយកប្ប ចំណែកអ្នកណាសម្រុះសម្រួលសង្ឃដែលបែកគ្នាហើយ ឱ្យ

ព្រមព្រៀងគ្នាវិញជួបបុណ្យដ៏ប្រសើរ រមែងរីករាយក្នុងស្ថានសួគ៌មួយកប្ប ទេវ-ទត្ត មិនបានយកចិត្តទុកដាក់ក្នុងព្រះឱវាទនោះឡើយ ។

តមក ទេវទត្តជួបព្រះអានន្ទ នៅពេលកំពុងត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទើបប្រាប់សេចក្តីបំណងរបស់ខ្លួនដល់ព្រះអានន្ទថា តាំងពីថ្ងៃនេះទៅ ខ្ញុំនឹងធ្វើឧបោសថកម្មបែកអំពីព្រះមានព្រះភាគ និងភិក្ខុសង្ឃ ។ ព្រះអានន្ទ នាំសេចក្តីនោះមកក្រាបទូលព្រះមានព្រះភាគតាមពាក្យរបស់ភិក្ខុទេវទត្ត ព្រះ-អង្គទ្រង់ជ្រាបហើយ ទ្រង់បន្លឺឧទានថា :

**អំពើល្អ មនុស្សល្អធ្វើបានងាយ មនុស្សអាក្រក់ធ្វើបានលំបាក អំពើអាក្រក់មនុស្សអាក្រក់ធ្វើបានងាយ តែអរិយជនធ្វើអំពើអាក្រក់នោះបានដោយលំបាក ។**

បន្ទាប់ពីនោះមក ទេវទត្តនាំភិក្ខុបួសថ្មីក្នុងសំណាក់របស់ខ្លួន ដែលមិនទាន់ដឹងធម៌ ដឹងវិន័យ អំពីក្រុងរាជគ្រឹះ ធ្វើដំណើរទៅកាន់គយាសីសប្រទេស ។

ព្រះសាស្តាជ្រាបហេតុការណ៍នោះហើយ ត្រាស់ជាមួយព្រះសារីបុត្រ និងព្រះមោគ្គល្លានថា បើពួកអ្នកមានសេចក្តីអាណិតចំពោះភិក្ខុបួសថ្មីទាំងនោះ ចូរប្រញាប់តាមទៅ ព្រោះភិក្ខុទាំងនោះ កំពុងប្រឈមមុខនឹងសេចក្តីវិនាស ។ ព្រះអគ្គសាវ័កទាំង ២ ទើបធ្វើដំណើរ ជាប់តាមភិក្ខុថ្មីទាំងនោះ ទៅកាន់គយាសីសៈ ទេវទត្តយល់ថា ព្រះអគ្គសាវ័កទាំង ២ តាមមកព្រោះពេញចិត្តក្នុងធម៌របស់ខ្លួន ទើបនិមន្តឱ្យគង់ ក្រោយពីណែនាំទូន្មានភិក្ខុទាំងនោះហើយ ទេវទត្តពោលថា

ធម៌កថាចូរជាក់ច្បាស់ដល់អ្នកចុះ យើងនឿយហត់ហើយ នឹងតម្រេតខ្នងបន្តិច ហើយក៏ផ្តេកខ្លួនលក់បាត់ទៅ ។

បន្ទាប់មក ព្រះសារីបុត្រសម្តែងធម៌ឱ្យភិក្ខុទាំងឡាយយល់ច្បាស់ហើយ ពោលថា អ្នកទាំងឡាយយើងនឹងទៅគាល់ព្រះមានព្រះភាគ អ្នកណាពេញចិត្ត ក្នុងធម៌របស់ព្រះសាស្តា អ្នកនោះចូរមកតាមយើង ព្រះសារីបុត្រ និងព្រះមោគ្គ-ល្លាន នាំភិក្ខុទាំងនោះត្រឡប់ទៅវត្តវេឡុវ័នវិញ ។ លុះដល់វត្តវេឡុវ័នហើយ ព្រះសារីបុត្រក្រាបទូលថា គួរឱ្យភិក្ខុទាំងនេះឧបសម្បទាសាជាថ្មីឬ ព្រះសាស្តា ត្រាស់ថាកុំឡើយ អ្នកចូរឱ្យភិក្ខុទាំងនោះសម្តែង **អាបត្តិថុល្លច្ច័យ** ចុះ ។

**កោកាលិកភិក្ខុ** ជាសិស្សជំនិតរបស់ទេវទត្ត ឃើញហេតុការណ៍ដូច្នោះ ទើបដាស់ទេវទត្តឱ្យភ្ញាក់ឡើងពោលថា អគ្គសាវ័កទាំងពីរនាំភិក្ខុទាំងនោះទៅ អស់ហើយ យើងធ្លាប់ដាស់តឿនអ្នកហើយថា កុំទុកចិត្តក្នុងអ្នកទាំងពីរនេះ ។ ទេវទត្តឈឺចិត្តជាខ្លាំង ក្អួតធ្លាក់ឈាម មានជម្ងឺរហូតដល់ ៩ ខែ ក្នុងទីបំផុតនឹក ឃើញកំហុស ត្រូវការទៅគាល់ព្រះពុទ្ធអង្គ ដើម្បីទូលសូមខមាទោស ទើបឱ្យ សិស្សដែលនៅសល់នាំខ្លួនទៅគាល់ កាលសិស្សនាំទេវទត្ត មកជិតដល់វត្តជេតពន ក៏ដាក់គ្រែស្នែងក្បែរមាត់ស្រះបោក្ខរណី ហើយនាំគ្នាចុះទៅស្រង់ទឹក ទេវទត្ត ក្រោកឡើងអង្គុយ លុះដាក់ជើងទាំងពីរដល់ផែនដី។ ស្រូបទេវទត្តលិចចុះរហូត ដល់ក ក្នុងពេលដងកាំបិតចុចដល់ផ្ទៃដី ទេវទត្តពោលថា ខ្ញុំព្រះអង្គសូមដល់ព្រះ ពុទ្ធអង្គនោះ ជាទីពឹងដោយឆ្អឹងទាំងនេះ ព្រមដោយខ្យល់ដង្ហើម ។

ទេវទត្តលិចចុះក្នុងផែនដីហើយ ទៅកើតក្នុង **អវិចិមហានរក** ត្រូវភ្លើងនរកឆាបឆេះព្រោះ **អនន្តរិយកម្ម** ដែលខ្លួនបានធ្វើចំពោះព្រះពុទ្ធជាម្ចាស់ ។ អដ្ឋកថាធម្មបទ ពោលថា ព្រោះការដឹងកំហុសក្នុងវារៈចិត្តចុងបំផុត អនាគតទេវទត្តនឹងបានត្រាស់ដឹងជា ព្រះបច្ចេកពុទ្ធមួយអង្គនាមថា **អដ្ឋិស្សរៈ** ។

## សេចក្តីបញ្ជាក់បន្ថែម

ដែលពោលសន្និដ្ឋានថា ប្រហែលជាក្នុងវស្សា ៣៧ ភិក្ខុទេវទត្តសម្តែងឫទ្ធិទាល់តែព្រះបាទអជាតសត្រូវជឿជាក់ថា បានសម្រេចមគ្គផលហើយ និងញុះញង់ឱ្យព្រះបាទអជាតសត្រូវផ្តាច់ព្រះជន្ម ព្រះបាទពិម្ពិសារនោះ មានមកក្នុងន័យដូចគ្នាច្រើនកន្លែង គឺ :

១. ក្នុងវិន័យបិដក ចុល្លវគ្គ ទុតិយភាគ ពោលថា ក្នុងពេលនោះព្រះសាស្តាយាងចារិកអំពីអនុបិយនិគមទៅកាន់ក្រុងកោសម្ពី ។

២. ក្នុងខុទ្ទកនិកាយ គាថាធម្មបទបឋមលី ភាគ ១ ពោលថា កាលភិក្ខុទេវទត្តសម្តែងឫទ្ធិចំពោះព្រះបាទអជាតសត្រូវនោះ ព្រះសាស្តាទ្រង់គង់នៅក្រុងកោសម្ពី ។

## នៅរយៈពេលប្រហែលជាវស្សាទី ៣៨

( ៨ ) ព្រះបាទអជាតសត្រូវ ទ្រង់រឭកដល់កំហុសដែលធ្វើគតព្រះបិតា ទ្រង់មានសេចក្តីក្តៅក្រហាយព្រះទ័យ មានព្រះរាជបញ្ជាឱ្យពេទ្យជីវកកោមារ-ភត្តនាំទៅគាល់ព្រះពុទ្ធអង្គ ដែលទ្រង់គង់នៅ **ជីវកម្ពវនារាម** ទូលសួរដល់

សាមញ្ញផលដែលគប្បីបានទទួលក្នុងបច្ចុប្បន្ន ព្រះអង្គទ្រង់សម្ដែង **សាមញ្ញ-ផលសូត្រ** ពោលអំពីផលរបស់ភាពជាសមណៈ គឺ ប្រយោជន៍ដែលបានអំពីការទ្រទ្រង់ភេទជាសមណៈ ត្រាស់អានិសង្សរបស់ការចេញបួស ទ្រង់ចង្អុលបង្ហាញឱ្យឃើញថា ជីវិតរបស់ឃរាវាសចង្អៀងចង្អល់ បព្វជ្ជាជាផ្លូវទូលាយក្នុងការប្រព្រឹត្តិព្រហ្មចរិយៈឱ្យបរិសុទ្ធបរិបូរណ៍ ជាសាមញ្ញផលដែលឃើញបានក្នុងបច្ចុប្បន្ន ។

ព្រះបាទអជាតសត្រូវទ្រង់ជ្រះថ្លា សូមថ្វាយខ្លួនដល់ព្រះរតនត្រ័យជាសរណៈ ទ្រង់ជាពុទ្ធមាមកៈ ជាអ្នកឧបត្ថម្ភទំនុកបម្រុងព្រះពុទ្ធសាសនាតមកយ៉ាងខ្លាំងក្លា ។ កាលព្រះបាទ អជាតសត្រូវយាងត្រឡប់ទៅហើយ ព្រះសាស្ដាត្រាស់នឹងពួកភិក្ខុថា បើស្ដេចអង្គនេះមិនបានធ្វើបិតុឃាតទេ ធម៌ដែលតថាគតសម្ដែងក្នុងថ្ងៃនេះ យ៉ាងហោចណាស់ក៏បានជាសោតាបន្ន តែព្រោះព្រះរាជាសេពគប់មិត្តអាក្រក់ ព្រះអង្គនឹងត្រូវទៅកើតក្នុង **លោហកុម្ភីនរក** អស់កាលដ៏យូរ បន្ទាប់ពីនោះ ទើបបានសម្រេចជាព្រះបច្ចេកពុទ្ធ ព្រះនាមថា **ជីវិតវិសេសៈ** ។

ព្រះបាទបសេនទិកោសលទ្រង់ពិរោធ ដែលអជាតសត្រូវ ធ្វើគតព្រះ-រាជបិតារបស់ខ្លួនឯង ទើបលើកទ័ពមករឹបអូសយកស្រុកដែលព្រះបាទមហា-កោសល (ព្រះរាជបិតា) ទ្រង់ប្រទានដល់ព្រះនាងកោសលទេវី (ព្រះកនិដ្ឋភាតា) ជាចំណងដៃក្នុងថ្ងៃអភិសេកជាមួយព្រះបាទពិម្ពិសារ ដោយប្រកាសហេតុផលថា អ្នកធ្វើបិតុឃាតមិនមានសិទ្ធិគ្រប់គ្រងស្រុក ដែលធ្លាប់ជាអាណាខេត្តរបស់ដែនកោសលឡើយ ។

ព្រះបាទអជាតសត្រូវ លើកកម្លាំងចេញទៅច្បាំង ជួនចាញ់ជួនឈ្នះគ្នាជាច្រើនលើក ក្នុងលើកចុងក្រោយ ព្រះបាទបសេនទិកោសលអាស្រ័យការបានលួចស្តាប់ វិធីលើកទ័ពពីភិក្ខុមួយរូប ទើបចាប់ព្រះបាទអជាតសត្រូវបាន បញ្ជាឱ្យលះបង់រាជសម្បត្តិ តែតមកត្រឡប់លែងឱ្យជាឥស្សរៈវិញ ព្រោះឃើញថាជាក្មួយ ព្រមទាំងលើកព្រះធីតាឈ្មោះ **វជិរា** ឱ្យអភិសេកជាមួយព្រះបាទអជាតសត្រូវផង ។ តមក ខណៈដែលព្រះពុទ្ធអង្គគង់នៅនិគមឈ្មោះ **មេទឡុបៈ** ដែនសក្កៈរបស់ពួកសក្យរាជ ព្រះបាទបសេនទិកោសលយាងទៅថ្វាយបង្គំព្រះសាស្តាមុននឹងយាងចូលព្រះគន្ធកុដិ ទ្រង់ប្រគល់គ្រឿងរាជកកុធភ័ណ្ឌ ឱ្យទីឃការាយនអាមាត្យជាអ្នករក្សា ព្រោះឃើញថាជាការមិនសមគួរ ដែលនឹងចូលទៅគាល់ព្រះសាស្តា ដោយយសដ៏ធំក្រៃលែង ត្រិះរិះថានឹងចូលទៅតែមួយព្រះអង្គឯង ។

**ទីឃការាយនៈ** គិតក្បត់ដណ្តើមរាជសម្បត្តិ ដោយការចងអាឃាតដែលព្រះបាទបសេនទិកោសលបញ្ជាឱ្យសម្លាប់ពន្ធុលសេនាបតីជាអ៊ំ ព្រមទាំងកូនប្រុស ៣២ នាក់ ព្រោះព្រះបាទបសេនទិកោសលជឿពាក្យញុះញង់របស់អាមាត្យដទៃដោយអាស្រ័យការវិនិច្ឆ័យក្តីដ៏ល្អរបស់សេនាបតីពន្ធុលៈ តមក ទីឃការាយនៈជាក្មួយរបស់ពន្ធុលៈ បានទទួលតែងតាំងឱ្យជាអាមាត្យជំនួស តែព្រះបាទបសេនទិកោសល មិនព្រមសូមអភ័យទោសចំពោះពន្ធុលៈ ទាំងដែលអស់ជីវិតទៅហើយក៏ដោយ ទើបជាមូលហេតុឱ្យទីឃការាយនៈ គិតក្បត់ដណ្តើមរាជសម្បត្តិ ។ ទីឃការាយនៈ ឆក់យកឱកាសនោះនាំគ្រឿងរាជកកុធភ័ណ្ឌ ដែលជាសញ្ញាសម្គាល់

របស់ព្រះមហាក្សត្រ ទៅថ្វាយដល់ **វិឌូឌភៈ** ព្រះរាជឱរសរបស់ព្រះបាទបសេនទិកោសល ជាមួយនាងវាសភខត្តិយា តែងតាំងវិឌូឌភៈឱ្យជាព្រះរាជា សល់ត្រឹមតែសេះមួយក្បាល និងទាសីម្នាក់ ទុកឱ្យព្រះបាទបសេនទិកោសល ។

ព្រះបាទបសេនទិកោសល យាងចេញមកពីព្រះគន្ធកុដិ មិនឃើញទីឃ-ការាយនៈ ដឹងហេតុការណ៍អំពីនាងទាសីនោះហើយ ទើបយាងទៅក្រុងរាជគ្រឹះ ដើម្បីសូមកម្លាំងអំពីព្រះបាទអជាតសត្រូវទៅជួយ កាលយាងដល់នគររាជគ្រឹះ ជាពេលដែលបិទទ្វារនគរហើយ ទើបយាងចូលផ្ទំនៅក្នុងសាលាសំណាក់មួយ ព្រោះតែទ្រង់ព្រះជរាហើយ ប្រកបដោយការនឿយហត់ក្នុងការធ្វើដំណើរ ព្រះបាទបសេនទិកោសល សោយទិវង្គតក្នុងសាលាសំណាក់នោះឯង ។

**ព្រះបាទវិឌូឌភៈ** កាលចម្រើនវ័យបានទទួលតំណែងជាសេនាបតី ដល់ព្រះជន្ម ១៦ ព្រះកុមារយាងទៅសួរសុខទុក្ខសក្យត្រកូល មហាថ្លឹកដែលតាមទៅបានឮពាក្យរបស់ទាសីម្នាក់និយាយថា នេះជាអាសនៈបុត្ររបស់នាងទាសីវាស-ភខត្តិយាអង្គុយ ហើយយកទឹកលាយទឹកដោះស្រស់លាងអាសនៈនោះ មហាថ្លឹកត្រឡប់មកទូលឱ្យដឹង ទើបព្រះបាទវិឌូឌភៈពោលថា កាលបើយើងបានឡើងគ្រងរាជសម្បត្តិហើយ នឹងត្រឡប់មកយកឈាមរបស់សក្យៈទាំងឡាយលាងអាសនៈឱ្យទាល់តែបាន ។

លុះបានសោយរាជសម្បត្តិហើយ ទើបព្រះបាទវិឌូឌភៈលើកកងទ័ពទៅដើម្បីកម្ចាត់ពួកសក្យទាំងអស់ សូម្បីតែទារកដែលនៅបៅដោះក៏មិនទុក វៀរតែ

ព្រះមហានាមជាជីតាប៉ុណ្ណោះ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រះបាទវិឌូឌភៈ ទ្រង់លើកទ័ពមក បានយាងទៅហាមជាច្រើនលើក ទីបំផុតទ្រង់ឃើញបុព្វកម្ម របស់ពួកសក្យៈ ដែលធ្លាប់នាំគ្នាបាចថ្នាំពិសសម្លាប់សត្វតាមមកទាន់ ទើបមិន យាងទៅហាម ស្ដេចវិឌូឌភៈដឹងថាពួកសក្យៈមិនសម្លាប់សត្វ ក៏ចាប់ពួកសក្យៈ សម្លាប់អស់ជាច្រើន នៅសល់តែមហានាម និងអ្នកដែលមិនមានកម្មពៀរ ឈាម របស់ពួកសក្យៈបានហូរដូចជាទឹកស្ទឹង ។

នៅពេលយាងត្រឡប់មកនគរសាវត្ថីវិញ មកដល់ស្ទឹងអចិរវតីក្នុងវេលា យប់ ព្រះបាទវិឌូឌភៈបញ្ជាឱ្យតាំងបន្ទាយស្នាក់នៅ ពលទាំងនោះពួកខ្លះមានកម្ម ក្រាស់ ដេកត្រង់ឆ្នេរខ្សាច់មាត់ស្ទឹង ចំណែកពួកដែលមានកម្មស្រាលក៏ឡើងទៅ ដេកក្នុងទីខ្ពស់ យប់នោះមានភ្លៀងធ្លាក់ខ្លាំង ទឹកហូរជោរជន់ដែលមិនអាចគេច ទាន់ ធ្វើឱ្យព្រះបាទវិឌូឌភៈផ្ទុំត្រង់ឆ្នេរខ្សាច់មាត់ស្ទឹង អស់ព្រះជន្មព្រមដោយ បរិវារ ត្រូវទឹកបន្សាត់យកទៅកាន់មហាសមុទ្រ ជាចំណីរបស់ត្រី និងអណ្ដើក ក្នុងទឹកនោះឯង ។

## នៅរយៈពេលប្រហែលជាវស្សាទី ៤៣

( ៩ ) ក្រៅពីគោលអាងក្នុងទីគ្រប់កន្លែង ដែលពោលថា **ព្រះយសោធរាថេរី** បរិនិព្វានក្នុងព្រះជន្មាយុ ៧៨ គឺបរិនិព្វាមុនព្រះពុទ្ធអង្គ ២ ឆ្នាំ មិនឃើញ មានក្នុងទីដទៃណាទៀត ដូច្នោះទើបសន្និដ្ឋានថា ព្រះយសោធរាថេរីបរិនិព្វាន ក្នុងព្រះវស្សាទី ៤៣ នេះ ។

ក្នុងខុទ្ទកនិកាយ អបទាន ត្រង់យសោធរាថេរីបទាន ពោលទុកថា **ព្រះយសោធរាថេរី** ចូលគាល់ក្រាបទូលលាព្រះអង្គថា ខ្ញុំម្ចាស់នឿយណាយក្នុងសង្សារវដ្តទើបចេញបួស ខ្ញុំម្ចាស់មានញាណក្នុង **អត្ថៈ ធម្មៈ និរុត្តិ និង បដិភាណ** កើតឡើងក្នុងសំណាក់របស់ព្រះអង្គ ខ្ញុំម្ចាស់ដុតកិលេសទាំងឡាយហើយ ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ខ្ញុំម្ចាស់បានធ្វើស្រេចហើយ កម្មទាំងពួងជាចំណែកអតីតៈ បច្ចុប្បន្ន និងអនាគតរបស់ខ្ញុំម្ចាស់អស់ទៅហើយ ឥឡូវនេះ ខ្ញុំម្ចាស់មានអាយុ ៧៨ ឆ្នាំ ឆ្លងចូលបច្ឆិមវ័យហើយ ខ្ញុំម្ចាស់សូមថ្វាយបង្គំព្រះយុគលបាទ ទូលលាបរិនិព្វាន កាលខ្ញុំម្ចាស់ត្រាច់រង្គាត់ក្នុងវដ្តសង្សារ បើមានសេចក្តីភ្លាំងភ្លាត់យ៉ាងណាចំពោះព្រះអង្គ សូមទ្រង់ប្រោសអត់ទោសនោះ ដល់ខ្ញុំម្ចាស់ផង ។

ក្រៅពីនោះ ក៏មិនមានអធិប្បាយលម្អិតថា ព្រះថេរីទូលលាបរិនិព្វាន ខណៈដែលព្រះពុទ្ធអង្គទ្រង់គង់នៅក្នុងទីណា និងក្រោយពីថ្វាយការបូជាព្រះសពហើយ អដ្ឋិធាតុរបស់ព្រះថេរីតម្កល់ទុកក្នុងទីណា មិនមានទាំងអស់ ។

## នៅក្នុងព្រះវស្សាទី ៤៤

( ១០ ) ទ្រង់គង់ចាំព្រះវស្សាក្នុងក្រុងសាវត្ថី ទ្រង់សម្តែងធម្មទេសនាដល់ភិក្ខុទាំងឡាយក្នុងវត្តជេតពន មានជាច្រើនសូត្រ ដូចជា :

- **វិតក្កសណ្ឋានសូត្រ** ពោលអំពីខេត្តដែន និងអារម្មណ៍របស់អកុសលវិតក្កៈ

-**មហាទុក្ខខន្ធសូត្រ** ពោលអំពីទោសរបស់កាម និងទោសរបស់រូប

-**ធម្មទាយាទសូត្រ** ពោលអំពីធម្មទាយាទ អាមិសទាយាទ និងមជ្ឈិមាបដិបទា

-**អស្សាទសូត្រ** ពោលអំពីគុណទោស និងគ្រឿងរលាស់ចេញនៃខន្ធ ៥

-**វត្ថូបមសូត្រ** ពោលអំពីកាលចិត្តសៅហ្មង ទុគ្គតិក៏រមែងប្រាកដ

-**និវាបសូត្រ** ពោលអំពីសមណព្រាហ្មណ៍ ៤ ប្រភេទ

-**វម្មិកសូត្រ** ពោលអំពីកុមារកស្សបទូលសួរបញ្ហារបស់ទេវតា ១៥ ចំណុច

-**រាជសូត្រ** ពោលអំពីគុណធមិរបស់ព្រះអរិយសាវ័ក

-**សក្ការសូត្រ** ពោលអំពីការបានពាល់ត្រូវព្រះនិព្វាន

-**គណកមោគ្គល្លានសូត្រ** ពោលអំពីធមិ ៧ ប្រការដែលគួរបដិបត្តិដោយលំដាប់

ក្រៅពីនោះ នៅមានត្រាស់ព្រះសូត្រដទៃៗ ជាច្រើនទៀត ។

សម័យនោះ ខណៈដែលព្រះមានព្រះភាគគង់នៅវត្តជេតពន កាលបឋមយាមកន្លងទៅហើយ ទេវបុត្តឈ្មោះ **ហត្ថកៈ** មានរស្មីដ៏ល្អញ៉ាំងវត្តជេតពនទាំងអស់ឱ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ តាំងចិត្តថានឹងឈរគាល់ចំពោះព្រះភក្ត្រព្រះមានព្រះភាគ តែកាយរបស់ទេវបុត្តរមែងលិចចុះ មិនអាចតាំងនៅបាន ប្រៀបដូចទឹកដោះថ្លា ឬប្រេងដែលគេស្រោចចុះលើខ្សាច់ រមែងជ្រាបបាត់ទៅមិនតាំងនៅ យ៉ាងណាមិញ កាយរបស់ហត្ថកទេវបុត្តក៏ដូច្នោះ ។

លំដាប់នោះ ព្រះមានព្រះភាគត្រាស់ជាមួយហត្ថកទេវបុត្តថា ម្នាល-

ហត្ថកៈ អ្នកចូរនិម្មិតកាយឱ្យគ្រោតគ្រាត ហត្ថកទេវបុត្តនិម្មិតកាយឱ្យគ្រោតគ្រាតហើយ ថ្វាយបង្គំព្រះពុទ្ធអង្គ ឈរគាល់ក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលហត្ថកៈ ធម៌ណាដែលអ្នកធ្លាប់ប្រព្រឹត្តកាលនៅជាមនុស្ស ធម៌នោះ ឥឡូវនេះអ្នកនៅតែប្រព្រឹត្តឬ ?

ហត្ថកទេវបុត្តទូលឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ណាដែលខ្ញុំព្រះអង្គធ្លាប់ប្រព្រឹត្តកាលនៅជាមនុស្ស សូម្បីឥឡូវនេះ ខ្ញុំព្រះអង្គក៏នៅតែប្រព្រឹត្ត និងខ្ញុំព្រះអង្គប្រព្រឹត្តធម៌ដែលមិនធ្លាប់ប្រព្រឹត្ត កាលនៅជាមនុស្សថែមទៀតផង ក្នុងបច្ចុប្បន្ន ព្រះមានព្រះភាគមានកេរ្តិ៍ឈ្មោះ ដេរដាស់ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា រាជមហាមាត្យ តិរ្ថិយ៍ សាវ័កតិរ្ថិយ៍ ដូចម្តេចខ្ញុំព្រះអង្គក៏មានកិត្តិយសដោយពួកទេវបុត្តដូច្នោះ ទេវបុត្តទាំងឡាយនាំគ្នាមកពីទីឆ្ងាយៗ តាំងចិត្តនឹងស្តាប់ធម៌ក្នុងសំណាក់របស់ខ្ញុំព្រះអង្គ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅមិនទាន់ឆ្អែត នៅមិនទាន់នឿយណាយក្នុងការឃើញព្រះអង្គ ក្នុងការស្តាប់ព្រះសទ្ធម្ម និងការឧបដ្ឋាកព្រះសង្ឃឡើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅមិនទាន់ឆ្អែត នៅមិនទាន់ធុញទ្រាន់ក្នុងធម៌ ៣ ប្រការនោះ ក៏អស់ជីវិតទៅ ។

ហត្ថកទេវបុត្ត នៅមិនទាន់ឆ្អែតក្នុងធម៌ ៣ ប្រការ ត្រឡប់មកពីអវិហាព្រហ្មលោក មកគាល់ព្រះមានព្រះភាគក្នុងព្រះវិហារជេតវនារាម ដោយប្រការដូច្នេះ ។

# ក្រោយអំពីចេញព្រះវស្សាទី ៤៤

( ១១ ) ក្នុងជេតវនវិហារ ព្រះសារីបុត្រ ចូលទៅធ្វើវត្តថ្វាយព្រះពុទ្ធអង្គ ហើយក៏សម្រាកពេលថ្ងៃ អង្គុយសមាធិចូលផលសមាបត្តិ ចេញពីផលសមាបត្តិ កើតបរិវិតក្កថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយបរិនិព្វានមុន ឬអគ្គសាវ័កបរិនិព្វានមុន ដឹងថាព្រះអគ្គសាវ័កបរិនិព្វានមុន ទើបពិចារណាមើលអាយុសង្ខាររបស់ខ្លួន ដឹងថានឹងប្រព្រឹត្តទៅបានត្រឹម ៧ ថ្ងៃទៀតប៉ុណ្ណោះ ។ ទើបលោកត្រិះរិះថា ព្រះរាហុលបរិនិព្វានក្នុងឋានតាវត្តិង្ស ព្រះអញ្ញាកោណ្ឌញ្ញៈបរិនិព្វានឯស្រះមណ្ឌាកិណីព្រៃឆទ្ទន្ត យើងនឹងបរិនិព្វានទីណា លោកកើតសតិប្រារព្ធមាតាឡើងថា មាតារបស់យើងសូម្បីជាមាតារបស់ព្រះអរហន្តដល់ទៅ ៧ អង្គ តែមិនទាន់ជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ពិចារណាឃើញថា មាតាមានឧបនិស្ស័យនឹងសម្រេចដោយទេសនារបស់យើង បើយើងមិនខ្វល់ខ្វាយប្រោសមាតា ជនទាំងឡាយនឹងពោលថា ព្រះសារីបុត្រជាទីពឹងដល់ពួកជនដទៃ តែមិនអាចនឹងកម្ចាត់ការយល់ខុសរបស់មាតាបាន ទើបមានបំណងទៅបរិនិព្វានក្នុងបន្ទប់ដែលលោកប្រសូតិ ដើម្បីដោះមាតាពីមិច្ឆាទិដ្ឋិ ។

ព្រះសារីបុត្រ ត្រិះរិះថា នឹងចូលទៅទូលលាព្រះពុទ្ធអង្គក្នុងថ្ងៃនេះ ទើបហៅព្រះចុន្ទត្ថេរជាប្អូនឱ្យប្រាប់ដល់ភិក្ខុបរិស័ទ ៥០០ រូបថា យើងនឹងទៅនាឡក-គ្រាម ភិក្ខុទាំងនោះរៀបចំសេនាសនៈ បោសសម្អាតទីសម្រាកពេលថ្ងៃរួច មកកាន់សំណាក់របស់ព្រះថេរៈ ។ ព្រះសារីបុត្រនាំភិក្ខុទាំង ៥០០ រូប ចូលទៅ

ក្រាបទូលលាព្រះពុទ្ធអង្គថា បពិត្រព្រះមហាមុនីលោកនាថជាម្ចាស់ ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំលាជាគ្រាចុងក្រោយ ជីវិតរបស់ខ្ញុំព្រះអង្គតិច កន្លងទៅ ៧ ថ្ងៃទៀត ខ្ញុំព្រះអង្គនឹងបោះបង់ផ្ទះ គឺអត្តភាព សូមព្រះមានព្រះភាគទ្រង់មេត្តាអនុញ្ញាត សូមព្រះសុគតប្រោសអនុញ្ញាតដល់ខ្ញុំព្រះអង្គផង នេះជាវេលាបរិនិព្វានខ្ញុំព្រះអង្គនឹងអស់អាយុសង្ខារហើយ ព្រះអង្គ ។

ព្រះមានព្រះភាគត្រាស់សួរថា អ្នកនឹងបរិនិព្វានទីណា កាលព្រះសារីបុត្រក្រាបទូលថា នឹងបរិនិព្វានក្នុងបន្ទប់ដែលខ្ញុំព្រះអង្គប្រសូតិក្នុងនាឡកគ្រាម ទើបត្រាស់ថា ម្នាលសារីបុត្រ ឥឡូវនេះ អ្នកចូរសម្គាល់កាលដ៏គួរចុះ ការដែលបងប្អូនរបស់អ្នកបានឃើញភិក្ខុប្រកបដោយគុណដូច្នេះ រកបានកម្រ ព្រោះហេតុដូច្នោះ អ្នកចូរសម្តែងធមិដល់បងប្អូនទាំងនោះផង ។

ព្រះថេរៈដឹងថា ព្រះសាស្តាបំណងឱ្យសម្តែងឫទ្ធិផ្សេងៗ មុននឹងសម្តែងធមិ ទើបព្រះថេរៈសម្តែងឫទ្ធិផ្សេងៗ ហើយសម្តែងធមិ ចុះមកថ្វាយបង្គំព្រះមានព្រះភាគ ក្រាបទូលថា ដល់ពេលទៅរបស់ខ្ញុំព្រះអង្គហើយ នេះជាការឃើញចុងក្រោយ នឹងមិនមានការឃើញព្រះអង្គទៀតឡើយ ព្រះថេរៈធ្វើប្រទក្សិណផ្គងអញ្ជលីហើយ ឆ្ពោះមុខត្រឡប់ទៅរហូតផុតទស្សនវិស័យ ព្រះមានព្រះភាគជាម្ចាស់ត្រាស់នឹងភិក្ខុដែលឈរហែហមថា ពួកអ្នកចូរតាមទៅជូនដំណើរបងប្រុសរបស់ពួកអ្នកចុះ ពួកភិក្ខុទាំងឡាយ នាំគ្នាជូនដំណើរទៅរហូតដល់ស៊ុំទ្វារព្រះថេរៈពោលថា បានហើយអ្នកមានអាយុ ពួកអ្នកចូរជាអ្នកមិនប្រមាទចុះ ។

ព្រះសារីបុត្រធ្វើដំណើរទៅនាឡកគ្រាម ជាមួយព្រះចុន្ទៈជាប្អូនប្រុស និងពួកភិក្ខុជាបរិវារ លុះដល់ផ្ទះហើយក៏កើតបក្ខន្ទិកាពាធ ធ្លាក់ឈាម យប់នោះក្នុងពេលដែលអាពាធធ្ងន់ ស្តេចមហាព្រហ្ម ស្តេចមហារាជ សក្កទេវរាជមកសួរសុខទុក្ខ ញោមស្រីឃើញដូច្នោះ ទើបគិតថា កូនយើងមានសក្តិធំដូច្នេះ សូម្បីតែស្តេចមហាព្រហ្មជាសាស្តារបស់យើងក៏មកសួរសុខទុក្ខដែរ ហើយព្រះសាស្តារបស់កូនយើង នឹងមានអានុភាពធំក្រៃលែងជាងដូចម្តេចទៅ !...

ព្រះសារីបុត្រជ្រាបថា ញោមស្រីមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធអង្គហើយ ទើបពណ៌នាគុណរបស់បរមសាស្តាថា ឈ្មោះថា អ្នកដែលស្មើដោយសីល សមាធិ បញ្ញា និងវិមុត្តិញ្ញាណទស្សនៈ ប្រៀបធៀបហ្នឹងព្រះពុទ្ធអង្គមិនមានឡើយ ហើយសម្តែងព្រះធម៌ទេសនាប្រកបដោយព្រះពុទ្ធគុណថា ឥតិបិសោ ភគវា..... យ៉ាងនេះជាដើម ក្នុងវេលាចប់ព្រះធម្មទេសនា នាងព្រាហ្មណីបានសម្រេចសោតាបត្តិផល ផុតចាកមិច្ឆាទិដ្ឋិ នេះជាការតបគុណមាតាក្នុងវារៈ ចុងបំផុតរបស់លោក ។

ពេលជិតភ្លឺ ព្រះសារីបុត្រឱ្យព្រះចុន្ទៈហៅប្រជុំភិក្ខុសង្ឃ ដែលមកតាមព្រះចុន្ទៈគ្រាប់ឱ្យគង់ បន្ទាប់ពីនោះព្រះសារីបុត្របានពោលនឹងភិក្ខុទាំងឡាយថា អ្នកដ៏មានអាយុ ពួកអ្នកនៅជាមួយខ្ញុំអស់ ៤៤ ឆ្នាំហើយ បើមានការមិនគប្បីយ៉ាងណាមួយ តាមផ្លូវកាយវាចារបស់ខ្ញុំ សូមអ្នកមានអាយុអត់ទោសនោះដល់ខ្ញុំផងចុះ ។ ភិក្ខុទាំងឡាយពោលថា លោកម្ចាស់ រាល់ពេលដែលពួកយើងខ្ញុំ

ជាប់តាមលោកដូចស្រមោល ឈ្មោះថា កម្មដែលមិនគាប់ចិត្តមិនមានដល់ពួកយើងខ្ញុំឡើយ តែបើពួកយើងខ្ញុំបានធ្វើកាយវាចា ដែលមិនគាប់ចិត្តលោកម្ចាស់ សូមលោកម្ចាស់ ប្រោសអត់ទោសនោះដល់ពួកយើងខ្ញុំផង ។

កាលពន្លឺអរុណប្រាកដឡើង ព្រះសារីបុត្រក៏បរិនិព្វានដោយអនុបាទិសេសនិព្វានក្នុងថ្ងៃ ១៥ កើត ខែកត្តិក នាងសារីជាញោមស្រីចូលទៅច្របាច់ខ្នងជើង ទើបដឹងថា លោកធ្វើមរណកាលហើយ ទេព្តា និងមនុស្សជាច្រើននាំគ្នាធ្វើសក្ការៈក្នុងទីស្ថានបរិនិព្វាន ពួកមហាជននាំគ្នាធ្វើជើងថ្ករដោយឈើក្រអូប ធ្វើឈាបនកិច្ចសរីរៈរបស់លោក ក្រោយពីឈាបនកិច្ចស្រេចបាច់ហើយ ព្រះចុន្ទវិសេសអដ្ឋិធាតុ និងបរិក្ខាររបស់ព្រះសារីបុត្រ នាំទៅថ្វាយព្រះសាស្តាដែលពេលនោះ ទ្រង់គង់នៅក្នុងវត្តជេតពនក្រុងសាវត្ថី ព្រះអង្គប្រោសឱ្យសាងស្តូបតម្កល់អដ្ឋិធាតុរបស់ព្រះសារីបុត្រទុក ក្នុងវិហារជេតវនារាម ។

ព្រះសារីបុត្រ ជាអគ្គសាវ័កស្តាំរបស់ព្រះពុទ្ធអង្គ ជាអ្នកមានបញ្ញាច្រើន ជាកម្លាំងដ៏សំខាន់របស់ព្រះបរមសាស្តា ក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា ព្រះអង្គទ្រង់លើកតម្កើងថា ជាកំពូលជាងភិក្ខុទាំងឡាយ ផ្នែកខាងបញ្ញា លោកជាអ្នកមានបដិភាណក្នុងការសម្តែងព្រះធម្មទេសនា អាចសម្តែងធម៌ឱ្យទូលំទូលាយពិស្តារ ដូចជាព្រះពុទ្ធអង្គ ទើបមានពាក្យហៅលើកតម្កើងលោកម្យ៉ាងទៀតថា **ព្រះធម្មសេនាបតី** ។

**បន្ទាប់ពីនោះ ទ្រង់យាងចារិកទៅកាន់ក្រុងរាជគ្រឹះ ទ្រង់គង់ក្នុងវត្តវេឡុវ័ន**

( ១២ ) ព្រះមហាមោគ្គល្លានត្ថេរ ជាអគ្គសាវ័កឆ្វេងរបស់ព្រះពុទ្ធអង្គ ជាកម្លាំងដ៏សំខាន់របស់ព្រះបរមសាស្ដា ក្នុងការជួយឧបត្ថម្ភឱ្យព្រះពុទ្ធតម្រិះសម្រេច ព្រោះលោកជាអ្នកមានឫទ្ធានុភាពច្រើន បានទទួលលើកតម្កើងពីព្រះពុទ្ធអង្គថា ជាគូអគ្គសាវ័កក្នុងការឱ្យឧបការៈដល់ភិក្ខុ អ្នកចូលមកបួសក្នុងធម្មវិន័យ រហូតបានទទួលការលើកតម្កើងប្រៀបធៀប អំពីព្រះពុទ្ធអង្គថា ព្រះសារីបុត្រប្រៀបដូចមាតាអ្នកបង្កើតកូន ព្រះមោគ្គល្លានប្រៀបដូច មេដោះអ្នកចិញ្ចឹមទារកដែលកើតហើយ គឺព្រះសារីបុត្ររមែងណែនាំឱ្យតាំងនៅក្នុងសោតា-បត្តិផល ព្រះមោគ្គល្លានរមែងណែនាំឱ្យតាំងនៅក្នុងគុណ ដែលខ្ពស់ក្រៃលែងឡើង ។

មុនបរិនិព្វាន លោកស្នាក់នៅកាឡសិលានិគម ក្នុងដែនមគធៈ ពួកតិត្ថិយ៍ប្រឹក្សាគ្នាថា លាភសក្ការៈទាំងឡាយដែលកើតឡើងដល់ព្រះសមណគោតម ក៏ដោយអាស្រ័យព្រះមោគ្គល្លានត្ថេរ ព្រោះលោកអាចនាំដំណឹងអំពីស្ថានសួគ៌ និងនរកមកប្រាប់ដល់មនុស្ស ដឹកនាំមនុស្សឱ្យកើតសេចក្ដីជ្រះថ្លា បើពួកយើងកម្ចាត់ព្រះមោគ្គល្លានត្ថេរបាន លាភសក្ការៈរបស់ពួកយើងក៏នឹងរុងរឿងឡើង ទើបបានជួលពួកចោរឱ្យទៅសម្លាប់ព្រះថេរៈ ។

ព្រះមហាមោគ្គល្លានដឹងហេតុ គេចពួកចោរបានច្រើនដង ទីបំផុតលោកពិចារណាឃើញថា កម្មចាស់តាមមកទាន់ហើយ ទើបមិនគេចព្រមឱ្យពួកចោរវាយកម្ទេចរាងកាយខ្ទេច ពួកចោរសម្គាល់ថា ព្រះថេរៈអស់ជីវិតហើយ ក៏បោះ

ចោលរាងកាយរបស់លោកចូលទៅក្នុងគុម្ពឈើមួយ ហើយគេចទៅ ។ ព្រះមហាមោគ្គល្លានមិនទាន់ធ្វើមរណកាល រក្សាអត្តភាព ប្រមូលឆ្អឹងដែលបែកល្អិតឱ្យតាំងឡើងដោយអំណាចនៃឈាន ហើយចូលទៅគាល់ព្រះមានព្រះភាគថ្វាយបង្គំលាបរិនិព្វាន ។

ព្រះមានព្រះភាគត្រាស់សួរថា អ្នកនឹងបរិនិព្វានក្នុងទីណា ព្រះមោគ្គល្លានត្ថេរក្រាបទូលថា ក្នុងកាឡសិលានិគម ដែនមគធៈ ព្រះអង្គ, ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលមោគ្គល្លាន បើដូច្នោះអ្នកចូរសម្តែងធម៌ដល់តថាគតសិន ព្រោះថាឥឡូវនេះ តថាគតនឹងមិនបានឃើញសាវ័កប្រាកដដូចជាអ្នកនេះតទៅទៀតឡើយ ។ ព្រះមោគ្គល្លានត្ថេរ ថ្វាយបង្គំព្រះសាស្តា ហើយសម្តែងឫទ្ធានុភាពផ្សេងៗ ដូចជាព្រះសារីបុត្រក្នុងថ្ងៃនឹងបរិនិព្វានដែរ សម្តែងធម៌ស្រេចហើយ ត្រឡប់ចុះមកថ្វាយបង្គំលាព្រះមានព្រះភាគជាម្ចាស់ ទៅបរិនិព្វានក្នុងកាឡសិលានិគម ក្នុងថ្ងៃ ១៥ រោច ខែកត្តិក ព្រះអង្គយាងទៅធ្វើឈាបនកិច្ចហើយ មានព្រះតម្រាស់ឱ្យរើសអដ្ឋិធាតុមកតម្កល់ទុកក្នុងស្តូប ក្បែរស៊ុំទ្វារវត្តវេឡុវ័ន ។

( ១៣ ) បន្ទាប់ពីនោះ ព្រះអង្គយាងទៅគង់នៅភ្នំគិជ្ឈកូដ រយៈពេលនោះ **ព្រះបាទអជាតសត្រូវ** បំណងនឹងរួមដែនវជ្ជីមកទុកក្នុងអំណាច ទើបបញ្ជូន វស្សការព្រាហ្មណ៍ទៅគាល់ព្រះពុទ្ធអង្គ ទូលសួរថា ព្រះបាទអជាតសត្រូវប្រាថ្នា យាងទៅបង្ក្រាបដែនវជ្ជី តើព្រះអង្គទ្រង់ព្យាករណ៍ដូចម្តេច ? ព្រះមាន

ព្រះភាគ ត្រាស់ថា ដរាបណាដែនវជ្ជីតាំងនៅក្នុង **អបរិហានិយធម៌ ៧ ប្រការ** ដែលតថាគតធ្លាប់សម្តែងទុកហើយ ដរាបនោះអ្នកដែនវជ្ជីក៏មានតែសេចក្តីចម្រើន មិនមានសេចក្តីសាបសូន្យ មិនមានអ្នកណាអាចបំបែកដែនវជ្ជីបាន វស្សការ-ព្រាហ្មណ៍កាលបានស្តាប់ហើយគិតថា ព្រះបាទអជាតសត្រូវមិនមានផ្លូវដែលនឹងយកឈ្នះដែនវជ្ជីបាន ក្រៅអំពីរកវិធីញុះញង់ឱ្យបែកសាមគ្គីគ្នាប៉ុណ្ណោះ ទើបត្រឡប់មកក្រាបទូលឱ្យព្រះបាទអជាតសត្រូវជ្រាប ទើបព្រះរាជាបញ្ជូនវស្សការ-ព្រាហ្មណ៍ឱ្យជាសត្រូវ ចូលទៅរកឧបាយធ្វើឱ្យពួកក្សត្រលិច្ឆវីបែកបាក់សាមគ្គីគ្នា ដោយការញុះញង់ឱ្យរាជកុមារទាំងឡាយ មានការរង្កៀសគ្នានិងគ្នា បន្ទាប់មកក៏ពង្រីកវង្សចេញទៅ រហូតដល់ព្រះរាជវង្សានុវង្សធំៗ និងបណ្តាជនវជ្ជីទាំង-ឡាយ វស្សការព្រាហ្មណ៍ត្រូវប្រើពេលដល់ ៣ ឆ្នាំ ទើបសម្រេចផលបាន ។

ក្រោយពីវស្សការព្រាហ្មណ៍ត្រឡប់ទៅហើយ ព្រះអង្គត្រាស់ហៅភិក្ខុមកប្រជុំគ្នាក្នុងឧបដ្ឋានសាលា ទ្រង់សម្តែងភិក្ខុអបរិហានិយធម៌ គឺធម៌ដែលធ្វើឱ្យកើតសេចក្តីព្រមព្រៀមគ្នាក្នុងសង្ឃថា :

**១. ចូរព្យាយាមប្រជុំគ្នារឿយ ៗ**

**២. ចូរព្រមព្រៀងគ្នាប្រជុំ**

**៣. នឹងមិនបញ្ញត្តសិក្ខាបទដែលមិនបានបញ្ញត្តទុក និងមិនដក សិក្ខាបទដែលតថាគតបញ្ញត្តហើយ**

**៤. នឹងសក្ការៈគោរពរាប់អាន ស្តាប់ភិក្ខុជាថេរៈ**

**៥. នឹងមិនលុះក្នុងអំណាចរបស់តណ្ហាដែលកើតឡើង**

**៦. នឹងត្រេកអរចំពោះសេនាសនៈក្នុងព្រៃ**

**៧. ចូរតាំងចិត្តថា បណ្តាភិក្ខុសាមណេរជាអ្នកមានសីល មិនទាន់មក សូមឱ្យមក ដែលមកហើយសូមឱ្យនៅជាសុខ**

ម្នាលភិក្ខុទាំងឡាយ បើពួកអ្នកនៅព្រមព្រៀងគ្នាក្នុងអបរិហានិយធម៌ ៧ ប្រការនេះ ដរាបណា ភិក្ខុទាំងឡាយនឹងមានតែសេចក្តីចម្រើន មិនមានសេចក្តីសាបសូន្យដរាបនោះ ។

( ១៤ ) យាងទៅកាន់ **អម្ពលដ្ឋិកា** ទ្រង់សម្តែងសីល សមាធិ បញ្ញា និងវិមុត្តិដល់ភិក្ខុទាំងឡាយ បន្ទាប់មកទ្រង់យាងទៅកាន់ដែន **នាលន្ទា** ទ្រង់គង់នៅបាវារិកម្ពវ័ន ក្នុងទីនោះទ្រង់សម្តែងសីល សមាធិ បញ្ញា និងវិមុត្តិដល់ភិក្ខុទាំងឡាយដែលជាប់តាមទៅ និងទ្រង់ប្រារព្ធដល់ព្រះសារីបុត្រថា ធ្លាប់បានពោលវាចាសម្តែងដល់សេចក្តីជ្រះថ្លាយ៉ាងក្រៃលែងក្នុងតថាគត ដោយពាក្យពេចន៍ថា ទាំងក្នុងអតីតៈ បច្ចុប្បន្ន និងអនាគត នឹងមិនមានអ្នកណាមានបញ្ញាដឹងក្រៃលែងជាងក្នុងព្រះសម្មាសម្ពោធិញាណ ដូចជាព្រះតថាគត ។

បន្ទាប់ពីនាលន្ទា យាងចារិកទៅកាន់ **បាដលិគ្រាម** កាលយាងទៅដល់ ឧបាសកនៅដែនបាដលិគ្រាមនាំគ្នាចូលទៅគាល់ ដើម្បីទូលថ្វាយសាលា ព្រះពុទ្ធអង្គទ្រង់ទទួលដោយតុណ្ហីភាព កាលព្រះអង្គចូលគង់ប្រថាប់ព្រមដោយភិក្ខុ-សង្ឃហើយ ឧបាសកនៅបាដលិគ្រាម ក៏ចូលទៅតាមដើម្បីស្តាប់ធម៌ ព្រះសាស្តា

ទ្រង់សម្ដែងទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្ដសីល ៥ ប្រការ អានិសង្សនៃសីលសម្បត្តិរបស់បុគ្គលមានសីល ៥ ប្រការ និងសម្ដែងធម្មីកថាដ៏ច្រើនទៀត ហើយទ្រង់មានព្រះតម្រាស់ថា ម្នាលគហបតីទាំងឡាយ រាត្រីកន្លងទៅហើយ អ្នកចូរសម្គាល់កាលដ៏គួរចុះ កាលឧបាសកនៅបាដលិគ្រាមគេចចេញទៅហើយ ព្រះពុទ្ធអង្គ យាងចូលទៅកាន់សុញ្ញាគារ ។

លុះព្រឹកឡើង ព្រះមានព្រះភាគត្រាស់នឹងព្រះអានន្ទថា បាដលិគ្រាមនេះ ក្នុងអនាគតនឹងក្លាយជារាជធានីរបស់មគធៈឈ្មោះ **បាដលិបុត្រ** នឹងមានសេចក្ដីចម្រើនរុងរឿង ដែននេះនឹងជាដែនដ៏កំពូលនៃទីប្រជុំជន របស់ពួកមនុស្សជាអរិយៈ តែក្នុងកាលតទៅអន្តរាយនឹងកើតដល់ដែនបាដលិបុត្រ ដោយហេតុណាមួយ គឺអំពីភ្លើង អំពីទឹក ឬអំពីការបែកបាក់សាមគ្គីគ្នា។ ក្នុងទីនោះ មហាមាត្យនៃដែនមគធៈ ២ នាក់ គឺ ***សុនីធៈ និងវស្សការ*** ដែលមកមើលការកសាងបាដលិគ្រាមទុកការពារសម្រាប់ការរុករានអំពីនគរវជ្ជី បានក្រាបទូលនិមន្តព្រះសាស្ដា និងភិក្ខុសង្ឃសោយភត្តាហារក្នុងទីលំនៅរបស់ខ្លួន ក្រោយភត្តកិច្ច ព្រះអង្គទ្រង់សម្ដែងអានិសង្សរបស់ការឱ្យទាន ហើយត្រាស់អនុមោទនាដោយព្រះគាថាថា :

**បណ្ឌិតកាលនៅក្នុងទីណា គប្បីអញ្ជើញលោកអ្នកមានសីល**
**ដែលសង្រួមហើយ ប្រព្រឹត្តព្រហ្មចរិយៈ ឱ្យបរិភោគក្នុងទីនោះ**
**គួរឧទ្ទិសទក្ខិណាទាន ដើម្បីទេវតាដែលឋិតនៅក្នុងទីនោះ ។**

**ទេវតាដែលបណ្ឌិតបូជាហើយ រមែងអនុគ្រោះបណ្ឌិតនោះ ដូចមាតាអនុគ្រោះបុត្រ បុគ្គលដែលទេវតាអនុគ្រោះហើយ រមែងមានសេចក្ដីចម្រើនសព្វកាល ។**

ព្រះអង្គទ្រង់អនុមោទនាហើយ យាងចារិកតទៅ អាមាត្យទាំងពីរជូនដំណើររហូតដល់មាត់ស្ទឹងគង្គា សម័យនោះ ទឹកក្នុងស្ទឹងឡើងពេញមាត់ច្រាំង មនុស្សទាំងឡាយឆ្លងស្ទឹងនោះដោយទូក ឬដោយក្បូន ព្រះសាស្ដាទ្រង់បន្លឺឧទានថា :

**ជនពួកណា ឆ្លងអន្លង់ទឹក សូម្បីទឹកមានប្រមាណតិច រមែងត្រូវអាស្រ័យទូក ឬក្បូនឆ្លងទៅ តែអ្នកមានបញ្ញា ប្រាសចាកទូក ឬក្បូនក៏ឆ្លងបានដោយស្ពាន គឺអរិយមគ្គដ៏ប្រសើរ។**

( ១៥ ) យាងឆ្លងស្ទឹងគង្គាដល់ **ឧក្កចេលជនបទ** ដែនវជ្ជីទ្រង់គង់ក្បែរមាត់ស្ទឹង ទ្រង់សរសើរគុណរបស់អគ្គសាវ័កទាំងពីរ ដោយប្រៀបព្រះអង្គដូចដើមព្រីងធំដែលចាស់ ព្រះអគ្គសាវ័កទាំងពីរដូចមែកព្រីងធំដែលបាក់ធ្លាក់មក ក្រៅពីនោះទ្រង់សម្ដែង **ចូឡគោបាលសូត្រ** ដល់ភិក្ខុទាំងឡាយ សម្ដែងពីសេចក្ដីល្ងង់ខ្លៅរបស់នាយគោបាល ដែលកៀងគោឆ្លងស្ទឹងដោយមិនបានពិចារណា ធ្វើឱ្យហ្វូងគោត្រូវក្រសែទឹកផាត់នាំទៅ រហូតដល់សេចក្ដីស្លាប់ ។

យាងទៅកាន់ **កោដិគ្រាម** ខណៈដែលទ្រង់គង់ក្នុងទីនោះ ព្រះអង្គត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគត និងពួកអ្នកត្រាច់រង្គាត់

វិលវល់អស់កាលយូរយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះ អរិយសច្ច ៤ ហើយត្រាស់ព្រះគាថា ថាៈ

**ព្រោះមិនឃើញអរិយសច្ច ៤ តាមសេចក្ដីពិត ទើបតថាគត**
**និងអ្នកទាំងឡាយវិលវល់ទៅ អស់កាលដ៏យូរលង់ ឥឡូវនេះ**
**អរិយសច្ច ៤ នោះ តថាគតឃើញហើយ តណ្ហាដែលនាំទៅ**
**កាន់ភព តថាគតដកបានហើយ ឫសកែវនៃទុក្ខ តថាគតដក**
**ចោលហើយ ឥឡូវនេះ ភពថ្មីមិនមានសម្រាប់តថាគតឡើយ ។**

ខណៈដែលព្រះមានព្រះភាគទ្រង់ប្រថាប់គង់នៅក្នុង កោដិគ្រាម ទ្រង់សម្ដែងធម្មីកថាដល់ភិក្ខុទាំងឡាយថា សីល សមាធិ និងបញ្ញាមានដោយប្រការដូច្នេះ **សមាធិ** ដែលសីលអប់រំហើយ រមែងមានផលច្រើនមានអានិសង្សច្រើន **បញ្ញា** ដែលសមាធិអប់រំហើយ រមែងមានផលច្រើនមានអានិសង្សច្រើន **ចិត្ត** ដែលបញ្ញាអប់រំហើយ នឹងរួចផុតចាកអាសវៈទាំងឡាយ ។

បន្ទាប់ពីនោះ យាងទៅប្រថាប់គង់ក្នុង នាទិកគ្រាម ទ្រង់សម្ដែងធម៌ឈ្មោះ អាទាស កញ្ចក់ធម៌ជាគោលក្នុងការព្យាករណ៍គតិ គឺសម្បរាយភពរបស់ព្រះអរិយបុគ្គលដល់ព្រះអានន្ទ ព្រះអានន្ទទូលសួរថា ភិក្ខុឈ្មោះនោះ ភិក្ខុនីឈ្មោះនោះធ្វើមរណកាលហើយ ក្នុងនាទិកគ្រាម លោកមានគតិដូចម្ដេច មានភពខាងមុខដូចម្ដេច ព្រះអង្គ ? ប៉ុណ្ណេះជាដើម ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ភិក្ខុឈ្មោះ **សាឡហៈ** ធ្វើឱ្យ

ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ជាអ្នកតាំងនៅក្នុងទិដ្ឋធម្មហើយ ម្នាលអានន្ទ ភិក្ខុនីឈ្មោះ **នន្ទា** មានសំយោជនៈខាងក្រោម ៥ អស់ហើយ បរិនិព្វានក្នុងជាន់សុទ្ធាវាស ជាអ្នកមិនត្រឡប់មកកាន់លោកនេះទៀតឡើយ ក្រៅពីនោះ ទ្រង់បានព្យាករណ៍ឧបាសកទាំងឡាយ ក្នុងស្រុកនាទិកៈជាច្រើនទៀត មានជាដើមថា ឧបាសកក្នុងស្រុកនាទិកៈ ៩៦ នាក់ ធ្វើមរណកាលហើយ ព្រោះសំយោជនៈ ៣ អស់ហើយ ព្រោះរាគៈ ទោសៈ និងមោហៈស្រាលស្តើង ជាសកទាគាមី និងត្រឡប់មកកាន់លោកនេះម្តងទៀតប៉ុណ្ណោះ ហើយនឹងធ្វើទីបំផុតទុក្ខបាន ដូច្នេះជាដើម ។

គ្រានោះ ក្នុងវេលាល្ងាចព្រះមានព្រះភាគជាម្ចាស់ត្រាស់ជាមួយនឹងព្រះអានន្ទថា ខណៈដែលតថាគតព្យាករណ៍គតិរបស់អ្នកស្រុកនាទិកៈ ***ជវនសភយក្ខ*** បានចូលមកគាល់តថាគត បន្លឺសំឡេងថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះថា ***ពិម្ពិសារ*** ខ្ញុំព្រះអង្គបានភាពជាសម្លាញ់របស់ស្តេចវេស្សវ័ណមហារាជ ជាលើកទី ៧ ក្នុងទេវលោក ខ្ញុំព្រះអង្គចុតិចាកទេវលោកហើយ និងជាស្តេចក្នុងពួកមនុស្ស ៧ ជាតិទៀត ។ ម្នាលអានន្ទ ***ជវនសភៈ*** ប្រកាសថា បពិត្រព្រះមានព្រះភាគជាម្ចាស់ ក្រៅអំពីសាសនាព្រះអង្គ ខ្ញុំព្រះអង្គនឹងមិនដឹងការសម្រេចគុណវិសេសដ៏អស្ចារ្យដូច្នេះឡើយ ។ តាំងពីថ្ងៃដែលខ្ញុំព្រះអង្គជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះមានព្រះភាគជាដើមមក ខ្ញុំព្រះអង្គបានដឹងច្បាស់នូវការមិនថោកថយអស់កាលយូរ សេចក្តីប្រាថ្នាដើម្បីជាសកទាគាមី របស់ខ្ញុំព្រះអង្គ

ប្រាកដជាមាន ។

ក្នុងអដ្ឋកថាពោលថា មុនសោយទិវង្គត ព្រះបាទពិម្ពិសារទ្រង់បរិកម្មថា **ពុទ្ធោ ធម្មោ សង្ឃោ** ហើយក៏សោយទិវង្គតទៅ ចាប់តាំងពីថ្ងៃដែលបានជាសោតាបន្នក្នុងលដ្ឋិវ័ន ព្រះរាជាទ្រង់ញ៉ាំងកាលឱ្យកន្លងទៅ ដោយសេចក្តីសង្ឃឹមក្នុងសកទាគាមី បានចម្រើនវិបស្សនាដើម្បីប្រយោជន៍ដល់ព្រះសកទាគាមី ដរាបដល់សោយទិវង្គត ។

បន្ទាប់ពីនោះ ព្រះអង្គទ្រង់សម្តែង **បឋមមរណស្សតិសូត្រ** ពោលអំពីការចម្រើនមរណស្សតិ ដែលមានផលច្រើនដល់ភិក្ខុទាំងឡាយ ត្រាស់សួរភិក្ខុទាំងនោះថា អ្នកចម្រើនមរណស្សតិដូចម្តេច ភិក្ខុមួយរូបទូលថា គប្បីធ្វើទុកក្នុងចិត្តថា **យើងគប្បីរស់នៅបានរហូត មួយថ្ងៃមួយយប់** ភិក្ខុមួយរូបទូលថា **យើងគប្បីរស់នៅអស់រយៈពេលដែលឆាន់បិណ្ឌបាតម្តង** ភិក្ខុមួយរូបទូលថា **យើងគប្បីរស់នៅអស់ពេលត្រឹមតែហុតបបរមួយមាត់** ។

ព្រះមានព្រះភាគត្រាស់ថា សូម្បីដូច្នោះក៏ឈ្មោះថាជាអ្នកប្រមាទ ម្នាលភិក្ខុទាំងឡាយ អ្នកគប្បីសិក្សាយ៉ាងនេះថា **យើងគប្បីរស់នៅបានរយៈពេលត្រឹមតែដកដង្ហើមចូល ហើយនិងចេញ ឬ ដកដង្ហើមចេញ ហើយនិងចូល** ម្នាលភិក្ខុ ដូច្នេះតថាគតពោលថា ជាអ្នកមិនប្រមាទ ក្រៅពីនោះទ្រង់សម្តែង **ទុតិយ-តតិយមរណស្សតិសូត្រ** និងសីល សមាធិ បញ្ញា វិមុត្តិដល់ភិក្ខុទាំងឡាយ ។

គ្រានោះ គហបតីឈ្មោះ **ទារុកម្មិកៈ** បានចូលទៅគាល់ព្រះពុទ្ធអង្គ ព្រះសាស្តាត្រាស់សួរថា ត្រកូលរបស់អ្នកនៅតែឱ្យទានឬ ? គហបតីក្រាបទូលថា ខ្ញុំព្រះអង្គនៅតែឱ្យចំពោះភិក្ខុជាព្រះអរហន្ត ដែលបានសម្រេចអរហត្តផល ជាអ្នកនៅព្រៃជាវត្ត ត្រាច់បិណ្ឌបាតជាវត្ត កាន់សំពត់បង្សុកូលជាវត្ត ។ ព្រះសាស្តាត្រាស់ថា គហបតីនៅគ្រប់គ្រងផ្ទះ មិនងាយនឹងដឹងថា ភិក្ខុណាជាព្រះអរហន្ត ភិក្ខុណាជាអ្នកនៅព្រៃជាវត្ត ជាដើម ។

ម្នាលគហបតី ភិក្ខុណាជាអ្នកមិនរាយមាយ មិនប្រកាន់ខ្លួន មិនមាត់រឹង មានសតិតាំងមាំ មានសម្បជញ្ញៈ មានចិត្តមូលតែមួយ សង្រួមឥន្ទ្រិយ៍ កាលបើដូច្នេះ **ម្នាលគហបតី ចូរអ្នកឱ្យសង្ឃទានចុះ ព្រោះកាលអ្នកឱ្យសង្ឃទាន មានចិត្តជ្រះថ្លាក្នុងសង្ឃ កាលអស់ជីវិតទៅនឹងទៅកាន់សុគតិទេវលោក។** ទារុកម្មិកគហបតី ទូលទទួលព្រះតម្រាស់ថា ខ្ញុំព្រះអង្គនឹងឱ្យសង្ឃទានតាំងពីឥឡូវនេះតទៅ ព្រះមានព្រះភាគទ្រង់សរសើរអានិសង្សរបស់សង្ឃទាន ដូច្នេះ។

ព្រះសាស្តាយាងចារិកទៅកាន់ក្រុងវេសាលី ទ្រង់គង់ក្នុងសួនស្វាយរបស់នាងអម្ពបាលី **នាងអម្ពបាលី** ជ្រាបដំណឹងថា ព្រះសាស្តាយាងមកគង់ក្នុងសួនរបស់ខ្លួន ទើបចេញទៅគាល់ និមន្តដើម្បីថ្វាយភត្តាហារក្នុងថ្ងៃស្អែក ព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃ យាងទៅកាន់រោងទានរបស់នាងអម្ពបាលីស្រីផ្កាមាស ក្រោយភត្តកិច្ច នាងអម្ពបាលីថ្វាយសួនស្វាយឱ្យជាអារាម ព្រះអង្គទ្រង់ទទួលហើយអនុមោទនា រួចយាងត្រឡប់ទៅអម្ពបាលីវ័ន ក្នុងទីនេះព្រះអង្គទ្រង់

សម្តែងសីល សមាធិ បញ្ញា និងវិមុត្តិដល់ភិក្ខុទាំងឡាយទៀត ។

**អម្ពបាលិវ័ន ជាអារាមក្រោយបំផុត ដែលព្រះអង្គទ្រង់ទទួលមុនស្តេចបរិនិព្វាន ។ ព្រះវិមលកោណ្ឌញ្ញត្ថេរ** ជាកូនប្រុសរបស់នាងអម្ពបាលី ដែលកើតពីព្រះបាទពិម្ពិសារ បួសក្នុងសំណាក់របស់ព្រះសាស្តា ក្នុងក្រុងសាវត្ថី សម្រេចព្រះអរហត្តផលហើយ បានសម្តែងធម៌ដល់នាងអម្ពបាលី តមកនាងអម្ពបាលីចេញបួសបានសម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ក្នុងទីបំផុត ។

# ព្រះវស្សាទី ៤៥ ជាវស្សាចុងក្រោយបំផុត

(១៦) ទ្រង់គង់ចាំព្រះវស្សា **ក្នុងស្រុកវេឡុវគ្រាម** ជិតនគរវេសាលី ក្នុងទីនេះ ព្រះអង្គទ្រង់អនុញ្ញាតឱ្យភិក្ខុទាំងឡាយ ទៅចាំវស្សាតាមអធ្យាស្រ័យ រៀង១ខ្លួន ជុំវិញនគរវេសាលី ចំណែកព្រះអង្គទ្រង់ចាំព្រះវស្សាក្នុងស្រុកវេឡុ-វគ្រាម ដូច្នេះព្រោះព្រះអង្គទ្រង់ព្រះតម្រិះថា តថាគតនៅបានត្រឹម ១០ ខែទៀត ក៏នឹងបរិនិព្វាន បើឱ្យភិក្ខុសង្ឃទៅនៅឆ្ងាយ នឹងមិនងាយស្រួលដល់ការប្រទាន ឱវាទ និងមិនអាចឃើញតថាគតក្នុងពេលបរិនិព្វាន ។

ក្នុងចន្លោះវស្សាព្រះអង្គទ្រង់ប្រឈួនធ្ងន់ ជិតតែនឹងបរិនិព្វាន តែព្រះអង្គ ទ្រង់អត់ធន់ ចំពោះវេទនានោះ ដោយមានព្រះតម្រិះថា ការដែលមិនបានលា ភិក្ខុសង្ឃ និងអ្នកឧបដ្ឋាក ជាមុននឹងបរិនិព្វាននោះមិនសមគួរ ទើបទ្រង់អធិដ្ឋាន ឱ្យសង្ខារតាំងនៅសិន (ក្នុងសុមង្គលវិលាសិនី ពោលថា ព្រះអង្គទ្រង់ចូលផលសមាបត្តិ គ្របសង្កត់វេទនា បណ្តេញរោគាពាធឱ្យស្ងប់) ។

**សក្កទេវរាជ** ទ្រង់ជ្រាបការអាពាធរបស់ព្រះសាស្តា ទ្រង់ត្រិះរិះថា នឹងទៅកាន់សំណាក់ព្រះអង្គ ហើយធ្វើគិលានុបដ្ឋាក ទើបចូលទៅគាល់ ថ្វាយ បង្គំហើយទ្រង់គក់ព្រះបាទដោយព្រះហស្តទាំងពីរ ព្រះសាស្តាត្រាស់សួរថា នោះ ជានរណា សក្កទេវរាជក្រាបទូលថា ខ្ញុំព្រះអង្គ គឺស្តេចសក្កៈ មកដើម្បីបម្រើ ទ្រង់ដែលប្រឈួន ព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា ម្នាលស្តេចសក្កៈ ក្លិនមនុស្សរមែងប្រាកដដល់ទេវតា

ទាំងឡាយ ដូចសាកសពដែលចងទុកនឹងក ផ្សាយឡើងរាប់រយយោជន៍ អ្នកចូរត្រឡប់ទៅចុះ ភិក្ខុគិលានុបដ្ឋាករបស់តថាគតមាន ។ ស្តេចសក្កៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូម្បីខ្ញុំព្រះអង្គតាំងនៅសែនឆ្ងាយ តែបានហិតក្លិននៃសីលរបស់ព្រះអង្គមកហើយ ខ្ញុំព្រះអង្គនឹងសូមបម្រើព្រះអង្គ ហើយមិនឱ្យបុគ្គលដទៃប៉ះពាល់ភាជនៈលោហិតរបស់ព្រះសាស្តា ទ្រង់ទូលទុកលើសិរសានាំទៅ មិនមានអាការខ្ពើមសូម្បីត្រឹមតែជ្រួញចិញ្ចើម ចំពោះព្រះភក្ត្រ ដូចនាំភាជនៈរបស់ក្រអូបទៅដូច្នោះ សក្កទេវរាជបដិបត្តិចំពោះព្រះសាស្តាដូច្នេះ ក្នុងវេលាដែលព្រះសាស្តាមានសេចក្តីសុខកាយហើយ ទើបយាងត្រឡប់ទៅទេវលោកវិញ។

ភិក្ខុទាំងឡាយប្រជុំគ្នា ពោលសរសើរស្តេចសក្កៈទ្រង់លះទិព្វសម្បត្តិ ទ្រង់ធ្វើការឧបដ្ឋាកព្រះសាស្តា ព្រះអង្គទ្រង់ឮហើយត្រាស់ថា ការដែលសក្កទេវរាជធ្វើដូច្នោះ មិនគួរអស្ចារ្យទេ ស្តេចសក្កៈស្តាប់ធម្មទេសនាហើយបានសម្រេចជាសោតាបន្ន លះភាពជាស្តេចសក្កៈជរា បានជាស្តេចសក្កៈកម្លោះ តថាគតមានឧបការច្រើនដល់ស្តេចសក្កៈ ដោយប្រការយ៉ាងនេះ ។ ទើបព្រះអង្គទ្រង់ឱ្យឱវាទដល់ភិក្ខុថា ម្នាលភិក្ខុទាំងឡាយ **ការឃើញព្រះអរិយបុគ្គលក្តី ការនៅជាមួយព្រះអរិយបុគ្គលទាំងឡាយក្តី ធ្វើឱ្យកើតសុខគ្រប់កាល អ្នកទាំងឡាយចូរគប់រកអ្នកប្រាជ្ញ ជាពហូស្សូត ជាអរិយបុគ្គល ជាសប្បុរស មានបញ្ញាល្អ ព្រោះការបាននៅរួមជាមួយអ្នកប្រាជ្ញ នាំឱ្យកើតសុខ ដូចការសមាគមនៃពួកញាតិជាទីស្រឡាញ់ រមែងមានតែសេចក្តីសុខដូច្នោះ ។**

ក្រោយពីបាត់ប្រឈួនហើយមិនយូរ ព្រះអង្គយាងចេញទៅប្រថាប់គង់ខាងក្រោយព្រះគន្ធកុដិ ត្រាស់ជាមួយព្រះអានន្ទថា ម្នាលអានន្ទ ក៏ក្នុងកាលឥឡូវនេះ តថាគតជរាហើយ កន្លងកាលឆ្លងវ័យមកតាមលំដាប់ វ័យរបស់តថាគតកំពុងឈានចូលឆ្នាំទី ៨០ ហើយ ម្នាលអានន្ទ រទេះចាស់គ្រាំគ្រា ប្រព្រឹត្តទៅបានដោយការចងអបដោយឫស្សី ដូចម្ដេច រាងកាយរបស់តថាគតក៏ប្រព្រឹត្តទៅបាន ដូចការអបដោយឫស្សីដូច្នោះឯង ។

**អ្នកទាំងឡាយចូរមានខ្លួនជាកោះ មានខ្លួនជាទីពឹង ចូរមានធម៌ជាកោះ មានធម៌ជាសរណៈចុះ កុំមានវត្ថុដទៃជាសរណៈឡើយ ។**

ព្រះសាស្ដាទ្រង់ឱវាទឱ្យភិក្ខុចម្រើនសតិប្បដ្ឋាន ៤ ទ្រង់ត្រាស់សតិប្បដ្ឋាន ៤ នឹងភិក្ខុទាំងឡាយថា **អ្នកគប្បីជាបុគ្គលមានសតិ** ពិចារណាឃើញកាយក្នុងកាយ មានសេចក្ដីព្យាយាម មានសម្បជញ្ញៈ មានសតិ កម្ចាត់បង់អភិជ្ឈា និងទោមនស្សក្នុងលោកចេញ ពិចារណាឃើញវេទនាក្នុងវេទនា ។ល។ ពិចារ-ណាឃើញចិត្តក្នុងចិត្ត ។ល។ ពិចារណាឃើញធម៌ក្នុងធម៌ មានព្យាយាម មានសម្បជញ្ញៈ មានសតិ កម្ចាត់បង់អភិជ្ឈា និងទោមនស្សក្នុងលោកចេញ ភិក្ខុគប្បីជាអ្នកមានសតិយ៉ាងនេះឯង ។

**អ្នកគប្បីជាអ្នកមានសម្បជញ្ញៈ** ធ្វើសេចក្ដីដឹងខ្លួន ក្នុងការឈានទៅមុខ ឈានថយក្រោយ ការក្រឡេកមើល ការងាកឆ្វេងស្ដាំ ការបត់ចូលចេញ ការគ្រងចីវរ សង្ឃាដិ បាត្រ ការឆាន់ ការផឹក ការលិទ្ធភ្លក្ស ការបន្ទោបង់ឧច្ចារបស្សាវៈ

ការដើរ ឈរ អង្គុយ ដេក កិរិយាលក់ ការភ្ញាក់ ការនិយាយ ការស្ងៀម ភិក្ខុគប្បីជាអ្នកមានសម្បជញ្ញៈ **នេះជាអនុសាសនីរបស់តថាគត សម្រាប់អ្នកទាំងឡាយ** ។

បន្ទាប់ពីនោះ ទ្រង់ត្រាស់សម្បជញ្ញៈ ៤ បានដល់ **សាត្ថកសម្បជញ្ញៈ ១ សប្បាយសម្បជញ្ញៈ ១ គោចរសម្បជញ្ញៈ ១ អសម្មោហសម្បជញ្ញៈ ១** (សេចក្តីពិស្តារមានក្នុង សំយុត្តនិកាយ មហាវារវគ្គ អដ្ឋកថាសតិសូត្រ) ហើយត្រាស់ថា ភិក្ខុណាមួយ ជាអ្នកប្រាថ្នាក្នុងការសិក្សាដូច្នេះ នឹងជាអ្នកប្រសើរបំផុត ក្នុងព្រះសូត្រនេះព្រះអង្គត្រាស់អំពីសម្បជញ្ញៈ រួមជាមួយសតិប្បដ្ឋានជាខាងដើម ។

ព្រឹកឡើង ព្រះអង្គយាងចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលី សម្រេចភត្តកិច្ចហើយ ក្នុងវេលារសៀលទ្រង់បបួលព្រះអានន្ទទៅកាន់ **បាវាឡចេតីយ៍** ជិតក្រុងវេសាលី ដែលពីដើមជាទីនៅរបស់យក្សឈ្មោះ បាវាឡៈ ត្រាស់សម្តែងឥទ្ធិបាទ ៤ ដែលជាផ្លូវនៃការសម្រេច ៤ ប្រការគឺ :

**១. ឆន្ទៈ សេចក្តីពេញចិត្តក្នុងការធ្វើ**

**២. វីរិយៈ សេចក្តីព្យាយាមក្នុងការធ្វើ**

**៣. ចិត្តៈ ការយកចិត្តទុកដាក់ក្នុងការធ្វើ**

**៤. វិមង្សា ការពិចារណារកហេតុផល ក្នុងការធ្វើនោះ ។**

ធម៌ ៤ ប្រការនេះ បើអ្នកណាចម្រើន ធ្វើឱ្យច្រើន កាលប្រាថ្នាក៏គប្បីអធិដ្ឋានជីវិតឱ្យតាំងនៅបានរហូតអាយុកប្ប ឬលើសជាងអាយុកប្ប[១] អាស្រ័យព្រះអានន្ទនៅជាសេក្ខបុគ្គល ទើបមិនឆ្លៀវឆ្លាសក្នុងពាក្យប្រារព្ធរបស់ព្រះសាស្ដា មិនបានក្រាបទូល សូមឱ្យព្រះមានព្រះភាគតាំងនៅអស់កប្ប ដោយត្រូវមារបណ្ដាលចិត្ត លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងព្រះអានន្ទថា ឥឡូវនេះអ្នកចូរសម្គាល់កាលដ៏គួរចុះ ។ ព្រះអានន្ទគេចចេញមកគង់ទៀបគល់ឈើមួយមិនឆ្ងាយអំពីព្រះមានព្រះភាគទ្រង់គង់ មារបានចូលមកក្រាបទូលសូមឱ្យព្រះអង្គបរិនិព្វាន មារពោលថា សូមព្រះមានព្រះភាគទ្រង់បរិនិព្វាន សូមព្រះសុគតទ្រង់បរិនិព្វាន ក្នុងកាលឥឡូវនេះចុះ ។

មារក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគត្រាស់នឹងមារមានចិត្តបាបថា ដរាបណាដែលបរិស័ទ ៤ របស់តថាគតនៅមានគុណសម្បត្តិមិនទាន់គ្រប់ ៣ ប្រការទេ ដរាបនោះតថាគតនឹងមិនបរិនិព្វានឡើយ សម្បត្តិ ៣ ប្រការគឺ :

**១. ជាអ្នកប្រាជ្ញ យល់ និងបដិបត្តិតាមពាក្យទូន្មានបានយ៉ាងត្រឹមត្រូវ**

**២. អាចនាំយកធម៌នោះ ទៅណែនាំទូន្មានអ្នកដទៃបាន**

**៣. បើមាននរណាពោលតិះដៀល ធ្វើឱ្យជំទាស់ ឬសម្ដែងពាក្យទូន្មានខុស អាចពោលកែខៃចង្អុលបង្ហាញ ឱ្យត្រឹមត្រូវតាមគោលការណ៍របស់ពុទ្ធវចនៈបាន ។**

---

[១] ពាក្យថា អាយុកប្ប គឺ កាលកំណត់នៃជំនាន់មនុស្ស សម័យនោះ មានអាយុ ១០០ ឬ លើស ១០០

មារទូលតទៅថា ឥឡូវនេះបរិស័ទ ៤ របស់ព្រះអង្គមានគុណសម្បត្តិគ្រប់ទាំង ៣ ប្រការហើយ ។ ព្រះអង្គត្រាស់តបថា ម្នាលមារមានចិត្តបាប អ្នកចូរខ្វល់ខ្វាយតិចចុះ អំណើះពីនេះទៅ ៣ ខែទៀត តថាគតនឹងបរិនិព្វាន អដ្ឋកថាពោលថា ព្រះអង្គទ្រង់ដាក់ព្រះជន្មាយុសង្ខារ ក្នុងមាឃបុណ្ណមី (ពេញបូរមីខែមាឃ) កាលមារត្រឡប់ទៅហើយ ព្រះអង្គទ្រង់ដាក់ព្រះជន្មាយុសង្ខារ ខណៈនោះផែនដីដ៏ធំ ក៏កម្រើកញាប់ញ័រ ព្រះអានន្ទក្រាបទូលសួរដល់មូលហេតុ ព្រះអង្គត្រាស់ហេតុដែលនាំឱ្យផែនដីដ៏ធំ កម្រើកញាប់ញ័រ ៨ ប្រការគឺ :

១. មហាប្រថពីតាំងនៅលើទឹក ទឹកតាំងនៅលើខ្យល់ ខ្យល់តាំងនៅលើអាកាស **សម័យដែលខ្យល់ធំបក់ផាត់ រមែងធ្វើទឹកឱ្យកម្រើក លុះទឹកកម្រើកហើយ ផែនដីនេះរមែងកម្រើក ។**

២. សមណព្រាហ្មណ៍ ឬទេវតាអ្នកមានឫទ្ធិ **ចម្រើនបឋវីសញ្ញាបន្តិចបន្តួច ចម្រើនអាបោសញ្ញាច្រើន អាចធ្វើផែនដីនេះឱ្យកម្រើកបាន ។**

៣. កាលណាព្រះពោធិសត្វចុតិចាកតុសិត មានសតិសម្បជញ្ញៈ **ឈានចុះកាន់គភ៌ព្រះមាតា ផែនដីនេះរមែងកម្រើក ។**

៤. កាលណាព្រះពោធិសត្វ មានសតិសម្បជញ្ញៈ **ប្រសូតិចាកគភ៌ព្រះមាតា ផែនដីនេះរមែងកម្រើក ។**

៥. កាលណាតថាគត **ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញាណ ផែនដីនេះរមែងកម្រើក ។**

៦. កាលណាតថាគត **ញុំាងធម្មចក្កដ៏កំពូលឱ្យប្រព្រឹត្តទៅ ផែនដីនេះរមែងកម្រើក ។**

៧. កាលណាតថាគត មានសតិសម្បជញ្ញៈ **ដាក់អាយុសង្ខារ ផែនដីនេះរមែងកម្រើក ។**

៨. កាលណាតថាគត **បរិនិព្វានដោយអនុបាទិសេសនិព្វាន ផែនដីនេះរមែងកម្រើក ។**

ទើបព្រះអានន្ទជ្រាបថា ព្រោះហេតុអ្វីទើបផែនដីកម្រើក បានទូលអង្វរសូមឱ្យព្រះអង្គទ្រង់ព្រះជន្មនៅរហូតទៅ ព្រះអង្គត្រាស់ថា ឥឡូវនេះតថាគតដាក់អាយុសង្ខារហើយ នឹងលះបង់ព្រោះហេតុនៃជីវិតតទៅទៀតនោះ មិនជាឋានៈដែលតថាគតធ្វើបានឡើយ ។

បន្ទាប់ពីនោះ មានតម្រាស់ឱ្យព្រះអានន្ទ ប្រជុំសង្ឃទាំងអស់ដែលនៅជុំវិញក្រុងវេសាលី ក្នុងឧបដ្ឋានសាលាត្រាស់ **ពោធិបក្ខិយធម៌ ៣៧ ប្រការ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ៍ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨** ត្រាស់ដាស់តឿនភិក្ខុមិនឱ្យប្រមាទ ហើយត្រាស់សម្តែងព្រះគាថា ថា :

**ពពួកជន ទាំងក្មេងទាំងចាស់ ទាំងពាលទាំងបណ្ឌិត ទាំង**
**អ្នកមានទាំងអ្នកក្រ សុទ្ធតែមានសេចក្តីស្លាប់នៅខាងមុខ**
**ភាជនៈដីដែលជាងឆ្នាំងសូនឡើង ទាំងតូចទាំងធំ ទាំងឆ្អិន**

ទាំងនៅគ្រប់ប្រភេទ មានការបែកជាទីបំផុត ដូចម្ដេចមិញ
ជីវិតរបស់សត្វទាំងឡាយ ក៏ដូច្នោះដែរ ។

និងត្រាស់តទៅថា វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគតសល់តិច តថាគតនឹងលះពួកអ្នកទៅ តថាគតបានធ្វើទីពឹងដល់ខ្លួនហើយ ពួកអ្នកចូរកុំប្រមាទ មានសតិ មានសីលដោយល្អចុះ ចូរជាអ្នកមានសេចក្ដីត្រិះរិះតាំងមាំដោយល្អ ចូរតាមរក្សាចិត្តរបស់ខ្លួនចុះ ។

# ផែនទី ដែលព្រះអង្គទៅដើម្បីបរិនិព្វាន

## ផ្លូវធ្វើពុទ្ធដំណើរមុនបរិនិព្វាន

(១៧) ព្រឹកថ្ងៃតមក ព្រះអង្គយាងចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលី ខាងក្រោយភត្តមុនចេញដំណើរ ទ្រង់ងាកព្រះវរកាយទៅទតក្រុងវេសាលីជាគ្រាចុងក្រោយ ហើយយាងទៅកាន់ស្រុក **ភណ្ឌគ្រាម** ព្រមដោយភិក្ខុសង្ឃដ៏ច្រើន ខណៈដែលទ្រង់គង់នៅក្នុងភណ្ឌគ្រាម ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា :

**ព្រោះមិនដឹងច្បាស់អរិយសច្ច ៤ ប្រការ តថាគត និងពួកអ្នកទើបត្រាច់រង្គាត់ទៅអស់កាលយូរយ៉ាងនេះ ឥឡូវនេះ តថាគតបានដឹងច្បាស់នូវសីល សមាធិ បញ្ញា និងវិមុត្តិដែលជាអរិយៈហើយ តណ្ហាដែលនឹងនាំទៅកាន់ភពអស់ហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ។**

ក្រៅពីនោះ ទ្រង់សម្តែងធម្មីកថាជាច្រើនដទៃទៀតថា យ៉ាងនេះសីល យ៉ាងនេះសមាធិ យ៉ាងនេះបញ្ញា សមាធិដែលសីលអប់រំហើយមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលបញ្ញាអប់រំហើយរមែងរួចផុតចាកអាសវៈទាំងពួង។

ព្រះអង្គទ្រង់ប្រថាប់គង់ក្នុងភណ្ឌគ្រាម តាមពេញព្រះទ័យហើយ យាងតទៅកាន់ **ហត្ថិគ្រាម** ទ្រង់គង់នៅឧទ្យាននាគភវ័ន គ្រានោះ ឧគ្គគហបតីស្រវឹងស្រាអស់ ៧ ថ្ងៃ អ្នករបាំហែហមបម្រើជុំវិញ លុះបានឃើញព្រះមានព្រះភាគក៏កើតហិរិឱត្តប្បៈយ៉ាងខ្លាំង កាលចូលគាល់ព្រះសាស្តា ការស្រវឹងសុរាបាត់អស់ទៅ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ប្រោស បានសម្រេចមគផលទាំង ៣

សេដ្ឋីលះពួកអ្នករបាំ ជាអ្នកត្រេកអរយ៉ាងក្រៃលែងក្នុងទាន ថ្វាយទានដល់តែភិក្ខុសង្ឃប៉ុណ្ណោះ ។ ទេវតាចូលមករកក្នុងរាត្រី ប្រាប់ដល់សេដ្ឋីថា ម្នាលគហបតី ភិក្ខុរូបនោះ មានវិជ្ជា ៣ មានអភិញ្ញា ៦ រូបនោះទ្រុស្តសីល រូបនេះមានសីល សេដ្ឋីស្តាប់ពាក្យរបស់ទេវតាហើយ ក៏បានដឹងគុណរបស់ភិក្ខុតាមពិត ទើបថ្វាយទានដោយចិត្តយ៉ាងស្មើ ។

ព្រះអង្គត្រាស់នឹងភិក្ខុទាំងឡាយថា ឧគ្គគហបតី ជាអ្នកប្រកបដោយធម៌ ដែលគួរអស្ចារ្យមិនធ្លាប់មានមក ៨ ប្រការ គឺ :

- កាលឃើញព្រះសាស្តាហើយមានសេចក្តីជ្រះថ្លា ស្វាងស្រវឹងសុរា ។
- កាលចូលទៅអង្គុយជិត ស្តាប់អនុបុព្វីកថាហើយ បានធម្មចក្ខុ ជាអរិយបុគ្គល ។
- កាលសមាទានសីលហើយ មានចិត្តធ្ងន់អនុញ្ញាតឱ្យភរិយា ជាឥស្សរៈដល់ខ្លួន ។
- កាលលះភោគទ្រព្យ ក៏ឱ្យដល់អ្នកមានសីល និង កល្យាណធម៌ ។
- កាលចូលទៅរកភិក្ខុ ក៏ចូលទៅរកដោយគោរព ស្តាប់ធម៌ដោយគោរព ។
- កាលថ្វាយទានដល់សង្ឃ ក៏ធ្វើដោយស្មើមិនចំពោះមុខ ។
- ជឿថាធម៌ដែលព្រះសាស្តាត្រាស់នោះល្អហើយ និងកាន់យកជាសរណៈរហូតតទៅ ។
- សូម្បីធ្វើមរណកាលមុនព្រះសាស្តា ក៏ដាក់ចិត្តថា នឹងមិនត្រឡប់មកកាន់

**លោកនេះម្តងទៀតឡើយ ។**

( ព្រោះឧគ្គគហបតី សម្រេចជាអនាគាមីហើយ )

ព្រះសាស្តាសរសើរឧគ្គគហបតីថា ជាកំពូលជាងឧបាសកទាំងពួង អ្នកឧបដ្ឋាកភិក្ខុសង្ឃ បន្ទាប់ពីនោះ ព្រះអង្គយាងចារិកឆ្លងកាត់ស្រុក **អម្ពគ្រាម ជម្ពុគ្រាម** តាមលំដាប់ រហូតដល់ **ភោគនគរ** ប្រថាប់គង់ក្នុង **អានន្ទចេតីយ៍** ទ្រង់សម្តែង **មហាបទេស ៤** មាន សេចក្តីថា :

បើមានភិក្ខុក្នុងធម្មវិន័យនេះ ពោលថា នេះគឺធម៌ នេះគឺវិន័យ

**- ដែលបានស្តាប់មកអំពីព្រះឱស្ឋរបស់ព្រះសាស្តាដោយត្រង់**

**- ដែលបានស្តាប់មកអំពីសំណាក់សង្ឃ ចំពោះមុខព្រះថេរៈ**

**- ដែលបានស្តាប់មកអំពីព្រះថេរៈច្រើនរូប ជាពហូស្សូត**

**- ដែលបានស្តាប់មកអំពីព្រះថេរៈមួយរូប ជាពហូស្សូត ។**

ពួកអ្នកកុំប្រញាប់ជឿ ឬហាមឃាត់ ចូរផ្ទៀងផ្ទាត់ក្នុងព្រះសូត្រ និងប្រៀបធៀបក្នុងព្រះវិន័យ បើមានសេចក្តីដូចគ្នា គប្បីជឿថា នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា បើមិនដូចគ្នា បញ្ជាក់ថា សង្ឃនោះចាំមកខុស ពួកអ្នកគប្បីលះបង់ចោលពាក្យពោលនោះ ។

ក្រោយពីនោះ ទ្រង់សម្តែងធម្មីកថាដទៃទៀត ជាច្រើនដល់ភិក្ខុទាំងឡាយថា យ៉ាងនេះសីល យ៉ាងនេះសមាធិ យ៉ាងនេះបញ្ញា សមាធិដែលសីលអប់រំហើយ មានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលសមាធិអប់រំហើយ មាន

ផលច្រើន មានអានិសង្សច្រើន ចិត្តដែលបញ្ញាអប់រំហើយ រមែងរួចផុតចាក អាសវៈទាំងពួង ។

( ១៨ ) តពីនោះមក ព្រះអង្គយាងទៅកាន់ **ក្រុងបាវា** គង់នៅក្នុងអម្ព-វ័នរបស់នាយចុន្ទ នាយចុន្ទកម្មារបុត្រជ្រាបដំណឹងទើបចូលទៅគាល់ ក្រាបទូលនិមន្តសោយភត្តាហារក្នុងថ្ងៃស្អែកឡើង ។ លុះវេលាព្រឹក ព្រះមានព្រះភាគព្រមដោយភិក្ខុសង្ឃ យាងទៅកាន់និវេសន៍របស់នាយចុន្ទ នាយចុន្ទបាននាំភោជនាហារដែលត្រៀមទុក មាន ***សូករមទ្ទវៈ*** រួមផងមកថ្វាយ ។ ព្រះពុទ្ធអង្គត្រាស់នឹងនាយចុន្ទថា អ្នកចូរអង្គាសតថាគត ដោយសូករមទ្ទវៈ ដែលត្រៀមទុក និងអង្គាសភិក្ខុសង្ឃដោយភត្តាហារដទៃ បន្ទាប់មក បញ្ជាឱ្យនាយចុន្ទ កប់សូករ-មទ្ទវៈដ៏សេសចុះក្នុងរណ្ដៅ ព្រោះទ្រង់ដឹងថា កាលបរិភោគហើយ មិនមានអ្នកណាក្នុងលោកនឹងគប្បីឱ្យរលាយទៅបានដោយល្អឡើយ ។

ក្រោយពីព្រះមានព្រះភាគ សោយភត្តាហាររបស់នាយចុន្ទកម្មារបុត្រហើយ កើតអាពាធខ្លាំងក្លាដោយ **លោហិតបក្ខន្ទិកាពាធ** មានវេទនាធ្ងន់ជិតនឹងបរិនិព្វាន តែទ្រង់មានសតិសម្បជញ្ញៈគ្របសង្កត់វេទនាទាំងនោះបាន ដោយមិនទ្រង់ញាប់ញ័រ ប្រាប់ព្រះអានន្ទថា **តថាគតនឹងទៅក្រុងកុសិនារា** ។ កាលធ្វើដំណើរបានមួយរយៈ ទ្រង់ចូលឈប់សម្រាកត្រង់គល់ឈើក្បែរផ្លូវ ត្រាស់នឹងព្រះអានន្ទថា **តថាគតនឿយណាស់នឹងអង្គុយ តថាគតស្រេកទឹកណាស់** ព្រះអានន្ទក្រាបទូលថា កាលអម្បាញ់មិញនេះកងរទេះ ៥០០ គ្រឿង ទើបឆ្លង

ទៅ ទឹកនោះនៅល្អក់ កកុធានទីនៅមិនឆ្ងាយពីនេះ ទីនោះមានទឹកថ្លាស្អាត មានកំពង់ទឹករាបស្មើគួររីករាយ សូមព្រះអង្គទ្រង់ឆាន់ និងស្រង់ក្នុងស្ទឹងនោះចុះ តែព្រះពុទ្ធអង្គ ក៏នៅត្រាស់ដូចដើមទៀត លើកទី ៣ ទើបព្រះអានន្ទកាន់បាត្រ ចុះទៅកាន់ស្ទឹងនោះ គួរឱ្យអស្ចារ្យ ទឹកត្រឡប់ជាថ្លាស្អាត ព្រះអានន្ទដងទឹកហើយត្រឡប់មកក្រាបទូលថា **គួរអស្ចារ្យហ្ន៎ ហេតុមិនធ្លាប់មាន ការដែលព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន ទើបទឹកថ្លាស្អាតមិនល្អក់កករ។**

ក្នុងពេលនោះ **បុក្កុសមល្លបុត្រ** សិស្សរបស់អាឡារតាបសកាឡាមគោត្រ ធ្វើដំណើរពីកុសិនារាទៅក្រុងបាវា ឃើញព្រះមានព្រះភាគគង់ក្បែរគល់ឈើ ទើបចូលទៅថ្វាយបង្គំ ហើយទូលថា គួរឱ្យអស្ចារ្យ សម័យមួយ អាឡារតាបសអង្គុយនៅក្បែរគល់ឈើ ដូចជាព្រះអង្គដែរ ខណៈនោះ ក្បួនរទេះដ៏ច្រើនឆ្លងកាត់ទៅ កាលក្បួនរទេះឆ្លងកាត់ទៅហើយ បុរសម្នាក់មកសួរថា លោកឃើញក្បួនរទេះឆ្លងទៅឬទេ អាឡារតាបសឆ្លើយថា មិនឃើញ និងមិនបានឮសំឡេង បុរសនោះសួរថា លោកលក់ឬ អាឡារតាបសឆ្លើយថា យើងមិនលក់ទេ បុរសនោះប្លែកក្នុងចិត្តថា កាលបើនៅភ្ញាក់ ហេតុអ្វីទើបមិនឃើញ និងមិនបានឮ

ព្រះពុទ្ធអង្គត្រាស់ថា អ្នកចូរប្រៀបធៀបនឹងរឿងដែលតថាគតនិទានឱ្យស្តាប់ ក្នុងគ្រាមួយតថាគតអាស្រ័យនៅត្រង់រោងត្បាល់ក្រុងអាតុមា (កន្លែងខ្លះពោលថា រោងតម្បាញ) ខណៈនោះភ្លៀងធ្លាក់ខ្លាំង ផ្គររន្ទះបាញ់មកត្រូវអ្នកស្រែពីរនាក់បងប្អូនរហូតស្លាប់ ព្រមទាំងគោ ៤ ក្បាលទៀត កាលភ្លៀងរាំងហើយ ពពួក

ជននាំគ្នាមកមើលកន្លែងកើតហេតុ តថាគតចេញទៅសួរគេថា ពួកអ្នកមកមើលអ្វី ពួកនោះត្រឡប់សួរតថាគតថា ព្រះអង្គគង់ទីណាទើបមិនជ្រាបរឿងដែលកើតឡើងអម្បាញ់មិញនេះ តថាគតឆ្លើយថា តថាគតនៅទីនេះឯង ។

ជនទាំងនោះសួរថា ព្រះអង្គបានឃើញអ្វីឬ តថាគតឆ្លើយថា តថាគតមិនបានឃើញទេ ព្រះអង្គបានឮសំឡេងអ្វីខ្លះឬ តថាគតឆ្លើយថា តថាគតមិនបានឮទេ ព្រះអង្គលក់ឬ តថាគតមិនបានលក់ទេ ។ ជនទាំងនោះសួរតទៅទៀតថា បើដូច្នោះកាលភ្លៀងកំពុងធ្លាក់យ៉ាងខ្លាំង ផ្លេកបន្ទោរឆ្វែលឆ្វាត់ រន្ទះបាញ់ ហេតុដូចម្ដេចទើបមិនបានឃើញ មិនបានឮ ទាំងដែលនៅភ្ញាក់ ជនទាំងនោះគិតថា គួរអស្ចារ្យ បព្វជិតរមែងនៅដោយវិហារធម៌ដ៏ស្ងប់ ដូច្នេះឯង ។

ព្រះសាស្ដាត្រាស់សួរបុក្កុសៈថា រវាងរឿងអាចារ្យរបស់អ្នក ជាមួយនឹងរឿងរបស់តថាគត ណាធ្វើបានដោយកម្រជាង បុក្កុសៈទូលតបថា ករណីរបស់ព្រះអង្គធ្វើបានដោយកម្រជាង ព្រះអង្គ ភាសិតរបស់ព្រះអង្គជាក់ច្បាស់ណាស់ បព្វជិតរមែងនៅដោយវិហារធម៌ដ៏ស្ងប់ដូច្នេះឯង ។ បុក្កុសមល្លបុត្រ កើតសេចក្ដីជ្រះថ្លាក្នុងព្រះសាស្ដា សូមថ្វាយខ្លួនជាឧបាសកអ្នកដល់ព្រះរតនត្រ័យអស់មួយជីវិត ហើយថ្វាយសំពត់មួយគូសាច់ម៉ដ្ឋរលោង មានពណ៌ដូចមាសទឹកដប់ចំពោះព្រះសាស្ដា ព្រះពុទ្ធអង្គត្រាស់ថា អ្នកចូរឱ្យតថាគតដណ្ដប់មួយផ្ទាំង ឱ្យអានន្ទដណ្ដប់មួយផ្ទាំង ហើយញ៉ាំងបុក្កុសមល្លបុត្រឱ្យឃើញច្បាស់ ឱ្យសមាទាន ឱ្យអាចហ៊ាន ឱ្យរីករាយដោយធម្មីកថា បុក្កុសៈថ្វាយបង្គំហើយចេញដំណើរតទៅ ។

កាលបុក្កុសមល្លបុត្រ ចេញទៅហើយមិនយូរ ព្រះអានន្ទបានបង្អោន សំពត់នោះចូលទៅធៀបព្រះវរកាយរបស់ព្រះពុទ្ធអង្គ ក្រាបទូលថា គួរអស្ចារ្យ ព្រះឆវីវណ្ណរបស់ព្រះតថាគត បរិសុទ្ធិផូរផង់ក្រៃលែងណាស់ សំពត់នេះកាលធៀបព្រះវរកាយហើយ រមែងប្រាកដដូចធ្យូងភ្លើង ដែលប្រាសចាកអណ្តាតដូច្នោះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ក្នុងកាលទាំងពីរ កាយរបស់តថាគតរមែងបរិសុទ្ធិ ឆវីវណ្ណរមែងផូរផង់ក្រៃលែង គឺ :

**រាត្រីដែលតថាគត ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ១**

**រាត្រីដែលតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វាន ១**

ម្នាលអានន្ទ ក្នុងបច្ឆិមយាមនៃរាត្រីនេះ តថាគតនឹងបរិនិព្វាននៅត្រង់ចន្លោះមែកសាលព្រឹក្សទាំងគូ ក្នុងសាលវ័ននៃមល្លក្សត្រ ក្រុងកុសិនារា មកចុះអានន្ទ យើងនឹងទៅកាន់ **កកុធានទី** ។

កាលយាងទៅដល់ **កកុធានទី** ទ្រង់ស្រង់ ទ្រង់សោយ ហើយយាងទៅកាន់អម្ពវ័ន ត្រាស់នឹង **ព្រះចុន្ទកៈ** ថា ម្នាលចុន្ទកៈ អ្នកជួយក្រាលសំពត់សង្ឃាដិបត់ជា ៤ ជាន់ឱ្យតថាគត តថាគតនឿយហត់ណាស់ នឹងផ្ទុំសម្រាក ហើយទ្រង់មនសិការ **ឧដ្ឋានសញ្ញាមនសិការ** (សម្រាកមួយភ្លែតហើយនឹងយាងដំណើរតទៅ) ដោយមានព្រះចុន្ទកៈអង្គុយគាល់នៅចំព្រះភក្ត្រ ។

គ្រានោះ ព្រះពុទ្ធអង្គត្រាស់នឹងព្រះអានន្ទថា ជួនកាលអាចនឹងមានអ្នកធ្វើសេចក្តីក្តៅក្រហាយចិត្ត ឱ្យកើតដល់នាយចុន្ទកម្មារបុត្រ ក្នុងកាលជាខាង

ក្រោយថា តថាគតបរិភោគបិណ្ឌបាតរបស់អ្នកហើយបរិនិព្វាន ម្នាលអានន្ទ អ្នកចូរជួយកម្ចាត់បង់សេចក្តីក្តៅក្រហាយចិត្ត របស់ចុន្ទកម្មារបុត្រដោយព្រះតម្រាស់របស់តថាគតថា :

**តថាគតបរិភោគបិណ្ឌបាតណាហើយ ត្រាស់ដឹងអនុត្តរសម្មា-សម្ពោធិញ្ញាណ ១ !**

**តថាគតបរិភោគបិណ្ឌបាតណាហើយ បរិនិព្វានដោយអនុបាទិ-សេសនិព្វាន ១ !**

បិណ្ឌបាតទាំងពីរនេះមានផលស្មើគ្នា មានអានិសង្សស្មើគ្នា មានផលធំជាង មានអានិសង្សធំជាងបិណ្ឌបាតដទៃៗ កម្មដែលចុន្ទកម្មារបុត្រសន្សំហើយប្រព្រឹត្តទៅដើម្បី អាយុ វណ្ណៈ សុខៈ យស សួគ៌ និងប្រព្រឹត្តទៅដើម្បីភាពជាធំក្រៃលែង។ ក្នុងកាលតមក **នាងសុជាតា** និង **នាយចុន្ទ** បានស្តាប់ព្រះសាស្តាត្រាស់ដូច្នោះ រឭកដល់ផលនៃការថ្វាយទានរបស់ខ្លួនថា ជាលាភរបស់យើងហ្ន៎ ទើបកើតបីតិសោមនស្សយ៉ាងក្រៃលែង ។

(១៩) បន្ទាប់ពីនោះ ត្រាស់នឹងអានន្ទថា យើងនឹងឆ្លងទៅកាន់ត្រើយឯនាយនៃស្ទឹង **ហិរញ្ញវតី** កាលដល់សាលវ័នដែលជាទីឈប់សម្រាកនៃពួកមល្ល-ក្សត្រ ក្រុងកុសិនារា មានព្រះតម្រាស់ឱ្យអានន្ទ រៀបចំទីគង់ប្រថាប់ក្រោមចន្លោះនៃមែកសាលព្រឹក្សទាំងគូ បែរព្រះសិរសាទៅទិសឧត្តរ ត្រាស់ថា តថាគតនឿយហត់ហើយ នឹងផ្ទុំ ហើយទ្រង់ផ្ទុំ **អនុដ្ឋានសេយ្យា** (ផ្ទុំហើយមិនក្រោកទៀត

ឡើយ ) ។ គ្រានោះ សាលព្រឹក្សទាំងគូចេញផ្ការីកស្គុះស្គាយខុសរដូវកាល ជ្រុះរោយរាយចុះកាន់ព្រះសរីរៈរបស់ព្រះតថាគតដើម្បីបូជា ផ្កាមណ្ឌារវៈ លម្អិតនៃចន្ទន៍ដែលជារបស់ទិព្វ ក៏ធ្លាក់ចុះមកអំពីអាកាស ដើម្បីបូជាព្រះតថាគត តូរ្យតន្ត្រីដែលជាទិព្វក៏លេង ប្រព្រឹត្តទៅក្នុងអាកាស ដើម្បីបូជាព្រះពុទ្ធអង្គ ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់នឹងព្រះអានន្ទថា ម្នាលអានន្ទ តថាគតបានឈ្មោះថា បរិស័ទបូជាដោយគ្រឿងសក្ការៈប្រមាណប៉ុណ្ណោះក៏ទេ ព្រោះវត្ថុទាំងនេះ គឺជា **អាមិសបូជា** ( ការបូជាដោយវត្ថុ ) ។ ម្នាលអានន្ទ ចំណែកអ្នកណាមិនថាជាភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌ប្រព្រឹត្តធម៌ អ្នកនោះឈ្មោះថា បានសក្ការៈ គោរព និងបូជាតថាគតដោយ **ធម្មបូជា** ដែលជាការបូជាដ៏ឧត្តម ។

គ្រានោះ **ព្រះឧបវាណៈ** ឈរបក់ផ្លិតនៅចំព្រះភក្ត្រ ព្រះអង្គមានព្រះតម្រាស់ឱ្យព្រះឧបវាណៈគេចចេញ ព្រះអានន្ទសង្ស័យ ទូលសួរដល់ហេតុដែលត្រាស់ដូច្នោះ ព្រះពុទ្ធអង្គត្រាស់ថា ដើម្បីបើកឱកាសឱ្យពួកទេវតា បានចូលមកគាល់ដោយជិត ។ ព្រះអានន្ទទូលសួរថា ក្នុងបច្ចុប្បន្ន ភិក្ខុពីទិសផ្សេងៗ នឹងនាំគ្នាមកគាល់ដើម្បីឃើញព្រះអង្គ កាលព្រះអង្គកន្លងទៅហើយ ពួកខ្ញុំព្រះអង្គនឹងមានវត្ថុអ្វីសម្រាប់ជាទីគួរឃើញ ដើម្បីរឭកដល់ព្រះអង្គ ព្រះអង្គ ! ព្រះមានព្រះភាគត្រាស់ថា **សង្វេជនីយដ្ឋាន ៤** កន្លែង គឺ :

~ **ទីកន្លែងដែលតថាគតប្រសូត ១**

- **ទីកន្លែងដែលតថាគតត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ១**
- **ទីកន្លែងដែលតថាគតញ៉ាំងធម្មចក្កឱ្យប្រព្រឹត្តទៅ ១**
- **ទីកន្លែងដែលតថាគតបរិនិព្វាន ១ ។**

សង្វេជនីយដ្ឋាន ៤ កន្លែងនេះឯង ជាកន្លែងគួរឃើញ គួរពួករបស់បរិស័ទ ៤ អ្នកមានសទ្ធាក្នុងព្រះសាសនា ជនណាចារិកទៅកាន់ស្ថានទីទាំងនេះ ដោយចិត្តជ្រះថ្លា លុះធ្វើកាលកិរិយា នឹងទៅកាន់សុគតិ ទេវលោកដោយឥតសង្ស័យ ។

ព្រះអង្គត្រាស់នឹង ព្រះអានន្ទតទៅថា មានបុគ្គលដែលគួរដល់ការសាងស្តូបទុកបូជា ៤ ចំពូក ឈ្មោះថា **ថូបារហបុគ្គល ៤** គឺ :

- **ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ១**
- **ព្រះបច្ចេកពុទ្ធជាម្ចាស់ ១**
- **ព្រះសាវ័ករបស់ព្រះតថាគត ១**
- **ព្រះចៅចក្រពត្តិ ១ ។**

ព្រះអានន្ទទូលសួរទៀតថា ខ្ញុំព្រះអង្គនឹងបដិបត្តិចំពោះព្រះសរីរៈ របស់ព្រះអង្គដូចម្តេច ព្រះសាស្តាត្រាស់តបថា ពួកអ្នកកុំខ្វល់ខ្វាយរឿងសរីរៈរបស់តថាគតឡើយ ចូរបន្តក្នុងការងារប្រយោជន៍ខ្លួន ជាអ្នកមិនប្រមាទ មានខ្លួន-បញ្ជូនទៅហើយចុះ បណ្ឌាក្សត្រ ព្រាហ្មណ៍ គហបតីអ្នកជ្រះថ្លាក្នុងតថាគតមានជនទាំងនោះ នឹងធ្វើការបូជាសរីរៈរបស់តថាគតខ្លួនឯង ។

ដោយអាស្រ័យ ព្រះអានន្ទនៅជាសេក្ខបុគ្គល ទើបមិនអាចហាមឃាត់

សេចក្តីសោក បានចេញទៅឈរឃំនៅខាងក្រៅ រំពឹងគិតថា មិនយូរទៀតទេ ព្រះសាស្តាក៏នឹងបរិនិព្វានចោលហើយ ។ ព្រះសាស្តា មិនឃើញព្រះអានន្ទ ទើបមានព្រះតម្រាស់ឱ្យរក ហើយត្រាស់ថា អ្នកកុំសោកសង្រេងសង្រៃឡើយ វត្ថុណាកើតហើយ មានហើយ បច្ច័យតាក់តែងហើយ រមែងមានការរលត់ទៅជាធម្មតា ។

**ម្នាលអានន្ទ អ្នកជាឧបដ្ឋាកតថាគតដោយកាយកម្ម វចីកម្ម និងមនោកម្ម ដែលប្រកបដោយមេត្តា ជាប្រយោជន៍ទំនុកបម្រុង ជាសេចក្តីសុខមិនមានពីរ រកប្រមាណមិនបានអស់កាលយូរ អ្នកបានធ្វើបុណ្យទុកហើយ អ្នកចូរប្រកបសេចក្តីព្យាយាមចុះ អ្នកនឹងជាអ្នកមិនមានអាសវៈដោយឆាប់រហ័ស ។**

រួចហើយ ព្រះអង្គត្រាស់សរសើរព្រះអានន្ទនឹងភិក្ខុទាំងឡាយថា អានន្ទជាបណ្ឌិត ស្គាល់កាល ស្គាល់បុគ្គល និងត្រាស់សេចក្តីអស្ចារ្យ ៤ ប្រការ ដែលមាននៅក្នុងព្រះអានន្ទ គឺមិនថាអ្នកណា កាលបានចូលជិតអានន្ទ រមែងត្រេកអរដោយបានឃើញ បានស្តាប់ធម៌ពេញចិត្តក្នុងធម៌ និងមិនឆ្អែតក្នុងធម៌ដែលអានន្ទសម្តែង ។ បន្ទាប់ពីនោះ ត្រាស់ឱ្យព្រះអានន្ទទៅប្រាប់ដំណឹងដល់ពួកមល្លក្សត្រថា ព្រះសាស្តានឹងបរិនិព្វានក្នុងបច្ឆិមយាមនៃរាត្រីនេះ ដើម្បីប្រទានឱកាសឱ្យដល់ពួកមល្លក្សត្រ បានចូលគាល់មុនបរិនិព្វាន ក្សត្រទាំងនោះនឹងមិនមាន វិប្បដិសារីក្នុងខាងក្រោយថា ព្រះសាស្តាមកបរិនិព្វានក្នុងអាណាខេត្តរបស់ពួកខ្លួន

តែត្រឡប់ជាមិនបានចូលគាល់ ។

ពួកស្ដេចមល្លក្សត្រជ្រាបដំណឹងពីអានន្ទ មានការសោយសោកកន្ទក់កន្ទេញ ប្រញាប់នាំគ្នាមកគាល់ព្រះអង្គ ព្រះអានន្ទបានរៀបចំឱ្យចូលថ្វាយបង្គំតាមលំដាប់ត្រកូល រហូតស្រេចអស់ខាងក្នុងយាមដំបូងនៃរាត្រី ។

(២០) **សុភទ្ទបរិព្វាជក** អ្នកក្រុងកុសិនារា ចូលទៅសូមគាល់ព្រះអង្គដើម្បីទូលសួរបញ្ហាដែលខ្លួននៅសង្ស័យ បានសូមអនុញ្ញាតនឹងព្រះអានន្ទដល់ ៣ លើក តែព្រះអានន្ទមិនអនុញ្ញាត ព្រោះក្រែងថា ព្រះអង្គនឹងទ្រង់នឿយហត់ ព្រះអង្គស្ដាប់ពាក្យពេចន៍ដែលព្រះអានន្ទ និងសុភទ្ទសន្ទនាគ្នា ទើបមានព្រះតម្រាស់ឱ្យសុភទ្ទចូលគាល់ ហើយទ្រង់សម្ដែងធម៌ប្រោសថា **ធម៌វិន័យណាមានអរិយមគ្គប្រកបដោយអង្គ ៨ ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះ-អនាគាមី និងព្រះអរហន្ត រមែងមានតែក្នុងធម្មវិន័យនេះ ប្រសិនបើសមណៈទាំងនោះ បដិបត្តិល្អបដិបត្តិប្រពៃ តាមផ្លូវអរិយមគ្គមានអង្គ ៨ លោកនេះនឹងមិនស្វាត់ចាកព្រះអរហន្តឡើយ !**

**សុភទ្ទបរិព្វាជក** ស្ដាប់ព្រះធម៌ទេសនាហើយមានសេចក្ដីជ្រះថ្លា សូមឧបសម្ប័ទក្នុងព្រះពុទ្ធសាសនា ទើបព្រះអង្គត្រាស់ឱ្យព្រះអានន្ទជាអ្នកបព្វជ្ជាដោយវិធីទទួល **ត្រៃសរណគមន៍** ព្រះអង្គទ្រង់ប្រទានឧបសម្ប័ទ ហើយត្រាស់ប្រាប់កម្មដ្ឋាន ព្រះសុភទ្ទទទួលកម្មដ្ឋាន និងអធិដ្ឋានចង្ក្រមក្នុងបរិវេណឧទ្យាននោះឯង បានសម្រេចអរហត្តផលក្នុងយប់នោះ ព្រមដោយបដិសម្ភិទា ៤ វិមោក្ខ

៨ អភិញ្ញា ៦ ជា **បច្ឆិមសក្ខិសាវ័ក** គឺព្រះអរហន្តសាវ័កចុងក្រោយ ទាន់ឃើញព្រះពុទ្ធជាម្ចាស់មុនបរិនិព្វាន ។

អដ្ឋកថាពោលថា ក្នុងអតីតជាតិ ព្រះសុភទ្ទជាប្អូនប្រុសរបស់ព្រះអញ្ញា-កោណ្ឌញ្ញៈ ។

(២១) បន្ទាប់ពីនោះ ព្រះសាស្ដាត្រាស់ដល់អានន្ទនិងភិក្ខុសង្ឃទាំង-ឡាយថា ក្រោយពីតថាគតបរិនិព្វានហើយ ចូរបដិបត្តិដូច្នេះ ។

១. ចូរគណសង្ឃប្រកាន់ព្រះធម៌វិន័យដែលទ្រង់សម្ដែង និងទ្រង់បញ្ញត្តទុកហើយនោះ ជាសាស្ដាជំនួសតទៅ ។
២. ភិក្ខុដែលមានវស្សាចាស់ជាង ចូរហៅភិក្ខុដែលខ្ចីវស្សាជាងដោយឈ្មោះ ត្រកូល ឬពាក្យថា អាវុសោ ។
៣. ភិក្ខុដែលមានវស្សាខ្ចីជាង ចូរហៅភិក្ខុអ្នកចាស់វស្សាជាងដោយពាក្យថា ភន្តេ ឬ អាយស្មា ។
៤. សិក្ខាបទដែលមិនសំខាន់ អនុញ្ញាតឱ្យគណសង្ឃដកបាន ។
៥. ឱ្យព្រះអានន្ទដាក់ទណ្ឌកម្មដល់ឆន្នភិក្ខុ ដោយការមិនឱ្យគណ-សង្ឃប្រដៅដាស់តឿនទូន្មាន និងការគប់រក ។

បន្ទាប់ពីនោះ ប្រទានឱកាសឱ្យពួកភិក្ខុទាំងឡាយ សួរក្នុងកិច្ចបដិបត្តិដែលមានសេចក្ដីសង្ស័យនៅក្នុងចិត្ត តែមិនមានអ្នកណាមានសេចក្ដីសង្ស័យសូម្បីព្រះអង្គទ្រង់ត្រាស់សួរដល់ ៣ លើក ក៏មិនមានភិក្ខុណាសាកសួរឡើយ ។

ព្រះអានន្ទទូលថា អស្ចារ្យណាស់ មិនមានភិក្ខុសូម្បីតែមួយរូបដែលសង្ស័យក្នុង កិច្ចបដិបត្តិ ។ ទើបព្រះអង្គត្រាស់ថា ព្រោះភិក្ខុដែលប្រជុំគ្នា ៥០០ រូបនេះ យ៉ាងហោចក៏ជាព្រះសោតាបន្ន មានការមិនថោកថយជាធម្មតា នឹងបានត្រាស់ ដឹងនៅក្នុងកាលខាងមុខដោយពិតប្រាកដ ។

## បច្ឆិមវាចា

(២២) **ព្រះអង្គត្រាស់បច្ឆិមពុទ្ធវចនៈថា**

**ម្នាលភិក្ខុទាំងឡាយ តថាគតដាស់តឿនអ្នកជា**

**គ្រាចុងក្រោយថា សង្ខារធម៌ទាំងឡាយមានសេចក្តី**

**វិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញុំាងប្រយោជន៍**

**ឱ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ៕**

## បរិនិព្វាន

(២៣) បន្ទាប់ពីនោះ ព្រះមានព្រះភាគជាម្ចាស់

ទ្រង់ចូលបឋមជ្ឈាន ចេញពីបឋមឈានហើយ

ទ្រង់ចូលទុតិយជ្ឈាន ចេញពីទុតិយជ្ឈានហើយ

ទ្រង់ចូលតតិយជ្ឈាន ចេញពីតតិយជ្ឈានហើយ

ទ្រង់ចូលចតុត្ថជ្ឈាន ចេញពីចតុត្ថជ្ឈានហើយ

ទ្រង់ចូលអាកាសានញ្ចាយតនៈ

**ចេញពីអាកាសានញ្ចាយតនសមាបត្តិ ហើយទ្រង់ចូលវិញ្ញាណញ្ចាយតនៈចេញពីវិញ្ញាណញ្ញាយតនសមាបត្តិ ហើយទ្រង់ចូលអាកិញ្ចញ្ញាយតនៈ ចេញពីអាកិញ្ចញ្ញាយតនសមាបត្តិហើយ ទ្រង់ចូលនេវសញ្ញានាសញ្ញាយតនៈ ចេញពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ទ្រង់ចូលសញ្ញាវេទយិតនិរោធ ។**

គ្រានោះ ព្រះអានន្ទបានសួរព្រះអនុរុទ្ធថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានហើយឬនៅ ព្រះអនុរុទ្ធពោលថា អានន្ទដ៏មានអាយុ ព្រះអង្គនៅមិនទាន់ទ្រង់បរិនិព្វានទេ ទ្រង់ចូលសញ្ញាវេទយិតនិរោធ ។

**ព្រះមានព្រះភាគ ទ្រង់ចេញពីសញ្ញាវេទយិតនិរោធសមាបត្តិ ដោយបដិលោមរហូតដល់បឋមជ្ឈាន ចេញពីបឋមជ្ឈាន ចូលទុតិយជ្ឈាន ចេញពីទុតិយជ្ឈាន ចូលតតិយជ្ឈាន ចេញពីតតិយជ្ឈាន ចូលចតុត្ថជ្ឈាន ចេញពីចតុត្ថជ្ឈានហើយ ព្រះអង្គរំលត់ខន្ធបរិនិព្វាន ក្នុងលំដាប់នៃការពិចារណាអង្គចតុត្ថជ្ឈាន។**

ព្រះពុទ្ធអង្គទ្រង់បរិនិព្វានដោយ **អនុបាទិសេសនិព្វាន** ក្នុងបច្ឆិមយាមនៃរាត្រីពេញបូរមី ខែពិសាខ ព្រមដោយការបរិនិព្វាន ផែនដីកម្រើកញាប់ញ័រយ៉ាងខ្លាំង ទាំងស្គរទិព្វក៏បន្លឺឡើង ។ ព្រមដោយការបរិនិព្វាន **ស្ដេចសហម្បតី-**

ព្រហ្ម បានពោលសង្វេជនីយគាថា ថា :

**សត្វទាំងឡាយទាំងពួង នឹងត្រូវលះចោលរាងកាយទុកក្នុងលោកនេះ សូម្បីព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏នៅតែស្ដេចបរិនិព្វាន ។**

ព្រមដោយការបរិនិព្វាន សក្កទេវរាជបានពោលសង្វេជនីយគាថា ថា

**សង្ខារធម៌ទាំងឡាយមិនទៀងមែនពិត មានការកើតឡើង និងវិនាសទៅវិញជាធម្មតា លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្ដីសុខគ្រប់យ៉ាង ។**

កាលព្រះមានព្រះភាគជាម្ចាស់បរិនិព្វានហើយ ព្រះអនុរុទ្ធដាស់តឿនភិក្ខុទាំងឡាយ ដែលនៅជាសេក្ខបុគ្គលថា ពួកអ្នកកុំសោយសោកឡើយ រឿងនេះព្រះមានព្រះភាគ បានត្រាស់ប្រាប់ទុកជាមុនហើយមិនមែនឬ ការព្រាត់ប្រាសចាកវត្ថុជាទីស្រឡាញ់ពេញចិត្តទាំងអស់ តែងតែមាន វត្ថុណាកើតឡើងហើយមានបច្ច័យតាក់តែងហើយ រមែងមានការបែកធ្លាយទៅជាធម្មតា ការប្រាថ្នាថាសូមវត្ថុនោះកុំវិនាសទៅឡើយ មិនជាឋានៈដែលអាចប្រព្រឹត្តទៅបានឡើយ ។

ព្រះអនុរុទ្ធ និងព្រះអានន្ទ ញុំាងរាត្រីនោះឱ្យកន្លងទៅដោយធម្មីកថាដល់ភិក្ខុទាំងឡាយ ព្រះអនុរុទ្ធបញ្ជាព្រះអានន្ទថា ទៅចុះអានន្ទ អ្នកចូរចូលទៅក្រុងកុសិនារា ប្រាប់ដល់ពួកមល្លក្សត្រក្រុងកុសិនារាថា ម្នាលវាសិដ្ឋៈទាំងឡាយព្រះមានព្រះភាគជាម្ចាស់បរិនិព្វានហើយ សូមពួកលោកចូរជ្រាបកាលដ៏គួរ ក្នុងកាលឥឡូវនេះចុះ ។ ព្រះអានន្ទទទួលពាក្យរបស់ព្រះអនុរុទ្ធ ក្នុងវេលាព្រឹក

ដណ្ដប់សំពត់ហើយ កាន់បាត្រចូលទៅក្នុងក្រុងកុសិនារា ដើម្បីប្រាប់ដំណឹងការបរិនិព្វានរបស់ព្រះពុទ្ធអង្គ តែមួយអង្គឯង ។

## ប្រាប់ដំណឹងបរិនិព្វាន

សម័យនោះ ពួកមល្លក្សត្រក្រុងកុសិនារា ប្រជុំគ្នាត្រង់សាលា ដោយរឿងព្រះពុទ្ធអង្គបរិនិព្វាន ព្រះអានន្ទបានប្រាប់ដល់មល្លក្សត្រក្រុងកុសិនារាថា វាសិដ្ឋៈទាំងឡាយ ព្រះមានព្រះភាគជាម្ចាស់ស្ដេចបរិនិព្វានហើយ សូមអ្នកទាំងឡាយសម្គាល់កាលដ៏គួរក្នុងកាលឥឡូវនេះចុះ ។ មល្លក្សត្រ ឱរស សុណិសា និងបជាបតីស្ដាប់ពាក្យរបស់ព្រះអានន្ទហើយ មានសេចក្ដីសោយសោក ពួកខ្លះរំសាយសក់ ផ្គងព្រះហស្ថទាំងពីរទួញយំ បម្រះននៀលទៅមក ទ្រង់រៀបរាប់ថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានឆាប់ម៉្លេះ ព្រះសុគតទ្រង់បរិនិព្វានឆាប់ម៉្លេះ ព្រះអង្គជាអ្នកមានចក្ខុក្នុងលោក អន្តរធានឆាប់ម៉្លេះ ។

គ្រានោះ មល្លក្សត្រក្រុងកុសិនារាត្រាស់បញ្ជានឹងពួកបុរសថា ពួកអ្នកចូរត្រៀមគ្រឿងក្រអូប ផ្កាឈើ និងគ្រឿងតន្ត្រីគ្រប់ជំពូក ក្នុងក្រុងកុសិនារាឱ្យព្រមសព្វ ចំណែកមល្លក្សត្រកុសិនារាកាន់របស់ប្រអូប ផ្កាឈើ និងសំពត់ ៥០០ គូយាងទៅកាន់សាលវ័ន ដើម្បីសក្ការបូជា ព្រះសរីរៈរបស់ព្រះមានព្រះភាគជា-ម្ចាស់ ។ ពួកមល្លក្សត្រ សួរព្រះអានន្ទថា ពួកខ្ញុំករុណានឹងគប្បីបដិបត្តិចំពោះព្រះសរីរៈរបស់ព្រះតថាគតដូចម្ដេច ? ព្រះអានន្ទពោលថា **ពួកមហាបពិត្រ**

គប្បីបដិបត្តិចំពោះព្រះសរីរៈព្រះតថាគត ដូចដែលគេបដិបត្តិចំពោះព្រះ-សរីរៈរបស់ស្តេចចក្រពត្តិចុះ ។

លំដាប់នោះ ពួកមល្លក្សត្រក្រុងកុសិនារាបញ្ជាឱ្យពួកបុរស ត្រៀមគ្រឿងប្រើប្រាស់ តាមដែលព្រះអានន្ទប្រាប់គ្រប់យ៉ាងឱ្យព្រមសព្វ ពួកមល្លក្សត្រក្រុងកុសិនារាយាងទៅកាន់សាលវ័ន ដែលជាកន្លែងបរិនិព្វានរបស់ព្រះពុទ្ធអង្គ បូជាព្រះបរមសពដោយគ្រឿងក្រអូប ផ្កាឈើ ជួយគ្នារុំព្រះសរីរៈព្រះមានព្រះភាគជាម្ចាស់ដោយសំពត់ថ្មី ឆ្លាស់ដោយសំឡី ហើយរុំដោយសំពត់ថ្មី ឆ្លាស់គ្នាដូច្នោះ រហូតអស់សំពត់ ៥០០ គូ ហើយនិមន្តព្រះសរីរៈចុះក្នុងមឈូសមាស ដែលពេញដោយប្រេងក្រអូប គ្របដោយមឈូសមាសដទៃទៀត បញ្ជាឱ្យសាង និងប្រដាប់តាក់តែងរោងមណ្ឌបឱ្យល្អស្អាត បូជាព្រះសរីរៈរបស់ព្រះពុទ្ធជាម្ចាស់ដោយគ្រឿងក្រអូប ផ្កាឈើ ការរាំ ច្រៀង ប្រគុំញ៉ាំងថ្ងៃនោះឱ្យកន្លងទៅ ដោយប្រការយ៉ាងនេះ ។

ពួកស្តេចមល្លក្សត្រ ធ្វើការបូជាដូច្នេះអស់ ៦ ថ្ងៃ លុះក្នុងថ្ងៃទី ៧ ត្រៀមការថ្វាយព្រះភ្លើង ពួកស្តេចមល្លៈក្រុងកុសិនារា មានព្រះតម្រិះថា នឹងឱ្យមល្លបាមោក្ខ និមន្តព្រះបរមសពទៅថ្វាយព្រះភ្លើង នាទិសទក្សិណនៃព្រះនគរ ។

## មល្លបាមោក្ខ ៨

សម័យនោះ មល្លបាមោក្ខ ៨ អង្គ គិតគ្នាថា យើងនឹងលើកព្រះសរីរៈរបស់ព្រះមានព្រះភាគជាម្ចាស់ តែក៏មិនអាចលើកឡើងបាន ទើបពួកស្តេចមល្លៈ

ក្រុងកុសិនារាសួរព្រះអនុរុទ្ធថា អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យដែលមល្លបាមោក្ខ ៨ អង្គនេះ មិនអាចលើកព្រះសពព្រះមានព្រះភាគឡើងបាន ព្រះអនុរុទ្ធពោលថា បពិត្រវាសិដ្ឋៈទាំងឡាយ ពួកអ្នកមានសេចក្តីបំណងផ្សេង តែពួកទេវតាមាន បំណងផ្សេង ពួកមល្លក្សត្រសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន តើពួកទេព្តាមាន សេចក្តីបំណងដូចម្តេច ?

ព្រះអនុរុទ្ធឆ្លើយថា វាសិដ្ឋៈទាំងឡាយ ពួកអ្នកមានសេចក្តីបំណងនឹង និមន្តព្រះសរីរៈរបស់ព្រះមានព្រះភាគជាម្ចាស់ ទៅថ្វាយព្រះភ្លើងឯទិសទក្សិណ នៃព្រះនគរ តែពួកទេព្តាមានបំណងថា នឹងនិមន្តទៅទិសឧត្តរ ចូលកាន់ព្រះនគរ ដោយទិសឧត្តរ និមន្តទៅកណ្តាលនគរ ហើយចេញតាមទិសបូពា ថ្វាយព្រះភ្លើង ព្រះសរីរៈរបស់ព្រះមានព្រះភាគជាម្ចាស់ក្នុង **មកុដពន្ធនចេតិយ៍** របស់ពួក មល្លក្សត្រនៅទិសបូពានៃព្រះនគរ ស្តេចមល្លៈពោលថា ចូរឱ្យប្រព្រឹត្តទៅតាម បំណងរបស់ពួកទេវតាចុះ ។

សម័យនោះ ក្រុងកុសិនារាដេរដាសទៅដោយផ្កាមណ្ឌារវៈ តាមដងផ្លូវ ប្រមាណត្រឹមជង្គង់ គ្រានោះពួកទេវតា និងពួកស្តេចមល្លៈក្រុងកុសិនារា ធ្វើ សក្ការបូជាព្រះសរីរៈរបស់ព្រះមានព្រះភាគដោយការរាំ ច្រៀង ប្រគុំ ផ្កា គ្រឿង-ក្រអូបទាំងដែលជារបស់ទិព្វ ទាំងជារបស់មនុស្ស និមន្តព្រះបរមសពទៅខាង ទិសឧត្តរ ហើយនិមន្តចូលកាន់ព្រះនគរដោយទ្វារទិសឧត្តរ និមន្តទៅកណ្តាល ព្រះនគរចេញទៅតាមទ្វារទិសបូពា ហើយដាក់ព្រះសរីរៈព្រះមានព្រះភាគ លើ

ចិត្តកាធាក្នុង **មកុដពន្ធនចេតិយ៍** របស់ពួកស្ដេចមល្លក្សត្រ ។

សម័យនោះ **ព្រះមហាកស្សប** ព្រមដោយភិក្ខុសង្ឃពួកធំប្រមាណ ៥០០ រូប ធ្វើដំណើរពីក្រុងបាវាឆ្ពោះទៅក្រុងកុសិនារា ព្រះមហាកស្សបចុះគង់សម្រាកក្បែរដើមឈើមួយដើម ។ ខណៈនោះ អាជីវកម្នាក់កាន់ផ្កាមណ្ឌារវៈពីក្រុងកុសិនារា ធ្វើដំណើរទៅកាន់ក្រុងបាវា ព្រះមហាកស្សបបានឃើញអាជីវកនោះមកពីចម្ងាយ ទើបសួរអាជីវកនោះថា ម្នាលអ្នកមានអាយុ អ្នកបានជ្រាបដំណឹងព្រះសាស្ដារបស់យើងខ្លះឬទេ អាជីវកឆ្លើយថា យើងជ្រាបព្រះសមណ-គោតមបរិនិព្វានបាន ៧ ថ្ងៃគម្រប់នឹងថ្ងៃនេះ ក៏ផ្កាមណ្ឌារវៈដែលកាន់នេះ យើងនាំមកពីទីនោះ ។

ក្នុងអដ្ឋកថាមហាបរិនិព្វានសូត្រ ពោលថា អាជីវកយកឈើដោតផ្កាមណ្ឌារវៈកាន់មកដូចឆ័ត្រ កាលព្រះមហាកស្សបត្ថេរឃើញហើយ គិតថា ផ្កាមណ្ឌារវៈនោះ នឹងប្រាកដក្នុងមនុស្សលោក លុះត្រាតែព្រះសព្វញ្ញូពោធិសត្វយាងចុះកាន់ព្រះគភ៌របស់ព្រះមាតាជាដើម តែក្នុងថ្ងៃនេះ ព្រះសាស្ដារបស់យើងក៏មិនបានយាងចុះកាន់ព្រះគភ៌ មិនបានយាងចុះចាកគភ៌ ទាំងថ្ងៃនេះព្រះអង្គក៏មិនបានត្រាស់ដឹង មិនប្រកាសព្រះធម្មចក្ក មិនបានសម្ដែងយមកបាដិហារិយ៍ មិនបានយាងចុះចាកទេវលោក មិនបានទ្រង់ដាក់អាយុសង្ខារ តែព្រះសាស្ដារបស់យើងទ្រង់ព្រះជរា អាចនឹងទ្រង់បរិនិព្វានជាពិតប្រាកដ ។ ពួកភិក្ខុដែលនៅមិនទាន់អស់រាគៈជ្រាបសេចក្ដីហើយមានការយំសោក ចំណែកភិក្ខុដែលប្រាសចាករាគៈ

ហើយ មានសតិសម្បជញ្ញៈពិចារណាថា សង្ខារធម៌ទាំងឡាយមិនទៀងហ្ន៎ ។

បព្វជិតអ្នកបួសចាស់ឈ្មោះ **សុភទ្ទ** អង្គុយនៅក្នុងបរិស័ទនោះបានពោលនឹងពួកភិក្ខុថា ពួកលោកកុំសោយសោកខ្សឹកខ្សួលឡើយ ពួកយើងផុតល្អហើយ ព្រោះថា ព្រះមហាសមណៈនោះបៀតបៀនពួកយើងថា វត្ថុនេះគួរដល់អ្នក វត្ថុនេះមិនគួរដល់អ្នក តែឥឡូវនេះពួកយើងប្រាថ្នាវត្ថុណា ក៏នឹងធ្វើវត្ថុនោះ ។

ព្រះមហាកស្សបបានស្តាប់ដូច្នោះ គិតថា ព្រះសាស្តាបរិនិព្វានត្រឹម ៧ ថ្ងៃ ក៏មានហេតុដែលធ្វើឱ្យសង្ឃកន្លងល្មើសព្រះវិន័យបញ្ញត្តហើយ ទើបត្រិះរិះឱ្យមានការសង្គាយនាព្រះធម្មវិន័យ ដើម្បីរួបរួមឱ្យជាពួកក្រុម សម្រាប់ពួកសង្ឃនឹងបានប្រព្រឹត្តបដិបត្តិតាម ដូចដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងទុកថា :

**ម្នាលអានន្ទ ធម៌វិន័យណា ដែលតថាគតសម្តែងហើយ បញ្ញត្តហើយដល់អ្នកទាំងឡាយ ធម៌ និងវិន័យនោះនឹងជាសាស្តារបស់អ្នកទាំងឡាយ កាលអំណើះអស់ពីតថាគតទៅហើយ ។**

បន្ទាប់ពីនោះមក ព្រះមហាកស្សបដាស់តឿនភិក្ខុទាំងឡាយថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទូន្មានទុកជាមុនហើយ មិនមែនឬ សេចក្តីព្រាត់ប្រាសចាកបុគ្គលជាទីស្រឡាញ់ពេញចិត្តទាំងអស់ពិតជាមាន វត្ថុណាកើតមានហើយ ដែលបច្ច័យតាក់តែងហើយ រមែងមានការបែកធ្លាយជាធម្មតា សេចក្តីប្រាថ្នាថា សូមវត្ថុនេះកុំវិនាសទៅ មិនជាឋានៈដែលនឹងអាចប្រព្រឹត្តទៅបានឡើយ ។

# មល្លបាមោក្ខ ៤

មល្លបាមោក្ខ ៤ អង្គ អុជថ្វាយព្រះភ្លើងលើចិត្តកាធា តែក៏មិនអាចឱ្យឆេះបាន ពួកស្តេចមល្លៈត្រាស់សួរព្រះអនុរុទ្ធថា អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យ ដែលបាមោក្ខទាំង ៤ មិនអាចញ៉ាំងភ្លើងឱ្យឆេះចិត្តកាធាបាន ។ ព្រះអនុរុទ្ធពោលថា វាសិដ្ឋៈទាំងឡាយ ពួកទេវតាមានសេចក្ដីបំណងថា ព្រះមហាកស្សបព្រមដោយភិក្ខុសង្ឃពួកធំប្រមាណ ៥០០ រូប កំពុងធ្វើដំណើរពីក្រុងបាវាមកកាន់ក្រុងកុសិនារា ដើម្បីគាល់ព្រះសាស្តា ដរាបណាដែលព្រះមហាកស្សប និងភិក្ខុសង្ឃមិនទាន់មកដល់ ដរាបនោះ ចិត្តកាធារបស់ព្រះមានព្រះភាគជាម្ចាស់មិនឆេះឡើងឡើយ រហូតទាល់តែព្រះមហាកស្សបថ្វាយបង្គំព្រះបាទាទាំងគូ របស់ព្រះមានព្រះភាគជាម្ចាស់សិន ពួកស្តេចមល្លៈពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមឱ្យប្រព្រឹត្តទៅតាមបំណងរបស់ពួកទេវតាចុះ ។

# ថ្វាយព្រះភ្លើង

( ២៤ ) លុះព្រះមហាកស្សប និងភិក្ខុសង្ឃធ្វើដំណើរមកដល់ **មកុដ-ពន្ធនចេតីយ៍** ចូលទៅកាន់ចិត្តកាធារបស់ព្រះមានព្រះភាគជាម្ចាស់ហើយ គ្រង-ចីវរឆៀងស្មាម្ខាង ផ្គងអញ្ជលី ធ្វើប្រទក្សិណចិត្តកាធា ៣ ជុំ ឈរនៅខាងចុងព្រះបាទារបស់ព្រះសាស្តា ខណៈនោះគួរអស្ចារ្យ ព្រះបាទាទាំងគូបានលៀនចេញមកក្រៅមឈូសមាស ព្រះថេរៈ និងភិក្ខុសង្ឃបានថ្វាយបង្គំដោយសិរសា សូម្បី

ពួកភិក្ខុទាំង ៥០០ រូបនោះ ក៏ថ្វាយបង្គំព្រមគ្នា ។

កាលព្រះមហាកស្សប និងភិក្ខុទាំង ៥០០ រូបនោះថ្វាយបង្គំហើយ ចិត្តកាធារបស់ព្រះមានព្រះភាគជាម្ចាស់ក៏ឆេះឡើងឯង ដោយអានុភាពរបស់ទេវតា។

ព្រះសរីរៈរបស់ព្រះមានព្រះភាគត្រូវភ្លើងឆេះអស់ហើយ **ខ្សែទឹកធ្លាក់ចុះមកពីអាកាស និងផុសឡើងពីផែនដី រំលត់ចិត្តកាធារបស់ព្រះសាស្តាសល់តែព្រះបរមសារីរិកធាតុ** បន្ទាប់ពីនោះ ស្តេចមល្លកុសិនារាអារាធនាព្រះបរមសារីកិរិកធាតុទាំងអស់ តម្កល់ចុះក្នុងកោដ្ឋមាស ប្រោះព្រំដោយសុគន្ធវារិគ្រប់ប្រភេទ រោយគន្ធជាតិទៅក្នុងកោដ្ឋមាស នាំកោដ្ឋមាសទៅប្រតិស្ឋានលើខ្នងដំរីដែលប្រដាប់ហើយ បូជាដោយមាល័យ និងគ្រឿងក្រអូបជាដើមនាំចូលទៅខាងក្នុងព្រះនគរ តម្កល់ទុកលើបល្ល័ង្កដែលធ្វើដោយរតនៈ ៧ ប្រការ ក្នុងសាលា បាំងស្វេតច្ឆត្រខាងលើ ធ្វើសក្ការបូជាព្រះបរមសារីរិកធាតុ របស់ព្រះមានព្រះភាគជាម្ចាស់ដោយការរាំ ច្រៀង និងផ្កាឈើគ្រឿងក្រអូបរហូត ៧ ថ្ងៃ ។

## ស្ថានទីបរិនិព្វាន

( ២៥ ) ប្រសិនបើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះពុទ្ធអង្គមានព្រះបំណងយាងមកបរិនិព្វាននៅក្រុងកុសិនារា ទាំងដែលនឹងត្រូវធ្វើដំណើរ អំពីទីដែលព្រះអង្គប្រសូត ត្រាស់ដឹង និងសម្តែងបឋមទេសនា មកអស់ផ្លូវដ៏សែនឆ្ងាយ ?

ហេតុផលដោយសង្ខេប ដែលសម្តែងទុកក្នុងអដ្ឋកថា មាន ៣ យ៉ាង គឺ :

១. ដើម្បីសម្តែង **មហាសុទស្សនសូត្រ** ជនជាច្រើនកាលស្តាប់ធម្មទេសនារបស់ព្រះតថាគតហើយ នឹងគិតថា កុសលគួរតែធ្វើ គួរតែបំពេញឱ្យច្រើនឡើង ។

២. ដើម្បីទ្រង់ប្រោស **បច្ឆិមសាវ័ក** គឺ សុភទ្ទបរិព្វាជកឱ្យសម្រេចមគ្គផល ។

៣. ដើម្បី **ទោណព្រាហ្មណ៍** នឹងរម្ងាប់ការវិវាទ និងធ្វើនាទីបែងចែកព្រះបរមសារីរិកធាតុ ។

ក្នុងសម័យនៃការបរិនិព្វាន ព្រះមានព្រះភាគប្រថាប់គង់ក្នុងសាលវ័នជិតក្រុងកុសិនារា ព្រះអានន្ទទូលអង្វរថា សូមព្រះមានព្រះភាគកុំទ្រង់បរិនិព្វានក្នុងនគរតូច ជានគរទួល ជាសាខានគរនេះឡើយ នគរធំដូចជា រាជគ្រឹះ សាវត្ថី កោសម្ពី ពារាណសី ពួកក្សត្រមហាសាល ព្រាហ្មណ៍មហាសាល គហបតីមហាសាល ដែលជ្រះថ្លាក្នុងព្រះតថាគតមានច្រើន អ្នកទាំងនោះនឹងធ្វើសក្ការបូជាព្រះសរីរៈ របស់ព្រះតថាគតជាម្ចាស់ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ កុសិនារានេះពីកាលមុនជារាជធានីមាននាមថា **កុសាវតី** ព្រះបាទ **មហាសុទស្សនៈ** ជាក្សត្របានទទួលមុទ្ធាភិសេក ទ្រង់ជាព្រះរាជាដោយធម៌ ជាធំក្នុងផែនដី ជាស្តេចចក្រពត្តិ កុសាវតីជានគរស្តុកស្តម្ភរុងរឿង មានជនច្រើន មានភិក្ខាហាររកបានងាយ កុសាវតីរាជ-

ធានីមិនធ្លាប់ស្ងប់អំពីសំឡេងដំរី សំឡេងសេះ សំឡេងរថ សំឡេងស្គរ សំឡេងសំភោរ សំឡេងពិណ សំឡេងច្រៀង សំឡេងកណ្ដឹង សំឡេងប្រគុំ និងសំឡេងជន ទាំងឡាយ ទាំងថ្ងៃទាំងយប់ ។

ព្រះអង្គត្រាស់សម្ដែងដល់អានិសង្សនៃទាន ដែលព្រះបាទមហាសុ-ទស្សនៈ ទ្រង់បានទទួលក្នុងគ្រានោះថា វត្ថុគ្រប់យ៉ាងជារបស់វិសេស ដែលហូរមកពីកុសលធម៌ដ៏ល្អ ទ្រង់បានបំពេញមកយូរហើយ ព្រះបាទមហាសុទស្សនៈ ទ្រង់ថ្វាយទានដល់សមណៈទាំងឡាយ ដោយសមណបរិក្ខារ ឧបត្ថម្ភព្រាហ្មណ៍ទាំងឡាយដោយព្រាហ្មណបរិក្ខារ ទ្រង់ត្រិះរិះស្វែងរកសេចក្ដីសុខ ដល់អ្នកនគររបស់ព្រះអង្គ ដោយឱ្យទានដល់មហាជនទាំងឡាយ នូវគ្រឿងឧបភោគបរិភោគ និងសេចក្ដីត្រូវការទាំងពួងរបស់ជនទាំងនោះ អ្នកណាប្រាថ្នាអ្វី ក៏ទទួលយកទៅ ការងារយ៉ាងដទៃរបស់អ្នកនគរទាំងឡាយមិនមាន ជនក្នុងជម្ពូទ្វីបបរិភោគទានរបស់ព្រះរាជាប៉ុណ្ណោះ ។

ព្រះអង្គទ្រង់បដិបត្តិធម៌សមគួរដល់ធម៌ ទ្រង់ប្រព្រឹត្តព្រហ្មចរិយៈ ទ្រង់ចម្រើនព្រហ្មវិហារធម៌ ៤ ក្រោយពីសោយទិវង្គត បានទៅកាន់ព្រហ្មលោក ។ ហើយត្រាស់ទូន្មានព្រះអានន្ទទៀតថា ម្នាលអានន្ទ អ្នកចូរមើលចុះសង្ខារទាំងនោះកន្លងទៅ រលត់ទៅ ប្រែប្រួលទៅអស់ហើយ ម្នាលអានន្ទ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះ មិនយឺនយូរយ៉ាងនេះ មិនគួរឱ្យត្រេកអរយ៉ាងនេះ ម្នាលអានន្ទ ព្រោះហេតុនេះគួរនឿយណាយក្នុងសង្ខារទាំងពួង ព្រោះកាលនឿយ-

ណាយរមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេកទើបរួចផុត កាលរួចផុតហើយ រមែងមានញាណដឹងថា ជាតិអស់ហើយ កិច្ចដែលគួរធ្វើបានធ្វើចប់ហើយ។

កាលបានរៀបរាប់សេចក្តីរុងរឿងនៃនគរកុសាវតី ឱ្យព្រះអានន្ទស្តាប់ ដើម្បីជាហេតុផល ដែលព្រះអង្គយាងមកបរិនិព្វាននៅកុសិនារានេះហើយ ព្រះមានព្រះភាគបានត្រាស់ថា ម្នាលអានន្ទ **ព្រះបាទមហាសុទស្សនៈក្នុងសម័យនោះ គឺជាតថាគតក្នុងកាលឥឡូវនេះ** តថាគត រមែងដឹងទីដែលត្រូវដាក់ចុះនូវរាងកាយ ម្នាលអានន្ទ តថាគតមិនឃើញទីណាក្នុងលោក ទាំងទេវលោក មារលោក ព្រហ្មលោក ដែលតថាគតនឹងបោះចោលរាងកាយជាគ្រាចុងក្រោយ ក្រៅអំពីទីកន្លែងនេះឡើយ ។

សេចក្តីពិស្តារសូមពិនិត្យមើលក្នុងទីឃនិកាយ មហាវគ្គ មហាសុទស្សនសូត្រ

**កុសិនារា ទើបជាទីបំផុតនៃការធ្វើដំណើរ ទីបំផុតនៃព្រះឱវាទ ទីបំផុតនៃព្រះពុទ្ធកិច្ច ទីបំផុតនៃព្រះជន្មជីព ទីបំផុតនៃភពជាតិ របស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ របស់យើងព្រះអង្គនេះ ។**

## នោណព្រាហ្មណ៍

(២៦) គ្រានោះ បណ្តាអ្នកគ្រប់គ្រងដែនដីផ្សេងៗ ជ្រាបដំណឹងថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានហើយ នៅនគរកុសិនារា ទើបបញ្ជូនទូតទៅចរចាសូមចំណែកនៃព្រះបរមសារីរិកធាតុ អំពីពួកស្តេចមល្លៈនគរកុសិនារា

ដើម្បីនាំទៅធ្វើសក្ការបូជា ក្នុងដែនរបស់ខ្លួន តែពួកស្ដេចមល្លៈនគរកុសិនារា បដិសេធ ពួកស្ដេច និងព្រាហ្មណ៍ទាំងនោះរួម ៧ នគរ នាំគ្នាមកដាក់ពាក្យបញ្ជាក់ថា នឹងឱ្យព្រះបរមធាតុ ឬនឹងច្បាំង ហើយពង្រាយទ័ពឡោមព័ទ្ធនគរកុសិនារា ។ ពួកស្ដេចមល្លៈ នគរកុសិនារាត្រាស់ថា ធម្មតាថា រតនៈដែលស្មើដោយព្រះពុទ្ធរតនៈមិនមានក្នុងលោក ព្រមទាំងទេវលោក ក៏រតនៈនោះកើតឡើងក្នុងគាមខេត្តរបស់ពួកយើង ពួកយើងនឹងមិនព្រមឱ្យចំណែកនៃព្រះបរមសារីរិកធាតុនោះដល់អ្នកណាឡើយ ។

**ទោណព្រាហ្មណ៍** បានស្ដាប់ការវិវាទរបស់ស្ដេចទាំងនោះហើយ ត្រិះរិះថា ពួកស្ដេចទាំងនេះបង្កវិវាទនឹងគ្នា ក្នុងទីដែលព្រះមានព្រះភាគជាម្ចាស់បរិ-និព្វាន ជាការមិនសមគួរ ចាំបាច់យើងនឹងរម្ងាប់ការវិវាទនោះចេញ ទើបទោណ-ព្រាហ្មណ៍ ឡើងទៅឈរនៅលើទីខ្ពស់ ពោលថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សូមពួកអ្នកចូរស្ដាប់ពាក្យរបស់ខ្ញុំ ព្រះសាស្ដារបស់យើងទាំងឡាយ ជាអ្នកពោលសរសើរខន្តី កាលដែលពួកអ្នកកាប់ប្រហារគ្នា ដោយហេតុនៃព្រះបរមសារីរិកធាតុរបស់ព្រះពុទ្ធជាម្ចាស់ ដែលជាវត្ថុគួរដល់ការសក្ការៈយ៉ាងខ្ពង់ខ្ពស់បំផុតដូច្នេះមិនល្អឡើយ ពួកអ្នកទាំងអស់ចូរអនុគ្រោះនូវគ្នានិងគ្នាចុះ ។

ពាក្យពោលលើកដំបូង របស់ទោណព្រាហ្មណ៍ មិនមានអ្នកណាចាប់អារម្មណ៍ ព្រោះម្នាក់ៗកំពុងប្រកែកទាស់ទែងគ្នាថា នឹងធ្វើយ៉ាងណា ។ អាស្រ័យទោណព្រាហ្មណ៍ជាអាចារ្យរបស់ពួកក្សត្រ និងព្រាហ្មណ៍ក្នុងផ្ទៃជម្ពូទ្វីប មិនមាន

អ្នកណាមិនស្គាល់គាត់ ទើបប្រកាសដោយសំឡេងដ៏ឮខ្លាំងឡើងទៀតថា ពួកអ្នកចាំសំឡេងអាចារ្យរបស់ខ្លួនបានឬទេ បើចាំបាន ចូរអ្នករាល់គ្នាស្ងៀមស្ងាត់ ហើយស្តាប់វាចាដែលខ្ញុំនឹងពោលឱ្យល្អ ។

ពួកស្តេចទាំងអស់លុះបានឮសំឡេង ចាំបានថា ជាសំឡេងរបស់ទោណព្រាហ្មណ៍ ជាអាចារ្យរបស់ពួកខ្លួន ទើបនាំគ្នាស្ងប់ស្ងាត់សំឡេងភ្លាម ។ ទោណព្រាហ្មណ៍ពោលដូចមុនជាលើកទី ២ ហើយប្រកាសថា **សូមពួកយើងទាំងអស់គ្នា ចូរយល់ព្រមត្រេកអរបែងចែកព្រះបរមសារីរិកធាតុ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ចេញជា ៨ ចំណែក ហើយនាំចំណែករបស់ខ្លួនត្រឡប់ទៅប្រតិស្ឋានក្នុងព្រះស្តូប នៅដែនរបស់ខ្លួនចុះ ដើម្បីព្រះបរមសារីរិកធាតុនឹងបានផ្សព្វផ្សាយទៅក្នុងទិសទាំងឡាយ ពួកជនអ្នកជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់នៅមានច្រើន ។**

ទូតទាំងនោះពោលថា បពិត្រព្រាហ្មណ៍ ពួកខ្ញុំទាំងឡាយយល់ព្រមតាមពាក្យណែនាំរបស់លោក បើដូច្នោះ សូមលោកនោះឯងចូរបែងចែកព្រះបរមសារីរិកធាតុរបស់ព្រះពុទ្ធអង្គចេញជា ៨ ចំណែកស្មើៗ គ្នា ឱ្យរៀបរយចុះ ។

## ការបែងចែកព្រះបរមសារីរិកធាតុ

**ទោណព្រាហ្មណ៍** ទទួលពាក្យរបស់ក្សត្រទាំងនោះហើយ ចាត់ការបែងចែកព្រះបរមសារីរិកធាតុរបស់ព្រះពុទ្ធអង្គចេញជា ៨ ចំណែកស្មើៗ គ្នា គឺ :

**ក្សត្រមគធៈ** នាំទៅប្រតិស្ឋានក្នុងស្តូប និងឆ្លងក្នុងនគរ **រាជគ្រឹះ**

**ក្សត្រលិច្ឆវី** នាំទៅប្រតិស្ឋានក្នុងស្តូប និងឆ្លងក្នុងនគរ **វេសាលី**

**ក្សត្រសក្យៈ** នាំទៅប្រតិស្ឋានក្នុងស្តូប និងឆ្លងក្នុងនគរ **កបិលពស្តុ**

**ក្សត្រថូលី** នាំទៅប្រតិស្ឋានក្នុងស្តូប និងឆ្លងក្នុងនគរ **អល្លកប្បៈ**

**ក្សត្រកោលិយៈ** នាំទៅប្រតិស្ឋានក្នុងស្តូប និងឆ្លងក្នុងដែន **រាមគ្រាម**

**ក្សត្រមល្លកុសិនារា** នាំទៅប្រតិស្ឋានក្នុងស្តូប និងឆ្លងក្នុងនគរ **កុសិនារា**

**ក្សត្រមល្លបាវា** នាំទៅប្រតិស្ឋានក្នុងស្តូប និងឆ្លងក្នុងនគរ **បាវា**

**ក្សត្រវេដ្ឋទីបៈ** នាំទៅប្រតិស្ឋានក្នុងស្តូប និងឆ្លងក្នុងនគរ **វេដ្ឋទីបៈ**

**ក្សត្រមោរិយៈ** នគរបិប្ផលិវ័ន បញ្ជូនទូតមកសូមចំណែកក្រោយគេ ទើបបានតែព្រះអង្គារ ( ធ្យូង ) បានសាងព្រះស្តូបប្រតិស្ឋានព្រះអង្គារ និងឆ្លងក្នុងនគរបិប្ផលិវ័ន ។ ចំណែក **ទោណព្រាហ្មណ៍** សូមនាឡិដែលវាល់ព្រះបរមសារីរិកធាតុនឹងទូតទាំងនោះ ដើម្បីនាំទៅសាងព្រះស្តូប និងឆ្លងនៅដែនរបស់ខ្លួនដូចគ្នា ។

ក្នុងអដ្ឋកថាពោលថា កាលពួកស្តេចទាំងនោះយល់ព្រម ទើបទោណ-ព្រាហ្មណ៍បញ្ជាឱ្យបើកប្រអប់មាស ពួកស្តេចទាំងឡាយមកឈរក្បែរប្រអប់មាសនោះ ម្នាក់ៗឃើញព្រះបរមសារីរិកធាតុ មានពណ៌ដូចមាស នាំគ្នាយំរៀបរាប់ថា បពិត្រព្រះមានព្រះភាគ ជាសព្វញ្ញុពុទ្ធ ពីមុនខ្ញុំព្រះអង្គទាំងឡាយ បានឃើញព្រះសរីរៈរបស់ព្រះអង្គមានព្រះឆវីដូចមាស ឥឡូវនេះសល់ត្រឹមតែព្រះបរម-ធាតុ មានពណ៌ដូចមាសប៉ុណ្ណោះ ។

ខណៈដែលកំពុងបែងចែកព្រះបរមធាតុនោះ ទោណព្រាហ្មណ៍ដឹងថាពួកស្តេចទាំងនោះភ្លេចខ្លួន ទើបឆក់យកព្រះចង្កូមកែវខាងស្តាំលាក់ក្នុងផ្នួងសក់ ព្រះបរមសារីរិកធាតុទាំងអស់រួមមាន ១៦ នាឡិ ក្សត្រមួយព្រះអង្គៗ បាននាំទៅពីរៗ នាឡិល្មម ។ កាលទោណព្រាហ្មណ៍កំពុងបែងចែកព្រះបរមធាតុ ស្តេចសក្កទេវរាជពិចារណាមើលថា នរណាហ្ន៎ ឆក់យកព្រះចង្កូមកែវខាងស្តាំរបស់ព្រះមានព្រះភាគទៅ ទ្រង់ឃើញថាទោណព្រាហ្មណ៍ឆក់យកទៅ ទ្រង់ព្រះតម្រិះថា សូម្បីព្រាហ្មណ៍ ក៏មិនអាចធ្វើសក្ការៈឱ្យសមគួរដល់ព្រះចង្កូមកែវបាន ទើបទ្រង់កាន់យកព្រះចង្កូមកែវដែលព្រាហ្មណ៍លាក់ទុកនោះ ចេញពីផ្នួងសក់ ទៅប្រតិស្ឋានទុកក្នុងប្រអប់មាស នាំទៅកាន់ទេវលោកប្រតិស្ឋាន ក្នុងព្រះចូឡាមុនីចេតិយ៍ក្នុងទេវលោក ។

ចំណែកទោណព្រាហ្មណ៍ លុះបែងចែកព្រះបរមធាតុហើយ មិនឃើញព្រះចង្កូមកែវ តែព្រោះខ្លួនឆក់យកមកដោយកិរិយាលួចលាក់ ទើបមិនអាចសូម្បីតែនឹងសួរថា នរណាឆក់យកព្រះចង្កូមកែវរបស់យើងទៅ ។ ព្រាហ្មណ៍គិតថា យើងនឹងសូមនាឡិមាសដែលវាល់ព្រះបរមធាតុទៅសាងស្តូប ទើបទូលក្សត្រទាំងនោះថា លោកដ៏ចម្រើនទាំងឡាយ ប្រោសប្រទាននាឡិនេះដល់ខ្ញុំព្រះអង្គចុះ ហើយក៏នាំទៅសាងព្រះស្តូបតម្កល់ និងធ្វើការឆ្លងដូចគ្នា ។

ព្រះបាទអជាតសត្រូវ បានអារាធនាព្រះបរមសារីរិកធាតុអំពីក្រុងកុសិ-នារា ត្រឡប់មកកាន់ក្រុងរាជគ្រឹះ ដោយការបូជាដ៏ធំក្រៃលែង ដូចគ្នានឹងពួក

ស្តេចមល្លក្សត្រធ្វើការបូជាចន្លោះមកុដពន្ធនចេតិយ៍ និងសាលាដែរ ត្រាស់ឱ្យពួករាជបរិវារហែហមប្រអប់មាសដែលតម្កល់ព្រះបរមធាតុ ដោយការពារយ៉ាងតឹងរឹង ក្នុងចន្លោះផ្លូវបានឃើញផ្កាឈើមានពណ៌ដូចមាស នៅក្នុងទីណាក៏បេះផ្កាឈើទាំងនោះបូជា ក្នុងថ្ងៃទី ៧ ព្រះបរមធាតុមកដល់នគររាជគ្រឹះ មានមហាជនជួបជុំរង់ចាំទទួលបដិសណ្ឋារៈតាមដងផ្លូវរហូត ទ្រង់បញ្ជាឱ្យកសាងព្រះស្តូបប្រតិ-ស្ឋានព្រះបរមសារីរិកធាតុ ហើយទ្រង់ធ្វើបុណ្យដ៏ធំ សូម្បីក្សត្រដទៃក៏អារាធនាព្រះបរមធាតុទៅកាន់នគររបស់ខ្លួនរៀងៗ ខ្លួន កសាងព្រះស្តូបទុកបូជា ហើយធ្វើបុណ្យឆ្លងដ៏ធំដូចគ្នា ។

ក្រោយពីថ្វាយព្រះភ្លើងព្រះពុទ្ធសរីរៈហើយ ក្នុងថ្ងៃប្រជុំក្សត្រនគរផ្សេង ៗ ដើម្បីធ្វើការបែងចែកព្រះបរមសារីរិកធាតុ ព្រះមហាកស្សបត្ថេររឭកដល់ពាក្យ ដែលសុភទ្ទវុឌ្ឍិបព្វជិតពោល កាលព្រះមានព្រះភាគទ្រង់បរិនិព្វានបាន ៧ ថ្ងៃថា អ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយកុំសោកឡើយ ពួកយើងផុតល្អហើយចាកមហាសមណៈព្រះអង្គនោះ ព្រោះថា ពួកយើងត្រូវព្រះមហាសមណៈអង្គនោះរង់ចាំហាមប្រាមថា នេះគួរ នេះមិនគួរដល់ពួកយើងទាំងឡាយក៏ឥឡូវនេះ ពួកយើងប្រាថ្នាធ្វើកម្មណា ក៏នឹងធ្វើកម្មនោះ មិនប្រាថ្នាធ្វើកម្មណានឹងមិនធ្វើនូវកម្មនោះ ។

ដោយហេតុនេះ ទើបព្រះមហាកស្សបត្ថេរត្រិះរិះថា យើងគប្បីសង្គា-យនាព្រះធម៌វិន័យ ជាវិធីរក្សាព្រះសាសនានេះ ឱ្យតាំងមាំអស់កាលយូរ ទើប

បានពោលដឹកនាំភិក្ខុសង្ឃ នៅកណ្ដាលទីប្រជុំក្នុងសាលា ជាកន្លែងបែងចែកព្រះបរមធាតុ ឱ្យស្រុះស្រួលគ្នាធ្វើសង្គាយនា ដោយពោលថា ម្នាលអាវុសោ **យើងទាំងឡាយ គួរធ្វើសង្គាយនាព្រះធម៌វិន័យ ព្រោះថាក្នុងកាលខាងមុខ អធម៌នឹងរុងរឿង ធម៌នឹងត្រូវសាបសូន្យ អវិន័យនឹងរុងរឿង វិន័យនឹងសាបសូន្យ ក្នុងកាលខាងមុខពួកអធម្មវាទីនឹងមានកម្លាំង ពួកធម្មវាទីនឹងទន់ខ្សោយ ពួកអវិន័យវាទីនឹងមានកម្លាំង ពួកវិន័យវាទីនឹងទន់ខ្សោយ ។**

គណសង្ឃ ក៏យល់ព្រមតាមសេចក្ដីត្រិះរិះ របស់ព្រះមហាកស្សបត្ថេរ ពោលថា បើដូច្នោះ ព្រះថេរៈប្រោសជ្រើសរើសភិក្ខុទាំងឡាយចុះ ព្រះមហាក-ស្សប ជ្រើសរើសព្រះអរហន្ត ដែលទ្រទ្រង់ព្រះត្រៃបិដក សម្រេចបដិសម្ភិទា បែកធ្លាយក្នុងវិជ្ជា ៣ ជាដើម ចំនួន ៤៩៩ រូប នៅខ្វះមួយរូប ។ ភិក្ខុទាំងឡាយពោលជាមួយនឹងព្រះថេរៈតទៅថា សូមលោកម្ចាស់ចូរជ្រើសរើសព្រះអានន្ទចូលរួមក្នុងការធ្វើសង្គាយនាផងចុះ សូម្បីលោកត្រឹមតែជាសេក្ខបុគ្គល តែក៏មិនលុះដោយអំណាចឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិ ទាំងជាអ្នកមានការចងចាំព្រះធម៌ និងព្រះវិន័យដ៏កំពូល និងជាប្រយោជន៍ចំពោះការសង្គាយនា ទើបព្រះមហាកស្សប ជ្រើសរើសព្រះអានន្ទទុកមួយរូបទៀត តាមបំណងរបស់ភិក្ខុទាំងឡាយ ។

សង្ឃទាំងនោះព្រមព្រៀងគ្នា ជ្រើសរើសក្រុងរាជគ្រឹះជាកន្លែងធ្វើ **បឋមសង្គាយនា** បន្ទាប់ពីនោះ ព្រះមហាកស្សបត្ថេរពោលនឹងភិក្ខុសង្ឃថា ខាងក្នុង

៤០ ថ្ងៃនេះ អ្នកមានកិច្ចកង្វល់យ៉ាងណា។ សូមឱ្យគ្រប់គ្នាធ្វើកិច្ចដែលគួរធ្វើនោះឱ្យស្រេចបាច់ ពោលដូច្នេះហើយ ព្រះមហាកស្សបត្ថេរ និងព្រះអនុរុទ្ធត្ថេរក៏នាំពួកសង្ឃជាបរិវារត្រឡប់ទៅក្រុងរាជគ្រឹះ សូម្បីព្រះថេរៈជាធំអង្គដទៃ ក៏នាំបរិវារទៅកាន់លំនៅដ្ឋានរៀងៗ ខ្លួន ។

ក្នុងថេរគាថា ពោលថា ក្រោយពីធ្វើសង្គាយនាលើកដំបូងហើយ ព្រះអនុរុទ្ធត្ថេរត្រឡប់ទៅចាំវស្សាចុងក្រោយ ក្នុងវេឡុវគ្រាម ដែនវជ្ជី ដែលជាទីកន្លែងចាំវស្សាចុងក្រោយរបស់ព្រះសាស្តាដូចគ្នា ហើយបរិនិព្វានខាងក្រោមគុម្ពប្ញស្សី ក្នុងវេឡុវគ្រាម ដោយអនុបាទិសេសនិព្វាន ។ **ចំណែកព្រះបុណ្ណត្ថេរ** មានភិក្ខុជាបរិវារ ៧០០ រូប នៅសម្រាកក្នុងក្រុងកុសិនារា ដោយបំណងនឹងលួងលោមមហាជនដែលនាំគ្នាមកធ្វើសក្ការបូជា នៅស្ថានទីបរិនិព្វាន របស់ព្រះសាស្តា ។ ព្រះអានន្ទកាន់បាត្រ និងចីវររបស់ព្រះមានព្រះភាគជាម្ចាស់ដូចកាលដែលនៅមិនទាន់បរិនិព្វាន ធ្វើដំណើរត្រឡប់ទៅកាន់ក្រុងសាវត្ថី ព្រមដោយភិក្ខុសង្ឃ ៥០០ រូប ក្នុងចន្លោះផ្លូវមានភិក្ខុដែលជាបរិវារច្រើនឡើងរហូតប្រមាណមិនបាន មានសំឡេងយំខ្សឹកខ្សួលឱ្យទ្រហឹងតាមផ្លូវ កាលមកដល់ក្រុងសាវត្ថី អ្នកក្រុងសាវត្ថីម្នាក់ៗនាំគ្នាកាន់ផ្កា គ្រឿងក្រអូបទៅទទួល យំរៀបរាប់ថា បពិត្រព្រះអានន្ទដ៏ចម្រើន កាលមុនលោកមកជាមួយនឹងព្រះមានព្រះភាគឥឡូវនេះ លោកចោលព្រះមានព្រះភាគទុកនៅទីណា មានការសោយសោករៀបរាប់ជាអនេក ដូចក្នុងថ្ងៃដែលបរិនិព្វាន ដូច្នោះដែរ ។

ក្នុងអដ្ឋកថាព្រហ្មជាលសូត្រ ពោលថា ព្រះអានន្ទទូន្មានមហាជន ឱ្យយល់ដោយធម្មីកថាប្រកបដោយការមិនទៀងជាដើម ហើយចូលកាន់ព្រះជេត-វនវិហារ ថ្វាយបង្គំព្រះគន្ធកុដិដែលព្រះពុទ្ធអង្គប្រថាប់គង់ បើកទ្វារនាំគ្រែតាំងចេញបោសសម្អាត ចោលសម្រាមផ្កាឈើស្ងួត លោកបានធ្វើគ្រប់យ៉ាងជាវត្តដែលត្រូវបដិបត្តិ ដូចក្នុងវេលាដែលព្រះមានព្រះភាគជាម្ចាស់ គង់ព្រះជន្មនៅឡើយ ធ្វើការផងយំរៀបរាប់ផងថា ពេលថ្ងៃនេះជាពេលស្រង់ទឹករបស់ព្រះអង្គ ពេលនេះជាពេលសម្ដែងធម៌ ជាពេលសម្រេចសីហសេយ្យា ជាវេលាស្រប់ព្រះភក្ត្រជាដើម ដូច្នេះព្រោះលោកនៅជាសេក្ខបុគ្គល ព្រះអានន្ទជាអ្នកពោរពេញទៅដោយសេចក្ដីស្រឡាញ់ក្នុងព្រះសាស្ដា ជាអ្នកមានការជិតស្និទ្ធដោយមានការឧបការៈគ្នា និងគ្នាមកអស់ច្រើនសែនជាតិហើយ ។

ទេវតាមួយអង្គដែលស្ថិតនៅក្នុងព្រៃធំ ជិតក្រុងសាវត្ថីឃើញដូច្នោះ ទើបមកពោលដាស់តឿនព្រះអានន្ទថា បពិត្រព្រះអានន្ទដ៏ចម្រើន បើលោកនៅតែលួងលោមចិត្តអ្នកដទៃ និងនៅតែសម្ដែងសេចក្ដីអាឡោះអាល័យ ក្នុងព្រះតថាគតដូច្នេះ លោកនឹងមានឱកាសបំពេញសមណធម៌ ដើម្បីការរួចផុតបានដូចម្ដេចទៅ ព្រះអានន្ទ បានស្ដាប់ពាក្យដាស់តឿនរបស់ទេវតា ទើបព្យាយាមរម្ងាប់សេចក្ដីសោក និងសូមឱ្យពួកភិក្ខុសង្ឃនាំគ្នាជួសជុល វត្ថុដែលទ្រុឌទ្រោមក្នុងព្រះវិហារជេតវនរហូតស្រេចបាច់ ។ លុះជិតថ្ងៃចូលព្រះវស្សា អានន្ទ និងព្រះថេរៈជាធំៗ ក៏លាភិក្ខុសង្ឃ ធ្វើដំណើរចេញទៅក្រុងរាជគ្រឹះ ដើម្បីត្រៀម

ធ្វើសង្គាយនាព្រះធម្មវិន័យ ។

ទីក្រុងរាជគ្រឹះក្នុងសម័យនោះ មានវត្តធំ ១៨ វត្តអមជុំវិញ ក្នុងវេលាដែលព្រះមានព្រះភាគទ្រង់បរិនិព្វាន ភិក្ខុនាំគ្នាកាន់បាត្រចីវររៀង១ខ្លួន ហើយលះបង់សេនាសនៈនាំគ្នាទៅគាល់ព្រះពុទ្ធអង្គ ។ កាលសម្រេចកិច្ចហើយ ព្រះថេរៈគិតគ្នាថា ពួកយើងត្រូវធ្វើការជួសជុលវិហារដែលទ្រុឌទ្រោម រហូតខែខាងដើមនៃវស្សានរដូវ ដើម្បីបូជាពាក្យប្រៀនប្រដៅរបស់ ព្រះមានព្រះភាគជាម្ចាស់ និងដើម្បីកម្ចាត់បង់ពាក្យតិះដៀលរបស់ពួកតិរ្ថិយ៍ ដែលនឹងតិះដៀលថាសាវ័ករបស់ព្រះគោតមថែរក្សាវត្តអារាម ក្នុងកាលព្រះសាស្តានៅមានព្រះជន្មប៉ុណ្ណោះ កាលព្រះអង្គបរិនិព្វានហើយ ក៏នាំគ្នាបោះបង់ចោល ។

ព្រះបាទអជាតសត្រូវទ្រង់ជ្រាបហេតុ បានព្រះរាជទានជាង ដែលធ្វើការដ៏មានថ្វីដៃមកជួយ បានចាត់ការជួសជុលមហាវិហារធំទាំងអស់ រហូតខែខាងដើមវស្សានរដូវ រួចស្រេចបាច់ហើយ ព្រះថេរៈទូលព្រះរាជាថា ការជួសជុលវត្តសម្រេចហើយ ឥឡូវនេះអាត្មាភាពទាំងឡាយ នឹងធ្វើការសង្គាយនាព្រះធម៌ និង ព្រះវិន័យ ។ ព្រះបាទអជាតសត្រូវមានព្រះតម្រាស់ថា ល្អហើយ លោកម្ចាស់ ! លោកម្ចាស់ទាំងឡាយ ការងារខាងអាណាចក្រសូមឱ្យជានាទីរបស់ញោម ចំណែកខាងពុទ្ធចក្រ សូមឱ្យជានាទីរបស់លោកម្ចាស់ទាំងឡាយ ។

ព្រះបាទអជាតសត្រូវ ត្រាស់បញ្ជាឱ្យសាងធម្មសភា សម្រាប់ការធ្វើសង្គាយនាក្បែរមាត់គុហា **សត្តបណ្ណិ** នៅអែបភ្នំវេភារៈ តាមដែលព្រះថេរៈ

ទាំងឡាយប្រាថ្នា ។

## ព្រះបាទអជាតសត្រូវ - ព្រះមហាកស្សបត្ថេរ រក្សាព្រះបរមសារីរិកធាតុ

(២៧) ក្រោយពីការសង្គាយនាគ្រាដំបូងចប់ស្រេចបាច់ហើយ ក្នុងកាលតមក ព្រះមហាកស្សបត្ថេរពិចារណាឃើញអន្តរាយ ដែលអាចនឹងកើតឡើងដល់ព្រះបរមសារីរិកធាតុក្នុងអនាគត ទើបចូលទៅគាល់ព្រះបាទអជាតសត្រូវទូលថា មហាបពិត្រ ព្រះអង្គគួររក្សាព្រះបរមសារីរិកធាតុ មករួមទុកទីក្រុងរាជគ្រឹះ ។ ព្រះបាទអជាតសត្រូវត្រាស់ថា ល្អណាស់ កិច្ចក្នុងការរក្សាព្រះបរមសារីរិកធាតុនោះជារបស់ញោម តែថា ញោមនឹងនាំព្រះសារីរិកធាតុទាំងនោះមកបានដូចម្តេច ព្រះមហាកស្សបទូលថា ការទៅនាំព្រះបរមធាតុនោះ ជាភារៈរបស់ពួកអាត្មាភាព ។

ព្រះថេរៈ បានទៅអារាធនាព្រះបរមធាតុពីរាជត្រកូលទាំង ៧ នោះ មកប្រតិស្ឋានទុកក្នុងកន្លែងមួយនៅទិសអគ្នេយ៍នៃក្រុងរាជគ្រឹះ ចំណែកព្រះបរមធាតុក្នុងរាមគ្រាម ពួកនាគរក្សាទុក ដោយព្រះថេរៈឃើញថាតទៅក្នុងអនាគត ស្តេចនាគនឹងអារាធនាព្រះបរមធាតុទាំងនេះ ទៅប្រតិស្ឋានទុកក្នុងមហាចេតីយ៍ក្នុងមហាវិហារនៅកោះលង្កា ។

ព្រះរាជាបានបញ្ជាឱ្យជីកទីនោះជម្រៅ ៨០ ហត្ថ កកាយដីចេញអំពីទីនោះ ឱ្យរៀបឥដ្ឋជំនួស បញ្ជាឱ្យក្រាលគ្រឿងកម្រាលលោហៈទុកខាងក្រោម សាងស្តូបទុកមួយថ្នាក់ៗ ៨ ព្រះរាជាតម្កល់ព្រះបរមសារីរិកធាតុ របស់ព្រះមានព្រះភាគទុកក្នុងប្រអប់ចន្ទន៍លឿង ទ្រង់ដាក់ប្រអប់ចន្ទន៍លឿងនោះចុះក្នុងប្រអប់ចន្ទន៍លឿងមួយទៀត ទ្រង់រួមប្រអប់ចន្ទន៍លឿង ៨ ប្រអប់ ទុកក្នុងប្រអប់តែមួយ ។ ដោយវិធីយ៉ាងនោះ ទ្រង់តម្កល់ទុកក្នុងស្តូបចន្ទន៍ក្រហម ស្តូបភ្លុក ស្តូបរតនៈ ស្តូបមាស ស្តូបប្រាក់ ស្តូបកែវមណី ស្តូបកែវទទឹម ស្តូបកែវប្រវាឡ ស្តូបកែវផលិក មួយមុខៗ ៨ ដោយន័យដូចគ្នា ។

ចេតិយ៍កែវផលិកជាចេតិយ៍នៅក្រៅគេបង្អស់ លើចេតិយ៍កែវផលិកនោះ បញ្ជាឱ្យកសាងផ្ទះធ្វើដោយរតនៈសុទ្ធ លើផ្ទះរតនៈនោះ ឱ្យកសាងផ្ទះធ្វើដោយមាសទុក លើផ្ទះមាសនោះ ឱ្យកសាងផ្ទះធ្វើដោយប្រាក់ លើផ្ទះប្រាក់នោះឱ្យកសាងផ្ទះធ្វើដោយទង់ដែង លើផ្ទះទង់ដែងនោះ ឱ្យរោយគ្រាប់ខ្សាច់ធ្វើដោយរតនៈគ្រប់យ៉ាង រោយផ្កាដែលដុះក្នុងទឹក និងផ្កាឈើដែលដុះលើគោកទុក ១០០០ ផ្កា បញ្ជាឱ្យកសាងជាតក ៥៥០ ជាតក កសាងព្រះអសីតិមហាថេរៈ ព្រះបាទសុទ្ធោទនមហារាជ ព្រះនាងមហាមាយាទេវី សហជាតវត្ថុទាំង ៧ គ្រប់យ៉ាងដូចពោលមកនេះ ធ្វើដោយមាសទាំងអស់ ហើយបញ្ជាឱ្យតាំងឆ្នាំងដាក់ទឹកពេញ ដែលធ្វើដោយមាស និងប្រាក់មួយមុខៗ ៥០០ ឆ្នាំង ឱ្យលើកទង់មាស ៥០០ ទង់ ឱ្យធ្វើប្រទីបមាស ៥០០ ប្រទីបប្រាក់ ៥០០ ទ្រង់ដាក់សំពត់សំបក

ឈើទុកក្នុងប្រទីបទាំងនោះ ចាក់ដោយប្រេងក្រអូប ហើយអុជបូជា ។

គ្រានោះ ព្រះមហាកស្សបត្ថេរអធិដ្ឋានថា សូមផ្កាឈើកុំស្វិត ក្លិនក្រអូបកុំបាត់ ប្រទីបកុំរលត់ ហើយឱ្យចារិកអក្សរទុកលើផែនមាសថា ក្នុងអនាគតកាលសម័យព្រះកុមារព្រះនាមអសោក នឹងឡើងសោយរាជសម្បត្តិជាធម្មរាជា ស្ដេចនឹងទ្រង់ធ្វើព្រះបរមសារីរិកធាតុទាំងនេះឱ្យផ្សព្វផ្សាយទៅ ដូច្នេះ ។ ព្រះបាទអជាតសត្រូវ ទ្រង់ដោះគ្រឿងប្រដាប់ទាំងអស់បូជា ទ្រង់បិទទ្វារទង់ដែងហើយយាងចេញមក ទ្រង់ប្រថាប់ត្រាព្រះមហាក្សត្រទុកត្រង់ទ្វារ ទ្រង់ដាក់ដុំកែវមណីមួយដុំធំទុកត្រង់ទីនោះ ហើយប្រោសឱ្យចារិកអក្សរទុកថា **ក្នុងអនាគតកាល សម័យផែនដីព្រះបាទអសោកមហារាជយាងមកក្នុងទីនេះ ចូរកាន់យកដុំកែវមណីនេះ ទម្លាយត្រាហើយបើកទ្វារចូលទៅធ្វើសក្ការៈព្រះបរមសារីរិកធាតុទាំងឡាយចុះ ។**

សក្កទេវរាជ ហៅវិស្សុកម្មទេវបុត្រមកបញ្ជាថា នែ៎វិស្សុកម្មទេវបុត្រ ព្រះបាទអជាតសត្រូវទ្រង់រក្សាព្រះបរមធាតុហើយ អ្នកចូរតាំងកងការពារទុកក្នុងទីនោះ វិស្សុកម្មទេវបុត្រនិម្មិតជារូបយន្តមានរាងរៅដ៏កាច កាន់ព្រះខ័នពណិកែវផលិក ការពារបរិវេណបន្ទប់ព្រះបរមសារីរិកធាតុនោះ រូបយន្តនោះកម្រើកខ្លួនបានរហ័សដូចខ្យល់ ។ កាលការរក្សាព្រះបរមសារីរិកធាតុសម្រេចរៀបរយហើយ ព្រះមហាកស្សបត្ថេរតាំងនៅរហូតអស់អាយុក៏បរិនិព្វានទៅ ព្រះបាទអជាតសត្រូវសោយទិវង្គតហើយ ទៅកើតក្នុងលោហកុម្ភីនរក ពួកមនុស្ស

សូម្បីទាំងនោះក៏នាំគ្នាធ្វើកាលកិរិយាតាមលំដាប់ ។

## រឿងព្រះមហាកស្សបត្ថេរ

(២៨) **ព្រះមហាកស្សបត្ថេរ** ជាមហាសាវ័កទី ៣ របស់ព្រះសមណ-គោតមសម្មាសម្ពុទ្ធជាបរមគ្រូនៃយើង មានអាយុវែងមករហូតដល់ក្រោយពុទ្ធ-បរិនិព្វានហើយ ក្នុងខណៈដែលព្រះអង្គទ្រង់មានព្រះជន្មនៅឡើយ លោកមិនសូវមានការសម្ដែងធម៌ច្រើនណាស់ណាទេ ព្រោះលោកសមាទានដ៏យ៉ាងតឹងរឹងនូវធុតង្គវត្ត ទើបគង់នៅតែក្នុងព្រៃជាប្រចាំ ក្រោយពីព្រះពុទ្ធជាម្ចាស់បរិនិព្វានហើយ លោកជាប្រធានសំខាន់ក្នុងការធ្វើបឋមសង្គាយនា ជាអ្នកទទួលមតិកព្រះធម្មវិន័យម្នាក់ក្នុងព្រះពុទ្ធសាសនា ។

ក្នុងទីឃនិកាយ មហាបរិនិព្វានសូត្រពោលថា កាលពួកមល្លក្សត្រអារា-ធនាព្រះបរមសពរបស់ព្រះសាស្ដាឡើងកាន់ចិត្តកាធាហើយ ក៏មិនអាចនឹងថ្វាយព្រះភ្លើងឱ្យឆេះបាន ព្រោះទេវតាដែលធ្លាប់ជាឧបដ្ឋាកព្រះមហាកស្សបមកក្នុងកាលមុន ជ្រាបថាព្រះមហាកស្សប កំពុងធ្វើដំណើរពីក្រុងបាវា មកកាន់កុសិនារាដើម្បីថ្វាយបង្គំព្រះសាស្ដា ទើបទេវតាបណ្ដាលមិនឱ្យភ្លើងឆេះចិត្តកាធា លុះព្រះមហាកស្សប និងភិក្ខុសង្ឃ ៥០០ រូបមកដល់ និងបានថ្វាយបង្គំព្រះបាទារបស់ព្រះសាស្ដាហើយ ភ្លើងក៏ឆេះឡើងឯង ដោយអានុភាពរបស់ទេវតា ។

កាលចប់ការថ្វាយព្រះភ្លើង និងទោណព្រាហ្មណ៍បែងចែកព្រះបរមធាតុ

ក៏នាំគ្នាទៅកសាងស្តូបទុកបូជាក្នុងនគររបស់ខ្លួនរៀង ៗខ្លួន ។ ក្រោយពីព្រះ-មានព្រះភាគបរិនិព្វានបាន ៤ ខែ ទើបលោកដឹកនាំភិក្ខុទាំងឡាយ ធ្វើសង្គាយនាព្រះធម្មវិន័យ ។

ព្រះមហាកស្សបត្ថេរគង់នៅក្នុងវត្តវេឡុវ័នរហូតមក តមក លោកពិចា-រណាថា ជីវិតរបស់លោកនឹងឃឺនយូរទៅទៀតបានប៉ុនណា ជ្រាបថានឹងបរិនិព្វានក្នុងថ្ងៃស្អែក ទើបតាំងចិត្តទៅបរិនិព្វាននៅ **កុក្កុជសម្បាតបព៌ត** (ភ្នំ ៣) ជិតក្រុងរាជគ្រឹះ តាំងចិត្តអធិដ្ឋានថា កាលនិព្វានហើយ សូមឱ្យភ្នំទាំង ៣ ចូរមករួមជាភ្នំតែមួយ កាលព្រះបាទអជាតសត្រូវមក ទ្រង់ធ្វើសក្ការៈ ក៏សូមឱ្យភ្នំទាំង ៣ នោះបើកចេញ ដើម្បីឱ្យព្រះបាទអជាតសត្រូវបានទតឃើញ បន្ទាប់ពីនោះ ចូរត្រឡប់បិទដូចដើម និងសូមឱ្យសរីរៈតាំងនៅរហូតដល់យុគសម័យព្រះសាសនារបស់ព្រះអរិយមេត្តេយ្យ ។

ព្រះអរិយមេត្តេយ្យ នឹងទ្រង់លើកសរីរៈរបស់លោកទុកក្នុងព្រះហស្ត ពោលពាក្យសរសើរគុណរបស់លោកហើយ បន្ទាប់ពីនោះ ភ្លើងក៏នឹងបណ្តាលឆេះឡើងឯង ដុតបំផ្លាញសរីរៈឱ្យអស់ទៅ បានឮមកថា ព្រះមហាកស្សត្ថេរមានអាយុវែងដល់ទៅ ១២០ ឆ្នាំ ។

## រឿងព្រះអានន្ទ

(២៩) អដ្ឋកថាអានន្ទត្ថេរាបទាន ពោលដល់រឿងព្រះអានន្ទថា **ព្រះអានន្ទ** ជាព្រះរាជឱរសរបស់ព្រះបាទសុក្កោទនៈ និងព្រះនាងកិសាគោតមី កាល

រាប់តាមលំដាប់សក្យវង្ស ព្រះអានន្ទក៏ជាអនុជារបស់ព្រះសាស្តា និងជាសហ-ជាតិរបស់ព្រះសិទ្ធត្ថរាជកុមារ ។

កាលព្រះពោធិសត្វទ្រង់ចេញមហាភិនេស្ក្រមណ៍ ទ្រង់សម្រេចព្រះ-សម្មាសម្ពោធិញ្ញាណ ទ្រង់ប្រកាសព្រះធម្មចក្កដ៏ប្រសើរ ហើយទ្រង់យាងទៅកាន់ក្រុងកបិលពស្តុ ដើម្បីប្រោសព្រះពុទ្ធបិតា ក្នុងខណៈដែលទ្រង់ត្រឡប់មកក្រុងរាជគ្រឹះ ចុះប្រថាប់ត្រង់អនុបិយអម្ពវ័ន ព្រះអានន្ទព្រមទាំងព្រះរាជវង្ស ៥ ព្រះអង្គ និងឧបលិជាភូសាមាលា ទូលសូមបព្វជ្ជាឧបសម្បទា ព្រះមានព្រះភាគទ្រង់ប្រទានឯហិភិក្ខុឧបសម្បទា បានស្តាប់ធម្មកថារបស់ព្រះបុណ្ណមន្តានីបុត្រជាក្មួយរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ ព្រះអានន្ទតាំងនៅក្នុងសោតាបត្តិផល ។

ក្នុងព្រះវស្សាទី ២០ ព្រះអង្គទ្រង់តែងតាំងឱ្យជាពុទ្ធុប្បដ្ឋាកប្រចាំ លោកជាអ្នកយកចិត្តទុកដាក់ក្នុងការឧបដ្ឋាក មានភក្តីភាពក្នុងព្រះបរមសាស្តា សូម្បីជីវិតក៏លះបង់ជំនួសព្រះអង្គបាន ព្រះអានន្ទជាអ្នកប្រកបដោយការចងចាំធម៌ដ៏អស្ចារ្យ ជាអ្នករក្សាឃ្លាំងព្រះធម៌របស់ព្រះសាស្តា ទាំងដែលនៅជាព្រះសេក្ខ-បុគ្គលនៅឡើយ ។

ព្រោះហេតុដែលព្រះអានន្ទជាអ្នកទ្រទ្រង់នូវគុណ គឺជាពហូសូតនោះឯង ក្រោយពីព្រះសាស្តាបរិនិព្វានហើយ ៤ ខែ ព្រះមហាកស្សបប្រាថ្នានឹងធ្វើសង្គាយនាព្រះធម្មវិន័យ ដោយសារសុភទ្ទវុឌ្ឍិបព្វជិត ពោលចម្រូងចម្រាសព្រះធម្មវិន័យ ទើបព្រះមហាកស្សបត្ថេរជ្រើសរើសឱ្យអានន្ទ ជាអ្នកវិសជ្ជនាព្រះធម៌

ក្នុងចំណែកព្រះសុត្តន្តបិដក និងអភិធម្មបិដក ។

គ្រានោះ ព្រះអានន្ទគិតថា ស្អែកនេះនឹងធ្វើសង្គាយនាព្រះធម្មវិន័យ យើងនៅជាសេក្ខបុគ្គល ការទៅប្រជុំរួមជាមួយនឹងព្រះថេរៈជាអសេក្ខៈមិនសមគួរឡើយ កើតសេចក្ដីឧស្សាហ៍ចម្រើនកាយគតាសតិ ប្រឹងប្រែងរហូតអស់មួយរាត្រីនោះ ចង្រ្កមទាល់តែកន្លងមជ្ឈិមយាម គិតថា យើងធ្វើសេចក្ដីព្យាយាមខ្លាំងពេក ទើបចុះចាកទីចង្រ្កមក្នុងវេលាជិតភ្លឺ ចូលទៅកាន់វិហារដោយបំណងនឹងសម្រាក ខណៈដែលកំពុងទម្រេតកាយចុះសិរសានៅមិនទាន់ដល់ខ្នើយ ជើងទាំងពីរត្រឹមតែលើកផុតចាកដី ក្នុងចន្លោះនោះ ចិត្តក៏រួចផុតចាកអាសវៈទាំងឡាយ សម្រេចអរហត្តផលព្រមដោយអភិញ្ញា ៦ និងបដិសម្ភិទា ៤ ក្នុងយប់មុនថ្ងៃប្រជុំសង្គាយនានោះឯង ការបានជាព្រះអរហន្តរបស់ព្រះអានន្ទ វៀរចាកឥរិយាបថទាំង ៤ ។

លុះដល់វេលាធ្វើសង្គាយនា ភិក្ខុព្រមព្រៀងគ្នាហើយ ព្រះអានន្ទគិតថា ឥឡូវនេះជាវេលាសមគួរនឹងចូលកាន់ទីប្រជុំ កាលនឹងសម្ដែងអានុភាព ព្រះអានន្ទផុសពីផែនដីបង្ហាញខ្លួនលើអាសនៈ ក្នុងខណៈនោះ (កន្លែងខ្លះពោលថា លោកហោះទៅឰដ៏អាកាសហើយ អង្គុយលើអាសនៈរបស់ខ្លួន) ។

ព្រះមហាកស្សបឃើញអាការព្រះអានន្ទដូច្នោះ ជ្រាបថាព្រះអានន្ទបានសម្រេចព្រះអរហត្តហើយ មានការដឹងថា បើព្រះសាស្ដាគង់ព្រះជន្មនៅឡើយ ព្រះអង្គក៏នឹងគប្បីប្រទានសាធុការដល់ព្រះអានន្ទក្នុងថ្ងៃនេះពិត ឥឡូវនេះ យើង

នឹងឱ្យសាធុការ ដែលព្រះសាស្ដាគួរប្រទានដល់ព្រះអានន្ទ ដូច្នេះហើយព្រះមហាកស្សបបានឱ្យសាធុការ ៣ ដង ។

## ព្រះអានន្ទបរិនិព្វាន

កាលតមក ព្រះអានន្ទត្ថេរត្រិះរិះថា យើងបានដំណើរជីវិតមកយូរដល់ ១២០ ឆ្នាំ រហូតឥឡូវនេះ ព្រះពុទ្ធសាសនាបានផ្សព្វផ្សាយទៅល្មមសមគួរហើយ បណ្ដាភិក្ខុសង្ឃ និងពួកជនទូទៅក៏ព្រមទទួល និងបដិបត្តិតាមពាក្យទូន្មានរបស់ព្រះសាស្ដា ដោយសេចក្ដីជ្រះថ្លា សមគួរដល់កាលដែលយើងនឹងនិព្វានបានហើយ ទើបព្រះអានន្ទប្រាប់ដល់ពួកភិក្ខុ និងជនទាំងឡាយថា បន្ទាប់ពីនេះទៅ ៧ ថ្ងៃទៀត យើងនឹងនិព្វាន ។

បណ្ដាអ្នកដែលអាស្រ័យនៅតាមដងស្ទឹង រោហិណី ទាំងពីរខាងបានដឹងដំណឹង នាំគ្នាពោលថា ពួកយើងបានឧបការព្រះថេរៈមកជាច្រើន ហេតុដូច្នោះលោកគួរបរិនិព្វានក្នុងអាណាខេត្តរបស់យើង ព្រះអានន្ទត្ថេរជ្រាបសេចក្ដីហើយក៏គិតថា ជនទាំងពីរខាងនៃស្ទឹងនេះ ឱ្យឧបការៈដល់យើងមកប្រហាក់ប្រហែលគ្នា បើយើងនឹងបរិនិព្វានលើច្រាំងណាមួយ នឹងកើតការវិវាទគ្នារវាងជនទាំងពីរខាង ទើបពោលថា អ្នកទាំងឡាយមិនចំពោះថានៅច្រាំងខាងណា សូមឱ្យប្រជុំគ្នានៅប្របមាត់ច្រាំងរបស់ខ្លួន យើងនឹងធ្វើឱ្យពួកអ្នកបានទទួលការពេញចិត្តឱ្យបានគ្រប់ៗ គ្នា និងស្មើៗ គ្នា ។

លុះដល់ថ្ងៃទី ៧ ទើបព្រះអានន្ទត្ថេរសម្តែងឫទ្ធិឡើងទៅប្រតិស្ឋាននៅក្នុងអាកាស ពាក់កណ្តាលស្ទឹងរោហិណី អធិដ្ឋានថា សូមបាដិហារិយ៍ចូរកើតមានដល់សរីរៈរបស់យើង កាលយើងរំលត់ខន្ធបរិនិព្វានហើយ សូមឱ្យតេជោធាតុកើតឡើងឆេះសរីរៈខ្លួនឯង និងសូមឱ្យអដ្ឋិធាតុរបស់យើងខ្ចាយចុះទៅទាំងពីរខាងនៃស្ទឹងស្មើៗគ្នា ហើយក៏ចូលសមាបត្តិ បណ្តាលឱ្យកើតតេជោធាតុឆេះឡើង ដុតសរីរៈរហូតអស់ អដ្ឋិធាតុរបស់លោកខ្ចាយធ្លាក់ចុះកាន់មាត់ច្រាំង ទាំងពីរស្មើៗគ្នា ព្រះរាជានៃកោលិយនគរ និងកបិលពស្តុម្ខាងៗ កសាងព្រះចេតីយ៍ធំ បញ្ចុះអដ្ឋិធាតុលើត្រើយនៃស្ទឹងនោះទាំងសងខាង ជនទាំងឡាយក៏ខ្សឹកខ្សួលនឹកដល់ព្រះថេរៈ ដោយសេចក្តីអាល័យយ៉ាងក្រៃលែង ។

## រឿងព្រះចុន្ទត្ថេរ

(៣០) **ព្រះចុន្ទត្ថេរ** ជាបុត្ររបស់ព្រាហ្មណ៍វង្គន្តៈ និងនាងសារី ចាប់កំណើតត្រង់ស្រុកនាលកៈ ជាប្អូនប្រុសរបស់ព្រះសារីបុត្រ ចេញបព្វជ្ជាជាសាមណេរតាមបងប្រុសតាំងពីអាយុ ៧ ខួប ដោយមានព្រះអានន្ទជាព្រះ-ឧបជ្ឈាយ៍ បព្វជ្ជាមិនយូរប៉ុន្មានក៏សម្រេចព្រះអរហត្តផល ព្រមដោយបដិសម្ភិទា ៤ ក្នុងខណៈដែលនៅជាសាមណេរ ភិក្ខុទាំងឡាយនិយមហៅថា មហាចុន្ទ ឬ **សាមណេរចុន្ទ** ជាប់រហូតមក សូម្បីលោកជាព្រះថេរៈហើយក៏ដោយ ។ ឧបនិស្ស័យរបស់ព្រះចុន្ទៈ ពេញចិត្តនៅក្នុងទីស្ងប់ស្ងាត់ ជាសប្បាយគួរដល់ការ

បំពេញសមណធម៌ ។ សម័យមួយ ខណៈដែលព្រះមានព្រះភាគ ទ្រង់គង់នៅស្រុកសាមគ្រាម ដែនសក្កៈ វេលានោះនិគ្រន្ថនាដបុត្រ មេលទ្ធិម្នាក់ស្នាក់នៅក្នុងនគរបាវាឈឺធ្ងន់ មុនស្លាប់បានគិតថា លទ្ធិរបស់យើងនេះមិនអាចនឹងជួយឱ្យអ្នកបដិបត្តិតាមផុតទុក្ខបាន តែបើយើងត្រឡប់ពាក្យទូន្មានក្នុងខណៈនេះ ក៏នឹងមិនមានអ្នកណាជឿស្តាប់ ទើបរកមធ្យោបាយឱ្យបរិវារបែកខ្ញែកគ្នា ដើម្បីព្រះសាស្តានឹងបានសម្តែងធម៌ប្រោសក្នុងខាងក្រោយ ។

កាលនិគ្រន្ថនាដបុត្រមរណកាលហើយ ពួកនិគ្រន្ថបែកគ្នាជាពីរពួក កើតជម្លោះវិវាទគ្នាថា លោកមិនដឹងច្បាស់ យើងដឹងច្បាស់ធម៌វិន័យនេះ ម្នាក់ៗ ក៏ឈ្លោះប្រកែកគ្នា តាមការយល់ក្នុងវត្ថុដែលខ្លួនបានស្តាប់មកអំពីអាចារ្យ សូម្បីសាវ័កជាគ្រហស្ថក៏មានចិត្តប្រែត្រឡប់ ឃើញថាធម៌វិន័យដែលនិគ្រន្ថនាដបុត្រពោលខុស ឱ្យដឹងខុស មិននាំចេញចាកទុក្ខ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ មិនជាទីពឹងអាស្រ័យបាន ។

ព្រះចុន្ទត្ថេរនាំសេចក្តីនោះមកប្រាប់នឹងព្រះអានន្ទ ទាំងពីរអង្គទើបនាំគ្នាទៅក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ដោយគិតថាកាលព្រះសាស្តាបរិនិព្វានហើយ សូមពួកសង្ឃកុំបែកបាក់គ្នាដូច្នេះឡើយ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ធម៌ណាដែលតថាគតសម្តែងហើយដល់អ្នកទាំងឡាយ ដោយការត្រាស់ដឹងដ៏ក្រៃលែង គឺ **សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ៍ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ និងអរិយមគ្គមានអង្គ ៨** តើអ្នកឃើញភិក្ខុសូម្បីពីររូបមានវាទៈ

ផ្សេងគ្នា ក្នុងធម៌ទាំងនោះឬ អានន្ទ ? ទូលថា ខ្ញុំព្រះអង្គមិនបានឃើញភិក្ខុសូម្បីពីររូបមានវាទៈផ្សេងគ្នា ក្នុងធម៌ទាំងនេះទេ ។

ទើបព្រះសាស្តាត្រាស់ **សាមគាមសូត្រ** សម្តែងមូលហេតុនៃការវិវាទ ៦ ប្រការគឺ ភិក្ខុកាលកើត **សេចក្តីក្រោធ ការលប់គុណ ការច្រណែន ការអំណួត ការឃើញខុស ការប្រកាន់មាំក្នុងទិដ្ឋិរបស់ខ្លួន** ភិក្ខុគួរលះចេញឱ្យអស់ ដើម្បីរម្ងាប់ដើមហេតុនៃការវិវាទ ។

បន្ទាប់ពីនោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ **សារាណីយធម៌** ធម៌ជាទីតាំងនៃការនឹករឭកដល់គ្នា ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនវិវាទគ្នា ដើម្បីការព្រមព្រៀងគ្នា ដើម្បីមូលមិត្តជាមួយគ្នា ៦ ប្រការគឺ :

**១. តាំងកាយកម្មប្រកបដោយមេត្តា ក្នុងមិត្តសព្រហ្មចារី**

**២. តាំងវចីកម្មប្រកបដោយមេត្តា ក្នុងមិត្តសព្រហ្មចារី**

**៣. តាំងមនោកម្មប្រកបដោយមេត្តា ក្នុងមិត្តសព្រហ្មចារី**

**៤. បែងចែកលាភដែលបានមកដោយធម៌ ឱ្យដល់មិត្តសព្រហ្មចារី**

**៥. រក្សាសីលឱ្យបរិសុទ្ធ ស្មើគ្នានឹងមិត្តសព្រហ្មចារី**

**៦. មានទស្សនៈដូចគ្នា** (ទិដ្ឋិសាមញ្ញតា) **នឹងមិត្តសព្រហ្មចារីដទៃ**

ត្រាស់ដាស់តឿនថា ពួកអ្នកគប្បីសមាទានសារាណីយធម៌ ៦ ប្រការនេះប្រព្រឹត្តឱ្យល្អចុះ ធម៌នោះនឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់

ពួកអ្នកអស់កាលដ៏យូរអង្វែង ។

ទ្រង់ណែនាំព្រះមហាចុន្ទត្ថេរថា ឱ្យប្រៀបធៀបនឹងព្រះធម៌វិន័យដែលព្រះអង្គទ្រង់សម្ដែងទុកហើយ **និងគួរសង្គាយនា** គឺរួបរួមព្រះធម៌ទុកឱ្យជាពួក ដើម្បីបានជាបែបផែនតែមួយ ដោយត្រឹមត្រូវទាំងសេចក្ដី និងព្យញ្ជនៈទាំងនេះដើម្បីការឋិតថេររបស់ព្រះសាសនា តទៅអនាគតអស់កាលដ៏យូរ ។ ក្រៅពីនោះ ទ្រង់សម្ដែង **បាសាទិកសូត្រ** មានពាក្យណែនាំថា បើមានម្ចាស់លទ្ធិដទៃណា មកសាកសួរដល់អានិសង្សរបស់ឈាន ៤ ថា ដើម្បីប្រាថ្នាផលអ្វី ឱ្យឆ្លើយថា ប្រាថ្នាដើម្បី :

**ជាព្រះសោតាបន្ន** នឹងបានត្រាស់ដឹងតទៅខាងមុខ

**ជាព្រះសកទាគាមី** ដែលនឹងត្រឡប់មកកើតតែម្ដងទៀត

**ជាព្រះអនាគាមី** ដែលនឹងមិនត្រឡប់មកកើតក្នុងកាមភពទៀត

**ជាព្រះអរហន្ត** ដើម្បីរួចផុតចាកអាសវៈទាំងពួង ។

ព្រះមហាចុន្ទត្ថេរក្រៅពីជាធម្មកថិកហើយ នៅមានសមត្ថភាពអាចបណ្ដាលឥទ្ធិឫទ្ធិ ដូចក្នុង ខុទ្ទកនិកាយធម្មបទ ពោលទុកក្នុងគ្រាដែលព្រះសាស្ដាសម្ដែងយមកបាដិហារិយ៍ថា ព្រះចុន្ទ ពេលនោះនៅជាសាមណេរបានក្រាបទូលព្រះសាស្ដា សូមសម្ដែងបាដិហារិយ៍ជំនួស កាលព្រះសាស្ដាសួរថា អ្នកនឹងសម្ដែងដូចម្ដេច ចុន្ទសាមណេរឆ្លើយថា នឹងទៅអង្រួនដើមព្រីងធំក្នុងជម្ពូទ្វីប នាំផ្លែព្រីងមកឱ្យមហាជនដែលប្រជុំគ្នានេះបរិភោគ និងទៅនាំផ្កាបារិច្ឆត្តកៈ អំពីទេវលោក

មកថ្វាយព្រះសាស្តា តែព្រះអង្គទ្រង់ហាមឃាត់ ។

ព្រះមហាចុន្ទត្ថេរ ធ្លាប់ធ្វើនាទីឧបដ្ឋាកព្រះសាស្តាមកពីមុន ដែលទ្រង់តែងតាំងព្រះអានន្ទ តែក៏នៅជួយព្រះអានន្ទរហូតមក វៀរតែវេលាដែលលោកត្រូវទៅបម្រើព្រះសារីបុត្រប៉ុណ្ណោះ ។ ក្នុងកាលជិតនឹងបរិនិព្វាន ព្រះសាស្តាត្រាស់ហៅព្រះមហាចុន្ទឱ្យក្រាលសំពត់សង្ឃាដិ ដើម្បីផ្ទុំសម្រាកនៅប្របមាត់ស្ទឹងកកុធា មុនដែលនឹងព្រះសាស្តាទ្រង់យាងដល់សាលវ័នក្រុងកុសិនារា ជាស្ថានបរិនិព្វាន ។

ក្រោយអំពីព្រះសាស្តាបរិនិព្វានហើយ ក្នុងកាលតមក ព្រះមហាចុន្ទត្ថេរក៏បរិនិព្វាន តែមិនមានការអធិប្បាយលម្អិតថា លោកបរិនិព្វានកាលណា និងអដ្ឋិធាតុរបស់លោកតម្កល់ទុកនៅក្នុងទីណាឡើយ ។

ការតវង្សនៃព្រះពុទ្ធសាសនា ដែលមានមករហូតសព្វថ្ងៃនេះ សូមបណ្ឌិតគប្បីអាននូវប្រវត្តិរបស់ព្រះបាទអសោកមហារាជ និងប្រវត្តិនៃព្រះពុទ្ធសាសនាដែលផ្សព្វផ្សាយមកកាន់កោះលង្កា និងជ្រោយសុវណ្ណភូមិដែលមានប្រវត្តិមកក្នុងអដ្ឋកថា សមន្តប្បាសាទិកា និងការរចនារបស់បុព្វបុរសខ្មែរ ក្នុងសម័យសម្តេចព្រះសង្ឃរាជសុមេធាធិបតី **ជួន ណាត** ផងចុះ ដោយសៀវភៅនេះក្រាស់ណាស់ ហើយខ្ញុំជាអ្នករៀបចំមិនបានយកដាក់ថែមទេ ។

**បោះពុម្ព ពុទ្ធសករាជ ២៥៤៩**

**ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៤**

**ប្រមូលរួបរួមដោយខ្ញុំព្រះករុណា អត្ថាភាព សេម រឿយ**

**វាយកុំព្យូទ័រ** ដោយភិក្ខុ **មុី សាលួន** និងខ្ញុំព្រះករុណា **សេម រឿយ**

# ឈ្មោះអ្នកជួយកែសម្រួល និងពិនិត្យអក្ខរាវិរុទ្ធ

| | |
|---|---|
| ១- ព្រះធម្មាចារ្យ លឹម ធន់ | នៅអាស្រមព្រះគន្ធកុដិ |
| ២- ព្រះធមាចារ្យ យង់ សុផាត | នៅអាស្រមព្រះគន្ធកុដិ |
| ៣- ភិក្ខុ គុណ ប៊ុននាថ | នៅអាស្រមព្រះគន្ធកុដិ |
| ៤- ព្រះធម្មាចារ្យ គូ សុភាព | នៅវត្តគល់ទទឹង |
| ៥- ភិក្ខុ ឆឹម វិបុល | នៅវត្តគល់ទទឹង |
| ៦- ភិក្ខុ ហ៊ី ហេង | នៅវត្តគល់ទទឹង |
| ៧- ភិក្ខុ សាន សាបុន | នៅវត្តគល់ទទឹង |
| ៨- ភិក្ខុ គឹម យាន | នៅវត្តគល់ទទឹង |
| ៩- ភិក្ខុ អ៊ឹម វុឌ្ឍា | នៅវត្តគល់ទទឹង |
| ១០- ភិក្ខុ ឆាយ កន | នៅវត្តគល់ទទឹង |
| ១១- ភិក្ខុ សៀម សុខុម | នៅវត្តគល់ទទឹង |
| ១២- ភិក្ខុ ឯម ឆា | នៅវត្តគល់ទទឹង |
| ១៣- ឧទ្ទេសាចារ្យ ម៉ៅ សំអឿន | នៅវត្តគល់ទទឹង |
| ១៤- ព្រះធម្មាចារ្យ សុន្ទរ៍ សាមឿន | នៅវត្តគីរីរម្យកំពង់ស្ពឺ |
| ១៥- ភិក្ខុ ថៃ ភិរម្យ | នៅវត្តគីរីរម្យ កំពង់ស្ពឺ |
| ១៦- ភិក្ខុ គឹម ចន្ធូ | នៅវត្តធុតង្គចំការដូង |
| ១៧- ភិក្ខុ ស សត្ថា | នៅអាស្រមព្រះគន្ធកុដិ |
| ១៨- ភិក្ខុ ខ្លឹង | នៅអាស្រមព្រះគន្ធកុដិ |
| ១៩- ភិក្ខុ យេន | នៅអាស្រមព្រះគន្ធកុដិ |
| ២០- ឧបាសក ហាយ ចំរើន | នៅបាត់ដំបង |
| ២១- ឧបាសក អ៊ិម រៃយ៉ា | នៅបាត់ដំបង |
| ២២- ឧបាសក ម៉ៅ អៀប | នៅបាត់ដំបង |